# ព្រះ

# ត្រៃបិដកបាលី

និង

សេចក្ដីប្រែជាភាសាខ្មែរ

# វិនយបិដក

## ភិក្ខុនីវិភង្គ បច្ឆិមភាគ

## ៥

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

# វិនយបិដក ភិក្ខុនីវិភង្គ

## បឋមភាគ

៨

ព.ស. ២៤៩៨

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# បឋមបារាជិកំ(១)

(១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាឡ្ហោ មិគារនត្តា ភិក្ខុនីសង្ឃស្ស វិហារំ កត្តុកាមោ ហោតិ ។ អថខោ សាឡ្ហោ មិគារនត្តា ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោច ឥច្ឆាមហំ អយ្យេ ភិក្ខុនីសង្ឃស្ស វិហារំ កាតុំ ទេថ មេ នវកម្មិកំ ភិក្ខុនិន្តិ ។ តេន ខោ បន សមយេន ចតស្សោ ភគិនិយោ ភិក្ខុនីសុ បព្វជិតា ហោន្តិ នន្ទា នន្ទវតី សុន្ទរីនន្ទា

១ អដ្ឋ សិក្ខាបទគណនា ភិក្ខុនី អសាធារណាបត្តិភេទេន វេទិតព្វា ។



ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ

ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

# បារាជិកទី ១

(១) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់សម្រេចឥរិយាបថនៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង មានចៅសេដ្ឋីឈ្មោះសាឡ្ហៈ ជាចៅនៃមិគារមាតា(១) មានសេចក្តីប្រាថ្នានឹងសាងវិហារ (ប្រគេន) ភិក្ខុនីសង្ឃ ។ ទើបសាឡ្ហៈ ជាចៅមិគារមាតា (នោះ) ចូលទៅរកភិក្ខុនីទាំងឡាយ ហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ ខ្ញុំប្រាថ្នានឹងសាងវិហារ (ប្រគេន) ភិក្ខុនីសង្ឃ សូមលោកម្ចាស់ទាំងឡាយ ចាត់ភិក្ខុនីដែលជាអ្នកចេះត្រួតត្រានវកម្មឲ្យខ្ញុំ ។ សម័យនោះឯង មានស្រីបងប្អូនគ្នា ៤ នាក់ ឈ្មោះ នន្ទា ១ នន្ទវតី ១ សុន្ទរីនន្ទា ១ ថុល្លនន្ទា ១ បានបួសក្នុង

១ ជាឈ្មោះនាងវិសាខា ។ ក្នុងអដ្ឋកថា ពន្យល់ថា ឪពុកក្មេកនាងវិសាខាឈ្មោះមិគារ-សេដ្ឋី ។ កាលនាងវិសាខារៀបការជាមួយនឹងកូនខ្លួន ដល់ទៅថ្ងៃក្រោយបានស្តាប់ធម៌ព្រះដ៏មានព្រះភាគ ក៏មានសេចក្តីជ្រះថ្លា បានសុំនាងវិសាខាធ្វើជាម្តាយ ហេតុនេះ ទើបគេហៅនាងវិសាខានោះថា មិគារ-មាតា ។

ថុល្លនន្ទាតិ ។ តាសុ សុន្ទរីនន្ទា ភិក្ខុនី តរុណបព្វជិតា អភិរូបា ហោតិ ទស្សនីយា បាសាទិកា បណ្ឌិតា ព្យត្តា មេធាវិនី ទក្ខា អនលសា តត្រុបាយាយ វីមំសាយ សមន្នាគតា អលំ កាតុំ អលំ សំវិធាតុំ ។ អថខោ ភិក្ខុនីសង្ឃោ សុន្ទរីនន្ទំ ភិក្ខុនឹ សម្មន្និត្វា សាឡ្ហស្ស មិគារនត្តុនោ អទាសិ នវកម្មិកំ ។ តេន ខោ បន សមយេន សុន្ទរីនន្ទា ភិក្ខុនី សាឡ្ហស្ស មិគារនត្តុនោ និវេសនំ អភិក្ខណំ គច្ឆតិ វាសឹ ទេថ បរសុំ ទេថ កុឋារឹ ទេថ កុទ្ទាលំ ទេថ និខាទនំ ទេថាតិ ។ សាឡ្ហោបិ មិគារនត្តា ភិក្ខុនុបស្សយំ អភិក្ខណំ គច្ឆតិ កតាកតំ ជានិតុំ ។ តេ អភិណ្ហំ ទស្សនេន បដិពទ្ធចិត្តា អហេសុំ ។ អថខោ សាឡ្ហោ មិគារនត្តា សុន្ទរីនន្ទំ ភិក្ខុនឹ ទូសេតុំ ឱកាសំ អលភមានោ ឯតទេវ អត្ថាយ ភិក្ខុនីសង្ឃស្ស ភត្តំ អកាសិ ។ អថខោ សាឡ្ហោ មិគារនត្តា ភត្តគ្គេ អាសនំ បញ្ញាបេន្តោ ឯត្តកា ភិក្ខុនិយោ អយ្យាយ សុន្ទរីនន្ទាយ វុឌ្ឍតរាតិ ឯកមន្តំ អាសនំ បញ្ញាបេសិ ឯត្តកា នវកតរាតិ ឯកមន្តំ



សំណាក់ពួកភិក្ខុនី ។ បណ្ដាភិក្ខុនីទាំងនោះ សុន្ទរីនន្ទាភិក្ខុនី បួសតាំងពីក្មេង ជាភិក្ខុនីមានរូបល្អល្អះ គួរគេយគន់មើល គួរជាទីជ្រះថ្លា ជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ មានប្រាជ្ញា ឆ្លៀវឆ្លាស មិនមានសេចក្ដីខ្ជិលច្រអូស ប្រកបដោយយោបល់ជាគ្រឿងយល់ក្នុងកិច្ចនោះ ៗ អាចធ្វើ ទាំងអាចចាត់ចែង (ឲ្យគេធ្វើ) បាន ។ ទើបភិក្ខុនីសង្ឃសន្មតសុន្ទរីនន្ទាភិក្ខុនីឲ្យជាអ្នកត្រួតត្រាការងារ ដល់សាឡ្ហជាចៅមិគារមាតា ។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនីតែងដើរទៅកាន់លំនៅរបស់សាឡ្ហជាចៅមិគារមាតាញយ ៗ តែងនិយាយថា ចូរអ្នកឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យគន្លាក (ដល់ខ្ញុំ) ។ ឯសាឡ្ហជាចៅមិគារមាតាក៏តែងទៅកាន់លំនៅរបស់ភិក្ខុនីជាញឹកញយ ដើម្បីដឹងការដែលធ្វើរួចហើយនិងមិនទាន់ធ្វើ ។ ជនទាំងពីរនោះ ជាមនុស្សមានចិត្តប្រតិព័ទ្ធ (និងគ្នា) ដោយសារឃើញគ្នារឿយ ៗ ។ ឯសាឡ្ហជាចៅមិគារមាតា មិនបានឱកាសដើម្បីប្រទុស្ត-ចំពោះនឹងសុន្ទរីនន្ទាភិក្ខុនីបាន ហើយក៏ធ្វើភត្ត (ប្រគេន) ភិក្ខុនីសង្ឃ ដើម្បីត្រូវការសុន្ទរីនន្ទាភិក្ខុនីនុ៎ះឯង ។ ក្នុងវេលាដែលសាឡ្ហជាចៅមិគារមាតារៀបចំក្រាលអាសនៈក្នុងរោងទាន ក៏ក្រាលអាសនៈទាំងឡាយ ដើម្បីភិក្ខុនីចាស់ ៗ ) ដោយគិតថា ពួកភិក្ខុនីប៉ុណ្ណេះ ប្រហែលជាចាស់ជាងសុន្ទរីនន្ទាជាម្ចាស់ ហើយក៏ក្រាលអាសនៈទាំងឡាយ (ទៀត ដើម្បីភិក្ខុនីក្មេង ៗ ) ដោយគិតថា

## បឋមបារាជិក សុន្ទរីនន្ទាភិក្ខុនីវត្ថុ

អាសនំ បញ្ញាបេសិ បដិច្ឆន្នេ ឱកាសេ ឧក្កុដ្ឋេ សុន្ទ-
រីនន្ទាយ ភិក្ខុនិយា អាសនំ បញ្ញាបេសិ យថា ថេរា
ភិក្ខុនិយោ ជានេយ្យុំ នវកានំ ភិក្ខុនីនំ សន្តិកេ
និសិន្នាតិ នវកាបិ ភិក្ខុនិយោ ជានេយ្យុំ ថេរានំ
ភិក្ខុនីនំ សន្តិកេ និសិន្នាតិ ។ អថខោ សាឡ្ហោ មិគារ-
នត្តា ភិក្ខុនីសង្ឃស្ស កាលំ អារោចាបេសិ កាលោ
អយ្យេ និដ្ឋិតំ ភត្តន្តិ ។ សុន្ទរីនន្ទា ភិក្ខុនី សល្លក្ខេត្វា
ន ពហុកតោ សាឡ្ហោ មិគារនត្តា ភិក្ខុនីសង្ឃស្ស ភត្តំ
អកាសិ មំ សោ សេវិតុកាមោ សចាហំ គមិស្សាមិ
អន្តរាយោ មេ ភវិស្សតីតិ អន្តេវាសិនឹ ភិក្ខុនឹ(១)
អាណាបេសិ គច្ឆ មេ បិណ្ឌបាតំ នីហរ យោ ច មំ
បុច្ឆតិ គិលានាតិ បដិវេទេហីតិ ។ ឯវំ អយ្យេតិ ខោ សា
ភិក្ខុនី សុន្ទរីនន្ទាយ ភិក្ខុនិយា បច្ចស្សោសិ ។ តេន ខោ
បន សមយេន សាឡ្ហោ មិគារនត្តា ពហិទ្វារកោដ្ឋកេ
ឋិតោ ហោតិ សុន្ទរីនន្ទំ ភិក្ខុនឹ បដិបុច្ឆន្តោ កហំ អយ្យេ
អយ្យា សុន្ទរីនន្ទា កហំ អយ្យេ អយ្យា សុន្ទរីនន្ទាតិ ។

១ ឆ. អន្តេវាសិកំ ភិក្ខុនឹ ។ ម. អន្តេវាសិ ភិក្ខុនឹ ។



## បារាជិកទី ១ និទានសុន្ទរីនន្ទាភិក្ខុនី

ពួកភិក្ខុនីជំនាញបុរសក្មេងជាងសុន្ទរីនន្ទាចាស់ ទើបក្រាលអាសនៈសម្រាប់សុន្ទរីនន្ទាភិក្ខុនីក្នុងទីកំបាំងជាប់នឹងក្រុក (ត្រង់គៀនជញ្ជាំង) ធ្វើឲ្យពួកភិក្ខុនីចាស់ៗ ដឹងថា សុន្ទរីនន្ទាភិក្ខុនីគង់ជិតពួកភិក្ខុនីក្មេងៗ ធ្វើឲ្យពួកភិក្ខុនីក្មេងៗ ដឹងថា សុន្ទរីនន្ទាភិក្ខុនីអង្គុយជិតភិក្ខុនីចាស់ៗ ។ ទើបសាឡ្ហជាចៅមិគារមាតាប្រើមនុស្សឲ្យទៅទូលកន្លកាលដល់ភិក្ខុនីសង្ឃថា បពិត្រលោកម្ចាស់ កាលគួរហើយ ភត្តសម្រេចហើយ ។ សុន្ទរីនន្ទាភិក្ខុនីកំណត់ (ក្នុងចិត្ត) ថា សាឡ្ហជាចៅមិគារមាតាធ្វើភត្តដល់ភិក្ខុនីសង្ឃ មិនមែនធ្វើដោយការគោរពការច្រើនច្រើនទេ គាត់ប្រាថ្នាតែនឹងប្រែប្រួលដល់អញ បើប្រសិនជាអញទៅ សំឡេងនោះខ្សឹប (ខែរ) មុខជានឹងមានដល់អញ (មិនខាន) គិតហើយក៏បង្គាប់ភិក្ខុនីជាសិស្សថា លោកប្អូនទៅចុះ ប្អូនយកបិណ្ឌបាត (មកឲ្យ) ខ្ញុំផង ម្យ៉ាងទៀតបើមានអ្នកណាសួររកខ្ញុំ ប្អូនប្រាប់គេថាខ្ញុំឈឺ ។ ឯភិក្ខុនីនោះបានស្ដាប់ពាក្យសុន្ទរីនន្ទាភិក្ខុនីហើយ ក៏ទទួលពាក្យថា ករុណាលោកម្ចាស់ ។ សម័យនោះឯង សាឡ្ហជាចៅមិគារមាតាឈរនៅខាងក្រៅខ្លោងទ្វារ ហើយសួររកសុន្ទរីនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ឈ្មោះសុន្ទរីនន្ទានៅឯណា បពិត្រលោកម្ចាស់ លោកម្ចាស់ឈ្មោះសុន្ទរីនន្ទានៅឯណា ។

ឯវំ វុត្តេ សុន្ទរីនន្ទាយ ភិក្ខុនិយា អន្តេវាសិនី ភិក្ខុនី សាឡ្ហំ មិគារនត្តារំ ឯតទវោច គិលានាវុសោ បិណ្ឌបាតំ នីហរិស្សាមីតិ ។ អថខោ សាឡ្ហោ មិគារនត្តា យំ មយ្ហំ(១) ភិក្ខុនីសង្ឃស្ស កតំ អការសិ អយ្យាយ សុន្ទរីនន្ទាយ ការណាតិ មនុស្សេ អាណាបេត្វា ភិក្ខុនីសង្ឃំ ភត្តេន បរិវិសថាតិ វត្វា យេន ភិក្ខុនុបស្សយោ តេនុបសង្កមិ ។ តេន ខោ បន សមយេន សុន្ទរីនន្ទា ភិក្ខុនី ពហារាមកោដ្ឋកេ ឋិតា ហោតិ សាឡ្ហំ មិគារនត្តារំ បដិមានេន្តី ។ អទ្ទសា ខោ សុន្ទរីនន្ទា ភិក្ខុនី សាឡ្ហំ មិគារនត្តារំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ឧបស្សយំ បវិសិត្វា សសីសំ បារុបិត្វា មញ្ចកេ និបជ្ជិ ។ អថខោ សាឡ្ហោ មិគារនត្តា យេន សុន្ទរីនន្ទា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា សុន្ទរីនន្ទំ ភិក្ខុនឹ ឯតទវោច កឹតេ អយ្យេ អផាសុ កិស្ស និបន្នាសីតិ ។ ឯវំ ហោតិ អាវុសោ ហោតិ យា អនិច្ឆន្តំ ឥច្ឆតីតិ ។ ក្យាហំ អយ្យេ ន ឥច្ឆិស្សាមិ

១ ឥតោ បរំ អត្ថាយាតិ ឯកេសុ បោត្ថកេសុ ទិស្សតិ ។



កាលសាឡ្ហជាចៅមិគារមាតានិយាយយ៉ាងនេះហើយ ភិក្ខុនីជាសិស្សរបស់សុន្ទរីនន្ទាភិក្ខុនីក៏និយាយពាក្យនេះនឹងសាឡ្ហជាចៅមិគារមាតាថា ម្នាលអ្នកដ៏មានអាយុ សុន្ទរីនន្ទាភិក្ខុនីឈឺ អាត្មាអញនឹងនាំយកបិណ្ឌបាតទៅ(ប្រគេនលោក) ។ លំដាប់នោះ សាឡ្ហជាចៅមិគារមាតាគិតថា អញបានធ្វើភត្តណា (ប្រគេន) ភិក្ខុនីសង្ឃ ភត្តនោះអញធ្វើព្រោះហេតុតែសុន្ទរីនន្ទាជាម្ចាស់ (ទេតើ) គិតហើយក៏បង្គាប់ពួកមនុស្សថា អ្នកទាំងឡាយចូរអង្គាសភត្ត (ប្រគេន) ភិក្ខុនីសង្ឃចុះ ថាហើយក៏ដើរទៅកាន់លំនៅរបស់ភិក្ខុនី ។ លំដាប់នោះឯង សុន្ទរីនន្ទាភិក្ខុនីឈរនៅខាងក្រៅខ្លោងទ្វារអារាម គយគន់មើលសាឡ្ហជាចៅមិគារមាតា ។ សុន្ទរីនន្ទាភិក្ខុនីបានឃើញសាឡ្ហជាចៅមិគារមាតា ដើរមកអំពីចម្ងាយ លុះឃើញហើយក៏ស្ទុះចូលទៅកាន់លំនៅ ហើយដេកលើគ្រែតូចស្លុកសម្ពត់គ្របដល់ក្បាល ។ លំដាប់នោះ សាឡ្ហជាចៅមិគារមាតា ក៏ចូលសំដៅទៅរកសុន្ទរីនន្ទាភិក្ខុនី លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងសុន្ទរីនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនស្រួលសប្បាយដូចម្ដេច ហេតុដូចម្ដេចបានជាសិង ។ ឯសុន្ទរីនន្ទាភិក្ខុនីឆ្លើយតបថា ម្នាលអ្នកដ៏មានអាយុ ស្រីណាប្រាថ្នាគេ ។ មិនប្រាថ្នាវិញ ហេតុនេះបានជាយ៉ាងនេះឯង ។ សាឡ្ហជាចៅមិគារមាតាជាបុរសមានតម្រេកក៏និយាយតបថា បពិត្រលោកម្ចាស់ ខ្ញុំមិនមែនមិនប្រាថ្នាលោក

អបិចាយំ ឱកាសំ ន លភាមិ តំ ទូសេតុន្តិ អវស្សុតោ អវស្សុតាយ សុន្ទរីនន្ទាយ ភិក្ខុនិយា កាយសំសគ្គំ សមាបជ្ជិ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី ជរាទុព្វលា ចរណគិលានា សុន្ទរីនន្ទាយ ភិក្ខុនិយា អវិទូរេ និបន្នា ហោតិ ។ អទ្ទសា ខោ សា ភិក្ខុនី សាឡ្ហំ មិគារនត្តារំ អវស្សុតំ អវស្សុតាយ សុន្ទរីនន្ទាយ ភិក្ខុនិយា កាយសំសគ្គំ សមាបជ្ជន្តំ ទិស្វាន ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម អយ្យា សុន្ទរីនន្ទា អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយិស្សតីតិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា សន្តុដ្ឋា លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា សុន្ទរីនន្ទា អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយិស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ តេ[១] ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

១ យេ តេ ភិក្ខូ អប្បិច្ឆាតិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ម្ចាស់ថ្លៃ តែថាខ្ញុំមិនបាននូវឱកាសនឹងផ្តើមសេពកិច្ចនឹងភិក្ខុនីនោះម្ចាស់ (ទេតើ) ជាហើយក៏ល្បួងចាប់ពាល់កាយសុន្ទរីនន្ទាភិក្ខុនី ដែលជាស្រីមានតម្រេកដែរ ។ សម័យនោះឯង មានភិក្ខុនីមួយរូបជាភិក្ខុនីមានកំឡាំងថយព្រោះជរា ឈឺជើងសំងំជិតសុន្ទរីនន្ទាភិក្ខុនី ។ ឯភិក្ខុនីនោះ បានឃើញពិតនូវសាឡ្ហៈជាចៅមិគារមាតាដែលមានតម្រេក កំពុងតែល្បួងចាប់ពាល់កាយសុន្ទរីនន្ទាភិក្ខុនីដែលមានតម្រេកដែរ លុះឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សុន្ទរីនន្ទាជាម្ចាស់មានតម្រេក មិនគួរនឹងត្រេកអរនឹងបុរសបុគ្គលដែលមានតម្រេកមកចាប់ពាល់កាយខ្លួនសោះ ។ ទើបភិក្ខុនីនោះនាំរឿងនុ៎ះទៅប្រាប់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីណា ដែលមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីខ្មាសបាប មានសេចក្តីរង្កៀស ប្រាថ្នាសិក្សា ពួកភិក្ខុនីអម្បាលនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សុន្ទរីនន្ទាជាម្ចាស់មានតម្រេក មិនគួរនឹងត្រេកអរនឹងបុរសបុគ្គល ដែលមានតម្រេក មកស្ទាបអង្អែលកាយខ្លួនទេ ។ ទើបភិក្ខុនីអម្បាលនោះនាំរឿងនុ៎ះទៅប្រាប់ភិក្ខុទាំងឡាយ ។ ឯភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល

កថំ ហិ នាម សុន្ទរីនន្ទា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបា-តាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ សុន្ទរីនន្ទា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស កាយ-សំសគ្គំ សាទិយតីតិ[1] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា អននុច្ឆវិកំ[2] ភិក្ខវេ សុន្ទរីនន្ទាយ ភិក្ខុនិយា អននុលោមិកំ អប្បតិរូបំ អស្សាមណកំ អកប្បិយំ អករណីយំ កថំ ហិ នាម ភិក្ខវេ សុន្ទរីនន្ទា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស កាយសំសគ្គំ សាទិយិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ ភិក្ខវេ អប្ប-សន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯកច្ចានំ អញ្ញ-ថត្តាយាតិ ។ អថខោ ភគវា សុន្ទរីនន្ទំ ភិក្ខុនឹ

១ ឱ. ម. សាទិយតីតិ ។ ២ ឱ. ម. អននុច្ឆវិយំ ។



បន្ទុះបង្អាប់ថា សុន្ទរីនន្ទាភិក្ខុនីមានតម្រេក មិនគួរនឹងត្រេកអរនឹងឲ្យបុរសបុគ្គលដែលមានតម្រេក ស្ទាបអង្អែលកាយខ្លួនសោះ ។ ភិក្ខុនីទាំងនោះក្រាបទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាសុន្ទរីនន្ទាភិក្ខុនីមានតម្រេក ហើយត្រេកអរនឹងបុរសបុគ្គលដែលមានតម្រេក មកស្ទាបអង្អែលកាយ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើនៃសុន្ទរីនន្ទាភិក្ខុនីនេះមិនសមគួរ មិនចំនួន មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ ម្នាលភិក្ខុទាំងឡាយ សុន្ទរី-នន្ទាភិក្ខុនីមានតម្រេក មិនគួរនឹងត្រេកអរឲ្យបុរសបុគ្គលដែលមានតម្រេកស្ទាបអង្អែលកាយ (ខ្លួន) ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះច្បាស់ជានាំបណ្ដាលឲ្យមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លា ឲ្យមិនជ្រះថ្លានឹងនាំបណ្ដាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ ឲ្យត្រឡប់ជាក្លាយមកយកចិត្តចាកជ្រះថ្លាទៅវិញ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀល

## បឋមបារាជិកា ភិក្ខុនីកណ្ឌោ

អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ទុប្បោសតាយ មហិច្ឆតាយ អសន្តុដ្ឋតាយ សង្គណិកាយ កោសជ្ជស្ស អវណ្ណំ ភាសិត្វា អនេកបរិយាយេន សុភរតាយ សុបោសតាយ អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណំ ភាសិត្វា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខុនីនំ សិក្ខាបទំ បញ្ញាបេស្សាមិ ទស អត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ទុម្មង្កូនំ ភិក្ខុនីនំ និគ្គហាយ បេសលានំ ភិក្ខុនីនំ ផាសុវិហារាយ ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ឯវញ្ច បន ភិក្ខវេ



## បារាជិកទី ១ និទានសុន្ទរីនន្ទាភិក្ខុនី

សុន្ទរីនន្ទាភិក្ខុនីដោយអនេកបរិយាយ ហើយទ្រង់សំដែងទោសនៃបុគ្គលមានសភាពដែលគេចិញ្ចឹមបានដោយក្រ ក្សោតដោយក្រ មានសេចក្តីប្រាថ្នាច្រើន មិនសន្តោស ច្រឡូកច្រឡំដោយពួកគណៈ និងសេចក្តីខ្ជិលច្រអូស ហើយទ្រង់សំដែងសរសើរគុណនៃបុគ្គលមានសភាពដែលគេចិញ្ចឹមងាយ ក្សោតងាយ មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស កែងផុសខាត់ចិត្ត កំចាត់បង់នូវកិលេស មានសេចក្តីជ្រះថ្លា មិនសន្សំនូវកិលេសវដ្ដ និងមានសេចក្តីប្រារព្ធព្យាយាម ដោយអនេកបរិយាយ ហើយទ្រង់សំដែងធម្មីកថាដ៏សមគួរ ដល់ការបញ្ញត្តិសិក្ខាបទនោះៗ ចំពោះភិក្ខុ ហើយទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុនី ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីការស្រួលដល់សង្ឃ ១ ដើម្បីញាំញីពួកភិក្ខុនីដែលទ្រុស្តសីល ១ ដើម្បីនៅជាសុខដល់ពួកភិក្ខុនីដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីហាត់នូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញ៉ាំងពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ១ ដើម្បីញ៉ាំងពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើង ១ ដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យស្ថិតនៅ ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យបួនយ៉ាង

ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស អធក្ខកំ ឧព្ភជាណុមណ្ឌលំ អាមសនំ វា បរាមសនំ វា គហណំ វា ឆុបនំ វា បដិបីឡនំ វា សាទិយេយ្យ អយម្បិ បារាជិកា ហោតិ អសំវាសា ឧព្ភជាណុមណ្ឌលិកាតិ ។

[២] យា បនាតិ យា យាទិសា យថាយុត្តា យថាជច្ចា យថានាមា យថាគោត្តា យថាសីលា យថាវិហារិនី យថាគោចរា ថេរា វា នវា វា មជ្ឈិមា វា ឯសា វុច្ចតិ យា បនាតិ ។ ភិក្ខុនីតិ ភិក្ខិកាតិ ភិក្ខុនី ភិក្ខាចរិយំ អជ្ឈុបគតាតិ ភិក្ខុនី ភិន្នបដធរាតិ ភិក្ខុនី សមញ្ញាយ ភិក្ខុនី បដិញ្ញាយ ភិក្ខុនី ឯហិ ភិក្ខុនីតិ ភិក្ខុនី តីហិ សរណគមនេហិ ឧបសម្បន្នាតិ ភិក្ខុនី



មានសំវាសទិយជាដើម) ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងឡើងនូវ សិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមានតម្រេក ហើយត្រេកអរនឹងការ ស្ទាបក្តី អង្អែលក្តី ចាប់ក្តី ពាល់ក្តី ច្របាច់ក្តី ខាងក្រោមតាំងពីដងកាំបិត ចុះមក ខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ នៃបុរសបុគ្គលដែលមាន តម្រេក ភិក្ខុនីនេះ ត្រូវអាបត្តិបារាជិក ឈ្មោះឧព្ភជាណុមណ្ឌលិកា (ព្រោះ ឲ្យបុរសស្ទាបអង្អែលប្រទេសខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ) ជាស្រី មិនមានសំវាស ។

[២] ត្រង់ពាក្យថា ណាមួយ អធិប្បាយថា (ភិក្ខុនី)ណាមួយ ទោះចាស់ក្តី ក្មេងក្តី កណ្តាលក្តី ដែលប្រកបគួរយ៉ាងណា មានជាតិយ៉ាង ណា មានឈ្មោះយ៉ាងណា មានគោត្រយ៉ាងណា មានសីលយ៉ាង ណា មានធម៌ជាគ្រឿងនៅយ៉ាងណា មានគោចរយ៉ាងណា ភិក្ខុនីនោះ ហៅថា ណាមួយ ។ ពាក្យថា ភិក្ខុនី សេចក្តីថា ដែលហៅថា ភិក្ខុនី ព្រោះជាអ្នកសូម ហៅថា ភិក្ខុនី ព្រោះជាអ្នកចូលទៅអាស្រ័យ នឹងការត្រាច់ទៅដើម្បីសូម ហៅថា ភិក្ខុនី ព្រោះទ្រទ្រង់នូវសំពត់ដែល កាត់ដាច់ ហៅថា ភិក្ខុនី ព្រោះមានសភាពជាសមណី ហៅថា ភិក្ខុនី ព្រោះប្តេជ្ញាខ្លួន (ថាជាអ្នកបួស) ហៅថា ភិក្ខុនី ព្រោះសម្រេចជា ឯហិភិក្ខុនី ហៅថា ភិក្ខុនី ព្រោះឧបសម្បទាដោយត្រៃសរណគមន៍

ភទ្រាតិ ភិក្ខុនី(១) សារាតិ ភិក្ខុនី(២) សេក្ខាតិ ភិក្ខុនី(៣) អសេក្ខាតិ ភិក្ខុនី(៤) សមគ្គេន ឧភតោសង្ឃេន ញត្តិចតុត្ថេន កម្មេន អកុប្បេន ឋានារហេន ឧបសម្បន្នាតិ ភិក្ខុនី តត្រ យាយំ ភិក្ខុនី សមគ្គេន ឧភតោសង្ឃេន ញត្តិចតុត្ថេន កម្មេន អកុប្បេន ឋានារហេន ឧបសម្បន្នា អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អវស្សុតា នាម សារត្តា អបេក្ខវតី(៥) បដិពទ្ធចិត្តា ។ អវស្សុតោ នាម សារត្តោ អបេក្ខវា បដិពទ្ធចិត្តោ ។ បុរិសបុគ្គលោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ វិញ្ញូ បដិពលោ កាយសំសគ្គំ សមាបជ្ជិតុំ ។ អធក្ខកន្តិ ហេដ្ឋក្ខកំ ។ ឧព្ភជាណុមណ្ឌលន្តិ ឧបរិជាណុមណ្ឌលំ ។ អាមសនំ នាម អាមដ្ឋមត្តំ ។ បរាមសនំ នាម ឥតោចិតោ ច សញ្ចោបនំ ។ គហណំ នាម គហិតមត្តំ ។ ឆុបនំ នាម

១ ឱ. ម. ភទ្រា ភិក្ខុនី ។ ២ ឱ. ម. សារា ភិក្ខុនី ។ ៣ សេក្ខា ភិក្ខុនី ។ ៤ អសេក្ខា ភិក្ខុនី ។ ៥ ឱ. ម. អបេក្ខវា ។



ហៅថា ភិក្ខុនី ព្រោះជាស្រីចំរើន ហៅថា ភិក្ខុនី ព្រោះមានធម៌ជាខ្លឹម ហៅថា ភិក្ខុនី ព្រោះជាអ្នកសិក្សា ហៅថា ភិក្ខុនី ព្រោះមិនបាច់សិក្សា ហៅថា ភិក្ខុនី ព្រោះឧភតោសង្ឃ(១)ដ៏ព្រមព្រៀងគ្នា ឲ្យឧបសម្បទាដោយញត្តិចតុត្ថកម្មជាធម៌សមគួរដល់ហេតុឥតមានកម្រើក (អកុប្ប) បណ្តាភិក្ខុនីទាំងឡាយនោះ ភិក្ខុនីណាដែលឧភតោសង្ឃព្រមព្រៀងគ្នាឲ្យឧបសម្បទាដោយញត្តិចតុត្ថកម្មជាសមគួរដល់ហេតុឥតមានកម្រើក (អកុប្ប) ភិក្ខុនីនេះ គប្បីគេហៅថា ភិក្ខុនីក្នុងសេចក្តីនេះ ។ ភិក្ខុនីមានសេចក្តីត្រេកត្រអាល សំឡឹងមើល មានចិត្តប្រតិព័ទ្ធ ហៅថា មានតម្រេក ។ បុរសមានសេចក្តីត្រេកត្រអាល សំឡឹងមើល មានចិត្តប្រតិព័ទ្ធ ហៅថា បុរសមានតម្រេក ។ មនុស្សប្រុសដែលដឹងក្តីអាចដើម្បីលូកស្ទាបអង្អែលកាយបាន មិនមែនយក្ស មិនមែនប្រេត មិនមែនតិរច្ឆាន ហៅថា បុរសបុគ្គល ។ ពាក្យថា ខាងក្រោមតាំងពីជីកាំបិតចុះមក គឺសេចក្តីថា ខាងក្រោមនៃជីកាំបិត ។ ពាក្យថា ខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ គឺសេចក្តីថា ខាងលើមណ្ឌលនៃជង្គង់ ។ ដែលហៅថា ស្ទាប គឺគ្រាន់តែប៉ះពាល់ ។ ដែលហៅថា អង្អែល គឺបញ្ជោសអង្អែលខាងនេះផង ខាងនោះផង ។ ដែលហៅថា កាន់ គឺគ្រាន់តែចាប់ ។ ដែលហៅថា ពាល់

១ សង្ឃទាំងពីរពួក គឺភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ។

ផុដ្ឋមត្តំ ។ បដិបីឡនំ វា សាទិយេយ្យាតិ អង្គំ គហេត្វា និប្បីឡនំ សាទិយតិ ។ អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ បារាជិកា ហោតីតិ សេយ្យថាបិ នាម បុរិសោ សីសច្ឆិន្នោ អភព្វោ តេន សរីរពន្ធនេន ជីវិតុំ ឯវមេវ ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស អធក្ខកំ ឧព្ភជាណុមណ្ឌលំ អាមសនំ វា បរាមសនំ វា គហណំ វា ឆុបនំ វា បដិបីឡនំ វា សាទិយន្តី អស្សមណី ហោតិ អសក្យធីតា តេន វុច្ចតិ បារាជិកា ហោតីតិ ។ អសំវាសាតិ សំវាសោ នាម ឯកកម្មំ ឯកុទ្ទេសោ សមសិក្ខតា ឯសោ សំវាសោ នាម សោ តាយ សទ្ធឹ នត្ថិ តេន វុច្ចតិ អសំវាសាតិ ។



គឺគ្រាន់តែប៉ះត្រូវ ។ ពាក្យថា ត្រេកអរនឹងការឲ្យបៀត គឺភិក្ខុនីត្រេកអរនឹងការចាប់អង្គឲ្យបៀត ។ ពាក្យថា ភិក្ខុនីនេះក្តី គឺតថាគតប្រៀបផ្ទឹមគ្នានឹងពួកភិក្ខុនីមានហើយក្នុងកាលមុន ។ ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយថា បុរសដែលដាច់ក្បាលមិនអាចដើម្បីរស់នៅ ដោយការតភ្ជាប់សរីរៈនោះវិញ យ៉ាងណាមិញ ភិក្ខុនីដែលមានតម្រេកកាលបើចូលចិត្តនឹងស្ទាបក្តី អង្អែលក្តី ចាប់ក្តី ពាល់ក្តី ឲ្យបៀតក្តី ខាងក្រោមតាំងពីដងកាំបិតចុះមក ខាងលើកងមណ្ឌលនៃជង្គង់ឡើងទៅ នៃបុរសបុគ្គលដែលមានតម្រេកដែរ ក៏មិនមែនជាសមណី មិនមែនជាសក្យធីតាឡើយ ភិក្ខុនីនោះ តថាគតហៅថា ត្រូវអាបត្តិបារាជិក ដោយហេតុនោះឯង ។ ពាក្យថា ជាស្រីមិនមានសំវាស សេចក្តីថា ដែលហៅថា សំវាស (នោះ) គឺសង្ឃកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សភាពជាបុគ្គលមានសិក្ខាស្មើគ្នា នេះហៅថា សំវាស សំវាសនោះមិនមានរួមឡើយជាមួយភិក្ខុនីនោះទេ ព្រោះហេតុដូច្នោះ ទើបតថាគតហៅថា ជាស្រីមិនមានសំវាស (គឺមិនមានកិរិយារួមរួមជាមួយនឹងសង្ឃ) ។

(ក) ឧភតោ អវស្សុតេ អធក្ខកំ ឧព្ភជានុមណ្ឌលំ កាយេន កាយំ អាមសតិ អាបត្តិ បារាជិកស្ស ។ កាយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស ។ កាយបដិពទ្ធេន កាយំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស ។ កាយបដិពទ្ធេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

(ខ) ឧព្ភក្ខកំ អធោជានុមណ្ឌលំ កាយេន កាយំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស ។ កាយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។



(ក) កាលបើជនទាំងពីរ(១) (គឺភិក្ខុនីនិងបុរស) មានតម្រេកដូចគ្នា ហើយភិក្ខុនីប៉ះបុរសស្ទាបកាយ ដោយកាយ ខាងក្រោមទាំងពីរដងកាំបិតចុះមក ខាងលើទាំងពីមណ្ឌលនៃជង្គង់ឡើងទៅ (ភិក្ខុនី) ត្រូវអាបត្តិបារាជិក ។ ភិក្ខុនីប៉ះបុរសស្ទាបវត្ថុដែលជាប់នឹងកាយដោយកាយ (ភិក្ខុនី) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុនីប៉ះបុរសស្ទាបកាយដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុនីប៉ះបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីប៉ះបុរសស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីប៉ះបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីប៉ះបុរសស្ទាបវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល (ភិក្ខុនី) ត្រូវអាបត្តិទុក្កដ ។

(ខ) ភិក្ខុនីប៉ះបុរសស្ទាបកាយដោយកាយ ខាងលើទាំងពីដងកាំបិតឡើងទៅ ខាងក្រោមទាំងពីមណ្ឌលនៃជង្គង់ចុះមក (ភិក្ខុនី) ត្រូវអាបត្តិថុល្លច្ច័យ(២) ។ ភិក្ខុនីប៉ះបុរសស្ទាបវត្ថុដែលជាប់នឹងកាយដោយកាយ ត្រូវអាបត្តិទុក្កដ ។

---

១ តាំងពីពាក្យលេខ ៣ ដល់លេខ ៤ និយាយតែពីជនទាំងពីរ គឺភិក្ខុនី និងបុរសត្រេកអរដូចគ្នា។
២ បានជាត្រូវអាបត្តិថុល្លច្ច័យ ព្រោះត្រេកអរទាំងពីរខាង គឺខាងភិក្ខុនី ខាងបុរស ។

កាយបដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយបដិពទ្ធេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

(៨) ឯកតោ អវស្សុតេ អធក្ខកំ ឧព្ភជាណុមណ្ឌលំ កាយេន កាយំ អាមសតិ អាបត្តិ ថុល្លច្ចយស្ស ។ កាយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយបដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយបដិពទ្ធេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយបដិពទ្ធំ អាមសតិ



ភិក្ខុនីឬបុរសស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល (ភិក្ខុនី) ត្រូវអាបត្តិទុក្កដ ។

(៨) កាលបើមានតម្រេកក្នុងចិត្ត[១] (គឺតែភិក្ខុនីម្ខាង) ហើយភិក្ខុនីឬបុរស ស្ទាបអវយវៈកាយ ខាងក្រោមកំពីងផងកំប៉ុងចុះទៅ ខាងលើត់ង់មណ្ឌលនៃជង្គង់ឡើងមក (ភិក្ខុនី) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុនីឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយ

---

១ តាំងពីបព្វលេខ ៨ ដល់បព្វលេខ ៦ និយាយអំពីការត្រេកអរតែម្ខាង គឺតែខាងភិក្ខុនី ។

អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

[៦] ឧព្ភក្ខកំ អធោជាណុមណ្ឌលំ កាយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

(៧) ឯកតោ អវស្សុតេ យក្ខិយា វា បេតិយា វា បណ្ឌកស្ស វា តិរច្ឆានគតមនុស្សវិគ្គហាយ វា អធក្ខកំ ឧព្ភជាណុមណ្ឌលំ កាយេន កាយំ អាមសតិ



វត្ថុដែលសម្រាប់ប្រោះប្រួសម្រាប់ពាល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទីប្តុប្រុសស្ទាបវត្ថុដែលសម្រាប់ប្រោះប្រួសម្រាប់ពាល ដោយវត្ថុដែលសម្រាប់ប្រោះប្រួសម្រាប់ពាល ត្រូវអាបត្តិទុក្កដ ។

[៦] ភិក្ខុទីប្តុប្រុសស្ទាបកាយដោយកាយ ខាងលើតាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលនៃជង្គង់ចុះមក (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ[១] ។ ភិក្ខុទីប្តុប្រុសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទីប្តុប្រុសស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទីប្តុប្រុសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទីប្តុប្រុសស្ទាបកាយ ដោយវត្ថុដែលសម្រាប់ប្រោះប្រួសម្រាប់ពាល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទីប្តុប្រុសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់ប្រោះប្រួសម្រាប់ពាល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទីប្តុប្រុសស្ទាបវត្ថុដែលសម្រាប់ប្រោះប្រួសម្រាប់ពាល ដោយវត្ថុដែលសម្រាប់ប្រោះប្រួសម្រាប់ពាល ត្រូវអាបត្តិទុក្កដ ។

(៧) កាលបើដំនាំនឹងរោងវ (គឺភិក្ខុនឹងនាងយក្សាជាដើម) មានកន្ទែកដូចគ្នា ហើយភិក្ខុនីស្ទាបកាយ ដោយកាយ ខាងក្រោមតាំងពីដងកាំបិតចុះមក ខាងលើតាំងពីមណ្ឌលនៃជង្គង់ឡើងទៅ របស់យក្សាក្តី ប្រេតក្តី

---

១ បានជាត្រូវអាបត្តិទុក្កដ ព្រោះត្រេកអរតែម្ខាង គឺតែខាងភិក្ខុ ។

អាបត្តិ ថុល្លច្ចយស្ស ។ កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

(៤) ឧព្ភក្ខកំ អធោជាណុមណ្ឌលំ កាយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។



ទើយក្តី ភិក្ខុនីដែលមានតម្រេកនឹងកាយបុរសត្រេក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុនីស្ទាបនូវវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ដោយវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។

(៤) ភិក្ខុនីស្ទាបកាយដោយកាយ ខាងលើតាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលនៃជង្គង់ចុះមក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបកាយដោយវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ដោយវត្ថុដែលសម្រាប់ច្រាះបុសសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។

(៩) ឯកតោ អវស្សុតេ អធក្ខកំ ឧព្ភជាណុមណ្ឌលំ កាយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

(១០) ឧទ្ធក្ខកំ អធោជាណុមណ្ឌលំ កាយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ



(៩) កាលបើមានតម្រេកតែម្ខាង (គឺមានតែភិក្ខុនីតែម្ខាង) ហើយភិក្ខុនីស្ទាបកាយ (របស់បុរសជាដើម) ដោយកាយរបស់ខ្លួន ខាងក្រោមតាំងពីដងកាំបិតចុះមក ខាងលើតាំងពីមណ្ឌលនៃជង្គង់ឡើងទៅ (ភិក្ខុនី) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។

(១០) ភិក្ខុនីស្ទាបកាយដោយកាយខាងលើតាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលនៃជង្គង់ចុះមក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាប

អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

[១១] អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តិយា អសាទិយន្តិយា ឧម្មត្តិកាយ ខិត្តចិត្តាយ វេទនដ្ដាយ អាទិកម្មិកាយាតិ ។

បឋមបារាជិកំ និដ្ឋិតំ ។



កាយ ដោយវត្ថុដែលសម្រាប់បោះបង់សម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះបង់សម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់បោះបង់សម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះបង់សម្រាប់ចោល ត្រូវអាបត្តិទុក្កដ ។

[១១] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺ ភិក្ខុនីមិនក្លែង ១ មិនមានស្មារតី ១ មិនដឹងខ្លួន ១ មិនត្រេកអរ ១ ឆ្កួត ១ មានចិត្តរវើរវាយ ១ វេទនាគ្របសង្កត់ ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

បារាជិកទី ១ ចប់ ។

## ទុតិយបារាជិកំ

[៦២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សុន្ទរីនន្ទា ភិក្ខុនី សាឡ្ហេន មិគារនត្តុនា(១) គព្ភិនី ហោតិ ។ យាវ គព្ភោ តរុណោ អហោសិ តាវ ឆាទេសិ ។ បរិបក្កេ គព្ភេ វិព្ភមិត្វា វិជាយិ ។ ភិក្ខុនិយោ ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោចុំ សុន្ទរីនន្ទា ខោ អយ្យេ អចិរបក្កន្តា វិជាតា កច្ចិ នោ សា ភិក្ខុនីយេវ សមានា គព្ភិនីតិ ។ ឯវំ អយ្យេតិ ។ កិស្ស បន ត្វំ អយ្យេ ជានំ បារាជិកំ ធម្មំ អជ្ឈាបន្នំ ភិក្ខុនឹ នេវ អត្តនា បដិចោទេសិ ន គណស្ស អារោចេសីតិ ។ យោ ឯតិស្សា អវណ្ណោ មយ្ហេសោ អវណ្ណោ យា ឯតិស្សា អកិត្តិ មយ្ហេសា អកិត្តិ យោ ឯតិស្សា អយសោ មយ្ហេសោ អយសោ យោ

១ មិគារនត្តា សទ្ទិន្ទិម ភគ្គំ បោត្ថកេ ទិស្សតិ ។

## បារាជិកទី ២

[១៦] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់គង់នៅក្នុងជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនីមានគភ៌ដោយសាឡ្ហជាចៅមិគារមាតា ។ កាលគភ៌នៅខ្ចីនៅឡើយ ក៏នាងបិទបាំងទុកបាន ។ លុះគភ៌ (នោះ) ចាស់ (ជិតគ្រប់ខែ) ភិក្ខុនីនោះក៏សឹកទៅ ហើយសម្រាលកូន ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ សុន្ទរីនន្ទា សឹកទៅមិនទាន់បានយូរប៉ុន្មាន ក៏សម្រាល (កូនភ្លាម) សុន្ទរីនន្ទានោះ មានគភ៌តាំងអំពីនៅជាភិក្ខុនីនៅឡើយទេឬ ។ ថុល្លនន្ទាភិក្ខុនីឆ្លើយតបថា យ៉ាងហ្នឹងហើយ លោកម្ចាស់ ។ ពួកភិក្ខុនីអម្បាលនោះ ក៏និយាយថា បពិត្រលោកម្ចាស់ (បើ) លោកម្ចាស់ដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ ចុះហេតុដូចម្ដេចបានជាលោកម្ចាស់មិនចោទដោយខ្លួនឯង ក៏មិនប្រាប់ដល់ពួកគណៈ ។ ថុល្លនន្ទាភិក្ខុនីក៏និយាយថា ទោសណាដែលកើតឡើងដល់សុន្ទរីនន្ទានុ៎ះ ទោសនោះនឹងមានដល់ខ្ញុំ កេរ្តិ៍អាក្រក់ណាដែលកើតឡើងដល់សុន្ទរីនន្ទានុ៎ះ កេរ្តិ៍អាក្រក់នោះនឹងមានដល់ខ្ញុំ សេចក្ដីឥតយស(១)ណាដែលកើតឡើងដល់សុន្ទរីនន្ទានុ៎ះ សេចក្ដីឥតយសនោះនឹងមានដល់ខ្ញុំ សេចក្ដីសូន្យលាភ

១ អដ្ឋកថា ថា សេចក្ដីវិបត្តិបរិវារ ឬដំណៀលស្គុលទីព័ទ្ធជុំ ។

តិស្សា អលាភោ មយ្ហេសោ អលាភោ ត្យាហំ អយ្យេ អត្តនោ អវណ្ណំ អត្តនោ អកិត្តឹ អត្តនោ អយសំ អត្តនោ អលាភំ បរេសំ អារោចេស្សាមីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ជានំ បារាជិកំ ធម្មំ អជ្ឈាបន្នំ ភិក្ខុនឹ នេវ អត្តនា បដិចោទេស្សតិ ន គណស្ស អារោចេស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ធម្មឹ កថំ កត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ជានំ បារាជិកំ ធម្មំ អជ្ឈាបន្នំ ភិក្ខុនឹ នេវ អត្តនា បដិចោទេតិ[១] ន គណស្ស អារោចេតីតិ[២] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ជានំ បារាជិកំ ធម្មំ អជ្ឈាបន្នំ ភិក្ខុនឹ នេវ អត្តនា បដិចោទេស្សតិ ន

១ ម. បដិចោទេសិ ។ ២ ម. យ. អារោចេសីតិ ។



ណាដែលកើតឡើងដល់សុន្ទរីនន្ទានុ៎ះ សេចក្តីសូន្យលាភនោះនឹងមានដល់ខ្ញុំ (មិនខាន) បពិត្រលោកម្ចាស់ (បើដូច្នោះ) ខ្ញុំនឹងប្រាប់ទោសរបស់ខ្លួន កេរ្តិ៍អាក្រក់របស់ខ្លួន សេចក្តីអាប់យសរបស់ខ្លួន សេចក្តីសូន្យលាភរបស់ខ្លួន ដល់ពួកជនដទៃដូចម្តេចបាន ។ ពួកភិក្ខុនីណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនីអម្បាលនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ មិនគួរនឹងមិនចោទដោយខ្លួនឯង នឹងមិនប្រាប់ដល់ពួកគណៈសោះ ។ លំដាប់នោះ ពួកភិក្ខុនីអម្បាលនោះ ជំរាបរឿងនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ប្រជុំភិក្ខុសង្ឃ ទ្រង់សំដែងធម្មីកថា ហើយទ្រង់សួរបញ្ជាក់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ មិនចោទដោយខ្លួនឯង នឹងមិនប្រាប់ដល់ពួកគណៈ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ មិនគួរនឹងមិនចោទដោយខ្លួនឯង នឹងមិនប្រាប់ដល់ពួកគណៈទេ

គណស្ស អារោចេស្សតីតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ ភិក្ខវេ អប្បសន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯក- ច្ចានំ អញ្ញថត្តាយាតិ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ ។ យា បន ភិក្ខុនី ជានំ បារាជិកំ ធម្មំ អជ្ឈាបន្នំ ភិក្ខុនឹ នេវ អត្តនា បដិចោទេយ្យ ន គណស្ស អារោចេយ្យ យទា ច សា ឋិតា វា អស្ស ចុតា វា នាសិតា វា អវស្សដា វា សា បច្ឆា ឯវំ វទេយ្យ បុព្វេវាហំ អយ្យេ អញ្ញាសឹ ឯតំ ភិក្ខុនឹ ឯវរូបា ច ឯវរូបា ច សា ភគិនីតិ នោ ច ខោ អត្ត- នា បដិចោទេស្សំ ន គណស្ស អារោចេស្សន្តិ អយម្បិ បារាជិកា ហោតិ អសំវាសា វជ្ជប្បដិច្ឆាទិកាតិ ។

[១៣] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ជានាតិ នាម សាមំ វា ជានាតិ



នៃភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ទាំងមិនមែននាំឲ្យរឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាហើយនោះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះច្បាស់ជានាំបណ្ដាលឲ្យមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លាឲ្យខានជ្រះថ្លា ទាំងនាំបណ្ដាលពួកមនុស្សខ្លះដែលជ្រះថ្លាហើយឲ្យត្រឡប់ជាទាស់ចិត្តបាត់ជ្រះថ្លាទៅវិញ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយដឹងថា ភិក្ខុនីដទៃត្រូវអាបត្តិបារាជិក ហើយមិនចោទដោយខ្លួនឯង ទាំងមិនប្រាប់ដល់ពួកគណៈ កាលណាបើភិក្ខុនីនោះស្ថិតនៅក្ដី ច្យុតហើយក្ដី វិនាសហើយក្ដី ចៀសទៅកាន់លទ្ធិដទៃហើយក្ដី ភោះភិក្ខុនីដែលដឹងរឿងនោះ និយាយយ៉ាងនេះក្នុងកាលជាខាងក្រោយថា បពិត្រលោកម្ចាស់ ខ្ញុំបានដឹង(រឿង)ភិក្ខុនីនោះថា នាងនោះមានសភាពយ៉ាងនេះមួយ យ៉ាងនេះមួយ ក្នុងកាលមុនដែរ ប៉ុន្តែខ្ញុំមិនបានចោទចំពោះខ្លួនឯង ទាំងមិនបានប្រាប់ដល់ពួកគណៈទេ ដូច្នេះ ភិក្ខុនីនេះ ក៏ត្រូវអាបត្តិបារាជិក ឈ្មោះវជ្ជប្បដិច្ឆាទិកា (ព្រោះជួយបិទបាំងទោសគេ) ជាស្រីមិនមានសំវាស ។

[១៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខា- បទទី ១ នៃបារាជិកនេះ ។ ដែលហៅថា ដឹង គឺភិក្ខុនីដឹងដោយខ្លួនឯងក្ដី

អញ្ញេ វា តស្សា អារោចេន្តិ សា វា អារោចេតិ ។ បារាជិកំ ធម្មំ អជ្ឈាបន្នន្តិ អដ្ឋន្នំ បារាជិកានំ អញ្ញតរំ បារាជិកំ ។ នេវ អត្តនា បដិចោទេយ្យាតិ ន សយំ ចោទេយ្យ ។ ន គណស្ស អារោចេយ្យាតិ ន អញ្ញាសំ ភិក្ខុនីនំ អារោចេយ្យ ។

(១៤) យទា ច សា ឋិតា វា អវស្សដាតិ ឋិតា នាម សលិង្គេ ឋិតា វុច្ចតិ ។ ចុតា នាម កាលង្ក-តា(១) វុច្ចតិ ។ នាសិតា នាម សយំ វា វិព្ភន្តា ហោតិ អញ្ញេហិ(២) វា នាសិតា ។ អវស្សដា នាម តិត្ថាយតនំ សង្កន្តា វុច្ចតិ ។

(១៥) សា បច្ឆា ឯវំ វទេយ្យ បុព្វេវាហំ អយ្យេ អញ្ញាសឹ ឯតំ ភិក្ខុនឹ ឯវរូបា ច ឯវរូបា ច សា ភគិ-និតិ នោ ច ខោ អត្តនា បដិចោទេស្សន្តិ ន សយំ ចោទេស្សំ ។ ន គណស្ស អារោចេស្សន្តិ ន អញ្ញាសំ ភិក្ខុនីនំ អារោចេស្សំ ។

១ ម. ឱ. កាលំ កតា ។ ២ អញ្ញាហីតិ សព្វត្ថ ទិស្សតិ ។



ខាងពួកអ្នកដទៃមកប្រាប់ដល់ភិក្ខុនីនោះក្ដី ភិក្ខុនីដែលត្រូវបារាជិកនោះប្រាប់ក្ដី ។ ពាក្យថា ត្រូវអាបត្តិបារាជិក សេចក្ដីថា បណ្ដាបារាជិកទាំង ៨ (ប្រការ) ត្រូវបារាជិកណាមួយ ។ ពាក្យថា មិនចោទដោយខ្លួនឯង គឺមិនចោទនូវ (ជំនុំសង្ឃ) ដោយខ្លួនឯង ។ ពាក្យថា មិនប្រាប់ដល់ពួកគណៈ គឺមិនប្រាប់ដល់ពួកភិក្ខុនីឯទៀត ។

(១៤) ត្រង់ពាក្យថា កាលណាបើភិក្ខុនីនោះស្ថិតនៅក្ដី ក៏ដែលហៅថា ស្ថិតនៅ បានដល់ភិក្ខុនីស្ថិតនៅក្នុងភេទនៃខ្លួនដដែល ។ ដែលហៅថា ច្យុត គឺធ្វើកាលកិរិយាស្លាប់ទៅហើយ ។ សឹកខ្លួនឯងក្ដី ពួកភិក្ខុនីឯទៀតឲ្យវិនាសក្ដី ហៅថា វិនាសហើយ ។ ទៀសទៅកាន់លទ្ធិតិរ្ថិយ ហៅថា ទៀសទៅកាន់លទ្ធិដទៃ ។

(១៥) ត្រង់ពាក្យថា នោះភិក្ខុនីដែលដឹងរឿងនោះនិយាយយ៉ាងនេះក្នុងកាលជាខាងក្រោយថា បពិត្រលោកម្ចាស់ ខ្ញុំបានដឹង (រឿង) ភិក្ខុនីនោះថា ភគិនីនោះមានសភាពយ៉ាងនេះមួយ យ៉ាងនេះមួយ ក្នុងកាលមុនដែរ ប៉ុន្តែខ្ញុំមិនបានចោទដោយខ្លួនឯង សេចក្ដីថា ខ្ញុំមិនបានចោទ (ជំនុំសង្ឃ) ដោយខ្លួនឯង ។ ពាក្យថា ខ្ញុំមិនបានប្រាប់ដល់ពួកគណៈ សេចក្ដីថា ខ្ញុំមិនប្រាប់ដល់ពួកភិក្ខុនីដទៃឡើយ ។

[១៦] អយម្បីតិ បុរិមំ ឧបាទាយ វុច្ចតិ ។
បារាជិកា ហោតីតិ សេយ្យថាបិ នាម បណ្ឌុបលាសោ
ពន្ធនា បវុត្តោ[1] អភព្វោ ហរិតត្ថាយ ឯវមេវ ភិក្ខុនី
ឆិន្នំ ជានិត្វា នេវ អត្តនា បដិចោទេស្សាមិ ន គណស្ស អារោចេស្សាមីតិ ធុរំ
និក្ខិត្តមត្តេ អស្សមណី ហោតិ អសក្យធីតា តេន
វុច្ចតិ បារាជិកា ហោតីតិ ។ អសំវាសាតិ សំវាសោ
នាម ឯកកម្មំ ឯកុទ្ទេសោ សមសិក្ខតា ឯសោ
សំវាសោ នាម សោ តាយ សទ្ធឹ នត្ថិ តេន វុច្ចតិ
អសំវាសាតិ ។

[១៧] អនាបត្តិ សង្ឃស្ស ភណ្ឌនំ វា កលហោ
វា វិគ្គហោ វា វិវាទោ វា ភវិស្សតីតិ នារោចេតិ
សង្ឃភេទោ វា សង្ឃរាជិ វា ភវិស្សតីតិ នារោចេតិ

[1] បមុត្តោតិបិ បាឋោ ។





[១៦] ត្រង់ពាក្យថា ភិក្ខុនីនេះក្តី តថាគតពោលប្រៀបធៀបនឹងភិក្ខុនីដែលត្រូវអាបត្តិបារាជិកមុន ១ ។ ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយថា ធម្មតាស្លឹកឈើទុំដែលជ្រុះផុតអំពីទងហើយ មិនគួរល្អលាស់ឡើងវិញបាន មានឧបមាយ៉ាងណាមិញ ភិក្ខុនីដែលដឹងថា ភិក្ខុនីដទៃត្រូវអាបត្តិបារាជិកហើយ គ្រាន់តែដាក់ធុរៈថា អញមិនចោទចំពោះខ្លួនឯង អញមិនប្រាប់ដល់ពួកគណៈផង ក៏មិនមែនជាសមណី មិនមែនជាធីតារបស់ព្រះពុទ្ធជាសក្យត្រកូលឡើយ ព្រោះហេតុនោះ ភិក្ខុនីនោះបានជាតថាគតហៅថា ត្រូវអាបត្តិបារាជិក ។ ពាក្យថា មិនមានសំវាស អធិប្បាយថា ដែលហៅថា សំវាស (នោះ) គឺសង្ឃកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សភាពជាបុគ្គលមានសិក្ខាស្មើគ្នា នេះហៅថា សំវាស សំវាសនុ៎ះមិនមានជាមួយនឹងភិក្ខុនីនោះ ព្រោះហេតុដូច្នោះ បានជាតថាគត ហៅថា ជាភិក្ខុនីមិនមានសំវាស ។

[១៧] ភាវៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺ ភិក្ខុនីមិនប្រាប់ព្រោះគិតថា សេចក្តីកេហកក្តី សេចក្តីឈ្លោះប្រកែកក្តី សេចក្តីបែកបាក់ផ្សេងគ្នាក្តី សេចក្តីវិវាទក្តី នឹងកើតមានដល់សង្ឃ ១ មិនប្រាប់ ព្រោះគិតថា សង្ឃបែកបាក់គ្នា ឬសេចក្តីប្រេះឆានៃសង្ឃនឹងកើតមាន ១

អយំ កក្ខឡោ ផរុសោ ជីវិតន្តរាយំ វា ព្រហ្មចរិយន្ត-រាយំ វា ករិស្សតីតិ នារោចេតិ អញ្ញា បតិរូបា ភិក្ខុនិ-យោ អបស្សន្តី នារោចេតិ ន ឆាទេតុកាមា នារោចេតិ បញ្ញាយិស្សតិ សកេន កម្មេនាតិ នារោចេតិ ឧម្មត្តិ-កាយ អាទិកម្មិកាយាតិ ។

ទុតិយបារាជិកំ និដ្ឋិតំ ។





មិនប្រាប់ព្រោះគិតថា ភិក្ខុនីនេះកាចកាចគគ្រោតគ្រាតនឹងធ្វើអន្តរាយដល់ជីវិត ឬអន្តរាយដល់ព្រហ្មចរិយធម៌ ១ ភិក្ខុនីនោះមិនបានឃើញពួកភិក្ខុនីឯទៀតដ៏សមគួរហើយមិនប្រាប់ ១ ភិក្ខុនីនោះមិនមានសេចក្តីប្រាថ្នានឹងបិទបាំងមិនប្រាប់ ១ ភិក្ខុនីមិនប្រាប់ព្រោះគិតថា ភិក្ខុនីនោះនឹងប្រាកដដោយកម្មរបស់ខ្លួន (មិនអាប) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីទាន់ដើមបញ្ញត្តិ ១ ។

បារាជិកទី ២ ចប់ ។

## តតិយបារាជិកំ

(១៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហ-
រតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ
បន សមយេន ថុល្លនន្ទា ភិក្ខុនី សមគ្គេន សង្ឃេន
ឧក្ខិត្តំ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ អនុវត្តតិ ។ យា តា
ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិ-
បាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា សមគ្គេន
សង្ឃេន ឧក្ខិត្តំ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ អនុវត្តិស្សតីតិ
។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សមគ្គេន
សង្ឃេន ឧក្ខិត្តំ អរិដ្ឋំ គទ្ធពាធិបុព្វំ អនុវត្តតីតិ ។ សច្ចំ
ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ
ថុល្លនន្ទា ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ អរិដ្ឋំ
គទ្ធពាធិបុព្វំ អនុវត្តិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា
បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ

## បារាជិកទី ៣

(១៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅជេតពនារាមរបស់
អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនីប្រ-
ព្រឹត្តតាមភិក្ខុឈ្មោះអរិដ្ឋ ជាអ្នកកើតក្នុងត្រកូលអ្នកសម្លាប់ត្មាតដែលសង្ឃ
ព្រមព្រៀងគ្នាលើកវត្តហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រា-
ថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់
ថា លោកម្ចាស់ថុល្លនន្ទាមិនសមបើនឹងប្រព្រឹត្តតាមអរិដ្ឋភិក្ខុ ជាអ្នកកើត
ក្នុងត្រកូលអ្នកសម្លាប់ត្មាតដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយសោះ
។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី
ប្រព្រឹត្តតាមអរិដ្ឋភិក្ខុ ជាអ្នកកើតក្នុងត្រកូលអ្នកសម្លាប់ត្មាតដែលសង្ឃព្រម
ព្រៀងគ្នាលើកវត្តហើយ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា
បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោស
ថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងប្រព្រឹត្តតាមអរិដ្ឋភិក្ខុ
ជាអ្នកកើតក្នុងត្រកូលអ្នកសម្លាប់ត្មាត ដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត
ហើយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន
ដែលមិនទាន់ជ្រះថ្លាហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ

សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុំ ធម្មេន វិនយេន សត្ថុសាសនេន អនាទរំ អប្បដិការំ អកតសហាយំ តមនុវត្តេយ្យ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា ឯសោ ខោ អយ្យេ ភិក្ខុ សមគ្គេន សង្ឃេន ឧក្ខិត្តោ ធម្មេន វិនយេន សត្ថុសាសនេន អនាទរោ អប្បដិការោ អកតសហាយោ មាយ្យេ ឯតំ ភិក្ខុំ អនុវត្តីតិ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ បារាជិកា ហោតិ អសំវាសា ឧក្ខិត្តានុវត្តិកាតិ ។

(១៩) យា បនាតិ យា យាទិសា ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សមគ្គោ នាម



ឲ្យសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយប្រព្រឹត្តតាមភិក្ខុដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយប្រោសប្រែមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា នែលោកម្ចាស់ ភិក្ខុនេះឯងដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយប្រោសប្រែមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ នែលោកម្ចាស់ លោកកុំប្រព្រឹត្តតាមភិក្ខុនេះឡើយ ភិក្ខុនីនោះកាលភិក្ខុនីទាំងឡាយនិយាយឲ្យយ៉ាងនេះ នៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មជាគំរប់បីដង ដើម្បីឲ្យលះបង់វត្ថុនោះ បើភិក្ខុនីនោះកាលត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មជាគំរប់បីដង លះបង់វត្ថុនោះបាន ការលះបង់បាននោះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះក៏ត្រូវបារាជិក ឈ្មោះឧក្ខិត្តានុវត្តិកា (ព្រោះប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត) ជាស្រីមិនបានសំវាស ។ ៤

(១៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌនេះរួចហើយ ។ សង្ឃដែលមានសំវាសស្មើគ្នា

### តតិយបារាជិកេ សិក្ខាបទវិភង្គោ

សមគ្គោ នាម សមានសំវាសកោ សមានសីមាយំ ឋិតោ ។ ឧក្ខិត្តោ នាម អាបត្តិយា អទស្សនេ(១) វា អប្បដិកម្មេ(២) វា អប្បដិនិស្សគ្គេ(៣) វា ឧក្ខិត្តោ ។ ធម្មេន វិនយេនាតិ យេន ធម្មេន យេន វិនយេន ។ សត្ថុសាសនេនាតិ ជិនសាសនេន ពុទ្ធសាសនេន ។ អនាទរោ នាម សង្ឃំ វា គណំ វា បុគ្គលំ វា កម្មំ វា នាទិយតិ ។ អប្បដិការោ នាម ឧក្ខិត្តោ អនោសារិតោ ។ អកតសហាយោ នាម សមានសំវាសកា ភិក្ខូ វុច្ចន្តិ សហាយា សោ តេហិ សទ្ធិំ នត្ថិ តេន វុច្ចតិ អកតសហាយោតិ ។ តមនុវត្តេយ្យាតិ យំទិដ្ឋិកោ សោ(៤) ហោតិ យំខន្តិកោ យំរុចិកោ សាបិ តំទិដ្ឋិកា ហោតិ តំខន្តិកា តំរុចិកា ។

១-២-៣ [illegible] ទំព័រ ៦៣ ។ ៤ សោ [illegible] ។



### បារាជិកទី ៣ សិក្ខាបទវិភង្គ

ស្ថិតនៅក្នុងសីមាស្មើគ្នា ឈ្មោះថា ព្រមព្រៀងគ្នា ៗ ភិក្ខុដែលឈ្មោះថា សង្ឃលើកវត្តហើយ គឺភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនធ្វើតបកម្មអាបត្តិ(១) ព្រោះមិនលះបង់ (ទិដ្ឋិអាក្រក់) ក្តី ៗ ពាក្យថា តាមធម៌ តាមវិន័យ គឺតាមធម៌ឯណា តាមវិន័យឯណា ៗ ពាក្យថា តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា គឺតាមពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គឺតាមពុទ្ធសាសនា ៗ ដែលហៅថា មិនអើពើ គឺភិក្ខុមិនអើពើនឹងសង្ឃក្តី គណក្តី បុគ្គលក្តី កម្មក្តី ៗ ភិក្ខុដែលសង្ឃលើកវត្តហើយ មិនហៅចូលពួក ឈ្មោះថា ជាភិក្ខុដែលសង្ឃជួយប្រោសប្រែមិនបាន ៗ ដែលហៅថា មិនមានការរួបរួមជាមួយនឹងសង្ឃ គឺភិក្ខុទាំងឡាយដែលមានសំវាសស្មើគ្នា សង្ឃហៅថាមានការរួបរួមជាមួយគ្នា ការរួបរួមជាមួយគ្នានោះមិនមានមួយអន្លើដោយភិក្ខុទាំងឡាយនោះទេ ហេតុនោះ ភិក្ខុនោះទើបសង្ឃហៅថា ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ ៗ ពាក្យថា ប្រព្រឹត្តតាមភិក្ខុនោះ គឺភិក្ខុនោះមានទិដ្ឋិយ៉ាងណា មានសេចក្តីចូលចិត្តយ៉ាងណា មានសេចក្តីគាប់ចិត្តយ៉ាងណា ភិក្ខុនីនោះក៏មានទិដ្ឋិយ៉ាងនោះ មានសេចក្តីចូលចិត្តយ៉ាងនោះ មានសេចក្តីគាប់ចិត្តយ៉ាងនោះដែរ ៗ

១ ដឹងថាត្រូវអាបត្តិហើយ ៗ មិនសំដែងអាបត្តិនោះ ៗ

(៦០) សា ភិក្ខុនីតិ យា សា ឧក្ខិត្តានុវត្តិកា ភិក្ខុនី ។ ភិក្ខុនីហីតិ អញ្ញាហិ ភិក្ខុនីហិ ។ យា បស្សន្តិ យា សុណន្តិ តាហិ វត្តព្វា ឯសោ ខោ អយ្យេ ភិក្ខុ សមគ្គេន សង្ឃេន ឧក្ខិត្តោ ធម្មេន វិនយេន សត្ថុសាសនេន អនាទរោ អប្បដិការោ អកតសហាយោ មាយ្យេ ឯតំ ភិក្ខុំ អនុវត្តីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សា ភិក្ខុនី សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វា ឯសោ ខោ អយ្យេ ភិក្ខុ សមគ្គេន សង្ឃេន ឧក្ខិត្តោ ធម្មេន វិនយេន សត្ថុសាសនេន អនាទរោ អប្បដិការោ អកតសហាយោ មាយ្យេ ឯតំ ភិក្ខុំ អនុវត្តីតិ ។ ទុតិយម្បិ វត្តព្វា



(៦០) ត្រង់ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីដែលប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តហើយនោះ ។ ពាក្យថា ដែលភិក្ខុនីទាំងឡាយ គឺភិក្ខុនីទាំងឡាយដទៃ ។ ភិក្ខុនីទាំងឡាយឯណាឃើញ ភិក្ខុនីឯណាឮ ភិក្ខុនីទាំងឡាយនោះត្រូវនិយាយនឹងភិក្ខុនីនោះថា នែលោកម្ចាស់ ភិក្ខុនេះឯងដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា គឺជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយធ្វើម្រើមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ នែលោកម្ចាស់ លោកកុំប្រព្រឹត្តតាមភិក្ខុនេះឡើយ ។ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយនិយាយអស់វារៈជាគំរប់ពីរដងផង ត្រូវនិយាយអស់វារៈជាគំរប់បីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាំងឡាយ (ឯទៀត) ឮហើយមិននិយាយ ត្រូវអាបត្តិទុក្កដ ។ ត្រូវសង្ឃទាញភិក្ខុនីនោះមកកាន់ទីកណ្តាលសង្ឃ ហើយនិយាយថា នែនាងភិក្ខុនី ភិក្ខុនេះឯងដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយធ្វើម្រើមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ នែនាងភិក្ខុនី នាងកុំប្រព្រឹត្តតាមភិក្ខុនេះឡើយ ។ ត្រូវសង្ឃនិយាយនឹងភិក្ខុនីនោះ

តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

(៦១) សា ភិក្ខុនី សមនុភាសិតព្វា ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុំ ធម្មេន វិនយេន សត្ថុសាសនេន អនាទរំ អប្បដិការំ អកតសហាយំ តមនុវត្តតិ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុំ ធម្មេន វិនយេន សត្ថុសាសនេន អនាទរំ អប្បដិការំ អកតសហាយំ តមនុវត្តតិ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសតិ តស្ស វត្ថុស្ស



អស់វារៈជាគំរប់ពីរដងផង ត្រូវនិយាយអស់វារៈជាគំរប់បីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននុះនេះជាការល្អ បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ ។

(៦១) ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវាចា ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសូត្រសមនុភាសនវាចា (ចំពោះភិក្ខុនីឈ្មោះនោះ) យ៉ាងនេះ ។ ភិក្ខុនីដែលឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃឲ្យដឹងថា បពិត្រលោកម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះប្រព្រឹត្តតាមភិក្ខុនោះដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត តាមធម៌ តាមវិន័យ តាមពាក្យប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ សង្ឃជួយព្រោមព្រែងមិនបាន មិនមានការប្រួមជាមួយនឹងសង្ឃ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវសូត្រសមនុភាសនវាចាចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ នេះជាញត្តិ ។ បពិត្រព្រះភិក្ខុនីសង្ឃជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះប្រព្រឹត្តតាមភិក្ខុដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ សង្ឃជួយព្រោមព្រែងមិនបាន មិនមានការប្រួមជាមួយនឹងសង្ឃ ភិក្ខុនីនោះមិនលះបង់វត្ថុនោះ ។ សង្ឃក៏សូត្រសមនុភាសនវាចាចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ

បដិនិស្សគ្គាយ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ភិក្ខុនិយា សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ សមនុភដ្ឋា សាយំ ឥត្ថន្នាមា ភិក្ខុនី តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៦៦) ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ បារាជិកស្ស ។

(៦៧) អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ បារាជិកា ហោតីតិ សេយ្យថាបិ នាម បុថុសិលា ទ្វេធា ភិន្នា អប្បដិសន្ធិកា ហោតិ ឯវមេវ ភិក្ខុនី យាវតតិយំ សមនុភាសិយមានា អប្បដិនិស្សជ្ជន្តី អស្សមណី ហោតិ អសក្យធីតា តេន វុច្ចតិ



ចេញ ។ ការសូត្រសមនុភាសនាដ៏ចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ ខ្ញុំសូត្រសេចក្ដីនេះអស់វារៈជាគំរប់ពីរផង ។ បេ ។ ខ្ញុំសូត្រសេចក្ដីនេះអស់វារៈទីបីផង ។ បេ ។ ភិក្ខុនីឈ្មោះនេះសង្ឃសូត្រសមនុភាសនារួចហើយ ដើម្បីឲ្យលះបង់វត្ថុនោះ ។ ការសូត្រសមនុភាសនានោះគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

(៦៦) ភិក្ខុនីនោះត្រូវទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាទាំងពីរឡាយ ត្រូវអាបត្តិបារាជិកក្នុងវេលាចប់កម្មវាចា ។

(៦៧) ត្រង់ពាក្យថា ភិក្ខុនីនេះក្ដី តថាគតពោលប្រៀបធៀបនឹងភិក្ខុនីដែលត្រូវអាបត្តិបារាជិកមុន ៗ ។ ពាក្យថា ត្រូវបារាជិក សេចក្ដីថា ថ្មដ៏ក្រាស់ដែលបែកជាពីរចំណែកហើយជាវត្ថុជាតិតភ្ជាប់វិញមិនបាន មានឧបមាយ៉ាងណាមិញ ភិក្ខុនីដែលសង្ឃសូត្រសមនុភាសនាដ៏អស់វារៈទីបីហើយនៅមិនលះបង់ ក៏មិនមែនជាសមណី[1] មិនមែនជាធីតារបស់ព្រះពុទ្ធជាសក្យត្រកូល ក៏មានឧបមេយ្យដូច្នោះដែរ

---

១ សមណៈស្រី ហៅថា សមណី ។

បារាជិកា ហោតីតិ ។ អសំវាសាតិ សំវាសោ នាម ឯកកម្មំ ឯកុទ្ទេសោ សមសិក្ខតា ឯសោ សំវាសោ នាម សោ តាយ សទ្ធិំ នត្ថិ តេន វុច្ចតិ អសំវាសាតិ ។

[៦៦] ធម្មកម្មេ ធម្មកម្មសញ្ញា នប្បដិនិស្សជ្ជតិ អាបត្តិ បារាជិកស្ស ។ ធម្មកម្មេ វេមតិកា នប្បដិនិស្សជ្ជតិ អាបត្តិ បារាជិកស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា នប្បដិនិស្សជ្ជតិ អាបត្តិ បារាជិកស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៦៧] អនាបត្តិ អសមនុភាសន្តិយា បដិនិស្សជ្ជន្តិយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

តតិយបារាជិកំ និដ្ឋិតំ ។



ហេតុនោះ ទើបតថាគតហៅភិក្ខុនីនោះថា ត្រូវបារាជិក ។ ពាក្យថា គ្មានសំវាស ដែលហៅថា សំវាស គឺកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា ការសិក្សាស្មើគ្នា នេះឈ្មោះថា សំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុនីនោះទេ ហេតុនោះ ទើបតថាគតហៅភិក្ខុនីនោះថា មិនមានសំវាស ។

(៦៦) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិបារាជិក ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិបារាជិក ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិបារាជិក ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៦៧) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ ពួក) គឺ ភិក្ខុនី (ដែលសង្ឃ) មិនសូត្រសមនុភាសនវិធី ១ ភិក្ខុនីបានលះបង់ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

បារាជិកទី ៣ ចប់ ។

# ចតុត្ថបារាជិកំ

[៦២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថគ្គហណំបិ សាទិយន្តិ សង្ឃាដិកណ្ណគ្គហណំបិ សាទិយន្តិ សន្តិដ្ឋន្តិបិ សល្លបន្តិបិ សង្កេតំបិ គច្ឆន្តិ បុរិសស្សបិ អព្ភាគមនំ សាទិយន្តិ ឆន្នំបិ អនុបវិសន្តិ កាយំបិ តទត្ថាយ ឧបសំហរន្តិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថគ្គហណំបិ សាទិយិស្សន្តិ សង្ឃាដិកណ្ណគ្គហណំបិ សាទិយិស្សន្តិ សន្តិដ្ឋិស្សន្តិបិ សល្លបិស្សន្តិបិ សង្កេតំបិ គច្ឆិស្សន្តិ បុរិសស្សបិ អព្ភាគមនំ សាទិយិស្សន្តិ ឆន្នំបិ អនុបវិសិស្សន្តិ កាយំបិ តទត្ថាយ ឧបសំហរិស្សន្តិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយាតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា

# បារាជិកទី ៤

[៦២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រាសម័យនោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយ (ភិក្ខុនីពួក ៦ នាក់) មានសេចក្ដីត្រេកអរនឹងការចាប់ដៃខ្លះ នឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសដែលមានតម្រេក ឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងប្រុសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីបិទបាំងខ្លះ ពិតរណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីនឹងសេពអសទ្ធម្មនុ៎ះ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមានតម្រេក មិនគួរនឹងត្រេកអរនឹងការចាប់ដៃខ្លះ ត្រេកអរនឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសបុគ្គលដែលត្រេកត្រអាល ឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងប្រុសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីកំបាំងខ្លះ ពិតរណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីសេពអសទ្ធម្មនុ៎ះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីទាំង

## ចតុត្ថបារាជិកេ បញ្ញត្តិ

ភិក្ខុនិយោ អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថគ្គហណម្បិ សាទិយន្តិ សង្ឃាដិកណ្ណគ្គហណម្បិ សាទិយន្តិ សន្តិដ្ឋន្តិបិ សល្លបន្តិបិ សង្កេតម្បិ គច្ឆន្តិ បុរិសស្សបិ អព្ភាគមនំ សាទិយន្តិ ឆន្នម្បិ អនុបវិសន្តិ កាយម្បិ តទត្ថាយ ឧបសំហរន្តិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្ពគ្គិយា ភិក្ខុនិយោ អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថគ្គហណម្បិ សាទិយិស្សន្តិ សង្ឃាដិកណ្ណគ្គហណម្បិ សាទិយិស្សន្តិ សន្តិដ្ឋិស្សន្តិបិ សល្លបិស្សន្តិបិ សង្កេតម្បិ គច្ឆិស្សន្តិ បុរិសស្សបិ អព្ភាគមនំ សាទិយិស្សន្តិ ឆន្នម្បិ អនុបវិសិស្សន្តិ កាយម្បិ តទត្ថាយ ឧបសំហរិស្សន្តិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថគ្គហណំ វា សាទិយេយ្យ សង្ឃាដិកណ្ណគ្គហណំ វា សាទិយេយ្យ



## បារាជិកទី ៤ សេចក្តីបញ្ញត្តិ

តម្រេក ត្រេកអរនឹងការចាប់ដៃខ្លះ ត្រេកអរនឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសបុគ្គលដែលត្រេកត្រអាល ឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងបុរសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីកំបាំងខ្លះ ពារណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីនឹងសេពអសទ្ធម្មនុ៎ះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមានតម្រេក មិនគួរនឹងត្រេកអរនឹងការចាប់ដៃខ្លះ ត្រេកអរនឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសបុគ្គលដែលមានតម្រេក ឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងបុរសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីកំបាំងខ្លះ ពារណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីនឹងសេពអសទ្ធម្មនុ៎ះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមានតម្រេក ហើយត្រេកអរនឹងការចាប់ដៃក្តី ត្រេកអរនឹងការចាប់ជាយសង្ឃាដីក្តី របស់បុរសបុគ្គលដែលមានតម្រេក

សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា សង្កេតំ វា គច្ឆេយ្យ បុរិសស្ស វា អព្ភាគមនំ សាទិយេយ្យ ឆន្នំ វា អនុបវិសេយ្យ កាយំ វា តទត្ថាយ ឧបសំហរេយ្យ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ អយម្បិ បារាជិកា ហោតិ អសំវាសា អដ្ឋវត្ថុកាតិ ។

(៤៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អវស្សុតា នាម សារត្តា អបេក្ខវតី[១] បដិពទ្ធចិត្តា ។ អវស្សុតោ នាម សារត្តោ អបេក្ខវា បដិពទ្ធចិត្តោ ។ បុរិសបុគ្គលោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ វិញ្ញូ បដិពលោ កាយសំសគ្គំ សមាបជ្ជិតុំ ។ ហត្ថគ្គហណំ វា សាទិយេយ្យាតិ ហត្ថោ នាម កប្បរំ ឧបាទាយ យាវ អគ្គនខា ។ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ ឧព្ភក្ខកំ អធោជាណុមណ្ឌលំ គហណំ សាទិយតិ អាបត្តិ ថុល្លច្ចយស្ស ។ សង្ឃាដិកណ្ណគ្គហណំ វា សាទិយេយ្យាតិ ឯតស្ស

១ ឱ. ម. អបេក្ខា ។



ឈរជាមួយក្តី ចរចាជាមួយក្តី ទៅកាន់ទីសង្កេតក្តី ត្រេកអរនឹងប្រុសដើរចូលមកជិតក្តី ចូលទៅកាន់ទីកំបាំងក្តី ពិចារណាកាយដើម្បីអសទ្ធម្មនោះក្តី ដើម្បីនឹងសេពអសទ្ធម្មនុ៎ះ ភិក្ខុនីនេះក្តី ត្រូវបារាជិក ឈ្មោះអដ្ឋវត្ថុកា (ព្រោះប្រកបដោយវត្ថុ ៨[១]) រកសំវាសគ្មាន ។

[៤៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌនេះរួចហើយ ។ ភិក្ខុនីដែលត្រេកអរមានសេចក្តីស្រេកឃ្លាន មានចិត្តប្រតិព័ទ្ធ ឈ្មោះថាមានតម្រេក ។ បុរសដែលត្រេកអរខ្លាំង មានចិត្តប្រតិព័ទ្ធ ឈ្មោះថាមានតម្រេក ។ មនុស្សប្រុសដែលដឹងក្តីអាចសម្រេចអង្អែលកាយបាន ឈ្មោះថា បុរសបុគ្គល មិនមែនយក្ស ប្រេត ប្រុស តិរច្ឆាន ឈ្មោះទេ ។ ពាក្យថា ត្រេកអរនឹងការចាប់ដៃក្តី សេចក្តីថា ដែលហៅថា ដៃ គឺកំណត់តាំងពីកែងដៃរហូតដល់ចុងក្រចក ។ ភិក្ខុនីត្រេកអរនឹងការចាប់ ខាងលើតាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលជង្គង់ចុះមក ប្រយោជន៍សេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច-យ ។ ពាក្យថា ត្រេកអរនឹងការចាប់ជាយសង្ឃាដីក្តី គឺភិក្ខុនីត្រេកអរ

១ ភិក្ខុនីធ្វើខុសក្នុងគ្រប់ចំណុច ៨ ។ ទើបត្រូវបារាជិក បើខុសតែ ៧ ណាមួយ ហើយដាក់ទោសថា ដែលខុសប្រាំពីរនោះហើយ ក៏សំដែងអាបត្តិចេញ ទល់ធ្វើក្រោយប្រាំពីរទៀតដល់ទៅ ៨ ដងក្តី ក៏មិនជាបារាជិកឡើយ ។

អសទ្ធម្មស្ស បដិសេវនត្ថាយ និវត្ថំ វា បារុតំ វា គហណំ សាទិយតិ អាបត្តិ ថុល្លច្ចយស្ស ។ សន្តិដ្ឋេយ្យ វាតិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ បុរិសស្ស ហត្ថបាសេ តិដ្ឋតិ អាបត្តិ ថុល្លច្ចយស្ស ។ សល្លបេយ្យ វាតិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ បុរិសស្ស ហត្ថបាសេ ឋិតា សល្លបតិ អាបត្តិ ថុល្លច្ចយស្ស ។ សង្កេតំ វា គច្ឆេយ្យាតិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ បុរិសេន ឥត្ថន្នាមំ អាគច្ឆាតិ វុត្តា គច្ឆតិ បទេ បទេ អាបត្តិ ទុក្កដស្ស បុរិសស្ស ហត្ថបាសំ ឱក្កន្តមត្តេ អាបត្តិ ថុល្លច្ចយស្ស ។ បុរិសស្ស វា អព្ភាគមនំ សាទិយេយ្យាតិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ បុរិសស្ស អព្ភាគមនំ សាទិយតិ អាបត្តិ ទុក្កដស្ស ហត្ថបាសំ ឱក្កន្តមត្តេ អាបត្តិ ថុល្លច្ចយស្ស ។ ឆន្នំ វា អនុបវិសេយ្យាតិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ យេន កេនចិ បដិច្ឆន្នំ ឱកាសំ បវិដ្ឋមត្តេ អាបត្តិ ថុល្លច្ចយស្ស ។ កាយំ វា តទត្ថាយ



ចំពោះការចាប់សំពត់ដែលស្លៀកក្តី ដែលដណ្តប់ក្តី ប្រយោជន៍នឹងសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ ។ ពាក្យថា ឈរជាមួយក្តី គឺភិក្ខុនីឈរក្នុងហត្ថបាសប្រុស ប្រយោជន៍នឹងសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ ។ ពាក្យថា ចរចាជាមួយក្តី គឺភិក្ខុនីឈរក្នុងហត្ថបាសប្រុសហើយចរចាជាមួយ ប្រយោជន៍នឹងសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ ។ ពាក្យថា ទៅកាន់ទីសង្កេតក្តី គឺភិក្ខុនីដែលប្រុសនិយាយថា លោកចូរមកកាន់ទីឱកាសឈ្មោះនេះឬនុះ ប្រយោជន៍ដល់ការសេពអសទ្ធម្មនុ៎ះ ហើយក៏ទៅ ត្រូវអាបត្តិទុក្កដ គ្រប់ ៗ ជំហាន លុះចូលទៅដល់ហត្ថបាសប្រុសហើយ ក៏ត្រូវអាបត្តិថុល្លច្ច័យ ។ ពាក្យថា ត្រេកអរនឹងប្រុសដើរចូលមកជិតក្តី គឺភិក្ខុនីត្រេកអរនឹងប្រុសដើរចូលមកជិត ប្រយោជន៍ដល់ការសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិទុក្កដ លុះដើរចូលមកដល់ហត្ថបាសកាលណា ក៏ត្រូវអាបត្តិថុល្លច្ច័យ ។ ពាក្យថា ចូលទៅកាន់ទីកំបាំងក្តី គឺភិក្ខុនីគ្រាន់តែចូលទៅកាន់ទីឱកាសដ៏បិទបាំងដោយរបស់ណាមួយ ប្រយោជន៍ដល់ការសេពអសទ្ធម្មនុ៎ះ ក៏ត្រូវអាបត្តិថុល្លច្ច័យ ។ ពាក្យថា ឱនរាងកាយប្រយោជន៍

ឧបសំហរេយ្យាតិ ឯតស្ស អសទ្ធម្មស្ស បដិសេវនត្ថាយ បុរិសស្ស ហត្ថបាសេ ឋិតា កាយំ ឧបសំហរតិ អាបត្តិ ថុល្លច្ចយស្ស ។

(៦៨) អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ បារាជិកា ហោតីតិ សេយ្យថាបិ នាម តាលោ មត្ថកច្ឆិន្នោ អភព្វោ បុនវិរុឡ្ហិយា ឯវមេវ ភិក្ខុនី អដ្ឋមំ វត្ថុំ បរិបូរេន្តី អស្សមណី ហោតិ អសក្យធីតា តេន វុច្ចតិ បារាជិកា ហោតីតិ ។ អសំវាសាតិ សំវាសោ នាម ឯកកម្មំ ឯកុទ្ទេសោ សមសិក្ខតា ឯសោ សំវាសោ នាម សោ តាយ សទ្ធឹ នត្ថិ តេន វុច្ចតិ អសំវាសាតិ ។

(៦៩) អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តិយា អសាទិយន្តិយា ឧម្មត្តិកាយ ខិត្តចិត្តាយ វេទនដ្ដាយ អាទិកម្មិកាយាតិ ។

ចតុត្ថបារាជិកំ និដ្ឋិតំ ។



ដល់អសទ្ធម្មនោះក្ដី គឺភិក្ខុនីឈរក្នុងហត្ថបាសប្រុស ហើយតិចតេណាក៏ កាយប្រយោជន៍ដល់ការសេពអសទ្ធម្មនុះ ត្រូវអាបត្តិថុល្លច្ច័យ ។

(៦៨) ត្រង់ពាក្យថា ភិក្ខុនីនេះក្ដី គឺភិក្ខុនីនេះឯង គឺជាគូរពោល ប្រៀបផ្ទឹមនឹងភិក្ខុនីមុនៗ ។ ពាក្យថា ត្រូវអាបត្តិបារាជិក សេចក្ដីថា ដើមត្នោតដែលកំបុតចុងមិនគួរដុះឡើងវិញទៀតបាន មានឧបមាយ៉ាងណាមិញ ភិក្ខុនីដែលញុំាងវត្ថុជាគំរប់ ៨ ឲ្យពេញ ក៏មិនមែនជាសមណី មិនមែនជាធីតារបស់ព្រះពុទ្ធជាសក្យត្រកូល ក៏មានឧបមេយ្យយ៉ាងនោះដែរ ហេតុនោះ បានជាលោកពោលហៅថា ភិក្ខុនីនោះ ត្រូវអាបត្តិបារាជិក (ជាអ្នកចាញ់) ។ ពាក្យថា រកសំវាសគ្មាន គឺដែលហៅថា សំវាស បានដល់កម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សេចក្ដីសិក្សាស្មើគ្នា នេះឈ្មោះថា សំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុនីនោះទេ ហេតុនោះបានជាលោកពោលហៅថា ភិក្ខុនីនោះជាស្រីមិនមានសំវាស ។

(៦៩) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុនីមិនក្លែងឲ្យកន្លង ១ ភិក្ខុនីមិនមានសតិ ១ ភិក្ខុនីមិនដឹងខ្លួន ១ ភិក្ខុនីមិនត្រេកអរ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីមានចិត្តរវើរវាយ ១ ភិក្ខុនីដែលវេទនាគ្របសង្កត់ ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

បារាជិកទី ៤ ចប់ ។

បារាជិកកណ្ឌេ ឧទ្ទេសាវសានំ

[៣០] ឧទ្ទិដ្ឋា ខោ អយ្យាយោ អដ្ឋ បារាជិកា ធម្មា យេសំ ភិក្ខុនី អញ្ញតរំ វា អញ្ញតរំ វា អាបជ្ជិត្វា ន លភតិ ភិក្ខុនីហិ សទ្ធិំ សំវាសំ យថា បុរេ តថា បច្ឆា បារាជិកា ហោតិ អសំវាសា ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បារាជិកកណ្ឌំ និដ្ឋិតំ ។



បារាជិកកណ្ឌ ឧទ្ទេសាវសាន

[៣០] បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិបារាជិកទាំងឡាយ ៨ ខ្ញុំសំដែងឡើងហើយ បណ្ដាអាបត្តិបារាជិកទាំងឡាយ ៨ នុ៎ះ ភិក្ខុនីណា ត្រូវអាបត្តិបារាជិកណាមួយ ភិក្ខុនីនោះមិនបាននៅរួមជាមួយនឹងភិក្ខុនីទាំងឡាយឡើយ (ព្រោះ) ខ្លួនត្រូវអាបត្តិបារាជិក គេសំរួសគ្នា កាលអំពីមុន គឺកាលដែលខ្លួននៅជាគ្រហស្ថមានសភាពយ៉ាងណា កាលតាំងក្រោយដែលខ្លួនត្រូវបារាជិកហើយ ក៏មានសភាពដូច្នោះដែរ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងរឿងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធក្នុងរឿងនុ៎ះហើយ ហេតុនោះ បានជានៅស្ងៀម ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

បារាជិកកណ្ឌ ចប់ ។

# សត្តរសកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ សត្តរស សង្ឃាទិសេសា

ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## បឋមសង្ឃាទិសេសំ

[៣១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ ភិក្ខុសង្ឃស្ស ឧទ្ទោសិតំ ទត្វា កាលង្កតោ ហោតិ ។ តស្ស ទ្វេ បុត្តា ហោន្តិ ឯកោ អស្សទ្ធោ អប្បសន្នោ ឯកោ សទ្ធោ បសន្នោ ។ តេ បេត្តិកំ សាបតេយ្យំ វិភជឹសុ ។ អថខោ សោ អស្សទ្ធោ អប្បសន្នោ តំ សទ្ធំ បសន្នំ ឯតទវោច អម្ហាកំ ឧទ្ទោសិតោ តំ ភាជេមាតិ[1] ។ ឯវំ វុត្តេ សោ សទ្ធោ បសន្នោ តំ អស្សទ្ធំ អប្បសន្នំ ឯតទវោច មាយ្យោ ឯវំ អវច អម្ហាកំ បិតុនា ភិក្ខុសង្ឃស្ស ទិន្នោតិ ។ ទុតិយម្បិ ខោ អស្សទ្ធោ

[1] ម. ភាជមាតិ ។

# សត្តរសកណ្ឌ

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិសង្ឃាទិសេសទាំង ១៧ នេះឯង

ដែលមកកាន់ឧទ្ទេស ។

## សង្ឃាទិសេសទី ១

(៣១) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសកម្នាក់ប្រគេនឃ្លាំង (កន្លែងដាក់របស់) ដល់ភិក្ខុសង្ឃ ហើយធ្វើមរណកាលទៅ ។ ឧបាសកនោះមានកូនពីរនាក់ ម្នាក់មិនមានសទ្ធាមិនជ្រះថ្លា ម្នាក់មានសទ្ធាជ្រះថ្លា ។ កូនទាំងពីរនាក់នោះយកសម្បត្តិដែលជារបស់បិតាមកចែកគ្នា ។ ឯបុរសដែលគ្មានសទ្ធាគ្មានជ្រះថ្លា នោះបាននិយាយពាក្យនេះនឹងបុរសដែលមានសទ្ធាជ្រះថ្លានោះថា ឃ្លាំងរបស់យើងមាន យើងនឹងចែកឃ្លាំងនោះ ។ កាលបើបុរសដែលឥតសទ្ធាឥតជ្រះថ្លានោះនិយាយយ៉ាងនេះហើយ បុរសដែលមានសទ្ធាជ្រះថ្លានោះបាននិយាយពាក្យនេះនឹងបុរសដែលមិនមានសទ្ធាមិនជ្រះថ្លានោះថា អ្នកម្ចាស់កុំនិយាយយ៉ាងនេះឡើយ ឃ្លាំងនោះបិតារបស់យើងប្រគេនដល់ភិក្ខុសង្ឃទៅហើយ ។ បុរសដែលមិនមានសទ្ធាមិនជ្រះថ្លានិយាយពាក្យនេះ

អប្បសទ្ទោ តំ សទ្ទំ បសទ្ទំ ឯតទវោច អព្ភាគតំ ឧទ្ទោសិតោ តំ កាលេមាតិ ។ អជ្ឈោ សោ សទ្ទោ បសទ្ទោ តំ អសទ្ទំ អប្បសទ្ទំ ឯតទវោច សាយេយ្យ ឯវំ អវច អព្ភាគតំ ឋិតុឌា កិត្តុជីសវិស្សេ ធិប្ពោតិ ។ តតិយម្បិ ទោ សោ អសទ្ទោ អប្បសទ្ទោ តំ សទ្ទំ បសទ្ទំ ឯតទវោច អព្ភាគតំ ឧទ្ទោសិតោ តំ កាលេមាតិ ។ អជ្ឈោ សោ សទ្ទោ បសទ្ទោ សរេច មយ្ហំ កាសេយ្យតំ អប្បំបិ កិត្តុជីសវិស្សេ ធស្សមីតិ តំ អសទ្ទំ អប្ប-សទ្ទំ ឯតទវោច កាលេកតិ ។ អជ្ឈោ សោ ឧទ្ទោសិតោ គេហំ កាជិយមានោ តស្ស អសទ្ទស្ស អប្បសទ្ទស្ស ទាបុណាំ[១] ។ អជ្ឈោ សោ អសទ្ទោ អប្បសទ្ទោ កិត្តុជិយោ ឧបសង្កមិត្វា ឯតទវោច ធិត្វាមជ្ឈេយ្យ អព្ភាគតំ ឧទ្ទោសិតោតិ ។ ឯវំ វុត្តេ ជុល្លបន្ថោ កិត្តុជី តំ ឯស ឯតទវោច ខាយេយ្យ ឯវំ អវច តព្ភាគតំ ឋិតុឌា កិត្តុជីសវិស្សេ ធិប្ពោតិ ។ ធិប្ពោ ធ ធិប្ពោតិ ហេយ្យកោ

១ ៖ ម. ដាបុណ្ណាំ ។



នឹងបុរសដែលមានសម្តីជ្រះថ្លានោះអស់វារៈពីរដងថា ឃ្លាំងរបស់យើងមាន យើងនឹងថែកន្លែងឃ្លាំងនោះ ។ បើបុរសដែលមានសម្តីជ្រះថ្លានោះបាននិយាយពាក្យនេះនឹងបុរសដែលគ្មានសម្តីមិនជ្រះថ្លានោះថា អ្នកម្ចាស់កុំនិ-យាយយ៉ាងនេះឡើយ ឃ្លាំងនោះមិនមែនយើងប្រគេនដល់ភិក្ខុសង្ឃហើយ ។ បុរសដែលគ្មានសម្តីឥតជ្រះថ្លានោះ បាននិយាយពាក្យនេះនឹងបុរសដែលមានសម្តីជ្រះថ្លានោះអស់វារៈគំរប់បីដងថា ឃ្លាំងរបស់យើងមាន យើងនឹងថែកន្លែងឃ្លាំងនោះ ។ លំដាប់នោះ បុរសដែលមានសម្តីជ្រះថ្លាក៏និយាយថា បើឃ្លាំងនឹងបានមកអញ អញនឹងប្រគេនភិក្ខុសង្ឃ ហើយក៏បាននិយាយពាក្យនេះនឹងបុរសមិនមានសម្តីមិនជ្រះថ្លានោះថា យើងថែកគ្នាចុះ ។ ឯឃ្លាំងនោះកាលដែលអ្នកទាំងពីរចែកគ្នាហើយ ក៏បានទៅលើក្នុងដែលមិនមានសម្តីមិនជ្រះថ្លានោះ ។ បើបុរសដែលឥតសម្តីឥតជ្រះថ្លានោះចូលទៅរកភិក្ខុទាំងឡាយ ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ លោកទាំងឡាយចូរចេញទៅ ឃ្លាំងជារបស់យើង ។ កាលបើបុរសដែលគ្មានសម្តីគ្មានជ្រះថ្លានោះនិយាយយ៉ាងនេះហើយ ចុល្លបន្ថកភិក្ខុក៏បាននិយាយពាក្យនេះនឹងបុរសនោះថា នែអ្នកម្ចាស់ អ្នកកុំនិយាយយ៉ាងនេះឡើយ ឃ្លាំងនេះមិនមែនរបស់អ្នក ប្រគេនដល់ភិក្ខុសង្ឃហើយតើ ។ ផងទាំងពីរនោះសួរមហាមាត្យថា ទៅក្រមថា ឃ្លាំងនោះគេបានប្រគេនភិក្ខុ

អពោអត្តេ បុច្ឆិំសុ ។ មហាមត្តា ឯវមាហំសុ កោ អយ្យោ ជានាតិ ភិក្ខុនីសង្ឃស្ស ទិន្នោតិ ។ ឯវំ វុត្តេ ថុល្លនន្ទា ភិក្ខុនី តេ មហាមត្តេ ឯតទវោច អយ្យា(១) តុម្ហេហិ ទិដ្ឋំ វា សុតំ វា សក្ខឹ ឋបយិត្វា ទានំ ទិយមានន្តិ ។ អថខោ តេ មហាមត្តា សច្ចំ ខោ អយ្យា អាហាតិ តំ ឧទោសិតំ ភិក្ខុនីសង្ឃស្ស អកំសុ ។ អថខោ សោ បុរិសោ បរាជិតោ ឧជ្ឈាយតិ ខិយ្យតិ វិបាចេតិ អស្សមណិយោ ឥមា មុណ្ឌា ពន្ធកិនិយោ កថំ ហិ នាម អម្ហាកំ ឧទោសិតំ អច្ឆិន្ទាបេស្សន្តីតិ ។ ថុល្លនន្ទា ភិក្ខុនី មហាមត្តានំ ឯតមត្ថំ អារោចេសិ ។ មហាមត្តា តំ បុរិសំ ទណ្ឌាបេសុំ ។ អថខោ សោ បុរិសោ ទណ្ឌិតោ(២) ភិក្ខុនុបស្សយស្ស អវិទូរេ អាជីវកសេយ្យំ ការាបេត្វា អាជីវកេ ឧយ្យោជេសិ ឯតា ភិក្ខុនិយោ អច្ចាវទថាតិ ។ ថុល្លនន្ទា ភិក្ខុនី មហាមត្តានំ ឯតមត្ថំ អារោចេសិ ។ មហាមត្តា តំ បុរិសំ ពន្ធាបេសុំ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ បឋមំ(៣) ហិ នាម ភិក្ខុនិយោ ឧទោសិតំ



សង្ឃហើយឬមិនបានប្រគេន (ទេ) ។ មហាមាត្យទាំងឡាយបាននិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ តើអ្នកណាដឹងថា យ៉ាងនោះគេប្រគេនភិក្ខុនីសង្ឃហើយ (ខ្លះដែរ) ។ កាលបើមហាមាត្យទាំងឡាយនិយាយយ៉ាងនេះហើយ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងមហាមាត្យទាំងឡាយនោះថា កាលដែលគេឲ្យទាន (នោះ) សឹងមានសមកនឹងសាក្សីអ្នកទាំងឡាយក៏បានឃើញ បានឮខ្លះដែរ ។ ទើបមហាមាត្យទាំងឡាយនោះនិយាយថា លោកម្ចាស់និយាយពាក្យនេះពិតមែន ហើយកាត់ឲ្យថ្វាយឲ្យយ៉ាងនោះដល់ភិក្ខុនីសង្ឃវិញ ។ ឯបុរសនោះលុះចាញ់គេហើយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ស្រីផ្កាមាសស្រីតើរលទាំងនេះមិនមែនជាសមណីទេ មិនសមបើនឹងឲ្យគេដណ្ដើមយកឃ្លាំងរបស់យើងសោះ ។ ថុល្លនន្ទាភិក្ខុនីប្រាប់ដំណើរនុ៎ះដល់មហាមាត្យទាំងឡាយ ។ មហាមាត្យទាំងឡាយក៏ពិន័យបុរសនោះ ។ ឯបុរសនោះលុះត្រូវពិន័យហើយ ក៏ឲ្យគេសាងលំនៅកន្លែងក្បែរជិតលំនៅភិក្ខុនី ហើយបញ្ជូនពួកអាជីវកទៅដោយពាក្យថា អ្នកទាំងឡាយចូរជេរភិក្ខុនីទាំងឡាយនុ៎ះ ។ ថុល្លនន្ទាភិក្ខុនីប្រាប់ដំណើរនុ៎ះដល់មហាមាត្យទាំងឡាយ ។ មហាមាត្យទាំងឡាយក៏ចាប់ចងបុរសនោះធ្វើទោស (ដាក់គុក) ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរនឹង (ប្រព្រឹត្តល្មើសដោយ

## បឋមសង្ឃាទិសេស បញ្ញត្តិ

អច្ឆិន្ទាបេសុំ ទុតិយម្បិ ទណ្ឌាបេសុំ តតិយម្បិ ពន្ធាបេសុំ ឥទានិ ឃាតាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ឧស្សយវាទិកា វិហរិស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ឧស្សយវាទិកា វិហរតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ឧស្សយវាទិកា វិហរិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ឧស្សយវាទិកា វិហរេយ្យ គហបតិនា វា គហបតិបុត្តេន វា ទាសេន វា កម្មករេន វា អន្តមសោ សមណបរិព្ពាជកេនាបិ អយំ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។



## សង្ឃាទិសេសទី ១ សេចក្តីបញ្ញត្តិ

ស្ទានហើយ ។ គឺ ១ ឲ្យមហាមាត្យដណ្តើមយកឃ្លាំងរបស់គេ ២ ឲ្យមហាមាត្យពិន័យលក់គេ ៣ ឲ្យមហាមាត្យចាប់ដាក់គុកគេ ឥឡូវនេះមុខជានឹងឲ្យមហាមាត្យសម្លាប់គេ ។ ភិក្ខុនីទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀលបន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទាម្តេចក៏សមបើនឹងពោលពាក្យដោយសេចក្តីប្រណាំង(ប្តឹងក្តី)ដូច្នេះ ។ ទើបភិក្ខុនីទាំងឡាយនោះប្រាប់ដំណើរនុះដល់ភិក្ខុទាំងឡាយ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីជាអ្នកប្តឹងក្តី ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរនឹងជាអ្នកប្តឹងក្តីគេទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយជាអ្នកប្តឹងក្តីនឹងគហបតិក្តី កូនគហបតិក្តី ខ្ញុំគេក្តី អ្នកស៊ីឈ្នួលក្តី ដោយហោចទៅសូម្បីតែសមណបរិព្វាជក ភិក្ខុនីនេះត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិ គួរបណ្តេញចេញពីគណសង្ឃ ។

(៣៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឧស្សយវាទិកា នាម អឌ្ឌការិកា វុច្ចតិ ។ គហបតិ នាម យោ កោចិ អគារំ អជ្ឈាវសតិ ។ គហបតិបុត្តោ នាម យេ កេចិ(១) បុត្តភាតរោ ។ ទាសោ នាម អន្តោជាតោ ធនក្កីតោ ករមរានីតោ ។ កម្មការោ(២) នាម ភតកោ អាហតកោ ។ សមណបរិព្វាជកោ នាម ភិក្ខុញ្ច ភិក្ខុនិញ្ច សិក្ខមានញ្ច សាមណេរញ្ច សាមណេរិញ្ច ឋបេត្វា យោ កោចិ បរិព្វាជកសមាបន្នោ ។ អឌ្ឌំ ករិស្សាមីតិ ទុតិយំ វា បរិយេសតិ គច្ឆតិ វា អាបត្តិ ទុក្កដស្ស ។ ឯកស្ស អារោចេតិ អាបត្តិ ទុក្កដស្ស ។ ទុតិយស្ស អារោចេតិ អាបត្តិ ថុល្លច្ចយស្ស ។ អឌ្ឌបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។

(៣៧) បឋមាបត្តិកន្តិ សហ វត្ថុជ្ឈាចារា អាបជ្ជតិ អសមនុភាសនាយ ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារីយតិ ។ សង្ឃាទិសេសោតិ សង្ឃោវ តស្សា

១ ឱ ម. យោកេចិ ។ ២ ឱ ម. កម្មករោ ។



(៣៦) ត្រង់បទថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងទីខាងដើម ទើបរួចហើយ ។ ដែលហៅថា ប្ដឹងក្ដី គឺសំដៅយកភិក្ខុនីជាអ្នកក្ដី ។ ជនណាមួយនៅគ្រប់គ្រងផ្ទះ ជននោះឈ្មោះថា គហបតិ ។ ដែលហៅថា កូនគហបតិ គឺជនទាំងឡាយណាមួយជាកូនទាំងបងប្អូនប្រុស របស់គហបតិនោះ ។ ដែលហៅថា ខ្ញុំ គឺខ្ញុំដែលកើតក្នុងផ្ទះ ខ្ញុំដែលលោះដោយទ្រព្យ ឬមនុស្សឈ្លើយ ដែលគេចាប់បាននាំមក ។ ដែលហៅថា អ្នកធ្វើការ គឺអ្នកធ្វើការស៊ីឈ្នួល អ្នកធ្វើការដែលគេនាំត្រៀមឧបករណ៍ ។ ជនណាមួយដែលបួសក្នុងសំណាក់បរិព្វាជក លើកលែងតែភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ នឹងសាមណេរីចេញ ហៅថា សមណបរិព្វាជក ។ ភិក្ខុនីគិតថា អញនឹងធ្វើគតីក្ដី ហើយស្វែងរក (គូ) ជាគំរប់ពីរក្ដី ដើរទៅក្ដី ត្រូវអាបត្តិទុក្កដ ប្ដឹងទៅម្នាក់ ត្រូវអាបត្តិទុក្កដ ប្ដឹងទៅអ្នកទីពីរ ត្រូវអាបត្តិថុល្លច្ច័យ សម្រេចក្ដី ត្រូវអាបត្តិសង្ឃាទិសេស ។

(៣៧) ត្រង់ពាក្យថា ជាបឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិមួយអន្លើដោយការប្រព្រឹត្តកន្លងវត្ថុ (ជាដំបូង) មិនមែនដោយសូត្រសមនុភាសនកម្មទេ ។ ពាក្យថា គួរបណ្ដេញចេញចាកសង្ឃ គឺភិក្ខុនីនោះត្រូវភិក្ខុនីឯទៀតនាំចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស គឺសង្ឃគង់

អាបត្តិយា មានត្តំ ទេតិ មូលាយ បដិកស្សតិ អព្ភេតិ ។ ន សម្ពហុលា ភិក្ខូ ន ឯកោ ភិក្ខុ តេន វុច្ចតិ សង្ឃាទិសេសោតិ ។ តស្សេវ អាបត្តិនិកាយស្ស នាមកម្មំ អធិវចនំ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

(៣៥) អនាបត្តិ មនុស្សេហិ អាគន្តុយមានា គច្ឆតិ អាគន្តុំ យាចតិ អវោចិស្ស អាចិក្ខតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

---

## ទុតិយសង្ឃាទិសេសំ

(៣៩) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន វេសាលិយំ អញ្ញតរស្ស ឧទាយិស្ស ឧបដ្ឋាយិកា អតិចារិនី ហោតិ ។ អថខោ សោ ឧទាយី តំ ឥត្ថឹ ឯកតោ ភុញ្ជន សាធុ វិហាមាហំ ចេតនំ ទោ តេ ភិក្ខុ វិស្សាសមត្តិ[1] ។ ឯវំបិ សា វុច្ចមានា ន អាគមិ ។ តេន

---

● ១. ម. ភវិស្សាមាតិ ។



គាបចេញមានក្នុ ដើម្បីអាបត្តិនោះ នឹងកាញអត្ថាបត្តិមកជាក់ក្នុងមូលាបត្តិ អព្ភានក្នុង ក៏ក្នុងកិច្ចយាព្រឹងប្រមាណ (២.៣រូប) ឲ្យមានក្នុង ក៏ក្នុងឲ្យ ប្រកឬមិនប៉ុន ហេតុនោះ បានជាពាក្យតហៅពួកអាបត្តិនោះថា សង្ឃា-ទិសេស ។ ពាក្យថា សង្ឃាទិសេសជានាមកម្មគឺជាឈ្មោះនៃអាបត្តិនិកាយនោះឯង ព្រោះហេតុនោះ បានជាពាក្យតហៅអាបត្តិនិកាយនោះថា សង្ឃាទិសេស ។

[៣៦] ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុដែលមនុស្សវាលិច្ឆវីយកោះទៅ ១ ភិក្ខុដែលសួមសាត្រូ ក៏ (សួម ឲ្យភេសភាវជួយគេក្រៅ ១ ភិក្ខុដែលមិនបំពានឈ្មោះ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាអាទិកម្មិក ១ ។

---

## សង្ឃាទិសេសទី ២

[៣៧] សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភរិយា របស់ស្ដេចលិច្ឆវី ១ អង្គប្រព្រឹត្តកន្លងចិត្ត (ប្តី) ។ លើកស្ដេចលិច្ឆវីនោះបាន និយាយពាក្យនេះនឹងស្រីនោះថា អញសុំលើកនាងឯង ចូរនាងឯងលះ (អំពើនោះ) ចេញ ទំអញនឹងធ្វើសេចក្ដីនាសដល់នាងឯង ។ ស្រីនោះទុក ជាស្ដេចលិច្ឆវីនោះនិយាយហើយនោះក៏មិនអើពើឡើយ ។ សម័យនោះឯង

ខោ បន សមយេន វេសាលិយំ(១) លិច្ឆវិគណោ សន្និ-បតិតោ ហោតិ កេនចិទេវ ករណីយេន ។ អថខោ សោ លិច្ឆវី តេ លិច្ឆវយោ ឯតទវោច ឯកំ មេ អយ្យា(២) ឥត្ថឹ អនុជានាថាតិ ។ កា នាម សាតិ ។ មយ្ហំ បជាបតី អតិចរតិ តំ ឃាតេស្សាមីតិ ។ ជានាហីតិ ។ អស្សោសិ ខោ សា ឥត្ថី សាមិកោ កិរ មំ ឃាតេតុ-កាមោតិ វរភណ្ឌំ អាទាយ សាវត្ថឹ គន្ត្វា តិត្ថិយេ ឧប-សង្កមិត្វា បព្វជ្ជំ យាចិ ។ តិត្ថិយា ន ឥច្ឆឹសុ បព្វាជេតុំ ។ ភិក្ខុនិយោ ឧបសង្កមិត្វា បព្វជ្ជំ យាចិ ។ ភិក្ខុនិយោបិ ន ឥច្ឆឹសុ បព្វាជេតុំ ។ ថុល្លនន្ទំ ភិក្ខុនឹ ឧបសង្កមិត្វា ភណ្ឌកំ ទស្សេត្វា បព្វជ្ជំ យាចិ ។ ថុល្លនន្ទា ភិក្ខុនី ភណ្ឌកំ គហេត្វា បព្វាជេសិ ។ អថខោ សោ លិច្ឆវី តំ ឥត្ថឹ គវេសន្តោ សាវត្ថឹ គន្ត្វា ភិក្ខុនីសុ បព្វជិតំ ទិស្វា យេន រាជា បសេនទិ កោសលោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ បសេនទឹ កោសលំ ឯតទវោច បជាបតី មេ ទេវ វរភណ្ឌំ អាទាយ សាវត្ថឹ អនុប្បត្តា

១ ម. ម. វេសាលិយា ។ ២ ម. ម. អយ្យោ ។



ជួនជាមានការប្រជុំពួកស្តេចលិច្ឆវីក្នុងក្រុងវេសាលីដោយកិច្ចនីមួយ ។ ទើបស្តេចលិច្ឆវីនោះបានទូលពាក្យនេះនឹងស្តេចលិច្ឆវីទាំងឡាយនោះថា ទេវព្រះអង្គទាំងឡាយ សូមព្រះអង្គទាំងឡាយអនុញ្ញាតស្រីម្នាក់ដល់ខ្ញុំ ។ ស្តេចលិច្ឆវីទាំងឡាយនោះសួរថា ស្រីនោះជាអ្វី ។ ស្តេចលិច្ឆវីនោះឆ្លើយថា ជាប្រពន្ធខ្ញុំ ក្បត់ចិត្តខ្ញុំ ខ្ញុំនឹងសម្លាប់វានោះចោល ។ ស្តេចលិច្ឆវីទាំងឡាយនិយាយថា ព្រះអង្គចូរដឹងចុះ ។ ស្រីនោះក៏បានឮពត៌មានថា ប្តីចង់សម្លាប់អញ ហើយក៏យករបស់ដែលមានថ្លៃទៅកាន់ក្រុងសាវត្ថី ចូលទៅរកពួកតិរ្ថិយហើយក៏សូមបព្វជ្ជា ។ តិរ្ថិយទាំងឡាយមិនចូលចិត្តឲ្យស្រីនោះបួសឡើយ ។ ស្រីនោះចូលទៅរកពួកភិក្ខុនីហើយសូមបព្វជ្ជា (ទៀត) ។ ភិក្ខុនីទាំងឡាយក៏មិនចូលចិត្តឲ្យនាងនោះបួសដែរ ។ ស្រីនោះចូលទៅរកថុល្លនន្ទាភិក្ខុនី បង្ហាញបង្វិចរបស់ហើយសូមបព្វជ្ជា ។ ថុល្លនន្ទាភិក្ខុនីទទួលយកបង្វិចរបស់ហើយឲ្យស្រីនោះបួស ។ ឯស្តេចលិច្ឆវីនោះកាលស្វែងរកស្រីនោះ បានទៅកាន់ក្រុងសាវត្ថីឃើញស្រីនោះបួសក្នុងសំណាក់ភិក្ខុនីទាំងឡាយ ហើយក៏ចូលទៅគាល់ស្តេចបសេនទិកោសល លុះចូលទៅដល់ហើយក្រាបទូលពាក្យនេះនឹងព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព ភរិយារបស់ខ្ញុំ នាំយករបស់មានថ្លៃហើយមកកាន់ក្រុងសាវត្ថីនេះ (សព្វថ្ងៃនេះ) សូមព្រះអង្គ

តំ ទេវោ អនុជានាតូតិ ។ តេនហិ ភណេ វិចិនិត្វា អាចិក្ខាតិ ។ ទិដ្ឋា ទេវ ភិក្ខុនីសុ បព្វជិតាតិ ។ សចេ ភណេ ភិក្ខុនីសុ បព្វជិតា ន សា លព្ភា កិញ្ចិ កាតុំ ។ ស្វាក្ខាតោ ភគវតា ធម្មោ ចរតុ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។ អថខោ សោ លិច្ឆវី ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនិយោ ចោរឹ បព្វាជេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តស្ស លិច្ឆវិស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ចោរឹ បព្វាជេស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ចោរឹ បព្វាជេតីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ

១ ម. បព្វាជេសីតិ ។





អនុញ្ញាតស្រីនោះឲ្យបួស ។ ស្ដេចមានព្រះរាជឱង្ការថា នែនាយ បើដូច្នោះ ចូរអ្នកពិចារណា ហើយមកក្រាបបង្គំទូល ។ ស្ដេចលិច្ឆវីនោះទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គបានឃើញស្រីនោះបួសក្នុងសំណាក់ភិក្ខុនីទាំងឡាយហើយ ។ ស្ដេចមានព្រះឱង្ការថា នែនាយ បើស្រីនោះបួសក្នុងសំណាក់ភិក្ខុនីទាំងឡាយហើយ ការធ្វើអ្វីៗបន្តិចដល់ភិក្ខុនីនោះមិនបានទេ ព្រោះថា ធម៌គឺព្រះដ៏មានព្រះភាគសំដែងល្អហើយ ចូរភិក្ខុនីនោះប្រព្រឹត្តព្រហ្មចរិយ ដើម្បីធ្វើនូវទីបំផុតទុក្ខដោយប្រពៃចុះ ។ ទើបស្ដេចលិច្ឆវីនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមនឹងបំបួសស្រីជាចោរនោះ ។ ភិក្ខុនីទាំងឡាយបានឮពាក្យស្ដេចលិច្ឆវីនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទាមិនសមបើនឹងបំបួសស្រីចោរនោះ ។ ទើបភិក្ខុនីទាំងឡាយនោះប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីបំបួសស្រីជាចោរ ពិតមែនឬ ។ ភិក្ខុទាំងឡាយទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងបំបួសស្រីចោរទេ ម្នាលភិក្ខុទាំងឡាយ

ថុល្លនន្ទា ភិក្ខុនី ចោរឹ វុដ្ឋាបេស្សតិ នេតំ ភិក្ខវេ អប្ប-
សន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ
ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី
ជានំ ចោរឹ វជ្ឈំ វិទិតំ អនបលោកេត្វា រាជានំ វា សង្ឃំ
វា គណំ វា បូគំ វា សេណឹ វា អញ្ញត្រ កប្បា វុដ្ឋា-
បេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា
និស្សារណីយំ សង្ឃាទិសេសន្តិ ។

(៣៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ
។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។
ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្សា
អារោចេន្តិ សា វា អារោចេតិ ។ ចោរី នាម យា
បញ្ចមាសកំ វា អតិរេកបញ្ចមាសកំ វា អគ្ឃនកំ
អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ ឯសា ចោរី នាម ។
វជ្ឈា នាម យំ កត្វា វជ្ឈប្បត្តា ហោតិ ។ វិទិតា
នាម អញ្ញេហិ មនុស្សេហិ ញាតា ហោតិ វជ្ឈា ឯសា-
តិ ។ អនបលោកេត្វាតិ អនាបុច្ឆា ។ រាជា នាម
យត្ថ រាជា អនុសាសតិ រាជា អបលោកេតព្វោ ។



អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយដឹងថាស្រីជាចោរដែលគេដឹងច្បាស់ថាគួរសម្លាប់ ហើយមិនបានប្រាប់ស្តេចក្តី សង្ឃក្តី គណៈក្តី ប្រជុំជនក្តី សេនាក្តី ហើយបំបួស (ស្រីនោះ) វៀរតែកប្ប (គឺមានសំបុត្រត្រឡប់) ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

(៣៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីដូចខាងដើម សិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលឈ្មោះថា ដឹង គឺភិក្ខុនីដឹងខ្លួនឯងក្តី ជនទាំងឡាយដទៃប្រាប់ភិក្ខុនីនោះក្តី ស្រីចោរនោះប្រាប់ក្តី ។ ដែលហៅថា ស្រីចោរ គឺស្រីណា មានចេតនាលួចយកទ្រព្យ មានថ្លៃប្រាំមាសកក្តី លើសពីប្រាំមាសកក្តី ដែលគេមិនបានឲ្យ ស្រីនេះឈ្មោះថា ស្រីចោរ ។ ស្រីដល់នូវទោសគួរសម្លាប់ គឺស្រីធ្វើអំពើណា អំពើនេះឈ្មោះថា ទោសគួរសម្លាប់ ។ ដែលហៅថា គេដឹងច្បាស់ គឺស្រីដែលមនុស្សទាំងឡាយដទៃដឹងថា ស្រីនេះមានទោសគួរសម្លាប់ ។ ពាក្យថា មិនបានប្រាប់ គឺមិនបានដកថា ។ ដែលហៅថា ស្តេច គឺស្តេចគ្រប់គ្រងក្នុងទីណា ត្រូវភិក្ខុនីថ្វាយដំណឹងស្តេច (ក្នុងទីនោះ) ។

សង្ឃោ នាម ភិក្ខុនីសង្ឃោ វុច្ចតិ ភិក្ខុនីសង្ឃំ អប-លោកេត្វា ។ គណោ នាម យត្ថ គណោ អនុសាសតិ គណោ អបលោកេត្វា ។ បូគោ នាម យត្ថ បូគោ អនុសាសតិ បូគោ អបលោកេត្វា ។ សេណិ នាម យត្ថ សេណិ អនុសាសតិ សេណិ អបលោកេត្វា ។ អញ្ញត្រ កប្បាតិ ឋបេត្វា កប្បំ ។ កប្បំ នាម ទ្វេ កប្បានិ តិត្ថិយេសុ វា បព្វជិតា ហោតិ អញ្ញាសុ វា ភិក្ខុនីសុ បព្វជិតា ។ អញ្ញត្រ កប្បា វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ សង្ឃាទិសេសស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

(៣៧) អយម្បិ បុរិមំ ឧបាទាយ វុច្ចតិ ។ បឋ-មាបត្តិកាតិ សហ វត្ថុជ្ឈាចារា អាបជ្ជតិ អសមនុភា-



ដែលហៅថា សង្ឃ សំដៅយកភិក្ខុនីសង្ឃ ភិក្ខុនីត្រូវច្បាប់ភិក្ខុនីសង្ឃ (នោះឯង) ។ ដែលហៅថា គណៈ គឺគណៈភិក្ខុនីក្រុមណាមួយ ភិក្ខុនីត្រូវច្បាប់គណភិក្ខុនី (ក្រុមនោះដែរ) ។ ដែលហៅថា ប្រជុំជន គឺចំ-ណោមមនុស្សក្រុមណាមួយ ភិក្ខុនីត្រូវច្បាប់ចំណោមមនុស្ស (ក្រុមនោះ) ។ ដែលហៅថា សេនា គឺសេនាក្រុមណាមួយ ភិក្ខុនីត្រូវច្បាប់សេនា (ក្រុមនោះ) ។ ពាក្យថា វៀរលែងតែកប្ប គឺមានសំបុត្រច្បាប់ សេចក្ដីថា លើកលែងតែមានសំបុត្រច្បាប់ ។ ដែលហៅថា កប្ប បានដល់ កប្បពីរយ៉ាង (ជាដំបូង) ស្រីនេះធ្លាប់បួសក្នុងសំណាក់តិរ្ថិយតាំងនិក្ខ្យយក្ដី ស្រីនេះធ្លាប់បួសក្នុងសំណាក់ភិក្ខុនីតាំងនិក្ខ្យយដទៃក្ដី ។ ភិក្ខុនីគិតថា អញនឹងបំបួស (ស្រីនោះ) ហើយស្វែងរកគណៈក្ដី ភិក្ខុនីជាអាចារ្យក្ដី បាត្រក្ដី ចីវរក្ដី សម្មតសីមាក្ដី ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសំបុត្រច្បាប់ ភិក្ខុនីជាឧបជ្ឈាយ៍ត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងខណៈចប់កម្មវាចាពីរលើក ចប់កម្មវាចាស្រេច ត្រូវអាបត្តិសង្ឃាទិសេស ចំណែកគណៈនិងភិក្ខុនីជាអាចារ្យ ត្រូវត្រឹមអាបត្តិទុក្កដ ។

(៣៧) ពាក្យថា ភិក្ខុនីនេះក្ដី សំដៅកាលបើប្រៀបធៀបនឹងភិក្ខុនីដែលត្រូវអាបត្តិមុន ១ ។ ពាក្យថា បឋមាបត្តិកា គឺភិក្ខុនីត្រូវអាបត្តិ

សនាយ ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារីយតិ ។ សង្ឃាទិសេសោតិ ។បេ។ តេនបិ វុច្ចតិ សង្ឃាទិ-សេសោតិ ។

(៣៨) ចោរិយា ចោរីសញ្ញា អញ្ញត្រ កប្បា វុដ្ឋាបេតិ អាបត្តិ សង្ឃាទិសេសស្ស ។ ចោរិយា វេមតិកា អញ្ញត្រ កប្បា វុដ្ឋាបេតិ អាបត្តិ ទុក្កដស្ស ។ ចោរិយា អចោរីសញ្ញា អញ្ញត្រ កប្បា វុដ្ឋាបេតិ អនាបត្តិ ។ អចោរិយា ចោរីសញ្ញា អាបត្តិ ទុក្កដស្ស ។ អចោរិយា វេមតិកា អាបត្តិ ទុក្កដស្ស ។ អចោរិយា អចោរី-សញ្ញា អនាបត្តិ ។

(៣៩) អនាបត្តិ អជានន្តី វុដ្ឋាបេតិ អបលោ-កេត្វា វុដ្ឋាបេតិ កប្បកតំ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



មួយអន្លើដោយការប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសន ។ ពាក្យថា គួរបណ្ដេញចេញចាកសង្ឃ គឺភិក្ខុនីនោះត្រូវភិក្ខុនីឯទៀតនាំចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានសេចក្ដីអធិ-ប្បាយក្នុងសង្ឃាទិសេសទី ១ រួចហើយ ។

(៣៨) ស្រីចោរ ភិក្ខុនីសំគាល់ថាស្រីចោរ ហើយបំបួស (ស្រីនោះ) ត្រូវអាបត្តិសង្ឃាទិសេស វៀរលែងតែមានសំបុត្រច្បាប់ ។ ស្រីចោរ ភិក្ខុនីសង្ស័យ ហើយបំបួស (ស្រីនោះ) ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសំបុត្រច្បាប់ ។ ស្រីចោរ ភិក្ខុនីសំគាល់ថាមិនមែនចោរ ហើយបំបួស (ស្រីនោះ) មិនត្រូវអាបត្តិ វៀរលែងតែមានសំបុត្រច្បាប់ ។ មិនមែនស្រីចោរ ភិក្ខុនីសំគាល់ថាស្រីចោរ ត្រូវអាបត្តិទុក្កដ ។ មិនមែនស្រីចោរ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនស្រីចោរ ភិក្ខុនីសំគាល់ថាមិនមែនស្រីចោរ មិនត្រូវអាបត្តិ ។

(៣៩) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុនីមិនដឹងហើយបំបួស ១ ភិក្ខុនីដែលប្រាប់ដល់អ្នកកាន់ការមានស្ដេចជាដើម ហើយទើបបំបួស ១ ភិក្ខុនីបំបួសស្រីដែលមានសំបុត្រច្បាប់ពីក្នុងកាលមុនរួចហើយ (គឺស្រីដែលបានបួសក្នុងសំណាក់ពួកតិរ្ថិយ ឬភិក្ខុនីឯទៀត) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

# តតិយសង្ឃាទិសេសំ

[៤០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភទ្ទាយ កាបិលានិយា អន្តេវាសិនី(១) ភិក្ខុនីហិ សទ្ធឹ ភណ្ឌិត្វា គាមកេ(២) ញាតិកុលំ អគមាសិ ។ ភទ្ទា កាបិលានី តំ ភិក្ខុនឹ អបស្សន្តី ភិក្ខុនិយោ បុច្ឆិ កហំ ឥត្ថន្នាមា ន ទិស្សតីតិ ។ ភិក្ខុនីហិ សទ្ធឹ អយ្យេ ភណ្ឌិត្វា ន ទិស្សតីតិ ។ អម្ហា អមុកស្មឹ គាមកេ ឯតិស្សា ញាតិកុលំ តត្ថ ភទ្ទា វិចិនថាតិ ។ ភិក្ខុនិយោ តត្ថ គន្ត្វា តំ ភិក្ខុនឹ បស្សិត្វា ឯតទវោចុំ កិស្ស ត្វំ អយ្យេ ឯកិកា អាគតា កច្ចិសិ អប្បធំសិតាតិ ។ អប្បធំសិតម្ហិ អយ្យេតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី ឯកា គាមន្តរំ

១ ឧ. ម. អន្តេវាសិកា ។ ២ ឧ. ម. គាមកំ ។

# សង្ឃាទិសេសទី ៣

[៤០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីថេរី ឈ្លោះនឹងភិក្ខុនីទាំងឡាយហើយក៏បាននៅកាន់ត្រកូលញាតិក្នុងស្រុក ។ ភទ្ទាកាបិលានីថេរីកាលមិនឃើញភិក្ខុនីនោះ ក៏សួរភិក្ខុនីទាំងឡាយថា ភិក្ខុនីឈ្មោះនេះទៅណា មិនឃើញ ។ ភិក្ខុនីទាំងឡាយប្រាប់ថា បពិត្រលោកម្ចាស់ ភិក្ខុនីនោះឈ្លោះនឹងភិក្ខុនីទាំងឡាយហើយ (ស្រាប់តែ) មិនឃើញ ។ ភទ្ទាកាបិលានីថេរីនិយាយថា នែនាងទាំងឡាយ ត្រកូលញាតិរបស់ភិក្ខុនីនេះមាននៅក្នុងស្រុកឈ្មោះឯណោះ ចូរនាងទាំងឡាយទៅពិនិត្យរកក្នុងត្រកូលនោះមើល ។ ភិក្ខុនីទាំងឡាយទៅក្នុងទីនោះឃើញភិក្ខុនីនោះ ហើយបាននិយាយពាក្យនេះថា នែលោកម្ចាស់ ហេតុអ្វីក៏លោកមកតែម្នាក់ឯង មិនមានគេបៀតបៀនលោកទេឬ ។ ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ ខ្ញុំមិនមានអ្នកណា បៀតបៀនទេ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងទៅ

គច្ឆិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី ឯកា គាមន្តរំ គច្ឆតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី ឯកា គាមន្តរំ គច្ឆិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី ឯកា គាមន្តរំ គច្ឆេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារ-ណីយំ សង្ឃាទិសេសន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុ-នីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៥១) តេន ខោ បន សមយេន ទ្វេ ភិក្ខុនិយោ សាកេតា សាវត្ថឹ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ អន្តរា-មគ្គេ នទី តរិតព្វា ហោតិ ។ អថខោ តា ភិក្ខុនិយោ នាវិកេ ឧបសង្កមិត្វា ឯតទវោចុំ សាធុ នោ អាវុសោ អម្ហេ តារេហីតិ ។ នាយ្យេ សក្កា ឧភោ សកឹ តារេតុន្តិ ។



កាន់ចន្លោះស្រុកតែម្នាក់ឯងដូច្នេះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទៅកាន់ចន្លោះស្រុកតែម្នាក់ឯង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនគួរបើនឹងទៅកាន់ចន្លោះស្រុកតែម្នាក់ឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯង ភិក្ខុនីនេះក្ដី ក៏ត្រូវអាបត្តិសង្ឃាទិសេសឈ្មោះបឋមាបត្តិក គួរបណ្ដេញចេញចាកសង្ឃ ។ ឯសិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ ។

(៥១) សម័យនោះឯង ភិក្ខុនីទាំងឡាយពីររូបដើរពីក្រុងសា-កេតហើយដើរផ្លូវឆ្ងាយទៅកាន់ក្រុងសាវត្ថី ។ ក្នុងចន្លោះផ្លូវមានស្ទឹងដែលភិក្ខុនីទាំងឡាយនោះត្រូវឆ្លង ។ ទើបភិក្ខុនីទាំងឡាយនោះចូលទៅរកពួកអ្នកទូកហើយបាននិយាយពាក្យនេះថា នែអ្នកដ៏មានអាយុ សូមឲ្យអ្នកទាំងឡាយអាណិតចំលងនាងយើង (ផង) ។ ពួកអ្នកទូកនិយាយថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនអាចចំលងលោកម្ចាស់ទាំងពីររូបតែម្ដងបានទេ ។

## តតិយសង្ឃាទិសេសោ បឋមានុប្បញ្ញត្តិ

ឯកកោ ឯកំ ឧត្តារេសិ ។ ឧត្តិណ្ណា ឧត្តិណ្ណំ ទូសេសិ ។ អនុត្តិណ្ណា អនុត្តិណ្ណំ ទូសេសិ ។ តា បច្ឆា សមាគន្ត្វា បុច្ឆិសុ កច្ចិសិ អយ្យេ អប្បធំសិតាតិ ។ បធំសិតម្ហិ អយ្យេ ត្វំ បន អយ្យេ អប្បធំសិតាតិ ។ បធំសិតម្ហិ អយ្យេតិ ។ អថខោ តា ភិក្ខុនិយោ សាវត្ថឹ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី ឯកា នទីបារំ គច្ឆិស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី ឯកា នទីបារំ គច្ឆតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី ឯកា នទីបារំ គច្ឆិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា



## សង្ឃាទិសេសទី ៣ អនុប្បញ្ញត្តិទី ១

អ្នកទូកម្នាក់ចម្លងនូវភិក្ខុនី ១ រូប ។ អ្នកទូកដែលឆ្លងរួចទៅហើយក៏ប្រទូស្ត (សេពសន្ថវ) នឹងភិក្ខុនីដែលឆ្លងរួចទៅហើយ ។ អ្នកទូកដែលមិនទាន់ឆ្លង ក៏ប្រទូស្តនឹងភិក្ខុនីដែលមិនទាន់ឆ្លង ។ ភិក្ខុនីទាំងពីរនោះមកប្រជុំគ្នាក្នុងវេលាក្រោយហើយសួរគ្នាថា នែលោកម្ចាស់ អ្នកទូកមិនបៀតបៀនលោកទេឬ ។ ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ ខ្ញុំអ្នកទូកបៀតបៀនហើយ ចុះចំណែកខាងលោកម្ចាស់ អ្នកទូកមិនបៀតបៀនលោកទេឬ ។ ភិក្ខុនីនោះក៏និយាយថា លោកម្ចាស់ ខ្ញុំអ្នកទូកបៀតបៀនហើយដែរ ។ លំដាប់នោះភិក្ខុនីទាំងឡាយនោះទៅកាន់ក្រុងសាវត្ថី ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងសោះ ។ ទើបភិក្ខុនីទាំងឡាយនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនគួរបើនឹងទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ

បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ ។ យា បន ភិក្ខុនី ឯកា វា គាមន្តរំ គច្ឆេយ្យ ឯកា វា នទីបារំ គច្ឆេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៥២) តេន ខោ បន សមយេន សម្ពហុលា ភិក្ខុនិយោ កោសលេសុ ជនបទេសុ សាវត្ថិំ គច្ឆន្តា[១] សាយំ អញ្ញតរំ គាមំ ឧបគច្ឆិំសុ[២] ។ តត្ថ អញ្ញតរា ភិក្ខុនី អភិរូបា ហោតិ ទស្សនីយា បាសាទិកា ។ អញ្ញតរោ បុរិសោ តស្សា ភិក្ខុនិយា សហ ទស្សនេន បដិពទ្ធចិត្តោ ហោតិ ។ អថខោ សោ បុរិសោ តាសំ ភិក្ខុនីនំ សេយ្យំ បញ្ញាបេន្តោ តស្សា ភិក្ខុនិយា សេយ្យំ ឯកមន្តំ បញ្ញាបេសិ ។ អថខោ សា ភិក្ខុនី សល្លក្ខេត្វា បរិយុដ្ឋិតោ អយំ បុរិសោ សចេ រត្តឹ អាគច្ឆិស្សតិ វិប្បការោ មេ ភវិស្សតីតិ ភិក្ខុនិយោ អនាបុច្ឆា អញ្ញតរំ កុលំ គន្ត្វា

១ ម. ឱ. គន្ត្វា ។ ២ [illegible] ។



មិនមែនជាទៅដើម្បីជ្រះថ្លារបស់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ លុះភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងក្តី ភិក្ខុនីនេះឯង ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះបឋមាបត្តិក គួរឲ្យបណ្តេញចេញចាកសង្ឃ ។ ព្រះដ៏មានព្រះភាគបាន ទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុនីទាំងឡាយយ៉ាងនេះឯង ។

(៥៥) សម័យនោះឯង ភិក្ខុនីទាំងឡាយច្រើនរូបទៅកាន់ក្រុងសាវត្ថីក្នុងជនបទកោសល ទើបចូលទៅកាន់ស្រុក ១ ក្នុងវេលាល្ងាច ។ បណ្តាភិក្ខុនីទាំងឡាយនោះ ភិក្ខុនី ១ មានរូបល្អ គួរពិតពិលរមិលមើល នាំមកនូវសេចក្តីជ្រះថ្លា ។ បុរសម្នាក់មានចិត្តប្រតិព័ទ្ធនឹងការឃើញភិក្ខុនីនោះ ។ ឯបុរសនោះបានក្រាលទីសិងដល់ភិក្ខុនីទាំងឡាយនោះ ក៏ក្រាលទីសិងដើម្បីភិក្ខុនីនោះក្នុងទីម្ខាងដោយឡែក ។ ទើបឯភិក្ខុនីនោះកំណត់យល់ឃើញហើយក៏គិតថា បុរសនេះមានកន្ត្រៃបសន្ធោសហើយ បើគាត់ចូលមកក្នុងវេលាយប់ អញមុខជានឹងមានសេចក្តីវិប្បការមិនប្រក្រតី ហើយក៏មិនលាភិក្ខុនីទាំងឡាយ ស្រាប់តែទៅកាន់ត្រកូលមួយហើយក៏សម្រេច

សេយ្យំ កប្បេសិ ។ អថខោ សោ បុរិសោ រត្តឹ អា-
គន្ត្វា តំ ភិក្ខុនឹ គវេសន្តោ ភិក្ខុនិយោ ឃដ្ដេសិ ។
ភិក្ខុនិយោ តំ ភិក្ខុនឹ អបស្សន្តិយោ ឯវមាហំសុ និស្សំ-
សយំ ខោ សា ភិក្ខុនី បុរិសេន សទ្ធឹ និក្ខន្តាតិ ។
អថខោ សា ភិក្ខុនី តស្សា រត្តិយា អច្ចយេន យេន តា
ភិក្ខុនិយោ តេនុបសង្កមិ ។ ភិក្ខុនិយោ តំ ភិក្ខុនឹ ឯត-
ទវោចុំ កិស្ស ត្វំ អយ្យេ បុរិសេន សទ្ធឹ និក្ខន្តាតិ ។
នាហំ អយ្យេ បុរិសេន សទ្ធឹ និក្ខន្តាតិ ភិក្ខុនីនំ
ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា
។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ
នាម ភិក្ខុនី ឯកា រត្តឹ វិប្បវសិស្សតីតិ ។បេ។ សច្ចំ
កិរ ភិក្ខវេ ភិក្ខុនី ឯកា រត្តឹ វិប្បវសតីតិ ។ សច្ចំ
ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ
ភិក្ខុនី ឯកា រត្តឹ វិប្បវសិស្សតិ នេតំ ភិក្ខវេ អប្ប-
សន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ





និយាយបបួល ។ លំដាប់នោះ បុរសនោះមកក្នុងវេលារាត្រីស្វែងរកភិក្ខុនី
នោះក៏បៀតបៀនភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយកាលបើមិនឃើញ
ភិក្ខុនីនោះបាននិយាយយ៉ាងនេះថា ភិក្ខុនីនោះចេញទៅជាមួយនឹងប្រុស
ជាប្រាកដហើយ ។ ឯភិក្ខុនីនោះលុះកន្លងរាត្រីនោះទៅបានចូលទៅរក
ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងភិក្ខុនីនោះ
ថា នែលោកម្ចាស់ ហេតុអ្វី បានជាលោកចេញទៅជាមួយនឹងប្រុស ។
ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ ខ្ញុំមិនបានចេញទៅជាមួយនឹងប្រុស
ទេ ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយ
ឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស
តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងនៅប្រាសចាកគ្នាក្នុងវេលា
រាត្រីតែម្នាក់ឯងសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ
ឮថាភិក្ខុនីនៅប្រាសចាក (គ្នា) ក្នុងវេលារាត្រីតែម្នាក់ឯង ពិតមែនឬ ។
ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។
ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនគួរបើ
នឹងនៅប្រាសចាក (គ្នា) ក្នុងវេលារាត្រីតែម្នាក់ឯងទេ ម្នាលភិក្ខុទាំងឡាយ
អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬ
នាំឲ្យរឹតតែជ្រះថ្លាឡើងដល់ជនទាំងឡាយ ដែលជ្រះថ្លាស្រាប់ហើយទេ

។ ២ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ឯកា វា គាមន្តរំ គច្ឆេយ្យ ឯកា វា នទីបារំ គច្ឆេយ្យ ឯកា វា រត្តឹ វិប្បវសេយ្យ ឯកា វា គណម្ហា ឱហីយេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សា-រណីយំ សង្ឃាទិសេសន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៤៣) តេន ខោ បន សមយេន សម្ពហុលា ភិក្ខុនិយោ កោសលេសុ ជនបទេសុ សាវត្ថឹ អទ្ធាន-មគ្គប្បដិបន្នា ហោន្តិ ។ តត្ថ អញ្ញតរា ភិក្ខុនី វច្ចេន បីឡិតា ឯកិកា ឱហីយិត្វា បច្ឆា អគមាសិ ។ មនុស្សា តំ ភិក្ខុនឹ បស្សិត្វា ទូសេសុំ ។ អថ ខោ សា ភិក្ខុនី យេន តា ភិក្ខុនិយោ តេនុបសង្កមិ ។ ភិក្ខុនិយោ តំ ភិក្ខុនឹ ឯតទវោចុំ កិស្ស ត្វំ អយ្យេ ឯកិកា ឱហីនា កច្ចិសិ អប្បទុសិតាតិ ។ ទូសិ-តម្ហិ អយ្យេតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី





។ ២ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងក្តី ប្រាសចាកគ្នាក្នុងវេលាយប់តែម្នាក់ឯងក្តី ភិក្ខុនីនេះឯង ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុនីទាំងឡាយហើយយ៉ាងនេះ ។

(៤៣) សម័យនោះឯង ភិក្ខុនីទាំងឡាយច្រើនរូបដើរផ្លូវឆ្ងាយ ទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទ ។ បណ្តាភិក្ខុនីទាំងឡាយនោះ ភិក្ខុនីមួយរូបមានឧច្ចារៈបៀតបៀន (ឈឺដោះទុក្ខសត្វ) បង្អង់នៅតែម្នាក់ឯង ហើយដើរទៅក្នុងកាលជាខាងក្រោយ ។ មនុស្សទាំងឡាយឃើញភិក្ខុនីនោះហើយប្រទូស្ត ។ ទើបភិក្ខុនីនោះចូលទៅរកភិក្ខុនីទាំងឡាយនោះ ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា នែលោកម្ចាស់ ហេតុអ្វីក៏លោកបង្អង់ឈប់នៅតែម្នាក់ឯង ហើយលោកមិនមានអ្នកណាបៀតបៀនទេឬ ។ ភិក្ខុនីនោះប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវគេបៀតបៀនទៅហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងឈប់បង្អង់ឲ្យយឺតយូរ

ឯកា គណម្ហា ឱហីយិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី ឯកា គណម្ហា ឱហីយតីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី ឯកា គណម្ហា ឱហីយិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ឯកា វា គាមន្តរំ គច្ឆេយ្យ ឯកា វា នទីបារំ គច្ឆេយ្យ ឯកា វា រត្តឹ វិប្បវសេយ្យ ឯកា វា គណម្ហា ឱហីយេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។

[៤៤] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឯកា វា គាមន្តរំ គច្ឆេយ្យាតិ បរិក្ខិត្តស្ស គាមស្ស បរិក្ខេបំ បឋមំ បាទំ អតិក្កាមេន្តិយា អាបត្តិ ថុល្លច្ចយស្ស ទុតិយំ បាទំ អតិក្កាមេន្តិយា អាបត្តិ សង្ឃាទិសេសស្ស ។ អបរិក្ខិត្តស្ស គាមស្ស ឧបចារំ បឋមំ បាទំ អតិក្កាមេន្តិយា អាបត្តិ ថុល្លច្ចយស្ស ទុតិយំ បាទំ

១ ម. ឱហីយីតិ ។



ជាអ្នកតែម្នាក់ឯងសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីបង្អង់ខ្លួនឲ្យយឺតយូរជាអ្នកតែម្នាក់ឯង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនគួរបង្អង់ខ្លួនឲ្យយឺតយូរជាអ្នកតែម្នាក់ឯងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី ទៅកាន់ត្រើយស្ទឹងខាងនាយម្នាក់ឯងក្តី នៅប្រាសចាកគ្នាក្នុងវេលាយប់តែម្នាក់ឯងក្តី ឃ្លាតឲ្យឆ្ងាយអំពីពួកតែម្នាក់ឯងក្តី ភិក្ខុនីនេះឯង ក៏ត្រូវអាបត្តិឈ្មោះសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញ ។

[៤៤] ពាក្យថា ភិក្ខុនីណាមួយ គឺអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី គឺភិក្ខុនីឈានជំហានជាបឋមកន្លងទៅកាន់របងនៃស្រុកដែលមានរបង ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានទី ២ ទៅ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុនីឈានជំហានជាបឋមកន្លងទៅកាន់ឧបចារស្រុកដែលមិនមានរបង ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានទី ២ ត្រូវអាបត្តិ

អតិក្កាមេន្តិយា អាបត្តិ សង្ឃាទិសេសស្ស ។ ឯកា វា នទីបារំ គច្ឆេយ្យាតិ នទី នាម តិមណ្ឌលំ បដិច្ឆាទេត្វា យត្ថ កត្ថចិ ឧត្តរន្តិយា ភិក្ខុនិយា អន្តរវាសកោ តេមិយតិ ។ បឋមំ បាទំ ឧត្តារេន្តិយា[១] អាបត្តិ ថុល្លច្ចយស្ស ទុតិយំ បាទំ ឧត្តារេន្តិយា[២] អាបត្តិ សង្ឃាទិសេសស្ស ។ ឯកា វា រត្តឹ វិប្បវសេយ្យាតិ សហ អរុណុគ្គមនា ទុតិយិកាយ ភិក្ខុនិយា ហត្ថបាសំ វិជហន្តិយា អាបត្តិ ថុល្លច្ចយស្ស វិជហិតេ អាបត្តិ សង្ឃាទិសេសស្ស ។ ឯកា វា គណម្ហា ឱហីយេយ្យាតិ អគាមកេ អរញ្ញេ ទុតិយិកាយ ភិក្ខុនិយា ទស្សនូបចារំ វា សវនូបចារំ វា វិជហន្តិយា អាបត្តិ ថុល្លច្ចយស្ស វិជហិតេ អាបត្តិ សង្ឃាទិសេសស្ស ។

(៤៨) អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ បឋមាបត្តិកាតិ សហ វត្ថុជ្ឈាចារា អាបជ្ជតិ អសមនុភាសនាយ ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារីយតិ ។ សង្ឃាទិសេសោ ។បេ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

១-២ ឱ. ម. ឧត្តរន្តិយាតិ ។



សង្ឃាទិសេស ។ ពាក្យថា ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯង គឺភិក្ខុនីបិទបាំងមណ្ឌលទាំង៣ហើយឆ្លងទៅក្នុងទីណាមួយ ស្បង់នៃភិក្ខុនីនោះក៏ទទឹកជោក ទីនោះហៅថាស្ទឹង ។ ភិក្ខុនីឆ្លងផុតជំហានដំបូង ត្រូវអាបត្តិថុល្លច្ច័យ ឆ្លងផុតជំហានទី ២ ត្រូវអាបត្តិសង្ឃាទិសេស ។ ពាក្យថា នៅប្រាសចាកគ្នាក្នុងវេលារាត្រីតែម្នាក់ឯង គឺភិក្ខុនីកំពុងលះហត្ថបាសនៃភិក្ខុនីទី ២ ត្រូវអាបត្តិថុល្លច្ច័យព្រមគ្នានឹងអរុណរះឡើង លុះលះហត្ថបាសស្រឡះហើយ ត្រូវអាបត្តិសង្ឃាទិសេស ។ ពាក្យថា ឈប់ឡើយហ្វូងអំពីពួកតែម្នាក់ឯង គឺភិក្ខុនីកំពុងលះទស្សនូបចារ ( កន្លែងដែលមើលគ្នាឃើញ ) ក្តី សវនូបចារ ( កន្លែងដែលស្តាប់ឮ ) ក្តី របស់ភិក្ខុនីទី ២ ក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិថុល្លច្ច័យ លុះលះបង់ដាច់ស្រឡះហើយ ត្រូវសង្ឃាទិសេស ។

(៤៨) ពាក្យថា ភិក្ខុនីនេះឯង គឺជាការពោលប្រៀបធៀបនឹងភិក្ខុនីដែលត្រូវអាបត្តិមុនៗ ។ ពាក្យថា បឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិព្រមគ្នានឹងពេលដែលប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនវិធីទេ ។ ពាក្យថា គួរបណ្តេញចេញ គឺភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយបណ្តេញចេញចាកសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយក្នុងសង្ឃាទិសេសទី ១ រួចហើយ ។

[៦៦] អនាបត្តិ ទុតិយិកា ភិក្ខុនី បក្កន្តា វា ហោតិ វិព្ភន្តា វា កាលង្កតា វា បក្ខសង្កន្តា វា អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## ចតុត្ថសង្ឃាទិសេសំ

[៦៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ចណ្ឌកាលី ភិក្ខុនី ភណ្ឌនការិកា ហោតិ កលហការិកា វិវាទការិកា ភស្សការិកា សង្ឃេ អធិករណការិកា ។ ថុល្លនន្ទា ភិក្ខុនី តស្សា កម្មេ ករិយមានេ បដិក្កោសតិ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី គាមកំ អគមាសិ កេនចិទេវ ករណីយេន ។ អថខោ ភិក្ខុនីសង្ឃោ ថុល្លនន្ទា ភិក្ខុនី បក្កន្តាតិ ចណ្ឌកាលឹ ភិក្ខុនឹ អាបត្តិយា អទស្សនេ(១) ឧក្ខិបិ ។ ថុល្លនន្ទា ភិក្ខុនី គាមកេ តំ ករណីយំ

១ ឱ. ម. អទស្សនេន ។



[៦៦] ភ. ដែលមិនត្រូវអាបត្តិ ( គឺសិក្ខាបទនេះមាន ៤ យ៉ាង ) គឺភិក្ខុនីទី ២ ចៀសចេញទៅក្ដី សឹកទៅក្ដី ស្លាប់ទៅក្ដី ចូលទៅកាន់ពួកតិរ្ថិយក្ដី១ ភិក្ខុនីមានសេចក្ដីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

---

## សង្ឃាទិសេសទី ៤

[៦៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់ អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ចណ្ឌកាលីភិក្ខុនី ជាអ្នកធ្វើសេចក្ដីបង្កហេតុឈ្លោះប្រកែកគ្នា ធ្វើនូវតែពាក្យកាច ជាអ្នកបង្កើតអធិករណ៍ក្នុងសង្ឃ ។ ថុល្លនន្ទាភិក្ខុនីក៏រកនូវកម្មហាក់ឡើយ ដែលចណ្ឌកាលីភិក្ខុនីនោះធ្វើ ។ ចំណែកសម័យនោះឯង ថុល្លនន្ទាភិក្ខុនី បានទៅកាន់ស្រុកតូច ដោយកិច្ចអ្វីមួយ ។ លំដាប់នោះ ភិក្ខុនីសង្ឃ ដឹងថា ថុល្លនន្ទាភិក្ខុនីចៀសចេញទៅហើយ ។ ក៏លើកវត្តចំពោះចណ្ឌកាលីភិក្ខុនី ព្រោះសេចក្ដីមិនឃើញអាបត្តិ ។ ថុល្លនន្ទាភិក្ខុនីក៏សម្រេចការណាកិច្ចដែល

ចរិត្វា បុនទេវ សាវត្ថឹ បច្ចាគច្ឆិ ។ ចណ្ឌកាលី ភិក្ខុនី ថុល្លនន្ទាយ ភិក្ខុនិយា អាគច្ឆន្តិយា នេវ អាសនំ បញ្ញបេសិ ន បាទោទកំ ន បាទបីឋំ ន បាទកឋលិកំ ឧបនិក្ខិបិ ន បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសិ ន បានីយេន អាបុច្ឆិ ។ ថុល្លនន្ទា ភិក្ខុនី ចណ្ឌកាលឹ ភិក្ខុនឹ ឯតទវោច កិស្ស ត្វំ អយ្យេ មយិ អាគច្ឆន្តិយា នេវ អាសនំ បញ្ញបេសិ ន បាទោទកំ ន បាទបីឋំ ន បាទកឋលិកំ ឧបនិក្ខិបិ ន បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសិ ន បានីយេន អាបុច្ឆិ ។ ឯវញ្ហេតំ អយ្យេ ហោតិ យថាតំ អនាថាយាតិ ។ កិស្ស បន ត្វំ អយ្យេ អនាថាតិ ។ ឥមា មំ អយ្យេ ភិក្ខុនិយោ អយំ អនាថា អប្បញ្ញាតា នត្ថិ ឥមិស្សា កាចិ បដិវត្តាតិ អាបត្តិយា អទស្សនេ ឧក្ខិបឹសូតិ ។ ថុល្លនន្ទា ភិក្ខុនី ពាលា ឯតា អព្យត្តា ឯតា នេតា ជានន្តិ កម្មំ វា កម្មទោសំ វា កម្មវិបត្តឹ វា កម្មសម្បត្តឹ វា មយំ ខោ ជានាម កម្មម្បិ កម្មទោសម្បិ កម្មវិបត្តិម្បិ កម្មសម្បត្តិម្បិ មយំ ខោ អកតំ វា កម្មំ ការេយ្យាម





រួចត្រាច់ទៅក្នុងស្រុកនោះហើយក៏ត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ។ ចណ្ឌកាលីភិក្ខុនីកាលបើថុល្លនន្ទាភិក្ខុនីមកដល់ ក៏មិនក្រាលអាសនៈឲ្យ មិនចូលទៅដម្កល់ទឹកលាងជើង តាំងជើង ទីរណេសក្រាប់ជើងឡើយ មិនក្រោកទទួលយកបាត្រចីវរ មិនអើពើដោយទឹកផឹក ។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងចណ្ឌកាលីភិក្ខុនីថា នែលោកម្ចាស់ កាលបើយើងមកដល់ ហេតុអ្វីក៏លោកមិនក្រាលអាសនៈឲ្យ មិនចូលមកដម្កល់ទឹកលាងជើង តាំងជើង ទីរណេសក្រាប់ជើងឲ្យ មិនក្រោកទទួលយកបាត្រចីវរ មិនអើពើដោយទឹកផឹក ។ ចណ្ឌកាលីភិក្ខុនីនិយាយថា បពិត្រលោកម្ចាស់ ការនេះបានជាយ៉ាងហ្នឹង ព្រោះខ្ញុំជាមនុស្សអនាថា ។ ថុល្លនន្ទាភិក្ខុនីសួរថា នែលោកម្ចាស់ ហេតុអ្វីក៏លោកជាមនុស្សអនាថា ។ ចណ្ឌកាលីភិក្ខុនីនិយាយថា នែលោកម្ចាស់ ភិក្ខុនីទាំងឡាយនេះពោលថា ភិក្ខុនីនេះជាមនុស្សអនាថាមិនមានអ្នកណាស្គាល់ គ្មានភិក្ខុនីណាមួយជាអ្នកប្រតិបត្តិភិក្ខុនីនេះទេ ដូច្នេះហើយក៏លើកវត្តចំពោះខ្ញុំ ព្រោះសេចក្ដីមិនឃើញអាបត្តិ ។ ថុល្លនន្ទាភិក្ខុនីនិយាយថា ភិក្ខុនីទាំងឡាយនេះល្ងង់ ភិក្ខុនីអស់នេះមិនឈ្លាស ភិក្ខុនីទាំងឡាយនេះមិនស្គាល់កម្ម ទោសរបស់កម្ម កម្មវិបត្តិ កម្មសម្បត្តិ ឯយើងទើបដឹងកម្មផង ទោសរបស់កម្មផង កម្មវិបត្តិផង កម្មសម្បត្តិផង យើងហ្នឹងឯងត្រូវធ្វើកម្មដែលសង្ឃមិនបានធ្វើផង ត្រូវកាត់កម្មដែលសង្ឃ

## ចតុត្ថសង្ឃាទិសេសេ បញ្ញត្តិ

កតំ វា កម្មំ កោបេយ្យាមាតិ លហុំ លហុំ ភិក្ខុនិសង្ឃំ សន្និបាតេត្វា ចណ្ឌកាឡិំ ភិក្ខុនិំ ឱសារេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនិំ ធម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនិំ ធម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេសីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនិំ ធម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី

១ ម. ឱសារេសីតិ ។



## សង្ឃាទិសេសទី ៤ សេចក្តីបញ្ញត្តិ

ធ្វើហើយឲ្យកម្រើកវិញ ដូច្នេះហើយប្រជុំភិក្ខុនីសង្ឃភ្លាម ៗ ហើយសូត្រ (ដកកម្ម) បញ្ចូលចណ្ឌកាលីភិក្ខុនីមកវិញ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទាមិនសមបើនឹងមិនប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ ហើយសូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅព្រះសាស្តាទេ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីមិនបានប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ សូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅព្រះសាស្តា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងមិនប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ ហើយសូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅព្រះសាស្តាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនឹ ធម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។

(៤៨) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សមគ្គោ នាម សង្ឃោ សមានសំវាសកោ សមានសីមាយំ ឋិតោ ។ ឧក្ខិត្តា នាម អាបត្តិយា អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ឧក្ខិត្តា ។ ធម្មេន វិនយេនាតិ យេន ធម្មេន យេន វិនយេន ។ សត្ថុសាសនេនាតិ ជិនសាសនេន ពុទ្ធសាសនេន ។ អនបលោកេត្វា ការកសង្ឃន្តិ កម្មការកសង្ឃំ អនាបុច្ឆា ។ អនញ្ញាយ គណស្ស ឆន្ទន្តិ គណស្ស ឆន្ទំ អជានិត្វា ។ ឱសារេស្សាមីតិ គណំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។



ភិក្ខុនីណាមួយមិនបានប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់គណៈ ហើយស្រុះស្រួលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ភិក្ខុនីនេះក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

(៤៨) ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ សង្ឃដែលមានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាស្មើគ្នា ឈ្មោះថា ព្រមព្រៀងគ្នា ។ ភិក្ខុនីដែលឈ្មោះថា សង្ឃលើកវត្ត គឺភិក្ខុនីដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ មិនសំដែងអាបត្តិ មិនលះបង់ (ទិដ្ឋិអាក្រក់) ក្តី ។ ពាក្យថា តាមធម៌ តាមវិន័យ គឺតាមធម៌យ៉ាងណា តាមវិន័យយ៉ាងណា ។ ពាក្យថា តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា គឺតាមពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គឺតាមពុទ្ធសាសនា ។ ពាក្យថា មិនប្រាប់ការកសង្ឃ គឺមិនប្រាប់សង្ឃជាអ្នកធ្វើកម្ម ។ ពាក្យថា មិនដឹងសេចក្តីប្រាថ្នារបស់គណៈ គឺមិនដឹងសេចក្តីពេញចិត្តរបស់ពួក ។ ភិក្ខុនីគិតថា អញនឹងស្រុះស្រួលពួក ហើយស្វែងរកពួកក្តី សម្មតិសីមាក្តី ត្រូវអាបត្តិទុក្កដ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំង ២ ក្នុងខណៈចប់កម្មវាចាពីរលើក ត្រូវអាបត្តិសង្ឃាទិសេសក្នុងខណៈសូត្រចប់កម្មវាចាស្រេច ។

[៤៩] អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ បឋមាបត្តិកន្តិ សហ វត្ថុជ្ឈាចារា អាបជ្ជតិ អសមនុភាសនាយ ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារីយតិ ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

[៥០] ធម្មកម្មេ ធម្មកម្មសញ្ញា ឱសារេតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកា ឱសារេតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា ឱសារេតិ អាបត្តិ សង្ឃាទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។





[៤៩] ពាក្យថា ភិក្ខុនីនេះក្តី គឺជាពាក្យពោលប្រៀបធៀបនឹងភិក្ខុនី ដែលប្រព្រឹត្តលើសមុនៗ ។ ពាក្យថា បឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនទៅទេ ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះ ត្រូវភិក្ខុនីឯទៀតបណ្តេញចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃសត្តរសកណ្ឌរួចហើយ ។

[៥០] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយសូត្របញ្ចូលពួក ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយសូត្របញ្ចូលពួក ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយសូត្របញ្ចូលពួក ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៥៣) អនាបត្តិ កម្មការកសង្ឃំ អបលោកេត្វា ឱសារេតិ គណស្ស ឆន្ទំ ជានិត្វា ឱសារេតិ វត្តេ វត្តន្តិំ ឱសារេតិ អសន្តេ កម្មការកេ ឱសារេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## បញ្ចមសង្ឃាទិសេសំ

(៥៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សុន្ទរីនន្ទា ភិក្ខុនី អភិរូបា ហោតិ ទស្សនីយា បាសាទិកា ។ មនុស្សា ភត្តគ្គេ សុន្ទរីនន្ទំ ភិក្ខុនឹ បស្សិត្វា អវស្សុតា អវស្សុតាយ សុន្ទរីនន្ទាយ ភិក្ខុនិយា អគ្គគ្គានិ ភោជនានិ ទេន្តិ ។ សុន្ទរីនន្ទា ភិក្ខុនី យាវទត្ថំ ភុញ្ជតិ ។ អញ្ញា ភិក្ខុនិយោ ន ចិត្តរូបំ លភន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា សុន្ទរីនន្ទា អវស្សុតា អវស្សុតស្ស





(៥៣) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុនីប្រាប់សង្ឃជាអ្នកធ្វើសង្ឃកម្ម ហើយទើបសូត្របញ្ចូលពួក ១ ភិក្ខុនីដឹងសេចក្ដីប្រាថ្នារបស់គណៈ ហើយទើបសូត្របញ្ចូលពួក ១ ភិក្ខុនីសូត្របញ្ចូលភិក្ខុនីដែលប្រព្រឹត្តតាមវត្ត កាលបើគ្មានសង្ឃជាអ្នកធ្វើសង្ឃកម្មទើបភិក្ខុនីសូត្របញ្ចូលពួក ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីធ្វើមុនបញ្ញត្តិ ១ ។

---

## សង្ឃាទិសេសទី ៥

(៥៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនី មានរូបល្អ គួរពិតពិលរមិលរមើល នាំមកនូវសេចក្ដីជ្រះថ្លា ។ មនុស្សទាំងឡាយឃើញសុន្ទរីនន្ទាភិក្ខុនីក្នុងរោងភត្តហើយ មានសេចក្ដីតម្រេកត្រេ-ក ឲ្យភោជនទាំងឡាយសុទ្ធតែប្រសើរដល់សុន្ទរីនន្ទាភិក្ខុនី ដែលមានតម្រេកដែរ ។ សុន្ទរីនន្ទាភិក្ខុនីឆាន់ (ភោជន) តាមតែឆ្អែត ។ ភិក្ខុនីទាំងឡាយដទៃមិនបានអាហារដ៏សមគួរដល់ចិត្តឡើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្ដុះបង្អាប់ថា នាងសុន្ទរីនន្ទាភិក្ខុនីមិនសមបើនឹងមាន

## បញ្ចមសង្ឃាទិសេស បញ្ញត្តិ

បុរិសបុគ្គលស្ស ហត្ថតោ ខាទនីយំ ភោជនីយំ សហត្ថា បដិគ្គហេត្វា ខាទិស្សតិ ភុញ្ជិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ សុន្ទរីនន្ទា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថតោ ខាទនីយំ ភោជនីយំ សហត្ថា បដិគ្គហេត្វា ខាទតិ ភុញ្ជតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម ភិក្ខវេ សុន្ទរីនន្ទា ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថតោ ខាទនីយំ ភោជនីយំ សហត្ថា បដិគ្គហេត្វា ខាទិស្សតិ ភុញ្ជិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។



## សង្ឃាទិសេសទី ៥ សេចក្តីបញ្ញត្តិ

កម្រេកទទួលខាទនីយភោជនីយាហារអំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃខ្លួនហើយទំពាស៊ីឬឆាន់ហោង ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា សុន្ទរីនន្ទាភិក្ខុនីមានតម្រេកទទួលខាទនីយភោជនីយាហារអំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃរបស់ខ្លួន ហើយទំពាស៊ីឬបរិភោគ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ សុន្ទរីនន្ទាភិក្ខុនី មិនគួរបើនឹងមានតម្រេកហើយទទួលខាទនីយភោជនីយាហារអំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃរបស់ខ្លួនហើយទំពាស៊ីឬឆាន់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែនជានាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមានតម្រេកទទួលយកខាទនីយក្តី ភោជនីយក្តី អំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃខ្លួនហើយទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

(៤៣) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អវស្សុតា នាម សារត្តា អបេក្ខវតី បដិពទ្ធចិត្តា ។ អវស្សុតោ នាម សារត្តោ អបេក្ខវា បដិពទ្ធចិត្តោ ។ បុរិសបុគ្គលោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ វិញ្ញូ បដិពលោ សារជ្ជិតុំ ។ ខាទនីយំ នាម បញ្ច ភោជនានិ ឧទកទន្តបោណំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ថុល្លច្ចយស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ សង្ឃាទិសេសស្ស ។

(៤៤) អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ បឋមាបត្តិកាតិ សហ វត្ថុជ្ឈាចារា អាបជ្ជតិ អសមនុភាសនាយ ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារីយតិ ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។ ឧទកទន្តបោណំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។





(៤៣) ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ ។ ភិក្ខុនីដែលឈ្មោះថា មានតម្រេក គឺភិក្ខុនីដែលត្រេកអរ ការត្រេកអាល័យ មានចិត្តប្រតិព័ទ្ធ ។ បុរសដែលឈ្មោះថា មានតម្រេក គឺបុរសដែលត្រេកត្រអាលសំឡឹងរកយកតែ មានចិត្តប្រតិព័ទ្ធ ។ ដែលហៅថា បុរសបុគ្គល សំដៅយកមនុស្សប្រុសដែលដឹងក្ដីអាចត្រេកអរបាន មិនមែនយក្សប្រុស ប្រេតប្រុស តិរច្ឆានឈ្មោលទេ ។ ដែលហៅថា ខាទនីយ គឺលើកលែងតែភោជន ៥ យ៉ាងចេញ នឹងទឹក នឹងឈើស្ទន់ ក្រៅពីនោះឈ្មោះថា ខាទនីយទាំងអស់ ។ ភោជន ៥ យ៉ាង គឺបាយ ១ នំស្រស់ ១ នំគ្រៀម ១ ត្រី ១ សាច់ ១ ឈ្មោះថា ភោជនីយ ។ ភិក្ខុនីគិតថា អញនឹងទំពាស៊ីឬនឹងបរិភោគហើយទទួលយក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុនីនោះត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗពំនូតដែលលេបចូលទៅ ។

(៤៤) ពាក្យថា ភិក្ខុនីនេះក្ដី សំដៅការពោលប្រៀបធៀបនឹងភិក្ខុនីទាំងឡាយមុនៗ ។ ពាក្យថា បឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនាទេ ។ ពាក្យថា គួរបណ្ដេញចេញចាកសង្ឃ គឺភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយបណ្ដេញចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ ។ ភិក្ខុនីទទួលទឹកនឹងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។

បញ្ចមសង្ឃាទិសេសេ អនាបត្តិវារោ

(៥៥) ឯកតោ អវស្សុតេ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ថុល្លច្ចយស្ស ។ ឧទកទន្តបោណំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ ឧភតោ អវស្សុតេ យក្ខស្ស វា បេតស្ស វា បណ្ឌកស្ស វា តិរច្ឆានគតមនុស្សវិគ្គហស្ស វា ហត្ថតោ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ថុល្លច្ចយស្ស ។ ឧទកទន្តបោណំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ ឯកតោ អវស្សុតេ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ ឧទកទន្តបោណំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

(៥៦) អនាបត្តិ ឧភតោ អនវស្សុតា ហោន្តិ អនវស្សុតោតិ ជានន្តី បដិគ្គណ្ហាតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



សង្ឃាទិសេសទី ៥ ករណីដែលមិនត្រូវអាបត្តិ

(៥៥) កាលបើមានតម្រេកតែម្ខាង ហើយភិក្ខុនីនឹកថា អញនឹងទំពាស៊ីឬនឹងបរិភោគ ក៏ទទួលយក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីនោះត្រូវអាបត្តិថុល្លច្ចយគ្រប់ៗ ពំនូតដែលលេបចូលទៅ ។ ភិក្ខុនីទទួលទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។ កាលបើបុគ្គលមានតម្រេកទាំងពីរខាង ហើយភិក្ខុនីនឹកថា អញនឹងទំពាស៊ីឬនឹងបរិភោគនូវរបស់ ក៏ទទួលយកអំពីដៃយក្ស ប្រុសក្តី ប្រេតក្តី បណ្ឌក (ខ្ទើយ)ក្តី តិរច្ឆានដែលមានរូបកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីនោះ ត្រូវអាបត្តិថុល្លច្ចយគ្រប់ៗ ពំនូតដែលលេបចូលទៅ ។ ភិក្ខុនីទទួលទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។ កាលបើមានតម្រេកតែម្ខាង ហើយភិក្ខុនីនឹកថា អញនឹងទំពាស៊ីឬនឹងបរិភោគនូវរបស់ ក៏ទទួលយក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដគ្រប់ៗ ពំនូតដែលលេបចូលទៅ ។ ភិក្ខុនីទទួលយកទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។

(៥៦) ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺបើទាំងពីរពួក (ភិក្ខុនីនិងប្រុស) មិនមានតម្រេកទាំងពីរខាង ១ ភិក្ខុនីដឹងថាប្រុសនោះមិនមានតម្រេក ទើបទទួលយក ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីធ្វើមុនបញ្ញត្តិ ១ ។

# ឆដ្ឋំ សង្ឃាទិសេសំ

[៥៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សុន្ទរីនន្ទា ភិក្ខុនី អភិរូបា ហោតិ ទស្សនីយា បាសាទិកា ។ មនុស្សា ភត្តគ្គេ សុន្ទរីនន្ទំ ភិក្ខុនឹ បស្សិត្វា អវស្សុតា សុន្ទរីនន្ទាយ ភិក្ខុនិយា អគ្គមគ្គានិ ភោជនានិ ទេន្តិ ។ សុន្ទរីនន្ទា ភិក្ខុនី កុក្កុច្ចាយន្តី ន បដិគ្គណ្ហាតិ ។ អនន្តរិកា ភិក្ខុនី សុន្ទរីនន្ទំ ភិក្ខុនឹ ឯតទវោច កិស្ស ត្វំ អយ្យេ ន បដិគ្គណ្ហាសីតិ ។ អវស្សុតោ អយ្យេ អយំ បុរិសោតិ[១] ។ ត្វំ បន អយ្យេ អវស្សុតាតិ ។ នាហំ អយ្យេ[២] អវស្សុតាតិ ។ កិញ្ច អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អនវស្សុតា ឥង្ឃយ្យេ យំ តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គហេត្វា ខាទ វា ភុញ្ជ វាតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ ។

---

១ ឱ. អយំ បុរិសោតិ នត្ថិ ។ ២ ឱ. [illegible] អយ្យេ នាហំ នត្ថិ ។

# សង្ឃាទិសេសទី ៦

[៥៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនីមានរូបល្អ គួរពិតពិលរមិលមើល នាំមកនូវសេចក្តីជ្រះថ្លា ។ មនុស្សទាំងឡាយបានឃើញសុន្ទរីនន្ទាភិក្ខុនីក្នុងរោងភត្តក៏មានតម្រេក ហើយឲ្យភោជនទាំងឡាយដ៏ឆ្ងាញ់ៗ ដល់សុន្ទរីនន្ទាភិក្ខុនី ដែលមានតម្រេកដែរ ។ សុន្ទរីនន្ទាភិក្ខុនីរង្កៀសក៏មិនទទួលយក ។ ភិក្ខុនីដែលអង្គុយលើអាសនៈបន្ទាប់បានពោលពាក្យនុះនឹងសុន្ទរីនន្ទាភិក្ខុនីថា នែលោកម្ចាស់ ហេតុអ្វីក៏នាងមិនទទួលយក ។ សុន្ទរីនន្ទាភិក្ខុនីនិយាយថា នែលោកម្ចាស់ បុរសនេះមានតម្រេក ។ ភិក្ខុនីទាំងឡាយនោះសួរថា នែលោកម្ចាស់ ចំណែកខាងលោកមានតម្រេកឬទេ ។ សុន្ទរីនន្ទាភិក្ខុនីនិយាយថា នែលោកម្ចាស់ ខ្ញុំមិនមានតម្រេកទេ ។ ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ បុគ្គលប្រុសនេះទុកជាមានតម្រេកក្តី មិនមានតម្រេកក្តីនឹងធ្វើអ្វីដល់នាងបាន នែលោកម្ចាស់ ព្រោះហេតុ កាលណាបើលោកមិនមានតម្រេកហើយ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណាជាខាទនីយក្តី ជាភោជនីយក្តីដល់លោក លោកចូរទទួលយកនូវវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ីឬបរិភោគចុះ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ ។

តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ-
នី ឯវំ វក្ខតិ កិំ តេ អយ្យេ ឯសោ បុរិសបុគ្គលោ
ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ
អនវស្សុតា ឥង្ឃ អយ្យេ យំ តេ ឯសោ បុរិសបុគ្គលោ ទេតិ
ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គហេ-
ត្វា ខាទ វា ភុញ្ជ វា ។បេ។ សច្ចំ កិរ ភិក្ខវេ
ភិក្ខុនី ឯវំ វទេតិ កិំ តេ អយ្យេ ឯសោ បុរិសបុគ្គលោ
ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ
អនវស្សុតា ឥង្ឃ អយ្យេ យំ តេ ឯសោ បុរិសបុគ្គលោ
ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា
បដិគ្គហេត្វា ខាទ វា ភុញ្ជ វា ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី
ឯវំ វក្ខតិ កិំ តេ អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ
អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អនវស្សុតា
ឥង្ឃ អយ្យេ យំ តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ





ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ម្តេចក៏ភិក្ខុនីមិន
សមគួរនឹងពោលយ៉ាងនេះថា នែលោកម្ចាស់ បុគ្គលប្រុសនេះទុកជាមាន
តម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយ
ចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនោះឲ្យវត្ថុ
ឯណាជាខាទនីយៈ ភោជនីយៈដល់លោក លោកចូរទទួលយកវត្ថុនោះ
ដោយដៃខ្លួន ហើយទំពាស៊ីឬឆាន់ចុះ ។បេ។ ទ្រង់ត្រាស់សួរថា
ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីពោលយ៉ាងនេះថា នែលោកម្ចាស់
បុគ្គលប្រុសនេះទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់
លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិន
មានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណាជាខាទនីយៈ ភោជនីយៈ
ដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី
ឬឆាន់ចុះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា ពិតមែន
ព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោស
ថា ម្នាលភិក្ខុទាំងឡាយ ម្តេចក៏ភិក្ខុនីមិនសមគួរនឹងពោលយ៉ាងនេះថា
នែលោកម្ចាស់ បុគ្គលប្រុសនេះទុកជាមានតម្រេកក្តី មិនមានតម្រេក
ក្តីនឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើ
លោកមិនមានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណាជាខាទនីយៈ

វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គហេត្វា ខាទ វា ភុញ្ជ វាតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ឯវំ វទេយ្យ កិន្តេ អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អនវស្សុតា ឥង្ឃ អយ្យេ យន្តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គហេត្វា ខាទ វា ភុញ្ជ វាតិ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។

[៨៨] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឯវំ វទេយ្យាតិ កិន្តេ អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អនវស្សុតា ឥង្ឃ អយ្យេ យន្តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា



ជាភោជនីយវត្ថុដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ីឬបរិភោគចុះទេ ម្នាលភិក្ខុទាំងឡាយ អំពើរបស់ភិក្ខុនីនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយពោលយ៉ាងនេះថា នែលោកម្ចាស់ បុគ្គលប្រុសនេះទុកជាមានតម្រេកក្តី មិនមានតម្រេកក្តីនឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណា ជាខាទនីយវត្ថុ ជាភោជនីយវត្ថុដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ីឬបរិភោគចុះ ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

(៨៨) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ ។ ពាក្យថា ពោលយ៉ាងនេះ គឺភិក្ខុនីនិយាយបញ្ចុះដោយពាក្យថា នែលោកម្ចាស់ បុគ្គលប្រុសនេះទុកជាមានតម្រេកក្តីមិនមានតម្រេកក្តីនឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណា ជាខាទនីយវត្ថុ ភោជនីយវត្ថុដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃ

បដិក្កមោហញ្ញា ទានំ វា កុញ្ញំ កតំ ឧទ្ទិស្ស ជេតិ អាបត្តិ ទុក្កដស្ស ។ តស្ស ខេទេ ទានំ សង្ឃាទិ កុញ្ញំ សង្ឃាទិតំ បដិក្កមនំ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ថុល្លច្ចយស្ស ។ អជ្ឈោហារបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ អយម្បិ បរិមោចនា វុត្តា ។ ឧបមាបត្តិកោ សហ វត្ថុស្សា ជាក អាបជ្ជតិ សមនុភាសនាយ ។ និស្សរណីយន្តិ សង្ឃម្ហា និស្សារិយតំ ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។ ឧបក្កមន្តោ តស្ស បដិក្កន្តំ ឧទ្ទិស្ស ជេតិ អាបត្តិ ទុក្កដស្ស ។ តស្ស ខេទេ ទានំ សង្ឃាមំ កុញ្ញំ សង្ឃាមិតំ បដិក្កន្តំ អាបត្តិ ទុក្កដស្ស ។

(៥៩) ឯកកោ អវស្សុតោ យក្ខស្ស វា បេតស្ស វា បណ្ឌកស្ស វា តិរច្ឆានគតមនុស្សវិគ្គហស្ស វា ហត្ថតោ ខាទនីយំ វា ភោជនីយំ វា ទានំ វា កុញ្ញំ កតំ ឧទ្ទិស្ស ជេតិ អាបត្តិ ទុក្កដស្ស ។ តស្ស



វុឌ ហើយទាំងសង្ឃមិនបានចុះដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទទួលយកដោយគិតថា អញនឹងធ្វើទាំងសង្ឃមិនបានកាត់តាមពាក្យភិក្ខុដែលពោលបញ្ចូននោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិថុល្លច្ច័យក្នុងកាលដែលលេបចូលទៅ ។ ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេសក្នុងពេលដែលបានចូលហើយ ។ ពាក្យថា ភិក្ខុនេះគួរ គប់គតពោលប្រើប្រដូចនឹងភិក្ខុទាំងឡាយមុន ៗ ។ ពាក្យថា ដាបប់មាបត្តិក នី ភិក្ខុនីត្រូវអាបត្តិព្រមនឹងនឹងប្រព្រឹត្តកម្មនិកា មិនមែនដោយសូត្រសមនុភាសនាទេ ។ ពាក្យថា ខ្ញុំបណ្តេញចេញចាកសង្ឃ គឺភិក្ខុនោះត្រូវភិក្ខុទាំងឡាយបណ្តេញចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយដូចសិក្ខាបទខាងដើមរួចហើយ ។ ភិក្ខុនីបញ្ចូនដោយពាក្យថា លោកចូរទទួលយកទាំងនឹងលើសទំនុកដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះទទួលដោយគិតថា អញនឹងធ្វើទាំងសង្ឃមិនបានកាត់តាមពាក្យភិក្ខុនីដែលពោលបញ្ចូននោះ ត្រូវអាបត្តិទុក្កដ ។

(៥៩) កាលបើមានតម្រេកតែម្នាក់ ភិក្ខុនីបញ្ចូនដោយពាក្យថា លោកចូរ (ទទួល) ខាទនីយក្តី ភោជនីយក្តី អំពីដៃយក្សក្តី ប្រេតក្តី បណ្ឌកក្តី តិរច្ឆានមានរូបរាងដូចមនុស្សក្តី ហើយទាំងសង្ឃមិនបានត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះទទួលដោយគិតថា អញនឹងធ្វើទាំងសង្ឃ

វចនេន ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ ភោជនបរិយោសានេ អាបត្តិ ថុល្លច្ចយស្ស ។ ឧទក-ទន្តបោណំ បដិគ្គណ្ហាតុ ឧយ្យោជេតិ អាបត្តិ ទុក្កដស្ស ។ តស្សា វចនេន ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

(៦០) អនាបត្តិ អនវស្សុតោតិ ជានន្តី ឧយ្យោជេតិ កុបិតា ន បដិគ្គណ្ហាតីតិ ឧយ្យោជេតិ កុលានុទ្ទយ-តាយ ន បដិគ្គណ្ហាតីតិ ឧយ្យោជេតិ ឧម្មត្តិកាយ អាទិ-កម្មិកាយាតិ ។

## សត្តមសង្ឃាទិសេសំ

(៦១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន



ឬនឹងបរិភោគតាមពាក្យភិក្ខុនីដែលពោលបញ្ចុះនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដគ្រប់ៗពំនូតដែលលេបចូលទៅ ។ ភិក្ខុនីនោះត្រូវអាបត្តិថុល្លច្ច័យក្នុងវេលាដែលឆាន់រួចហើយ ។ ភិក្ខុនីពោលបញ្ចុះថា លោកចូរទទួលយកទឹកនិងឈើស្ទន់ចុះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទទួលដោយគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគតាមពាក្យភិក្ខុនីជាអ្នកពោលបញ្ចុះនោះ ត្រូវអាបត្តិទុក្កដ ។

(៦០) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុ-នីដឹងថា បុរសនោះមិនមានតម្រេកទើបបញ្ចុះ ១ ភិក្ខុនីបញ្ចុះដោយគិតថា ភិក្ខុនីនេះក្រោធហើយក៏មិនទទួលយក ១ ភិក្ខុនីបញ្ចុះដោយគិតថា ភិក្ខុនីនេះមិនទទួលយកព្រោះខ្លួនមានសេចក្ដីអនុគ្រោះត្រកូល ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

## សង្ឃាទិសេសទី ៧

(៦១) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅវត្តជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ចណ្ឌកាលី

តេន ខោ បន សមយេន ចណ្ឌកាលី ភិក្ខុនី ភិក្ខុនីហិ សទ្ធឹ ភណ្ឌិត្វា កុបិតា អនត្តមនា ឯវំ វទេតិ ពុទ្ធំ បច្ចក្ខាមិ ធម្មំ បច្ចក្ខាមិ សង្ឃំ បច្ចក្ខាមិ សិក្ខំ បច្ចក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថញ្ហិ នាម អយ្យា ចណ្ឌកាលី កុបិតា អនត្តមនា ឯវំ វក្ខតិ ពុទ្ធំ បច្ចក្ខាមិ ។ បេ ។ សិក្ខំ បច្ចក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេតិ ពុទ្ធំ បច្ចក្ខាមិ ។ បេ ។ សិក្ខំ បច្ចក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ





ភិក្ខុនីឈ្លោះទើសទាស់អន់ចិត្តនឹងភិក្ខុនីទាំងឡាយ ហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយឯណាជាសមណី[១] ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីទាំងឡាយនេះមិនមែនជាសមណីដូចម្តេចបាន សមណីទាំងឡាយដទៃដែលមានខ្មាស មានសេចក្តីរង្កៀស ជាអ្នកប្រាថ្នាការសិក្សាក៏មាននូវដែរ អញនឹងប្រព្រឹត្តព្រហ្មចរ្យក្នុងសំណាក់សមណីទាំងឡាយនោះ ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា លោកម្ចាស់ចណ្ឌកាលីខឹងអាក់អន់ចិត្ត មិនសមបើនឹងពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ។ បេ ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយឯណាជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីអម្បាលនេះមិនមែនជាសមណីដូចម្តេចបាន សមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀស មានសេចក្តីប្រាថ្នាការសិក្សាក៏មានដែរ អញនឹងប្រព្រឹត្តព្រហ្មចរ្យក្នុងសំណាក់សមណីទាំងឡាយនោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនីខឹងអាក់អន់ចិត្តហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ។ បេ ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយឯណាជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីអម្បាលនេះមិន

---

១ សមណៈស្រី ហៅថា សមណី ដូចជាភិក្ខុស្រី ហៅថា ភិក្ខុនី ។

សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី កុបិតា អនត្តមនា ឯវំ វក្ខតិ ពុទ្ធំ បច្ចាចិក្ខាមិ ។បេ។ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេយ្យ ពុទ្ធំ បច្ចាចិក្ខាមិ ។បេ។ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ



ហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃជាអ្នកមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាក៏មានខ្លះដែរ អាត្មាអញនឹងប្រព្រឹត្តព្រហ្មចរិយធម៌សំណាក់សមណីទាំងឡាយនោះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនីខឹងអាក់អន់ចិត្តហើយ មិនគួរបីនឹងពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ជាអ្នកប្រាថ្នាការសិក្សាក៏មានខ្លះដែរ អាត្មាអញនឹងប្រព្រឹត្តព្រហ្មចរិយធម៌សំណាក់សមណីទាំងឡាយនោះដូចម្ដេច ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយខឹងអាក់អន់ចិត្តហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាក៏មានខ្លះដែរ

ព្រហ្មចរិយំ ចរិស្សាមីតិ ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ កុបិតា អនត្តមនា ឯវំ អវច ពុទ្ធំ បច្ចក្ខាមិ ។ បេ ។ សិក្ខំ បច្ចក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ អភិរមាយ្យេ ស្វាក្ខាតោ ធម្មោ ចរ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ ។ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។

[៦៦] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ កុបិតា អនត្តមនាតិ អនភិរទ្ធា



អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះ ។ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា ម្នាលលោកម្ចាស់ លោកកុំខឹងតក់អន់ហើយនិយាយយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ។ បេ ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះមិនមែនជាសមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះឡើយ ។ នែលោកម្ចាស់ ចូរលោកត្រេកអរ (ព្រោះ) ធម៌ព្រះដ៏មានព្រះភាគសំដែងល្អហើយ ចូរលោកប្រព្រឹត្តព្រហ្មចារ្យដើម្បីធ្វើនូវទីបំផុតទុក្ខដោយប្រពៃចុះ ឯភិក្ខុនីនោះកាលបើត្រូវភិក្ខុនីទាំងឡាយពោលយ៉ាងនេះ នៅតែប្រកាន់យ៉ាងនោះដដែល ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសន៍ចំពោះភិក្ខុនីនោះអស់វារៈជាគំរប់បីដង ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ បើភិក្ខុនីនោះកាលត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសន៍ទៅដរាបគំរប់បីដង (ហើយ) លះបង់វត្ថុនោះបាន ការលះបង់បាននោះជាការល្អ បើលះបង់មិនបានទេ ភិក្ខុនីនេះក៏ត្រូវអាបត្តិសង្ឃាទិសេស ជាយាវតតិយក គួរបណ្តេញចេញចាកសង្ឃ ។

[៦៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ ។ ពាក្យថា ទាំងខឹងទាំងអន់ចិត្ត គឺភិក្ខុនីមានចិត្តមិនត្រេកអរ

អាហតចិត្តា ខិលជាតា ។ ឯវំ វទេយ្យាតិ ពុទ្ធំ បច្ចាចិក្ខាមិ ។ បេ ។ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។

(៦៣) សា ភិក្ខុនីតិ យា សា ឯវំវាទិនី ភិក្ខុនី ។ ភិក្ខុនីហីតិ អញ្ញាហិ ភិក្ខុនីហិ ។ យា បស្សន្តិ យា សុណន្តិ តាហិ វត្តព្វា មាយ្យេ កុបិតា អនត្តមនា ឯវំ អវច ពុទ្ធំ បច្ចាចិក្ខាមិ ។ បេ ។ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ អភិរមាយ្យេ ស្វាក្ខាតោ ធម្មោ ចរ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។



មានចិត្តដែលគេសង្កត់សង្កិនហើយ មានចិត្តរឹងរូស ។ ពាក្យថា ភិក្ខុនីពោលយ៉ាងនេះ គឺភិក្ខុនីពោលថា ខ្ញុំលាព្រះពុទ្ធ ។ បេ ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះមិនហៅជាសមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សានឹងមានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះ ។

(៦៣) ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីដែលពោលយ៉ាងនេះជាប្រក្រតីនោះឯង ។ ពាក្យថា ប្រាប់ភិក្ខុនីទាំងឡាយ គឺប្រាប់ភិក្ខុនីទាំងឡាយដទៃ ។ ភិក្ខុនីទាំងឡាយឯណាឃើញ ឯណាឮ ភិក្ខុនីទាំងឡាយនោះត្រូវពោលហាមភិក្ខុនីនោះថា នែលោកម្ចាស់ លោកកុំខឹងកាត់អន់ចិត្ត ហើយនិយាយយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ។ បេ ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនោះមិនហៅជាសមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សានឹងមានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះឡើយ នែលោកម្ចាស់ លោកចូរត្រេកអរចុះ (ព្រោះ) ធម៌ គឺព្រះដ៏មានព្រះភាគសំដែងល្អហើយ លោកចូរប្រព្រឹត្តព្រហ្មចរិយធម៌ដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ ។

ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ ។ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សា ភិក្ខុនី សង្ឃមជ្ឈំបិ អាកឌ្ឍិត្វា វត្តព្វា មាយ្យេ កុបិតា អនត្តមនា ឯវំ អវច ពុទ្ធំ បច្ចាចិក្ខាមិ ។ បេ ។ សិក្ខំ បច្ចាចិក្ខាមិ អភិរមាយ្យេ សមណិ-យោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ អភិរមាយ្យេ ស្វាក្ខាតោ ធម្មោ ចរ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ ។ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។



ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយអស់វារៈពីរដងផង ត្រូវនិយាយអស់វារៈបីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាំងឡាយឮហើយមិននិយាយ ត្រូវអាបត្តិទុក្កដ ។ ត្រូវភិក្ខុនីទាំងឡាយទាញភិក្ខុនីនោះមកកាន់ទីកណ្ដាលសង្ឃហើយនិយាយហាមថា នែលោកម្ចាស់ លោកកុំខឹងកក់អន់ចិត្ត ហើយនិយាយយ៉ាងនេះថា ខ្ញុំលះព្រះពុទ្ធ ។ បេ ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះទើបហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាក៏មាននូវដែរ អញនឹងប្រព្រឹត្តព្រហ្មចរិយក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះ ។ នែលោកម្ចាស់ លោកចូរត្រេកអរចុះ (ព្រោះ) ធម៌ ដែលព្រះដ៏មានព្រះភាគសំដែងល្អហើយ ចូរលោកប្រព្រឹត្តព្រហ្មចរិយដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃចុះ ។ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយនិយាយហាមអស់វារៈពីរដងផង ត្រូវនិយាយហាមអស់វារៈបីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ ។

(៦៤) សា ភិក្ខុនី សមនុភាសិតព្វា ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេតិ ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេតិ ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ



(៦៤) ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសន-វិធីយ៉ាងនេះ ។ ភិក្ខុនីដែលឈ្លាសប្រតិពលត្រូវផ្ទៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះខឹងគាក់អន់ចិត្តពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនោះមិនមែនជាសមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សាក៏មានខ្លះដែរ អាត្មាអញនឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់សមណីទាំងឡាយនោះដូ-ច្នេះ ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ ។ បើសមនុភាសនកម្មបានកាលសមគួរដល់សង្ឃហើយ ត្រូវសង្ឃសូត្រសមនុភាសនវិធី ដល់ភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះខឹងគាក់អន់ចិត្តហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនោះមិនមែនជាសមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សា

សត្តមសិក្ខាបទស្ស សិក្ខាបទវិភង្គ បទភាជន

[illegible]

(៦៨) [illegible]



សត្តមសិក្ខាបទ សិក្ខាបទវិភង្គ ការស្រាយសេចក្ដីអធិប្បាយ

[illegible]

(៦៨) [illegible]

[៦៦] អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ យាវតតិយកន្តិ យាវតតិយំ សមនុភាសនាយ អាបជ្ជតិ ន សហ វត្ថុជ្ឈាចារា ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារិយតិ ។ សង្ឃាទិសេសោតិ ។បេ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

[៦៧] ធម្មកម្មេ ធម្មកម្មសញ្ញា នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកា នប្ប-ដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃា-ទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៦៨] អនាបត្តិ អសមនុភាសន្តិយា បដិនិស្សជ្ជ-ន្តិយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។





(៦៦) ពាក្យថា ភិក្ខុនីនេះក្តី (គឺភិក្ខុនីនេះឯង) ដែលគេថាតគោល ប្រៀបផ្ទឹមនឹងភិក្ខុនីដែលត្រូវសង្ឃាទិសេសមុន ៗ ។ ពាក្យថា យាវតតិ-យក គឺភិក្ខុនីត្រូវអាបត្តិដោយ (សង្ឃ) សូត្រសមនុភាសនាទៅគំរប់ជាគំ-រប់បីដង មិនមែនត្រូវព្រមគ្នាដោយការប្រព្រឹត្តល្មើសវត្ថុទេ ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយបណ្តេញចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយដូចមុនហើយ ។

(៦៧) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៦៨) ពួកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុនីដែលសង្ឃមិនបានសូត្រសមនុភាសនាក្តី ១ ភិក្ខុនីលះបង់ឯង ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

## អដ្ឋមសង្ឃាទិសេសំ

(៦៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ចណ្ឌកាលី ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា[១] កុបិតា អនត្តមនា ឯវំ វទេតិ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ទោសគាមិនិយោ ច ភិក្ខុនិយោ មោហគាមិនិយោ ច ភិក្ខុនិយោ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ចណ្ឌកាលី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ វក្ខតិ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។ សច្ចំ កិរ ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ វទេតិ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។ សច្ចំ

១ ម. បច្ចាហតា ។ ឯវំ សព្វត្ថ [illegible] ។

## សង្ឃាទិសេសទី ៨

(៦៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនី ដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍អ្វីមួយ ហើយទឹងតូចចិត្ត ពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្អប់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្តីវង្វេងផង ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីជាម្ចាស់ដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍ណាមួយហើយ មិនគួរទឹងទែងគក់អន់ចិត្តហើយពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះសោះ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនីដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍ណាមួយ ហើយទឹងតូចចិត្តពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា

ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ វក្ខតិ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ វទេយ្យ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ អវច ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ អយ្យា ខោ ឆន្ទាបិ គច្ឆេយ្យ ទោសាបិ គច្ឆេយ្យ មោហាបិ គច្ឆេយ្យ ភយាបិ គច្ឆេយ្យាតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ, សា ភិក្ខុនី





បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនីដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍ណាមួយហើយ មិនត្រេកអរនឹងខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយដែលភិក្ខុនីសង្ឃធ្វើឲ្យចាញ់ព្រោះអធិករណ៍ណាមួយ ហើយខឹងអាក់អន់ចិត្តពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង ។ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា នែលោកម្ចាស់ លោកដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍ណាមួយ ហើយខឹងអាក់អន់ចិត្តនិយាយយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះ លោកម្ចាស់ហ្នឹងឯង លុះដោយសេចក្តីស្រឡាញ់ខ្លះ លុះដោយសេចក្តីស្អប់ខ្លះ លុះដោយសេចក្តីល្ងង់ខ្លះ លុះដោយសេចក្តីខ្លាចខ្លះ ។ ភិក្ខុនីនោះកាលដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ នៅតែប្រកាន់យ៉ាងនោះដដែល

ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។

(៧០) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ កិស្មិញ្ចិទេវ អធិករណេតិ អធិករណំ នាម ចត្តារិ អធិករណានិ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ។ បច្ចាកតា នាម បរាជិតា វុច្ចតិ ។ កុបិតា អនត្តមនាតិ អនភិរទ្ធា អាហតចិត្តា ខិលជាតា ។ ឯវំ វទេយ្យាតិ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។

(៧១) សា ភិក្ខុនីតិ យា សា ឯវំវាទិនី ភិក្ខុនី ។ ភិក្ខុនីហីតិ អញ្ញាហិ ភិក្ខុនីហិ ។ យា បស្សន្តិ យា សុណន្តិ តាហិ វត្តព្វា មាយ្យេ កិស្មិញ្ចិទេវ អធិករណេ



ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីដរាបដល់គំរប់បីដង ដើម្បីឲ្យលះបង់កម្មនោះចេញ ។ ភិក្ខុនីនោះកាលបើត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីដរាបដល់គំរប់បីដង លះបង់កម្មនោះបាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាយាវតតិយក គួរបណ្តេញចេញពីសង្ឃ ។

(៧០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ព្រោះអធិករណ៍ណាមួយ ដែលហៅថា អធិករណ៍ បានដល់អធិករណ៍ទាំងឡាយបួន គឺវិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ។ ដែលហៅថា ភិក្ខុនីសង្ឃធ្វើឲ្យចាញ់ គឺសំដៅយកភិក្ខុនីដែលភិក្ខុនីសង្ឃផ្តាញ់ផ្តួលហើយ ។ ពាក្យថា ទើសទាស់អន់ចិត្ត គឺភិក្ខុនីមិនត្រេកអរ មានចិត្តតឹងតាសទ្រាំទប់ហើយ មានចិត្តរឹងត្អឹង ។ ពាក្យថា ពោលយ៉ាងនេះ គឺពោលថា ភិក្ខុនីទាំងឡាយលុះអំណាចសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះអំណាចសេចក្តីខ្លាចផង ។

(៧១) ត្រង់ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីជាអ្នកពោលយ៉ាងនេះ ជាប្រក្រតីនោះឯង ។ ពាក្យថា ភិក្ខុនីទាំងឡាយ គឺភិក្ខុនីទាំងឡាយដទៃ ។ ភិក្ខុនីទាំងឡាយឯណាឃើញ ឯណាឮ ភិក្ខុនីនោះត្រូវភិក្ខុនី

បច្ចាកតា កុបិតា អនត្តមនា ឯវំ អវច ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ អយ្យា ខោ ឆន្ទាបិ គច្ឆេយ្យ ។ បេ ។ ភយាបិ គច្ឆេយ្យាតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សា ភិក្ខុនី សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វា មាយ្យេ កិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ អវច ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ អយ្យា ខោ ឆន្ទាបិ គច្ឆេយ្យ ។ បេ ។ ភយាបិ គច្ឆេយ្យាតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។



ទាំងឡាយនោះនិយាយហាមប្រាមថា នែលោកម្ចាស់ កាលបើភិក្ខុនីសង្ឃផ្ចាលផ្ចាញ់ព្រោះអធិករណ៍ណាមួយ ហើយខឹងអាក់អន់ចិត្ត កុំពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីភ័យផងដូច្នេះថា លោកម្ចាស់ហ្នឹងឯង លុះដោយសេចក្ដីស្រឡាញ់ខ្លះ ។ បេ ។ លុះដោយសេចក្ដីភ័យខ្លះ ។ ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីនោះអស់វារៈពីរដងផង ត្រូវនិយាយនឹងភិក្ខុនីនោះអស់វារៈបីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាំងឡាយឯណាឮហើយមិននិយាយ ភិក្ខុនីទាំងនោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាំងឡាយត្រូវចាប់ទាញភិក្ខុនីនោះមកកាន់ទីកណ្ដាលសង្ឃ ហើយនិយាយថា នែលោកម្ចាស់ បើភិក្ខុនីសង្ឃផ្ចាញ់ផ្ចាលព្រោះអធិករណ៍ណាមួយ លោកខឹងអាក់អន់ចិត្តហើយកុំពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីភ័យផងដូច្នេះថា លោកម្ចាស់ហ្នឹងឯង លុះដោយសេចក្ដីស្រឡាញ់ខ្លះ ។ បេ ។ លុះដោយសេចក្ដីភ័យខ្លះ ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីនោះអស់វារៈពីរដងផង ត្រូវនិយាយអស់វារៈបីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

(៨៤) សា ភិក្ខុនី សមនុភាសិតព្វា ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វា ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ វទេតិ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចាកតា កុបិតា អនត្តមនា ឯវំ វទេតិ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ។ បេ ។ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ភិក្ខុនិយា សមនុភាសនា តស្ស វត្ថុស្ស



(៨៤) ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសូត្រសមនុភាសនវិធីយ៉ាងនេះ គឺភិក្ខុនីដែលឈ្លាសប្រតិពលត្រូវផ្សាយឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះ ត្រូវសង្ឃបានផ្ចាញ់ព្រោះអធិករណ៍ណាមួយ ហើយទើងតក់អន់ចិត្តពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ ។ បើសង្ឃមានកាលគួរដល់ហើយ សង្ឃត្រូវសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនីនេះឈ្មោះនេះត្រូវសង្ឃបានផ្ចាញ់ព្រោះអធិករណ៍ណាមួយ ទើងតក់អន់ចិត្តហើយពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ។ បេ ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ ការសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ

បដិនិស្សគ្គាយ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ តតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ សមនុភដ្ឋា សង្ឃេន ឥត្ថន្នាមា ភិក្ខុនី តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(១៧) ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តិយា ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ ។

(១៨) អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ យាវតតិយកាតិ យាវតតិយំ សមនុភាសនាយ



គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ ខ្ញុំពោលសេចក្តីនេះអស់វារៈជាគំរប់ពីរដងផង ។បេ។ ខ្ញុំពោលសេចក្តីនេះអស់វារៈជាគំរប់បីដងផង ។បេ។ សង្ឃសូត្រសមនុភាសនូវភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះហើយ ។ ការសូត្រសមនុភាសនៈនោះគាប់ចិត្តដល់សង្ឃ ហេតុនោះសង្ឃទើបស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវកិរិយានេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

(១៧) ភិក្ខុនីនោះត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យពីរឡាយក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រចប់កម្មវាចាស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ កាលបើភិក្ខុនីនោះត្រូវអាបត្តិសង្ឃាទិសេស អាបត្តិទុក្កដដែលត្រូវក្នុងខណៈចប់ញត្តិ (ក្តី) អាបត្តិថុល្លច្ច័យពីរឡាយដែលត្រូវក្នុងខណៈចប់កម្មវាចាពីរលើក (ក្តី) រមែងរម្ងាប់ទៅ (ឯង) ។

(១៨) ត្រង់ពាក្យថា ភិក្ខុនីនេះក្តី គឺភិក្ខុនីនេះឯង ដែលតថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីមុន ៗ ដែលត្រូវអាបត្តិនោះដែរ ។ ពាក្យថា ជាយាវតតិយក គឺភិក្ខុនីនោះត្រូវសង្ឃាទិសេសក្នុងខណៈដែលសូត្រសមនុភាសនទី

អាបជ្ជតិ ន សហ វត្ថុជ្ឈាចារា ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារិយតិ ។ សង្ឃាទិសេសោតិ ។បេ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

[៧៥] ធម្មកម្មេ ធម្មកម្មសញ្ញា នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកា នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិ-សេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៧៦] អនាបត្តិ អសមនុភាសន្តិយា បដិនិស្សជ្ជន្តិ-យា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



កំលាត់ប៉ុណ្ណេះ មិនត្រូវព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុទេ ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីទាំងឡាយឲ្យភិក្ខុនីនោះចៀសចេញពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានសេចក្តីដូចគ្នានឹងបឋមសង្ឃាទិសេសខាងដើម ។

[៧៥] កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសំគាល់ថាកម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ មិនលះបង់ ត្រូវអាបត្តិសង្ឃា-ទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៧៦] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនី (ដែលសង្ឃ) មិនបានស្មូត្រសមនុភាសនវាចា ១ ភិក្ខុនីដែលលះបង់ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

# នវមសង្ឃាទិសេសំ

[៣៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទាយ ភិក្ខុនិយា អន្តេវាសិនិយោ(១) ភិក្ខុនិយោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា(២) ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ សំសដ្ឋា វិហរិស្សន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកាតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា

១ ឱ. អន្តេវាសិភិក្ខុនិយោ ។ ម. អន្តេវាសិកា ភិក្ខុនិយោ ។ ២ វជ្ជបដិច្ឆាទិកាតិ យុត្តតរំ ។

# សង្ឃាទិសេសទី ៩

(៣៧) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុនី ជាអន្តេវាសិនី(១) របស់ថុល្លនន្ទាភិក្ខុនី នៅច្រឡូកច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសភិក្ខុនីដទៃគ្នា ។ ភិក្ខុនីទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីដទៃគ្នាសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា

(១) ភិក្ខុនីជាសិស្ស ។

កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ សំសដ្ឋា វិហរិស្សន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ ភិក្ខុនិយោ បនេវ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា ។ តា ភិក្ខុនិយោ ភិក្ខុនីហិ ឯវមស្សុ វចនីយា ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ ឯវញ្ច តា ភិក្ខុនិយោ ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យុំ តា ភិក្ខុនិយោ ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ





ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនគួរបើនឹងនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនទាន់ឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាហើយទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ( បើពួកភិក្ខុនីទាំងឡាយនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា ។ ភិក្ខុនីទាំងឡាយនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា បងស្រីលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកគ្នា) សង្ឃតែងសរសើរសេចក្តីស្ងាត់ (ចាកគ្នា) របស់បងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីទាំងឡាយនោះកាលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះហើយ គឺនៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនីទាំងឡាយនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនាដរាបដល់គំរប់បីដង ដើម្បីឲ្យលះបង់នូវវត្ថុនោះ ។ បើភិក្ខុនីទាំងឡាយនោះកាលភិក្ខុនី

សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យុំ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យុំ ឥមាបិ ភិក្ខុនិយោ យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។

(៧៨) ភិក្ខុនិយោ បនេវាតិ ឧបសម្បន្នាយោ វុច្ចន្តិ ។ សំសដ្ឋា វិហរន្តីតិ អននុលោមិកេន កាយិកវាចសិកេន(១) សំសដ្ឋា វិហរន្តិ ។ បាបាចារាតិ បាបកេន អាចារេន សមន្នាគតា ។ បាបសទ្ទាតិ បាបកេន កិត្តិសទ្ទេន អព្ភុគ្គតា ។ បាបសិលោកាតិ បាបកេន មិច្ឆាជីវេន ជីវិតំ កប្បេន្តិ ។ ភិក្ខុនីសង្ឃស្ស វិហេសិកាតិ អញ្ញមញ្ញិស្សា កម្មេ ករិយមានេ បដិក្កោសន្តិ ។ អញ្ញមញ្ញិស្សា វជ្ជបដិច្ឆាទិកាតិ អញ្ញមញ្ញំ វជ្ជំ បដិច្ឆាទេន្តិ ។

(៧៩) តា ភិក្ខុនិយោតិ យា តា សំសដ្ឋា ភិក្ខុនិយោ ។ ភិក្ខុនីហីតិ អញ្ញាហិ ភិក្ខុនីហិ ។ យា បស្សន្តិ យា សុណន្តិ តាហិ វត្តព្វា ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិ-

១ កាយិកវាចសិកេន សំសដ្ឋេនាតិ ភវិតព្វំ ។

ទាំងឡាយ ដែលសង្ឃសមនុភាសន៍ដល់គំរប់បីដង លះបង់វត្ថុនោះបាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីទាំងឡាយនេះក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយក គួរបណ្តេញចេញ ។

(៧៨) ត្រង់ពាក្យថា ចំណែកភិក្ខុនីទាំងឡាយ គឺសំដៅយកស្រ្តីដែលបានឧបសម្បទាហើយ ។ ពាក្យថា នៅច្រឡំដោយគ្រហស្ថ គឺនៅច្រឡំដោយកាយកម្ម វចីកម្ម (របស់គ្រហស្ថ) ដែលមិនសមគួរ (ដល់បព្វជិត) ។ ពាក្យថា មានមារយាទអាក្រក់ គឺប្រកបដោយមារយាទអាក្រក់ ។ ពាក្យថា មានកិត្តិសព្ទអាក្រក់ គឺល្បីឮដោយកិត្តិសព្ទអាក្រក់ ។ ពាក្យថា មានការចិញ្ចឹមជីវិតអាក្រក់ គឺសម្រេចជីវិតដោយមិច្ឆាជីវៈអាក្រក់ ។ ពាក្យថា បៀតបៀនភិក្ខុនីសង្ឃ គឺកាលសង្ឃធ្វើកម្មដល់ភិក្ខុនីដទៃគ្នា ក៏ឃាត់ ។ ពាក្យថា បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា គឺបិទបាំងទោសគ្នា ។

(៧៩) ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយនោះ គឺភិក្ខុនីដែលច្រឡំ (ដោយគ្រហស្ថ) នោះឯង ។ ពាក្យថា ដែលភិក្ខុនីទាំងឡាយ គឺដែលភិក្ខុនីទាំងឡាយដទៃ ។ ភិក្ខុនីទាំងឡាយណា បានឃើញបានឮ ភិក្ខុនីទាំងឡាយនោះគួរនិយាយតាមក្រមថា បង្អូនស្រីទាំងឡាយនៅច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការ

### នវមសង្ឃាទិសេសស្ស សិក្ខាបទវិភង្គោ

លោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថាយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជន្តិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជន្តិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ តា ភិក្ខុនិយោ សង្ឃមជ្ឈំបិ អាកឌ្ឍិត្វា វត្តព្វា ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថាយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជន្តិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជន្តិ អាបត្តិ ទុក្កដស្ស ។



### សង្ឃាទិសេសទី ៩ សិក្ខាបទវិភង្គ

ចំអ្អឹមចំអែកអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកគ្នា) សង្ឃតែងពោលសរសើរសេចក្តីស្ងាត់ (ចាកគ្នា) របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីទាំងឡាយនោះអស់វារៈជាគំរប់ពីរដង ត្រូវនិយាយអស់វារៈជាគំរប់បីដង ។ បើភិក្ខុនីទាំងឡាយនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាំងឡាយដទៃឮហើយមិននិយាយ ត្រូវអាបត្តិទុក្កដ ។ ត្រូវភិក្ខុនីទាំងឡាយទាញភិក្ខុនីទាំងឡាយនោះមកកណ្តាលសង្ឃ ហើយពោលថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយនៅច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចំអ្អឹមចំអែកអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា បពិត្រលោកម្ចាស់ សូមលោកទាំងឡាយស្ងាត់ (ចាកគ្នា) សង្ឃតែងសរសើរសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីទាំងឡាយនោះអស់វារៈជាគំរប់ពីរដង ត្រូវនិយាយអស់វារៈជាគំរប់បីដង ។ បើភិក្ខុនីទាំងឡាយនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

[៩០] តា ភិក្ខុនិយោ សមនុភាសិតព្វា ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វា ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ ឥត្ថន្នាមា ច ឥត្ថន្នាមា ច ភិក្ខុនិយោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនិសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា ។ តា តំ វត្ថុំ នប្បដិនិស្សជ្ជន្តិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខុនិយោ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ ឥត្ថន្នាមា ច ឥត្ថន្នាមា ច ភិក្ខុនិយោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនិសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា ។ តា តំ វត្ថុំ នប្បដិនិស្សជ្ជន្តិ ។ សង្ឃោ ឥត្ថន្នាមញ្ច ឥត្ថន្នាមញ្ច ភិក្ខុនិយោ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ច ឥត្ថន្នាមាយ ច ភិក្ខុនីនំ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ





[៩០] គប្បីភិក្ខុនីទាំងឡាយស្មូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីស្មូត្រសមនុភាសនវិធីយ៉ាងនេះ គឺភិក្ខុនីដែលឈ្លាសប្រតិពលត្រូវប្រកាសឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីទាំងឡាយឈ្មោះនេះផង ៗ នៅច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា ។ ភិក្ខុនីទាំងឡាយនោះមិនលះបង់វត្ថុនោះឡើយ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីស្មូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផង ៗ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីទាំងឡាយឈ្មោះនេះផង ៗ នៅច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីដទៃគ្នា ។ ភិក្ខុនីទាំងឡាយនោះមិនលះបង់វត្ថុនោះឡើយ ។ សង្ឃស្មូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផង ៗ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ ការស្មូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផង ៗ ដើម្បីឲ្យលះបង់វត្ថុនោះចេញ

សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ សមនុភដ្ឋា សង្ឃេន ឥត្ថន្នាមា ច ឥត្ថន្នាមា ច ភិក្ខុនិយោ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៨១) ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តីនំ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ ។ ទ្វេ តិស្សោ ឯកតោ សមនុភាសិតព្វា តទុត្តរិ ន សមនុភាសិតព្វា ។

(៨២) ឯតាបិ ភិក្ខុនិយោតិ បុរិមាយោ ឧបាទាយ វុត្តំ ។ យាវតតិយកន្តិ យាវតតិយំ សមនុភាសនាយ



គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ ខ្ញុំសូត្រសេចក្ដីនេះអស់វារៈជាគំរប់ពីរដងផង ។ បេ ។ ខ្ញុំសូត្រសេចក្ដីនេះអស់វារៈជាគំរប់បីដងផង ។ បេ ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផង ។ ដើម្បីឲ្យលះបង់វត្ថុនោះហើយ ។ ការសូត្រសមនុភាសនវិធីនោះគាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវកិរិយានេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៨១] ភិក្ខុនីទាំងឡាយ ត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យ ទាំងឡាយក្នុងខណៈចប់កម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេសក្នុងខណៈចប់កម្មវាចាស្រេច ។ កាលបើភិក្ខុនីទាំងឡាយត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលត្រូវក្នុងខណៈចប់ញត្តិ (ក្ដី) អាបត្តិថុល្លច្ច័យ ទាំងឡាយដែលត្រូវក្នុងខណៈចប់កម្មវាចាពីរដង (ក្ដី) ក៏រម្ងាប់ទៅឯង ។ ភិក្ខុនីទាំងឡាយគប្បីសូត្រសមនុភាសនវិធី ចំពោះភិក្ខុនីពីរឬបីរួមជាមួយគ្នាបាន មិនត្រូវសូត្រសមនុភាសនវិធីឲ្យលើសអំពីពីរឬបីនោះឡើយ ។

[៨២] ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយនេះក្ដី គឺភិក្ខុនីទាំងឡាយដែលគេពោលប្រៀបធៀបនឹងភិក្ខុនីទាំងឡាយមុនៗ ។ ពាក្យថា ឈ្មោះយាវតតិយកៈ សេចក្ដីថា ភិក្ខុនីទាំងឡាយត្រូវអាបត្តិ (សង្ឃាទិសេស)

អាបជ្ជតិ ន សហា វត្ថុជ្ឈាចារា ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារីយតិ ។ សង្ឃាទិសេសោតិ ។ បេ ។ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

(៨៣) ធម្មកម្មេ ធម្មកម្មសញ្ញា ន បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកា ន បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា ន បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

(៨៤) អនាបត្តិ អសមនុភាសន្តិយា បដិនិស្សជ្ជន្តិយា ឧម្មត្តិកាយ ខិត្តចិត្តាយ វេទនដ្ដាយ អាទិកម្មិកាយាតិ ។



ដោយស្មូត្រសមនុភាសនវាចាដល់វារជាគំរប់បី មិនមែនត្រូវព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុទេ ។ ពាក្យថា គួរបណ្ដេញចេញ គឺភិក្ខុនីទាំងឡាយគួរនាំភិក្ខុនីដែលត្រូវអាបត្តិសង្ឃាទិសេសនោះចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស មានសេចក្ដីអធិប្បាយក្នុងសង្ឃាទិសេសទី ១ រួចហើយ ។

(៨៣) កម្មប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថាកម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីទាំងឡាយមានសេចក្ដីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៨៤) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុនីទាំងឡាយដែលភិក្ខុនីសង្ឃមិនបានស្មូត្រសមនុភាសនវាចា ១ ភិក្ខុនីទាំងឡាយលះបង់ចេញ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីមានចិត្តរវើរវាយ ១ ភិក្ខុនីដែលវេទនាគ្របសង្កត់ ១ ភិក្ខុនីជាតន្ដើមបញ្ញត្តិ ១ ។

# ទសមសង្ឃាទិសេសំ

(៨៩) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយោវ ថុល្លនន្ទា ភិក្ខុនី សង្ឃេន សមនុភដ្ឋា ភិក្ខុនិយោ ឯវំ វទេតិ សំសដ្ឋា វ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ ន កិញ្ចិ អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយ បរិភវេន អក្ខន្តិយា វេភស្សា[១] ទុព្ពល្យា ឯវមាហ ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថយ្យេ

១ ម. ឆ. វេភស្សិយា ។ ឯវំ សព្វត្ថ ញាតព្វំ ។

# សង្ឃាទិសេសទី ១០

(៨៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ថុល្លនន្ទាភិក្ខុនីពោលពាក្យយ៉ាងនេះនឹងភិក្ខុនីទាំងឡាយ ដែលសង្ឃសូត្រសមនុភាសនហើយថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃដែលមានមារយាទយ៉ាងនេះ មានកិត្តិសព្ទយ៉ាងនេះ ចំឡើមដំរៃកយ៉ាងនេះ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកដទៃគ្នា មាននៅក្នុងសង្ឃដែរ សង្ឃមិនបានពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ ដោយពេបជ្រាយ ដោយក្តួចអំណត់ (ក្រោធ) ដោយសំដីបង្រិប ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកច្រឡូកច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចំឡើមដំរៃកអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកដទៃគ្នា ចត់ក្រែលោកម្ចាស់ សូមលោកទាំងឡាយស្ងាត់ (ចាកពួក)

វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ យា តា ភិក្ខុ-
និយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបា-
ចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា សង្ឃេន
សមនុភដ្ឋា ភិក្ខុនិយោ ឯវំ វក្ខតិ សំសដ្ឋាវ អយ្យេ
តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ ។ បេ ។
វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ
។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សង្ឃេន
សមនុភដ្ឋា ភិក្ខុនិយោ ឯវំ វទេតិ សំសដ្ឋាវ អយ្យេ
តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ ។ បេ ។ វិវិច្ចថយ្យេ
វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្ល-
នន្ទា ភិក្ខុនី សង្ឃេន សមនុភដ្ឋា ភិក្ខុនិយោ ឯវំ



សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុ-
នីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ
ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទាមិនសមបើ
នឹងពោលយ៉ាងនេះនឹងភិក្ខុនីទាំងឡាយដែលសង្ឃសូត្រ សមនុភាសនទៅ
ហើយថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ
ដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ ។ បេ ។ នែ
លោកម្ចាស់ទាំងឡាយ ចូរលោកទាំងឡាយស្ងាត់ (ចាកពួក) សង្ឃសរ-
សើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ បេ ។ ព្រះដ៏
មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីនិយាយ
យ៉ាងនេះនឹងភិក្ខុនីទាំងឡាយ ដែលសង្ឃសូត្រសមនុភាសនទៅហើយថា
បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយ
គ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ ។ បេ ។ បពិត្រ
លោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរ-
សើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ពិតមែនឬ ។ ភិក្ខុ
ទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះ
សម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី
មិនគួរបើនឹងពោលយ៉ាងនេះនឹងភិក្ខុនីទាំងឡាយ ដែលសង្ឃសូត្រសមនុ-

តេរសសង្ឃាទិសេស បញ្ញត្តិ

វក្ខតិ សំសដ្ឋា វ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ ។ បេ ។ អីទ្ធេយ្យេ វិវេកញ្ញេវ គតិធំ សម្ផ្លើ វណ្ណោតីតិ ចេតំ ភិក្ខុនី អញ្ញសង្ឃាធំ វា បសាទាយ ។ បេ ។ បរិញ្ញ បន ភិក្ខុនី ភិក្ខុនិយោ ឯវំ សិក្ខាបទំ ឧទ្ទិសន្តុ ។ យា បន ភិក្ខុនី ឯវំ វទេយ្យ សំសដ្ឋា វ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនិសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ ន កិញ្ចិ អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយ បរិភវេន អក្ខន្តិយា វេភស្សា ទុព្វល្យា ឯវមាហ ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា



សង្ឃាទិសេសទី ១០ សេចក្តីបញ្ញត្តិ

ការសម្តែងហើយថា បងស្រីលោកម្ចាស់ទាំងឡាយ លោកទាំងឡាយ ចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកផ្សេងគ្នាឡើយ ។ បេ ។ បងស្រីលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្វាក់ (ពាក្យគួរ) សរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ជួរចុះឯង ឃ្លាតភិក្ខុនីទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយពោលយ៉ាងនេះថា បងស្រីលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកផ្សេងគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយឯទៀតដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចំរើនឈ្មោះដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីក្រុមពួកគ្នា មាននៅក្នុងសង្ឃដែរ សង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ ដោយពេបជ្រាយ ដោយគ្មានអំណត់ ដោយសំដីបន្ទ្រូប ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចំរើនឈ្មោះអាក្រក់

ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆា-
ទិកា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។
សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ ឯវំ
អវច សំសដ្ឋាវ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា
វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា
ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា
អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ ន កិញ្ចិ
អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយ បរិភវេន អក្ខន្តិយា
វេភស្សា ទុព្វល្យា ឯវមាហ ភគិនិយោ ខោ សំ-
សដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា
ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិ-
កា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។



ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា
បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្តាប់ (ពាកពួក)
សង្ឃសរសើរតែសេចក្ដីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុ-
នីនោះគប្បីភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ ចូរ
លោកកុំនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំង
ឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែក
ទែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃ ដែលមានមារយាទដូចគ្នា មាន
កិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ
ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃនេះ សង្ឃ
មិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះ
តែនឹងលោកទាំងឡាយដោយសេចក្ដីមើលងាយ ដោយគេបព្រាយ ដោយ
គ្មានអំណត់ ដោយសំដីបន្តិច ព្រោះលោកទាំងឡាយមានកំឡាំងថយ
ថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកនៅច្រឡូកច្រឡំ (ដោយ
គ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិត
អាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួក
ផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្តាប់ (ពាក
ពួក) សង្ឃសរសើរតែសេចក្ដីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។

ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ ។ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសន្តិ ។

(៤៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឯវំ វទេយ្យាតិ សំសដ្ឋា វ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ ន កិញ្ចិ អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយាតិ អវញ្ញាយ ។ បរិភវេនាតិ បរិភវេន ។ អក្ខន្តិយាតិ កោបេន ។ វេភស្សិយាតិ វិភស្សីកតា ។



ភិក្ខុនីនោះកាលដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ ក៏នៅតែប្រកាន់ដដែល ភិក្ខុនីនោះគប្បីភិក្ខុនីទាំងឡាយសូត្រសមនុភាសនៈដើម្បីឲ្យលះបង់ទ្រឹស្តីនោះចេញដល់ត្រឹមបីដង ។ បើភិក្ខុនីនោះកាលដែលភិក្ខុនីទាំងឡាយសូត្រសមនុភាសនៈចេញដល់ត្រឹមបីដង លះបង់ទ្រឹស្តីនោះបាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះក្តី (ក៏) ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយក គួរបណ្តេញចេញ ។

(៤៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃឧទ្ទានជិតគណ្ឌ ។ ពាក្យថា ពោលយ៉ាងនេះ គឺពោលថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ លោកទាំងឡាយកុំនៅផ្សេងៗ គ្នាឡើយ (ព្រោះ) ភិក្ខុនីទាំងឡាយសូម្បីឯទៀត ដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានកេរ្តិ៍ឈ្មោះដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកជំនិតគ្នា មាននៅក្នុងសង្ឃដែរ (តែ) សង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ និងដោយសេចក្តីមាក់ងាយ ។ ពាក្យថា ដោយសេចក្តីពេបជ្រាយ គឺដោយសេចក្តីស្អប់ខ្ពើម ។ ពាក្យថា ដោយគ្មានអំណត់ គឺដោយសេចក្តីខឹង ។ ពាក្យថា ដោយសំដីបញ្ឆិត គឺដោយពាក្យសំដីឡើសសេចាំង ។

ទុព្វល្យាតិ អបក្ខតា ។ ឯវមាហ ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ សា ភិក្ខុនីតិ យា សា ឯវំវាទិនី ភិក្ខុនី ។ ភិក្ខុនីហីតិ អញ្ញាហិ ភិក្ខុនីហិ ។ យា បស្សន្តិ យា សុណន្តិ តាហិ វត្តព្វា មាយ្យេ ឯវំ អវច សំសដ្ឋាវ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ ។ បេ ។ វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។



ពាក្យថា ដោយសេចក្តីទន់ខ្សោយមានពក្សពួកថយ គឺដោយសេចក្តីទន់ខ្សោយគ្មានបក្សពួក ។ ពុំលុះមន្ទនាក់ភិក្ខុនីពោលយ៉ាងនេះថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយនុ៎ះឯង ជាអ្នកនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ចាំងបាំងទោសរបស់ភិក្ខុនីពួកឯគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីឯណាដែលពោលជាប្រក្រតីយ៉ាងនេះនោះឯង ។ ពាក្យថា ដែលភិក្ខុនីទាំងឡាយ គឺដែលភិក្ខុនីទាំងឡាយដទៃ ។ ភិក្ខុនីទាំងឡាយឯណាឃើញ ឯណាឮ ភិក្ខុនីទាំងឡាយនោះគប្បីនិយាយនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ ចូរលោកកុំនិយាយពាក្យយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកនៃគ្នាឡើយ ។ បេ ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីនោះគឺភិក្ខុនីទាំងឡាយគប្បីពោលអស់វារៈគំរប់ពីរដងផង គប្បីពោលអស់វារៈគំរប់បីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះនោះជាការល្អ បើលះបង់មិនបាននេះ ត្រូវអាបត្តិទុក្កដ

សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សា ភិក្ខុនី សង្ឃមជ្ឈំបិ អាកឌ្ឍិត្វា វត្តព្វា មាយ្យេ ឯវំ អវច សំសដ្ឋា វ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ ។ បេ ។ អិច្ឆយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

(៨៧) សា ភិក្ខុនី សមនុភាសិតព្វា ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វា ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី សង្ឃេន សមនុ-ភដ្ឋា ភិក្ខុនិយោ ឯវំ វទេតិ សំសដ្ឋា វ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា



ភិក្ខុនីទាំងឡាយឮហើយមិននិយាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីនោះ គឺភិក្ខុនីទាំងឡាយនាំយកមកកាន់ទីកណ្តាលសង្ឃ ហើយពោលថា បពិត្រលោកម្ចាស់ លោកកុំពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ)ចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ ។ បេ ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្តាប់(ពាក្យគួរ) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីទាំងឡាយគួរភិក្ខុនីទាំងឡាយនិយាយអស់វារៈពីរដងទីបី គួរនិយាយអស់វារៈគំរប់បីដង ។ បើភិក្ខុនីនោះលះបង់ចេញ ការលះបង់នេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

(៨៧) ភិក្ខុនីទាំងឡាយគួរភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីយ៉ាងនេះ គឺភិក្ខុនីដែលឈ្លាសប្រតិភាណគប្បីផ្តៀងសង្ឃឲ្យដឹងថា បពិត្រសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីឈ្មោះនេះ ពោលយ៉ាងនេះនឹងភិក្ខុនីទាំងឡាយដែលសង្ឃសូត្រសមនុភាសនវិធីហើយថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រ-ហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃដែលមានមារយាទដូចនេះ មានកិត្តិសព្ទដូចនេះ មានការប៉ះពាល់ដែល

ភិក្ខុនិសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ ន កិញ្ចិ អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយ បរិភវេន អក្ខន្តិយា វេភស្សា ទុព្ពល្យា ឯវមាហ ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ ។ បេ ។ វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី សង្ឃេន សមនុកដ្ឋា ភិក្ខុនិយោ ឯវំ វទេតិ សំសដ្ឋាវ អយ្យេ[១] តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ

១ អយ្យាតិបិ ឥត្ថំ បោត្ថកេ ទិស្សតិ ។



ជួនគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ តែសង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ ។ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្ដីមើលងាយ ដោយសេចក្ដីពេបជ្រាយ ដោយខ្វះខន្តី ដោយសំដីបង្ក្រិច ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយញ៉ាំងឯងនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ។ បេ ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្ដីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ ។ បើកម្មានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនវាចានោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ នេះជាញត្តិ ។ បពិត្រសង្ឃដ៏ម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះពោលយ៉ាងនេះ នឹងភិក្ខុនីទាំងឡាយដែលសង្ឃសូត្រសមនុភាសនវាចាហើយថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ លោកទាំងឡាយកុំនៅបែកផ្សេងគ្នាឡើយ ស្បិតភិក្ខុនីទាំងឡាយដទៃដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការបំពុមដំណែដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ តែសង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនី

ន កិញ្ចិ អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយ បរិភវេន អក្ខន្តិយា វេភស្សា ទុព្វល្យា ឯវមាហ ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនិសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ភិក្ខុនិយា សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ សមនុភដ្ឋា សង្ឃេន ឥត្ថន្នាមា ភិក្ខុនី តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។





ទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយ ដោយសេចក្តីមើលងាយ ដោយពេបជ្រាយ ដោយមិនអត់ធ្មត់ ដោយសំដីច្រើន ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយនឹងនៅច្របូកច្របល់ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការបញ្ចុកមិនកែអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកជំនិត្ត បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកគ្នា) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះចេញទេ ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ ការសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈគំរប់ពីរផង ។ បេ ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈគំរប់បីផង ។ បេ ។ សង្ឃបានសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញហើយ ។ ការសូត្រសមនុភាសនវិធីនោះគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយការស្ងៀមនៅយ៉ាងនេះ ។

[៨៤] ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា កម្មវាចាបរិយោសានេ អាបត្តិ សង្ឃាទិសេសស្ស ។ សង្ឃាទិសេសំ អជ្ឈាបជ្ជន្តិយា ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ ។

[៨៥] អយម្បីតិ បុរិមាយោ ឧបាទាយ វុច្ចតិ ។ យាវតតិយកន្តិ យាវតតិយំ សមនុភាសនាយ អាបជ្ជតិ ន សហ វីតិក្កមា ។ និស្សារណីយន្តិ សង្ឃម្ហា និស្សារីយតិ ។ សង្ឃាទិសេសោតិ សង្ឃោវ តស្សា អាបត្តិយា មានត្តំ ទេតិ មូលាយ បដិកស្សតិ អព្ភេតិ ន សម្ពហុលា ន ឯកា ភិក្ខុនី តេន វុច្ចតិ សង្ឃាទិសេសោតិ ។ តស្សេវ[១] អាបត្តិនិកាយស្ស នាមកម្មំ អធិវចនំ តេនបិ វុច្ចតិ សង្ឃាទិសេសោតិ ។

១ តស្សេវាតិទំ កត្ថចិ បោត្ថកេ ទិស្សតិ ។



[៨៤] ភិក្ខុនីនោះត្រូវទុក្កដដោយសូត្រញត្តិ ត្រូវថុល្លច្ច័យទាំងពីរក្លាយ ដោយសូត្រកម្មវាចាពីរលើក ចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស ។ កាលភិក្ខុនីត្រូវអាបត្តិសង្ឃាទិសេស អាបត្តិទុក្កដត្រូវដោយសូត្រញត្តិ នឹងអាបត្តិថុល្លច្ច័យទាំងពីរក្លាយ ដែលត្រូវដោយសូត្រកម្មវាចាពីរលើក ក៏ស្ងប់រម្ងាប់ទៅឯង ។

[៨៥] ត្រង់ពាក្យថា ភិក្ខុនីនេះក្តី គឺភិក្ខុនីនេះឯងដែលតថាគតពោល ប្រៀបផ្ទឹមនូវភិក្ខុនីទាំងឡាយមុនៗ ។ ពាក្យថា ឈ្មោះយាវតតិយក គឺភិក្ខុនីត្រូវ (សង្ឃាទិសេស) ដោយការសូត្រសមនុភាសនគម្រប់បីដង មិនមែនត្រូវមួយអន្លើដោយសេចក្តីប្រព្រឹត្តកន្លងទេ ។ ពាក្យថា គួរបណ្តេញចេញ គឺភិក្ខុនីទាំងឡាយគួរដេញភិក្ខុនីនោះចេញអំពីសង្ឃ ។ ពាក្យថា សង្ឃាទិសេស គឺមានតែសង្ឃឲ្យមានត្តដើម្បីអាបត្តិនោះ ទាញត្រឡប់អន្តរាបត្តិមកដាក់ក្នុងមូលាបត្តិបាន ឬឲ្យអព្ភានកម្ម ភិក្ខុនីច្រើនរូបឲ្យមិនបាន ភិក្ខុនីមួយរូបក៏ឲ្យមិនបាន ហេតុនោះបានជាអាបត្តិនិកាយនោះ តថាគតឲ្យឈ្មោះថា សង្ឃាទិសេស ។ ពាក្យថា អាបត្តិសង្ឃាទិសេសជានាមកម្ម គឺជាឈ្មោះនៃអាបត្តិនិកាយនោះឯង ព្រោះហេតុនោះ អាបត្តិនិកាយនោះ តថាគតហៅថា សង្ឃាទិសេស ។

(៤០) ធម្មកម្មេ ធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ វេមតិកា នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

(៤១) អនាបត្តិ អសមនុភាសន្តិយា បដិនិស្សជ្ជន្តិយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

(៤២) ឧទ្ទិដ្ឋា ខោ អយ្យាយោ សត្តរស សង្ឃាទិសេសា ធម្មា នវ បឋមាបត្តិកា អដ្ឋ យាវតតិយកា យេសំ ភិក្ខុនី អញ្ញតរំ វា អញ្ញតរំ វា អាបជ្ជតិ តាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ



(៤០) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៤១) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ (សង្ឃ) មិនបានសូត្រសមនុភាសនៅឡើយ ១ ភិក្ខុនីបានលះបង់ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១[១] ។

(៤២) បពិត្រនាងម្ចាស់ទាំងឡាយ អាបត្តិសង្ឃាទិសេសទាំង ១៧ នុ៎ះ ខ្ញុំសំដែងឡើងហើយ អាបត្តិ ៩ ឈ្មោះបឋមាបត្តិកា អាបត្តិ ៨ ឈ្មោះយាវតតិយកា បណ្ដាអាបត្តិទាំង ១៧ នេះ ភិក្ខុនីអង្គណា ត្រូវអាបត្តិណា ។ ភិក្ខុនីអង្គនោះត្រូវប្រព្រឹត្តបក្ខមានត្តក្នុងសង្ឃទាំងពីរ ភិក្ខុនីដែលប្រព្រឹត្ត

១ ព្រះធម្មវិភង្គបទទៀតដែលមិនបានសំដែងនោះ លោកថា ព្រោះដូចគ្នានឹងសិក្ខាបទក្នុងភិក្ខុវិភង្គហើយ ។

ចិណ្ណមានត្តាយ ភិក្ខុនិយា[1] យត្ថ សិយា វីសតិគណោ ភិក្ខុនីសង្ឃោ តត្ថ សា ភិក្ខុនី អព្ភេតព្វា ។ ឯកាយបិ ចេ ឩនោ វីសតិគណោ ភិក្ខុនីសង្ឃោ តំ ភិក្ខុនឹ អព្ភេយ្យ សា ច ភិក្ខុនី អនព្ភិតា តា ច ភិក្ខុនិយោ គារយ្ហា ។ អយំ តត្ថ សាមីចិ ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

សត្តរសកណ្ឌំ និដ្ឋិតំ ។

---

១- ឱមេ បាឋា ទាំងបីយោគ្គរេ ចិណ្ណមានត្តា ភិក្ខុនី សោធិតា ។ ន សុះសាធិត ចិណ្ណមានត្តោ ភិក្ខុនី បាឡិយា សមេន្តា ។



មានត្តហើយ បើភិក្ខុនីសង្ឃពួក ២០ រូបមានក្នុងទីណា ភិក្ខុនីសង្ឃត្រូវអព្ភានភិក្ខុនីនោះ ក្នុងទីនោះ បើភិក្ខុនីសង្ឃពួក ២០ រូប ខ្វះសូម្បីតែភិក្ខុនី ១ រូប ហ៊ានអព្ភានភិក្ខុនីនោះ ភិក្ខុនីនោះឈ្មោះថា ភិក្ខុនីសង្ឃមិនទាន់អព្ភានទេ ភិក្ខុនីទាំងឡាយនោះឈ្មោះថា ត្រូវគេត្រះជំមាន ព្រោះការតិះដៀលផង ។ នេះជាសាមីចិកម្មក្នុងរឿងនោះ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់បីផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងអាបត្តិទាំងនេះ ហេតុនោះទើបលោកម្ចាស់ទាំងឡាយស្ងៀម ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

សង្ឃាទិសេសកណ្ឌ ១៧ សិក្ខាបទ ចប់ ។

# និស្សគ្គិយកណ្ឌំ

ឥមេ ខោ បនយ្យាយោ តឹស និស្សគ្គិយា
បាចិត្តិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## បត្តវគ្គស្ស បឋមសិក្ខាបទំ

(៨៣) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ ពហុបត្តេ សន្និចយំ ករោន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ពហុបត្តេ សន្និចយំ ករិស្សន្តិ បត្តវាណិជ្ជំ វា ភិក្ខុនិយោ ករិស្សន្តិ អាមត្តិកាបណំ វា បសារេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ បត្តសន្និចយំ ករិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា

# និស្សគ្គិយកណ្ឌ

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះនិស្សគ្គិយ
បាចិត្តិយមានចំនួន៣០នេះឯង តែងមកកាន់ឧទ្ទេស ។

## បត្តវគ្គ សិក្ខាបទទី ១

(៨៣) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយមានពួក ៦ ធ្វើនូវសេចក្តីសន្សំបាត្រជាច្រើន ។ មនុស្សទាំងឡាយ ដើរទៅកាន់ចារិកវិហារ បានឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុម្តេចក៏ភិក្ខុនីទាំងឡាយធ្វើនូវសេចក្តីសន្សំបាត្រដ៏ច្រើនម៉្លេះ ឬភិក្ខុនីទាំងឡាយនឹងធ្វើជំនួញបាត្រ ឬនឹងដាក់កន្លែងលក់ភាជនៈដី ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមានពួក ៦ មិនសមបើនឹងធ្វើសេចក្តីសន្សំបាត្រដូច្នេះសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមានពួក ៦

ភិក្ខុនិយោ បត្តសន្និចយំ ករោន្តីតិ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា
ភិក្ខុនិយោ បត្តសន្និចយំ ករិស្សន្តិ នេតំ ភិក្ខវេ អប្ប-
សន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ
ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី
បត្តសន្និចយំ ករេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[៨៦] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ
។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។
បត្តោ នាម ទ្វេ បត្តា អយោបត្តោ មត្តិកាបត្តោ ។
តយោ បត្តស្ស វណ្ណា ឧក្កដ្ឋោ បត្តោ មជ្ឈិមោ
បត្តោ ឱមកោ បត្តោ ។ ឧក្កដ្ឋោ នាម បត្តោ
អឌ្ឍាឡ្ហកោទនំ គណ្ហាតិ ចតុភាគំ ខាទនំ(១) តទុបិយំ
ព្យញ្ជនំ ។ មជ្ឈិមោ នាម បត្តោ នាឡិកោទនំ
គណ្ហាតិ ចតុភាគំ ខាទនំ តទុបិយំ ព្យញ្ជនំ ។
ឱមកោ នាម បត្តោ បត្ថោទនំ គណ្ហាតិ ចតុភាគំ
ខាទនំ តទុបិយំ ព្យញ្ជនំ ។ តតោ ឧក្កដ្ឋោ អបត្តោ

១ ម. ឆ. ខាទនីយំ ។



ធ្វើនូវសេចក្ដីសន្សំបាត្រដូច្នេះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា
បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ
ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមានពួក ៦
មិនគួរបើនឹងធ្វើសេចក្ដីសន្សំបាត្រដូច្នេះទេ ម្នាលភិក្ខុទាំងឡាយ ការណ៍នេះ
មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាល
ភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា
ភិក្ខុនីណាមួយធ្វើសេចក្ដីសន្សំបាត្រ ភិក្ខុនីនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

[៨៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទ
ទី ១ នៃបាតកដ៏កណ្ឌរួចហើយ ។ បាត្រ ២ យ៉ាង គឺបាត្រដែក ១ បាត្រដី ១
ឈ្មោះថា បាត្រ ។ ប្រមាណរបស់បាត្រមាន ៣ យ៉ាង គឺបាត្រខ្នាតធំ ១
បាត្រខ្នាតកណ្ដាល ១ បាត្រខ្នាតតូច ១ ។ ដែលហៅថា បាត្រខ្នាតធំ
គឺ បាត្រចំណុះបាយនៃអឌ្ឍកន្លះអាឡ្ហក ទំនប់ស្មើភាគទី ៤ ទំនួប
សមគួរនឹងបាយនោះ ។ ដែលហៅថា បាត្រខ្នាតកណ្ដាល គឺ បាត្រចំណុះ
បាយនៃនាឡិ ១ តាំងទំនប់ស្មើភាគទី ៤ ទំនួបសមគួរដល់បាយនោះ ។
ដែលហៅថា បាត្រខ្នាតតូច គឺ បាត្រចំណុះបាយនៃបត្ថ ១ មានទំនប់ស្មើ
ភាគទី ៤ ទំនួបសមគួរដល់បាយនោះ ។ បាត្រដែលមានខ្នាតធំហួស

ឱមកោ អបត្តោ ។ សន្និចយំ ករេយ្យាតិ អនធិដ្ឋិតោ អវិកប្បិតោ ។ និស្សគ្គិយោ ហោតិ(១) សហ អរុណុគ្គ-មនា និស្សគ្គិយោ ហោតិ និស្សជ្ជិតព្វោ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វោ ។

[៤៨] តាយ ភិក្ខុនិយា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អយំ មេ អយ្យេ បត្តោ រត្តាតិក្កន្តោ និស្សគ្គិយោ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេ-តព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ អាបត្តិ បដិគ្គ-ហេតព្វា ។ និស្សដ្ឋបត្តោ ទាតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ បត្តោ ឥត្ថន្នាមាយ ភិក្ខុនិយា និស្សគ្គិ-យោ សង្ឃស្ស និស្សដ្ឋោ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ បត្តំ ឥត្ថន្នាមាយ ភិក្ខុនិយា ទទេយ្យាតិ ។

១ សីហ. បរំ សព្វត្ថ និស្សគ្គោ ទិស្សតិ សោ អតិរេកាតិ បទំ វិភត្តោ ត្វេវ សាធុ ហោតិ មតិការំ អនាគតត្តា ។



ជាទីកំណត់ដែលពោលហើយនោះ មិនហៅថាបាត្រ ។ ពាក្យថា ធ្វើសេចក្ដីសន្សំ (បាត្រ) គឺបានដល់បាត្រ (ឯទៀតៗ) ដែលភិក្ខុនីមិនបាន អធិដ្ឋាន មិនបានវិកប្ប ។ បាត្រនោះជានិស្សគ្គិយ គឺជានិស្សគ្គិយ ព្រមគ្នានឹងអរុណរះឡើង បាត្រនោះភិក្ខុនីត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនី ១ រូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ បាត្រនោះភិក្ខុនីត្រូវលះយ៉ាងនេះ ។

[៤៨] ភិក្ខុនីនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងភិក្ខុនីចាស់ៗ អង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ បាត្ររបស់ខ្ញុំនេះកន្លងរាត្រីហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបាត្រនេះដល់សង្ឃ ។ លុះភិក្ខុនីនោះលះរួចហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុនីដែលឈ្លាសប្រតិពលគប្បីទទួលអាបត្តិ ។ ភិក្ខុនីសង្ឃត្រូវឲ្យបាត្រដែលភិក្ខុនីលះហើយនោះវិញដោយពាក្យថា បពិត្រលោកម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ បាត្រនេះជានិស្សគ្គិយ ភិក្ខុនីឈ្មោះនេះបានលះដល់សង្ឃហើយ ។ បើការលះបង់នេះសមគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យបាត្រនេះដល់ភិក្ខុនីឈ្មោះនេះវិញ ។

(៤៦) តាយ ភិក្ខុនិយា សម្ពហុលា ភិក្ខុនិយោ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្សុ វចនីយា អយំ មេ អយ្យាយោ បត្តោ រត្តាតិក្កន្តោ និស្សគ្គិយោ ឥមាហំ អយ្យានំ និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ អាបត្តិ បដិគ្គហេតព្វា ។ និស្សដ្ឋបត្តោ ទាតព្វោ សុណន្តុ មេ អយ្យាយោ អយំ បត្តោ ឥត្ថន្នាមាយ ភិក្ខុនិយា និស្សគ្គិយោ អយ្យានំ និស្សដ្ឋោ ។ យទិ អយ្យានំ បត្តកល្លំ អយ្យាយោ ឥមំ បត្តំ ឥត្ថន្នាមាយ ភិក្ខុនិយា ទទេយ្យុន្តិ ។

(៤៧) តាយ ភិក្ខុនិយា ឯកំ ភិក្ខុនឹ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អយំ មេ អយ្យេ បត្តោ រត្តាតិក្កន្តោ និស្សគ្គិយោ ឥមាហំ អយ្យាយ



(៤៦) ភិក្ខុនីនោះត្រូវចូលទៅរកភិក្ខុនីច្រើនរូប (២-៣ រូប) ហើយធ្វើឧត្តរាសង្គៀងស្មាម្ខាងហើយថ្វាយបង្គំជើងភិក្ខុនីចាស់ ៗ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ បាត្ររបស់ខ្ញុំនេះកន្លងរាត្រីហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបាត្រនេះដល់លោកម្ចាស់ទាំងឡាយ ។ លុះភិក្ខុនីនោះលះបាត្រហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុនីដែលឈ្លាសប្រតិពលគប្បីទទួលអាបត្តិ ។ ភិក្ខុនីទាំងឡាយត្រូវឲ្យបាត្រដែលភិក្ខុនីនោះលះហើយដោយពាក្យថា សូមលោកម្ចាស់ទាំងឡាយស្តាប់ខ្ញុំ បាត្រនេះរបស់ភិក្ខុនីឈ្មោះនេះ ជានិស្សគ្គិយ បានលះដល់លោកម្ចាស់ទាំងឡាយហើយ ។ បើកាលៈបរិច្ឆេទសមគួរដល់លោកម្ចាស់ទាំងឡាយហើយ លោកម្ចាស់ទាំងឡាយ ត្រូវឲ្យបាត្រនេះដល់ភិក្ខុនីឈ្មោះនេះវិញ ។

(៤៧) ភិក្ខុនីនោះត្រូវចូលទៅរកភិក្ខុនី ១ រូប ធ្វើឧត្តរាសង្គៀងស្មាម្ខាងហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង រួចពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ បាត្ររបស់ខ្ញុំនេះកន្លងរាត្រីហើយ ជានិស្សគ្គិយ

និស្សជ្ជាមីតិ ។ និស្សជ្ជិត្វា អាបត្តិ ទេសេតព្វា ។ តាយ ភិក្ខុនិយា អាបត្តិ បដិគ្គហេតព្វា ។ និស្សដ្ឋបត្តោ ទាតព្វោ ឥមំ បត្តំ អយ្យាយ ទម្មីតិ ។

(៩៨) រត្តាតិក្កន្តេ អតិក្កន្តសញ្ញា និស្សគ្គិយំ បាចិត្តិយំ ។ រត្តាតិក្កន្តេ វេមតិកា និស្សគ្គិយំ បាចិត្តិយំ ។ រត្តាតិក្កន្តេ អនតិក្កន្តសញ្ញា និស្សគ្គិយំ បាចិត្តិយំ ។ អនធិដ្ឋិតេ អធិដ្ឋិតសញ្ញា និស្សគ្គិយំ បាចិត្តិយំ ។ អវិកប្បិតេ វិកប្បិតសញ្ញា និស្សគ្គិយំ បាចិត្តិយំ ។ អវិស្សជ្ជិតេ វិស្សជ្ជិតសញ្ញា និស្សគ្គិយំ បាចិត្តិយំ ។ អនដ្ឋេ នដ្ឋសញ្ញា... អវិនដ្ឋេ វិនដ្ឋសញ្ញា... អភិន្នេ ភិន្នសញ្ញា... អវិលុត្តេ វិលុត្តសញ្ញា និស្សគ្គិយំ បាចិត្តិយំ ។





ខ្ញុំសូមលះបាត្រនេះដល់លោកម្ចាស់ ។ លុះភិក្ខុនីនោះលះបង់បាត្រហើយ ត្រូវសំដែងអាបត្តិចេញ ។ ភិក្ខុនី ១ រូបនោះគប្បីទទួលអាបត្តិ ។ ភិក្ខុនី ១ រូបត្រូវឲ្យបាត្រដែលភិក្ខុនីនោះលះហើយដោយពាក្យថា ខ្ញុំឲ្យបាត្រនេះដល់លោកម្ចាស់វិញ ។

(៩៨) បាត្រកន្លងរាត្រីហើយ ភិក្ខុនីសំគាល់ថាកន្លងហើយ ត្រូវនិស្សគ្គិយបាចិត្តិយ ។ បាត្រកន្លងរាត្រីហើយ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ ។ បាត្រកន្លងរាត្រីហើយ ភិក្ខុនីសំគាល់ថាមិនទាន់កន្លងទេ ត្រូវនិស្សគ្គិយបាចិត្តិយ ។ បាត្រមិនបានអធិដ្ឋានទេ ភិក្ខុនីសំគាល់ថាអធិដ្ឋានហើយ ត្រូវនិស្សគ្គិយបាចិត្តិយ ។ បាត្រមិនបានវិកប្បទេ ភិក្ខុនីសំគាល់ថាវិកប្បហើយ ត្រូវនិស្សគ្គិយបាចិត្តិយ ។ បាត្រមិនបានលះទេ ភិក្ខុនីសំគាល់ថាលះហើយ ត្រូវនិស្សគ្គិយបាចិត្តិយ ។ បាត្រមិនបានបាត់ទេ ភិក្ខុនីសំគាល់ថាបាត់ហើយ បាត្រមិនបានវិនាសទេ ភិក្ខុនីសំគាល់ថាវិនាសហើយ... បាត្រមិនបានបែកទេ ភិក្ខុនីសំគាល់ថាបែកហើយ... បាត្រគេមិនបានដណ្ដើមយកទេ ភិក្ខុនីសំគាល់ថាគេដណ្ដើមយកហើយ ត្រូវនិស្សគ្គិយបាចិត្តិយ ។

[៩៩] និស្សគ្គិយំ បត្តំ អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ រត្តានតិក្កន្តេ អតិក្កន្តសញ្ញា អាបត្តិ ទុក្កដស្ស ។ រត្តានតិក្កន្តេ វេមតិកា អាបត្តិ ទុក្កដស្ស ។ រត្តានតិក្កន្តេ អនតិក្កន្តសញ្ញា អនាបត្តិ ។

(១០០) អនាបត្តិ អន្តោអរុណំ អធិដ្ឋេតិ វិកប្បេតិ វិស្សជ្ជេតិ នស្សតិ វិនស្សតិ ឌយ្ហតិ អច្ឆិន្ទិត្វា គណ្ហន្តិ វិស្សាសំ គណ្ហន្តិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

(១០១) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ និស្សដ្ឋបត្តំ ន ទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា និស្សដ្ឋបត្តោ ន ទាតព្វោ យា ន ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។





[៩៩] ភិក្ខុនីមិនលះបង់បាត្រដែលជានិស្សគ្គិយៈហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ រាត្រីមិនបានកន្លងទៅ ភិក្ខុនីសំគាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ ។ រាត្រីមិនបានកន្លងទៅ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ រាត្រីមិនបានកន្លងទៅ ភិក្ខុនីសំគាល់ថាមិនទាន់កន្លងទៅ មិនត្រូវអាបត្តិ ។

[១០០] អ.ដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១០ យ៉ាង) គឺភិក្ខុនីអធិដ្ឋានក្នុងអរុណ ១ វិកប្បទុកក្នុងអរុណ ១ លះបង់ (បាត្រនោះ) ខាងក្នុងអរុណ ១ បាត្រខូចខាងក្នុងអរុណ ១ វិនាសខាងក្នុងអរុណ ១ បែកខាងក្នុងអរុណ ១ ពួកចោរដណ្តើមយកខាងក្នុងអរុណ ១ គេកាន់យកដោយវិស្សាសខាងក្នុងអរុណ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

[១០១] សម័យនោះឯង ភិក្ខុនីទាំងឡាយមានពួក ៦ មិនឲ្យបាត្រដែលភិក្ខុនីដទៃលះបង់នោះវិញ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវមិនឲ្យបាត្រដែលភិក្ខុនីដទៃលះបង់ហើយនោះទេ ភិក្ខុនីណាមិនឲ្យ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដ ។

## បត្តវគ្គស្ស ទុតិយសិក្ខាបទំ

[១០៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខុនិយោ គាមកាវាសេ វស្សំវុដ្ឋា សាវត្ថឹ អគមំសុ វត្តសម្បន្នា ឥរិយាបថសម្បន្នា ទុច្ចោឡា លូខចីវរា ។ ឧបាសកា តា ភិក្ខុនិយោ បស្សិត្វា ឥមា ភិក្ខុនិយោ វត្តសម្បន្នា ឥរិយាបថសម្បន្នា ទុច្ចោឡា លូខចីវរា ឥមា ភិក្ខុនិយោ អច្ឆិន្នា ភវិស្សន្តីតិ ភិក្ខុនិសង្ឃស្ស អកាលចីវរំ អទំសុ ។ ថុល្លនន្ទា ភិក្ខុនី អម្ហាកំ កឋិនំ អត្ថតំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេសិ ។ ឧបាសកា តា ភិក្ខុនិយោ បស្សិត្វា ឯតទវោចុំ អបយ្យាហិ ចីវរំ លទ្ធន្តិ ។ ន មយំ អាវុសោ ចីវរំ លភាម អយ្យា ថុល្លនន្ទា អម្ហាកំ កឋិនំ អត្ថតំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេសីតិ ។ ឧបាសកា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

## បត្តវគ្គ សិក្ខាបទទី ២

[១០៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ភិក្ខុនីទាំងឡាយច្រើនរូបគង់នៅចាំវស្សាក្នុងទីអាវាសដែលតាំងនៅស្រុកក្រៅ រួចហើយក៏ដើរទៅកាន់ក្រុងសាវត្ថី ជាអ្នកមានវត្តល្អ មានឥរិយាបថល្អ តែមានសំពត់អាក្រក់ មានចីវរសៅហ្មង ។ ពួកឧបាសកឃើញភិក្ខុនីទាំងឡាយនោះហើយក៏គិតគ្នាថា ភិក្ខុនីទាំងឡាយនេះបរិបូណ៌ដោយវត្ត បរិបូណ៌ដោយឥរិយាបថ តែមានសំពត់អាក្រក់ មានចីវរសៅហ្មង ភិក្ខុនីទាំងនេះប្រហែលជាចោរដណ្តើមយក (ចីវរ) ទេដឹង ហើយក៏បានថ្វាយអកាលចីវរដល់ភិក្ខុនីសង្ឃ ។ ថុល្លនន្ទាភិក្ខុនីក៏អធិដ្ឋានថា ពួកយើងបានក្រាលកឋិនហើយ សំពត់នេះជាកាលចីវរ ហើយក៏ប្រើឲ្យចែក (អកាលចីវរនោះ) ។ ពួកឧបាសកបានឃើញភិក្ខុនីទាំងឡាយនោះហើយ បានពោលពាក្យនេះថា លោកម្ចាស់ទាំងឡាយបានចីវរហើយឬ ។ ភិក្ខុនីទាំងឡាយនោះឆ្លើយថា នែអាវុសោ ពួកយើងមិនបានចីវរទេ ថុល្លនន្ទាជាម្ចាស់អធិដ្ឋានថា យើងបានក្រាលកឋិនហើយ (សំពត់នេះ) ជាកាលចីវរ ក៏ប្រើឲ្យចែក (អកាលចីវរនោះ) ។ ឧបាសកទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់

កថំ ហិ នាម អយ្យា ថុល្លនន្ទា អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ ឧបាសកានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេតីតិ[១] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

១ ម. ឱ. ភាជាបេសីតិ ។



ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរដូច្នេះ ហើយប្រើឲ្យចែក (អកាលចីវរនោះ) សោះ ។ ភិក្ខុនីទាំងឡាយបានឮពួកឧបាសកទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរហើយប្រើឲ្យចែកសោះ ។ ទើបភិក្ខុនីទាំងនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរហើយប្រើឲ្យចែក ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរហើយប្រើឲ្យចែកសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះដែលថុល្លនន្ទាភិក្ខុនីធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរហើយប្រើឲ្យចែក ភិក្ខុនីនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

[១០៣] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អកាលចីវរំ នាម អនត្ថតេ កឋិនេ ឯកាទសមាសេ ឧប្បន្នំ អត្ថតេ កឋិនេ សត្តមាសេ ឧប្បន្នំ កាលេបិ អាទិស្ស ទិន្នំ ឯតំ អកាលចីវរំ នាម ។ កាលចីវរន្តិ(១) អធិដ្ឋហិត្វា ភាជាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ អយ្យេ អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អយ្យាយ ទម្មីតិ ។

[១០៤] អកាលចីវរេ អកាលចីវរសញ្ញា កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អកាលចីវរេ វេមតិកា កាលចីវរន្តិ អធិដ្ឋហិត្វា

១ ឱ. ស្យាមស្ស បច្ឆិមេ មាសេ កាលចីវរន្តិ ករិត្វា ហោតូតិ ទិស្សតិ ។



[១០៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃពួកនិស្សគ្គិយរួចហើយ ។ ដែលហៅថា អកាលចីវរ គឺកាលបើភិក្ខុនីមិនបានក្រាលកឋិន ចីវរដែលកើតឡើងក្នុង ១១ ខែ (គឺតាំងពី ១ រោច ខែកត្តិក ទៅដល់ ១៥ កើត ខែអស្សុជ) កាលបើភិក្ខុនីបានក្រាលកឋិន ចីវរដែលកើតឡើងក្នុង ៧ ខែ (គឺតាំងពី ១ រោច ខែផល្គុន ទៅដល់ ១៥ កើត ខែអស្សុជ) ចីវរនេះបើទុកជាទាយកប្រគេនចំពោះថាជាកាលចីវរ ក៏នៅតែហៅថា អកាលចីវរដដែល ។ ភិក្ខុនីអធិដ្ឋានជាកាលចីវរ ហើយប្រើគេឲ្យចែក ត្រូវអាបត្តិទុក្កដក្នុងប្រយោគ ចីវរនោះជានិស្សគ្គិយ ក្នុងពេលដែលបានមក ភិក្ខុនីត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន ភិក្ខុនី ១ រូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ឯចីវរនោះ ត្រូវភិក្ខុនីលះយ៉ាងនេះ ។ បេ ។ បពិត្រលោកម្ចាស់ ចីវរនេះជាអកាលចីវរ ខ្ញុំអធិដ្ឋានជាកាលចីវរ ហើយប្រើគេឲ្យចែក ជានិស្សគ្គិយ (ត្រូវតែលះ) ខ្ញុំសូមលះចីវរនេះដល់សង្ឃ (ពាក្យតពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌនេះហើយ) ។

[១០៤] អកាលចីវរ ភិក្ខុនីសំគាល់ថា អកាលចីវរ ហើយអធិដ្ឋានឲ្យជាកាលចីវរ ហើយប្រើគេឲ្យចែក ត្រូវនិស្សគ្គិយបាចិត្តិយ ។ អកាលចីវរ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយអធិដ្ឋានឲ្យជាកាលចីវរ ហើយ

ភាជាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អកាលចីវរេ កាលចីវរសញ្ញា កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ កាលចីវរេ អកាលចីវរសញ្ញា អាបត្តិ ទុក្កដស្ស ។ កាលចីវរេ វេមតិកា អាបត្តិ ទុក្កដស្ស ។ កាលចីវរេ កាលចីវរសញ្ញា អនាបត្តិ ។

(១០៥) អនាបត្តិ អកាលចីវរំ អកាលចីវរសញ្ញា ភាជាបេតិ កាលចីវរំ កាលចីវរសញ្ញា ភាជាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## បត្តវគ្គស្ស តតិយសិក្ខាបទំ

(១០៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី អញ្ញតរាយ[១] ភិក្ខុនិយា សទ្ធិំ ចីវរំ បរិវត្តេត្វា[២] បរិភុញ្ជតិ ។ អថខោ សា ភិក្ខុនី តំ ចីវរំ សង្ហរិត្វា[៣] និក្ខិបិ ។ ថុល្លនន្ទា

១ ម. អញ្ញតរិស្សា ។ ២ សព្វត្ថ បរិវត្តេត្វាតិ ទិស្សតិ ។ ៣ ម. យ. សំហរិត្វា ។



ប្រើគេឲ្យចែក ត្រូវនិស្សគ្គិយបាចិត្តិយ ។ អកាលចីវរ ភិក្ខុនីសំគាល់ថាកាលចីវរ ហើយអធិដ្ឋានឲ្យជាកាលចីវរ ហើយប្រើគេឲ្យចែក ត្រូវនិស្សគ្គិយបាចិត្តិយ ។ កាលចីវរ ភិក្ខុនីសំគាល់ថាអកាលចីវរ ត្រូវអាបត្តិទុក្កដ ។ កាលចីវរ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលចីវរ ភិក្ខុនីសំគាល់ថាកាលចីវរ មិនត្រូវអាបត្តិ ។

(១០៥) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺអកាលចីវរ ភិក្ខុនីសំគាល់ថាអកាលចីវរមែន ហើយប្រើគេឲ្យចែក (អកាលចីវរនោះ)១ កាលចីវរ ភិក្ខុនីសំគាល់ថាកាលចីវរមែន ហើយប្រើគេឲ្យចែក (កាលចីវរនោះ)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាអាទិកម្មិក១ ។

---

## បត្តវគ្គ សិក្ខាបទទី ៣

(១០៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីដូរចីវរនឹងភិក្ខុនីមួយរូប ហើយប្រើប្រាស់ ទើបភិក្ខុនីនោះបត់ចីវរនោះ ហើយទុកដាក់ទៅ ។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា

ភិក្ខុនី តំ ភិក្ខុនឹ ឯតទវោច យន្តេ អយ្យេ មយា សទ្ធឹ ចីវរំ បរិវត្តិតំ កហំ តំ ចីវរន្តិ ។ អថខោ សា ភិក្ខុនី តំ ចីវរំ នីហរិត្វា ថុល្លនន្ទាយ ភិក្ខុនិយា ទស្សេសិ ។ ថុល្លនន្ទា ភិក្ខុនី តំ ភិក្ខុនឹ ឯតទវោច ហន្ទយ្យេ តុយ្ហំ ចីវរំ អាហរ មេតំ ចីវរំ យំ តុយ្ហំ តុយ្ហមេវេតំ យំ មយ្ហំ មយ្ហមេវេតំ អាហរ មេ តំ សកំ បច្ចាហរាតិ អច្ឆិន្ទិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ភិក្ខុនិយា សទ្ធឹ ចីវរំ បរិវត្តេត្វា អច្ឆិន្ទិស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភិក្ខុនិយា សទ្ធឹ ចីវរំ បរិវត្តេត្វា អច្ឆិន្ទតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភិក្ខុនិយា សទ្ធឹ ចីវរំ បរិវត្តេត្វា



បពិត្រលោកម្ចាស់ ចីវរដែលលោកម្ចាស់ដូរនឹងខ្ញុំ ចីវរនោះនៅឯណា ។ ឯភិក្ខុនីនោះយកចីវរនោះចេញមកបង្ហាញដល់ថុល្លនន្ទាភិក្ខុនី ។ ថុល្លនន្ទាភិក្ខុនីបានពោលពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ លោកម្ចាស់យកចីវររបស់លោកទៅវិញចុះ លោកម្ចាស់ឲ្យចីវរខ្ញុំមកខ្ញុំ ចីវរណារបស់លោក ចីវរនោះជារបស់លោកដដែល ចីវរណារបស់ខ្ញុំ ចីវរនោះជារបស់ខ្ញុំដដែលវិញ លោកម្ចាស់ឲ្យចីវរនោះមកខ្ញុំ លោកម្ចាស់ចូរយកចីវររបស់លោកទៅវិញចុះ ហើយក៏ដណ្តើមយកទៅ ។ ទើបភិក្ខុនីនោះបានប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទាមិនសមបើមកប្តូរចីវរនឹងភិក្ខុនីដទៃគ្នា ហើយដណ្តើមយកទៅវិញសោះ ។ ភិក្ខុនីទាំងឡាយនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយគឺភិក្ខុទាំងឡាយនោះឯង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីប្តូរចីវរនឹងភិក្ខុនីដទៃគ្នា ហើយដណ្តើមយកទៅវិញ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើមកប្តូរចីវរនឹងភិក្ខុនីដទៃគ្នា ហើយដណ្តើមយកទៅវិញទេ

អច្ឆិន្ទិស្សតិ ។ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ភិក្ខុនិយា សទ្ធឹ ចីវរំ បរិវត្តេត្វា សា បច្ឆា ឯវំ វទេយ្យ ហន្ទយ្យេ តុយ្ហំ ចីវរំ អាហរ មេតំ ចីវរំ យំ តុយ្ហំ តុយ្ហមេវេតំ យំ មយ្ហំ មយ្ហមេវេតំ អាហរ មេ តំ សកំ បច្ចាហរាតិ អច្ឆិន្ទេយ្យ វា អច្ឆិន្ទាបេយ្យ វា និស្សគ្គិយំ បាចិត្តិយន្តិ ។

(១០៧) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុនិយា សទ្ធិន្តិ អញ្ញាយ ភិក្ខុនិយា សទ្ធឹ ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បុបគំ បច្ឆិមំ ។ បរិវត្តេត្វាតិ បរិត្តេន វា វិបុលំ វិបុលេន វា បរិត្តំ បរិវត្តេត្វា[១] ។ អច្ឆិន្ទេយ្យាតិ សយំ អច្ឆិន្ទតិ និស្សគ្គិយំ[២] ហោតិ ។ អច្ឆិន្ទាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស សកឹ អាណត្តា ពហុកម្បិ អច្ឆិន្ទតិ

១ ម. ម. បរិវត្តេតិ ។ ២ សព្វត្ថ និស្សគ្គិយំ បាចិត្តិយន្តិ ទិស្សតិ ។



ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ប្តូរចីវរនឹងភិក្ខុនីដទៃគ្នា ហើយភិក្ខុនីនោះក្រឡប់ពោលយ៉ាងនេះក្នុងកាលជាខាងក្រោយថា បពិត្រលោកម្ចាស់ ណ្ហើយចុះ លោកចូរយកចីវររបស់លោកទៅវិញចុះ លោកចូរឲ្យចីវរនោះមកខ្ញុំវិញ ចីវរណារបស់លោក ចីវរនោះជារបស់លោកដដែល ចីវរណារបស់ខ្ញុំ ចីវរនោះជារបស់ខ្ញុំដដែលវិញ លោកចូរឲ្យចីវរនោះមកខ្ញុំ លោកចូរនាំយកចីវររបស់លោកទៅវិញចុះ (ហើយ) ដណ្ដើមយកឯងក្តី ប្រើគេឲ្យដណ្ដើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ ។

(១០៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ នោះសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា នឹងភិក្ខុនីដទៃគ្នា គឺមួយអន្លើដោយភិក្ខុនីដទៃ ។ ដែលហៅថា ចីវរ គឺចីវរ ៦ យ៉ាង ចីវរណាមួយយ៉ាងតូចបំផុតដែលគួរវិកប្បបាន ។ ពាក្យថា ប្តូរ គឺប្តូរនូវចីវរថ្លៃច្រើនដោយចីវរថ្លៃតិចក្តី នូវចីវរថ្លៃតិចដោយចីវរថ្លៃច្រើនក្តី ។ ពាក្យថា ដណ្ដើមយកឯង គឺភិក្ខុនីដណ្ដើមខ្លួនឯង ចីវរនោះជានិស្សគ្គិយ ។ ពាក្យថា ប្រើគេឲ្យដណ្ដើមយក គឺភិក្ខុនីបង្គាប់អ្នកដទៃ ត្រូវអាបត្តិទុក្កដ ភិក្ខុនីបង្គាប់តែម្តង អ្នកទទួលបង្គាប់ដណ្ដើមច្រើនដង ចីវរនោះជានិស្សគ្គិយ

និស្សគ្គិយំ ហោតិ ចជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា[១] វា ។ ឯវញ្ច បន ភិក្ខវេ ចជិតព្វំ ។បេ។ ឥទំ មេ អយ្យេ ចីវរំ ភិក្ខុនិយា សទ្ធិំ បរិវត្តេត្វា អច្ឆិន្នំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។បេ។ ទទេយ្យាតិ ។បេ។ ទទេយ្យុន្តិ ។បេ។ អយ្យាយ ទម្មីតិ ។

(១០៨) ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា ចីវរំ បរិវត្តេត្វា អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា និស្សគ្គិយំ បាចិត្តិយំ ។ ឧបសម្បន្នាយ វេមតិកា ចីវរំ បរិវត្តេត្វា អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា និស្សគ្គិយំ បាចិត្តិយំ ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា ចីវរំ បរិវត្តេត្វា អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញំ បរិក្ខារំ បរិវត្តេត្វា អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ សទ្ធិំ ចីវរំ វា អញ្ញំ វា បរិក្ខារំ បរិវត្តេត្វា អច្ឆិន្ទតិ វា អច្ឆិន្ទាបេតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ

[១] ឱ. ម. ឯកភិក្ខុនិយា ឥតិ ទិស្សតិ ។



ភិក្ខុនីនោះត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនី ១ រូបក៏បាន ។ ម្នាលភិក្ខុនីទាំងឡាយ ចីវរនោះភិក្ខុនីត្រូវលះយ៉ាងនេះ ។បេ។ បពិត្រលោកម្ចាស់ ចីវរនេះខ្ញុំបានប្តូរនឹងភិក្ខុនីដទៃ ហើយដណ្តើមយកមកវិញ ជានិស្សគ្គិយ (ត្រូវលះ) ខ្ញុំសូមលះចីវរនេះដល់សង្ឃ ។ (ពាក្យតទៅនេះ ទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌនេះហើយ) ។

(១០៨) ឧបសម្បន្នា[១] ភិក្ខុនីសំគាល់ថាឧបសម្បន្នា ប្តូរចីវរ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ប្តូរចីវរ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាមិនមែនឧបសម្បន្នា ប្តូរចីវរ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីប្តូរបរិក្ខារដទៃ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីប្តូរចីវរក្តី បរិក្ខារដទៃក្តី នឹងអនុបសម្បន្នា ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា

[១] សំដៅយកភិក្ខុនី ស្រីក្រៅពីភិក្ខុនី ហៅថា អនុបសម្បន្នា ។

ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។

[១០៩] អនាបត្តិ សា ច ទេតិ តស្សា ច វិស្សាសេន្តី គណ្ហាតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## បត្តវគ្គស្ស ចតុត្ថសិក្ខាបទំ

[១១០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី គិលានា ហោតិ ។ អថខោ អញ្ញតរោ ឧបាសកោ យេន ថុល្លនន្ទា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោច កឹ តេ អយ្យេ អផាសុ កឹ អាហរីយតូតិ ។ សប្បិនា មេ អាវុសោ អត្ថោតិ ។ អថខោ សោ ឧបាសកោ អញ្ញតរស្ស អាបណិកស្ស ឃរា



ភិក្ខុនីស្គាល់ថា ជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីស្គាល់ថាជាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(១០៩) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុនី (ដែលទទួលបួរ) នោះឲ្យវិញ ១ ភិក្ខុនី (ជាម្ចាស់បួរ) ស្និទ្ធស្នាលនឹងភិក្ខុនី (ជាអ្នកទទួលបួរ) នោះ កាន់យកទៅ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

---

## បត្តវគ្គ សិក្ខាបទទី ៤

(១១០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីមានជម្ងឺ ។ លំដាប់នោះ ឧបាសកម្នាក់ចូលទៅរកថុល្លនន្ទាភិក្ខុនីដល់ទីនោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ សេចក្តីមិនសប្បាយកើតមានដល់លោកម្ចាស់ឬ លោកម្ចាស់ឲ្យខ្ញុំរកបស់អ្វីមក ។ ថុល្លនន្ទាភិក្ខុនីនិយាយថា នែអាវុសោ អាត្មាត្រូវការដោយទឹកដោះថ្លា ។ ទើបឧបាសកនោះទៅយកទឹកដោះថ្លា

ការាបណស្ស សព្វំ អាហរិត្វា ចុល្លធនុគ្គហ កិច្ចានំ-
យោ អហោសិ ។ ចុល្លធនុ កិច្ចានិ ឯវមាហ(១)ន មេ
អាវុសោ សព្វំ អត្ថោ តេលេន មេ អត្ថោតិ ។
អថ សោ ឧបាសកោ យេន សោ អាបណិកោ
តេនុបសង្កមិ ឧបសង្កមិត្វា តំ អាបណិកំ ឯតទវោច
ន គារយ្ហ(២)អយ្យាយ សព្វំ អត្ថោ តេលេន អត្ថោ
ហន្ទ តេ សព្វំ តេលំ មេ ទេហីតិ ។ សចេ មយំ
អយ្យ(៣)វិក្កីតំ កណ្ហំ បុន អាធិយិស្សាម កោ
អម្ហាកំ
កណ្ហំ វិក្កាយិស្សតិ សព្វស្ស កាយេន សព្វំ ហានំ
តេលស្ស កាយំ អាហារ តេលំ ហរិស្សសីតិ ។ អថ
សោ ឧបាសកោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ
ហិ នាម អយ្យា ចុល្លធនុ អញ្ញំ វិញ្ញាបេត្វា អញ្ញំ
វិញ្ញាបេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស
ឧបាសកស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។
យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ
ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ចុល្លធនុ

---

១ សំ ឯវមាហ ។ ម. យោ ឥតស្ស ២ ទិស្សតិ ។ ៤ ។ ម. កិំឆ្សោ ។ ៣ ។ ម.
អយ្យោ ។



មានធ្មេញ ១ គឺបារ៉ាបណ៍: គឺតាំងអ្នកផ្សារម្នាក់ហើយបានប្រែគនមជល់ជុល្ល-
ធនុគ្គហៈ ។ ចុល្លធនុគ្គហៈបាននិយាយយ៉ាងនេះថា នែអាវុសោ អាត្មា
មិនត្រូវការដោយទឹកដោះរាវទេ អាត្មាត្រូវការដោយប្រេងវិញ ។ ទើប
ឧបាសកនោះចូលទៅកាន់អ្នកផ្សារនោះ លុះចូលទៅដល់ហើយបាននិយាយ
ពាក្យនេះនឹងអ្នកផ្សារនោះថា នែអ្នកម្ចាស់ ព្រោះលោកម្ចាស់មិនត្រូវការ
ដោយទឹកដោះរាវទេ ត្រូវការតែប្រេង អ្នកចូរយកទឹកដោះរាវរបស់អ្នកទៅ
វិញចុះ ចូរឲ្យប្រេងដល់ខ្ញុំវិញ ។ អ្នកផ្សារនោះថា នែអ្នកម្ចាស់ បើយើង
នឹងទទួលរបស់ដែលយើងលក់ទៅហើយយកមកវិញ កាលណាយើងនឹង
លក់របស់ទាំង អ្នកនាំយកទឹកដោះរាវទៅដោយថ្លៃទិញទឹកដោះរាវហើយ
ចូរអ្នកនាំថ្លៃទិញប្រេងមក ទើបនឹងនាំយកប្រេងទៅបាន ។ ឧបាសកនោះ
ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ចុល្លធនុមិនសមបើ
នឹងសុំរបស់ដទៃ ហើយសុំរបស់ឯទៀតសោះ ។ ភិក្ខុទាំងឡាយ
បានឮឧបាសកនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។
ភិក្ខុទាំងឡាយឯណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយ
នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ចុល្លធនុ

អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបេស្សតីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនី អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

(១១១) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អញ្ញំ វិញ្ញាបេត្វាតិ យំកិញ្ចិ វិញ្ញាបេត្វា ។ អញ្ញំ វិញ្ញាបេយ្យាតិ តំ ឋបេត្វា អញ្ញំ វិញ្ញាបេតិ បយោគេ ទុក្កដំ



មិនសមបើនឹងសុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញសោះ ។ ទើបភិក្ខុនីទាំងឡាយនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីសុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងសុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយសុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

(១១១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា សុំរបស់ដទៃ គឺបានសុំរបស់ណាមួយរួចហើយ ។ ពាក្យថា សុំរបស់ឯទៀតវិញ គឺភិក្ខុនីវៀរលែងរបស់ដែលសុំនោះ ហើយសុំរបស់ឯទៀតវិញ ត្រូវទុក្កដក្នុងប្រយោគសុំ

បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ អយ្យេ អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អយ្យាយ ទម្មីតិ ។

[១០៦] អញ្ញេ អញ្ញសញ្ញា អញ្ញំ វិញ្ញាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញេ វេមតិកា អញ្ញំ វិញ្ញាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញេ អនញ្ញសញ្ញា អញ្ញំ វិញ្ញាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អនញ្ញេ អញ្ញសញ្ញា អនញ្ញំ វិញ្ញាបេតិ អាបត្តិ ទុក្កដស្ស ។ អនញ្ញេ វេមតិកា អនញ្ញំ វិញ្ញាបេតិ អាបត្តិ ទុក្កដស្ស ។ អនញ្ញេ អនញ្ញសញ្ញា អនាបត្តិ ។



របស់នោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះបង់របស់នោះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនីមួយរូបក៏បាន ។ ម្នាលភិក្ខុនីទាំងឡាយ ភិក្ខុនីត្រូវលះយ៉ាងនេះ ។ បេ ។ បពិត្រលោកម្ចាស់ របស់ដទៃនេះ ខ្ញុំសុំហើយខ្ញុំទៅសុំរបស់ឯទៀតវិញ ជានិស្សគ្គិយ ខ្ញុំសូមលះបង់នេះដល់សង្ឃ ។ (ពាក្យតពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌនេះហើយ) ។

(១០៦) របស់ដទៃ ភិក្ខុនីសំគាល់ថារបស់ដទៃ ហើយសុំរបស់ដទៃដែរទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសុំរបស់ដទៃដែរទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដទៃ ហើយសុំរបស់ដទៃដែរទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថារបស់ដទៃ ហើយសុំរបស់មិនមែនដទៃ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសុំរបស់មិនមែនដទៃ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដទៃ មិនត្រូវអាបត្តិ ។

[១១៣] អនាបត្តិ តញ្ញេវ វិញ្ញាបេតិ អញ្ញញ្ច វិញ្ញាបេតិ អានិសំសំ ទស្សេត្វា វិញ្ញាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## បត្តវគ្គស្ស បញ្ចមសិក្ខាបទំ

(១១៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី គិលានា ហោតិ ។ អថខោ អញ្ញតរោ ឧបាសកោ យេន ថុល្លនន្ទា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោច កច្ចិ អយ្យេ ខមនីយំ កច្ចិ យាបនីយន្តិ ។ ន មេ អាវុសោ ខមនីយំ ន យាបនីយន្តិ ។ អមុកស្ស អយ្យេ អាបណិកស្ស ឃរេ កហាបណំ និក្ខិបិស្សាមិ



[១១៣] ការដែលមិនត្រូវអាបត្តិ (គឺនឹងសុំតាមបទនេះមាន ៦ យ៉ាង) គឺភិក្ខុនី (សុំរបស់ណាមុន ហើយរបស់នោះខិតខូចមិនល្អ) សុំរបស់នោះផងដែរ (ថែមទៀត) ១ ភិក្ខុនី (សុំរបស់អ្វីម្យ៉ាងហើយ) សុំរបស់ដទៃ (ទៀតព្រោះត្រូវប្រើការមិនបាន) ១ ភិក្ខុនីសុំដោយសំដែងអានិសង្សហើយសុំ (ពន្យល់របស់មួយ ថាទិញការរបស់មួយ ហើយសុំរបស់ទិញនោះ) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

---

## បត្តវគ្គ សិក្ខាបទទី ៥

[១១៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី មានជម្ងឺ ។ ឧបាសកម្នាក់ចូលទៅរកថុល្លនន្ទាភិក្ខុនីក្នុងវេលានោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់អាចអត់ទ្រាំសេចក្តីទុក្ខបានឬទេ លោកម្ចាស់អាចញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានឬទេ ។ ថុល្លនន្ទាភិក្ខុនីឆ្លើយថា នែអាវុសោ អាត្មាមិនអាចអត់ទ្រាំសេចក្តីទុក្ខបានទេ មិនអាចញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានទេ ។ ឧបាសកនោះនិយាយថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទុក

គតោ យំ ឥច្ឆេយ្យាសិ តំ អាហរេយ្យាសីតិ ។ ថុល្លនន្ទា ភិក្ខុនី អញ្ញតរំ សិក្ខមានំ អាណាបេសិ គច្ឆ សិក្ខមានេ អមុកស្ស អាបណិកស្ស ឃរា កហាបណស្ស តេលំ អាហរាតិ ។ អថខោ សា សិក្ខមានា តស្ស អាបណិកស្ស ឃរា កហាបណស្ស តេលំ អាហរិត្វា ថុល្លនន្ទាយ ភិក្ខុនិយា អទាសិ ។ ថុល្លនន្ទា ភិក្ខុនី ឯវមាហ[១] ន មេ សិក្ខមានេ តេលេន អត្ថោ សប្បិនា មេ អត្ថោតិ ។ អថខោ សា សិក្ខមានា យេន សោ អាបណិកោ តេនុបសង្កមិ ឧបសង្កមិត្វា តំ អាបណិកំ ឯតទវោច ន កិរ អាវុសោ អយ្យាយ តេលេន អត្ថោ សប្បិនា អត្ថោ ហន្ទ តេ តេលំ សប្បិំ មេ ទេហីតិ ។ សចេ មយំ អយ្យេ វិក្កីតំ ភណ្ឌំ បុន អាទិយិស្សាម កទា អម្ហាកំ ភណ្ឌំ វិក្កាយិស្សតិ តេលស្ស កយេន តេលំ ហដំ សប្បិស្ស កយំ អាហរ សប្បិំ ហរិស្សសីតិ ។ អថខោ សា សិក្ខមានា រោទន្តី អដ្ឋាសិ ។ ភិក្ខុនិយោ តំ

១ ឥទំ បាឋទ្វយំ ម. ម. បោត្ថកេសុ ន ទិស្សតិ ។



កហាបណៈក្នុងផ្ទះអ្នកផ្សារឯណោះ លោកត្រូវការរបស់ណា លោកគប្បីឲ្យបុគ្គលណាមួយទៅនាំយករបស់នោះអំពីផ្ទះនោះមកចុះ ។ ថុល្លនន្ទាភិក្ខុនីបង្គាប់សិក្ខមានា ១ រូបថា នែសិក្ខមានា នាងចូរទៅនាំយកប្រេង ១ កហាបណៈអំពីផ្ទះអ្នកផ្សារឯណោះមក ។ ទើបនាងសិក្ខមានានោះទៅនាំយកប្រេង ១ កហាបណៈអំពីផ្ទះអ្នកផ្សារនោះមកប្រគេនថុល្លនន្ទាភិក្ខុនី ។ ថុល្លនន្ទាភិក្ខុនីពោលយ៉ាងនេះថា នែសិក្ខមានា យើងមិនត្រូវការនឹងប្រេងទេ យើងត្រូវការតែទឹកដោះរាវ ។ ឯសិក្ខមានានោះចូលទៅរកអ្នកផ្សារនោះ លុះចូលទៅហើយបានពោលពាក្យនេះនឹងអ្នកផ្សារនោះថា នែអាវុសោ ឮថាលោកម្ចាស់មិនត្រូវការនឹងប្រេងទេ ត្រូវការតែទឹកដោះរាវ ចាំអ្នកចូរយកប្រេងរបស់អ្នកទៅចុះ ចូរឲ្យទឹកដោះរាវមកខ្ញុំវិញ ។ អ្នកផ្សារនោះនិយាយថា បពិត្រលោកម្ចាស់ បើខ្ញុំករុណានឹងទទួលយករបស់ដែលលក់ទៅហើយមកវិញ កាលណាខ្ញុំករុណានឹងលក់របស់បាន លោកនាំយកប្រេងតាមថ្លៃរបស់ប្រេងទៅ ហើយលោកចូរនាំយកថ្លៃទិញទឹកដោះរាវមក (ទៀត) ទើបលោកនាំយកទឹកដោះរាវទៅបាន ។ សិក្ខមានានោះក៏ឈរយំ ។ ភិក្ខុនីទាំងឡាយបានពោលពាក្យនេះនឹង

សិក្ខមានំ ឯតទវោច កិស្ស ត្វំ សិក្ខមានេ កេណសីតិ ។ អថខោ សា សិក្ខមានា ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អញ្ញំ ចេតាបេត្វា អញ្ញំ ចេតាបេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អញ្ញំ ចេតាបេត្វា អញ្ញំ ចេតាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អញ្ញំ ចេតាបេត្វា អញ្ញំ ចេតាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អញ្ញំ ចេតាបេត្វា អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

(១១៩) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អញ្ញំ ចេតាបេត្វាតិ យំ កិញ្ចិ ចេតាបេត្វា ។ អញ្ញំ ចេតាបេយ្យាតិ តំ ឋបេត្វា អញ្ញំ ចេតាបេតិ



សិក្ខមានានោះថា នែសិក្ខមានា ហេតុអ្វីក៏នាងទ័យ ។ ទើបសិក្ខមានានោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះតិះដៀល បន្ទុះ បង្អាប់ថា លោកម្ចាស់ថុល្លនន្ទាមិនសមបើនឹងឲ្យគេដូររបស់ខ្លួនហើយ ត្រឡប់ឲ្យគេដូររបស់ឯទៀតសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យគេដូររបស់ខ្លួនហើយ ត្រឡប់ឲ្យគេដូររបស់ឯទៀត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងឲ្យគេដូររបស់ខ្លួនហើយ ត្រឡប់ឲ្យគេដូររបស់ឯទៀតសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យគេដូររបស់ខ្លួនហើយ ត្រឡប់ឲ្យគេដូររបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។

(១១៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ឲ្យគេដូររបស់ខ្លួនហើយ គឺឲ្យគេដូររបស់ណាមួយហើយ ។ ពាក្យថា ត្រឡប់ឲ្យគេដូររបស់

បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ អយ្យេ អញ្ញំ ចេតាបេត្វា អញ្ញំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អយ្យាយ ទម្មីតិ ។

[១១៦] អញ្ញេ អញ្ញសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញេ វេមតិកា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញេ អនញ្ញសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អនញ្ញេ អញ្ញសញ្ញា អាបត្តិ ទុក្កដស្ស ។ អនញ្ញេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនញ្ញេ អនញ្ញសញ្ញា អនាបត្តិ ។



ឯទៀតវិញ គឺភិក្ខុនីមិនឲ្យគេទិញរបស់នោះហើយឲ្យគេទិញរបស់ដទៃវិញ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យទិញ របស់នោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះរបស់នោះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនី ១ រូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះយ៉ាងនេះ ។ បេ ។ បពិត្រលោកម្ចាស់ របស់ដទៃនេះ ខ្ញុំឲ្យគេទិញរួចហើយ ត្រឡប់ឲ្យគេទិញរបស់ដទៃវិញទៀត ជានិស្សគ្គិយ ខ្ញុំសូមលះរបស់នេះដល់សង្ឃ ។ (ពាក្យតពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌនេះហើយ) ។

[១១៦] របស់ដទៃ ភិក្ខុនីសំគាល់ថារបស់ដទៃ ហើយឲ្យគេទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដទៃ ហើយឲ្យគេទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថារបស់ដទៃ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដទៃ មិនត្រូវអាបត្តិ ។

(១១៧) អនាបត្តិ តញ្ញេវ ចេតាបេតិ អញ្ញញ្ច ចេតាបេតិ អានិសំសំ ទស្សេត្វា ចេតាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## បត្តវគ្គស្ស ឆដ្ឋសិក្ខាបទំ

[១១៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឧបាសកា ភិក្ខុនីសង្ឃស្ស ចីវរត្ថាយ ឆន្ទកំ សំហរិត្វា[១] អញ្ញតរស្ស បាវារិកស្ស ឃរេ បរិក្ខារំ និក្ខិបិត្វា ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ អមុកស្ស អយ្យេ បាវារិកស្ស ឃរេ ចីវរត្ថាយ បរិក្ខារោ និក្ខិត្តោ តតោ ចីវរំ ចេតាបេត្វា ភាជេថាតិ ។ ភិក្ខុនិយោ តេន បរិក្ខារេន សយំ[២]

---

១ ម. សំហរិត្វា ។ ២ ម. សយមត្ថំ ន ទិស្សតិ ។



(១១៧) ភិក្ខុនីដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុនី (ឲ្យគេទិញរបស់ណាមុនហើយរបស់នោះតិចពេកមិនល្មម) ហើយឲ្យគេទិញរបស់នោះដដែល (ថែមទៀត) ១ ភិក្ខុនី (ឲ្យគេទិញរបស់មួយរួចមុនហើយ) ឲ្យគេទិញរបស់មួយដទៃទៀត ដោយត្រូវការផ្លាស់ប្តូរជាដើម ១ ភិក្ខុនីសំដែងអានិសង្សហើយឲ្យគេទិញ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## បត្តវគ្គ សិក្ខាបទទី ៦

[១១៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឧបាសកទាំងឡាយប្រមូលបច្ច័យផលរៀងៗខ្លួនមក ដើម្បីប្រយោជន៍ជាចីវរដល់ភិក្ខុនីសង្ឃ ហើយផ្ញើទុកបរិក្ខារ (នោះ) ក្នុងផ្ទះអ្នកលក់សំពត់ម្នាក់ ហើយចូលទៅរកភិក្ខុនីទាំងឡាយ ជ្រាបពាក្យនេះថា បពិត្រលោកម្ចាស់ទាំងឡាយ យើងផ្ញើទុកបរិក្ខារប្រយោជន៍ដើម្បីជាចីវរក្នុងផ្ទះ អ្នកលក់សំពត់ឈ្មោះឯណោះហើយ ចូរលោកទាំងឡាយឲ្យគេទិញចីវរអំពីផ្ទះនោះមកចែកគ្នាចុះ ។ ភិក្ខុនីទាំងឡាយឲ្យគេទិញភេសជ្ជៈខ្លួនឯង

ភេសជ្ជំ ចេតាបេត្វា បរិភុញ្ជឹសុ ។ ឧបាសកា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ ឧបាសកានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ



ដោយបរិក្ខារនោះហើយបរិភោគ ។ ឧបាសកទាំងឡាយឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍ដល់វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ ជារបស់សង្ឃសោះ ។ ភិក្ខុនីទាំងឡាយបានឮឧបាសកទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍ដល់វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ ជារបស់សង្ឃសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍ដល់វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ ជារបស់សង្ឃ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍ដល់វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ ជារបស់សង្ឃទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ

ភិក្ខុនិយោ ឯវំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

(១១៩) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេនាតិ អញ្ញស្សត្ថាយ ទិន្នេន ។ សង្ឃិកេនាតិ សង្ឃស្សត្ថាយ[១] ន គណស្ស ន ឯកភិក្ខុនិយា ។ អញ្ញំ ចេតាបេយ្យាតិ យំ អត្ថាយ ទិន្នំ តំ ឋបេត្វា អញ្ញំ ចេតាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។បេ។ ឥទំ មេ អយ្យេ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។បេ។ ទទេយ្យាតិ ។បេ។ ទទេយ្យុន្តិ ។បេ។ អយ្យាយ ទម្មីតិ ។

---

១ ម. ឆ. សង្ឃស្ស ។



សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលគេយកប្រគេនដើម្បីប្រយោជន៍កិច្ចដទៃ គេឧទ្ទិសដើម្បីកិច្ចដទៃ ជារបស់សង្ឃ ត្រូវនិស្សគ្គិយបាចិត្តិយ ។

(១១៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ដោយបរិក្ខារដែលគេយកប្រគេនដើម្បីប្រយោជន៍កិច្ចដទៃ គេឧទ្ទិសដើម្បីកិច្ចដទៃ គឺគេយកទៅឲ្យដើម្បីកិច្ចដទៃ ។ ពាក្យថា ជារបស់សង្ឃ គឺគេយកប្រគេនចំពោះតែសង្ឃ មិនចំពោះគណៈ មិនចំពោះភិក្ខុនីមួយរូបទេ ។ ពាក្យថា ឲ្យគេទិញរបស់ដទៃ គឺរបស់ដែលគេយកឲ្យដើម្បីប្រយោជន៍កិច្ចណា ហើយភិក្ខុនីវៀរលែងកិច្ចនោះឲ្យគេទិញរបស់ដទៃវិញ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យទិញ របស់នោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះរបស់នោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនីមួយរូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះវត្ថុនោះយ៉ាងនេះ ។បេ។ បពិត្រលោកម្ចាស់ វត្ថុនេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលគេយកទៅឲ្យដើម្បីប្រយោជន៍កិច្ចដទៃ ឧទ្ទិសចំពោះកិច្ចដទៃ ជារបស់សង្ឃ (របស់នេះ) ជានិស្សគ្គិយ ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ ។ (ពាក្យតពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃនិស្សគ្គិយកណ្ឌនេះ) ។

និស្សគ្គិយកណ្ឌេ បត្តវគ្គេ ឆដ្ឋសិក្ខាបទស្ស បទភាជនីយំ

[១៦០] អញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ វេមតិកា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ និស្សដ្ឋំ បដិលភិត្វា យថាទានេ ឧបនេតព្វំ ។ អនញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អនាបត្តិ ។

[១៦១] អនាបត្តិ សេសកំ ឧបនេតិ សាមិកេ អបលោកេត្វា ឧបនេតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



និស្សគ្គិយកណ្ឌ បត្តវគ្គ សិក្ខាបទទី ៦ បទភាជនីយ

[១៦០] របស់គេឲ្យដើម្បីប្រយោជន៍ដទៃ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍ដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់គេឲ្យដើម្បីប្រយោជន៍ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់គេឲ្យដើម្បីប្រយោជន៍ដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍ដទៃទេ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីនោះបានវត្ថុដែលខ្លួនលះនោះមកវិញហើយ ត្រូវបង្អោនទៅក្នុងកិច្ចដែលទាយកគេឲ្យនោះយ៉ាងណា ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ដទៃ ភិក្ខុនីសំគាល់ថាវត្ថុដែលទាយកឲ្យដើម្បីប្រយោជន៍ដទៃ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ដទៃ មិនត្រូវអាបត្តិ ។

[១៦១] ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ (ទាយកប្រគេនដើម្បីវត្ថុណា) ភិក្ខុនី (ឲ្យគេទិញវត្ថុនោះហើយ) បង្អោនវត្ថុដែលសល់ (ក៏នាំទៅដើម្បីវត្ថុឯទៀត) ១ ភិក្ខុនីប្រាប់ម្ចាស់ទានហើយ ទើបបង្អោនទៅ ១ ភិក្ខុនីឲ្យគេចាត់ចែងហួសបំណងនៃទាយកក្នុងវេលាដែលមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## បត្តវគ្គស្ស សត្តមសិក្ខាបទំ

[១៦៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឧបាសកា ភិក្ខុនីសង្ឃស្ស ចីវរត្ថាយ ឆន្ទកំ សង្ឃរិត្វា អញ្ញតរស្ស បាណិកស្ស ឃរេ បរិក្ខារំ និក្ខិបិត្វា ភិក្ខុនិយោ ឧបសង្កមិត្វា បវេទេសុំ អមុកស្ស អយ្យេ បាណិកស្ស ឃរេ ចីវរត្ថាយ បរិក្ខារោ និក្ខិត្តោ តតោ ចីវរំ អាហរាបេត្វា ភាជេថាតិ ។ ភិក្ខុនិយោ តេន ច បរិក្ខារេន សយម្បិ យាចិត្វា ភេសជ្ជំ ចេតាបេត្វា បរិភុញ្ជិំសុ ។ ឧបាសកា ជានិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ ឧបាសកានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ

## បត្តវគ្គ សិក្ខាបទទី ៧

[១៦៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឧបាសកទាំងឡាយប្រមូលបរិក្ខារដែលបានមកហើយផ្ញើទុកបរិក្ខារ (នោះ) ក្នុងផ្ទះអ្នកលក់សំពត់ម្នាក់ ដើម្បីជាថ្លៃចីវរដល់ភិក្ខុនីសង្ឃ ហើយចូលទៅរកភិក្ខុនីទាំងឡាយពោលពាក្យនេះថា បពិត្រលោកម្ចាស់ យើងទាំងឡាយផ្ញើទុកបរិក្ខារ ដើម្បីជាថ្លៃចីវរក្នុងផ្ទះអ្នកលក់សំពត់ឈ្មោះឯណោះហើយ លោកទាំងឡាយចូរឲ្យអ្នកណាមួយនាំយកចីវរអំពីផ្ទះនោះមកចែកគ្នាចុះ ។ ភិក្ខុនីទាំងឡាយឲ្យគេទិញភេសជ្ជៈដោយបរិក្ខារនោះផង ដោយវត្ថុដែលសូមគេខ្លួនឯងផង ហើយក៏បរិភោគ ។ ពួកឧបាសកទាំងឡាយដឹងហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលនាំយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យបំពានក្នុងដទៃ ជារបស់សង្ឃ នឹងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ ។ ភិក្ខុនីទាំងឡាយបានឮពួកឧបាសកទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា

ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

[១៦៣] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេនាតិ



ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញវត្ថុដទៃដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានបុណ្យទ្រង់បន្ទោសថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ ដោយវត្ថុដែលសូមដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៦៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយមកក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ដោយបរិក្ខារដែលទាយក

អញ្ញស្សត្ថាយ និដ្ឋេន ។ សង្ឃិកេនាតិ សង្ឃស្សត្ថា-យ(១) ន គណស្ស ន ឯកាយ ភិក្ខុនិយា(២) ។ សញ្ញាចិកេនាតិ សយំ យាចិត្វា ។ អញ្ញំ ចេតាបេយ្យាតិ យំ អត្ថាយ ទិន្នំ តំ ឋបេត្វា អញ្ញំ ចេតាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ អយ្យេ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អយ្យាយ ទម្មីតិ ។

(១៦៦) អញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ

១ ឱ. ម. សង្ឃស្ស ។ ២ ឯកភិក្ខុនិយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ឲ្យដើម្បីប្រយោជន៍ផ្សេង ឲ្យចំពោះផ្សេង គឺដោយវត្ថុដែលគេនាំយកឲ្យដើម្បីវត្ថុផ្សេង ។ ពាក្យថា ជារបស់សង្ឃ គឺគេនាំយកបរិច្ចាគចំពោះតែសង្ឃ មិនមែនចំពោះគណៈ មិនមែនចំពោះភិក្ខុនី ១ រូប ។ ពាក្យថា ដោយខ្លួនឯង គឺដោយវត្ថុដែលសូម (គេ) ដោយខ្លួនឯង ។ ពាក្យថា ឲ្យគេទិញវត្ថុផ្សេង គឺរបស់ដែលគេនាំយកឲ្យដើម្បីជាតម្លៃវត្ថុណា ភិក្ខុនីវៀរលែងរបស់នោះហើយឲ្យគេទិញវត្ថុផ្សេងវិញ ត្រូវទុក្កដ ក្នុងប្រយោគដែលឲ្យទិញ វត្ថុនោះជានិស្សគ្គិយៈក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះវត្ថុនោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី ១ រូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះយ៉ាងនេះ ។ បេ ។ បពិត្រលោកម្ចាស់ វត្ថុជារបស់ខ្ញុំនេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលគេនាំយកឲ្យដើម្បីប្រយោជន៍ផ្សេង ឲ្យចំពោះផ្សេង ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯង (វត្ថុនេះ) ជានិស្សគ្គិយ (ត្រូវតែលះបង់) ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ ។ (ពាក្យតពីនេះទៅមានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌនេះ) ។

(១៦៦) របស់ដែលគេនាំយកឲ្យដើម្បីប្រយោជន៍ផ្សេង ភិក្ខុនីសំគាល់ថា របស់ដែលគេនាំយកឲ្យដើម្បីប្រយោជន៍ផ្សេងមែន ហើយឲ្យគេទិញវត្ថុផ្សេងវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដែលគេនាំយកឲ្យដើម្បី

វេមតិកា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ និស្សដ្ឋំ បដិលភិត្វា យថាទានេ ឧបនេតព្វំ ។ អនញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អនាបត្តិ ។

(១៤៨) អនាបត្តិ សេសកំ ឧបនេតិ សាមិកេ អបលោកេត្វា ឧបនេតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ប្រយោជន៍ក្នុងដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដែលទាយកឲ្យដើម្បីប្រយោជន៍ក្នុងដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ក្នុងដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីនោះបានវត្ថុ ដែលលះបង់ហើយមកវិញហើយ ត្រូវបង្អោនទៅក្នុងកិច្ចដែលទាយកនោះឲ្យ ចំពោះវត្ថុណា ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ក្នុងដទៃ ភិក្ខុនីសំគាល់ថារបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ក្នុងដទៃ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ក្នុងដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍ក្នុងដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍ក្នុងដទៃ មិនត្រូវអាបត្តិ ។

[១៤៩] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីបង្អោនរបស់ដែលសល់ទៅ ១ ភិក្ខុនីប្រាប់ម្ចាស់ទានហើយទើបបង្អោនទៅ ១ ភិក្ខុនីឲ្យគេដោះដូរនូវរបស់ដែលទាយកឲ្យក្នុងសម័យដែលមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## បត្តវគ្គស្ស អដ្ឋមសិក្ខាបទំ

(១៦៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន អញ្ញតរស្ស បូគស្ស បរិវេណវា-
សិកា ភិក្ខុនិយោ យាគុយា កិលមន្តិ ។ អថខោ
សោ បូគោ ភិក្ខុនីនំ យាគុអត្ថាយ ឆន្ទកំ សំហរិត្វា[១]
អញ្ញតរស្ស អាបណិកស្ស ឃរេ បរិក្ខារំ និក្ខិបិត្វា
ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោច អមុកស្ស អយ្យេ
អាបណិកស្ស ឃរេ យាគុអត្ថាយ បរិក្ខារោ និក្ខិត្តោ
តតោ តណ្ឌុលេ[២] អាហរាបេត្វា យាគុំ បចាបេត្វា
បរិភុញ្ជថាតិ ។ ភិក្ខុនិយោ តេន បរិក្ខារេន ភេសជ្ជំ
ចេតាបេត្វា បរិភុញ្ជឹសុ ។ អថខោ សោ បូគោ ជានិត្វា
ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនិ-
យោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហា-
ជនិកេន អញ្ញំ ចេតាបេស្សន្តីតិ ។ អស្សោសុំ ខោ

១ ឆ. សំហរិត្វា ។ ២ ម. ឆ. តណ្ឌុលំ ។

## បត្តវគ្គ សិក្ខាបទទី ៨

(១៦៦) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងជេតវនារាមរបស់
អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយ
ជាអ្នកនៅក្នុងបរិវេណរបស់ប្រជុំជន ១ ពួក ជាអ្នកទុក្ខលំបាកដោយបបរ ។
គ្រានោះឯង ប្រជុំជននោះក៏ប្រមូលបរិក្ខារដែលនាំមក ហើយផ្ញើទុកប-
រិក្ខារ (នោះ) ក្នុងផ្ទះអ្នកផ្សារម្នាក់ដើម្បីតាក់តែងបបរដល់ភិក្ខុនីទាំងឡាយ
ទើបចូលទៅរកភិក្ខុនីទាំងឡាយ ហើយបាននិយាយពាក្យនេះថា បពិត្រ
លោកម្ចាស់ យើងទាំងឡាយទុកបរិក្ខារដើម្បីតាក់តែងបបរក្នុងផ្ទះអ្នកផ្សារ
ឈ្មោះឯណោះ សូមលោកទាំងឡាយឲ្យអ្នកណាមួយនាំយកអង្ករទាំងឡាយ
អំពីផ្ទះនោះហើយឲ្យគេចំអិនបបរឆាន់ចុះ ។ ភិក្ខុនីទាំងឡាយឲ្យគេទិញ
ភេសជ្ជៈដោយបរិក្ខារនោះហើយក៏បរិភោគ ។ ទើបប្រជុំជននោះដឹងហើយ
ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើ
នឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេ
ឲ្យចំពោះវត្ថុដទៃ ជារបស់គណៈសោះ ភិក្ខុនីទាំងឡាយបានឮពួកឧបាសក(១)

១ ប្រើសំដៅប្រជុំជននោះ ។

ភិក្ខុនិយោ តស្ស ឧបាសកស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន អញ្ញំ ចេតាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន អញ្ញំ ចេតាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន អញ្ញំ ចេតាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។





នោះភិក្ខុនីពោលពាក្យ តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់គណៈទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ភិក្ខុនីនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៦៣] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេនាតិ អញ្ញស្សត្ថាយ ទិន្នេន ។ មហាជនិកេនាតិ គណស្សត្ថាយ ន សង្ឃស្ស ន ឯកភិក្ខុនិយា ។ អញ្ញំ ចេតាបេយ្យាតិ យំ អត្ថាយ ទិន្នំ តំ ឋបេត្វា អញ្ញំ ចេតាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។បេ។ ឥទំ មេ អយ្យេ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន អញ្ញំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។បេ។ ទទេយ្យាតិ ។បេ។ ទទេយ្យុន្តិ ។បេ។ អយ្យាយ ទម្មីតិ ។

[១៦៤] អញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ វេមតិកា



[១៦៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍ផ្សេង ឲ្យចំពោះផ្សេង គឺដោយបរិក្ខារដែលទាយកប្រគេនប្រយោជន៍ដើម្បីបាក់ចង់ផ្សេងទៀត ។ ពាក្យថា ជារបស់គណៈ (គឺទាយកលះចំពោះ) តែគណៈមិនមែនលះចំពោះសង្ឃ មិនមែនលះចំពោះភិក្ខុនី ១ រូប ។ ពាក្យថា ឲ្យគេទិញផ្សេង គឺរបស់ដែលគេឲ្យដើម្បីប្រយោជន៍ណា ភិក្ខុនីមិនឲ្យទិញរបស់នោះ ហើយឲ្យគេទិញរបស់ផ្សេងវិញ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យទិញ របស់នោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុនីត្រូវតែលះរបស់នោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី ១ រូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវតែលះរបស់នោះយ៉ាងនេះ ។បេ។ បពិត្រលោកម្ចាស់ របស់នេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍ផ្សេង គេឲ្យចំពោះផ្សេង ជារបស់គណៈ ជានិស្សគ្គិយ ខ្ញុំសូមលះរបស់នេះដល់សង្ឃ ។ (ពាក្យក្រៅពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌនេះ) ។

[១៦៤] របស់គេឲ្យដើម្បីប្រយោជន៍ផ្សេង ភិក្ខុនីសំគាល់ថា របស់គេឲ្យដើម្បីប្រយោជន៍ផ្សេង ហើយឲ្យគេទិញផ្សេងវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់គេឲ្យដើម្បីប្រយោជន៍ផ្សេង ភិក្ខុនីមាន

អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ និស្សដ្ឋំ បច្ចុទ្ធរិត្វា យថាទានេ ឧបនេតព្វំ ។ អនញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អនាបត្តិ ។

(១៦៩) អនាបត្តិ សេសកំ ឧបនេតិ សាមិកេ អបុច្ឆិត្វា ឧបនេតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



សេចក្ដីសង្ស័យ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីបានវត្ថុដែលខ្លួនលះនោះមកវិញហើយ ត្រូវបង្អោនទៅតាមវត្ថុដែលគេឲ្យចំពោះយ៉ាងណា ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ មិនត្រូវអាបត្តិ ។

(១៦៩) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីបង្អោនទៅនូវរបស់ដែលសល់ ១ ភិក្ខុនីប្រាប់ម្ចាស់ទានហើយទើបបង្អោនទៅ ១ ភិក្ខុនីឲ្យគេទាក់ទងនឹងបំណងតាមក្នុងសម័យមានសេចក្ដីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

# បត្តវគ្គស្ស នវមសិក្ខាបទំ

[១៣១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស បូគស្ស បរិវេណវាសិកា ភិក្ខុនិយោ យាគុយា កិលមន្តិ ។ អថខោ សោ បូគោ ភិក្ខុនីនំ យាគុអត្ថាយ ឆន្ទកំ សំហរិត្វា អញ្ញតរស្ស អាបណិកស្ស ឃរេ បរិក្ខារំ និក្ខិបិត្វា ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោច អមុកស្ស អយ្យេ អាបណិកស្ស ឃរេ យាគុអត្ថាយ បរិក្ខារោ និក្ខិត្តោ តតោ តណ្ឌុលេ[១] អាហរាបេត្វា យាគុំ បចាបេត្វា បរិភុញ្ជថាតិ ។ ភិក្ខុនិយោ តេន ច បរិក្ខារេន សយំ យាចិត្វា ភេសជ្ជំ ចេតាបេត្វា បរិភុញ្ជឹសុ ។ អថខោ សោ បូគោ ជានិត្វា ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តស្ស

---

១ ម. តណ្ឌុលំ ។

# បត្តវគ្គ សិក្ខាបទទី ៩

[១៣០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយនៅក្នុងបរិវេណរបស់ប្រជុំជនមួយពួក ជាពួកភិក្ខុនីលំបាកដោយបបរ ។ គ្រានោះឯង ប្រជុំជននោះប្រមូលបរិក្ខារដែលឲ្យទានមក ដើម្បីជាតំលៃបបរដល់ភិក្ខុនីទាំងឡាយ ហើយទុកបរិក្ខារ (នោះ) ក្នុងផ្ទះអ្នកផ្សារម្នាក់ ទើបចូលទៅរកភិក្ខុនីទាំងឡាយ ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ យើងទាំងឡាយទុកបរិក្ខារដើម្បីជាតំលៃបបរ ក្នុងផ្ទះអ្នកផ្សារឈ្មោះឯណោះ ចូរលោកទាំងឡាយឲ្យគេនាំយកអង្ករអំពីផ្ទះនោះមកហើយចំអិនបបរឆាន់ចុះ ។ តែភិក្ខុនីទាំងឡាយឲ្យគេទិញភេសជ្ជៈ ដោយបរិក្ខារនោះផង ដោយរបស់ដែលសូមគេដោយខ្លួនឯងផង ហើយបរិភោគ ។ ឯប្រជុំជននោះដឹងហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុផ្សេង ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុផ្សេង គេឲ្យចំពោះវត្ថុផ្សេង ជារបស់គណៈ នឹងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ ។ ភិក្ខុនីទាំងឡាយបានឮប្រជុំជននោះ

ឞុកស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។



ភិក្ខុនីពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយម្តេចក៏មិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ទាំងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ទាំងដោយវត្ថុដែលសូមដោយខ្លួនឯង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ទាំងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ទាំងដោយវត្ថុដែលសូមដោយខ្លួនឯង ភិក្ខុនីនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៣១] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេនាតិ អញ្ញស្សត្ថាយ ទិន្នេន ។ មហាជនិកេនាតិ គណស្សត្ថាយ ន សង្ឃស្ស ន ឯកភិក្ខុនិយា ។ សញ្ញាចិកេនាតិ សយំ យាចិត្វា ។ អញ្ញំ ចេតាបេយ្យាតិ យំ អត្ថាយ ទិន្នំ តំ ឋបេត្វា អញ្ញំ ចេតាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ បេ ។ ឥទំ មេ អយ្យេ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អយ្យាយ ទម្មីតិ ។



[១៣១] (ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយវគ្គខាងដើមហើយ ។ ពាក្យថា ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍ផ្សេង គេឲ្យចំពោះផ្សេង គឺដោយបរិក្ខារដែលគេឲ្យដើម្បីតាក់តែងវិហារផ្សេងទៀត ។ ពាក្យថា ជារបស់គណៈ គឺរបស់ចំពោះតែគណៈមិនមែនចំពោះសង្ឃ មិនមែនចំពោះភិក្ខុនីមួយរូប ។ ពាក្យថា ដោយវត្ថុដែលសូមដោយខ្លួនឯង គឺវត្ថុដែលសូមគេបានមកហើយដោយខ្លួនឯង ។ ពាក្យថា ឲ្យគេទិញវត្ថុដទៃ គឺរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុណា ភិក្ខុនីមិនឲ្យគេទិញវត្ថុនោះហើយឲ្យគេទិញវត្ថុដទៃវិញ (ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យទិញ) វត្ថុនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះរបស់នោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនីមួយរូបក៏បាន ។ ម្នាលភិក្ខុនីទាំងឡាយ ភិក្ខុនីត្រូវលះរបស់នោះយ៉ាងនេះ ។ បេ ។ បពិត្រលោកម្ចាស់ វត្ថុនេះខ្ញុំឲ្យគេទិញដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍ផ្សេង គេឲ្យចំពោះផ្សេង ជារបស់គណៈ ទិញដោយវត្ថុដែលសូមបានមកដោយខ្លួនឯង ជានិស្សគ្គិយ ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ ។ (ពាក្យតទៅនេះទៀត មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយវគ្គនេះ) ។

[១៣២] អញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ វេមតិកា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ និស្សដ្ឋំ បដិលភិត្វា យថាទានេ ឧបនេតព្វំ ។ អនញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អនាបត្តិ ។

[១៣៣] អនាបត្តិ សេសកំ ឧបនេតិ សាមិកេ អបលោកេត្វា ឧបនេតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



[១៣២] របស់ដែលគេឲ្យដើម្បីប្រយោជន៍តែដូចនេះ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍តែដូចនេះមែន ហើយឲ្យគេទិញតែដូចនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់គេឲ្យដើម្បីប្រយោជន៍តែដូចនេះ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យទិញតែដូចនោះវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់គេឲ្យដើម្បីប្រយោជន៍តែដូចនេះ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍តែដូចនេះ ហើយឲ្យគេទិញតែដូចនោះវិញ ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីបានវត្ថុដែលខ្លួនលះនោះមកវិញហើយ ត្រូវបង្អោនទៅរកកិច្ចដែលតាមការគេឲ្យចំពោះយ៉ាងណា ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍តែដូចនេះ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍តែដូចនេះ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍តែដូចនេះ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់គេឲ្យដើម្បីប្រយោជន៍តែដូចនេះ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍តែដូចនេះ មិនត្រូវអាបត្តិ ។

[១៣៣] ករណីដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីបង្អោនទៅរករបស់ដែលសល់១ ភិក្ខុនីប្រាប់ម្ចាស់របស់ហើយទើបបង្អោនទៅ១ ភិក្ខុនីឲ្យគេបាត់បែងខុសបំណងក្នុងកាលមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាអាទិកម្មិក១ ។

# បត្តវគ្គស្ស ទសមសិក្ខាបទំ

[១៣៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី ពហុស្សុតា ហោតិ ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ។ ពហូ មនុស្សា ថុល្លនន្ទំ ភិក្ខុនឹ បយិរុបាសន្តិ(១) ។ តេន ខោ បន សមយេន ថុល្លនន្ទាយ ភិក្ខុនិយា បរិវេណំ ឧទ្រិយតិ ។ មនុស្សា ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោចុំ កិស្សិទំ តេ(២) អយ្យេ បរិវេណំ ឧទ្រិយតីតិ ។ នត្ថាវុសោ ទាយកា នត្ថិ ការកាតិ ។ អថខោ តេ មនុស្សា ថុល្លនន្ទាយ ភិក្ខុនិយា បរិវេណត្ថាយ ឆន្ទកំ សំហរិត្វា(៣) ថុល្លនន្ទាយ ភិក្ខុនិយា បរិក្ខារំ អទំសុ ។ ថុល្លនន្ទា ភិក្ខុនី តេន ច បរិក្ខារេន សយំបិ យាចិត្វា ភេសជ្ជំ ចេតាបេត្វា បរិភុញ្ជិ ។ មនុស្សា ជានិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា

១ ម. បយិរុបាសន្តិ ។ ២ ម. តំ ។ ៣ ម. សំហរិត្វា ។

# បត្តវគ្គ សិក្ខាបទទី ១០

[១៣៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនីជាពហុស្សូតជាអ្នកឈ្លាសនិយាយក្លៀវក្លាប្រសប់ធ្វើធម្មកថា ។ មនុស្សទាំងឡាយជាច្រើនតែងចូលទៅអង្គុយជិត (សេពគប់) នឹងថុល្លនន្ទាភិក្ខុនី ។ សម័យនោះឯង ទីបរិវេណរបស់ថុល្លនន្ទាភិក្ខុនីក៏បាក់បែកទ្រុឌទ្រោម ។ មនុស្សទាំងឡាយបានពោលពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ ទីបរិវេណរបស់លោកនេះ ទ្រុឌទ្រោមដោយហេតុអ្វី ។ ថុល្លនន្ទាភិក្ខុនីនិយាយថា នែអ្នកដ៏មានអាយុ ព្រោះគ្មានពួកអ្នកឲ្យ គ្មានពួកអ្នកធ្វើ ។ ទើបមនុស្សទាំងឡាយនោះ ប្រមូលបរិក្ខារដែលរៃបានមកដើម្បីប្រយោជន៍ទីបរិវេណនៃថុល្លនន្ទាភិក្ខុនី ហើយបានឲ្យបរិក្ខារនោះដល់ថុល្លនន្ទាភិក្ខុនី ។ ថុល្លនន្ទាភិក្ខុនីឲ្យគេទិញភេសជ្ជៈដោយបរិក្ខារនោះផង ដោយរបស់ដែលសូមដោយខ្លួនឯងផង ហើយក៏បរិភោគ ។ មនុស្សទាំងឡាយដឹងហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា

អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន បុគ្គលិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន បុគ្គលិកេន សញ្ញាចិកេន អញ្ញំ ចេតាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន បុគ្គលិកេន សញ្ញាចិកេន អញ្ញំ ចេតាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន បុគ្គលិកេន សញ្ញាចិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។



មិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល ទាំងដោយវត្ថុដែលសូមមកហើយខ្លួនឯងនោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃចំពោះវត្ថុដទៃ ជារបស់បុគ្គល ទាំងដោយវត្ថុដែលសូមដោយខ្លួនឯងពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្មាសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល ទាំងដោយវត្ថុដែលសូមដោយខ្លួនឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល ទាំងដោយវត្ថុដែលសូមដោយខ្លួនឯង ភិក្ខុនីនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

[១៣៩] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេនាតិ អញ្ញស្សត្ថាយ ទិន្នេន ។ បុគ្គលិកេនាតិ ឯកភិក្ខុនិយា អត្ថាយ ន សង្ឃស្ស ន គណស្ស ។ សញ្ញាចិកេនាតិ សយំ យាចិត្វា ។ អញ្ញំ ចេតាបេយ្យាតិ យំ អត្ថាយ ទិន្នំ តំ ឋបេត្វា អញ្ញំ ចេតាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។បេ។ ឥទំ មេ អយ្យេ អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន បុគ្គលិកេន សញ្ញាចិកេន អញ្ញំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។បេ។ ទទេយ្យាតិ ។បេ។ ទទេយ្យុន្តិ ។បេ។ អយ្យាយ ទម្មីតិ ។



[១៣៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌនេះហើយ ។ ពាក្យថា ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍ដល់វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ គឺដោយបរិក្ខារដែលគេឲ្យដើម្បីតាក់តែងវត្ថុឯទៀត ។ ពាក្យថា ជារបស់បុគ្គល គឺគេឲ្យចំពោះតែភិក្ខុនីមួយរូបមិនឲ្យដល់សង្ឃ មិនឲ្យដល់គណៈឡើយ ។ ពាក្យថា ដោយវត្ថុដែលសូមដោយខ្លួនឯង គឺវត្ថុដែលសូមនាំមកដោយខ្លួនឯង ។ ពាក្យថា ទិញគេវិញនូវវត្ថុដទៃ គឺរបស់ដែលគេឲ្យដើម្បីប្រយោជន៍ដល់វត្ថុណា ភិក្ខុនីមិនចាត់ចែងវត្ថុនោះ ហើយទិញគេវិញនូវវត្ថុឯទៀតវិញ ត្រូវទុក្កដក្នុងប្រយោគដែលទិញ វត្ថុនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីគប្បីលះវត្ថុនោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនីមួយរូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះរបស់នោះយ៉ាងនេះ ។បេ។ បពិត្រលោកម្ចាស់ វត្ថុដទៃនេះខ្ញុំទិញគេវិញ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍ដល់វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល ខ្ញុំដោយវត្ថុដែលសូមដោយខ្លួនឯង ជានិស្សគ្គិយ ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ ។ (ពាក្យតទៅនេះមានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌនេះ) ។

(១៣៦) អញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ វេមតិកា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អញ្ញំ ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ និស្សដ្ឋំ បដិលភិត្វា យថាទានេ ឧបនេតព្វំ ។ អនញ្ញទត្ថិកេ អញ្ញទត្ថិកសញ្ញា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនញ្ញទត្ថិកេ អនញ្ញទត្ថិកសញ្ញា អនាបត្តិ ។

(១៣៧) អនាបត្តិ សេសកំ ឧបនេតិ សាមិកេ អបលោកេត្វា ឧបនេតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



(១៣៦) របស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ភិក្ខុនីសំគាល់ថារបស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ហើយឲ្យគេទិញក្នុងឯទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញក្នុងមួយទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់គេឲ្យដើម្បីប្រយោជន៍តែមួយ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ហើយឲ្យគេទិញក្នុងមួយទៀត ត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុនីបាននូវតែរបស់នោះមកវិញហើយ គប្បីបង្អោនទៅក្នុងតែដែលទាយកគេឲ្យចំពោះយ៉ាងណា ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ភិក្ខុនីសំគាល់ថារបស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍តែមួយ មិនត្រូវអាបត្តិ ។

(១៣៧) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីបង្អោនទៅនូវរបស់ដែលសល់ ១ ភិក្ខុនីប្រាប់ម្ចាស់គេហើយទើបបង្អោនទៅ ១ ភិក្ខុនីឲ្យគេបាត់ទៅវិញក្នុងសម័យណានីមួយព្រោះមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិ៍ដើមបញ្ញត្តិ ១ ។

## ចីវរវគ្គស្ស បឋមសិក្ខាបទំ

(១៣៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី ពហុស្សុតា ហោតិ ភាណិកា វិសារទា បដ្ឋា ធម្មិំ កថំ កាតុំ ។ អថខោ រាជា បសេនទិ កោសលោ សីតកាលេ មហគ្ឃំ កម្ពលំ បារុបិត្វា យេន ថុល្លនន្ទា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ថុល្លនន្ទំ ភិក្ខុនឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជានំ បសេនទិ កោសលំ ថុល្លនន្ទា ភិក្ខុនី ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា បសេនទិ កោសលោ ថុល្លនន្ទាយ ភិក្ខុនិយា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោច វទេយ្យាសិ អយ្យេ យេន អត្ថោ ។ សចេ មេ ត្វំ មហារាជ

## ចីវរវគ្គ សិក្ខាបទទី ១

(១៣៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីឈ្មោះថុល្លនន្ទា ជាពហុស្សូត ជាស្រីមានថ្វីមាត់ ក្លៀវក្លាប្រសប់ធ្វើធម្មីកថា ។ គ្រានោះ ព្រះបាទបសេនទិកោសល ដណ្តប់សំពត់កម្ពលមានដំឡៃច្រើនក្នុងកាលត្រជាក់ ហើយព្រះអង្គចូលទៅកាន់សំណាក់ថុល្លនន្ទាភិក្ខុនី លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំថុល្លនន្ទាភិក្ខុនី ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះស្តេចបសេនទិកោសលគង់នៅក្នុងទីដ៏សមគួរហើយ ថុល្លនន្ទាភិក្ខុនីក៏ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ កាលនោះ ស្តេចបសេនទិកោសល កាលថុល្លនន្ទាភិក្ខុនីពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា (រួចហើយ) ក៏មានបន្ទូលនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការវត្ថុណា គប្បីប្រាប់វត្ថុនោះចុះ ។ ថុល្លនន្ទាភិក្ខុនីទូលថា បពិត្រមហារាជ បើព្រះអង្គមានសេចក្តីប្រាថ្នានឹង

ញាតុកាមោសិ អហំ កម្ពលំ ទេហីតិ ។ អថខោ រាជា បសេនទិ កោសលោ ថុល្លនន្ទាយ ភិក្ខុនិយា កម្ពលំ ទត្វា ឧដ្ឋាយាសនា ថុល្លនន្ទំ ភិក្ខុនឹ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ មហិច្ឆា ឥមា ភិក្ខុនិយោ អសន្តុដ្ឋា កថំ ហិ នាម រាជានំ កម្ពលំ វិញ្ញាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា រាជានំ កម្ពលំ វិញ្ញាបេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី រាជានំ កម្ពលំ វិញ្ញាបេតីតិ[1] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី រាជានំ កម្ពលំ វិញ្ញាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ

[1] ម. ឧ. វិញ្ញាបេសីតិ ។



ប្រគេនឲ្យដល់អាត្មា ចូរព្រះអង្គប្រគេនសំពត់កម្ពលនេះចុះ ។ ទើបស្តេចបសេនទិកោសល ប្រគេនសំពត់កម្ពលដល់ថុល្លនន្ទាភិក្ខុនី ហើយក្រោកចាកអាសនៈថ្វាយបង្គំថុល្លនន្ទាភិក្ខុនី ធ្វើប្រទក្សិណហើយស្តេចចេញទៅ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះមានសេចក្តីប្រាថ្នាច្រើន គ្មានសន្តោស មិនសមបើនឹងសុំសំពត់កម្ពលពីស្តេចសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងសុំសំពត់កម្ពលពីស្តេចសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ថុល្លនន្ទាភិក្ខុនីសុំសំពត់កម្ពលពីស្តេច ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងសុំសំពត់កម្ពលពីស្តេចទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីកាលចាត់ចែង

គរុបាវុរណំ(១) បន ភិក្ខុនិយា ចេតាបេន្តិយា ចតុក្កំសបរមំ ចេតាបេតព្វំ តតោ ចេ ឧត្តរិំ(២) ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

(១៣៨) គរុបាវុរណំ នាម យំ កិញ្ចិ សីតកាលេ បាវុរណំ(៣) ។ ចេតាបេន្តិយាតិ វិញ្ញាបេន្តិយា ។ ចតុក្កំសបរមំ ចេតាបេតព្វន្តិ សោឡសកហាបណគ្ឃនកំ ចេតាបេតព្វំ ។ តតោ ចេ ឧត្តរិំ ចេតាបេយ្យាតិ តទុត្តរិំ វិញ្ញាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា ឯកភិក្ខុនិយា វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ អយ្យេ គរុបាវុរណំ អតិរេកចតុក្កំសបរមំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ បេ ។ អយ្យាយ ទម្មីតិ ។

១ ឱ. ម. គរុបាវុរណំ ។ ២ ឧត្តរិ ។ ៣ បាវុរណំ ។



សម្ពត់ដណ្ដប់ដែលមានសាច់ក្រាស់ ត្រូវតាត់ថ្លៃបានតែសម្ពត់ដែលមានដំឡៃបួនកហាបណៈបួនដងជាយ៉ាងច្រើន បើតាត់ថ្លៃសំពត់ដែលមានដំឡៃហួសពីនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

(១៣៨) ដែលហៅថា សំពត់ដណ្ដប់ដែលមានសាច់ក្រាស់ គឺសំពត់ដណ្ដប់ណាមួយសម្រាប់ដណ្ដប់ក្នុងរដូវរងា ។ ត្រង់ពាក្យថា កាលតាត់ថ្លៃ គឺថា កាលសូម(គេ) ។ ពាក្យថា ត្រូវតាត់ថ្លៃបានតែសំពត់មានដំឡៃបួនកហាបណៈបួនដងជាយ៉ាងច្រើន សេចក្ដីថា ត្រូវតាត់ថ្លៃបានតែសំពត់មានដំឡៃ ១៦ កហាបណៈ ។ ពាក្យថា បើតាត់ថ្លៃសំពត់ឲ្យលើសពីនោះទៅ សេចក្ដីថា ភិក្ខុនីសូមសំពត់ឲ្យលើសលុបពីនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសូម សំពត់នោះជានិស្សគ្គិយក្នុងវេលាដែលបានមក ភិក្ខុនីត្រូវលះបង់ដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី ១ រូបក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះបង់យ៉ាងនេះ ។ បេ ។ បពិត្រលោកម្ចាស់ សំពត់ដណ្ដប់ដែលមានសាច់ក្រាស់នេះមានដំឡៃលើសពីបួនកហាបណៈបួនដងជាកំណត់ ខ្ញុំបានសូមមកហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបង់សំពត់នេះដល់សង្ឃ ។ (ពាក្យក្រៅនេះទៅមានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌ) ។

(១៦០) អតិរេកចតុក្កំសេ អតិរេកសញ្ញា ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អតិរេកចតុក្កំសេ វេមតិកា ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អតិរេកចតុក្កំសេ ឩនកសញ្ញា ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ ឩនកចតុក្កំសេ អតិរេកសញ្ញា អាបត្តិ ទុក្កដស្ស ។ ឩនកចតុក្កំសេ វេមតិកា អាបត្តិ ទុក្កដស្ស ។ ឩនកចតុក្កំសេ ឩនកសញ្ញា អនាបត្តិ ។

(១៦១) អនាបត្តិ ចតុក្កំសបរមំ ចេតាបេតិ ឩនកចតុក្កំសបរមំ ចេតាបេតិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន មហគ្ឃំ ចេតាបេតុកាមស្ស អប្បគ្ឃំ ចេតាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



(១៦០) សំពត់មានថ្លៃលើសពីបួនកហាបណៈ ៤ ដង ភិក្ខុនីសំគាល់ថាលើសមែន ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ ។ សំពត់មានថ្លៃលើសពីបួនកហាបណៈ ៤ ដង ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ ។ សំពត់មានថ្លៃលើសពីបួនកហាបណៈ ៤ ដង ភិក្ខុនីសំគាល់ថាខ្វះវិញ ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ ។ សំពត់មានថ្លៃខ្វះពីបួនកហាបណៈ ៤ ដង ភិក្ខុនីសំគាល់ថាលើសវិញ ត្រូវអាបត្តិទុក្កដ ។ សំពត់មានថ្លៃខ្វះពីបួនកហាបណៈ ៤ ដង ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សំពត់មានថ្លៃខ្វះពីបួនកហាបណៈ ៤ ដង ភិក្ខុនីសំគាល់ថាខ្វះមែន មិនត្រូវអាបត្តិ ។

(១៦១) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺភិក្ខុនីសូមសំពត់ដណ្តប់មានថ្លៃត្រឹមបួនកហាបណៈ ៤ ដងជាកំណត់ ១ ភិក្ខុនីសូមសំពត់ដណ្តប់មានថ្លៃខ្វះពីបួនកហាបណៈ ៤ ដងជាកំណត់ ១ ភិក្ខុនីសូមសំពត់ដណ្តប់របស់ពួកញាតិ ១ ភិក្ខុនីសូមសំពត់ដណ្តប់របស់ពួកជនដែលបវារណា ១ ភិក្ខុនីសូមសំពត់ដណ្តប់ដើម្បីបុគ្គលដទៃ ១ ភិក្ខុនីដូរសំពត់ដណ្តប់ដោយទ្រព្យរបស់ខ្លួន ១ ជនមានសេចក្តីប្រាថ្នាឲ្យភិក្ខុនីសូមសំពត់ដណ្តប់មានថ្លៃច្រើន ភិក្ខុនីត្រឡប់សូមសំពត់ដណ្តប់មានថ្លៃតិច ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិដើមបញ្ញត្តិ ១ ។

## ចីវរវគ្គស្ស ទុតិយសិក្ខាបទំ

[១៤៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី ពហុស្សុតា ហោតិ ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ។ អថខោ រាជា បសេនទិ កោសលោ ឧណ្ហកាលេ មហគ្ឃំ ខោមំ ទារុបិត្វា យេន ថុល្លនន្ទា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ថុល្លនន្ទំ ភិក្ខុនឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជានំ បសេនទឹ កោសលំ ថុល្លនន្ទា ភិក្ខុនី ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា បសេនទិ កោសលោ ថុល្លនន្ទាយ ភិក្ខុនិយា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោច វទេយ្យាសិ អយ្យេ យេន អត្ថោតិ ។ សចេ មេ ត្វំ មហារាជ ទាតុកាមោសិ ឥមំ ខោមំ ទេហីតិ ។ អថខោ រាជា បសេនទិ កោសលោ ថុល្លនន្ទាយ

## ចីវរវគ្គ សិក្ខាបទទី ២

[១៦៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ជាពហុស្សូត ជាស្រីមានថ្វីមាត់ ជាស្រីក្លៀវក្លា ប្រសប់ធ្វើធម្មីកថា ។ សម័យនោះ ព្រះបាទបសេនទិកោសល ទ្រង់ដណ្តប់សំពត់សម្បកឈើមានដំឡៃច្រើនក្នុងកាលក្តៅ ហើយចូលទៅរកថុល្លនន្ទាភិក្ខុនី លុះយាងចូលទៅហើយក៏ថ្វាយបង្គំថុល្លនន្ទាភិក្ខុនីហើយ គង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសលគង់នៅក្នុងទីដ៏សមគួរហើយ ថុល្លនន្ទាភិក្ខុនីក៏ពន្យល់ឲ្យទ្រង់ឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ សម័យនោះ ព្រះបាទបសេនទិកោសល កាលថុល្លនន្ទាភិក្ខុនីពន្យល់ឲ្យទ្រង់ឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយក៏មានព្រះបន្ទូលនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការវត្ថុណា គប្បីប្រាប់វត្ថុនោះចុះ ។ ថុល្លនន្ទាភិក្ខុនីឆ្លើយថា បពិត្រមហារាជ បើព្រះអង្គប្រាថ្នានឹងប្រគេនដល់អាត្មាភាព សូមព្រះអង្គប្រគេនសំពត់សម្បកឈើនេះចុះ ។ ទើបព្រះបាទបសេនទិកោសល

ភិក្ខុនិយា ខោមំ ទត្វា ឧយ្យោជេសិ ថុល្លនន្ទា ភិក្ខុនី អភិភវេត្វា បនគ្ឃិណំ គហេត្វា បក្កាមិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ មហិច្ឆា ឥមា ភិក្ខុនិយោ អសន្តុដ្ឋា កថញ្ហិ នាម រាជានំ ខោមំ វិញ្ញាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថញ្ហិ នាម អយ្យា ថុល្លនន្ទា រាជានំ ខោមំ វិញ្ញាបេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី រាជានំ ខោមំ វិញ្ញាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី រាជានំ ខោមំ វិញ្ញាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ លហុបាវុរណំ[១] បន ភិក្ខុនិយា ចេតាបេន្តិយា អឌ្ឍតេយ្យកំសបរមំ ចេតាបេតព្វំ តតោ ចេ ឧត្តរិ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយន្តិ ។

១ ម. លហុបាវុរណំ ។





ប្រទានសំពត់សម្បុរលើដល់ថុល្លនន្ទាភិក្ខុនី រួចទ្រង់ក្រោកចាកអាសនៈ ថ្វាយបង្គំថុល្លនន្ទាភិក្ខុនី ធ្វើប្រទក្សិណហើយស្ដេចទៅ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះមានសេចក្ដីប្រាថ្នាធំ គ្មានសន្ដោស មិនសមបើនឹងសុំសំពត់សម្បុរលើអំពីស្ដេចសោះ ។ ពួកភិក្ខុនីឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុនីណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងសូមសំពត់សម្បុរលើអំពីស្ដេចសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីសូមសំពត់សម្បុរលើពីស្ដេច ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងសូមសំពត់សម្បុរលើអំពីស្ដេចទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីកាលចាត់ចែងសំពត់ដណ្ដប់ដែលមានសាច់ស្ដើង ត្រូវចាត់ចែងបានត្រឹមតែសំពត់ដែលមានតម្លៃ ត្រឹមដប់កហាបណៈជាយ៉ាងខ្ពស់ បើចាត់ចែងឲ្យលើសពីកំណត់នោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។

(១៥៣) លហុបាវុរណំ នាម យំ កិញ្ចិ ឧណ្ហកាលេ បាវុរណំ ។ ចេតាបេតព្វន្តិ វិញ្ញាបេតព្វំ ។ អឌ្ឍតេយ្យកំសបរមំ ចេតាបេតព្វន្តិ ទសកហាបណគ្ឃនកំ ចេតាបេតព្វំ ។ តតោ ចេ ឧត្តរិ ចេតាបេយ្យាតិ ឧត្តរិ វិញ្ញាបេតិ បយោគេ ទុក្កដំ បដិលាភេន និស្សគ្គិយំ ហោតិ និស្សជ្ជិតព្វំ សង្ឃស្ស វា គណស្ស វា បុគ្គលស្ស វា ។ ឯវញ្ច បន ភិក្ខវេ និស្សជ្ជិតព្វំ ។ បេ ។ ឥទំ មេ អយ្យេ លហុបាវុរណំ អតិរេកឌ្ឍតេយ្យកំសបរមំ ចេតាបិតំ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមីតិ ។ បេ ។ ទទេយ្យាតិ ។ បេ ។ ទទេយ្យុន្តិ ។ អយ្យាយ ទម្មីតិ ។

(១៥៤) អតិរេកឌ្ឍតេយ្យកំសេ អតិរេកសញ្ញា ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ អតិរេកឌ្ឍតេយ្យកំសេ វេមតិកា ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។



(១៥៣) ដែលហៅថា សំពត់ដណ្តប់មានសាច់ស្តើង គឺសំពត់ណាមួយសម្រាប់ដណ្តប់ក្នុងរដូវក្តៅ ។ ត្រង់ពាក្យថា កាលដោះដូរ គឺការសូម ។ ពាក្យថា ត្រូវដោះដូរបានតែសំពត់ដណ្តប់មានថ្លៃត្រឹមបួនកហាបណៈ ៣ ដងដោយកន្លះ សេចក្តីថា ត្រូវសូមបានតែសំពត់ដែលមានថ្លៃ ១០ កហាបណៈ ។ ពាក្យថា បើដោះដូរឲ្យលើសកំណត់នោះទៅ សេចក្តីថា ភិក្ខុនីសូមឲ្យលើសអំពីកំណត់នោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសូម សំពត់នោះជានិស្សគ្គិយក្នុងវេលាដែលបានមក ។ ភិក្ខុនីត្រូវលះបង់ដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី ១ រូបក៏បាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះបង់យ៉ាងនេះ ។ បេ ។ បពិត្រលោកម្ចាស់ សំពត់ដណ្តប់ដែលមានសាច់ស្តើងនេះ មានថ្លៃលើសពីបួនកហាបណៈ ៣ ដងដោយកន្លះជាកំណត់ ខ្ញុំបានសូមហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបង់សំពត់នេះដល់សង្ឃ ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃនិស្សគ្គិយកណ្ឌ) ។

[១៥៤] សំពត់ដណ្តប់មានថ្លៃលើសពីបួនកហាបណៈ ៣ ដងដោយកន្លះ ភិក្ខុនីសំគាល់ថាលើសមែន ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ ។ សំពត់ដណ្តប់មានថ្លៃលើសពីបួនកហាបណៈ ៣ ដងដោយកន្លះ តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ ។

អតិរេកអឌ្ឍតេយ្យកំសេ ឩនកសញ្ញា ចេតាបេតិ និស្សគ្គិយំ បាចិត្តិយំ ។ ឩនកអឌ្ឍតេយ្យកំសេ អតិរេកសញ្ញា អាបត្តិ ទុក្កដស្ស ។ ឩនកអឌ្ឍតេយ្យកំសេ វេមតិកា អាបត្តិ ទុក្កដស្ស ។ ឩនកអឌ្ឍតេយ្យកំសេ ឩនកសញ្ញា អនាបត្តិ ។

(១៤៩) អនាបត្តិ អឌ្ឍតេយ្យកំសបរមំ ចេតាបេតិ ឩនកអឌ្ឍតេយ្យកំសបរមំ ចេតាបេតិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន មហគ្ឃំ ចេតាបេតុកាមស្ស អប្បគ្ឃំ ចេតាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



សំពត់ដណ្តប់មានដំឡៃលើសពីបួនកហាបណៈ ៣ ជង់ដោយកន្លះ ភិក្ខុនីសំគាល់ថាខ្វះ ហើយស្ដូម ត្រូវនិស្សគ្គិយបាចិត្តិយ ។ សំពត់ដណ្តប់មានដំឡៃតិចជាងបួនកហាបណៈ ៣ ជង់ដោយកន្លះ ភិក្ខុនីសំគាល់ថាលើសហើយ ត្រូវអាបត្តិទុក្កដ ។ សំពត់ដណ្តប់មានដំឡៃខ្វះពីបួនកហាបណៈ ៣ ជង់ដោយកន្លះ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សំពត់ដណ្តប់មានដំឡៃខ្វះពីបួនកហាបណៈ ៣ ជង់ដោយកន្លះ ភិក្ខុនីសំគាល់ថាខ្វះមែន មិនត្រូវអាបត្តិ ។

(១៤៩) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុនីសុំសំពត់ដណ្តប់មានដំឡៃត្រឹមបួនកហាបណៈ ៣ ជង់ដោយកន្លះ ១ ភិក្ខុនីសុំសំពត់ដណ្តប់មានដំឡៃតិចជាងបួនកហាបណៈ ៣ ជង់ដោយកន្លះជាកំណត់ ១ ភិក្ខុនីសុំសំពត់ដណ្តប់របស់ពួកញាតិ ១ ភិក្ខុនីសុំសំពត់ដណ្តប់របស់ពួកជនដែលបវារណា ១ ភិក្ខុនីសុំសំពត់ដណ្តប់ដើម្បីបុគ្គលដទៃ ១ ភិក្ខុនីចាត់សំពត់ដណ្តប់មកដោយទ្រព្យរបស់ខ្លួន ១ ជនប្រាថ្នាដើម្បីទិញសំពត់ដណ្តប់មានដំឡៃច្រើន ភិក្ខុនីក្រឡប់ឲ្យទិញសំពត់ដណ្តប់មានដំឡៃតិច ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

(៧៤៦) ឧទ្ទិដ្ឋា ខោ អយ្យាយោ តឹស និស្សគ្គិយា បាចិត្តិយា ធម្មា ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

និស្សគ្គិយា បាចិត្តិយា និដ្ឋិតា(១) ។

១ ម. ឆ. តឹសនិស្សគ្គិយំ និដ្ឋិតំ ។





(៧៤៦) បពិត្រលោកម្ចាស់ទាំងឡាយ ធម្មគឺនិស្សគ្គិយបាចិត្តិយ ៣០ ខ្ញុំសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសូមសួរជាគំរប់ពីរដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសូមសួរជាគំរប់បីដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងអាបត្តិទាំងនេះ ព្រោះហេតុនោះបានជាលោកទាំងឡាយស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

និស្សគ្គិយ បាចិត្តិយ ចប់ ។

ឥមេ ខោ បនាយ្យាយោ ឆសដ្ឋិសតា បាចិត្តិយា
ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## លសុណវគ្គស្ស បឋមសិក្ខាបទំ

(១៤៧) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរេន ឧបាសកេន ភិក្ខុនីសង្ឃោ លសុណេន បវារិតោ ហោតិ យាសំ អយ្យានំ លសុណេន អត្ថោ អហំ លសុណេនាតិ ។ ខេត្តបាលោ ច អាណត្តោ ហោតិ សចេ ភិក្ខុនិយោ អាគច្ឆន្តិ ឯកេកមេកាយ ភិក្ខុនិយា ទ្វេ តយោ ភណ្ឌិកេ ទេហីតិ ។ តេន ខោ បន សមយេន សាវត្ថិយំ ឧស្សវោ ហោតិ ។ យថាភតំ លសុណំ បរិក្ខយំ អគមាសិ ។ ភិក្ខុនិយោ តំ ឧបាសកំ ឧបសង្កមិត្វា ឯតទវោចុំ លសុណេន អាវុសោ អត្ថោតិ ។ នត្ថយ្យេ យថាភតំ លសុណំ បរិក្ខីណំ ខេត្តំ គច្ឆថាតិ ។ ថុល្លនន្ទា ភិក្ខុនី ខេត្តំ



បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះបាចិត្តិយថែន
នេះមានចំនួន ១៦៦ តែងមកកាន់ឧទ្ទេស (គឺការសូត្ររាល់ៗកន្លះខែ)

## លសុណវគ្គ សិក្ខាបទទី ១

(១៤៧) សម័យនោះ ព្រះពុទ្ធជាម្ចាស់ជាមានព្រះភាគ គង់នៅក្នុងជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានឧបាសកម្នាក់បវារណាភិក្ខុនីសង្ឃដោយខ្ទឹមថា លោកម្ចាស់ទាំងឡាយណា ត្រូវការដោយខ្ទឹម ខ្ញុំព្រះករុណា (នឹងប្រគេនខ្ទឹមដល់លោកម្ចាស់ទាំងឡាយនោះ) ។ ឧបាសកនោះក៏បង្គាប់អ្នកគ្រប់គ្រងការខ្ទឹមថា បើពួកភិក្ខុនីមក អ្នកឯងចូរប្រគេនខ្ទឹមពីរបីមើមដល់ភិក្ខុនី ១ អង្គ ៗ ។ សម័យនោះឯង ក្រុងសាវត្ថី (មានលេងល្បែង) មហោស្រព ។ ខ្ទឹមដែលឧបាសកបាននាំមក ក៏អស់ហើយទៅ ។ ពួកភិក្ខុនីចូលទៅរកឧបាសកនោះ ហើយបានពោលពាក្យនេះថា ម្នាលអាវុសោ យើងទាំងឡាយត្រូវការដោយខ្ទឹម ។ ឧបាសកនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ទឹមគ្មានទេ ខ្ទឹមដែលបាននាំមកអស់ហើយទៅហើយ សូមលោកម្ចាស់និមន្តទៅចំការចុះ ។ ថុល្លនន្ទាភិក្ខុនី

គន្ត្វា ន មត្តំ ជានិត្វា ពហុំ លសុណំ ហរាបេសិ ។ ខេត្តបាលោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនិយោ ខេត្តំ គន្ត្វា ន មត្តំ ជានិត្វា ពហុំ លសុណំ ហរាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ ខេត្តបាលស្ស(១) ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ន មត្តំ ជានិត្វា ពហុំ លសុណំ ហរាបេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ន មត្តំ ជានិត្វា ពហុំ លសុណំ ហរាបេសីតិ(២) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ន មត្តំ ជានិត្វា ពហុំ លសុណំ ហរាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ ភិក្ខវេ អប្បសន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយាតិ ។

១ ឱ. ម. តស្ស ខេត្តបាលស្សាតិ ទិស្សតិ ។ ២ ឱ. ម. ហរាបេសីតិ ។



ទៅកាន់ចំការហើយ មិនដឹងប្រមាណក៏ឲ្យគេនាំយកខ្ទឹមទៅជាច្រើន ។ មនុស្សអ្នករក្សាចំការក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងទៅកាន់ចំការហើយ មិនដឹងប្រមាណឲ្យគេនាំយកខ្ទឹមទៅច្រើនដល់ម្លេះសោះ ។ ភិក្ខុនីទាំងឡាយបានឮអ្នករក្សាចំការពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នេះ) ហើយ ។ ពួកភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងមិនដឹងប្រមាណឲ្យគេនាំយកខ្ទឹមមកច្រើនដល់ម្លេះសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីមិនដឹងប្រមាណ ឲ្យគេនាំយកខ្ទឹមច្រើន ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងមិនដឹងប្រមាណ ឲ្យគេនាំយកខ្ទឹមមកច្រើនដល់ម្លេះសោះ ម្នាលភិក្ខុទាំងឡាយ អំពើនោះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទៀតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យខានជ្រះថ្លាទៅវិញ នាំជនពួកខ្លះដែលជ្រះថ្លាស្រាប់ហើយឲ្យផ្លាស់ចិត្តខ្លួនគំនិតទៅវិញជាយ៉ាងដទៃ ។

[១៥៨] អថខោ ភគវា ថុល្លនន្ទំ ភិក្ខុនឹ អនេកបរិយាយេន វិគរហិត្វា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ភូតបុព្វំ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អញ្ញតរស្ស ព្រាហ្មណស្ស បជាបតី អហោសិ ។ តិស្សោ ច ធីតរោ នន្ទា នន្ទវតី សុន្ទរីនន្ទា ។ អថខោ ភិក្ខវេ សោ ព្រាហ្មណោ កាលំកត្វា អញ្ញតរំ ហំសយោនឹ ឧបបជ្ជិ ។ តស្ស សព្វសោវណ្ណមយា បត្តា អហេសុំ ។ សោ តាសំ ឯកេកំ បត្តំ ទេតិ ។ អថខោ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អយំ ហំសោ អម្ហាកំ ឯកេកំ បត្តំ ទេតីតិ តំ ហំសរាជំ គហេត្វា និប្បត្តំ អកាសិ ។ តស្ស បុន ជាយមានា បត្តា សេតា សម្បជ្ជិំសុ ។ តទាបិ[1] ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អតិលោភេន សុវណ្ណា បរិហីនា ឥទានិ លសុណា បរិហាយិស្សតីតិ ។

១ ឥទាបិ ឥតិ បោត្ថកេ ទិស្សតិ ។



[១៥៨] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលថុល្លនន្ទាភិក្ខុនី ដោយអនេកបរិយាយ ហើយទ្រង់ធ្វើធម្មីកថាដ៏សមគួរដល់ពេលនោះ ដ៏ល្មមគួរដល់ពេលនោះដល់ភិក្ខុទាំងឡាយ ទើបទ្រង់ហៅភិក្ខុមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ ថុល្លនន្ទាភិក្ខុនី ធ្លាប់បានជាប្រពន្ធព្រាហ្មណ៍ ១ នាក់ ។ នាងមានកូនស្រី ៣ នាក់ គឺនាងនន្ទា ១ នាងនន្ទវតី ១ នាងសុន្ទរីនន្ទា ១ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ ព្រាហ្មណ៍នោះកំពុងធ្វើមរណកាលទៅ កើតក្នុងកំណើតសត្វហង្ស ១ ។ ហង្សនោះមានស្លាបសុទ្ធសឹងជាមាស ។ ហង្សនោះឲ្យស្លាបមួយៗ ដល់ប្រពន្ធនឹងកូនស្រីទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីគិតថា ហង្សនេះបានឲ្យស្លាបមួយៗ ដល់យើងទាំងឡាយ គិតដូច្នោះហើយក៏ចាប់ស្តេចហង្សនោះហើយក៏ដកយកស្លាបចេញអស់ក្នុងកាលនោះឯង ។ ស្លាបទាំងឡាយរបស់ហង្សនោះកាលដុះឡើងទៀត ក៏សទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីសាបសូន្យចាកមាសក្នុងកាលនោះ ព្រោះតែសេចក្តីលោភហួស ឥឡូវនេះមកសាបសូន្យចាកខ្ទឹម ។

(១៧៩) យំ លទ្ធំ តេន តុដ្ឋព្វំ
អតិលោភោ ហិ បាបកោ ។
ហំសរាជំ គហេត្វាន
សុវណ្ណា បរិហាយថាតិ ។

(១៨០) អថខោ ភគវា ថុល្លនន្ទំ ភិក្ខុនឹ អនេកបរិយាយេន វិគរហិត្វា ។ បេ ។ ឯវញ្ច បន ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី លសុណំ ខាទេយ្យ បាចិត្តិយន្តិ ។

(១៨១) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ លសុណំ នាម មាគធកំ[១] វុច្ចតិ ។ ខាទិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

(១៨២) លសុណេ លសុណសញ្ញា ខាទតិ អាបត្តិ បាចិត្តិយស្ស ។ លសុណេ វេមតិកា ខាទតិ អាបត្តិ បាចិត្តិយស្ស ។ លសុណេ អលសុណសញ្ញា ខាទតិ

១ ឱសាបីយពោត្ថកេ មាគធកំ ទិស្សតិ ។



(១៧៩) ទ្រព្យណា ដែលខ្លួនបានហើយ គួរតែត្រេកអរដោយទ្រព្យនោះ ព្រោះថាសេចក្ដីលោភលើសលុបជាសភាវៈដ៏លាមក ។ ថុល្លនន្ទាភិក្ខុនីលុះចាប់ស្ដេចហង្សបានហើយ ក៏សាបសូន្យចាកមាស ។

(១៨០) លំដាប់នោះ ព្រះមានព្រះភាគទ្រង់តិះដៀលថុល្លនន្ទាភិក្ខុនី ដោយអនេកបរិយាយ ។ បេ ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយទំពាស៊ីខ្ទឹម ត្រូវអាបត្តិបាចិត្តិយ ។

(១៨១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយរួចហើយក្នុងសិក្ខាបទទី ១ ។ បេ ។ ដែលហៅថា ខ្ទឹម សំដៅយកខ្ទឹមដែលកើតក្នុងដែនមគធ ។ ភិក្ខុនីទទួលខ្ទឹមដោយគិតថា អាត្មានឹងទំពាស៊ី ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ ពំនូតដែលលេបចូលទៅ ។

(១៨២) ខ្ទឹម ភិក្ខុនីសំគាល់ថាខ្ទឹមមែន ហើយទំពាស៊ី ត្រូវអាបត្តិបាចិត្តិយ ។ ខ្ទឹម ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយទំពាស៊ី ត្រូវអាបត្តិបាចិត្តិយ ។ ខ្ទឹម ភិក្ខុនីសំគាល់ថាមិនមែនខ្ទឹម ហើយទំពាស៊ី ត្រូវអាបត្តិ

អាបត្តិ បាចិត្តិយស្ស ។ អលសុណេ លសុណសញ្ញា[១] អាបត្តិ ទុក្កដស្ស ។ អលសុណេ វេមតិកា[២] អាបត្តិ ទុក្កដស្ស ។ អលសុណេ អលសុណសញ្ញា[៣] អនាបត្តិ ។

(១៥៣) អនាបត្តិ បលណ្ឌុកេ ភញ្ជនកេ ហរិតកេ ចាបលសុណេ សូបសម្បាកេ មំសសម្បាកេ តេលសម្បាកេ សាឡវេ ឧត្តរិភង្គេ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## លសុណវគ្គស្ស ទុតិយសិក្ខាបទំ

(១៥៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ សម្ពាធេ លោមំ សំហរាបេត្វា អចិរវតិយា នទិយា វេសិយាហិ សទ្ធឹ នគ្គា ឯកតិត្ថេ នហាយន្តិ ។ វេសិយា ឧជ្ឈាយន្តិ

១-២-៣ [illegible] ទិស្សតិ ។



បាចិត្តិយ ។ មិនមែនខ្ទឹម ភិក្ខុនីសំគាល់ថាខ្ទឹម ត្រូវអាបត្តិទុក្កដ ។ មិនមែនខ្ទឹម ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនខ្ទឹម ភិក្ខុនីសំគាល់ថាមិនមែនខ្ទឹម មិនត្រូវអាបត្តិ ។

(១៥៣) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១១ យ៉ាង) គឺភិក្ខុនីឆាន់ខ្ទឹមបារាំង ១ ភិក្ខុនីឆាន់ខ្ទឹមក្រហម ១ ភិក្ខុនីឆាន់ខ្ទឹមខៀវ ១ ភិក្ខុនីឆាន់ខ្ទឹមឥតមើម (ខ្ទឹមដើម) ១ ភិក្ខុនីឆាន់ខ្ទឹមដែលគេចំអិនដោយសម្ល ១ ភិក្ខុនីឆាន់ខ្ទឹមដែលគេចំអិនដោយសាច់ ១ ភិក្ខុនីឆាន់ខ្ទឹមដែលគេចំអិនជាមួយប្រេង ១ ភិក្ខុនីឆាន់ខ្ទឹមដែលគេដាក់ក្នុងបរក្រៀវ ១ ភិក្ខុនីឆាន់ខ្ទឹមដែលគេដាក់ក្នុងសម្លការី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

## លសុណវគ្គ សិក្ខាបទទី ២

(១៥៤) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ព្រះអង្គគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនីឲ្យគេដករោមក្នុងទីចង្អៀត ហើយស្រាតខ្លួនងូតក្នុងកំពង់តែ ១ ជាមួយនឹងពួកស្រីពេស្យាក្នុងស្ទឹងអចិរវតី ។ ពួកស្រីពេស្យាតិះដៀល

ខិយន្តិ វិបាចេន្តិ កថំ ហិ ណាម ភិក្ខុនិយោ សម្ពាធេ លោមំ សំហរាបេស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តាសំ មនុស្សានំ ឧជ្ឈាយន្តីនំ ខិយន្តីនំ វិបាចេន្តីនំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយន្តិ វិបាចេន្តិ កថំ ហិ ណាម ឆព្វគ្គិយា ភិក្ខុនិយោ សម្ពាធេ លោមំ សំហរាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ សម្ពាធេ លោមំ សំហរាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ ណាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ សម្ពាធេ លោមំ សំហរាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនី សម្ពាធេ លោមំ សំហរាបេយ្យ បាចិត្តិយន្តិ ។

(១៥៥) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សម្ពាធោ នាម ឧភោ ឧបកច្ឆកា



ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេដករោមក្នុងទីចង្អៀត ដូចជាស្រីគ្រហស្ថបរិភោគកាមគុណសោះ ។ ពួកភិក្ខុនីបានឮស្រីស្រុកទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ) ហើយ ។ ពួកភិក្ខុនីណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេដករោមក្នុងទីចង្អៀតសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីទាំងឡាយឲ្យគេដករោមក្នុងទីចង្អៀត ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេដករោមក្នុងទីចង្អៀតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យគេដករោមក្នុងទីចង្អៀត ត្រូវអាបត្តិបាចិត្តិយ ។

(១៥៥) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ បេ ។ ដែលហៅថា ទីចង្អៀត បានដល់ក្លៀកទាំង

ទុក្កដស្ស ។ សំហរាបេយ្យាតិ ឯកម្បិ លោមំ សំហរាបេតិ អាបត្តិ បាចិត្តិយស្ស ។ ពហុកេបិ លោមេ សំហរាបេតិ អាបត្តិ បាចិត្តិយស្ស ។

[១៩៦] អនាបត្តិ អាពាធប្បច្ចយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## លសុណវគ្គស្ស តតិយសិក្ខាបទំ

[១៩៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ទ្វេ ភិក្ខុនិយោ អនភិរតិយា បីឡិតា ឱវរកំ បវិសិត្វា តលឃាតកំ ករោន្តិ ។ ភិក្ខុនិយោ តេន សទ្ទេន ឧបធាវិត្វា តា ភិក្ខុនិយោ ឯតទវោចុំ កិស្ស តុម្ហេ អយ្យេ បុរិសេន សទ្ធឹ សម្បទុស្សថាតិ(១) ។ ន មយំ អយ្យេ បុរិសេន សទ្ធឹ សម្បទុស្សាមាតិ(២) ។ ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ យា តា

១ ម. ឆ. សម្បទុស្សថាតិ ។ ២ សម្បទុស្សាមាតិ ។



កាំបិតកន្ត្រៃបន្តាបដើម្បីកំបុត ។ ពាក្យថា ឲ្យគេដក សេចក្តីថា ភិក្ខុនីឲ្យគេដករោមសូម្បីតែមួយសរសៃ ត្រូវអាបត្តិបាចិត្តិយ ។ ឲ្យគេដករោមច្រើនសរសៃ ត្រូវអាបត្តិបាចិត្តិយ ។

(១៩៦) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យគេដករោម ព្រោះហេតុមានអាពាធ (កើតឫសក្រមជាដើម) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## លសុណវគ្គ សិក្ខាបទទី ៣

(១៩៧) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីពីររូបមានសេចក្តីអផ្សុកមិនត្រេកអរបៀតបៀន ក៏ចូលទៅកាន់បន្ទប់ហើយធ្វើនូវកិរិយាទះនូវប្រដាប់នៃអង្គជាត ។ ពួកភិក្ខុនីស្ទុះចូលទៅដោយឮសំឡេងនោះ ហើយពោលនូវពាក្យនេះនឹងភិក្ខុនីទាំងនោះថា បពិត្រលោកម្ចាស់ ចុះហេតុអ្វីបានជាលោកទាំងពីរប្រទុស្តមួយអន្លើដោយបុរស ។ ភិក្ខុនីទាំងនោះឆ្លើយថា បពិត្រលោកម្ចាស់ យើងទាំងពីររូបមិនប្រទុស្តមួយអន្លើដោយបុរសទេ ។ ពួកភិក្ខុនីប្រាប់សេចក្តីនុះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីណា

ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ តលឃាតកំ ករិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ តលឃាតកំ ករោន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ តលឃាតកំ ករិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ តលឃាតកេ បាចិត្តិយន្តិ ។

(១៨៨) តលឃាតកំ នាម សម្ផស្សំ សាទិយន្តី អន្តមសោ ឧប្បលបត្តេនបិ មុត្តករណេ បហារំ ទេតិ អាបត្តិ បាចិត្តិយស្ស ។

(១៨៩) អនាបត្តិ អាពាធប្បច្ចយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



មានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងធ្វើនូវកិរិយាទះនូវផ្ទៃអង្គជាតសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីធ្វើនូវកិរិយាទះនូវផ្ទៃអង្គជាត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបើនឹងធ្វើនូវកិរិយាទះនូវផ្ទៃអង្គជាតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា អាបត្តិបាចិត្តិយមានដល់ភិក្ខុនី ព្រោះកិរិយាទះនូវផ្ទៃអង្គជាត ។

(១៨៨) ដែលហៅថា ទះនូវផ្ទៃអង្គជាត គឺភិក្ខុនីត្រេកអរនូវសម្ផស្ស ហើយឲ្យនូវប្រហារក្នុងអង្គជាតដោយចុងស្លឹកឈូក ដោយហោចទៅសូម្បីតែប្រហារដោយស្លឹកឧប្បល គឺត្រូវអាបត្តិបាចិត្តិយ ។

(១៨៩) ឯដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីទះយកអង្គជាតព្រោះហេតុតែមានអាពាធ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអ្នកដើមបញ្ញត្តិ ១ ។

## លសុណវគ្គស្ស ចតុត្ថសិក្ខាបទំ

(៦២០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរេ(១) បុរាណរាជោរោធា ភិក្ខុនីសុ បព្វជិតា ហោតិ ។ អញ្ញតរា ភិក្ខុនី អនភិរតិយា បីឡិតា យេន សា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុនឹ ឯតទវោច រាជា ខោ អយ្យេ តុម្ហេ ចិរាចិរំ គច្ឆតិ កថំ តុម្ហេ ធារេថាតិ ។ ជតុមដ្ឋកេន អយ្យេតិ ។ កឹ ឯតំ អយ្យេ ជតុមដ្ឋកន្តិ ។ អថខោ សា ភិក្ខុនី តស្សា ភិក្ខុនិយា ជតុមដ្ឋកំ អាចិក្ខិ ។ អថខោ សា ភិក្ខុនី ជតុមដ្ឋកំ អាទិយិត្វា ធោវិតុំ វិស្សរិត្វា ឯកមន្តំ ឆឌ្ឌេសិ ។ ភិក្ខុនិយោ មក្ខិកាហិ សម្បរិកិណ្ណំ បស្សិត្វា ឯវមាហំសុ កស្សិទំ កម្មន្តិ ។ សា ឯវមាហ មយ្ហិទំ កម្មន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

១ ម. ឱ. អញ្ញតរា បុរាណរាជោរោធា ភិក្ខុនីសុ បព្វជិតានី ទិស្សតិ ។

## លសុណវគ្គ សិក្ខាបទទី ៤

(៦២០) សម័យនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានស្រីព្រះស្នំរបស់ស្តេចពីដើម បួសក្នុងសំណាក់ពួកភិក្ខុនីទាំងឡាយ ។ ភិក្ខុនីមួយរូបទៀតមានសេចក្តីអផ្សុកមកបៀតបៀន ក៏ចូលទៅរកភិក្ខុនីនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ ស្តេចយូរៗ ទើបទ្រង់ស្តេចមកនឹងលោកម្តង តើលោកអាចកែក្តុខចរណាសេសសង្វាសដូចម្តេចទៅ ។ ភិក្ខុនីនោះប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំបានកែក្តុខដោយដំបងរមៀតសណ្ឋានលិង្គធ្វើពីជ័រល័ក្ត ។ ភិក្ខុនីដែលអផ្សុកសួរថា បពិត្រលោកម្ចាស់ ដំបងរមៀតសណ្ឋានលិង្គធ្វើអំពីជ័រល័ក្តនោះ តើដូចម្តេច ។ ទើបភិក្ខុនីនោះប្រាប់ដំបងរមៀតសណ្ឋានលិង្គធ្វើអំពីជ័រល័ក្តដល់ភិក្ខុនីនោះ ។ គ្រានោះ ភិក្ខុនីនោះកាន់យកដំបងរមៀតសណ្ឋានលិង្គធ្វើអំពីជ័រល័ក្ត ហើយភ្លេចលាងទឹក ក៏ដាក់ចោលទៅក្នុងទីដ៏សមគួរមួយ ។ ពួកភិក្ខុនីឃើញរុយពាំទ្រព្យរាយប៉ោមដំបងនោះ ក៏សួរថា នេះជាកម្មរបស់អ្នកណា ។ ភិក្ខុនីនោះពោលថា កម្មនេះជាកម្មរបស់ខ្ញុំ ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងកាន់យក

កថំ ហិ នាម ភិក្ខុនី ជតុមដ្ឋកំ អាទិយិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី ជតុមដ្ឋកំ អាទិយតីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី ជតុមដ្ឋកំ អាទិយិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ ជតុមដ្ឋកេ បាចិត្តិយន្តិ ។

(១៦៧) ជតុមដ្ឋកំ នាម ជតុមយំ កដ្ឋមយំ បិដ្ឋមយំ មត្តិកាមយំ(២) ។ សម្ផស្សំ សាទិយន្តី អន្តមសោ ឧប្បលបត្តម្បិ មុត្តករណំ បវេសតិ អាបត្តិ បាចិត្តិយស្ស ។

(១៦៨) អនាបត្តិ អាពាធប្បច្ចយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

១ ម. ឆ. អាទិយតីតិ ។ ២ ម. ឆ. ឯត្ថន្តរេ អាទិយេយ្យាតិ ទិស្សតិ ។



ដំបងខ្លី មានសណ្ឋានលើងដែលគេធ្វើពីកាចមល័ក្ខសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីកាន់យកដំបងខ្លីមានសណ្ឋានលើងដែលគេធ្វើពីកាចមល័ក្ខ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងកាន់យកដំបងខ្លី មានសណ្ឋានលើងដែលគេធ្វើពីកាចមល័ក្ខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា អាបត្តិបាចិត្តិយ មានដល់ភិក្ខុនី ព្រោះដំបងខ្លីមានសណ្ឋានលើងដែលគេធ្វើពីកាចមល័ក្ខ ។

(១៦៧) ដែលហៅថា ដំបងខ្លីមានសណ្ឋានលើងដែលគេធ្វើពីកាចមល័ក្ខ បានដល់ដំបងខ្លីដែលគេធ្វើដោយកាចមល័ក្ខក្តី ឈើក្តី ម្សៅក្តី ដីស្អិតក្តី ។ ភិក្ខុនីកាលត្រេកអរនូវសម្ផស្ស ដោយហោចទៅត្រឹមតែស្លឹកឧប្បលឲ្យចូលទៅកាន់ទ្វារៈជាទីបន្ទោបង់នូវមូត្រ ត្រូវអាបត្តិបាចិត្តិយ ។

(១៦៨) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមានលំដាប់) គឺ ភិក្ខុនីញុំាងដំបងខ្លីឲ្យចូលទៅក្នុងផ្លូវមូត្រ ព្រោះហេតុតែមានអាពាធ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

# លសុណវគ្គស្ស បញ្ចមសិក្ខាបទំ

(១៦៣) តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា អជោភាតេ អដ្ឋាសិ ទុគ្គន្ធោ ភន្តេ មាតុគ្គាមោតិ ។ អថខោ ភគវា អាទិយន្តុ ភិក្ខុនិយោ ឧទកសុទ្ធិកន្តិ មហាបជាបតឹ គោតមឹ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ មហាបជាបតី គោតមី ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភិក្ខុនីនំ ឧទកសុទ្ធិកន្តិ ។

# លសុណវគ្គ សិក្ខាបទទី ៥

(១៦៣) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគព្រះអង្គគង់នៅនិគ្រោធារាម ទៀបក្រុងកបិលព័ស្តុក្នុងដែនសក្កៈ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ទិតនៅក្នុងទីដ៏សមគួរ ក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ មាតុគ្រាមមានក្លិនអាក្រក់ ។ ទើបព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាថា ពួកភិក្ខុនីចូរធ្វើការជម្រះដោយទឹកចុះ ហើយទ្រង់ញុំាងព្រះមហាបជាបតិគោតមីឲ្យយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ព្រះនាងមហាបជាបតិគោតមី កាលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា រួចហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយក្នុងវេលានោះមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការជម្រះដោយទឹកដល់ពួកភិក្ខុនី ។

[១៦៦] តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី ភគវតា ឧទកសុទ្ធិកា អនុញ្ញាតាតិ អតិគម្ភីរំ ឧទកសុទ្ធិកំ អាទិយន្តី មុត្តករណេ វណំ អកាសិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី អតិគម្ភីរំ ឧទកសុទ្ធិកំ អាទិយិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី អតិគម្ភីរំ ឧទកសុទ្ធិកំ អាទិយតីតិ[1] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី អតិគម្ភីរំ ឧទកសុទ្ធិកំ អាទិយិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ ឧទកសុទ្ធិកំ បន ភិក្ខុនិយា អាទិយមានាយ ទ្វង្គុលបព្វបរមំ អាទាតព្វំ តំ អតិក្កាមេន្តិយា បាចិត្តិយន្តិ ។

---

១ ឱ ម. អាទិយីតិ ។



[១៦៦] សម័យនោះឯង មានភិក្ខុនី ១ រូបគិតថា ការជម្រះដោយទឹក ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ (គិតដូច្នេះហើយ) ក៏ធ្វើការជម្រះដោយទឹកជ្រៅពេក ហើយក៏ធ្វើឲ្យកើតដំបៅក្នុងទីជាទីបន្ទោបង់នូវទឹកមូត្រ ។ ទើបភិក្ខុនីនោះ ប្រាប់សេចក្តីនុះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងធ្វើការជម្រះដោយទឹកជ្រៅពេកសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីធ្វើការជម្រះដោយទឹកជ្រៅពេក ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងធ្វើការជម្រះដោយទឹកជ្រៅពេកសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលភិក្ខុនីធ្វើការជម្រះដោយទឹក ត្រូវធ្វើការជម្រះបានត្រឹមតែពីរធ្នាប់ម្រាមដៃជាកំណត់ កាលឲ្យកន្លងហួសកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

(១៦៥) ឧទកសុទ្ធិកា នាម មុត្តករណស្ស ធោវនា វុច្ចតិ ។ អាទិយមានាតិ ធោវន្តិយា ។ ទ្វង្គុលបព្វបរមំ អាទាតព្វន្តិ ទ្វីសុ អង្គុលីសុ ទ្វេ បព្វបរមា អាទាតព្វា ។ តំ អតិក្កាមេន្តិយាតិ សម្ផស្សំ សាទិយន្តី អន្តមសោ កេសគ្គមត្តម្បិ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

(១៦៦) អតិរេកទ្វង្គុលបព្វេ អតិរេកសញ្ញា អាទិយតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកទ្វង្គុលបព្វេ វេមតិកា អាទិយតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកទ្វង្គុលបព្វេ ឩនកសញ្ញា អាទិយតិ អាបត្តិ បាចិត្តិយស្ស ។ ឩនកទ្វង្គុលបព្វេ អតិរេកសញ្ញា អាបត្តិ ទុក្កដស្ស ។ ឩនកទ្វង្គុលបព្វេ វេមតិកា អាបត្តិ ទុក្កដស្ស ។ ឩនកទ្វង្គុលបព្វេ ឩនកសញ្ញា អនាបត្តិ ។



(១៦៥) ដែលហៅថា ការជម្រះដោយទឹក សំដៅយកការលាងអវយវៈសម្រាប់បន្ទោបង់នូវទឹកមូត្រ ។ ត្រង់ពាក្យថា កាលធ្វើ គឺកាលលាង ។ ពាក្យថា ត្រូវធ្វើការជម្រះបានត្រឹមពីរថ្នាំងម្រាមដៃជាកំណត់ សេចក្ដីថា ភិក្ខុនីត្រូវលាងបានត្រឹមពីរថ្នាំងម្រាមដៃទាំងពីរ ។ ពាក្យថា កាលឲ្យកន្លងហួសពីកំណត់នោះទៅ សេចក្ដីថា កាលភិក្ខុនីត្រេកអរនូវសម្ផស្ស ហើយធ្វើឲ្យកន្លងកំណត់នោះទៅ ដោយហោចទៅសូម្បីតែប៉ុនចុងសក់ ក៏ត្រូវអាបត្តិបាចិត្តិយ ។

(១៦៦) ការជម្រះហួសកំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថាហួសមែន ហើយលាង ត្រូវអាបត្តិបាចិត្តិយ ។ ការជម្រះហួសកំណត់ពីរថ្នាំងម្រាមដៃ តែភិក្ខុនីសង្ស័យ ហើយលាង ត្រូវអាបត្តិបាចិត្តិយ ។ ការជម្រះហួសកំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថាមិនទាន់ហួសកំណត់ហើយលាង ត្រូវអាបត្តិបាចិត្តិយ ។ ការជម្រះមិនទាន់ដល់កំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថាលើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ការជម្រះមិនទាន់ដល់កំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ការជម្រះមិនទាន់ដល់កំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថា មិនទាន់ដល់កំណត់មែន មិនត្រូវអាបត្តិ ។

[១៦៧] អនាបត្តិ ទ្វង្គុលបព្វបរមំ អាទិយតិ ឩនកំ ទ្វង្គុលបព្វបរមំ អាទិយតិ អាពាធប្បច្ចយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## លសុណវគ្គស្ស ឆដ្ឋសិក្ខាបទំ

[១៦៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អារោហន្តោ នាម មហាមត្តោ ភិក្ខូសុ បព្វជិតោ ហោតិ ។ តស្ស បុរាណទុតិយិកា ភិក្ខុនីសុ បព្វជិតា ហោតិ ។ តេន ខោ បន សមយេន សោ ភិក្ខុ តស្សា ភិក្ខុនិយា សន្តិកេ ភត្តវិស្សគ្គំ ករោតិ ។ អថខោ សា ភិក្ខុនី តស្ស ភិក្ខុនោ ភុញ្ជន្តស្ស បានីយេន ច វិធូបនេន ច ឧបតិដ្ឋិត្វា អច្ចាវទតិ ។ អថខោ សោ ភិក្ខុ តំ ភិក្ខុនឹ អបសាទេតិ មា ភគិនិ ឯវរូបំ អកាសិ នេតំ កប្បតីតិ ។ បុព្វេ មំ ត្វំ ឯវញ្ច ឯវញ្ច ករោសិ ឥទានិ ឯត្តកំ ន



[១៦៧] ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុនីលាងកំណត់ត្រឹមពីរថ្នាំងម្រាមដៃ ១ ភិក្ខុនីលាងថយកំណត់ពីរថ្នាំងម្រាមដៃ ១ ភិក្ខុនីលាងហួសកំណត់ព្រោះហេតុនៃអាពាធ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាតន់ដើមបញ្ញត្តិ ១ ។

---

## លសុណវគ្គ សិក្ខាបទទី៦

[១៦៨] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានមហាមាត្យឈ្មោះអារោហន្ត បួសក្នុងសំណាក់ពួកភិក្ខុ ។ ស្រីជាប្រពន្ធរបស់មហាមាត្យនោះក៏បួសក្នុងសំណាក់ពួកភិក្ខុនីដែរ ។ គ្រានោះឯង ភិក្ខុនោះធ្វើនូវភត្តកិច្ច (ឆាន់ចង្ហាន់) ក្នុងសំណាក់ភិក្ខុនីនោះ ។ កាលភិក្ខុនោះកំពុងឆាន់ ភិក្ខុនីនោះបម្រើដោយទឹកផឹក ដោយផ្លិតផង ហើយនិយាយប៉ះទាំដោយពាក្យស្និទ្ធស្នាល ។ គ្រានោះ ភិក្ខុនោះបណ្តេញភិក្ខុនីនោះចេញដោយពាក្យថា នាងប្អូនស្រី នាងកុំធ្វើឲ្យកើតមានសភាពយ៉ាងនេះ ការនេះមិនគួរទេ ។ ភិក្ខុនីនោះនិយាយថា ក៏ដើមលោកធ្វើឲ្យកើតយ៉ាងនេះ ផងនិងនេះ ឥឡូវនេះលោកមិនអាចនឹងធ្វើឲ្យកើតមានប្រមាណប៉ុណ្ណោះទេ

សមាសីតិ ទាតីយ ថាលកំ មត្ថកេ អាសុម្ភិត្វា វិធូប-នេន បហារំ អទាសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី ភិក្ខុស្ស បហារំ ទស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី ភិក្ខុស្ស បហារំ ទេតីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី ភិក្ខុស្ស បហារំ ទស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនី ភិក្ខុស្ស ភុញ្ជន្តស្ស បានីយេន វា វិធូបនេន វា ឧប-តិដ្ឋេយ្យ បាចិត្តិយន្តិ ។

[១៦៨] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុស្សាតិ ឧបសម្បន្នស្ស ។ ភុញ្ជន្តស្សាតិ បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ ភុញ្ជន្តស្ស ។ បានីយំ

១ ម. ឱ. ទស្សតិ ។



ជាប់បច្ចាហើយ ក៏ចាក់ស្រោចទឹកពីលើក្បាលភិក្ខុនោះ ហើយក៏យកនូវផ្លិតវាយទៀត ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងវាយភិក្ខុសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីវាយភិក្ខុ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងវាយភិក្ខុសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយកាលភិក្ខុកំពុងឆាន់ ចាំបម្រើដោយទឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ ។

[១៦៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបាលីខាងដើមរួចហើយ ។ ពាក្យថា ភិក្ខុ សេចក្តីថា បុរសដែលបានឧបសម្បទហើយ ។ ពាក្យថា កាលភិក្ខុកំពុងឆាន់ សេចក្តីថា ភិក្ខុឆាន់ភោជនណាមួយ ក្នុងភោជនទាំង ៥ យ៉ាង ។ ដែលហៅថា ទឹក បានដល់ទឹក

នាម យំ កិញ្ចិ បានីយំ ។ វិធូបនំ នាម យា កាចិ វីជនី ។ ឧបតិដ្ឋេយ្យាតិ ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។

(១៧០) ឧបសម្បន្នេ ឧបសម្បន្នសញ្ញា បានីយេន វា វិធូបនេន វា ឧបតិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកា បានីយេន វា វិធូបនេន វា ឧបតិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញា បានីយេន វា វិធូបនេន វា ឧបតិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ ហត្ថបាសំ វិជហិត្វា ឧបតិដ្ឋតិ អាបត្តិ ទុក្កដស្ស ។ ខាទនីយំ ខាទន្តស្ស ឧបតិដ្ឋតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នស្ស ឧបតិដ្ឋតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។

(១៧១) អនាបត្តិ ទេតិ ទាបេតិ អនុបសម្បន្នំ អាណាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ទឹកគួរសម្រាប់ផឹកណាមួយ ។ ដែលហៅថា ផ្លិត បានដល់ផ្លិតសម្រាប់បក់ណាមួយ ។ ពាក្យថា បម្រើ សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយ ។

(១៧០) ឧបសម្បន្ន ភិក្ខុនីសំគាល់ថាឧបសម្បន្នមែន ហើយបម្រើដោយទឹកផឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ហើយបម្រើដោយទឹកផឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុនីសំគាល់ថាអនុបសម្បន្នវិញ ហើយបម្រើដោយទឹកផឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីលះបង់ហត្ថបាសហើយបម្រើ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុកំពុងទំពាស៊ីខាទនីយ ភិក្ខុនីបម្រើ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីបម្រើបុរសជាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាឧបសម្បន្នវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាអនុបសម្បន្នមែន ត្រូវអាបត្តិទុក្កដ ។

(១៧១) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ (ភិក្ខុនីប្រគេនគេមានទឹកជាដើម) ដល់ភិក្ខុដោយដៃខ្លួនឯង ១ ភិក្ខុនីឲ្យគេប្រគេនដល់ភិក្ខុ ១ ភិក្ខុនីបង្គាប់អនុបសម្បន្ន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## លសុណវគ្គស្ស សត្តមសិក្ខាបទំ

[១៧៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ សស្សកាលេ អាមកធញ្ញំ វិញ្ញាបេត្វា នគរំ អតិហរន្តិ ។ ទ្វារដ្ឋានេ(១) ទេថយ្យេ ភាគន្តិ បលិពុន្ធិត្វា មុញ្ចិំសុ ។ អថខោ តា ភិក្ខុនិយោ ឧបស្សយំ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អាមកធញ្ញំ វិញ្ញាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អាមកធញ្ញំ វិញ្ញាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អាមកធញ្ញំ វិញ្ញាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី

១ ទ្វារបាលាតិ គម្ពីរ បោត្ថកេ ទិស្សតិ ។

## លសុណវគ្គ សិក្ខាបទទី ៧

[១៧៦] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុនីនាំគ្នាសូមស្រូវស្រស់ក្នុងរដូវស្រូវ ហើយដឹកនាំទៅកាន់ក្រុង ។ មនុស្សទាំងឡាយឃាត់ហ្មត់ពួកភិក្ខុនីក្នុងទីទៀបទ្វារនគរ ដោយពាក្យថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយចូរឲ្យចំណែក(យើង)ខ្លះ ដូច្នោះហើយក៏លែងទៅ ។ ទើបពួកភិក្ខុនីទាំងនោះទៅកាន់លំនៅ ហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនាំគ្នាសូមស្រូវស្រស់សោះ ។បេ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីនាំគ្នាសូមស្រូវស្រស់ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបើនាំគ្នាសូមស្រូវស្រស់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីចូរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ

អាមកធញ្ញំ វិញ្ញាបេត្វា(១) វា វិញ្ញាបាបេត្វា(២) វា ភជ្ជិត្វា វា ភជ្ជាបេត្វា វា កោដ្ដេត្វា(៣) វា កោដ្ដាបេត្វា វា បចិត្វា វា បចាបេត្វា វា ភុញ្ជេយ្យ បាចិត្តិយន្តិ ។

(១៧៣) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីនំ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អាមកធញ្ញំ នាម សាលិ វីហិ យវោ គោធុមោ កង្គុ វរកោ កុទ្រូសកោ ។ វិញ្ញាបេត្វាតិ សយំ វិញ្ញាបេត្វា ។ វិញ្ញាបាបេត្វាតិ អញ្ញំ វិញ្ញាបាបេត្វា ។ ភជ្ជិត្វាតិ សយំ ភជ្ជិត្វា ។ ភជ្ជាបេត្វាតិ អញ្ញំ ភជ្ជាបេត្វា ។ កោដ្ដេត្វាតិ សយំ កោដ្ដេត្វា ។ កោដ្ដាបេត្វាតិ អញ្ញំ កោដ្ដាបេត្វា ។ បចិត្វាតិ សយំ បចិត្វា ។ បចាបេត្វាតិ អញ្ញំ បចាបេត្វា ។ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

(១៧៤) អនាបត្តិ អាពាធប្បច្ចយា អបរណ្ណំ វិញ្ញាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

១ ម. វិញ្ញត្វា ។ ២ ម. វិញ្ញាបេត្វា ។ ៣ ម. កោដ្ដិត្វា ។



សូមឯងក្តី ឲ្យគេសូមក្តី កិនឯងក្តី ឲ្យគេកិនក្តី បុកឯងក្តី ឲ្យគេបុកក្តី ចំអិនឯងក្តី ឲ្យគេចំអិនក្តី នូវស្រូវស្រស់ ហើយបរិភោគ ត្រូវអាបត្តិបាចិត្តិយ ។

(១៧៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ដែលហៅថា ស្រូវស្រស់ បានដល់ស្រូវខ្សាយស ស្រូវខ្សាយក្រហម ស្រូវដំណើប ស្រូវទន់ ស្គោ ស្កួយ នៃលបក ។ ពាក្យថា សូមឯង គឺសូមដោយខ្លួនឯង ។ ពាក្យថា ឲ្យគេសូម គឺឲ្យអ្នកដទៃសូម ។ ពាក្យថា កិនឯង សេចក្តីថា កិនដោយដៃខ្លួនឯង ។ ពាក្យថា ឲ្យគេកិន គឺឲ្យអ្នកដទៃកិន ។ ពាក្យថា បុកឯង គឺបុកដោយដៃខ្លួនឯង ។ ពាក្យថា ឲ្យគេបុក គឺឲ្យអ្នកដទៃបុក ។ ពាក្យថា ចំអិនឯង គឺចំអិនដោយដៃខ្លួនឯង ។ ពាក្យថា ឲ្យគេចំអិន គឺឲ្យអ្នកដទៃចំអិន ។ ភិក្ខុនីទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ ករដែលលេបចូលទៅ ។

(១៧៤) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីសូមព្រោះហេតុមានអាពាធ ១ ភិក្ខុនីសូមអបរណ្ណជាតិ (មានសណ្តែកល្ងជាដើម) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

# លសុណវគ្គស្ស អដ្ឋមសិក្ខាបទំ

[១៧៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ព្រាហ្មណោ និព្វិដ្ឋរាជភដោ តញ្ញេវ ភដបថំ យាចិស្សាមីតិ សីសំ នហាយិត្វា ភិក្ខុនុបស្សយំ និស្សាយ រាជកុលំ គច្ឆតិ ។ អញ្ញតរា ភិក្ខុនី កដាហេ វច្ចំ កត្វា តិរោកុដ្ដេ ឆឌ្ឌេន្តី តស្ស ព្រាហ្មណស្ស មត្ថកេ អាសុម្ភិ ។ អថ ខោ សោ ព្រាហ្មណោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ អស្សមណិយោ ឥមា មុណ្ឌា ពន្ធកិនិយោ កថំ ហិ នាម គូថកដាហំ មត្ថកេ អាសុម្ភិស្សន្តិ ឥមាសំ ឧបស្សយំ ឈាបេស្សាមីតិ ឧម្មុកំ(១) គហេត្វា ឧបស្សយំ បវិសតិ ។ អញ្ញតរោ ឧបាសកោ ឧបស្សយា និក្ខមន្តោ អទ្ទស តំ ព្រាហ្មណំ ឧម្មុកំ(២) គហេត្វា ឧបស្សយំ បវិសន្តំ ទិស្វាន តំ ព្រាហ្មណំ ឯតទវោច កិស្ស ត្វំ ភោ ឧម្មុកំ(៣) គហេត្វា ឧបស្សយំ

១.២-៣ តិណុក្កន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

# លសុណវគ្គ សិក្ខាបទទី ៨

[១៧៥] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ជាភដការមាត្យដែលស្តេចដកចេញហើយ គិតថា អញនឹងសូមការនោះវិញ គិតដូច្នោះហើយក៏កក់ក្បាល ហើយទៅអាស្រ័យនៅក្បែរទីសំណាក់ភិក្ខុនី រួចទើបដើរទៅកាន់ត្រកូលស្តេច ។ មានភិក្ខុនី ១ អង្គ កាលបន្ទោបង់វច្ចៈក្នុងខ្ទះ ហើយចោលទៅខាងក្រៅជញ្ជាំងក៏ត្រូវលើក្បាលព្រាហ្មណ៍នោះ ។ ទើបព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីត្រងោលទាំងនេះមិនមែនជាសមណី ជាស្រីផ្តាមាស មិនសមបើនឹងចាក់ខ្ទះលាមកលើក្បាលអញសោះ ហើយព្រាហ្មណ៍នោះ ក៏កាន់ចុងអុសដើរចូលទៅកាន់លំនៅរបស់ភិក្ខុនីដោយគិតថា អញនឹងដុតលំនៅពួកភិក្ខុនីទាំងនេះចេញ ។ មានឧបាសកម្នាក់កំពុងដើរចេញពីលំនៅរបស់ភិក្ខុនី បានឃើញព្រាហ្មណ៍នោះកាន់ចុងអុសដើរចូលទៅកាន់លំនៅរបស់ភិក្ខុនី លុះបានឃើញហើយក៏បាននិយាយពាក្យនេះនឹងព្រាហ្មណ៍នោះថា ម្នាលអ្នកដ៏ចំរើន អ្នកកាន់ចុងអុសដើរចូលទៅកាន់

បវិសសីតិ ។ ឥមា ភោ មំ មុណ្ឌា ពន្ធកិនិយោ គូថក-
ដាហំ មត្ថកេ អាសុម្ភិំសុ ឥមាសំ ឧបស្សយំ ឈាបេស្សា-
មីតិ ។ គច្ឆ ភោ មង្គលំ ឯតំ សហស្សំ លច្ឆសិ តញ្ច
ភោគន្តិ ។ អថខោ សោ ព្រាហ្មណោ សីសំ នហា-
យិត្វា រាជកុលំ គន្ត្វា សហស្សំ អលត្ថ តញ្ច ភោ-
គំ ។ អថខោ សោ ព្រាហ្មណោ ឧបស្សយំ បវិសិត្វា
ភិក្ខុនីនំ ឯតមត្ថំ អារោចេត្វា បរិភាសិ ។ យា តា
ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ
វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឧច្ចារំ តិរោកុឌ្ឌេ
ឆឌ្ឌេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ
ឧច្ចារំ តិរោកុឌ្ឌេ ឆឌ្ឌេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ
ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ
ឧច្ចារំ តិរោកុឌ្ឌេ ឆឌ្ឌេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ
វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ
ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ឧច្ចារំ វា



លំនៅរបស់ភិក្ខុនី ព្រោះហេតុអ្វី ។ ព្រាហ្មណ៍នោះឆ្លើយថា ម្នាលអ្នកដ៏ចំរើន
ពួកភិក្ខុនីត្រងោលទាំងនេះជាស្រីផ្កាមាស ចាក់លាមកចុះមកលើក្បាល
ខ្ញុំ ។ ខ្ញុំនឹងដុតលំនៅពួកភិក្ខុនីទាំងនេះ ។ ឧបាសកនោះឆ្លើយថា ម្នាលអ្នក
ដ៏ចំរើន អ្នកឯងចូរទៅចុះ ហេតុនេះជាមង្គលល្អទេ អ្នកនឹងបាន ១ ពាន់
កហាបណៈផង នឹងបានទ្រព្យនោះផង ។ កាលនោះ ព្រាហ្មណ៍នោះ ក៏កក់
លាងក្បាលរួចទៅកាន់រាជត្រកូល ក៏បាន ១ ពាន់កហាបណៈផង នឹងទ្រព្យ
នោះផង ។ គ្រានោះ ឧបាសកនោះចូលទៅកាន់លំនៅរបស់ភិក្ខុនីទាំង
ឡាយ ហើយប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុនី រួចពោលហាមប្រាម ។
ពួកភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស
តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងចោលឧច្ចារៈទៅខាងក្រៅ
ជញ្ជាំងសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួក
ភិក្ខុនីចោលឧច្ចារៈទៅខាងក្រៅជញ្ជាំង ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា
បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់
តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបើនឹងចោលឧច្ចារៈទៅ
ខាងក្រៅជញ្ជាំងទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់
ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ-
នីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយចោលឧច្ចារៈក្តី

បស្សាវំ វា សង្ការំ វា វិឃាសំ វា តិរោកុដ្ដេ វា តិរោបាការេ វា ឆឌ្ឌេយ្យ វា ឆឌ្ឌាបេយ្យ វា បាចិត្តិយន្តិ ។

(១៧៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឧច្ចារោ នាម គូថោ វុច្ចតិ ។ បស្សាវោ នាម មុត្តំ វុច្ចតិ ។ សង្ការំ នាម កចវរំ វុច្ចតិ ។ វិឃាសំ នាម ចលកានិ វា អដ្ឋិកានិ វា ឧច្ឆិដ្ឋោទកំ វា វុច្ចតិ[១] ។ កុដ្ដោ នាម តយោ កុដ្ដា ឥដ្ឋកាកុដ្ដោ សិលាកុដ្ដោ ទារុកុដ្ដោ ។ បាការោ នាម តយោ បាការា ឥដ្ឋកាបាការោ សិលាបាការោ ទារុបាការោ ។ តិរោកុដ្ដេតិ កុដ្ដស្ស បរតោ ។ តិរោបាការេតិ បាការស្ស បរតោ ។ ឆឌ្ឌេយ្យាតិ សយំ ឆឌ្ឌេតិ អាបត្តិ បាចិត្តិយស្ស ។ ឆឌ្ឌាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស សកឹ អាណត្តា ពហុកម្បិ ឆឌ្ឌេតិ អាបត្តិ បាចិត្តិយស្ស ។

(១៧៧) អនាបត្តិ ឱលោកេត្វា ឆឌ្ឌេតិ អវលញ្ជេ ឆឌ្ឌេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ឲ្យគេចោលក្តី ឧច្ចារៈក្តី បស្សាវៈក្តី សម្រាមក្តី កាកអាហារក្តី ទៅខាងក្រៅជញ្ជាំងក្តី ខាងក្រៅរបងក្តី ត្រូវអាបត្តិបាចិត្តិយ ។

[១៧៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានសេចក្តីអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ដែលហៅថា ឧច្ចារៈ បានដល់លាមក ។ ដែលហៅថា បស្សាវៈ បានដល់ទឹកមូត្រ ។ ដែលហៅថា សម្រាម បានដល់កំទេចកំទី ។ ដែលហៅថា កាកអាហារ គឺសំណល់ចំណីឡាយក្តី ឆ្អឹងចំណីឡាយក្តី ទឹកជំរះសេសសល់ក្តី ។ ដែលហៅថា ជញ្ជាំង បានដល់ជញ្ជាំងបីយ៉ាង គឺជញ្ជាំងឥដ្ឋ ជញ្ជាំងថ្ម ជញ្ជាំងឈើ ។ ដែលហៅថា របង បានដល់របងបីយ៉ាង គឺរបងឥដ្ឋ របងថ្ម របងឈើ ។ ពាក្យថា ខាងក្រៅជញ្ជាំង គឺខាងនាយជញ្ជាំង ។ ពាក្យថា ខាងក្រៅរបង គឺខាងនាយរបង ។ ពាក្យថា បោះចោល សេចក្តីថា ភិក្ខុនីបោះចោលដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ឲ្យគេចោល សេចក្តីថា ភិក្ខុនីបង្គាប់ឲ្យអ្នកដទៃចោល ត្រូវអាបត្តិទុក្កដ ភិក្ខុនីប្រើតែម្តង អ្នកទទួលបង្គាប់ចោលច្រើនដង ត្រូវអាបត្តិបាចិត្តិយ ។

[១៧៧] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុនីពិនិត្យមើលទីដីសមគួរហើយទើបចោល ១ ភិក្ខុនីចោលក្នុងទីដែលគេមិនប្រើប្រាស់ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## លសុណវគ្គស្ស នវមសិក្ខាបទំ

[១៧៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ព្រាហ្មណស្ស ភិក្ខុនុបស្សយំ និស្សាយ យវក្ខេត្តំ ហោតិ ។ ភិក្ខុនិយោ ឧច្ចារម្បិ បស្សាវម្បិ សង្ការម្បិ វិឃាសម្បិ ខេត្តេ ឆឌ្ឌេន្តិ ។ អថខោ សោ ព្រាហ្មណោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនិយោ អម្ហាកំ យវក្ខេត្តំ ទូសេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តស្ស ព្រាហ្មណស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឧច្ចារម្បិ បស្សាវម្បិ សង្ការម្បិ វិឃាសម្បិ ហរិតេ ឆឌ្ឌេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ឧច្ចារម្បិ បស្សាវម្បិ សង្ការម្បិ វិឃាសម្បិ ហរិតេ ឆឌ្ឌេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ឧច្ចារម្បិ បស្សាវម្បិ សង្ការម្បិ

## លសុណវគ្គ សិក្ខាបទទី៩

[១៧៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានស្រែស្រូវដំណើបរបស់ព្រាហ្មណ៍ម្នាក់ នៅជិតលំនៅរបស់ភិក្ខុនី ។ ពួកភិក្ខុនីបោះឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ របស់ជាសំណល់ខ្លះទៅក្នុងស្រែ ។ ឯព្រាហ្មណ៍នោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងប្រទូស្តស្រែស្រូវដំណើបរបស់យើងសោះ ។ ពួកភិក្ខុនីឮព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងបោះឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ របស់ជាសំណល់ខ្លះ ក្នុងទីមានតិណមានពណ៌ខៀវសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីបោះឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ របស់ជាសំណល់ខ្លះ ក្នុងទីមានតិណមានពណ៌ខៀវ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា ពិតមែនព្រះដ៏មានព្រះភាគពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបើនឹងបោះឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ វត្ថុជាសំណល់ខ្លះ

វិឃាសម្បិ ហរិតេ ឆឌ្ឌេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ឧច្ចារំ វា បស្សាវំ វា សង្ការំ វា វិឃាសំ វា ហរិតេ ឆឌ្ឌេយ្យ វា ឆឌ្ឌាបេយ្យ វា បាចិត្តិយន្តិ ។

(១៧៩) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឧច្ចារោ នាម គូថោ វុច្ចតិ ។ បស្សាវោ នាម មុត្តំ វុច្ចតិ ។ សង្ការំ នាម កចវរំ វុច្ចតិ ។ វិឃាសំ នាម ចលកានិ វា អដ្ឋិកានិ វា ឧច្ឆិដ្ឋោទកំ វា វុច្ចតិ ។ ហរិតំ នាម បុព្វណ្ណំ អបរណ្ណំ យំ មនុស្សានំ ឧបភោគបរិភោគំ រោបិមំ(១) ។ ឆឌ្ឌេយ្យាតិ សយំ ឆឌ្ឌេតិ អាបត្តិ បាចិត្តិយស្ស ។ ឆឌ្ឌាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស សកឹ អាណត្តា ពហុកម្បិ ឆឌ្ឌេតិ អាបត្តិ បាចិត្តិយស្ស ។

---

១ ឧទ្ធិ រោបកេ រោបិតន្តិ ទិស្សតិ ។



ក្នុងទីមានវត្ថុមានពណ៌ខៀវទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយចោលឯង ឬឲ្យគេចោល នូវឧច្ចារៈក្តី បស្សាវៈក្តី សម្រាមក្តី របស់ជាសំណល់ក្តី ក្នុងទីមានវត្ថុមានពណ៌ខៀវ ត្រូវអាបត្តិបាចិត្តិយ ។

[១៧៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ដែលហៅថា ឧច្ចារៈ បានដល់គូថ ។ ដែលហៅថា បស្សាវៈ បានដល់ទឹកមូត្រ ។ ដែលហៅថាសម្រាម បានដល់កំទេចកំទី ។ ដែលហៅថារបស់សំណល់ បានដល់កាកសាច់ ឬឆ្អឹង ឬទឹកដែលសេសសល់ ។ ដែលហៅថាវត្ថុមានពណ៌ខៀវ គឺវត្ថុណាជាបុព្វណ្ណជាតិ ឬអបរណ្ណជាតិ ជាដំណាំជាគ្រឿងឧបភោគនិងបរិភោគរបស់មនុស្សទាំងឡាយ ។ ពាក្យថា ចោលឯង សេចក្តីថា ភិក្ខុនីចោលដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ឲ្យគេចោល សេចក្តីថា ភិក្ខុនីបង្គាប់អ្នកដទៃឲ្យចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីបង្គាប់តែម្តង អ្នកទទួលបង្គាប់ចោលសូម្បីច្រើនដង ត្រូវអាបត្តិបាចិត្តិយ ។

[១៨០] ហរិតេ ហរិតសញ្ញា ឆឌ្ឌេតិ វា ឆឌ្ឌាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ ហរិតេ វេមតិកា ឆឌ្ឌេតិ វា ឆឌ្ឌាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ ហរិតេ អហរិតសញ្ញា ឆឌ្ឌេតិ វា ឆឌ្ឌាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ អហរិតេ ហរិតសញ្ញា អាបត្តិ ទុក្កដស្ស ។ អហរិតេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អហរិតេ អហរិតសញ្ញា អនាបត្តិ ។

[១៨១] អនាបត្តិ ឱលោកេត្វា ឆឌ្ឌេតិ ខេត្តមរិយាទេ ឆឌ្ឌេតិ សាមិកេ អាបុច្ឆា អបលោកេត្វា ឆឌ្ឌេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## លសុណវគ្គស្ស ទសមសិក្ខាបទំ

[១៨២] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន



[១៨០] ដំណាំ ភិក្ខុនីសំគាល់ថាដំណាំមែន ហើយចោលឯងក្តី ឲ្យគេចោលក្តី ត្រូវអាបត្តិបាចិត្តិយ ។ ដំណាំ តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយចោលឯងក្តី ឲ្យគេចោលក្តី ត្រូវអាបត្តិបាចិត្តិយ ។ ដំណាំ ភិក្ខុនីសំគាល់ថាមិនមែនដំណាំវិញ ហើយចោលឯងក្តី ឲ្យគេចោលក្តី ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនដំណាំ ភិក្ខុនីសំគាល់ថាដំណាំទៅវិញ ត្រូវអាបត្តិទុក្កដ ។ មិនមែនដំណាំ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនដំណាំ ភិក្ខុនីសំគាល់ថាមិនមែនដំណាំមែន មិនត្រូវអាបត្តិ ។

[១៨១] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ ពួក) ភិក្ខុនីមើលមើលទីសមគួរហើយទើបចោល ១ ភិក្ខុនីចោលលើភ្លឺស្រែ ១ ភិក្ខុនីសួរពួកម្ចាស់ដោយសព្វគ្រប់ហើយ ប្រាប់ដោយស្រួលបួលទើបចោល ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## លសុណវគ្គ សិក្ខាបទទី ១០

[១៨២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង

សមយេន រាជគហេ គិរគ្គសមជ្ជោ ហោតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ គិរគ្គសមជ្ជំ ទស្សនាយ អគមំសុ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ នច្ចម្បិ គីតម្បិ វាទិតម្បិ ទស្សនាយ គច្ឆិស្សន្តិ សេយ្យ-ថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិ-យា ភិក្ខុនិយោ នច្ចម្បិ គីតម្បិ វាទិតម្បិ ទស្សនាយ គច្ឆិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ នច្ចម្បិ គីតម្បិ វាទិតម្បិ ទស្សនាយ គច្ឆន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ នច្ចម្បិ គីតម្បិ វាទិតម្បិ ទស្សនាយ គច្ឆិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី នច្ចំ វា គីតំ វា វាទិតំ វា ទស្សនាយ គច្ឆេយ្យ បាចិត្តិយន្តិ ។



ក្នុងក្រុងរាជគ្រឹះមានមហោស្រពលើកំពូលភ្នំ ភិក្ខុនីទាំងឡាយមានពួក ៦ បាននាំគ្នាទៅមើលមហោស្រពដែលគេលេងលើកំពូលភ្នំ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមនឹងទៅមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តី ដូចជាពួកស្រីគ្រហស្ថបរិភោគកាមគុណដូច្នោះ ។ ពួកភិក្ខុនីបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមានពួក ៦ មិនសមនឹងទៅមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តីសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមានពួក ៦ ទៅមើលរបាំខ្លះ ចម្រៀងខ្លះ ប្រគំខ្លះ ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមានពួក ៦ មិនសមនឹងទៅមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តីទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយទៅដើម្បីមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តី ត្រូវអាបត្តិបាចិត្តិយ ។

(១៨៣) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ នច្ចំ នាម យំ កិញ្ចិ នច្ចំ ។ គីតំ នាម យំ កិញ្ចិ គីតំ ។ វាទិតំ នាម យំ កិញ្ចិ វាទិតំ ។ ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតា បស្សតិ វា សុណាតិ វា អាបត្តិ បាចិត្តិយស្ស ។ ទស្សនូបចារំ វិជហិត្វា បុនប្បុនំ បស្សតិ វា សុណាតិ វា អាបត្តិ បាចិត្តិយស្ស ។ ឯកមេកំ ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតា បស្សតិ វា សុណាតិ វា អាបត្តិ បាចិត្តិយស្ស ។ ទស្សនូបចារំ វិជហិត្វា បុនប្បុនំ បស្សតិ វា សុណាតិ វា អាបត្តិ បាចិត្តិយស្ស ។

(១៨៤) អនាបត្តិ អារាមេ ឋិតា បស្សតិ វា សុណាតិ វា ភិក្ខុនិយា ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគន្ត្វា នច្ចន្តិ វា គាយន្តិ វា វាទេន្តិ វា បដិបថំ គច្ឆន្តី បស្សតិ វា សុណាតិ វា សតិ ករណីយេ គន្ត្វា បស្សតិ វា សុណាតិ វា អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។





(១៨៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី ១ រួចហើយ ។ ដែលហៅថា រាំ បានដល់ការរាំណាមួយ ។ ដែលហៅថា ចម្រៀង បានដល់ចម្រៀងណាមួយ ។ ដែលហៅថា ប្រគំ បានដល់ប្រគំណាមួយ ។ ភិក្ខុនីទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ភិក្ខុនីឈរមើលក្តី ស្តាប់ក្តី ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុនីលះឧបចារសម្រាប់មើល ហើយមើលឃើញក្តី ស្តាប់ឮក្តី រឿយ ៗ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីទៅដើម្បីមើលម្តងមួយ ៗ ត្រូវអាបត្តិទុក្កដ ភិក្ខុនីឈរមើលក្តី ឈរស្តាប់ក្តី ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុនីលះបង់ឧបចារសម្រាប់មើល ហើយមើលឃើញក្តី ស្តាប់ឮក្តី រឿយ ៗ ត្រូវអាបត្តិបាចិត្តិយ ។

(១៨៤) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) ភិក្ខុនីឈរមើល ឬស្តាប់ក្នុងអារាម ១ ជនទាំងឡាយមកកាន់ទីកន្លែង ដែលភិក្ខុនីឈរនៅ ឬអង្គុយ ឬសឹង ហើយរាំក្តី ច្រៀងក្តី ប្រគំក្តី ១ ភិក្ខុនីកំពុងដើរទៅជួបតាមផ្លូវហើយឃើញក្តី ស្តាប់ក្តី ១ កាលបើភិក្ខុនីមានកិច្ចដើរទៅហើយឃើញក្តី ឮក្តី ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

លសុណវគ្គ ទី ១ ចប់ ។

## អន្ធការវគ្គស្ស បឋមសិក្ខាបទំ

(១៨៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ។ តេន ខោ បន សមយេន ភទ្ទាយ កាបិលានិយា អន្តេវាសិនិយា ភិក្ខុនិយា(*) ញាតកោ បុរិសោ គាមកា សាវត្ថិំ អគមាសិ កេនចិទេវ ករណីយេន។ អថខោ សា ភិក្ខុនី តេន បុរិសេន សទ្ធឹ រត្តន្ធការេ អប្បទីបេ ឯកេនេកា សន្តិដ្ឋតិបិ សល្លបតិបិ។ យា តា ភិក្ខុនិយោ អប្បិច្ឆា។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី រត្តន្ធការេ អប្បទីបេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្សតិបិ សល្លបិស្សតិបីតិ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី រត្តន្ធការេ អប្បទីបេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋតិបិ សល្លបតិបីតិ។ សច្ចំ ភគវាតិ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី រត្តន្ធការេ អប្បទីបេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្សតិបិ សល្លបិស្សតិបិ នេតំ ភិក្ខវេ

* ឧ. ម. អន្តេវាសិកភិក្ខុនិយោ។

## អន្ធការវគ្គ សិក្ខាបទទី ១

(១៨៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានបុរសជាញាតិរបស់ភិក្ខុនីជាកូនសិស្សរបស់នាងភទ្ទាកាបិលានីភិក្ខុនី ចេញពីស្រុកស្រែ មកកាន់ក្រុងសាវត្ថី ដោយមានកិច្ចនីមួយ។ កាលនោះ ភិក្ខុនីនោះ ស្ថិតនៅផង និយាយផង តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរសនោះ ក្នុងយប់ងងឹតឥតមានប្រទីបឡើយ។ ពួកភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីម្តេចសមនឹងស្ថិតនៅផង និយាយផង តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីបដូច្នេះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីស្ថិតនៅផង និយាយផង តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីប ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបីនឹងស្ថិតនៅផង និយាយផង តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីបទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យ

អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី រត្តន្ធការេ អប្បទីបេ បុរិសេន សទ្ធិំ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា បាចិត្តិយន្តិ ។

[១៨៦] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ រត្តន្ធការេតិ ឱគ្គតេ សុរិយេ ។ អប្បទីបេតិ អនាលោកេ ។ បុរិសោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ វិញ្ញូ បដិពលោ សន្តិដ្ឋិតុំ សល្លបិតុំ ។ សទ្ធិន្តិ ឯកតោ ។ ឯកេនេកាតិ បុរិសោ ចេវ ហោតិ ភិក្ខុនី ច ។ សន្តិដ្ឋេយ្យ វាតិ បុរិសស្ស ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ សល្លបេយ្យ វាតិ បុរិសស្ស ហត្ថបាសេ ឋិតា សល្លបតិ អាបត្តិ បាចិត្តិយស្ស ។ ហត្ថបាសំ វិជហិត្វា សន្តិដ្ឋតិ វា សល្លបតិ វា អាបត្តិ ទុក្កដស្ស ។ យក្ខេន វា បេតេន វា បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គហេន វា សទ្ធិំ សន្តិដ្ឋតិ វា សល្លបតិ វា អាបត្តិ ទុក្កដស្ស ។



ជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយស្ថិតនៅក្តី និយាយក្តី តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីប ត្រូវអាបត្តិបាចិត្តិយ ។

(១៨៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១ រួចហើយ ។ ពាក្យថា ក្នុងយប់ងងឹត សេចក្តីថា ក្នុងវេលាដែលព្រះអាទិត្យលិចចុះទៅហើយ ។ ពាក្យថា ឥតមានប្រទីប សេចក្តីថា មិនមានពន្លឺ ។ ដែលហៅថា បុរស បានដល់មនុស្សប្រុសជាអ្នកដឹងសេចក្តីអាចដើម្បីស្ថិតនៅផង និយាយផង មិនមែនយក្ស មិនមែនប្រេត មិនមែនតិរច្ឆាន ។ ពាក្យថា មួយអន្លើ គឺក្នុងទីជាមួយគ្នា ។ ពាក្យថា តែម្នាក់ឯងម្នាក់ គឺមានតែបុរស១ នឹងភិក្ខុនី១ ។ ពាក្យថា ស្ថិតនៅ សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា និយាយ សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរសហើយចរចា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីលះបង់ហត្ថបាសហើយស្ថិតនៅក្តី និយាយក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ថិតនៅក្តី និយាយក្តី មួយអន្លើដោយយក្សក្តី ប្រេតក្តី បណ្ឌកក្តី សត្វតិរច្ឆានដែលមានកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។

(១៨៧) អនាបត្តិ យា កាចិ(១) វិញ្ញូ ទុតិយា(២) ហោតិ អរហោបេក្ខា អញ្ញាវិហិតា សន្តិដ្ឋតិ វា សល្លបតិ វា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## អន្ធការវគ្គស្ស ទុតិយសិក្ខាបទំ

(១៨៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភទ្ទាយ កាបិលានិយា អន្តេវាសិនិយា ភិក្ខុនិយា ញាតកោ បុរិសោ គាមកា សាវត្ថិំ អគមាសិ កេនចិទេវ ករណីយេន ។ អថខោ សា ភិក្ខុនី ភគវតា បដិក្ខិត្តំ រត្តន្ធការេ អប្បទីបេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិតុំ សល្លបិតុន្តិ បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋតិបិ សល្លបតិបិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

១ ម. យោ កោចិ ។ ២ ទុតិយោ ។



(១៨៧) អនាបត្តិមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺមានភិក្ខុនីណាមួយដ៏ជាស្រីចេះដឹងនៅជាគំរប់ពីរ ១ ភិក្ខុនីប្រាថ្នាទីមិនស្ងាត់ (ហើយស្ថិតនៅក្តី និយាយក្តី) ១ ភិក្ខុនីមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃ ហើយស្ថិតនៅក្តី និយាយក្តី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាទាន់ដើមបញ្ញត្តិ ១ ។

## អន្ធការវគ្គ សិក្ខាបទទី ២

[១៨៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានបុរសជាញាតិរបស់ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី មានចេញពីស្រុកក្រៅទៅក្រុងសាវត្ថី ដោយកិច្ចនីមួយ ។ គ្រានោះ ភិក្ខុនីនោះគិតថា ការស្ថិតនៅក្តី និយាយក្តី តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីប ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (គិតដូច្នេះហើយ) ក៏ស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរសនោះឯង ក្នុងទីកាលដ៏កំបាំង ។ ពួកភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់ឯងម្នាក់មួយអន្លើដោយបុរស

កថំ ហិ នាម ភិក្ខុនី បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្សតិ សល្លបិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋតិ សល្លបតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្សតិ សល្លបិស្សតីតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា បាចិត្តិយន្តិ ។

(១៨៤) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បដិច្ឆន្នោ នាម ឱកាសោ កុដ្ដេន វា កវាដេន វា កិលញ្ជេន វា សាណិបាការេន វា



ក្នុងទីឱកាសបិទបាំងសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីស្ថិតនៅទ្វេ និយាយទ្វេ តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក្នុងទីឱកាសបិទបាំង ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏ម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមនឹងស្ថិតនៅទ្វេនិយាយទ្វេ តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក្នុងទីបិទបាំងទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយស្ថិតនៅក្តី និយាយក្តី តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក្នុងទីបិទបាំង ត្រូវអាបត្តិបាចិត្តិយ ។

(១៨៤) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ ។ ដែលហៅថា ទីកំបាំង បានដល់ទីឱកាសដែលគេបិទបាំងដោយគ្រឿងណាមួយ គឺដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលក្តី

រុក្ខេន វា ថម្ភេន វា កោដ្ឋលិកាយ[១] វា យេន កេនចិ បដិច្ឆន្នំ ហោតិ ។ បុរិសោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ វិញ្ញូ បដិពលោ សន្តិដ្ឋិតុំ សល្លបិតុំ ។ សទ្ធិន្តិ ឯកតោ ។ ឯកេនេកាតិ បុរិសោ ចេវ ហោតិ ភិក្ខុនី ច ។ សន្តិដ្ឋេយ្យ វាតិ បុរិសស្ស ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ សល្លបេយ្យ វាតិ បុរិសស្ស ហត្ថបាសេ ឋិតា សល្លបតិ អាបត្តិ បាចិត្តិយស្ស ។ ហត្ថបាសំ វិជហិត្វា សន្តិដ្ឋតិ វា សល្លបតិ វា អាបត្តិ ទុក្កដស្ស ។ យក្ខេន វា បេតេន វា បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គហេន វា សទ្ធិំ សន្តិដ្ឋតិ វា សល្លបតិ វា អាបត្តិ ទុក្កដស្ស ។

(១៩០) អនាបត្តិ យោ កោចិ វិញ្ញូ ទុតិយោ ហោតិ អរហោបេក្ខា អញ្ញវិហិតា សន្តិដ្ឋតិ វា សល្លបតិ វា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

១ ឱ. ម. កោដ្ឋលិយា ។



ដោយកំពែងក្តី ដោយដើមឈើក្តី ដោយសសរក្តី ដោយល្អីងខ្ទប់ក្តី ។ ដែលហៅថា បុរស បានដល់មនុស្សប្រុសដែលដឹងក្តីយល់ការ ដើម្បីស្ថិតនៅដើម្បីនិយាយ មិនមែនយក្ខ មិនមែនប្រេត មិនមែនតិរច្ឆាន ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ ពាក្យថា តែម្នាក់នឹងម្នាក់ សេចក្តីថា មានតែបុរស ១ នឹងភិក្ខុនី ១ ។ ពាក្យថា ស្ថិតនៅក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា និយាយក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរសហើយនិយាយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីលះបង់ហត្ថបាសហើយស្ថិតនៅក្តី និយាយក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ថិតនៅ ឬនិយាយ មួយអន្លើដោយយក្ខក្តី ប្រេតក្តី បណ្ឌកក្តី តិរច្ឆានមានកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។

(១៩០) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺមានភិក្ខុនីណាមួយដឹងសេចក្តីច្បាស់នៅជាគំរប់ពីរ ១ ភិក្ខុនីប្រាថ្នានូវទីមិនស្ងាត់ (ហើយស្ថិតនៅក្តី និយាយក្តី) ១ ភិក្ខុនីមានចិត្តបញ្ជូនទៅកាន់ការផ្សេងហើយស្ថិតនៅក្តី និយាយក្តី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## អន្ធការវគ្គស្ស តតិយសិក្ខាបទំ

(១៩១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភទ្ទាយ កាបិលានិយា អន្តេវាសិនិយា ភិក្ខុនិយា ញាតកោ បុរិសោ គាមកា សាវត្ថឹ អគមាសិ កេនចិទេវ ករណីយេន ។ អថខោ សា ភិក្ខុនី ភគវតា បដិក្ខិត្តំ បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិតុំ សល្លបិតុន្តិ តេនេវ បុរិសេន សទ្ធឹ អជ្ឈោកាសេ ឯកេនេកា សន្តិដ្ឋតិបិ សល្លបតិបិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី អជ្ឈោកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្សតិបិ សល្លបិស្សតិបីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី អជ្ឈោកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋតិបិ សល្លបតិបីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី អជ្ឈោកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្ស-

## អន្ធការវគ្គ សិក្ខាបទទី ៣

(១៩១) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានបុរសជាញាតិរបស់ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី ចេញពីស្រុកស្រែទៅក្រុងសាវត្ថី ដោយកិច្ចនីមួយ ។ កាលនោះ ភិក្ខុនីនោះគិតថា ការស្ថិតនៅក្តី និយាយក្តី តែម្នាក់ឯងនឹងម្នាក់ មួយអន្លើដោយបុរសក្នុងទីកំបាំង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (គិតដូច្នេះហើយ) ក៏ស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់ឯងនឹងម្នាក់ មួយអន្លើដោយបុរសនោះឯងក្នុងទីវាល ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងស្ថិតនៅខ្លះនិយាយខ្លះតែម្នាក់ឯងនឹងម្នាក់មួយអន្លើដោយបុរសក្នុងទីវាលសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីស្ថិតនៅខ្លះនិយាយខ្លះតែម្នាក់ឯងនឹងម្នាក់មួយអន្លើដោយបុរសក្នុងទីវាល ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមនឹងស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់ឯងនឹងម្នាក់ មួយអន្លើដោយបុរសក្នុងទីវាលទេ

តិបិ សល្លបិស្សតិបិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អជ្ឈោកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា បាចិត្តិយន្តិ ។

(១៨៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អជ្ឈោកាសេ នាម អប្បដិច្ឆន្នោ ហោតិ កុឌ្ឌេន វា កវាដេន វា កិលញ្ជេន វា សាណិបាការេន វា រុក្ខេន វា ថម្ភេន វា កោដ្ឋលិកាយ វា យេន កេនចិ អប្បដិច្ឆន្នោ ហោតិ ។ បុរិសោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ វិញ្ញូ បដិពលោ សន្តិដ្ឋិតុំ សល្លបិតុំ ។ សទ្ធិន្តិ ឯកតោ ។ ឯកេនេកាតិ បុរិសោ ចេវ ហោតិ ភិក្ខុនី ច ។ សន្តិដ្ឋេយ្យ វាតិ បុរិសស្ស ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ សល្លបេយ្យ វាតិ បុរិសស្ស ហត្ថបាសេ ឋិតា សល្លបតិ អាបត្តិ បាចិត្តិយស្ស ។ ហត្ថបាសំ វិជហិត្វា សន្តិដ្ឋតិ វា



ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែនជាទីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយស្ថិតនៅក្តី និយាយក្តី តែម្នាក់ឯងនឹងម្នាក់ មួយអន្លើដោយបុរសក្នុងទីវាល ត្រូវអាបត្តិបាចិត្តិយ ។

(១៨៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ដែលហៅថា ទីវាល បានដល់ទីដែលគេមិនបិទបាំង គឺទីដែលគេមិនបិទបាំងដោយវត្ថុណាមួយ គឺជញ្ជាំងក្តី សន្លឹកទ្វារក្តី កន្ទេលក្តី កំពែងសំពត់ក្តី ដើមឈើក្តី សសរក្តី ល្វែងបន្ទប់ក្តី ។ ដែលហៅថា បុរស បានដល់មនុស្សប្រុសដែលដឹងក្តី យល់ការស្ថិតនៅបាននិយាយបាន មិនមែនយក្ស មិនមែនប្រេត មិនមែនតិរច្ឆាន ។ ពាក្យថា មួយអន្លើ គឺក្នុងទីជាមួយគ្នា ។ ពាក្យថា តែម្នាក់ឯងនឹងម្នាក់ គឺមានតែបុរស ១ នឹងភិក្ខុនី ១ ។ ពាក្យថា ស្ថិតនៅក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា និយាយក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរសហើយនិយាយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីលះបង់

សល្លបតិ វា អាបត្តិ ទុក្កដស្ស ។ យក្ខេន វា បេតេន វា បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គហេន វា សទ្ធិំ សន្តិដ្ឋតិ វា សល្លបតិ វា អាបត្តិ ទុក្កដស្ស ។

(១៨៣) អនាបត្តិ យា កាចិ វិញ្ញូ ទុតិយា ហោតិ អរហោបេក្ខា អញ្ញាវិហិតា សន្តិដ្ឋតិ វា សល្លបតិ វា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អន្ធការវគ្គស្ស ចតុត្ថសិក្ខាបទំ

(១៨៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី រថិយាយបិ ព្យូហេបិ សិង្ឃាដកេបិ បុរិសេន សទ្ធិំ ឯកេនេកា សន្តិដ្ឋតិបិ សល្លបតិបិ និកណ្ណិកម្បិ ជប្បេតិ ទុតិយម្បិ ភិក្ខុនឹ ឧយ្យោជេតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ



[illegible] ហើយស្ថិតនៅក្តី និយាយក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីស្ថិតនៅ ឬនិយាយ មួយអន្លើដោយយក្សក្តី ប្រេតក្តី បណ្ឌកក្តី សត្វតិរច្ឆានមានកាយប្រែជាមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។

(១៨៣) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺមានភិក្ខុនីណាមួយដ៏ដឹងខុសត្រូវនៅជាគំរប់ពីរ ១ ភិក្ខុនីប្រាថ្នាទីមិនស្ងាត់ (ហើយស្ថិតនៅក្តី និយាយក្តី) ១ ភិក្ខុនីមានចិត្តបញ្ជូនទៅក្នុងអារម្មណ៍ដទៃហើយស្ថិតនៅក្តី និយាយក្តី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## អន្ធការវគ្គ សិក្ខាបទទី ៤

(១៨៤) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីឈរនៅខ្លះ និយាយខ្លះ ខ្សឹបជិតត្រចៀកខ្លះ តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក្នុងច្រកល្ហកខ្លះ ក្នុងច្រកទាល់(ទៀនគោះ)ខ្លះ ក្នុងទីប្រសព្វផ្លូវមានច្រក ៤ ឬមានច្រក ៣ ខ្លះ បញ្ជូនភិក្ខុនីជាគូកនចេញទៅខ្លះ ។ ពួកភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមនឹង

ហិ នាម អយ្យា ថុល្លនន្ទា រថិយាយបិ ព្យូហេបិ សិង្ឃាដកេបិ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្សតិបិ សល្លបិស្សតិបិ និកណ្ណិកម្បិ ជប្បិស្សតិ ទុតិយិកម្បិ ភិក្ខុនឹ ឧយ្យោជេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី រថិយាយបិ ព្យូហេបិ សិង្ឃាដកេបិ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋតិបិ សល្លបតិបិ និកណ្ណិកម្បិ ជប្បតិ ទុតិយិកម្បិ ភិក្ខុនឹ ឧយ្យោជេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី រថិយាយបិ ព្យូហេបិ សិង្ឃាដកេបិ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋិស្សតិបិ សល្លបិស្សតិបិ និកណ្ណិកម្បិ ជប្បិស្សតិ ទុតិយិកម្បិ ភិក្ខុនឹ ឧយ្យោជេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី រថិយាយ វា ព្យូហេ វា សិង្ឃាដកេ វា បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា និកណ្ណិកំ វា ជប្បេយ្យ ទុតិយិកំ វា ភិក្ខុនឹ ឧយ្យោជេយ្យ បាចិត្តិយន្តិ ។



ឈរនៅផ្លូវ និងយាយផ្លូវ ទ្វីបបិទក្រឡៅផ្លូវ តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក៏ចរហូតផ្លូវ ក៏ចរចាល់ផ្លូវ ក៏ទំប្រជុំផ្ទៃមាត់ត្រចៀក ឬផ្លូវ ៣ ផ្លូវ បណ្តេញភិក្ខុនីជាគូកនចេញទៅផ្លូវសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឈរនៅផ្លូវ និងយាយផ្លូវ ទ្វីបបិទក្រឡៅផ្លូវ តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក៏ចរហូតផ្លូវ ក៏ចរចាល់ផ្លូវក៏ទំប្រជុំផ្ទៃមាត់ត្រចៀក ឬផ្លូវ៣ផ្លូវ បណ្តេញភិក្ខុនីជាគូកនចេញផ្លូវ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមនឹងឈរនៅផ្លូវ និងយាយផ្លូវ ទ្វីបបិទក្រឡៅផ្លូវ តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក៏ចរហូតផ្លូវ ក៏ចរចាល់ផ្លូវ ក៏ទំប្រជុំផ្ទៃមាត់ត្រចៀក ឬផ្លូវ ៣ ផ្លូវ បណ្តេញភិក្ខុនីជាគូកនផ្លូវទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឈរនៅក្តី និយាយក្តី ទ្វីបបិទក្រឡៅក្តី តែម្នាក់ឯងម្នាក់ មួយអន្លើដោយបុរស ក៏ចរហូតក្តី ក៏ចរចាល់ក្តី ក៏ទំប្រជុំផ្ទៃមាត់ត្រចៀក ឬផ្លូវ ៣ ក្តី បណ្តេញភិក្ខុនីជាគូកនចេញក្តី ត្រូវអាបត្តិបាចិត្តិយ ។

(១៩៨) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ រថិយា នាម រច្ឆា ។ ព្យូហំ នាម យេនេវ បវិសន្តិ តេនេវ និក្ខមន្តិ ។ សិង្ឃាដកោ នាម ចច្ចរំ វុច្ចតិ ។ បុរិសោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ វិញ្ញូ បដិពលោ សន្តិដ្ឋិតុំ សល្លបិតុំ ។ សទ្ធិន្តិ ឯកតោ ។ ឯកេនេកាតិ បុរិសោ ចេវ ហោតិ ភិក្ខុនី ច ។ សន្តិដ្ឋេយ្យ វាតិ បុរិសស្ស ហត្ថបាសេ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ សល្លបេយ្យ វាតិ បុរិសស្ស ហត្ថបាសេ ឋិតា សល្លបតិ អាបត្តិ បាចិត្តិយស្ស ។ និកណ្ណិកំ វា ជប្បេយ្យាតិ បុរិសស្ស ឧបកណ្ណកេ អារោចេតិ អាបត្តិ បាចិត្តិយស្ស ។ ទុតិយិកំ វា ភិក្ខុនឹ ឧយ្យោជេយ្យាតិ អនាចារំ អាចរិតុកាមា ទុតិយិកំ ភិក្ខុនឹ ឧយ្យោជេតិ អាបត្តិ ទុក្កដស្ស ។ ទស្សនូបចារំ វា សវនូបចារំ វា វិជហន្តិយា



(១៩៨) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបទភាជនីកណ្ឌទី១ រួចហើយ ។ ដែលហៅថា ច្រកល្ហក បានដល់ផ្លូវដែលគេចេញចូលបាន (ថ្នល់) ។ ដែលហៅថា ច្រកពាល់ បានដល់ទីដែលគេចាំទំលុយចូលទៅតាមផ្លូវណា ចេញមកតាមផ្លូវនោះវិញទើបបាន ។ ដែលហៅថា ទីប្រជុំផ្លូវមានច្រកបួនច្រកបី បានដល់ស្ពានមុខព្រះលាន ។ ដែលហៅថា បុរស បានដល់មនុស្សប្រុសដែលដឹងសេចក្ដីឈ្លាស់អាចឈរនៅបាន និយាយបាន មិនមែនយក្ស មិនមែនប្រេត មិនមែនសត្វតិរច្ឆាន ។ ពាក្យថា មួយអន្លើ គឺក្នុងទីជាមួយគ្នា ។ ពាក្យថា ម្នាក់នឹងម្នាក់ គឺមានតែបុរស ១ ភិក្ខុនី ១ ។ ពាក្យថា ឈរនៅក្ដី សេចក្ដីថា ភិក្ខុនីឈរនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា និយាយក្ដី សេចក្ដីថា ភិក្ខុនីឈរនៅក្នុងហត្ថបាសនៃបុរសហើយនិយាយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ខ្សឹបជិតត្រចៀកក្ដី សេចក្ដីថា ភិក្ខុនីប្រាប់សេចក្ដីជិតត្រចៀកនៃបុរស ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា បណ្ដេញភិក្ខុនីជាគូកនចេញក្ដី សេចក្ដីថា ភិក្ខុនីមានសេចក្ដីប្រាថ្នាដើម្បីប្រព្រឹត្តអនាចារ ហើយបណ្ដេញភិក្ខុនីជាគំរប់ពីរ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាគូកនកំពុងលះបង់ឧបចារៈសម្រាប់មើលឃើញក្ដី ឧបចារៈសម្រាប់ស្ដាប់ក្ដី ភិក្ខុនីអ្នកបណ្ដេញ

អាបត្តិ ទុក្កដស្ស ។ វិជហិតេ អាបត្តិ បាចិត្តិយស្ស ។ ហត្ថបាសំ វិជហិត្វា សន្តិដ្ឋតិ វា សយតិ វា អាបត្តិ ទុក្កដស្ស ។ យក្ខេន វា បេតេន វា បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គហេន វា សទ្ធិំ សន្តិដ្ឋតិ វា សយតិ វា អាបត្តិ ទុក្កដស្ស ។

(១៨៦) អនាបត្តិ យា កាចិ វិញ្ញូ ទុតិយា ហោតិ អរហោបេក្ខា អញ្ញវិហិតា សន្តិដ្ឋតិ វា សយតិ វា ន អនាចារំ អាចរិតុកាមា សតិ ករណីយេ ទុតិយំ ភិក្ខុនីំ ឧយ្យោជេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## អន្ធការវគ្គស្ស បញ្ចមសិក្ខាបទំ

(១៨៧) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី អញ្ញតរស្ស កុលស្ស កុលុបិកា ហោតិ និច្ចភត្តិកា ។ អថខោ



ត្រូវអាបត្តិទុក្កដ លុះភិក្ខុនីជាគូគេលះបង់នូវហត្ថបាសទៅហើយ ភិក្ខុនីអ្នកបណ្តោយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីលះបង់ហត្ថបាសហើយឈរនៅក្តី ដេកក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈរនៅក្តី ដេកក្តី មួយអន្លើដោយយក្ខក្តី ប្រេតក្តី បណ្ឌកក្តី សត្វតិរច្ឆានមានកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។

(១៨៦) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺមានភិក្ខុនីណាមួយដ៏ជាអ្នកដឹងក្តីរស់នៅជាគូគ្នា ១ ភិក្ខុនីប្រាថ្នានូវទីមិនស្ងាត់ (ហើយឈរក្តីដេកក្តី) ១ ភិក្ខុនីមានចិត្តបញ្ចាលទៅក្នុងអារម្មណ៍ដទៃហើយឈរនៅក្តី ដេកក្តី ១ ភិក្ខុនីមិនមានសេចក្តីប្រាថ្នាដើម្បីប្រព្រឹត្តអនាចារហើយបណ្តោញភិក្ខុនីជាគូគេ ១ ភិក្ខុនីមានកិច្ចហើយបណ្តោញភិក្ខុនីជាគូគេ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## អន្ធការវគ្គ សិក្ខាបទទី ៥

(១៨៧) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានភិក្ខុនី ១ រូបជាជីដូនប្រចាំដោយនិច្ចភត្តរបស់ត្រកូល ១ ។ កាលនោះ

សា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា អាសនេ និសីទិត្វា សាមិកេ អនាបុច្ឆា បក្កាមិ ។ តស្ស កុលស្ស ទាសី ឃរំ សម្មជ្ជន្តី តំ អាសនំ ភាជនន្តរិកាយ បក្ខិបិ ។ មនុស្សា តំ អាសនំ អបស្សន្តា តំ ភិក្ខុនឹ ឯតទវោចុំ កហំ អយ្យេ អាសនន្តិ ។ នាហំ អាវុសោ អាសនំ បស្សាមីតិ ។ ទេហាយ្យេ តំ អាសនន្តិ បរិភាសិត្វា និច្ចភត្តំ បច្ឆិន្ទិំសុ ។ អថខោ តេ មនុស្សា ឃរំ សោធេន្តា តំ អាសនំ ភាជនន្តរិកាយ បស្សិត្វា តំ ភិក្ខុនឹ ខមាបេត្វា និច្ចភត្តំ បដ្ឋបេសុំ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី បុរេភត្តំ កុលានិ ឧបសង្កមិត្វា អាសនេ និសីទិត្វា សាមិកេ អនាបុច្ឆា បក្កមិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី បុរេភត្តំ កុលានិ ឧបសង្កមិត្វា អាសនេ និសីទិត្វា សាមិកេ អនាបុច្ឆា



ភិក្ខុនីនោះស្លៀកស្បង់ពីព្រឹក ហើយប្រដាប់បាត្រនិងចីវរ ចូលទៅកាន់ត្រកូលនោះ លុះចូលទៅដល់ហើយក៏អង្គុយលើអាសនៈ ហើយមិនបានលាពួកជនជាម្ចាស់ផ្ទះក៏ចៀសចេញទៅ ។ ទាសីរបស់ត្រកូលនោះ កាលបោសផ្ទះក៏ដាក់អាសនៈនោះទៅក្នុងចន្លោះនៃភាជន៍ ។ មនុស្សទាំងឡាយមិនឃើញអាសនៈនោះ ក៏និយាយពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ អាសនៈនៅឯណា ។ ភិក្ខុនីនោះប្រាប់ថា ម្នាលអាវុសោ អាត្មាមិនឃើញអាសនៈនោះទេ ។ មនុស្សទាំងឡាយទារយកអាសនៈនោះវិញថា នែលោកម្ចាស់ ចូរឲ្យអាសនៈនេះមក ហើយក៏ផ្ដាសា ផ្ដាច់ទាំងនិច្ចភត្តនោះចេញ ។ លំដាប់នោះ ពួកមនុស្សនោះនាំគ្នាជម្រះសំអាតផ្ទះក៏ឃើញអាសនៈនោះនៅក្នុងចន្លោះនៃភាជន៍ហើយសូមឲ្យភិក្ខុនីនោះអត់ទោសឲ្យ ក៏ប្រគេននិច្ចភត្តវិញ ។ ឯភិក្ខុនីនោះប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុនីទាំងឡាយ ពួកភិក្ខុនីណាមានសេចក្ដីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងចូលទៅកាន់ត្រកូលមុនពេលបាយ ហើយអង្គុយលើអាសនៈ រួចមិនលាពួកជនជាម្ចាស់ផ្ទះ ហើយចៀសចេញទៅសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីចូលទៅកាន់ត្រកូលក្នុងវេលាមុនបាយ ហើយអង្គុយ

បញ្ញាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី បុរេភត្តំ កុលានិ ឧប-សង្កមិត្វា អាសនេ និសីទិត្វា សាមិកេ អនាបុច្ឆា បក្កមិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខា-បទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី បុរេភត្តំ កុលានិ ឧបសង្កមិត្វា អាសនេ និសីទិត្វា សាមិកេ អនាបុច្ឆា បក្កមេយ្យ បាចិត្តិយន្តិ ។

[១៩៨] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុ-នីតិ ។ បុរេភត្តំ នាម អរុណុគ្គមនំ(១) ឧបាទាយ យាវ មជ្ឈន្តិកា ។ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណកុលំ វេស្សកុលំ សុទ្ទកុលំ ។ ឧបសង្ក-មិត្វាតិ តត្ថ គន្ត្វា ។ អាសនំ នាម បល្លង្កស្ស ឱកាសោ វុច្ចតិ ។ និសីទិត្វាតិ តស្មឹ និសីទិត្វា ។

១ ម. អរុណុគ្គំ ។



លើអាសនៈរួចមិនបានលាពួកជនជាម្ចាស់ក៏ចៀសចេញទៅ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមនឹងចូលទៅកាន់ត្រកូលទាំងឡាយក្នុងពេលមុនបាយ ហើយអង្គុយលើអាសនៈរួចមិនបានលាពួកជនជាម្ចាស់ផ្ទះ ហើយចៀសចេញទៅទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះ-ថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយចូលទៅកាន់ត្រកូលទាំងឡាយក្នុងពេលមុនបាយ ហើយអង្គុយលើអាសនៈ រួចមិនបានលាពួកជនជាម្ចាស់ផ្ទះចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

[១៩៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ដែលហៅថា ក្នុងពេលមុនបាយ គឺចាប់តាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់ ។ ដែលហៅថា ត្រកូល បានដល់ត្រ-កូលទាំង ៤ គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលអ្នកកេស៊ី (ជួញប្រែធ្វើស្រែចំការជាដើម)១ ត្រកូលអ្នកកេស៊ីឈ្នួលគេ១ ។ ពាក្យថា ចូលទៅរក គឺទៅក្នុងត្រកូលនោះ ។ ដែលហៅថា អាសនៈ សំដៅយកឱកាសនៃបល្ល័ង្ក ។ ពាក្យថា អង្គុយទៅ គឺអង្គុយលើអាសនៈនោះ ។

សាមិកេ អនាបុច្ឆា បក្កាមេយ្យាតិ យោ តស្មិំ កុលេ មនុស្សោ សាមិកោ នាម[1] តំ អនាបុច្ឆា ។ អនោវស្សកំ អតិក្កាមន្តិយា[2] អាបត្តិ បាចិត្តិយស្ស ។ អជ្ឈោកាសេ ឧបចារំ អតិក្កាមន្តិយា អាបត្តិ បាចិត្តិយស្ស ។

(១៩៩) អនាបុច្ឆិតេ អនាបុច្ឆិតសញ្ញា បក្កាមតិ អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ វេមតិកា បក្កាមតិ អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ អាបុច្ឆិតសញ្ញា បក្កាមតិ អាបត្តិ បាចិត្តិយស្ស ។ បល្លង្កស្ស អនោកាសេ អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ អនាបុច្ឆិតសញ្ញា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ អាបុច្ឆិតសញ្ញា អនាបត្តិ ។

---

១ ឱ. ម. វិញ្ញូតិ ទិស្សតិ ។ ២ ឱ. ម. អតិក្កាមេន្តិយា ។



ពាក្យថា មិនបានលាពួកជនជាម្ចាស់ផ្ទះ ហើយចៀសចេញទៅ សេចក្ដីថា មនុស្សណាជាម្ចាស់ផ្ទះក្នុងត្រកូលនោះ ដែលអាចដើម្បីប្រាប់គេ (ត្រូវបាន) ភិក្ខុនីមិនលាមនុស្សនោះ ។ កាលភិក្ខុនីឈានផុតទីដែលភ្លៀងធ្លាក់មិនត្រូវ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីកន្លងឧបចារផ្ទះចូលទៅកន្លែងវាល ត្រូវអាបត្តិបាចិត្តិយ ។

(១៩៩) ម្ចាស់ផ្ទះដែលខ្លួនមិនបានលា ភិក្ខុនីសំគាល់ថាមិនបានលាដែរ ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ម្ចាស់ផ្ទះដែលខ្លួនមិនបានលា តែភិក្ខុនីមានសេចក្ដីសង្ស័យ ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ម្ចាស់ផ្ទះដែលខ្លួនមិនបានលា ភិក្ខុនីសំគាល់ថាបានលា ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ (ភិក្ខុនីអង្គុយ)ក្នុងទីមិនមែនជាទីឱកាសនៃទីអង្គុយ (មិនលាហើយចៀសចេញទៅ) ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានលាហើយ ភិក្ខុនីសំគាល់ថាមិនទាន់លា ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានលាហើយ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានលាហើយ ភិក្ខុនីសំគាល់ថាបានលាមែន មិនត្រូវអាបត្តិ ។

[៦០០] អនាបត្តិ អាបុច្ឆា គច្ឆតិ អសំហារិមេ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អន្ធការវគ្គស្ស ឆដ្ឋសិក្ខាបទំ

[៦០១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ អភិនិសីទតិបិ អភិនិបជ្ជតិបិ ។ មនុស្សា ថុល្លនន្ទំ ភិក្ខុនឹ ហិរិយមានា អាសនេ នេវ អភិនិសីទន្តិ ន អភិនិបជ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ អភិនិសីទិស្សតិបិ អភិនិបជ្ជិស្សតិបីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា



[៦០០] ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុនីលាហើយទើបទៅ ១ ភិក្ខុនីអង្គុយលើអាសនៈដែលគេនាំយកទៅមិនបាន ១ ភិក្ខុនីមានជម្ងឺ ១ ភិក្ខុនីមានសេចក្ដីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## អន្ធការវគ្គ សិក្ខាបទទី ៦

[៦០១] សម័យនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាក្រោយបាយ ហើយមិនប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈ ។ ពួកមនុស្សកាលខ្មាសថុល្លនន្ទាភិក្ខុនី ក៏មិនហ៊ានអង្គុយ មិនហ៊ានដេក លើអាសនៈ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាម្ចាស់ មិនសមបើនឹងចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាក្រោយបាយ ហើយមិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈសោះ ។ ភិក្ខុនីទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ ។ ពួកភិក្ខុនីណាមានសេចក្ដីប្រាថ្នាតិច ។បេ។

ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ អភិនិសីទិស្សតិបិ អភិនិបជ្ជិស្សតិបីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ អភិនិសីទតិបិ អភិនិបជ្ជតិបីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ អភិនិសីទិស្សតិបិ អភិនិបជ្ជិស្សតិបិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា បាចិត្តិយន្តិ ។



ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមនឹងចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាក្រោយបាយហើយ មិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាក្រោយបាយ ហើយមិនប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមនឹងចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាក្រោយបាយ ហើយមិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាក្រោយបាយ មិនប្រាប់ពួកជនជាម្ចាស់ផ្ទះ ហើយអង្គុយក្តី ដេកក្តី លើអាសនៈ ត្រូវអាបត្តិបាចិត្តិយ ។

(៦០៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បច្ឆាភត្តំ នាម មជ្ឈន្ហិកេ វីតិវត្តេ យាវ អត្ថង្គតេ សុរិយេ ។ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណកុលំ វេស្សកុលំ សុទ្ទកុលំ ។ ឧបសង្កមិត្វាតិ តត្ថ គន្ត្វា ។ សាមិកេ អនាបុច្ឆាតិ យោ តស្មឹ កុលេ មនុស្សោ សាមិកោ ទាតុំ តំ អនាបុច្ឆា ។ អាសនំ នាម បល្លង្កស្ស ឱកាសោ វុច្ចតិ ។ អភិនិសីទេយ្យាតិ តស្មឹ អភិនិសីទតិ អាបត្តិ បាចិត្តិយស្ស ។ អភិនិបជ្ជេយ្យាតិ តស្មឹ អភិនិបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។

(៦០៧) អនាបុច្ឆិតេ អនាបុច្ឆិតសញ្ញា អាសនេ អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ វេមតិកា អាសនេ អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ អាបុច្ឆិតសញ្ញា អាសនេ អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ បល្លង្កស្ស អនោកាសេ



(៦០៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិក ក្នុងទី ១ រួចហើយ ៗ ដែលហៅថា ពេលខាងក្រោយបាយ បានដល់ពេលដែលព្រះអាទិត្យទ្រេតពីត្រង់ហើយ ដល់ព្រះអាទិត្យអស្តង្គតទៅ ៗ ដែលហៅថា ត្រកូល បានដល់ត្រកូលទាំង ៤ គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលអ្នកស៊ីជួញធ្វើស្រែចំការ ១ ត្រកូលអ្នកស៊ីឈ្នួល ១ ៗ ពាក្យថា ចូលទៅរក គឺទៅក្នុងត្រកូលនោះ ៗ ពាក្យថា មិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ សេចក្តីថា មនុស្សណាជាម្ចាស់ឬជាធំក្នុងត្រកូលនោះដែលអាចដើម្បីប្រគេន (វត្ថុ ១ បាន) ភិក្ខុនីមិនប្រាប់មនុស្សនោះ ៗ ដែលហៅថា អាសនៈ បានដល់ឱកាសបល្ល័ង្កអង្គុយពែនបាន ៗ ពាក្យថា អង្គុយ សេចក្តីថា ភិក្ខុនីអង្គុយលើអាសនៈនោះ ត្រូវអាបត្តិបាចិត្តិយ ៗ ពាក្យថា ដេក សេចក្តីថា ភិក្ខុនីដេកលើអាសនៈនោះ ត្រូវអាបត្តិបាចិត្តិយ ៗ

(៦០៧) ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ ភិក្ខុនីសំគាល់ថា មិនទាន់បានប្រាប់មែន ហើយអង្គុយក្តី ដេកក្តីលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ ៗ ម្ចាស់ផ្ទះដែលខ្លួនមិនបានប្រាប់ តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយអង្គុយក្តី ដេកក្តីលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ ៗ ម្ចាស់ផ្ទះដែលខ្លួនមិនបានប្រាប់ តែភិក្ខុនីសំគាល់ថាបានប្រាប់ ហើយអង្គុយក្តី ដេកក្តីលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ ៗ (ភិក្ខុនីអង្គុយឬដេក) ក្នុងទីមិនមែនជាទី

អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ អនាបុច្ឆិតសញ្ញា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ អាបុច្ឆិតសញ្ញា អនាបត្តិ ។

(៤០៦) អនាបត្តិ អាបុច្ឆា អាសនេ អភិនិសីទតិ វា អភិនិបជ្ជតិ វា ធុវប្បញ្ញត្តេ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## អន្ធការវគ្គស្ស សត្តមសិក្ខាបទំ

[៤០៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខុនិយោ កោសលេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តា សាយំ អញ្ញតរំ គាមំ ឧបគន្ត្វា អញ្ញតរំ ព្រាហ្មណកុលំ ឧបសង្កមិត្វា ឱកាសំ យាចឹសុ ។ អថខោ[១] ព្រាហ្មណី តា ភិក្ខុនិយោ

១. អថខោ សាតិ ទិស្សតិ ។



ទោសនៃទីអង្គុយ ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ តែភិក្ខុនីសំគាល់ថាមិនទាន់បានប្រាប់ ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ហើយ តែភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ ភិក្ខុនីសំគាល់ថាបានប្រាប់ហើយមែន មិនត្រូវអាបត្តិ ។

(៤០៦) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺ ភិក្ខុនីបានប្រាប់ហើយអង្គុយក្តី ដេកក្តីលើអាសនៈ១ ភិក្ខុនីអង្គុយឬដេក លើអាសនៈដែលគេក្រាលជានិច្ច១ ភិក្ខុនីមានជម្ងឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១ ។

## អន្ធការវគ្គ សិក្ខាបទទី៧

(៤០៧) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុនីច្រើនរូបកាលដែលទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ ក៏ចូលទៅកាន់ស្រុក១ ក្នុងវេលាល្ងាច ហើយចូលទៅកាន់ត្រកូលព្រាហ្មណ៍ម្នាក់ ហើយក៏សូមឱកាស ។ កាលនោះ នាងព្រាហ្មណីបានពោលពាក្យនេះ

ឯតទវោច អាគមេហិ អយ្យេ យាវ ព្រាហ្មណោ អាគច្ឆតីតិ ។ ភិក្ខុនិយោ យាវ ព្រាហ្មណោ អាគច្ឆតីតិ សេយ្យំ សន្ថរិត្វា ឯកច្ចា និសីទិំសុ ឯកច្ចា និបជ្ជិំសុ ។ អថខោ សោ ព្រាហ្មណោ រត្តឹ អាគន្ត្វា តំ ព្រាហ្មណឹ ឯតទវោច កា ឥមាតិ ។ ភិក្ខុនិយោ អយ្យាតិ ។ និក្កឌ្ឍថ ឥមា មុណ្ឌា ពន្ធកិនិយោតិ ឃរតោ និក្កឌ្ឍាបេសិ ។ អថខោ តា ភិក្ខុនិយោ សាវត្ថឹ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ វិកាលេ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា[១] អភិនិសីទិស្សន្តិបិ អភិនិបជ្ជិស្សន្តិបីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ វិកាលេ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទន្តិបិ អភិនិបជ្ជន្តិបីតិ ។ សច្ចំ

១ ឱ. ម. សន្ថរាបេត្វា ឥតិ ន ទិស្សតិ ។



នឹងភិក្ខុនីទាំងនោះថា បពិត្រនាងម្ចាស់ សូមលោកទាំងឡាយនៅចាំសិន ទំរាំព្រាហ្មណ៍មក ។ ពួកភិក្ខុនីគិតគ្នាថា នឹងចាំទំរាំព្រាហ្មណ៍មកសិនផង នឹងជួបគ្នាហើយក៏ក្រាលកម្រាលសម្រាប់ដេក រួចខ្លះអង្គុយ ខ្លះដេក ។ ឯព្រាហ្មណ៍នោះមកក្នុងរាត្រី ហើយពោលពាក្យនេះនឹងនាងព្រាហ្មណី នោះថា ស្រីទាំងនេះជាអ្វី ។ នាងព្រាហ្មណីឆ្លើយថា បពិត្រអ្នកម្ចាស់ (ស្រីទាំងឡាយនេះជា) ភិក្ខុនី ។ ព្រាហ្មណ៍ពោលថា អ្នកទាំងឡាយ ចូរទាញស្រីផ្កាមាសត្រងោលនេះចេញ ជាដូច្នេះហើយក៏ឲ្យគេទាញចេញពីផ្ទះទៅ ។ ឯភិក្ខុនីទាំងនោះនាំគ្នាទៅកាន់ក្រុងសាវត្ថី ហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមនឹងចូលទៅកាន់ត្រកូលក្នុងវេលាវិកាល ហើយមិនបានប្រាប់ពួកជនជាម្ចាស់សិន ក៏ក្រាលឯងខ្លះ ឲ្យគេក្រាលខ្លះនូវកម្រាលសម្រាប់ដេក រួចអង្គុយខ្លះ ដេកខ្លះសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាវិកាល ហើយមិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន ក៏ក្រាលឯងខ្លះ ឲ្យគេក្រាលខ្លះនូវកម្រាលសម្រាប់ដេក ហើយអង្គុយខ្លះ ដេកខ្លះ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។

ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ វិកាលេ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទិស្សន្តិបិ អភិនិបជ្ជិស្សន្តិបិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី វិកាលេ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា បាចិត្តិយន្តិ ។

(៦០៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ វិកាលោ នាម អត្ថង្គតេ សុរិយេ យាវ អរុណុគ្គមនា ។ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណកុលំ វេស្សកុលំ សុទ្ទកុលំ ។ ឧបសង្កមិត្វាតិ តត្ថ គន្ត្វា ។ សាមិកេ អនាបុច្ឆាតិ យោ តស្មឹ កុលេ មនុស្សោ សាមិកោ ទាតុំ តំ



ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបើនឹងចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាវិកាល មិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន ហើយក្រាលឯងខ្លះ ឲ្យគេក្រាលខ្លះនូវកម្រាលសម្រាប់ដេក រួចអង្គុយខ្លះ ដេកខ្លះទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយចូលទៅកាន់ត្រកូលទាំងឡាយក្នុងវេលាវិកាល ហើយមិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន ក៏ក្រាលឯងក្តី ឲ្យគេក្រាលក្តីនូវកម្រាលសម្រាប់ដេក ហើយអង្គុយក្តី ដេកក្តី ត្រូវអាបត្តិបាចិត្តិយ ។

(៦០៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងដំណាក់កណ្តាលទី១ រួចហើយ ។ ដែលហៅថា វេលាវិកាល គឺតាំងពីព្រះអាទិត្យអស្តង្គតទៅដរាបដល់អរុណរះឡើង ។ ដែលហៅថា ត្រកូល បានដល់ត្រកូលទាំង ៤ គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលអ្នករកស៊ីជួញប្រែធ្វើស្រែចំការ ១ ត្រកូលអ្នកស៊ីឈ្នួលគេ ១ ។ ពាក្យថា ចូលទៅរក គឺទៅកាន់ត្រកូលនោះ ។ ពាក្យថា មិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន សេចក្តីថា មនុស្សណាជាម្ចាស់ក្នុងត្រកូលនោះ ដែលអាចដើម្បីប្រគេន (វត្ថុ ។ បាន) ភិក្ខុនីមិនទាន់បានប្រាប់

អនាបុច្ឆា ។ សេយ្យំ នាម អន្តមសោ បណ្ណសន្ថារោបិ ។ សន្ថរិត្វាតិ សយំ សន្ថរតិ ។ សន្ថរាបេត្វាតិ អញ្ញំ សន្ថរាបេតិ ។ អភិនិសីទេយ្យាតិ តស្មិំ អភិនិសីទតិ អាបត្តិ បាចិត្តិយស្ស ។ អភិនិបជ្ជេយ្យាតិ តស្មិំ អភិនិបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។

[២០៧] អនាបុច្ឆិតេ អនាបុច្ឆិតសញ្ញា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ វេមតិកា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ អាបុច្ឆិតសញ្ញា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ អាបុច្ឆិតេ អនាបុច្ឆិតសញ្ញា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ អាបុច្ឆិតសញ្ញា អនាបត្តិ ។



មនុស្សនោះ ។ ដែលហៅថា កម្រាលសម្រាប់ដេក ដោយហោចទៅ សូម្បីតែកម្រាលជាវិការនៃស្លឹកឈើ (ក៏ជាកម្រាលដែរ) ។ ពាក្យថា ក្រាលឯង គឺក្រាលដោយខ្លួនឯង ។ ពាក្យថា ឲ្យគេក្រាល គឺឲ្យអ្នកដទៃក្រាល ។ ពាក្យថា អង្គុយ សេចក្ដីថា ភិក្ខុនីអង្គុយលើកម្រាលសម្រាប់ដេកនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ដេក គឺភិក្ខុនីដេកលើកម្រាលសម្រាប់ដេកនោះ ត្រូវអាបត្តិបាចិត្តិយ ។

[២០៧] ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រាប់មែន ហើយក្រាលឯងក្ដី ឲ្យគេក្រាលក្ដីនូវកម្រាលសម្រាប់ដេក ហើយអង្គុយក្ដី ដេកក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ តែភិក្ខុនីមានសេចក្ដីសង្ស័យ ហើយក្រាលឯងក្ដី ឲ្យគេក្រាលក្ដីនូវកម្រាលសម្រាប់ដេក ហើយអង្គុយក្ដី ដេកក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ ភិក្ខុនីសំគាល់ថាបានប្រាប់ទៅវិញ ហើយក្រាលឯងក្ដី ឲ្យគេក្រាលក្ដីនូវកម្រាលសម្រាប់ដេក ហើយអង្គុយក្ដី ដេកក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រាប់ទៅវិញ ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ហើយ ភិក្ខុនីសំគាល់ថាបានប្រាប់ហើយមែន មិនត្រូវអាបត្តិ ។

[២០៨] អនាបត្តិ អាបុច្ឆា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទតិ វា អភិនិបជ្ជតិ វា គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អន្ធការវគ្គស្ស អដ្ឋមសិក្ខាបទំ

[២០៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភទ្ទាយ កាបិលានិយា អន្តេវាសិនី ភិក្ខុនី(១) ភទ្ទំ កាបិលានឹ សក្កច្ចំ ឧបដ្ឋេតិ ។ ភទ្ទា កាបិលានី ភិក្ខុនិយោ ឯតទវោច អយំ មំ អយ្យេ ភិក្ខុនី សក្កច្ចំ ឧបដ្ឋេតិ ឥមិស្សាហំ ចីវរំ ទស្សាមីតិ ។ អថខោ សា ភិក្ខុនី ទុក្ខហិតេន ទុបដាកិតេន បរំ ឧដ្ឋាបេសិ(២) អហំ ខោ អយ្យេ អយ្យំ ន សក្កច្ចំ ឧបដ្ឋេមិ ន ហិ មេ អយ្យា ចីវរំ ទស្សតីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម

---

១ ម. អន្តេវាសិកភិក្ខុនី ។ ២ ម. ឧដ្ឋាបេសិ ចិវ្សតិ ។



[២០៨] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីប្រាប់ហើយក្រាលឯងក្ដី ឲ្យគេក្រាលក្ដីនូវគ្រែលាសម្រាប់ដេក ហើយអង្គុយក្ដី ដេកក្ដី១ ភិក្ខុនីមានជម្ងឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១ ។

---

## អន្ធការវគ្គ សិក្ខាបទទី ៨

[២០៩] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនីតែងតែបម្រើភទ្ទាកាបិលានីភិក្ខុនីដោយគោរព ។ ភទ្ទាកាបិលានីភិក្ខុនីពោលពាក្យនេះនឹងពួកភិក្ខុនីថា បពិត្រលោកម្ចាស់ ភិក្ខុនីនេះតែងបម្រើខ្ញុំដោយគោរព ខ្ញុំនឹងឲ្យចីវរដល់ភិក្ខុនីនេះ ។ ឯភិក្ខុនីនោះពោលមើលងាយវិញ ដោយការប្រកាន់យកសាក្រក់របស់ខ្លួន ដោយការពិចារណាខុស (របស់ខ្លួន) ថា បពិត្រលោកម្ចាស់ ខ្ញុំមិនបម្រើលោកម្ចាស់ដោយគោរពទេ ព្រោះលោកម្ចាស់មិនឲ្យចីវរមកខ្ញុំទេ ។ ពួកភិក្ខុនីណាមានសេចក្ដីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹង

ភិក្ខុនី ទុគ្គហិតេន ទូបធារិតេន បរំ ឧជ្ឈាបេស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី ទុគ្គហិតេន ទូបធារិតេន បរំ ឧជ្ឈាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី ទុគ្គហិតេន ទូបធារិតេន បរំ ឧជ្ឈាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី ទុគ្គហិតេន ទូបធារិតេន បរំ ឧជ្ឈាបេយ្យ បាចិត្តិយន្តិ ។

[៦១០] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ទុគ្គហិតេនាតិ អញ្ញថា គហិតេន(១) ។ ទូបធារិតេនាតិ អញ្ញថា ឧបធារិតេន ។ បរន្តិ ឧបសម្បន្នំ ឧជ្ឈាបេតិ អាបត្តិ បាចិត្តិយស្ស ។

១ ឱ. ម. ឧគ្គហិតេន ។



មើលងាយគេ ដោយការប្រកាន់អាក្រក់ ដោយការពិចារណាខុសសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីមើលងាយគេដោយការប្រកាន់យកអាក្រក់ ដោយការពិចារណាខុស ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងមើលងាយគេដោយការប្រកាន់យកអាក្រក់ ដោយការពិចារណាខុសទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមើលងាយគេដោយការប្រកាន់យកអាក្រក់ ដោយការពិចារណាខុស ត្រូវអាបត្តិបាចិត្តិយ ។

[៦១០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ពាក្យថា ដោយការប្រកាន់យកអាក្រក់ សេចក្តីថា ដោយការប្រកាន់យកដោយប្រការដទៃ (គឺប្រកាន់ខុស) ។ ពាក្យថា ដោយការពិចារណាខុស សេចក្តីថា ដោយការពិចារណាដោយប្រការដទៃ (យល់ខុស) ។ ពាក្យថា មើលងាយគេ សេចក្តីថា ភិក្ខុនីមើលងាយនូវឧបសម្បន្នដទៃ ត្រូវអាបត្តិបាចិត្តិយ ។

[២១១] ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា ឧជ្ឈាបេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកា ឧជ្ឈាបេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា ឧជ្ឈាបេតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នំ ឧជ្ឈាបេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។

[២១២] អនាបត្តិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## អន្ធការវគ្គស្ស ទសមសិក្ខាបទំ

[២១៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ អត្តនោ ភណ្ឌកំ អបស្សន្តិយោ ចណ្ឌកាលឹ ភិក្ខុនឹ ឯតទវោចុំ អយ្យេ



[២១១] ឧបសម្បន្នា ភិក្ខុនីសំគាល់ថាឧបសម្បន្នាមែន ហើយមើលងាយ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ហើយមើលងាយ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាអនុបសម្បន្នាទៅវិញ ហើយមើលងាយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមើលងាយអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថា ឧបសម្បន្នាទៅវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាមែន ត្រូវអាបត្តិទុក្កដ ។

[២១២] អ្នកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ២ យ៉ាង) គឺភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

## អន្ធការវគ្គ សិក្ខាបទទី ៩

[២១៣] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុនី កាលមិនឃើញភណ្ឌៈរបស់ខ្លួន ក៏បានពោលពាក្យនេះនឹងចណ្ឌកាលីភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ឃើញភណ្ឌៈរបស់ពួកយើង

អម្ហាកំ ភណ្ឌកំ បស្សេយ្យាសីតិ ។ ចណ្ឌកាលី ភិក្ខុនី ឧជ្ឈាយតិ ខីយតិ វិបាចេតិ អហមេវ នូន ចោរី អហមេវ នូនាលជ្ជិនី យា អយ្យា អត្តនោ ភណ្ឌកំ អបស្សន្តិយោ តា មំ ឯវមាហំសុ អបយ្យេ អម្ហាកំ ភណ្ឌកំ បស្សេយ្យាសីតិ សចាហយ្យេ តុម្ហាកំ ភណ្ឌកំ គណ្ហាមិ អស្សមណី ហោមិ ព្រហ្មចរិយា ចវាមិ និរយំ ឧបបជ្ជាមិ យា បន មំ អភូតេន ឯវមាហ សាបិ អស្សមណី ហោតុ ព្រហ្មចរិយា ចវតុ និរយំ ឧបបជ្ជតូតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ចណ្ឌកាលី អត្តានំបិ បរំបិ និរយេនបិ ព្រហ្មចរិយេនបិ អភិសបិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី អត្តានំបិ បរំបិ និរយេនបិ ព្រហ្មចរិយេនបិ អភិសបតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី អត្តានំបិ បរំបិ និរយេនបិ ព្រហ្មចរិយេនបិ អភិសបិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ



វត្ថុ ។ ចណ្ឌកាលីភិក្ខុនីក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ខ្ញុំឯងជាស្រីចោរពិតម្ល ខ្ញុំឯងនឹងជាស្រីគ្មានសេចក្តីខ្មាសពិតម្ល ពួកលោកម្ចាស់ណាមិនឃើញកណ្តាររបស់ខ្លួន ពួកលោកម្ចាស់នោះពោលនឹងខ្ញុំយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់ឃើញកណ្តាររបស់យើងដែរឬទេ បពិត្រលោកម្ចាស់ ប្រសិនបើខ្ញុំយកកណ្តាររបស់លោកម្ចាស់ ខ្ញុំមិនមែនជាសមណីទេ ខ្ញុំឃ្លាតចាកព្រហ្មចរិយធម៌ហើយ ខ្ញុំនឹងទៅកើតក្នុងនរក ចំណែកឯភិក្ខុនីណាពោលពាក្យយ៉ាងនេះនឹងខ្ញុំដោយពាក្យមិនពិត ភិក្ខុនីនោះឯង ចូរកុំឲ្យជាសមណី ចូរឃ្លាតចាកព្រហ្មចរិយធម៌ ចូរទៅកើតក្នុងនរកចុះ ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីជាម្ចាស់មិនសមនឹងផ្តាសាខ្លួនឯងផង អ្នកឯទៀតផង ដោយនរកផង ដោយព្រហ្មចរិយធម៌ផងសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនីផ្តាសាខ្លួនឯងផង អ្នកឯទៀតផង ដោយនរកខ្លះ ដោយព្រហ្មចរិយធម៌ខ្លះ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនីមិនសមនឹងផ្តាសាខ្លួនក្តី អ្នកឯទៀតក្តី ដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តីទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួក

វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អត្តានំ វា បរំ វា និរយេន វា ព្រហ្មចរិយេន វា អភិសបេយ្យ បាចិត្តិយន្តិ ។

[៦១៤] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អត្តានន្តិ បច្ចត្តំ ។ បរន្តិ ឧបសម្បន្នំ និរយេន វា ព្រហ្មចរិយេន វា អភិសបតិ អាបត្តិ បាចិត្តិយស្ស ។

[៦១៥] ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា និរយេន វា ព្រហ្មចរិយេន វា អភិសបតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកា និរយេន វា ព្រហ្មចរិយេន វា អភិសបតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា និរយេន វា ព្រហ្មចរិយេន វា អភិសបតិ អាបត្តិ បាចិត្តិយស្ស ។ តិរច្ឆានយោនិយា វា បេត្តិវិសយេន វា មនុស្សទោភគ្គេន[១] វា អភិសបតិ

១ ម. បេត្តិវិសយេន វា មនុស្សទោភគ្គេន ។



ដល់ជនដែលមិនទាន់ជ្រះថ្លា ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយជេរសាខ្លួនឯងក្តី អ្នកឯទៀតក្តី ដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៦១៤] ត្រង់ពាក្យថា ភិក្ខុនីណាមួយ ដូចអធិប្បាយហើយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ពាក្យថា ខ្លួនឯង គឺចំពោះខ្លួនឯង ។ ពាក្យថា អ្នកឯទៀត សេចក្តីថា ភិក្ខុនីជេរសាឧបសម្បន្នាដទៃ ដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៦១៥] ឧបសម្បន្នា ភិក្ខុនីសំគាល់ថាឧបសម្បន្នាមែន ហើយជេរ-សាដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្ប-ន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ហើយជេរសាដោយនរកក្តី ដោយព្រហ្ម-ចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុប-សម្បន្នាទៅវិញ ហើយជេរសាដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីជេរសាដោយកំណើតនៃសត្វតិរច្ឆានក្តី ដោយពេតវិស័យក្តី ដោយការជាមនុស្សមានត្រកូលថោកទាបក្តី ត្រូវអាបត្តិ

អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នំ អភិសបតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។

(៦០៦) អនាបត្តិ អត្ថបុរេក្ខាយ ធម្មបុរេក្ខាយ អនុសាសនីបុរេក្ខាយ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អន្ធការវគ្គស្ស ទសមសិក្ខាបទំ

(៦០៧) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ចណ្ឌកាលី ភិក្ខុនី ភិក្ខុនីហិ សទ្ធិំ ភណ្ឌិត្វា អត្តានំ វធិត្វា វធិត្វា រោទតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ចណ្ឌកាលី អត្តានំ វធិត្វា វធិត្វា រោទិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ



ទុក្កដ ។ ភិក្ខុនីផ្ដាសាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាជាឧបសម្បន្នវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន តែភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នដដែល ត្រូវអាបត្តិទុក្កដ ។

(៦០៦) ពួកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ ពួក) គឺ ភិក្ខុនីផ្ដាសាព្រោះធ្វើអត្ថឲ្យជាប្រធាន ១ ភិក្ខុនីផ្ដាសាព្រោះធ្វើធម៌ឲ្យជាប្រធាន ១ ភិក្ខុនីផ្ដាសាព្រោះធ្វើការប្រៀនប្រដៅឲ្យជាប្រធាន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## អន្ធការវគ្គ សិក្ខាបទទី ១០

(៦០៧) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនី ឈ្លោះនឹងភិក្ខុនីទាំងឡាយ ក៏យកដៃគប់ខ្លួនឯងហើយយំ ។ ពួកភិក្ខុនីណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនីនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីភិក្ខុនីមិនសមទំនងយកដៃគប់ខ្លួនហើយយំសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលី

ចណ្ឌកាឡី ភិក្ខុនី អត្តានំ វធិត្វា វធិត្វា រោទតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ចណ្ឌកាឡី ភិក្ខុនី អត្តានំ វធិត្វា វធិត្វា រោទិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អត្តានំ វធិត្វា វធិត្វា រោទេយ្យ បាចិត្តិយន្តិ ។

(២១៨) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អត្តានន្តិ បច្ចត្តំ ។ វធិត្វា វធិត្វា រោទតិ អាបត្តិ បាចិត្តិយស្ស ។ វធតិ ន រោទតិ អាបត្តិ ទុក្កដស្ស ។ រោទតិ ន វធតិ អាបត្តិ ទុក្កដស្ស ។

(២១៩) អនាបត្តិ ញាតិព្យសនេន វា ភោគព្យសនេន វា រោគព្យសនេន វា ផុដ្ឋា រោទតិ ន វធតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

អន្ធការវគ្គោ ទុតិយោ ។



ភិក្ខុនីវាយកប់ទះខ្លួនឯងហើយយំ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនីមិនសមនឹងវាយកប់ទះខ្លួនឯងហើយយំសោះ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយវាយកប់ទះខ្លួនឯងហើយយំ ត្រូវអាបត្តិបាចិត្តិយ ។

(២១៨) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ពាក្យថា ខ្លួនឯង គឺចំពោះខ្លួនឯង ។ ភិក្ខុនីវាយកប់ទះហើយយំ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីគ្រាន់តែវាយតែមិនយំ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីគ្រាន់តែយំតែមិនបានវាយ ត្រូវអាបត្តិទុក្កដ ។

(២១៩) អាការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីមានសេចក្ដីវិនាសញាតិក្ដី សេចក្ដីវិនាសភោគសម្បត្តិក្ដី សេចក្ដីវិនាសព្រោះរោគក្ដី មកប៉ះពាល់ហើយយំតែមិនវាយ (ខ្លួនឯង) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

អន្ធការវគ្គ ទី ២ ចប់ ។

## ឆត្តវគ្គស្ស បឋមសិក្ខាបទំ

(៦៦០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខុនិយោ អចិរវតិយា នទិយា វេសិយាហិ សទ្ធឹ នគ្គា ឯកតិត្ថេ នហាយន្តិ ។ វេសិយា តា ភិក្ខុនិយោ ឧប្បណ្ឌេសុំ(១) កិន្នុ ខោ នាម អយ្យេ តុម្ហាកំ ទហរានំ ព្រហ្មចរិយំ ចិណ្ណេន ននុ នាម កាមា បរិភុញ្ជិតព្វា យទា ជិណ្ណា ភវិស្សថ តទា ព្រហ្មចរិយំ ចរិស្សថ ឯវំ តុម្ហាកំ ឧភោ អត្ថា(២) បរិគ្គហិតា ភវិស្សន្តីតិ ។ ភិក្ខុនិយោ វេសិយាហិ ឧប្បណ្ឌិយមានា(៣) មង្កូ អហេសុំ ។ អថខោ តា ភិក្ខុនិយោ ឧបស្សយំ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខុនីនំ

១ ឱ. ម. ឧប្បណ្ឌេសុំ ។ ២ ម. អត្ថា ។ ៣ ឱ. ម. ឧប្បណ្ឌិយមានា ។

## ឆត្តវគ្គ សិក្ខាបទទី ១

(៦៦០) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុនីច្រើនរូបមានកាយអាក្រាតងូតទឹកក្នុងកំពង់ទឹកមួយ ជាមួយនឹងពួកស្រីពេស្យា ក្នុងស្ទឹងអចិរវតី ។ ពួកស្រីពេស្យានាំគ្នាចំអកលេងនឹងភិក្ខុនីទាំងនោះថា នែលោកម្ចាស់ទាំងឡាយ ពួកលោកកំពុងពេញក្រមុំទំសង្ស ព្រហ្មចរិយធម៌ប្រយោជន៍អ្វី ពួកលោកគួរតែនៅបរិភោគកាមទៅសិន កាលណាលោកទាំងឡាយចាស់ សឹមពួកលោកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងកាលណោះចុះ កាលបើធ្វើយ៉ាងនេះ ប្រយោជន៍ទាំងពីរឈ្មោះថាពួកលោកបានកាន់យកហើយ ។ ភិក្ខុនីទាំងឡាយកាលដែលពួកស្រីពេស្យានិយាយចំអក (ដូច្នេះ) ក៏មានសេចក្ដីអៀនខ្មាស ។ គ្រានោះ ភិក្ខុនីទាំងនោះនាំគ្នាទៅកាន់លំនៅហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្ត

សិក្ខាបទំ បញ្ញបេស្សាមិ ទស អត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ ។ បេ ។ វិនយានុគ្គហាយ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី នគ្គា នហាយេយ្យ បាចិត្តិយន្តិ ។

[៦៦១] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ នគ្គា នហាយេយ្យាតិ អនិវត្ថា វា អបារុតា វា នហាយតិ បយោគេ ទុក្កដំ នហានបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៦៦២] អនាបត្តិ អច្ឆិន្នចីវរិកាយ វា នដ្ឋចីវរិកាយ វា អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## នគ្គវគ្គស្ស ទុតិយសិក្ខាបទំ

[៦៦៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខុនីនំ ឧទកសាដិកា អនុញ្ញាតា ហោតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ ភគវតា



សិក្ខាបទដល់ភិក្ខុនីទាំងឡាយ ព្រោះអាស្រ័យនូវប្រយោជន៍ទាំងឡាយ ១០ ប្រការ គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ។បេ។ ដើម្បីអនុគ្រោះដល់វិន័យ ១ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយអាក្រាតកាយងូតទឹក ត្រូវអាបត្តិបាចិត្តិយ ។

(៦៦១] ត្រង់ពាក្យថា ភិក្ខុនីណាមួយមានសេចក្តីអធិប្បាយក្នុងបារាជិកកណ្ឌទី ១ រួចហើយ ។ ពាក្យថា អាក្រាតកាយងូតទឹក សេចក្តីថា ភិក្ខុនីមិនស្លៀកសំពត់ឬមិនដណ្តប់សំពត់ហើយងូតទឹក ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលងូត វេលាងូតស្រេច ត្រូវអាបត្តិបាចិត្តិយ ។

(៦៦២] អ្នកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុនីមានចីវរដែលពួកចោរលួចយកទៅ ឬមានចីវរបាត់ទៅ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

---

## នគ្គវគ្គ សិក្ខាបទទី ២

(៦៦៣) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់ក្នុងអារាមជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសំពត់ងូតទឹកដល់ពួកភិក្ខុនី ។ ពួកឆព្វគ្គិយា

ឧទកសាដិកា អនុញ្ញាតាតិ អប្បមាណិកាយោ ឧទ-
កសាដិកាយោ ធារេសុំ បុរតោបិ បច្ឆតោបិ អាកឌ្ឍ-
ន្តា អាហិណ្ឌន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។
តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ព-
គ្គិយា ភិក្ខុនិយោ អប្បមាណិកាយោ ឧទកសាដិកា-
យោ ធារេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្ពគ្គិយា
ភិក្ខុនិយោ អប្បមាណិកាយោ ឧទកសាដិកាយោ
ធារេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ
ហិ នាម ភិក្ខវេ ឆព្ពគ្គិយា ភិក្ខុនិយោ អប្បមាណិ-
កាយោ ឧទកសាដិកាយោ ធារេស្សន្តិ នេតំ ភិក្ខវេ
អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ
ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ ឧទកសាដិកំ
បន ភិក្ខុនិយា ការយមានាយ បមាណិកា ការេ-
តព្វា ។ តត្រិទំ បមាណំ ទីឃសោ ចតស្សោ វិទត្ថិយោ
សុគតវិទត្ថិយា តិរិយំ ទ្វេ វិទត្ថិយោ តំ អតិក្កាមេន្តិយា
ឆេទនកំ បាចិត្តិយន្តិ ។



ភិក្ខុនីទាំងឡាយនឹកគ្នាថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសំពត់ងូតទឹក
ហើយ ទើបនាំគ្នាស្លៀកដណ្តប់សំពត់ងូតទឹកទាំងឡាយ មិនមានប្រមាណ
ក៏ដាប់ទាញពីមុខខ្លះ ពីក្រោយខ្លះហើយត្រាច់ទៅ ។ ភិក្ខុនីទាំងឡាយ
ណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស
តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនីមិនសមបីនឹងទ្រទ្រង់នូវសំពត់
ងូតទឹកគ្មានប្រមាណសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា
ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយាភិក្ខុនី ទ្រទ្រង់នូវសំពត់ងូតទឹកមិន
មានប្រមាណ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស
ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាល
ភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនីមិនសមបីនឹងទ្រទ្រង់នូវសំពត់ងូតទឹកមិន
មានប្រមាណទេ ម្នាលភិក្ខុទាំងឡាយ អំពើនុះមិនជាទីជ្រះថ្លាដល់ជន
ទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី
ចូរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីកាលឲ្យគេធ្វើសំពត់ងូត
ទឹកគប្បីឲ្យគេធ្វើឲ្យល្មមប្រមាណ ។ ឯប្រមាណក្នុងសំពត់ងូតទឹកនោះ គឺ
បណ្តោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត កាលភិក្ខុនី
ធ្វើឲ្យកន្លងលើសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ[១] ។

---

១ គឺភិក្ខុនីត្រូវកាត់សំពត់នោះត្រឹមប្រមាណ ហើយសឹមសំដែងអាបត្តិទើបបាន ។

(៦៦៦) ឧទកសាដិកា នាម យាយ និវត្ថា(*) នហាយតិ ។ ការយមានាយាតិ ករេន្តិយា វា ការាបេន្តិយា វា បមាណិកា ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ ចតស្សោ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ទ្វេ វិទត្ថិយោ ។ តំ អតិក្កាមេត្វា ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ឆិន្ទិត្វា បាចិត្តិយំ ទេសេតព្វំ ។

(៦៦៧) អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

* ម. ឧ. និវត្ថា ។

៦១០



(៦៦៦) ភិក្ខុនីងូតទឹកដោយសំពត់ស្លៀកណា សំពត់ស្លៀកនោះ ឈ្មោះថាសំពត់ងូតទឹក ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ សេចក្តីថា ភិក្ខុនីកាលធ្វើឯងក្តី ប្រើឲ្យគេធ្វើក្តី គប្បីឲ្យធ្វើឲ្យត្រូវប្រមាណ ។ ឯប្រមាណក្នុងសំពត់ងូតទឹកនោះ គឺបណ្តោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ។ ភិក្ខុនីធ្វើឯងក្តី ប្រើគេឲ្យធ្វើក្តី ឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុនីត្រូវកាត់ក្នុងខណៈដែលបានមក ហើយសំដែងអាបត្តិបាចិត្តិយចេញ ។

(៦៦៧) ភិក្ខុនីសម្រេចដោយខ្លួនឯងនូវសម្ពត់ដែលខ្លួនធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីប្រើពួកអ្នកដទៃឲ្យសម្រេចនូវសម្ពត់ដែលខ្លួនធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីសម្រេចដោយខ្លួនឯងនូវសម្ពត់ដែលពួកអ្នកដទៃធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីប្រើពួកអ្នកដទៃឲ្យសម្រេចនូវសម្ពត់ដែលពួកអ្នកដទៃធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីធ្វើឯងក្តី ប្រើគេឲ្យធ្វើក្តី ដើម្បីប្រយោជន៍ដល់អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីបានសំពត់ងូតទឹកដែលអ្នកដទៃធ្វើស្រេចហើយមកប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៦៦៦] អនាបត្តិ បមាណិកំ ករោតិ ឩនកំ ករោតិ អញ្ញេន កតំ បមាណាតិក្កន្តំ បដិលភិត្វា ឆិន្ទិត្វា បរិភុញ្ជតិ វិតានំ វា ភូម្មត្ថរណំ វា សាណិបាការំ វា ភិសិំ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## នគ្គវគ្គស្ស តតិយសិក្ខាបទំ

[៦៦៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរិស្សា ភិក្ខុនិយា មហគ្ឃំ ចីវរទុស្សំ ឧប្បន្នំ ហោតិ ទុស្សិព្វិតំ ។ ថុល្លនន្ទា ភិក្ខុនី តំ ភិក្ខុនឹ ឯតទវោច សុន្ទរំ ខោ ឥទំ អយ្យេ ចីវរទុស្សំ ឧប្បន្នញ្ច ខោ ឧប្បន្នំ ទុស្សិព្វិតញ្ច ។ វិសិព្វេហិ អយ្យេ សិព្វិស្សាមីតិ ។ អាមយ្យេ សិព្វេហីតិ ។ អថ ខោ សា ភិក្ខុនី តំ ចីវរំ វិសិព្វេត្វា[១] ថុល្លនន្ទាយ ភិក្ខុនិយា អទាសិ ។ ថុល្លនន្ទា ភិក្ខុនី សិព្វិស្សាមិ សិព្វិស្សាមីតិ នេវ សិព្វេតិ ន សិព្វាបនាយ ឧស្សុក្កំ

១ វិសិព្វេត្វាតិ ទុស្សិព្វិតំ បុន សិព្វនត្ថាយ វិសិព្វេត្វា វិជដេត្វាតិ ទុតិយសារត្ថទីបនីដីកា ។



[៦៦៦] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺ ភិក្ខុនីធ្វើត្រឹមត្រូវប្រមាណ ១ ភិក្ខុនីធ្វើថយតិចប្រមាណចុះមក ១ ភិក្ខុនីបានឧទកសាដកដែលភិក្ខុនីដទៃធ្វើឲ្យកន្លងហួសប្រមាណ ហើយយកមកកាត់បញ្ចេញទើបប្រើប្រាស់ ១ ភិក្ខុនីធ្វើឲ្យជាពិតានក្តី ជាកម្រាលក្រាលដីក្តី ជាវាំងននក្តី ជាពូកក្តី ជាខ្នើយក្តី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

## នគ្គវគ្គ សិក្ខាបទទី ៣

[៦៦៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សម្ពត់សម្រាប់ធ្វើចីវររបស់ភិក្ខុនី ១ រូប មានដំឡៃច្រើន ចីវរ (នោះ) ធ្វើមិនល្អ ដេរមិនល្អ ។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា នែលោកម្ចាស់ សម្ពត់ចីវររបស់លោកនេះល្អណាស់ តែចីវរនោះធ្វើមិនល្អ ដេរមិនល្អ ។ ភិក្ខុនីនោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងស្រាយចេញ លោកម្ចាស់ចូរដេរឲ្យ ។ ថុល្លនន្ទាភិក្ខុនីឆ្លើយថា អើលោកម្ចាស់ ខ្ញុំនឹងដេរឲ្យ ។ លំដាប់នោះ ភិក្ខុនីនោះក៏ស្រាយចីវរនោះចេញ ហើយប្រគល់ឲ្យថុល្លនន្ទាភិក្ខុនី ។ ថុល្លនន្ទាភិក្ខុនីគិតថា អញនឹងដេរ ៗ តែមិនដេរ

ការេតិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោ-
ចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា
ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា
ថុល្លនន្ទា ភិក្ខុនិយា ចីវរំ វិសិព្វាបេត្វា នេវ សិព្វេស្សតិ
ន សិព្វាបនាយ ឧស្សុក្កំ ករិស្សតីតិ ។បេ។ សច្ចំ
កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភិក្ខុនិយា ចីវរំ វិសិព្វា-
បេត្វា នេវ សិព្វេតិ ន សិព្វាបនាយ ឧស្សុក្កំ ករោ-
តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ
នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភិក្ខុនិយា ចីវរំ វិសិព្វា-
បេត្វា នេវ សិព្វេស្សតិ ន សិព្វាបនាយ ឧស្សុក្កំ
ករិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ
។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ
ឧទ្ទិសន្តុ យា បន ភិក្ខុនី ភិក្ខុនិយា ចីវរំ វិសិព្វេត្វា
វា វិសិព្វាបេត្វា វា សា បច្ឆា អនន្តរាយិកិនី នេវ
សិព្វេយ្យ ន សិព្វាបនាយ ឧស្សុក្កំ ករេយ្យ អញ្ញត្រ
ចតូហបញ្ចាហា បាចិត្តិយន្តិ ។



មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ។ ភិក្ខុនីនោះក៏ប្រាប់សេចក្តីនុ៎ះដល់ពួក
ភិក្ខុនីដទៃ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។
ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ថុល្លនន្ទា
ម្ចាស់មិនសមបើនឹងឲ្យភិក្ខុនីដទៃស្រាយចីវរចេញហើយក៏មិនដេរខ្លួនឯង មិន
ធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរវិញសោះ ។បេ។ ព្រះអង្គត្រាស់សួរថា
ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យភិក្ខុនីដទៃស្រាយចីវរចេញហើយ
មិនដេរខ្លួនឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ពិតមែនឬ ។ ភិក្ខុទាំង
ឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មាន
ព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹង
ឲ្យភិក្ខុនីដទៃស្រាយចីវរចេញហើយ មិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បី
ឲ្យគេដេរទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់
ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី
ទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយស្រាយ
ឯងក្តី ឲ្យគេស្រាយក្តី នូវចីវររបស់ភិក្ខុនីដទៃ ភិក្ខុនីនោះមិនមានសេចក្តី
អន្តរាយក្នុងកាលជាខាងក្រោយទេ ហើយមិនដេរឯង មិនធ្វើការខ្វល់-
ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ (ដ៏កល់ទុក)
ត្រឹម ៤-៥ ថ្ងៃ ។

[៦៦៨] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុនិយាតិ អញ្ញាយ ភិក្ខុនិយា ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ ។ វិសិព្វេត្វាតិ សយំ វិសិព្វេត្វា ។ វិសិព្វាបេត្វាតិ អញ្ញំ វិសិព្វាបេត្វា ។ សា បច្ឆា អនន្តរាយិកិនីតិ អសតិ អន្តរាយេ ។ នេវ សិព្វេយ្យាតិ ន សយំ សិព្វេយ្យ ។ ន សិព្វាបនាយ ឧស្សុក្កំ ករេយ្យាតិ ន អញ្ញំ អាណាបេយ្យ ។ អញ្ញត្រ ចតុហបញ្ចាហាតិ ឋបេត្វា ចតុហបញ្ចាហំ ។ នេវ សិព្វិស្សាមិ ន សិព្វាបនាយ ឧស្សុក្កំ ករិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

[៦៦៩] ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា ចីវរំ វិសិព្វេត្វា វា វិសិព្វាបេត្វា វា សា បច្ឆា អនន្តរាយិកិនី នេវ សិព្វតិ ន សិព្វាបនាយ ឧស្សុក្កំ ករោតិ អញ្ញត្រ ចតុហបញ្ចាហា អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកា ចីវរំ វិសិព្វេត្វា វា វិសិព្វាបេត្វា វា សា បច្ឆា អនន្តរាយិកិនី នេវ សិព្វតិ ន



[៦៦៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងបាចិត្តិយកណ្ឌ សិក្ខាបទទី ១ រួចហើយ ។ ពាក្យថា ភិក្ខុនីដទៃ គឺភិក្ខុនីឯទៀត ។ ដែលហៅថា ចីវរនោះ បានដល់ចីវរ ៦ យ៉ាង ចីវរណាមួយ ។ ពាក្យថា ស្រាយឯង គឺស្រាយចេញដោយខ្លួនឯង ។ ពាក្យថា ឲ្យគេស្រាយ គឺប្រើអ្នកដទៃឲ្យស្រាយ ។ ពាក្យថា ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយក្នុងកាលជាខាងក្រោយទេ គឺគ្មានសេចក្តីអន្តរាយសោះឡើយ ។ ពាក្យថា មិនដេរឯង គឺភិក្ខុនីមិនដេរដោយខ្លួនឯង ។ ពាក្យថា មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ គឺភិក្ខុនីមិនបង្គាប់អ្នកដទៃឡើយ ។ ពាក្យថា វៀរលែងតែ (ដំកល់ទុក) ត្រឹម ៤-៥ ថ្ងៃ គឺលើកទុកត្រឹម ៤ ថ្ងៃ ៥ ថ្ងៃប៉ុណ្ណោះ ។ បើភិក្ខុនីត្រាន់តែដាក់ធុរៈថា អញមិនដេរឯង អញនឹងមិនធ្វើនូវសេចក្តីខ្វល់ខ្វាយដើម្បីឲ្យគេដេរផង ដូច្នេះ ក៏ត្រូវអាបត្តិបាចិត្តិយ ។

[៦៦៩] ឧបសម្បន្នា ភិក្ខុនីក៏សំគាល់ថាឧបសម្បន្នាមែន ហើយស្រាយឯងក្តី ប្រើគេឲ្យស្រាយក្តីនូវចីវរ លុះតមកខាងក្រោយ ភិក្ខុនីនោះក៏មិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ (ទុកដាក់) ត្រឹម ៤-៥ ថ្ងៃ ។ ឧបសម្បន្នា តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយស្រាយឯងក្តី ប្រើគេឲ្យស្រាយក្តី នូវចីវរ តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរ

សិព្វាបនាយ ឧស្សុក្កំ ករោតិ អញ្ញត្រ ចតុបញ្ចាហា អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា ចីវរំ វិសិព្វេត្វា វា វិសិព្វាបេត្វា វា សា បច្ឆា អនន្តរាយិកិនី នេវ សិព្វេតិ ន សិព្វាបនាយ ឧស្សុក្កំ ករោតិ អញ្ញត្រ ចតុបញ្ចាហា អាបត្តិ បាចិត្តិយស្ស ។ អញ្ញំ បរិក្ខារំ វិសិព្វេត្វា វា វិសិព្វាបេត្វា វា សា បច្ឆា អនន្តរាយិកិនី នេវ សិព្វេតិ ន សិព្វាបនាយ ឧស្សុក្កំ ករោតិ អញ្ញត្រ ចតុបញ្ចាហា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ចីវរំ វា អញ្ញំ វា បរិក្ខារំ វិសិព្វេត្វា វា វិសិព្វាបេត្វា វា សា បច្ឆា អនន្តរាយិកិនី នេវ សិព្វេតិ ន សិព្វាបនាយ ឧស្សុក្កំ ករោតិ អញ្ញត្រ ចតុបញ្ចាហា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។



ឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ (ទុកជាក់) ត្រឹម ៤-៥ ថ្ងៃប៉ុណ្ណោះ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាវិញ ស្រាយឯងក្តី ប្រើគេឲ្យស្រាយក្តី នូវចីវរ តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ (ទុកជាក់) ត្រឹម ៤-៥ ថ្ងៃ ។ ភិក្ខុនីស្រាយឯងក្តី ប្រើគេឲ្យស្រាយក្តី នូវបរិក្ខារដទៃ តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិទុក្កដ វៀរលែងតែ (ទុកជាក់) ត្រឹម ៤-៥ ថ្ងៃ ។ ភិក្ខុនីស្រាយឯងក្តី ប្រើគេឲ្យស្រាយក្តី នូវចីវរក្តី បរិក្ខារដទៃក្តី របស់អនុបសម្បន្ន តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិទុក្កដ វៀរលែងតែ (ទុកជាក់) ត្រឹម ៤-៥ ថ្ងៃ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាជាឧបសម្បន្នវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នដដែល ត្រូវអាបត្តិទុក្កដ ។

[៨៣០] អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ ករោន្តី(១) ចតុហបញ្ចាហំ អតិក្កាមេតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

# នគ្គវគ្គស្ស ចតុត្ថសិក្ខាបទំ

[៨៣១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ភិក្ខុនីនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមន្តិ ។ តានិ ចីវរានិ ចិរំ និក្ខិត្តានិ កណ្ណកិតានិ ហោន្តិ ។ តានិ ភិក្ខុនិយោ ឱតាបេន្តិ ។ ភិក្ខុនិយោ តា ភិក្ខុនិយោ ឯតទវោចុំ កស្សិមានិ អយ្យេ ចីវរានិ កណ្ណកិតានីតិ ។ អថ ខោ តា ភិក្ខុនិយោ ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ភិក្ខុនីនំ

១ ម. ករោន្តិ ។



[៨៣០] ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) ភិក្ខុនីមានសេចក្ដីអន្តរាយ ហើយស្វែងរកគ្នាមិនបាន ១ ភិក្ខុនីកំពុងតែធ្វើ ស្រាប់តែកន្លងទៅហួស ៤-៥ ថ្ងៃទៅ ១ ភិក្ខុនីមានជម្ងឺ ១ ភិក្ខុនីមានសេចក្ដីអន្តរាយផ្សេងៗ កើតឡើង ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

# នគ្គវគ្គ សិក្ខាបទទី ៤

[៨៣១] សម័យនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុនីផ្ញើរ (សង្ឃាដី) ទុកក្នុងដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទ ដោយមានតែស្បង់និងចីពរទៅប៉ុណ្ណោះ ។ ចីវរទាំងឡាយដែលពួកភិក្ខុនីផ្ញើរទុកយូរពេកនោះក៏ដុះផ្សិតស្រោបឡើងទៅអស់ ។ ភិក្ខុនីទាំងឡាយយកចីវរទាំងនោះទៅសំងំហាល ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងភិក្ខុនីទាំងនោះថា នែះលោកម្ចាស់ទាំងឡាយ ចីវរទាំងនេះរបស់អ្នកណា ក៏ដុះផ្សិតស្រោបឡើងអស់ ។ ទើបភិក្ខុនីទាំងនោះប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្ទោសថា

ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមិស្សន្តិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ភិក្ខុនីនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ភិក្ខុនីនំ ហត្ថេ ចីវរំ និក្ខិបិត្វា សន្តរុត្តរេន ជនបទចារិកំ បក្កមិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី បញ្ចាហិកំ សង្ឃាដិចារំ(១) អតិក្កាមេយ្យ បាចិត្តិយន្តិ ។

(២៣៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បញ្ចាហិកំ សង្ឃាដិចារំ(២) អតិក្កាមេយ្យាតិ បញ្ចមំ ទិវសំ បញ្ច ចីវរានិ នេវ និវាសេតិ ន បារុបតិ ន ឱតាបេតិ បញ្ចមំ ទិវសំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

១-២ ម. ឧ. សង្ឃាដិចារំ ។



ពួកភិក្ខុនីមិនសមបីនឹងផ្ញើចីវរក្នុងកណ្ដាប់ដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទ ដោយមានតែស្បង់និងចីពរប៉ុណ្ណោះសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយផ្ញើចីវរក្នុងកណ្ដាប់ដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទ ដោយមានតែស្បង់និងចីពរប៉ុណ្ណោះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបីនឹងផ្ញើចីវរក្នុងកណ្ដាប់ដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទ ដោយមានតែស្បង់និងចីពរទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ញុំាងចារៈនៃសង្ឃាដីឲ្យកន្លងហួស៥ថ្ងៃទៅ ត្រូវអាបត្តិបាចិត្តិយ ។

(២៣៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយដូចសិក្ខាបទទី១ នៃខុទ្ទកកណ្ឌរួចហើយ ។ ពាក្យថា ញុំាងចារៈនៃសង្ឃាដីឲ្យកន្លងហួស៥ថ្ងៃទៅ សេចក្ដីថា ភិក្ខុនីមិនបានស្លៀក មិនបានក្រង មិនបានសំងំលហាលនូវចីវរទាំង៥អស់ថ្ងៃទី៥ គឺជាវត្តឲ្យកន្លងហួសថ្ងៃទី៥ទៅ ត្រូវអាបត្តិបាចិត្តិយ ។

(២៣៣) បញ្ចាហាតិក្កន្តេ អតិក្កន្តសញ្ញា អាបត្តិ បាចិត្តិយស្ស ។ បញ្ចាហាតិក្កន្តេ វេមតិកា អាបត្តិ បាចិត្តិយស្ស ។ បញ្ចាហាតិក្កន្តេ អនតិក្កន្តសញ្ញា អាបត្តិ បាចិត្តិយស្ស ។ បញ្ចាហានតិក្កន្តេ អតិក្កន្តសញ្ញា អាបត្តិ ទុក្កដស្ស ។ បញ្ចាហានតិក្កន្តេ វេមតិកា អាបត្តិ ទុក្កដស្ស ។ បញ្ចាហានតិក្កន្តេ អនតិក្កន្តសញ្ញា អនាបត្តិ ។

(២៣៤) អនាបត្តិ បញ្ចមំ ទិវសំ បញ្ច ចីវរានិ និវាសេតិ វា បារុបតិ វា ឱតាបេតិ វា គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## នគ្គវគ្គស្ស បញ្ចមសិក្ខាបទំ

(២៣៥) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី បិណ្ឌាយ ចរិត្វា



(២៣៣) កាលនៃសង្ឃាដិកន្លងហួស ៥ ថ្ងៃទៅហើយ ភិក្ខុនីសំគាល់ថាកន្លងហួស ៥ ថ្ងៃទៅហើយ ត្រូវអាបត្តិបាចិត្តិយ ។ កាលនៃសង្ឃាដិកន្លងហួស ៥ ថ្ងៃទៅហើយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ ។ កាលនៃសង្ឃាដិកន្លងហួស ៥ ថ្ងៃទៅហើយ ភិក្ខុនីសំគាល់ថាមិនទាន់កន្លងទៅទេ ត្រូវអាបត្តិបាចិត្តិយ ។ កាលនៃសង្ឃាដិមិនទាន់កន្លងហួស ៥ ថ្ងៃទៅទេ ភិក្ខុនីសំគាល់ថាកន្លងទៅហើយ ត្រូវអាបត្តិទុក្កដ ។ កាលនៃសង្ឃាដិមិនទាន់កន្លងហួស ៥ ថ្ងៃទៅទេ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលនៃសង្ឃាដិមិនកន្លងហួស ៥ ថ្ងៃទៅទេ ភិក្ខុនីសំគាល់ថា មិនទាន់កន្លងទៅទេ មិនត្រូវអាបត្តិឡើយ ។

(២៣៤) ការដែលមិនត្រូវអាបត្តិ (គឺសំពត់ចីវរមាន ៥ យ៉ាង) គឺភិក្ខុនីស្លៀកក្តី ដណ្តប់ក្តី សំងំល ហាលក្តី នូវចីវរទាំង៥ ក្នុងថ្ងៃទី៥ ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## នគ្គវគ្គ សិក្ខាបទទី ៥

(២៣៥) សម័យនោះ ព្រះពុទ្ធជាម្ចាស់ព្រះមានព្រះភាគគង់ក្នុងវត្ត ជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង

អល្លចីវរំ បត្ថរិត្វា វិហារំ បាវិសិ ។ អញ្ញតរា ភិក្ខុនី តំ ចីវរំ បារុបិត្វា គាមំ បិណ្ឌាយ បាវិសិ ។ សា និក្ខមិត្វា ភិក្ខុនិយោ បុច្ឆិ អយ្យេ មយ្ហំ ចីវរំ បស្សេយ្យាថាតិ ។ ភិក្ខុនិយោ តស្សា ភិក្ខុនិយា ឯតមត្ថំ អារោចេសុំ ។ អថខោ សា ភិក្ខុនី ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនី មយ្ហំ ចីវរំ អនាបុច្ឆា បារុបិស្សតីតិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី ភិក្ខុនិយា ចីវរំ អនាបុច្ឆា បារុបិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី ភិក្ខុនិយា ចីវរំ អនាបុច្ឆា បារុបតីតិ[1] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី ភិក្ខុនិយា ចីវរំ អនាបុច្ឆា បារុបិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។

---

[1] ម. ឆ. បារុបីតិ ។



ភិក្ខុនី ១ រូប ត្រាច់បិណ្ឌបាត (ត្រឡប់មកវិញ) ក៏សំងិលចីវរដែលទទឹកដោយញើស ហើយចូលទៅកាន់វិហារ ។ មានភិក្ខុនី ១ រូប យកចីវរនោះគ្រង ហើយចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ភិក្ខុនីនោះចេញ (ពីវិហារ) ទៅហើយ សួរភិក្ខុនីទាំងឡាយថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយបានឃើញចីវររបស់ខ្ញុំដែរ ។ ភិក្ខុនីទាំងឡាយប្រាប់សេចក្ដីនុះដល់ភិក្ខុនីនោះ ។ ទើបភិក្ខុនីនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងមិនប្រាប់ដល់ខ្ញុំជាមុន ហើយយកចីវរទៅគ្រងសោះ ។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងមិនប្រាប់ជាមុនហើយយកចីវររបស់ភិក្ខុនីដទៃគ្នាទៅគ្រងសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីមិនបានប្រាប់ជាមុនហើយយកចីវររបស់ភិក្ខុនីដទៃគ្នាទៅគ្រង ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងមិនប្រាប់ជាមុនហើយយកចីវររបស់ភិក្ខុនីដទៃគ្នាទៅគ្រងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ចីវរសង្កមនីយំ ធារេយ្យ បាចិត្តិយន្តិ ។

(៦៣៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ចីវរសង្កមនីយំ នាម ឧបសម្បន្នាយ បញ្ចន្នំ ចីវរានំ អញ្ញតរំ ចីវរំ ។ ធារេយ្យាតិ សចេ និវាសេតិ វា បារុបតិ វា អាបត្តិ បាចិត្តិយស្ស ។

(៦៣៧) ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា ចីវរសង្កមនីយំ ធារេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកា ចីវរសង្កមនីយំ ធារេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា ចីវរសង្កមនីយំ ធារេតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នាយ ចីវរសង្កមនីយំ ធារេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញា អាបត្តិ



ភិក្ខុនីទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ទ្រទ្រង់ ( ស្លៀកដណ្តប់ ) នូវសង្កមនីយចីវរ[*] គឺចីវរដែលខ្លួនលបយក ទៅប្រើប្រាស់មួយសំណើរ ត្រូវអាបត្តិបាចិត្តិយ ។

(៦៣៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុង សិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ចីវរដែលឈ្មោះថា សង្កមនីយ នោះ បានដល់ចីវរទាំង ៥ ចំណែកណាមួយ របស់ស្រីដែលជាឧបសម្បន្នា ។ ភិក្ខុនីមិនប្រាប់ជាមុនហើយស្លៀកក្តី ដណ្តប់ក្តី នូវចីវរដែលភិក្ខុនីនោះមិនបាន ឲ្យក្តី នូវសង្កមនីយចីវរនោះក្តី ត្រូវអាបត្តិបាចិត្តិយ ។

(៦៣៧) ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ហើយ ទ្រទ្រង់នូវសង្កមនីយចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីមាន សេចក្តីសង្ស័យ ហើយទ្រទ្រង់នូវសង្កមនីយចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាទៅវិញ ហើយទ្រទ្រង់នូវ សង្កមនីយចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីទ្រទ្រង់នូវសង្កមនីយចីវររបស់ អនុបសម្បន្នា ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជា

---

* ចីវររបស់ភិក្ខុនីឯទៀត ដែលខ្លួនមិនបានប្រាប់ម្ចាស់ចីវរហើយកាន់យកទៅ ត្រូវតែប្រគល់ឲ្យម្ចាស់ចំពោះវិញ ។ (អដ្ឋកថាវិន័យ) ។

ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។

(៦៣៨) អនាបត្តិ សា ច ទេតិ តំ ច អាបុច្ឆា ធិការេតិ ច ទារុបតិ ច អច្ឆិន្នចីវរិកាយ នដ្ឋចីវរិកាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆក្កវគ្គស្ស ឆដ្ឋសិក្ខាបទំ

(៦៣៩) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទាយ ភិក្ខុនិយា ឧបដ្ឋាកកុលំ ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោច ភិក្ខុនីសង្ឃស្ស អយ្យេ ចីវរំ ទស្សាមាតិ ។ ថុល្លនន្ទា ភិក្ខុនី តុម្ហេ ពហុកិច្ចា ពហុករណីយាតិ អន្តរាយំ អកាសិ ។ តេន ខោ បន សមយេន តស្ស កុលស្ស ឃរំ ឌយ្ហតិ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា



ឧបសម្បន្នាទៅវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ ។

(៦៣៨) ភ.ដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុនីជាម្ចាស់ចីវរនោះឲ្យ ១ ភិក្ខុនីបានប្រាប់ហើយស្លៀតក្តី ដណ្តប់ក្តីនូវចីវរនោះ ១ ភិក្ខុនីមានចីវរចោរដណ្តើមយកទៅ ១ ភិក្ខុនីមានចីវរបាត់ទៅ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

## ឆក្កវគ្គ សិក្ខាបទទី ៦

(៦៣៩) សម័យនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី បាននិយាយភាសានេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងថ្វាយចីវរដល់ភិក្ខុនីសង្ឃ ។ ថុល្លនន្ទាភិក្ខុនីនិយាយថា អ្នកទាំងឡាយមានកិច្ចច្រើន មានការដែលត្រូវធ្វើច្រើន ដូច្នេះហើយក៏ធ្វើចីវរទានឲ្យអន្តរាយទៅ ។ ចួនសម័យនោះផ្ទះរបស់ត្រកូលនោះក៏ឆេះ ។ មនុស្សទាំងនោះក៏ពោលទោស តិះដៀល

ថុល្លនន្ទា អម្ហាកំ ទេយ្យធម្មំ អន្តរាយំ ករិស្សតិ ឧក-យេនម្ហា[1] បរិពាហិរា ភោគេហិ ច បុញ្ញេន ចាតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា គណស្ស ចីវរលាភំ អន្តរាយំ ករិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី គណស្ស ចីវរលាភំ អន្តរាយំ ករោតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី គណស្ស ចីវរលាភំ អន្តរាយំ ករិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី គណស្ស ចីវរលាភំ អន្តរាយំ ករេយ្យ បាចិត្តិយន្តិ ។

១ ម. ឆ. ហាយេម្ហា ។



បន្ទុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងធ្វើទេយ្យធម៌របស់យើងទាំងឡាយឲ្យអន្តរាយសោះ យើងទាំងឡាយនៅសាងប្រាសចាកប្រយោជន៍ទាំងពីរយ៉ាង គឺភោគៈផង បុណ្យផង ។ ភិក្ខុនីទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយទៅ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយទៅ ត្រូវអាបត្តិបាចិត្តិយ ។

(៦៦០) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ គណោ នាម ភិក្ខុនីសង្ឃោ វុច្ចតិ ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ ។ អន្តរាយំ ករេយ្យាតិ កថំ ឥមំ ចីវរំ ន ទទេយ្យុន្តិ អន្តរាយំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញំ បរិក្ខារំ អន្តរាយំ ករោតិ អាបត្តិ ទុក្កដស្ស ។ សម្ពហុលានំ ភិក្ខុនីនំ វា ឯកភិក្ខុនិយា វា អនុបសម្បន្នាយ វា ចីវរំ វា អញ្ញំ វា បរិក្ខារំ អន្តរាយំ ករោតិ អាបត្តិ ទុក្កដស្ស ។

(៦៦១) អនាបត្តិ អានិសំសំ ទស្សេត្វា និវារេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



(៦៦០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា គណៈ គឺថាភិក្ខុនីសង្ឃ ។ បណ្តាចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមវិកប្បបាន ហៅថាចីវរ ។ ពាក្យថា ធ្វើឲ្យអន្តរាយ សេចក្តីថា ភិក្ខុនីនិយាយថា ជនទាំងឡាយត្រូវឲ្យចីវរនេះធ្វើអ្វី ហើយធ្វើឲ្យអន្តរាយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីធ្វើបរិក្ខារដទៃឲ្យអន្តរាយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីធ្វើចីវរក្តី បរិក្ខារដទៃក្តី របស់ភិក្ខុនីច្រើនរូប (ពីររូបបីរូប) ក្តី របស់ភិក្ខុនីមួយរូបក្តី របស់អនុបសម្បន្នក្តី ឲ្យអន្តរាយ ត្រូវអាបត្តិទុក្កដ ។

(៦៦១) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីសំដែងអានិសង្សហើយហាមឃាត់[1] ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

១ ភិក្ខុនីពោលយ៉ាងនេះថា អ្នកទាំងឡាយប្រាថ្នានឹងទំនុកបំរុង ព្រោះឥឡូវនេះសំពត់ថ្លៃណាស់ ប្រហែលជា ២-៣ថ្ងៃទៀតគេប្រាកដនឹងយកមកថ្វាយហើយ ថ្ងៃណោះគាប់ល្មមសមគួរ ដូច្នេះហើយបានហាមឃាត់ ។ (អដ្ឋកថាវិន័យ) ។

## និស្សគ្គិយស្ស សត្តមសិក្ខាបទំ

(៦៦៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនីសង្ឃស្ស អកាលចីវរំ ឧប្បន្នំ ហោតិ ។ អថខោ ភិក្ខុនីសង្ឃោ តំ ចីវរំ ភាជេតុកាមោ សន្និបតិ ។ តេន ខោ បន សមយេន ថុល្លនន្ទាយ ភិក្ខុនិយា អន្តេវាសិនិយោ ភិក្ខុនិយោ[១] បក្កន្តា ហោន្តិ ។ ថុល្លនន្ទា ភិក្ខុនី តា ភិក្ខុនិយោ ឯតទវោច អយ្យេ ភិក្ខុនិយោ បក្កន្តា ន តាវ ចីវរំ ភាជិយិស្សតីតិ ចីវរវិភង្គំ បដិពាហិ[២] ។ ភិក្ខុនិយោ ន តាវ ចីវរំ ភាជិយិស្សតីតិ បក្កមឹសុ ។ ថុល្លនន្ទា ភិក្ខុនី អន្តេវាសិនីសុ ភិក្ខុនីសុ[៣] អាគតាសុ តំ ចីវរំ ភាជាបេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ធម្មិកំ ចីវរវិភង្គំ បដិពាហិស្សតីតិ ។ បេ ។

---

១ ម. អន្តេវាសិភិក្ខុនិយោ ។ ២ ឱ. ម. បដិពាហេសិ ។ ៣ ម. អន្តេវាសិភិក្ខុនីសុ ។ ឱ. អន្តេវាសិនីសុ ភិក្ខុនីសុ ។

## និស្សគ្គិយ សិក្ខាបទទី ៧

(៦៦៦) សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង អកាលចីវរបានកើតឡើងដល់ភិក្ខុនីសង្ឃ ។ លំដាប់នោះ ភិក្ខុនីសង្ឃប្រាថ្នាដើម្បីនឹងចែកចីវរនោះ ទើបប្រជុំគ្នា ។ វេលានោះឯង ពួកភិក្ខុនីជាអន្តេវាសិនី (កូនសិស្ស) របស់ថុល្លនន្ទាភិក្ខុនីចៀសចេញទៅ (ភ័ក្ត) ថុល្លនន្ទាភិក្ខុនីក៏បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងនោះថា ម្នាលលោកម្ចាស់ទាំងឡាយ ពួកភិក្ខុនីចៀសចេញទៅអស់ហើយ (សង្ឃ) កុំអាលចែកចីវរចុះ ហើយក៏ហាមឃាត់ការចែកចីវរ ។ ភិក្ខុនីទាំងឡាយនាំគ្នាចៀសចេញអស់ទៅដោយគិតថា សង្ឃមិនទាន់ចែកចីវរ ។ ថុល្លនន្ទាភិក្ខុនីកាលពួកភិក្ខុនីជាអន្តេវាសិនីមកព្រមគ្នាហើយ ក៏ឲ្យគេចែកចីវរនោះទៅ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌សោះ ។ បេ ។ ព្រះដ៏មានព្រះភាគ

សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ធម្មិកំ ចីវរវិភង្គំ បដិពាហតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ធម្មិកំ ចីវរវិភង្គំ បដិពាហិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ធម្មិកំ ចីវរវិភង្គំ បដិពាហេយ្យ បាចិត្តិយន្តិ ។

(៤៤៣) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ធម្មិកោ នាម ចីវរវិភង្គោ សមគ្គោ ភិក្ខុនីសង្ឃោ សន្និបតិតោ ភាជេតិ ។ បដិពាហេយ្យាតិ កថំ ឥមំ ចីវរំ ភាជេយ្យាតិ បដិពាហតិ អាបត្តិ បាចិត្តិយស្ស ។

(៤៤៤) ធម្មិកេ ធម្មិកសញ្ញា បដិពាហតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មិកេ វេមតិកា បដិពាហតិ អាបត្តិ



ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌ទេ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌ ត្រូវអាបត្តិបាចិត្តិយ ។

(៤៤៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ការចែកចីវរដែលឈ្មោះថាប្រកបដោយធម៌នោះ បានដល់ភិក្ខុនីសង្ឃមានសេចក្តីព្រមព្រៀងប្រជុំគ្នាចែក ។ ពាក្យថា ហាមឃាត់ សេចក្តីថា ភិក្ខុនីហាមឃាត់ដោយពាក្យថា ភិក្ខុនីចែកចីវរនេះធ្វើអ្វីដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ។

(៤៤៤) ការចែកចីវរប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាប្រកបដោយធម៌ ហើយហាមឃាត់ ត្រូវអាបត្តិបាចិត្តិយ ។ ការចែកចីវរប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយហាមឃាត់ ត្រូវអាបត្តិ

ទុក្កដស្ស ។ ធម្មេ អធម្មសញ្ញា បដិពាហតិ អនាបត្តិ ។ អធម្មេ ធម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មេ អធម្មសញ្ញា អនាបត្តិ ។

(៤៤៥) អនាបត្តិ អានិសំសំ ទស្សេត្វា បដិពាហតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## តុវដ្ដវគ្គស្ស អដ្ឋមសិក្ខាបទំ

(៤៤៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី នដានំបិ នដកានំបិ លង្ឃកានំបិ សោកជ្ឈាយិកានំបិ កុម្ភថូណិកានំបិ សមណចីវរំ ទេតិ មយ្ហំ បរិសតិ វណ្ណំ ភាសថាតិ ។



ទុក្កដ ។ កាលបើកម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាមិនប្រកបដោយធម៌វិញ ហើយហាមឃាត់ មិនត្រូវអាបត្តិ ។ កាលបើកម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កាលបើកម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលបើកម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាមិនប្រកបដោយធម៌ មិនត្រូវអាបត្តិ ។

(៤៤៥) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីសំដែងអានិសង្សហើយឃាត់[១] ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

## តុវដ្ដវគ្គ សិក្ខាបទទី ៨

(៤៤៦) សម័យនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅក្នុងវត្តជេត-ពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ថុល្ល-នន្ទាភិក្ខុនីបានឲ្យសមណចីវរដល់ពួករបាំខ្លះ ដល់ពួកគួនរាំខ្លះ ពួកអ្នកឡើងទំខ្លះ ដល់ពួកអ្នកគក្គរខ្លះ ដល់ពួកអ្នកវាយស្គរខ្លះ ដោយពាក្យថា អ្នកទាំងឡាយចូរពោលសរសើរយើង ក្នុងទីប្រជុំបរិស័ទរបស់យើង ។

---

១ ភិក្ខុនីនិយាយពន្យល់ថា សំពត់សាដកនេះមួយនឹងខែឆ្នាំមិនគ្រាន់ សូមអស់លោកបន្តែមចាំបន្តិចសិន ប្រហែលជា ២-៣ ថ្ងៃទៀត សំពត់នឹងកើតឡើងថ្មីសំរាប់យើងខែឆ្នាំគ្នាជាច្រើនទៀត ហើយនឹងលំអៀងមិនសង្ស័យ ។ (អដ្ឋកថាវិន័យ) ។

នដានំ នច្ចកានំ លង្ឃកានំ សោកជ្ឈាយិកានំ កុម្ភថូណិកានំ ថុល្លនន្ទាយ ភិក្ខុនិយា បរិសតិ វណ្ណំ ភាសន្តិ អយ្យា ថុល្លនន្ទា ពហុស្សុតា ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ[១] កាតុំ ទេថ អយ្យាយ ករោថ អយ្យាយាតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អាគារិកស្ស សមណចីវរំ ទស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាគារិកស្ស សមណចីវរំ ទេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាគារិកស្ស សមណចីវរំ ទស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អាគារិកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សមណចីវរំ ទទេយ្យ បាចិត្តិយន្តិ ។

១ ឱក្កាបទ្ធិមិ ញាណោ ។



ពួកមេញាក្តី ពួកអ្នករបាំក្តី ពួកអ្នកលោតទីក្តី ពួកអ្នកស្មូតក្តី ពួកអ្នកវាយស្គរក្តី នាំគ្នាពោលសរសើរថុល្លនន្ទាភិក្ខុនីក្នុងទីប្រជុំបរិសទ្យថា ថុល្លនន្ទាជាម្ចាស់ជាពហុស្សុត ជាអ្នកនិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា អ្នកទាំងឡាយចូរថ្វាយ (ទាន) ដល់លោកម្ចាស់ចុះ អ្នកទាំងឡាយចូរធ្វើ (សក្ការៈ) ដល់លោកម្ចាស់ចុះ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងឲ្យសមណចីវរដល់គ្រហស្ថសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យសមណចីវរដល់គ្រហស្ថ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងឲ្យសមណចីវរដល់គ្រហស្ថទេ ម្នាលភិក្ខុទាំងឡាយ អំពើនុះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យសមណចីវរដល់គ្រហស្ថក្តី ដល់បរិព្វាជកក្តី ដល់បរិព្វាជិកាក្តី ត្រូវអាបត្តិបាចិត្តិយ ។

(៤៤៧) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អាគារិកោ នាម យោ កោចិ អគារំ អជ្ឈាវសតិ ។ បរិព្វាជកោ នាម ភិក្ខុញ្ច សាមណេរញ្ច ឋបេត្វា យោ កោចិ បរិព្វាជកសមាបន្នោ ។ បរិព្វាជិកា នាម ភិក្ខុនិញ្ច សិក្ខមានញ្ច សាមណេរិញ្ច ឋបេត្វា យា កាចិ បរិព្វាជិកសមាបន្នា ។ សមណចីវរំ នាម កប្បកតំ វុច្ចតិ ។ ទេតិ អាបត្តិ បាចិត្តិយស្ស ។

(៤៤៨) អនាបត្តិ មាតាបិតូនំ ទេតិ តាវកាលិកំ ទេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## នគ្គវគ្គស្ស នវមសិក្ខាបទំ

(៤៤៩) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទាយ ភិក្ខុនិយា ឧបដ្ឋា-



(៤៤៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយ ក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ជនណាមួយនៅគ្រប់គ្រងផ្ទះ ជននោះឈ្មោះថា គ្រហស្ថ ។ បុរសណាមួយបួសជាបរិព្វាជក វៀរលែងតែភិក្ខុនិងសាមណេរចេញ បុរសនោះឈ្មោះថា បរិព្វាជក ។ ស្រីណាមួយបួសជាបរិព្វាជិកា វៀរលែងតែភិក្ខុនី សិក្ខមានា និងសាមណេរីចេញ ស្រីនោះឈ្មោះថា បរិព្វាជិកា ។ ចីវរដែលធ្វើកប្បរួចហើយ ហៅថា សមណចីវរ ។ ភិក្ខុនីឲ្យ (សមណចីវរ) ត្រូវអាបត្តិបាចិត្តិយ ។

(៤៤៨) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីឲ្យដល់មាតាបិតា ១ ភិក្ខុនីឲ្យគេខ្ចី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## នគ្គវគ្គ សិក្ខាបទទី ៩

(៤៤៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី បាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា

កាកុលំ ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោច សចេ មយំ អយ្យេ សក្កោម ភិក្ខុនីសង្ឃស្ស ចីវរំ ទស្សាមាតិ ។ តេន ខោ បន សមយេន វស្សំវុត្ថា ភិក្ខុនិយោ ចីវរភាជនាយ សន្និបតឹសុ ។ ថុល្លនន្ទា ភិក្ខុនី តា ភិក្ខុនិយោ ឯតទវោច អាគមេថ អយ្យេ អត្ថិ ភិក្ខុនី-សង្ឃស្ស ចីវរប្បច្ចាសាតិ ។ ភិក្ខុនិយោ ថុល្លនន្ទំ ភិក្ខុនឹ ឯតទវោចុំ គច្ឆយ្យេ តំ ចីវរំ ជានាហីតិ ។ ថុល្លនន្ទា ភិក្ខុនី យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា តេ មនុស្សេ ឯតទវោច ទេថាវុសោ ភិក្ខុនីសង្ឃស្ស ចីវរន្តិ ។ ន មយំ អយ្យេ សក្កោម ភិក្ខុនីសង្ឃស្ស ចីវរំ ទាតុន្តិ ។ ថុល្លនន្ទា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ទុព្វលចីវរប្បច្ចាសាយ ចីវរកាលសមយំ អតិក្កាមេស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ទុព្វលចីវរប្បច្ចាសាយ ចីវរកាលសមយំ អតិក្កា-



បពិត្រលោកម្ចាស់ បើយើងខ្ញុំទាំងឡាយអាច យើងខ្ញុំទាំងឡាយនឹងថ្វាយចីវរដល់ភិក្ខុនីសង្ឃ ។ សម័យនោះឯង ភិក្ខុនីទាំងឡាយនៅចាំវស្សារួចហើយប្រជុំដើម្បីនឹងចែកចីវរ ទើបប្រជុំគ្នា ។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងភិក្ខុនីទាំងនោះថា នែលោកម្ចាស់ទាំងឡាយ ពួកលោកម្ចាស់ចូរបង្អង់ចាំសិន (ផ្ចិត) មានគេនឹងថ្វាយចីវរដល់ភិក្ខុនីសង្ឃ ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា នែលោកម្ចាស់ លោកចូរទៅ លោកចូរដឹងចីវរនោះចុះ ។ ថុល្លនន្ទាភិក្ខុនីចូលទៅកាន់ត្រកូលនោះ លុះចូលទៅដល់ហើយក៏បាននិយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរឲ្យចីវរដល់ភិក្ខុនីសង្ឃចុះ ។ មនុស្សទាំងនោះនិយាយថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយមិនអាចនឹងប្រគេនចីវរដល់ភិក្ខុនីសង្ឃទេ ។ ថុល្លនន្ទាភិក្ខុនីប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបើនឹងញ៉ាំងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរដ៏ទុព្វលនោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ

មេតីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ទុព្វលចីវរប្បច្ចាសាយ ចីវរកាលសមយំ អតិក្កាមេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី ទុព្វលចីវរប្បច្ចាសាយ ចីវរកាលសមយំ អតិក្កាមេយ្យ បាចិត្តិយន្តិ ។

(៦៨០) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ទុព្វលចីវរប្បច្ចាសា នាម សចេ មយំ សក្កោម ទស្សាម ករិស្សាមាតិ វាចា ភិន្នា ហោតិ ។ ចីវរកាលសមយោ នាម អនត្ថតេ កឋិនេ វស្សានស្ស បច្ឆិមោ មាសោ អត្ថតេ កឋិនេ បញ្ច មាសា ។ ចីវរកាលសមយំ អតិក្កាមេយ្យាតិ

១ ម. អតិក្កាមេសីតិ ។



ចាំនឹងឲ្យ ឮថា ថុល្លនន្ទាភិក្ខុនីញ៉ាំងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរខ្សោយ ពិតមែនឬ ។ ភិក្ខុនីទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងញ៉ាំងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរដ៏ខ្សោយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនទាន់ជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ញ៉ាំងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរដ៏ខ្សោយ ត្រូវអាបត្តិបាចិត្តិយ ។

(៦៨០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា សេចក្តីប្រាថ្នាចីវរដ៏ខ្សោយ គឺត្រកូលគេបញ្ចេញវាចាថា បើយើងខ្ញុំទាំងឡាយអាច យើងខ្ញុំទាំងឡាយនឹងប្រគេន នឹងធ្វើ(ថ្វាយ) ។ ដែលហៅថា សម័យនៃចីវរកាល គឺភិក្ខុនីមិនទាន់បានក្រាលកឋិន កំណត់តែមួយខែជាខាងចុងនៃវស្សានរដូវ (តាំងពីថ្ងៃ ១ រោចខែអស្សុជរៀងដល់ ១៥ កើតខែកត្តិក) បើភិក្ខុនីបានក្រាលកឋិន កំណត់ ៥ ខែ (តាំងពីថ្ងៃ ១ រោចខែអស្សុជទៅដល់ ១៥ កើតខែផល្គុន) ។ ពាក្យថា ញ៉ាំងសម័យនៃចីវរកាលឲ្យកន្លងហួសទៅ

អនត្ថតេ កឋិនេ វស្សានស្ស បច្ឆិមំ ទិវសំ អតិក្កា-មេតិ អាបត្តិ បាចិត្តិយស្ស ។ អត្ថតេ កឋិនេ កឋិនុទ្ធារទិវសំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

(៦៩៣) ទុព្វលចីវរេ ទុព្វលចីវរសញ្ញា ចីវរកាល-សមយំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។ ទុព្វល-ចីវរេ វេមតិកា ចីវរកាលសមយំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ។ ទុព្វលចីវរេ អទុព្វលចីវរសញ្ញា ចីវរកា-លសមយំ អតិក្កាមេតិ អនាបត្តិ ។ អទុព្វលចីវរេ ទុព្វលចីវរសញ្ញា អាបត្តិ ទុក្កដស្ស ។ អទុព្វលចីវរេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អទុព្វលចីវរេ អទុព្វល-ចីវរសញ្ញា អនាបត្តិ ។

(៦៩៤) អនាបត្តិ អាទីនវំ ទស្សេត្វា និវារេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



នោះ សេចក្តីថា ភិក្ខុនីមិនបានក្រាលកឋិន ហើយញុំាងថ្ងៃ១ ជាទីបំផុតនៃវស្សានរដូវឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីបានក្រាលកឋិន ហើយញុំាងថ្ងៃដែលកឋិនដោះឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ ។

(៦៩៣) ចីវរដ៏ទុព្វល ភិក្ខុនីសំគាល់ថាចីវរដ៏ទុព្វលមែន ហើយធ្វើសម័យនៃចីវរកាលឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដ៏ទុព្វល ភិក្ខុនីមានសេចក្តីសង្ស័យ ហើយធ្វើសម័យនៃចីវរកាលឲ្យកន្លងហួសទៅ ត្រូវអាបត្តិទុក្កដ ។ ចីវរដ៏ទុព្វល ភិក្ខុនីសំគាល់ថាចីវរមិនទុព្វលទេ ហើយធ្វើសម័យនៃចីវរកាលឲ្យកន្លងហួសទៅ មិនត្រូវអាបត្តិទេ ។ ចីវរមិនទុព្វលទេ ភិក្ខុនីសំគាល់ថាចីវរទុព្វល ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទុព្វលទេ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរមិនទុព្វល ភិក្ខុនីសំគាល់ថាចីវរមិនទុព្វល មិនត្រូវអាបត្តិទេ ។

(៦៩៤) អនាបត្តិ (គឺមិនត្រូវអាបត្តិ) ដល់ភិក្ខុនីសំដែងអាទីនវ[១] ហើយហាមឃាត់ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

១ ភិក្ខុនីនិយាយថា កប្បាសរបស់គេខូចខាតនិងខាតដល់ បុគ្គលមានសទ្ធាជ្រះថ្លានាំមកប្រគេនមិនបាន ហៅថាសំដែងនូវអាទីនវក្នុងសំពត់ទាំងនេះ ។ (អដ្ឋកថាវិន័យ) ។

## នគ្គវគ្គស្ស ទសមសិក្ខាបទំ

[៤៩៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរេន ឧបាសកេន សង្ឃំ ឧទ្ទិស្ស វិហារោ ការាបិតោ ហោតិ ។ សោ តស្ស វិហារស្ស មហេ ឧភតោសង្ឃស្ស អកាលចីវរំ ទាតុកាមោ ហោតិ ។ តេន ខោ បន សមយេន ឧភតោសង្ឃស្ស កឋិនំ អត្ថតំ ហោតិ ។ អថខោ សោ ឧបាសកោ សង្ឃំ ឧបសង្កមិត្វា កឋិនុទ្ធារំ យាចិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ កឋិនំ ឧទ្ធរិតុំ ។ ឯវញ្ច បន ភិក្ខវេ កឋិនំ ឧទ្ធរិតព្វំ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ " កឋិនំ ឧទ្ធរេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ

## នគ្គវគ្គ សិក្ខាបទទី ១០

[៤៩៣] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងកាលនោះឯង មានឧបាសកម្នាក់ឲ្យគេធ្វើវិហារ (កុដិ) ឧទ្ទិសចំពោះសង្ឃ ។ ក្នុងកាលដែលឆ្លងវិហារនោះ ឧបាសកនោះប្រាថ្នានឹងថ្វាយអកាលចីវរដល់ឧភតោសង្ឃ ។ ក៏ក្នុងកាលនោះឯង ឧភតោសង្ឃបានក្រាលកឋិនហើយ ។ ទើបឧបាសកនោះចូលទៅរកសង្ឃហើយសូមឲ្យសង្ឃដកកឋិនចេញ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃដកកឋិនចេញបាន ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវដកកឋិនយ៉ាងនេះ ។ ភិក្ខុឈ្លាសប្រតិពលគប្បីញ៉ាំងសង្ឃឲ្យដឹងដោយញត្តិទុតិយកម្មវាចាថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើការដកកឋិននេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវដកកឋិន ។ នេះជាកិច្ចដែលប្រកាសឲ្យសង្ឃដឹង ។ បពិត្រ

សង្ឃោ កឋិនំ ឧទ្ធរតិ ។ យស្សាយស្មតោ ខមតិ កឋិនស្ស ឧទ្ធារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧព្ភតំ សង្ឃេន កឋិនំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[២៨២] អថខោ សោ ឧបាសកោ ភិក្ខុនីសង្ឃំ ឧបសង្កមិត្វា កឋិនុទ្ធារំ យាចិ ។ ថុល្លនន្ទា ភិក្ខុនី ចីវរំ អម្ហាកំ ភវិស្សតីតិ កឋិនុទ្ធារំ បដិពាហិ ។ អថខោ សោ ឧបាសកោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនិយោ អម្ហាកំ កឋិនុទ្ធារំ ន ទស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តស្ស ឧបាសកស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ធម្មិកំ កឋិនុទ្ធារំ បដិពាហិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ



ព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ឥឡូវនេះសង្ឃដកកឋិនចេញ ។ ការដកកឋិនគួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះពោលឡើង ។ កឋិនសង្ឃបានដកហើយ ។ ការដកកឋិនសមគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវកម្មនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

[២៨២] លំដាប់នោះ ឧបាសកនោះបានចូលទៅរកភិក្ខុនីសង្ឃ ហើយសូមឲ្យសង្ឃដកកឋិនចេញ ។ ថុល្លនន្ទាភិក្ខុនីបានហាមឃាត់នូវការដកកឋិនដោយគិតថា ចីវរនឹងមានដល់ពួកយើងទាំងឡាយ ។ ទើបឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងមិនឲ្យការដកកឋិនដល់ពួកយើងសោះ ។ ភិក្ខុនីទាំងឡាយបានឮឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងហាមឃាត់នូវការដកកឋិនប្រកបដោយធម៌សោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា

ថុល្លនន្ទា ភិក្ខុនី ធម្មិកំ កឋិនុទ្ធារំ បដិពាហតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ធម្មិកំ កឋិនុទ្ធារំ បដិពាហិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី ធម្មិកំ កឋិនុទ្ធារំ បដិពាហេយ្យ បាចិត្តិយន្តិ ។

(២៥៥) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ ឥយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ធម្មិកោ នាម កឋិនុទ្ធារោ សមគ្គោ ភិក្ខុនីសង្ឃោ សន្និបតិត្វា ឧព្ភារតិ ។ បដិពាហេយ្យាតិ កថំ ឥទំ កឋិនំ ឧព្ភរេយ្យាតិ បដិពាហតិ អាបត្តិ បាចិត្តិយស្ស ។



ម្នាលភិក្ខុទាំងឡាយ ព្រោះថាថុល្លនន្ទាភិក្ខុនី ហាមឃាត់នូវការដកកឋិនដ៏ប្រកបដោយធម៌ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងហាមឃាត់នូវការដកកឋិនដ៏ប្រកបដោយធម៌ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយហាមឃាត់នូវការដកកឋិនប្រកបដោយធម៌ ត្រូវអាបត្តិបាចិត្តិយ ។

(២៥៥) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបាចិត្តិយកណ្ឌរួចហើយ ។ ដែលហៅថា ការដកកឋិនប្រកបដោយធម៌នោះ បានដល់ភិក្ខុនីសង្ឃមានសេចក្ដីព្រមព្រៀងប្រជុំគ្នាដក ។ ពាក្យថា ហាមឃាត់ សេចក្ដីថា ភិក្ខុនីហាមឃាត់ថា ភិក្ខុនីសង្ឃដកកឋិននេះដូចម្ដេច ត្រូវអាបត្តិបាចិត្តិយ ។

[៤៨៦] ធម្មកម្មេ ធម្មកម្មសញ្ញា បដិពាហតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា បដិពាហតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា បដិពាហតិ អនាបត្តិ ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អនាបត្តិ ។

(៤៨៧) អនាបត្តិ អាទីនវំ ទស្សេត្វា បដិពាហតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

សិក្ខាបទំ តតិយំ ។





[៤៨៦] កាលដែលកម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាប្រកបដោយធម៌មែន ហើយហាមឃាត់ ត្រូវអាបត្តិបាចិត្តិយ ។ កាលដែលកម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយហាមឃាត់ ត្រូវអាបត្តិទុក្កដ ។ កាលដែលកម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាមិនប្រកបដោយធម៌ ហើយហាមឃាត់ មិនត្រូវអាបត្តិទេ ។ កាលដែលកម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កាលដែលកម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលដែលកម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាមិនប្រកបដោយធម៌មែន មិនត្រូវអាបត្តិទេ ។

(៤៨៧) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីសំដែងអាទីនវ(១) ហើយហាមឃាត់ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់ ។

---

១ ភិក្ខុនីសំដែងអាទីនវថា ភិក្ខុនីសង្ឃមានទំនាស់ប្រកែកគ្នាហើយ នឹងហាណកមានអាទីនវ កើតដោយទោស ។ (អដ្ឋកថាវិន័យ) ។

## តុវដ្ដវគ្គស្ស បឋមសិក្ខាបទំ

(៦៨៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ទ្វេ ឯកមញ្ចេ តុវដ្ដេន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ទ្វេ ឯកមញ្ចេ តុវដ្ដេស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ[១] ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ទ្វេ ឯក-មញ្ចេ តុវដ្ដេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិ-យោ ទ្វេ ឯកមញ្ចេ តុវដ្ដេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ទ្វេ ឯកមញ្ចេ តុវដ្ដេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ

១ ម. គិហិកាមភោគិនិយោតិ ។

## តុវដ្ដវគ្គ សិក្ខាបទទី ១

(៦៨៨) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីពីររូប ដេកលើគ្រែមួយ (ជាមួយគ្នា) ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកក្នុង វត្ត ឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីពីររូបមិន សមបើនឹងដេកលើគ្រែមួយ (ជាមួយគ្នា) ដូចពួកស្រីគ្រហស្ថអ្នកបរិភោគ កាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះ-ដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីពីររូបមិនសមបើនឹងដេកលើគ្រែមួយ (ជាមួយគ្នា) សោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីពីររូបដេកលើ គ្រែមួយ(ជាមួយគ្នា) ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ មេត្តាប្រោស ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាល ភិក្ខុទាំងឡាយ ភិក្ខុនីពីររូបមិនសមបើនឹងដេកលើគ្រែមួយ (ជាមួយគ្នា) ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិន

ភិ បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនិយោ ទ្វេ ឯកមញ្ចេ តុវដ្ដេយ្យុំ បាចិត្តិយន្តិ ។

(៦៥៩) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនិយោតិ ឧបសម្បន្នាយោ វុច្ចន្តិ ។ ទ្វេ ឯកមញ្ចេ តុវដ្ដេយ្យុន្តិ ឯកាយ និបន្នាយ អបរា និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ឧភោ វា និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។ ឧដ្ឋហិត្វា បុនប្បុនំ និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។

(៦៦០) អនាបត្តិ ឯកាយ និបន្នាយ អបរា និសីទតិ ឧភោ វា និសីទន្តិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## តុវដ្ដវគ្គស្ស ទុតិយសិក្ខាបទំ

(៦៦១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ទ្វេ ឯកត្ថរណបាវុរណា(*) តុវដ្ដេន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា

---

១ ម. ឯកត្ថរណបាវុរណា ។



ពាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីទាំងឡាយណា ពីររូបដេកលើគ្រែមួយ (ជាមួយគ្នា) ត្រូវអាបត្តិបាចិត្តិយ ។

(៦៥៩) ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយណា មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ភិក្ខុនីពីររូបដេកលើគ្រែមួយ (ជាមួយគ្នា) សេចក្តីថា កាលភិក្ខុនីម្នាក់ដេកនៅហើយ មានភិក្ខុនីដទៃទៅដេកដែរ ត្រូវអាបត្តិបាចិត្តិយ ។ មួយទៀតភិក្ខុនីពីររូបដេកព្រមគ្នា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីទាំងពីររូបក្រោកឡើងហើយដេកទៅវិញញយៗ ត្រូវអាបត្តិបាចិត្តិយ ។

(៦៦០) ការមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីម្នាក់ដេក ភិក្ខុនីដទៃអង្គុយ ឬភិក្ខុនីទាំងពីររូបអង្គុយ ១ ភិក្ខុនីទាំងពីររូបនោះឆ្កួត ១ ភិក្ខុនីទាំងពីររូបនោះជាដើមបញ្ញត្តិ ១ ។

---

## តុវដ្ដវគ្គ សិក្ខាបទទី ២

(៦៦១) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីពីររូបមានសំពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ដេកជាមួយគ្នា ។ មនុស្ស

បស្សន្តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ទ្វេ ឯកត្ថរណបាវុរណា តុវដ្ដេស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តាសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ទ្វេ ឯកត្ថរណបាវុរណា តុវដ្ដេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ទ្វេ ឯកត្ថរណបាវុរណា តុវដ្ដេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ទ្វេ ឯកត្ថរណបាវុរណា តុវដ្ដេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនិយោ ទ្វេ ឯកត្ថរណបាវុរណា តុវដ្ដេយ្យុំ បាចិត្តិយន្តិ ។



ទាំងឡាយ ដើរទៅកាន់ចារិកនៃវត្ត ឃើញហើយពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនីពីររូបមិនសមបើនឹងមានសំពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ដេកជាមួយគ្នាដូចយ៉ាងពួកស្រីគ្រហស្ថអ្នកបរិភោគកាមនោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនីពីររូបមិនសមបើនឹងមានសំពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ដេកជាមួយគ្នានោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីពីររូបមានសំពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ដេកជាមួយគ្នា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីពីររូបមិនសមបើនឹងមានសំពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ដេកជាមួយគ្នាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីទាំងឡាយឯណា ពីររូបមានសំពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។

(៦៦២) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនិយោតិ ឧបសម្បន្នាយោ វុច្ចន្តិ ។ ទ្វេ ឯកត្ថរណបាវុរណា តុវដ្ដេយ្យុន្តិ ឯកស្មឹ អត្ថរិត្វា ឯកស្មឹ បារុបន្តិ អាបត្តិ បាចិត្តិយស្ស ។

(៦៦៣) ឯកត្ថរណបាវុរណេ ឯកត្ថរណបាវុរណសញ្ញា តុវដ្ដន្តិ អាបត្តិ បាចិត្តិយស្ស ។ ឯកត្ថរណបាវុរណេ វេមតិកា តុវដ្ដន្តិ អាបត្តិ បាចិត្តិយស្ស ។ ឯកត្ថរណបាវុរណេ នានត្ថរណបាវុរណសញ្ញា តុវដ្ដន្តិ អាបត្តិ បាចិត្តិយស្ស ។ ឯកត្ថរណេ នានាបាវុរណេ[១] អាបត្តិ ទុក្កដស្ស ។ នានត្ថរណេ ឯកបាវុរណេ[២] អាបត្តិ ទុក្កដស្ស ។ នានត្ថរណបាវុរណេ ឯកត្ថរណបាវុរណសញ្ញា អាបត្តិ ទុក្កដស្ស ។ នានត្ថ-

---

១ ឱ. ម. នានាបាវុរណសញ្ញា ។ ២ ម. ឯកបាវុរណសញ្ញា ។ ឱ. ឯកត្ថរណបាវុរណសញ្ញា ។



(៦៦២) ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយណា មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ពីររូប មានសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ដេកជាមួយគ្នានោះ សេចក្តីថា ភិក្ខុនីពីររូបក្រាលនូវសម្ពត់នោះឯង ហើយដណ្តប់នូវសម្ពត់នោះផងដែល ត្រូវអាបត្តិបាចិត្តិយ ។

(៦៦៣) សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ភិក្ខុនីពីររូបសំគាល់ថាសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយផងដែល ហើយដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់តែមួយ ភិក្ខុនីសំគាល់ថាសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់ផ្សេងគ្នា ហើយដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីដេកលើក្រាលជាមួយគ្នា តែដណ្តប់សំពត់ផ្សេងគ្នា ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីដេកលើក្រាលផ្សេងគ្នា តែដណ្តប់ជាមួយគ្នា ត្រូវអាបត្តិទុក្កដ ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់ផ្សេងៗគ្នា ភិក្ខុនីសំគាល់ថាសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់ជាមួយគ្នា ត្រូវអាបត្តិទុក្កដ ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្តប់

រណោ ទាបុរណោ វេមតិកា អាបត្តិ ទុក្កដស្ស ។ ជានន្តុ- ណោ ទាបុរណោ ជានន្តុរណោ ទាបុរណោ សញ្ញា អនាបត្តិ ។

(៦៥៦) អនាបត្តិ វិត្ថាត់(១) ឧស្សេត្វា ទិបន្តិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## តុវដ្ដវគ្គស្ស តតិយសិក្ខាបទំ

(៦៥៧) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី ពហុស្សុតា ហោតិ ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ។ ភទ្ទាបិ កាបិលានី ពហុស្សុតា ហោតិ ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ឧឡារសម្ភាវិតា ។ មនុស្សា អយ្យា ភទ្ទា កាបិលានី ពហុស្សុតា ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ(២) កាតុំ ឧឡារសម្ភាវិតាតិ ភទ្ទំ កាបិលានឹ បឋមំ បយិរុបាសិត្វា បច្ឆា ថុល្លនន្ទំ ភិក្ខុនឹ បយិរុបាសន្តិ ។

១ ម. ឧ. វិត្ថាត់ ។ ២ ម. ធម្មឹ ។



ផ្សេងគ្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សម្គាល់សម្រាប់ក្រាលសម្រាប់ដណ្តប់ផ្សេងគ្នា ភិក្ខុនីសំគាល់ថាសម្គាល់សម្រាប់ក្រាលសម្រាប់ដណ្តប់ផ្សេងគ្នាដែល មិនត្រូវអាបត្តិទេឡើយ ។

(៦៥៦) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីសំដែងនូវទីកំណត់ហើយដេក ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

## តុវដ្តវគ្គ សិក្ខាបទទី ៣

(៦៥៧) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ស្តេចគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីជាពហុស្សូត ជាអ្នកឆ្លាតនិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា ។ សូម្បីភទ្ទាកាបិលានីភិក្ខុនីក៏ជាពហុស្សូត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា ជាអ្នកដែលមហាជនសរសើរក្រៃពេកនៃ ។ មនុស្សទាំងឡាយនិយាយថា ភទ្ទាកាបិលានីជាម្ចាស់ ជាពហុស្សូត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា ជាអ្នកដែលមហាជនសរសើរក្រៃពេកដូច្នេះ ហើយចូលទៅគាល់ភទ្ទាកាបិលានីភិក្ខុនីមុន ទើបចូលទៅរកថុល្លនន្ទាភិក្ខុនីជាក្រោយ ។

ថុល្លនន្ទា ភិក្ខុនី ឥស្សាបកតា ឥមា កិរ អប្បិច្ឆា សន្តុដ្ឋា បវិវិត្តា អសំសដ្ឋា យា ឥមា សញ្ញត្តិពហុលា វិញ្ញត្តិពហុលា វិហរន្តីតិ ភទ្ទាយ កាបិលានិយា បុរតោ ចង្កមតិបិ តិដ្ឋតិបិ និសីទតិបិ សេយ្យំបិ កប្បេតិ ឧទ្ទិសតិបិ ឧទ្ទិសាបេតិបិ សជ្ឈាយម្បិ ករោតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អយ្យាយ ភទ្ទាយ កាបិលានិយា សញ្ចិច្ច អផាសុំ ករិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភទ្ទាយ កាបិលានិយា សញ្ចិច្ច អផាសុំ ករោតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភទ្ទាយ កាបិលានិយា សញ្ចិច្ច អផាសុំ ករិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ភិក្ខុនិយា សញ្ចិច្ច អផាសុំ ករេយ្យ បាចិត្តិយន្តិ ។



ថុល្លនន្ទាភិក្ខុនីជាមនុស្សមានសេចក្តីឫស្យាគ្របសង្កត់ក៏ពោលថា ពួកភិក្ខុនីណាស្គាល់ច្រើនសូមច្រើន ធ្លាប់ឮថាភិក្ខុនីទាំងឡាយនេះជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ ពោលដូច្នេះហើយក៏ដើរខ្លះ ឈរខ្លះ អង្គុយខ្លះ សម្រេចការដេកខ្លះ សំដែងឯខ្លះ ឲ្យគេសំដែងខ្លះ ធ្វើការស្វាធ្យាយខ្លះ ក្នុងទីចំពោះមុខភទ្ទាកាបិលានីភិក្ខុនី ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងមកក្លែងធ្វើសេចក្តីមិនសប្បាយដល់ភទ្ទាកាបិលានីជាម្ចាស់នោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីក្លែងធ្វើសេចក្តីមិនសប្បាយដល់ភទ្ទាកាបិលានីភិក្ខុនី ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងក្លែងធ្វើសេចក្តីមិនសប្បាយដល់ភទ្ទាកាបិលានីភិក្ខុនីទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយក្លែងធ្វើសេចក្តីមិនសប្បាយដល់ភិក្ខុនីដទៃគ្នា ត្រូវអាបត្តិបាចិត្តិយ ។

(៦៦៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុនិយាតិ អញ្ញាយ ភិក្ខុនិយា ។ សញ្ចិច្ចាតិ ជានន្តី សញ្ជានន្តី ចេច្ច អភិវិតរិត្វា វីតិក្កមោ ។ អផាសុំ ករេយ្យាតិ ឥមិនា ឥមិស្សា អផាសុំ ភវិស្សតីតិ អនាបុច្ឆា បុរតោ ចង្កមតិ វា តិដ្ឋតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា សជ្ឈាយំ វា ករោតិ អាបត្តិ បាចិត្តិយស្ស ។

(៦៦៧) ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា សញ្ចិច្ច អផាសុំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកា សញ្ចិច្ច អផាសុំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា សញ្ចិច្ច អផាសុំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។



(៦៦៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយ ក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា ដល់ភិក្ខុនី គឺដល់ភិក្ខុនីដទៃ ។ ពាក្យថា ក្លែង សេចក្ដីថា ភិក្ខុនីកាលដឹងកាលស្គាល់ ហើយក្លែងប្រព្រឹត្តល្មើស ប្រព្រឹត្តកន្លង ។ ពាក្យថា ធ្វើសេចក្ដីមិនសប្បាយ សេចក្ដីថា ភិក្ខុនីគិតថា ដោយហេតុនេះ សេចក្ដីមិនសប្បាយចិត្ត នឹងមានដល់ភិក្ខុនីនេះ ដូច្នេះហើយមិនបានប្រាប់ ក៏ដើរខ្លះ ឈរខ្លះ អង្គុយខ្លះ សម្រេចការដេកខ្លះ សំដែងឯងខ្លះ ឲ្យគេសំដែងខ្លះ ធ្វើការស្វាធ្យាយខ្លះ ក្នុងទីខាងមុខ ត្រូវអាបត្តិបាចិត្តិយ ។

(៦៦៧) ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ហើយក្លែងធ្វើឲ្យមានសេចក្ដីមិនសប្បាយចិត្ត ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយក្លែងធ្វើសេចក្ដីឲ្យមិនសប្បាយចិត្ត ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាអនុបសម្បន្នា ហើយក្លែងធ្វើឲ្យមានសេចក្ដីមិនសប្បាយចិត្ត ត្រូវអាបត្តិបាចិត្តិយ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ ។

[៦៦៨] អនាបត្តិ ន អផាសុំ កត្តុកាមា អាបុច្ឆា បុរតោ ចង្កមតិ វា តិដ្ឋតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា សជ្ឈាយំ វា ករោតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## តុវដ្ដវគ្គស្ស ចតុត្ថសិក្ខាបទំ

[៦៦៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី ទុក្ខិតំ សហជីវិនឹ នេវ ឧបដ្ឋេតិ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករោតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ទុក្ខិតំ សហជីវិនឹ នេវ ឧបដ្ឋេស្សតិ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ទុក្ខិតំ សហជីវិនឹ នេវ ឧបដ្ឋេតិ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករោតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា



[៦៦៨] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីមិនប្រាថ្នានឹងធ្វើសេចក្តីមិនសប្បាយចិត្ត ហើយប្រាប់គេដើរចង្ក្រមក្តី ឈរក្តី អង្គុយក្តី សម្រេចការដេកក្តី សំដែងឯងក្តី ឲ្យគេសំដែងក្តី ធ្វើការស្វាធ្យាយក្តី ក្នុងការណ៍មុន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

## តុវដ្ដវគ្គ សិក្ខាបទទី ៤

[៦៦៩] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី មិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខ (មានជម្ងឺ) ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ម្ដេចក៏មិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីមិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្សដែលដល់នូវសេចក្តីទុក្ខ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា

កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ទុក្ខិតំ សហជីវិនឹ នេវ ឧបដ្ឋេស្សតិ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ទុក្ខិតំ សហជីវិនឹ នេវ ឧបដ្ឋេយ្យ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករេយ្យ បាចិត្តិយន្តិ ។

(៤៧០) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ទុក្ខិតា នាម គិលានា វុច្ចតិ ។ សហជីវិនី នាម សទ្ធិវិហារិនី វុច្ចតិ ។ នេវ ឧបដ្ឋេយ្យាតិ ន សយំ ឧបដ្ឋេយ្យ ។ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករេយ្យាតិ ន អញ្ញំ អាណាបេយ្យ ។ នេវ ឧបដ្ឋេស្សាមិ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។ អន្តេវាសិនឹ(១) វា អនុបសម្បន្នំ វា នេវ ឧបដ្ឋេតិ ន ឧបដ្ឋាបនាយ ឧស្សុក្កំ ករោតិ អាបត្តិ ទុក្កដស្ស ។

---

១ ម. អន្តេវាសឹ ។



ម្នាលភិក្ខុទាំងឡាយ ដូចម្តេចក៏ថុល្លនន្ទាភិក្ខុនីមិនសមបីនឹងមិនបម្រើឯង មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាគូសិស្ស ដែលដល់នូវសេចក្តីទុក្ខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំ-ដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាគូសិស្ស ដែលដល់នូវសេចក្តីទុក្ខ ត្រូវអាបត្តិបាចិត្តិយ ។

(៤៧០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃលសុណវគ្គរួចហើយ ។ ដែលហៅថា ដល់នូវសេចក្តីទុក្ខ សំដៅយកភិក្ខុនីដែលមានជម្ងឺ ។ ដែលហៅថា ភិក្ខុនីជាគូសិស្ស សំដៅយកភិក្ខុនីជាសទ្ធិវិហារិនី (មានឧបជ្ឈាយ៍ស្រីនៅជាមួយគ្នា) ។ ពាក្យថា មិនបម្រើឯង គឺមិនបម្រើដោយខ្លួនឯង ។ ពាក្យថា មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើ គឺមិនបង្គាប់អ្នកដទៃ ។ កាលភិក្ខុនីដាក់ធុរៈថា អញនឹងមិនបម្រើឯង នឹងមិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើ នូវអន្តេវាសិនីក្តី អនុបសម្បន្នក្តី ត្រូវអាបត្តិទុក្កដ ។

(៦៧១) អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## តុវដ្ដវគ្គស្ស បញ្ចមសិក្ខាបទំ

(៦៧២) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភទ្ទា កាបិលានី សាកេតេ វស្សំ ឧបគតា ហោតិ ។ សា កេនចិទេវ ករណីយេន ថុល្លនន្ទាយ ភិក្ខុនិយា សន្តិកេ ទូតំ បាហេសិ សចេ មេ អយ្យា ថុល្លនន្ទា ឧបស្សយំ ទទេយ្យ គច្ឆេយ្យាមហំ[១] សាវត្ថិន្តិ ។ ថុល្លនន្ទា ភិក្ខុនី ឯវមាហ អាគច្ឆតុ ទស្សាមីតិ ។ អថខោ ភទ្ទា កាបិលានី សាកេតា សាវត្ថឹ អគមាសិ ។ ថុល្លនន្ទា ភិក្ខុនី ភទ្ទាយ កាបិលានិយា ឧបស្សយំ អទាសិ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី ពហុស្សុតា ហោតិ

១ ម. ឧ. អាគច្ឆេយ្យាមហំ ។



(៦៧១) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺកាលបើមានសេចក្តីអន្តរាយ ហើយភិក្ខុនីស្វែងរកអ្នកឯទៀតជាអ្នកបម្រើ ជម្ងឺមិនបាន ១ ភិក្ខុនីឈឺខ្លួនឯង ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

## តុវដ្ដវគ្គ សិក្ខាបទទី៥

(៦៧២) សម័យនោះឯង ព្រះសម្មាសម្ពុទ្ធមានព្រះភាគ គង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភទ្ទាកាបិលានីភិក្ខុនីនៅចាំវស្សាក្នុងក្រុងសាកេត ។ ភទ្ទាកាបិលានីភិក្ខុនីនោះ បានបញ្ជូនទូតទៅកាន់សំណាក់ថុល្លនន្ទាភិក្ខុនីដោយកិច្ចមួយថា បើថុល្លនន្ទាជាម្ចាស់ឲ្យលំនៅដល់ខ្ញុំ ខ្ញុំនឹងទៅកាន់ក្រុងសាវត្ថី ។ ថុល្លនន្ទាភិក្ខុនីនិយាយតបយ៉ាងនេះថា ភទ្ទាកាបិលានីមកចុះ ខ្ញុំនឹងឲ្យ (នៅ) ។ លំដាប់នោះ ភទ្ទាកាបិលានីភិក្ខុនីបានចេញអំពីក្រុងសាកេតទៅកាន់ក្រុងសាវត្ថី ។ ថុល្លនន្ទាភិក្ខុនីក៏បានឲ្យលំនៅដល់ភទ្ទាកាបិលានីភិក្ខុនី ។ ក៏គ្រានោះឯង ថុល្លនន្ទាភិក្ខុនីជាពហុស្សូតជាអ្នកប៉ុននិយាយ ជាអ្នក

ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ។ ភទ្ទាបិ កាបិលានី ពហុស្សុតា ហោតិ ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ឧឡារសម្ភាវិតា ។ មនុស្សា អយ្យា ភទ្ទា កាបិលានី ពហុស្សុតា ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ឧឡារសម្ភាវិតាតិ ភទ្ទំ កាបិលានឹ បឋមំ បយិរុបាសិត្វា បច្ឆា ថុល្លនន្ទំ ភិក្ខុនឹ បយិរុបាសន្តិ ។ ថុល្លនន្ទា ភិក្ខុនី ឥស្សាបកតា ឥមា កិរ អប្បិច្ឆា សន្តុដ្ឋា បវិវិត្តា អសំសដ្ឋា យា ឥមា សញ្ញត្តិពហុលា វិញ្ញត្តិពហុលា វិហរន្តីតិ កុបិតា អនត្តមនា ភទ្ទំ កាបិលានឹ ឧបស្សយា និក្កឌ្ឍិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អយ្យាយ ភទ្ទាយ កាបិលានិយា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភទ្ទាយ កាបិលានិយា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍតីតិ(១) ។

១ ម. និក្កឌ្ឍីតិ ។



ក្លៀវក្លា ជាអ្នកប្រសប់ក្នុងធម្មកថា ។ សូម្បីភទ្ទាកាបិលានី ក៏ជាពហុស្សូត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ក្នុងធម្មកថាដែរ ហើយមហាជនគេសរសើរជាយ៉ាងច្រើនក្រៃពេក ។ មនុស្សទាំងឡាយនិយាយថា ភទ្ទាកាបិលានីជាម្ចាស់ជាពហុស្សូត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ក្នុងធម្មកថា ជាអ្នកដែលគេសរសើរជាយ៉ាងច្រើន និយាយយ៉ាងនេះហើយ ក៏ចូលទៅរកភទ្ទាកាបិលានីភិក្ខុនីមុន ហើយទៅរកថុល្លនន្ទាភិក្ខុនីជាខាងក្រោយ ។ ថុល្លនន្ទាភិក្ខុនីជាអ្នកមានសេចក្តីឫស្យាគ្របសង្កត់ហើយនិយាយថា ភិក្ខុនីទាំងឡាយណា ជាអ្នកស្គាល់ច្រើនជាអ្នកសួរច្រើន ចុះគួរថាភិក្ខុនីទាំងឡាយនេះជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ (និយាយយ៉ាងនេះហើយ) ក៏មានសេចក្តីខឹងអាក់អន់ចិត្ត ហើយដេញភទ្ទាកាបិលានីចេញចាកលំនៅ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងឲ្យលំនៅដល់ភទ្ទាកាបិលានីជាម្ចាស់ ហើយត្រឡប់ទាំងអាក់អន់ចិត្ត ដេញចេញសោះ ។ បេ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីឲ្យលំនៅដល់ភទ្ទាកាបិលានីភិក្ខុនី ហើយត្រឡប់ទាំងអាក់អន់ចិត្តដេញចេញ ពិតមែនឬ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភទ្ទាយ កាបិលានិយា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ភិក្ខុនិយា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍេយ្យ វា និក្កឌ្ឍាបេយ្យ វា បាចិត្តិយន្តិ ។

[៤៧៣] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុនិយាតិ អញ្ញាយ ភិក្ខុនិយា ។ ឧបស្សយោ នាម កវាដពទ្ធោ វុច្ចតិ ។ ទត្វាតិ សយំ ទត្វា ។ កុបិតា អនត្តមនាតិ អនភិរទ្ធា អាហតចិត្តា ខិលជាតា ។ និក្កឌ្ឍេយ្យាតិ គព្ភេ គហេត្វា បមុខំ និក្កឌ្ឍតិ អាបត្តិ បាចិត្តិយស្ស ។ បមុខេ គហេត្វា ពហិ និក្កឌ្ឍតិ អាបត្តិ បាចិត្តិយស្ស ។



ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងឲ្យលំនៅដល់ភទ្ទាកាបិលានីភិក្ខុនី ហើយត្រឡប់ទាំងខឹងអន់ចិត្ត ទាញច្រានចេញទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យលំនៅដល់ភិក្ខុនីដទៃ ហើយទ្រាំងខឹងអន់ចិត្ត ក៏ទាញឯងក្ដីឲ្យគេទាញក្ដី ត្រូវអាបត្តិបាចិត្តិយ ។

[៤៧៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា ដល់ភិក្ខុនី គឺដល់ភិក្ខុនីដទៃ ។ ទីកុដិដែលមានសន្លឹកទ្វារបិទបាំង ហៅថាលំនៅ ។ ពាក្យថា ឲ្យ គឺឲ្យដោយខ្លួនឯង ។ ពាក្យថា ទ្រាំងខឹងអន់ចិត្ត គឺមានចិត្តមិនត្រេកអរ មានចិត្តតឹងតាសម្លក់ខ្ញាញ់ខ្ទប់ មានចិត្តរឹងត្អឹង ។ ពាក្យថា ទាញឯង គឺភិក្ខុនីចាប់យកភិក្ខុនីឯទៀតហើយទាញច្រានចេញទៅកាន់របៀង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីចាប់ទាញច្រានចេញពីរបៀងទៅខាងក្រៅ ត្រូវអាបត្តិបាចិត្តិយ ។

ឯកេន បយោគេន ពហុកេបិ ទ្វារេ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។ និក្កឌ្ឍាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ ទុក្កដស្ស ។ សកឹ អាណត្តា ពហុកេបិ ទ្វារេ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

(៤៧៤) ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា ឧបស្សយំ ទត្វា កុបិតា អនត្តមនា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ តស្សា បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ អការភជពទ្ធា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ តស្សា បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នំ ការកជពទ្ធា វា អការកជពទ្ធា វា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ



ភិក្ខុនីទាញចេញឲ្យរំលងទ្វារច្រើន តែដោយប្រយោគ១ (ទាញតែម្តង) ត្រូវអាបត្តិបាចិត្តិយ(១) ។ ពាក្យថា ឲ្យគេទាញ សេចក្តីថា ភិក្ខុនីបង្គាប់ឲ្យអ្នកដទៃទាញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីបង្គាប់តែម្តងហើយ (អ្នកទទួលបង្គាប់) ទាញឲ្យរំលងទ្វារច្រើន ត្រូវអាបត្តិបាចិត្តិយ(១) ។

(៤៧៤) ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា បានឲ្យលំនៅហើយទើបខឹងអន់ចិត្ត ទាញឯងក្តី ឲ្យគេទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ បានឲ្យលំនៅហើយទើបខឹងអន់ចិត្ត ទាញឯងក្តី ឲ្យគេទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នា បានឲ្យលំនៅហើយទើបខឹងអន់ចិត្តក្រឡប់ទាញឯងក្តី ឲ្យគេទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីទាញឯងក្តី ឲ្យគេទាញក្តី នូវបរិក្ខារនៃភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាញឯងក្តី ឲ្យគេទាញក្តី (នូវភិក្ខុនីនោះ) ចាកលំនៅដែលមិនមានសន្ទឹកក្តារជាប់ទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាញឯងក្តី ឲ្យគេទាញក្តី នូវបរិក្ខារនៃភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាញឯងក្តី ឲ្យគេទាញក្តី នូវអនុបសម្បន្នាចាកលំនៅដែលមានសន្ទឹកក្តារជាប់ទៅក្តី មិនមានសន្ទឹកក្តារ

វា អាបត្តិ ទុក្កដស្ស ។ តស្សា បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។

(៤៧៨) អនាបត្តិ អលជ្ជិនិំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្សា បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា ឧម្មត្តិកំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្សា បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា ភណ្ឌនការិកំ... កលហការិកំ... វិវាទការិកំ... ភស្សការិកំ... សង្ឃេ អធិករណការិកំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្សា បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អន្តេវាសិនិំ វា សទ្ធិវិហារិនិំ វា ន សម្មាវត្តន្តិំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្សា បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ជាប់នៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាញចេញក្តី ឲ្យគេទាញចេញក្តី នូវបរិក្ខារនៃអនុបសម្បន្នានោះ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ ។

(៤៧៨) ទោះដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១៤ យ៉ាង) គឺភិក្ខុនីទាញចេញ ឬឲ្យគេទាញចេញនូវភិក្ខុនីជាអលជ្ជី ១ ទាញចេញ ឬឲ្យគេទាញចេញនូវបរិក្ខារនៃភិក្ខុនីជាអលជ្ជីនោះ ១ ទាញចេញ ឬឲ្យគេទាញចេញភិក្ខុនីឆ្កួត ១ ទាញចេញ ឬឲ្យគេទាញចេញនូវបរិក្ខារនៃភិក្ខុនីឆ្កួតនោះ ១ ទាញចេញ ឬឲ្យគេទាញចេញនូវភិក្ខុនីអ្នកធ្វើការបង្កហេតុ ១ អ្នកធ្វើការឈ្លោះ ១ អ្នកធ្វើការទាស់ទែង ១ អ្នកធ្វើពិរោធកថា ១ អ្នកធ្វើអធិករណ៍ក្នុងសង្ឃ ១ ទាញចេញ ឬឲ្យគេទាញចេញនូវបរិក្ខារនៃភិក្ខុនីទាំងនោះ ១ ទាញចេញ ឬឲ្យគេទាញចេញនូវភិក្ខុនីជាអន្តេវាសិនី ឬជាសទ្ធិវិហារិនីដែលប្រព្រឹត្តមិនល្អ ១ ទាញចេញ ឬឲ្យគេទាញចេញនូវបរិក្ខារនៃភិក្ខុនីនោះ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

# តុវដ្ដវគ្គស្ស ឆដ្ឋសិក្ខាបទំ

(៦៧៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន ចណ្ឌកាលី ភិក្ខុនី សំសដ្ឋា
វិហរតិ គហបតិនាបិ គហបតិបុត្តេនបិ ។ យា តា
ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ
វិបាចេន្តិ កថំ ហិ នាម អយ្យា ចណ្ឌកាលី សំសដ្ឋា
វិហរិស្សតិ គហបតិនាបិ គហបតិបុត្តេនបីតិ ។ បេ ។
សច្ចំ កិរ ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី សំសដ្ឋា
វិហរតិ គហបតិនាបិ គហបតិបុត្តេនបីតិ ។ សច្ចំ
ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម
ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី សំសដ្ឋា វិហរិស្សតិ
គហបតិនាបិ គហបតិបុត្តេនបិ នេតំ ភិក្ខវេ អប្ប-
សន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ
ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន
ភិក្ខុនី សំសដ្ឋា វិហរេយ្យ គហបតិនា វា គហបតិ-
បុត្តេន វា ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា

# តុវដ្ដវគ្គ សិក្ខាបទទី ៦

(៦៧៦) សម័យនោះ ព្រះសម្ពុទ្ធមានព្រះភាគគង់ក្នុងវត្តជេតវន
របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនី
នៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយបុត្ររបស់គហបតីខ្លះ ។ ភិក្ខុនី
ទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ
ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីជាម្ចាស់ម៉េចសមបីនឹងនៅ
ច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនគហបតីខ្លះសោះ ។ បេ ។ ព្រះ
ដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនីនៅ
ច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនរបស់គហបតីខ្លះ ពិតមែនឬ ។
ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មាន
ព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនីម៉េចសមបី
នឹងនៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនគហបតីខ្លះទេ ម្នាលភិក្ខុ
ទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លា
ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងឡើងនូវសិក្ខាបទ
នេះយ៉ាងនេះថា ភិក្ខុនីណាមួយនៅច្រឡូកច្រឡំដោយគហបតី ដោយ
កូនគហបតី ។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយពោលយ៉ាងនេះថា

មាយ្យេ សំសដ្ឋា វិហរិ គហបតិនាបិ គហបតិបុត្តេនបិ វិវិច្ចាយ្យេ វិវេកញ្ញេវ ភគិនិយា សង្ឃោ វណ្ណេតីតិ ។ ឯវញ្ច[១] សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ បាចិត្តិយន្តិ ។

(៤៧៧) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សំសដ្ឋា នាម អននុលោមិកេន កាយិកវាចសិកេន សំសដ្ឋា ។ គហបតិ នាម យោ កោចិ អគារំ អជ្ឈាវសតិ ។ គហបតិបុត្តោ នាម យោ កោចិ បុត្តភាតរោ ។

(៤៧៨) សា ភិក្ខុនីតិ យា សា សំសដ្ឋា ភិក្ខុនី ។ ភិក្ខុនីហីតិ អញ្ញាហិ ភិក្ខុនីហិ ។ យា បស្សន្តិ យា សុណន្តិ តាហិ វត្តព្វា មាយ្យេ សំសដ្ឋា វិហរិ

១ ម. ឧ. ឯវញ្ច បន សា ។



នែលោកម្ចាស់ លោកកុំនៅច្រឡូកច្រឡំដោយគហបតី ឬដោយកូនគហបតីឡើយ នែលោកម្ចាស់ លោកចូរស្ងាត់ចុះ សង្ឃរមែងសរសើរសេចក្តីស្ងាត់នៃបងប្អូនស្រី ។ ភិក្ខុនីនោះ កាលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ ហើយក៏នៅប្រកួតប្រកាន់ធ្វើយ៉ាងនោះដដែល ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មប្រកាសហាមដល់បីដង ដើម្បីឲ្យលះបង់វត្ថុនោះ ។ ភិក្ខុនីនោះបើភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មប្រកាសហាមដល់បីដងហើយលះវត្ថុនោះបាន ការលះដូច្នេះនេះជាការប្រពៃ បើមិនលះទេ ត្រូវអាបត្តិបាចិត្តិយ ។

(៤៧៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា ច្រឡូកច្រឡំនោះគឺច្រឡូកច្រឡំដោយកាយកម្មនិងវចីកម្ម ដ៏មិនសមគួរ ។ ដែលហៅថា គហបតី នោះ បានដល់ជនឯណាមួយនៅគ្រប់គ្រងផ្ទះ ។ ដែលហៅថា កូនគហបតី នោះ បានដល់ជនណាមួយជាកូនឬជាបងប្អូនប្រុស (នៃគហបតីនោះ) ។

(៤៧៨) ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីណាមួយដែលជាអ្នកច្រឡូកច្រឡំ ។ ពាក្យថា ត្រូវភិក្ខុនីទាំងឡាយ គឺត្រូវភិក្ខុនីទាំងឡាយដទៃ ។ ភិក្ខុនីទាំងឡាយណាបានឃើញ ភិក្ខុនីទាំងឡាយណាបានឮ ភិក្ខុនីទាំងឡាយនោះគប្បីនិយាយហាមប្រាមថា នែលោកម្ចាស់ លោក

គហបតិនាបិ គហបតិបុត្តេនបិ វិវិច្ចាយ្យេ វិវេកញ្ញេវ ភគិនិយា សង្ឃោ វណ្ណេតីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។ សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សា ភិក្ខុនី សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វា មាយ្យេ សំសដ្ឋា វិហរិ គហបតិនាបិ គហបតិបុត្តេនបិ វិវិច្ចាយ្យេ វិវេកញ្ញេវ ភគិនិយា សង្ឃោ វណ្ណេតីតិ ។ ទុតិយម្បិ វត្តព្វា តតិយម្បិ វត្តព្វា ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

(៦៧៩) សា ភិក្ខុនី សមនុភាសិតព្វា ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី សំសដ្ឋា វិហរតិ



កុំនៅច្រឡូកច្រឡំដោយគហបតី ឬដោយកូនរបស់គហបតីឡើយ នែលោកម្ចាស់ លោកចូរស្ងាត់ចុះ សង្ឃរមែងសរសើរសេចក្ដីស្ងាត់របស់បងប្អូនស្រី ។ ភិក្ខុនីទាំងនោះគប្បីនិយាយហាមអស់វារៈតំរប់ពីរដងផង គប្បីនិយាយហាមអស់វារៈតំរប់បីដងផង ។ បើភិក្ខុនីនោះលះបង់ ការលះបង់នុះនេះជាការប្រពៃ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាំងឡាយណា ឮហើយមិននិយាយ ភិក្ខុនីទាំងឡាយនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយទាញយកមកកាន់ទីកណ្ដាលសង្ឃ ហើយគប្បីនិយាយហាមប្រាមថា នែលោកម្ចាស់ លោកកុំនៅច្រឡូកច្រឡំដោយគហបតី ឬដោយកូនរបស់គហបតីឡើយ នែលោកម្ចាស់ លោកចូរស្ងាត់ចុះ សង្ឃរមែងសរសើរសេចក្ដីស្ងាត់នៃបងប្អូនស្រី ។ ភិក្ខុនីទាំងឡាយនោះគប្បីនិយាយហាមប្រាមអស់វារៈតំរប់ពីរដងផង គប្បីនិយាយហាមអស់វារៈតំរប់បីដងផង ។ បើភិក្ខុនីនោះលះបង់បាន ការលះបង់នុះនេះជាការប្រពៃ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

(៦៧៩) ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្ម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសូត្រសមនុភាសនកម្មប្រកាសហាមប្រាមយ៉ាងនេះ ។ ភិក្ខុនីដែលឆ្លាតប្រតិពលគប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះ នៅច្រឡូកច្រឡំ

គហបតិនាបិ គហបតិបុត្តេនបិ ។ សា តំ វត្ថុំ នប្បដិ-និស្សជ្ជតិ[១] ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ភិក្ខុនី សំសដ្ឋា វិហរតិ គហបតិនាបិ គហបតិបុត្តេនបិ ។ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ[២] ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ភិក្ខុនិយា សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ តតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ សមនុភដ្ឋា សង្ឃេន ឥត្ថន្នាមា ភិក្ខុនី តស្ស វត្ថុស្ស បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

---

១-២ ម. ឱ. ៤ បដិនិស្សជ្ជតិ ។



ដោយគហបតីខ្លះ ដោយកូនរបស់គហបតីខ្លះ ។ ភិក្ខុនីនោះមិនលះវត្ថុនោះចេញទេ ។ បើកម្មនោះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្មចំពោះភិក្ខុនីឈ្មោះនេះដើម្បីឲ្យលះវត្ថុនោះចេញ ។ នេះជាញត្តិ (គឺប្រកាសឲ្យសង្ឃដឹង) ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះ នៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនគហបតីខ្លះ ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះចេញទេ ។ ឥឡូវនេះសង្ឃសូត្រសមនុភាសនកម្មចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ ការសូត្រសមនុភាសនកម្មចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីពោលឡើង ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈជាគំរប់ពីរដងផង ។បេ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈជាគំរប់បីដងផង ។បេ។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់វត្ថុនោះចេញហើយ ។ ការសូត្រសមនុភាសនកម្មនេះគួរដល់សង្ឃហើយ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៤៨០] ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៤៨១] ធម្មកម្មេ ធម្មកម្មសញ្ញា នប្បដិនិស្ស-ជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា នប្បដិនិស្សជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អ-ធម្មកម្មសញ្ញា នប្បដិនិស្សជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្ម-កម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៤៨២] អនាបត្តិ អសមនុភាសន្តិយា បដិនិស្ស-ជ្ជន្តិយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## តុវដ្ដវគ្គស្ស សត្តមសិក្ខាបទំ

[៤៨៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ អន្តោរដ្ឋេ សាសង្ក-



(៤៨០) កាលសូត្រចប់ញត្តិ (ភិក្ខុនីនោះមិនលះបង់ក្តីនោះ) ត្រូវអាបត្តិទុក្កដ (១) កាលសូត្រកម្មវាចាពីរដង ត្រូវអាបត្តិទុក្កដ (២) កាលចប់កម្មវាចាជាស្រេច ត្រូវអាបត្តិបាចិត្តិយ ។

(៤៨១) កម្មជាធម៌ ភិក្ខុនីសំគាល់ថាកម្មជាធម៌ ហើយមិនលះបង់ក្តីនោះ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុនីសំគាល់ថាកម្មមិនជាធម៌ ហើយមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនជាធម៌ ភិក្ខុនីសំគាល់ថាកម្មជាធម៌វិញ ត្រូវអាបត្តិទុក្កដ ។ កម្មមិនជាធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនជាធម៌ ភិក្ខុនីសំគាល់ថាកម្មមិនជាធម៌ ត្រូវអាបត្តិទុក្កដ ។

(៤៨២) ពុះថ្កូលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីដែលសង្ឃមិនបានសូត្រសមនុភាសនកម្ម ១ ភិក្ខុនីលះបង់ក្តីនោះ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## តុវដ្ដវគ្គ សិក្ខាបទទី ៧

(៤៨៣) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយ

សម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរន្តិ ។ ធុត្តា ទូសេន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ



គ្មានពួកឈ្មួញទៅជាមួយ នាំគ្នាត្រាច់ទៅកាន់ចារិកក្នុងដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ។ ពួកអ្នកលេងនាំគ្នាប្រទូស្ត (ពួកភិក្ខុនីទាំងឡាយនោះ) ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយនាំគ្នាត្រាច់ទៅកាន់ចារិកក្នុងដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយគ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិកក្នុងដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិកក្នុងដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បី

សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរេយ្យ បាចិត្តិយន្តិ ។

(៨០៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អន្តោរដ្ឋេតិ យស្ស វិជិតេ វិហរតិ តស្ស រដ្ឋេ ។ សាសង្កំ នាម តស្មឹ មគ្គេ ចោរានំ និវិដ្ឋោកាសោ ទិស្សតិ ភុត្តោកាសោ ទិស្សតិ ឋិតោកាសោ ទិស្សតិ និសិន្នោកាសោ ទិស្សតិ និបន្នោកាសោ ទិស្សតិ ។ សប្បដិភយំ នាម តស្មឹ មគ្គេ ចោរេហិ មនុស្សា ហតា ទិស្សន្តិ វិលុត្តា ទិស្សន្តិ អាកោដិតា ទិស្សន្តិ ។ អសត្ថិកា នាម វិនា សត្ថេន ។ ចារិកំ ចរេយ្យាតិ កុក្កុដសំបាតេ[១] គាមេ គាមន្តរេ គាមន្តរេ អាបត្តិ បាចិត្តិយស្ស ។ អគាមកេ អរញ្ញេ អឌ្ឍយោជនេ អឌ្ឍយោជនេ អាបត្តិ បាចិត្តិយស្ស ។

១ ឱ. កុក្កុដសម្បាតេ ។



សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយគ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិកខាងក្នុងដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិបាចិត្តិយ ។

(៨០៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា ខាងក្នុងដែន គឺភិក្ខុនីនៅខាងក្នុងដែនរបស់ស្ដេចណា គឺត្រាច់ទៅក្នុងដែនរបស់ស្ដេចនោះ ។ ដែលហៅថា ទីប្រកបដោយសេចក្ដីរង្កៀសនោះ បានដល់កន្លែងដែលពួកចោរនៅក៏ប្រាកដ កន្លែងដែលពួកចោរបរិភោគក៏ប្រាកដ កន្លែងដែលពួកចោរឈរក៏ប្រាកដ កន្លែងដែលពួកចោរអង្គុយក៏ប្រាកដ កន្លែងដែលពួកចោរដេកក៏ប្រាកដក្នុងផ្លូវនោះ ។ ទីដែលហៅថា ប្រកបដោយភ័យចំពោះមុខនោះ គឺពួកមនុស្សដែលចោរសំឡាប់ក៏ប្រាកដ ដែលចោរប្លន់ក៏ប្រាកដ ដែលចោរវាយក៏ប្រាកដក្នុងផ្លូវនោះ ។ ដែលហៅថា គ្មានពួកឈ្មួញទៅជាមួយនោះ គឺវៀរចាកពួកឈ្មួញចេញ ។ ពាក្យថា ត្រាច់ទៅកាន់ចារិក សេចក្ដីថា ភិក្ខុនីត្រាច់ទៅក្នុងស្រុកកំណត់មួយរយៈមាន់ហើរ ត្រូវអាបត្តិបាចិត្តិយគ្រប់ ១ ចន្លោះស្រុក ។ ទីព្រៃមិនមែនជាស្រុក ភិក្ខុនីត្រាច់ទៅក្នុងទីនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ ១ កន្លះយោជន៍ ។

[៦៨៨] អនាបត្តិ សត្ថេន សហ គច្ឆតិ ខេមេ អប្បដិភយេ គច្ឆតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## តុវដ្ដវគ្គស្ស អដ្ឋមសិក្ខាបទំ

(៦៨៩) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរន្តិ ។ ធុត្តា ទូសេន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អន្តោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ



[៦៨៨] អំពើដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥ យ៉ាង) គឺភិក្ខុនីទៅជាមួយពួកឈ្មួញ ១ ភិក្ខុនីទៅក្នុងទីក្សេមក្សាន្តមិនមានភ័យ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## តុវដ្ដវគ្គ សិក្ខាបទទី ៨

(៦៨៩) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយ គ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិកខាងក្នុងដែនដែល គេសន្មតថាជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ។ អ្នកលេងទាំងឡាយក៏នាំគ្នាប្រទូស្ត (ពួកភិក្ខុនីនោះ) ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកភិក្ខុនីមិនសមគួរនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិកខាងក្នុងដែនដែលគេ សន្មតថាជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ សោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុនីគ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិក

ចរន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ តិរោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី តិរោរដ្ឋេ សាសង្កសម្មតេ សប្បដិភយេ អសត្ថិកា ចារិកំ ចរេយ្យ បាចិត្តិយន្តិ ។

(៦៨៧) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ តិរោរដ្ឋេតិ យស្ស វិជិតេ វិហរតិ តំ ឋបេត្វា អញ្ញស្ស រដ្ឋេ ។ សាសង្កំ នាម តស្មឹ មគ្គេ ចោរានំ និវិដ្ឋោកាសោ ទិស្សតិ ភុត្តោកាសោ ទិស្សតិ ឋិតោកាសោ



ខាងក្រៅដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបើនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយគ្មានពួកឈ្មួញទៅជាមួយ ហើយត្រាច់ទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិបាចិត្តិយ ។

(៦៨៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ខាងក្រៅដែន គឺភិក្ខុនីនៅក្នុងដែនរបស់ស្ដេចណា ហើយត្រាច់ទៅកាន់ក្នុងដែនរបស់ស្ដេចឯទៀត ក្រៅពីដែនរបស់ស្ដេចនោះ ។ ដែលហៅថា ជាទីប្រកបដោយសេចក្ដីរង្កៀសនោះ បានដល់កន្លែងដែលពួកចោរនៅក៏ប្រាកដ កន្លែងដែលពួកចោរបរិភោគក៏ប្រាកដ កន្លែងដែលពួកចោរឈរក៏ប្រាកដ

ធំស្សតិ និស្សង្ឃាការោ ធំស្សតិ ធំបង្ខារកោ ធំស្សតិ ។ សព្វឌីកយំ ញាម គស្មិ ឧភ្តេ ហោមហិ មនុស្សា ហាគា និស្សន្តិ វិសុត្តា និស្សន្តិ អារោបិតា និស្សន្តិ ។ អសត្ថិកា ជាម វិជា សត្ថេន ។ ចារិកំ ចរេយ្យាតិ តម្ហិ ជនបទ គាមេ គាមន្តរេ គាមន្តរេ អាបត្តិ បាចិត្តិយស្ស ។ អគាមកេ អរញ្ញេ អទ្ធ-យោជនេ អទ្ធយោជនេ អាបត្តិ បាចិត្តិយស្ស ។

(៤៨៨) អនាបត្តិ សត្ថេន សហ គច្ឆតិ ខេមេ អប្ប-ដិភយេ គច្ឆតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិ-កាយាតិ ។

---

## ឆត្តវគ្គស្ស តតិយសិក្ខាបទំ

(៤៨៩) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ អញ្ញតរិស្សា ចារិកំ ចរន្តិ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម



កន្ទេលដែលគួរនៅភេទ្ទមយក៏ត្រូវផង កន្ទេលដែលគួរនៅរអេកក៏ត្រូវផងក្នុងដែនោះ ។ ទីដែលហៅថា ប្រកបដោយភ័យចំពោះមុខនោះ គឺពួកមនុស្សដែលចោរតាំងទ្បាយសម្លាប់ក៏ត្រូវផង ដែលពួកចោរប្លន់ក៏ត្រូវផង ដែលពួកចោរវាយក៏ត្រូវផងក្នុងដែនោះ ។ ដែលហៅថា គ្មានពួកឈ្មួញ គឺវៀរចាកពួកឈ្មួញ ។ ពាក្យថា ត្រាច់ទៅកាន់ចារិក សេចក្តីថា ភិក្ខុនីត្រាច់ទៅក្នុងស្រុកកំណត់មួយរយៈមាន់ហើរ ត្រូវអាបត្តិបាចិត្តិយរាល់ៗចន្លោះស្រុក ។ ភិក្ខុនីត្រាច់ទៅក្នុងព្រៃមិនមែនស្រុក ត្រូវអាបត្តិបាចិត្តិយរាល់ៗកន្លះយោជន៍ ។

(៤៨៨) អនាបត្តិ ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីទៅជាមួយពួកឈ្មួញ ១ ភិក្ខុនីទៅក្នុងទីក្សេមក្សាន្តមិនមានភ័យ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិកបុគ្គល ១ ។

---

## ឆត្តវគ្គ សិក្ខាបទទី ៨

(៤៨៩) សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ពួកភិក្ខុនីត្រាច់ទៅកាន់ចារិកនាទីក្នុងដែនស្រុក ។ មនុស្សទាំងទ្បាយក៏ពោលទោស តិះដៀល

ភិក្ខុនិយោ អន្តោវស្សំ ចារិកំ ចរិស្សន្តិ ហរិតានិ តិណានិ សម្មទ្ទន្តា ឯកិន្ទ្រិយំ ជីវំ វិហេឋេន្តា ពហូ ខុទ្ទកេ បាណេ សង្ឃាតំ អាបាទេន្តាតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អន្តោវស្សំ ចារិកំ ចរិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អន្តោវស្សំ ចារិកំ ចរន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អន្តោវស្សំ ចារិកំ ចរិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អន្តោវស្សំ ចារិកំ ចរេយ្យ បាចិត្តិយន្តិ ។

(២៨០) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អន្តោវស្សន្តិ បុរិមំ វា តេមាសំ បច្ឆិមំ



បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងត្រូវទៅកាន់ចារិកខាងក្នុងវស្សា ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនជីវៈដែលរស់នៅមានឥន្ទ្រិយតែមួយ ញុំាងសត្វទាំងឡាយតូចៗ ឲ្យវិនាសទៅជាច្រើនដូច្នេះ ។ ពួកភិក្ខុនីបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងត្រូវទៅកាន់ចារិកខាងក្នុងវស្សាសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីត្រូវទៅកាន់ចារិកខាងក្នុងវស្សា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមបើនឹងត្រូវទៅកាន់ចារិកខាងក្នុងវស្សាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយត្រូវទៅកាន់ចារិកខាងក្នុងវស្សា ត្រូវអាបត្តិបាចិត្តិយ ។

(២៨០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃលសុណវគ្គរួចហើយ ។ ពាក្យថា ខាងក្នុងវស្សា

ក គេហាសំ អសត្ថិកា ។ ចារិកំ ចរេយ្យាតិ កុក្កុដសំ-បាតេ គាមេ គាមន្តរេ គាមន្តរេ អាបត្តិ បាចិត្តិយស្ស ។ អគាមកេ អរញ្ញេ អទ្ធយោជនេ អទ្ធយោជនេ អាបត្តិ បាចិត្តិយស្ស ។

[៤៩១] អនាបត្តិ សត្ថេន សហ គច្ឆតិ ខេមេ អប្បដិភយេ គច្ឆតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## តុវដ្ដវគ្គស្ស ទសមសិក្ខាបទំ

[៤៩២] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ រាជគហេ វស្សំ វុដ្ឋា តត្ថេវ អច្ឆន្តិ តត្ថ ហេមន្តំ តត្ថ គិម្ហំ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ អាហុណ្ឌរិកា ភិក្ខុនីនំ ទិសា អន្ធការា ន



សេចក្ដីថា ភិក្ខុនីមិនបានទៅជាមួយពួកឈ្មួញ កំណាត់ផ្លូវខាងដើមក្ដី[1] កំណាត់ផ្លូវខាងចុងក្ដី[2] ។ ពាក្យថា ត្រាច់ទៅកាន់ចារិក សេចក្ដីថា ភិក្ខុនីត្រាច់ទៅក្នុងស្រុកដែលមាន់មួយហើរទៅដល់ ត្រូវអាបត្តិបាចិត្តិយរាល់ៗចន្លោះស្រុក ភិក្ខុនីត្រាច់ទៅក្នុងទីព្រៃមិនមែនស្រុក ត្រូវអាបត្តិបាចិត្តិយរាល់ៗកន្លះយោជន៍ ។

[៤៩១] ភិក្ខុនីមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុនីទៅជាមួយសត្ថា(ពួកឈ្មួញ)ក្ដី ១ ភិក្ខុនីទៅព្រោះហេតុអ្វីមួយបៀតបៀន ១ ភិក្ខុនីមានសេចក្ដីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## តុវដ្ដវគ្គ សិក្ខាបទទី ១០

[៤៩២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ភិក្ខុនីទាំងឡាយ នៅចាំវស្សាក្នុងវត្តវេឡុវ័ន ទៀបក្រុងរាជគ្រឹះនោះឯង (ចេញវស្សាហើយក៏នៅ) ក្នុងទីនោះអស់ហេមន្តរដូវ (នៅ) ក្នុងទីនោះអស់គិម្ហរដូវ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ទិសទាំងឡាយចង្អៀត

១ បុរិមកស្មិំ ។ ២ បច្ឆិមកស្មិំ ។

ឥមាសំ ទិសា បក្ខាយន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខុនីនំ សិក្ខាបទំ បញ្ញាបេស្សាមិ ទស អត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ ។ បេ ។ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី វស្សំ វុត្ថា ចារិកំ ន បក្កមេយ្យ អន្តមសោ ឆប្បញ្ចយោជនានិបិ បាចិត្តិយន្តិ ។

(៤៨៣) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ វស្សំ វុត្ថា នាម បុរិមំ វា តេមាសំ បច្ឆិមំ



ងងឹតដល់ភិក្ខុនីទាំងឡាយ ទិសទាំងឡាយមិនប្រាកដច្បាស់ដល់ភិក្ខុនីទាំងនេះ (ប្រៀបដូច ប្រាកដជាមិនចេញអំពីទីនេះសោះ) ។ ពួកភិក្ខុនីបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបភិក្ខុនីទាំងនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុនីទាំងឡាយ ព្រោះអាស្រ័យអំណាចនៃប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្តីប្រពៃដល់សង្ឃ ១ ។ បេ ។ ដើម្បីសេចក្តីតាំងនៅយូរនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយនៅចាំវស្សារួចហើយ មិនចៀសចេញទៅកាន់ចារិក ដោយហោចទៅសូម្បីតែ ៥-៦ យោជន៍ ត្រូវអាបត្តិបាចិត្តិយ ។

(៤៨៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃលសុណវគ្គរួចហើយ ។ ដែលហៅថា នៅចាំវស្សារួចហើយ គឺនៅចាំវស្សាត្រៃមាសខាងដើមក្តី ត្រៃមាសខាងចុងក្តី ។

ក តេមាសំ វុត្ថា ។ ជាតិកំ ន វូបកាសាបេស្សាមិ អន្តម-
សោ ឆប្បញ្ចយោជនានីតិ(១) ធុរំ និក្ខិត្តមត្តេ អាបត្តិ
បាចិត្តិយស្ស ។

(៤៩៦) អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ទុតិយំ ភិក្ខុនឹ ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

ឆដ្ឋសិក្ខាបទំ ។

១ ។ ម. ឆប្បញ្ចយោជនានិបីតិ ។



ភិក្ខុនីត្រូវតែដាក់ធុរៈថា អញ្ញនឹងមិនចៀសចេញទៅកាន់ចារិក ដោយ
ហោចទៅសូម្បីតែ ៥-៦ យោជន៍ ក៏ត្រូវអាបត្តិបាចិត្តិយ ។

(៤៩៦) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីកាលមានសេចក្តីអន្តរាយ ហើយស្វែងរកភិក្ខុនីជាគ្នាជាន់ទៅក៏មិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាអ្នកដើមបញ្ញត្តិ១ ។

សិក្ខាបទទី ៦ ចប់ ។

## ចិត្តាគារវគ្គស្ស បឋមសិក្ខាបទំ

[៤៨៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន រញ្ញោ បសេនទិស្ស កោសលស្ស(១) ឧយ្យានេ ចិត្តាគារេ បដិភានចិត្តំ កតំ ហោតិ ។ ពហូ មនុស្សា ចិត្តាគារំ ទស្សនាយ គច្ឆន្តិ ។ ឆព្វគ្គិយាបិ ភិក្ខុនិយោ ចិត្តាគារំ ទស្សនាយ អគមំសុ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ចិត្តាគារំ ទស្សនាយ គច្ឆិស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ(២) ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ ចិត្តាគារំ ទស្សនាយ គច្ឆិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ចិត្តាគារំ

១ ឱ. បសេនទិកោសលស្ស ។ ២ ឱ. គិហិកាមភោគិនិយោតិ ។

## ចិត្តាគារវគ្គ សិក្ខាបទទី ១

(៤៨៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង នាយជាងគំនូរ គូរគំនូរក្នុងព្រះរាជដំណាក់ជីវចិត្រ(១)ក្នុងឧទ្យានរបស់ព្រះបាទបសេនទិកោសល ។ ពួកមនុស្សជាច្រើនតែងទៅមើលព្រះរាជដំណាក់ជីវចិត្រ (នោះ) ។ សូម្បីពួកឆព្វគ្គិយាភិក្ខុនី (ភិក្ខុនីពួក៦រូប) ក៏បានទៅមើលព្រះរាជដំណាក់ជីវចិត្រ (នោះដែរ) ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងទៅមើលព្រះរាជដំណាក់ជីវចិត្រដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមនោះ ។ ភិក្ខុនីទាំងឡាយបានឮពួកមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនីមិនសមបើនឹងទៅមើលព្រះរាជដំណាក់ជីវចិត្រសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយាភិក្ខុនីទៅមើលរាជដំណាក់ជីវចិត្រ

១ អដ្ឋកថា ថា ជាផ្ទះសំណាក់ដ៏វិចិត្រ សម្រាប់ស្ដេចក្រសាល ។

ទស្សនាយ គច្ឆន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ចិត្តាគារំ ទស្សនាយ គច្ឆិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី រាជាគារំ វា ចិត្តាគារំ វា អារាមំ វា ឧយ្យានំ វា បោក្ខរណឹ វា ទស្សនាយ គច្ឆេយ្យ បាចិត្តិយន្តិ ។

[៦៩៦] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ រាជាគារំ នាម យត្ថ កត្ថចិ រញ្ញោ កីឡិតុំ រមិតុំ កតំ ហោតិ ។ ចិត្តាគារំ នាម យត្ថ កត្ថចិ មនុស្សានំ កីឡិតុំ រមិតុំ កតំ ហោតិ ។ អារាមោ នាម យត្ថ កត្ថចិ មនុស្សានំ កីឡិតុំ រមិតុំ កតោ ហោតិ ។ ឧយ្យានំ នាម យត្ថ កត្ថចិ មនុស្សានំ កីឡិតុំ រមិតុំ កតំ ហោតិ ។ បោក្ខរណី នាម



ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនគួរបើទំនើរទៅមើលរាជដំណាក់ដ៏វិចិត្រទេ ម្នាលភិក្ខុទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយទៅដើម្បីមើលដំណាក់សម្រាប់ក្រសាលរបស់ស្តេចក្តី រោងដ៏វិចិត្រក្តី សួនក្តី ឧទ្យានក្តី ស្រះបោក្ខរណីក្តី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៦៩៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា ដំណាក់ក្រសាលរបស់ស្តេច បានដល់ដំណាក់ដែលគេសាងដើម្បីក្រសាលសប្បាយដល់ស្តេចនៅក្នុងកន្លែងណាមួយ ។ ដែលហៅថា រោងដ៏វិចិត្រ បានដល់រោងដែលគេសាងដើម្បីលេងសប្បាយដល់មនុស្សទាំងឡាយនៅក្នុងកន្លែងណាមួយ ។ ដែលហៅថា សួន បានដល់សួនដែលគេសាងដើម្បីលេងសប្បាយដល់មនុស្សទាំងឡាយក្នុងកន្លែងណាមួយ ។ ដែលហៅថា ឧទ្យាន បានដល់ឧទ្យានដែលគេសាងដើម្បីលេងសប្បាយដល់មនុស្សទាំងឡាយក្នុងទីណាមួយ ។ ដែលហៅថា ស្រះបោក្ខរណី បានដល់ស្រះបោក្ខរណីដែលគេ

យត្ថ កត្ថចិ មនុស្សានំ កីឡិតុំ រមិតុំ កតា ហោតិ ។ ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស យត្ថ ឋិតា បស្សតិ អាបត្តិ បាចិត្តិយស្ស ។ ទស្សនូបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ បាចិត្តិយស្ស ។ ឯកមេកំ ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស យត្ថ ឋិតា បស្សតិ អាបត្តិ បាចិត្តិយស្ស ។ ទស្សនូបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ បាចិត្តិយស្ស ។

[៤៩៧] អនាបត្តិ អារាមេ ឋិតា បស្សតិ គច្ឆន្តី វា អាគច្ឆន្តី វា បស្សតិ សតិ ករណីយេ គន្ត្វា បស្សតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ចិត្តាគារវគ្គស្ស ទុតិយសិក្ខាបទំ

(៤៩៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ អាសន្ទឹ បល្លង្កំ បរិភុញ្ជន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា



សានដើម្បីលេងសប្បាយរបស់មនុស្សទាំងឡាយក្នុងកន្លែងណាមួយ ។ ភិក្ខុនីទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ឈរមើលក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ ។ ភិក្ខុនីលះបង់ឧបចារមើល ហើយមើលរឿយ ៗ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីទៅដើម្បីមើលកន្លែងណាតែមួយ ៗ ត្រូវអាបត្តិទុក្កដ (មួយ ៗ) ឈរមើលក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ ។ លះបង់ឧបចារមើល ហើយមើលញយ ៗ ត្រូវអាបត្តិបាចិត្តិយ ។

(៤៩៧) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺ ភិក្ខុនីឈរក្នុងអារាមហើយមើល ១ ភិក្ខុនីកំពុងដើរទៅក្ដី ដើរមកក្ដី ឃើញ ១ កាលបើមានកិច្ចភិក្ខុនីទៅហើយឃើញ ១ ភិក្ខុនីមានសេចក្ដីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## ចិត្តាគារវគ្គ សិក្ខាបទទី ២

(៤៩៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយប្រើប្រាស់អាសន្ទិ[១]ខ្លះ បល្លង្ក[២]ខ្លះ ។ មនុស្សទាំងឡាយដើរទៅកាន់

---

១ ជើងម៉ាប្អូនទ្រនំដែលមានជើងខ្ពស់ ក្នុងអដ្ឋកថាថា បាទដល់អាសនៈគន្ធនហួសប្រមាណ ។ ២ គ្រែចិត្រដោយរូបសត្វសាហាវ ។

បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អាសន្ទឹ បល្លង្កំ បរិភុញ្ជិស្សន្តិ សេយ្យ-ថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អាសន្ទឹ បល្លង្កំ បរិភុញ្ជិស្សន្តិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អាសន្ទឹ បល្លង្កំ បរិភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អាសន្ទឹ បល្លង្កំ បរិភុញ្ជិស្សន្តិ នេតំ ភិក្ខវេ អប្ប-សន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អាសន្ទឹ វា បល្លង្កំ វា បរិភុញ្ជេយ្យ បាចិត្តិយន្តិ ។

(៦៨៨) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អាសន្ទិ នាម អតិក្កន្តប្បមាណា



ជាតិភាពរបស់ពួកហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងប្រើប្រាស់អាសន្ទិៈ បល្ល័ង្កៈ ដូចជាស្រីគ្រហស្ថជាអ្នកបរិភោគកាមៈនោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងប្រើប្រាស់អាសន្ទិៈបល្ល័ង្កៈនោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយប្រើប្រាស់អាសន្ទិៈ បល្ល័ង្កៈ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងប្រើប្រាស់អាសន្ទិៈ បល្ល័ង្កៈទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណា-មួយប្រើប្រាស់អាសន្ទិក្តី បល្ល័ង្កក្តី ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៦៨៨) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃពួកឆត្តវគ្គហើយ ។ អាសន្ទិៈដែលកន្លងហួសប្រមាណ

វុត្តំ ។ បល្លង្កោ នាម អាហរិមេហិ វាលេហិ កតោ ហោតិ ។ បរិភុញ្ជេយ្យាតិ តស្មិំ អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។

[៣០០] អនាបត្តិ អាសន្ទិយា បាទេ ឆិន្ទិត្វា បរិភុញ្ជតិ បល្លង្កស្ស វាលេ ភិន្ទិត្វា[១] បរិភុញ្ជតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## បិណ្ឌបាតវគ្គស្ស តតិយសិក្ខាបទំ

[៣០១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខុនិយោ សុត្តំ កន្តន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ សុត្តំ កន្តិស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា

---
១ ឱ ឆិន្ទិត្វា ។



គឺជាគ្រែធ្នេរឈ្មោះថា អាសន្ទិ ។ គ្រែដែលគេធ្វើដោយរោមសត្វកាចទាំងឡាយលើកទៅមកជាន ឈ្មោះថា បល្លង្ក ។ ពាក្យថា ប្រើប្រាស់ គឺភិក្ខុនីអង្គុយឬដេកលើអាសនៈនោះ ត្រូវអាបត្តិបាចិត្តិយ ។

(៣០០) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុនីកាត់ជើងអាសន្ទិហើយទើបប្រើប្រាស់១ ភិក្ខុនីទំលាយរោមសត្វកាចទាំងឡាយនៃបល្លង្កហើយទើបប្រើប្រាស់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ ។

---

## បិណ្ឌបាតវគ្គ សិក្ខាបទទី ៣

(៣០១) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយកាស្រៃ (ឬអរម្បុះ) ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារឃើញហើយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងការអរម្បុះដូចជាពួកស្រីគ្រហស្ថជាអ្នកបរិ-ភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះតិះដៀល ពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា

ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ សុត្តំ កន្តិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ សុត្តំ កន្តន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ សុត្តំ កន្តិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី សុត្តំ កន្តេយ្យ បាចិត្តិយន្តិ ។

[៣០២] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សុត្តំ នាម ឆ សុត្តានិ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គំ ។ កន្តេយ្យាតិ សយំ កន្តតិ បយោគេ ទុក្កដំ ឧជ្ជវុជ្ជវេ អាបត្តិ បាចិត្តិយស្ស ។



មានសេចក្តីត្រូវការតិច ។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងការអំបោះសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនីទាំងឡាយការអំបោះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនគួរបើនឹងការអំបោះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយការអំបោះ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៣០២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ ។ សូត្រទាំងឡាយមាន៦ យ៉ាងគឺ របស់ធ្វើដោយសម្បកឈើ១ ធ្វើដោយកប្បាស១ ធ្វើដោយសូត្រ(សម្បកនាង)១ ធ្វើដោយរោមសត្វ១ ធ្វើដោយធ្មៃ១ ភង្គៈ(របស់ដែលលាយដោយគ្រឿង៥ មានសម្បកឈើជាដើមជាមួយគ្នា)១ ឈ្មោះថាសូត្រ ។ ពាក្យថា ការ គឺភិក្ខុនីការដោយខ្លួនឯង ត្រូវអាបត្តិទុក្កដ ប្រយោគដែលការ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ កៈដែលបង្វិលមួយជុំៗ ។

[៣០៣] អនាបត្តិ កន្តិតសុត្តំ កន្តតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ចិត្តាគារវគ្គស្ស បញ្ចមសិក្ខាបទំ

[៣០៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ គិហិវេយ្យាវច្ចំ ករោន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ គិហិវេយ្យាវច្ចំ ករិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ គិហិវេយ្យាវច្ចំ ករោន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ គិហិវេយ្យាវច្ចំ ករិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ



[៣០៣] កាលដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីការអំបោះដែលគេការរួចហើយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

---

## ចិត្តាគារវគ្គ សិក្ខាបទទី ៥

[៣០៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅវត្តជេតពនជាអារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនគួរបើនឹងធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី គិហិវេយ្យាវច្ចំ ករេយ្យ បាចិត្តិយន្តិ ។

[៣០៥] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ គិហិវេយ្យាវច្ចំ នាម អាគារិកស្ស យាគុំ វា ភត្តំ វា ខាទនីយំ វា បចតិ សាដកំ វា វេឋនំ(១) វា ធោវតិ អាបត្តិ បាចិត្តិយស្ស ។

[៣០៦] អនាបត្តិ យាគុបានេ សង្ឃភត្តេ ចេតិយបូជាយ អត្តនោ វេយ្យាវច្ចករស្ស យាគុំ វា ភត្តំ វា ខាទនីយំ វា បចតិ សាដកំ វា វេឋនំ(២) វា ធោវតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ចិត្តាគារវគ្គស្ស បញ្ចមសិក្ខាបទំ

[៣០៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី ថុល្លនន្ទំ ភិក្ខុនឹ ឧបសង្កមិត្វា ឯតទវោច ឯហាយ្យេ ឥមំ

---

១-២ ម. វេឋនំ ។



ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ធ្វើការបម្រើគ្រហស្ថ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

(៣០៥) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលឈ្មោះថា ការខ្វល់ខ្វាយបម្រើគ្រហស្ថ គឺភិក្ខុនីចំអិនបបរក្តី បាយក្តី ខាទនីយក្តី លាងសាដកក្តី សំពត់ឈ្នួតក្តី ដើម្បីបុគ្គលដែលនៅគ្រប់គ្រងផ្ទះ ត្រូវអាបត្តិបាចិត្តិយ ។

(៣០៦) ការៈដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុនីជួយចម្អិនបបរក្តី សង្ឃភត្តក្តី ដើម្បីសង្ឃ ១ ភិក្ខុនីជួយគ្រហស្ថ គឺការបូជាចេតិយ ១ ភិក្ខុនីចម្អិនបបរក្តី បាយក្តី ខាទនីយក្តី លាងសាដកក្តី សំពត់ឈ្នួតក្តី ដើម្បីវេយ្យាវច្ចកររបស់ខ្លួន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិដើមបញ្ញត្តិ ១ ។

---

## ចិត្តាគារវគ្គ សិក្ខាបទទី ៥

(៣០៧) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនី ១ រូប ចូលទៅរកថុល្លនន្ទាភិក្ខុនី ហើយបាននិយាយពាក្យនេះថា នែនាងម្ចាស់

អធិករណំ វូបសមេហីតិ ។ ថុល្លនន្ទា ភិក្ខុនី សាធូតិ បដិស្សុណិត្វា[១] នេវ វូបសមេតិ ន វូបសមាយ ឧស្សុក្កំ ករោតិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា ភិក្ខុនិយា ឯហាយ្យេ ឥមំ អធិករណំ វូបសមេហីតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា នេវ វូបសមេស្សតិ ន វូបសមាយ ឧស្សុក្កំ ករិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភិក្ខុនិយា ឯហាយ្យេ ឥមំ អធិករណំ វូបសមេហីតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា នេវ វូបសមេតិ ន វូបសមាយ ឧស្សុក្កំ ករោតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ភិក្ខុនិយា ឯហាយ្យេ ឥមំ អធិករណំ វូបសមេហីតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា នេវ វូបសមេស្សតិ ន វូបសមាយ ឧស្សុក្កំ ករិស្សតិ នេតំ ភិក្ខវេ

១ ម. បដិសុណិត្វា ។



នាងចូរមករម្ងាប់អធិករណ៍នេះ ។ ថុល្លនន្ទាភិក្ខុនីត្រាន់តែទទួលពាក្យថាសាធុ តែមិនរម្ងាប់មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីរម្ងាប់អធិករណ៍នោះឡើយ ។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ កាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះផង ចុះទទួលពាក្យថា សាធុ ហើយ មិនសមបើនឹងមិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីរម្ងាប់ (អធិករណ៍នោះ)សោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី កាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះផង បានទទួលពាក្យថាសាធុហើយ តែមិនរម្ងាប់មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីរម្ងាប់ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី កាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះផង បានទទួលពាក្យថាសាធុហើយ ហេតុអ្វីក៏មិនរម្ងាប់មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីរម្ងាប់ ម្នាលភិក្ខុ

អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ភិក្ខុនិយា ឯហាយ្យេ ឥមំ អធិករណំ វូបសមេហីតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា សា បច្ឆា អនន្តរាយិកិនី នេវ វូបសមេយ្យ ន វូបសមាយ ឧស្សុក្កំ ករេយ្យ បាចិត្តិយន្តិ ។

(៣០៨) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុនិយាតិ អញ្ញាយ ភិក្ខុនិយា ។ អធិករណំ នាម ចត្តារិ អធិករណានិ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ។ ឯហាយ្យេ ឥមំ អធិករណំ វូបសមេហីតិ ឯហាយ្យេ ឥមំ អធិករណំ វិនិច្ឆេហិ ។ សា បច្ឆា អនន្តរាយិកិនីតិ អសតិ អន្តរាយេ ។ នេវ វូបសមេយ្យាតិ ន សយំ វូបសមេយ្យ ។ ន វូបសមាយ ឧស្សុក្កំ ករេយ្យាតិ



ទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយកាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះចុះ បានទទួលពាក្យថា សាធុហើយ ភិក្ខុនីនោះក្នុងកាលជាខាងក្រោយកាលមិនមានសេចក្ដីអន្តរាយ (នឹង) ហើយមិនរម្ងាប់ មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

(៣០៨) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌនេះហើយ ។ ពាក្យថា កាលដែលភិក្ខុនី បានដល់ភិក្ខុនីដទៃ ។ អធិករណ៍ទាំងឡាយ ៤ គឺវិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ឈ្មោះថា អធិករណ៍ ។ ពាក្យថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ គឺថា នែនាងម្ចាស់ នាងចូរមកវិនិច្ឆ័យអធិករណ៍នេះ ។ ពាក្យថា ភិក្ខុនីនោះក្នុងកាលជាខាងក្រោយកាលមិនមានសេចក្ដីអន្តរាយ គឺកាលបើសេចក្ដីអន្តរាយមិនមាន ។ ពាក្យថា មិនរម្ងាប់ គឺមិនរម្ងាប់ដោយខ្លួនឯង ។ ពាក្យថា មិនធ្វើសេចក្ដី

ន អញ្ញំ អាណាបេយ្យ ។ នេវ វូបសមេស្សាមិ ន វូបសមាយ ឧស្សុក្កំ ករិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

(៣០៤) ឧបសម្បន្នាយ ឧបសម្បន្នសញ្ញា អធិករណំ នេវ វូបសមេតិ ន វូបសមាយ ឧស្សុក្កំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកា អធិករណំ នេវ វូបសមេតិ ន វូបសមាយ ឧស្សុក្កំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញា អធិករណំ នេវ វូបសមេតិ ន វូបសមាយ ឧស្សុក្កំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នាយ អធិករណំ នេវ វូបសមេតិ ន វូបសមាយ ឧស្សុក្កំ ករោតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។



ខ្វល់ខ្វាយដើម្បីរម្ងាប់ គឺភិក្ខុនីមិនបង្គាប់ភិក្ខុនីដទៃ ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនរម្ងាប់ អញនឹងមិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់ផង ត្រូវអាបត្តិបាចិត្តិយ ។

(៣០៤) ឧបសម្បន្នា ភិក្ខុនីសំគាល់ថាឧបសម្បន្នា ហើយមិនរម្ងាប់មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់នូវអធិករណ៍ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្ដីសង្ស័យ មិនរម្ងាប់មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់នូវអធិករណ៍ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាមិនមែនឧបសម្បន្នា ហើយមិនរម្ងាប់មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់នូវអធិករណ៍ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនរម្ងាប់ មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់នូវអធិករណ៍របស់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្នា ភិក្ខុនីសំគាល់ថាឧបសម្បន្នា ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្នា ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្នា ភិក្ខុនីសំគាល់ថាមិនមែនឧបសម្បន្នា ត្រូវអាបត្តិទុក្កដ ។

[៣១០] អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ចិត្តាគារវគ្គស្ស ឆដ្ឋសិក្ខាបទំ

[៣១១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី នដានំបិ នដកានំបិ លង្ឃកានំបិ សោកជ្ឈាយិកានំបិ កុម្ភថូណិកានំបិ សហត្ថា ខាទនីយំ ភោជនីយំ ទេតិ មយ្ហំ បរិសតិ វណ្ណំ ភាសថាតិ ។ នដាបិ នដកាបិ លង្ឃកាបិ សោកជ្ឈាយិកាបិ កុម្ភថូណិកាបិ ថុល្លនន្ទាយ ភិក្ខុនិយា បរិសតិ វណ្ណំ ភាសន្តិ អយ្យា ថុល្លនន្ទា ពហុស្សុតា ភាណិកា វិសារទា បដ្ឋា ធម្មឹ កថំ កាតុំ ទេថ អយ្យាយ ករោថ អយ្យាយាតិ ។ យា





(៣១០) កាលដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៥ យ៉ាង) គឺ កាលបើមានសេចក្តីអន្តរាយហើយភិក្ខុនីស្វែងរកគ្នាមិនបាន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិកា ១ ។

---

## ចិត្តាគារវគ្គ សិក្ខាបទទី ៦

[៣១១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីឲ្យខាទនីយភោជនីយាហារដោយដៃខ្លួនឯង ដល់ពួកមេល្ខោនខ្លះ ដល់ពួកកូនល្ខោនខ្លះ ដល់ពួកអ្នកឡើងរ៉ាខ្លះ ដល់ពួកអ្នកបំបាត់សេចក្តីសោក (គឺអ្នកលេងកំប្លែងសើចត្លុក)ខ្លះ ដល់ពួកអ្នកវាយស្គរខ្លះ ដោយពាក្យថា អ្នកទាំងឡាយ ចូរពោលសរសើរគុណយើងក្នុងបរិស័ទផង ។ ពួកមេល្ខោនខ្លះ កូនល្ខោនខ្លះ អ្នកឡើងរ៉ាខ្លះ អ្នកលេងត្លុកកំប្លែងខ្លះ អ្នកលេងស្គរខ្លះ តែងពោលសរសើរគុណថុល្លនន្ទាភិក្ខុនីក្នុងបរិស័ទថា លោកម្ចាស់ថុល្លនន្ទាជាពហុស្សូត ជាអ្នកប្រសប់និយាយ ក្លៀវក្លា ឆ្លាសវាងវៃសំដែងធម្មកថា អ្នកទាំងឡាយចូរឲ្យទានដល់លោកម្ចាស់ចុះ ចូរធ្វើការបូជាដល់លោកម្ចាស់ចុះ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តី

តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អាគារិកស្ស សហត្ថា ខាទនីយំ ភោជនីយំ ទស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាគារិកស្ស សហត្ថា ខាទនីយំ ភោជនីយំ ទេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាគារិកស្ស សហត្ថា ខាទនីយំ ភោជនីយំ ទស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី អាគារិកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទទេយ្យ បាចិត្តិយន្តិ ។

(៣១៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អាគារិកោ នាម យោ កោចិ អគារំ អជ្ឈាវសតិ ។ បរិព្វាជកោ នាម ភិក្ខុញ្ច សាមណេរញ្ច ឋបេត្វា យោ កោចិ បរិព្វាជកសមាបន្នោ ។ បរិព្វាជិកា នាម ភិក្ខុនិញ្ច



ប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា នាងម្ចាស់ថុល្លនន្ទាមិនសមបើនឹងឲ្យខាទនីយភោជនីយាហារដល់គ្រហស្ថដោយដៃខ្លួនឯងសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យខាទនីយភោជនីយាហារ ដល់គ្រហស្ថដោយដៃខ្លួនឯង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងឲ្យខាទនីយភោជនីយាហារដល់គ្រហស្ថដោយដៃខ្លួនឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យខាទនីយៈ ឬភោជនីយៈ ដល់គ្រហស្ថក្តី បរិព្វាជកក្តី បរិព្វាជិកាក្តី ដោយដៃខ្លួនឯង ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៣១៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ បុគ្គលណាមួយនៅគ្រប់គ្រងផ្ទះ បុគ្គលនោះឈ្មោះថាគ្រហស្ថ ។ ជនណាមួយដែលបួសជាបរិព្វាជក លើកទុកតែភិក្ខុនិងសាមណេរចេញ អ្នកនោះហៅថា បរិព្វាជក ។ ស្រី

សិក្ខមានញ្ច សាមណេរិញ្ច ឋបេត្វា យា កាចិ បរិព្វាជិកាសមាបន្នា ។ ខាទនីយំ នាម បញ្ច ភោជនានិ ឧទកទន្តបោណំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ទទេយ្យាតិ កាយេន វា កាយបដិពទ្ធេន វា និស្សគ្គិយេន វា ទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧទកទន្តបោណំ ទេតិ អាបត្តិ ទុក្កដស្ស ។

(២១៣) អនាបត្តិ ទាបេតិ ន ទេតិ ឧបនិក្ខិបិត្វា ទេតិ ពាហិរលេបំ ទេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## ចិត្តាគារវគ្គស្ស សត្តមសិក្ខាបទំ

(២១៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី អាវសថចីវរំ



ណាមួយដែលបួសជាបរិព្វាជិកា លើកទុកតែភិក្ខុនី សិក្ខមានា និងសាមណេរីចេញ ឈ្មោះថា បរិព្វាជិកា ។ ដែលឈ្មោះថា ខាទនីយៈ គឺលើកទុកតែភោជន ៥ យ៉ាង និងទឹកនិងឈើស្ទន់ចេញ ក្រៅ (អំពីនោះ) ហៅថា ខាទនីយៈទាំងអស់ ។ ដែលហៅថា ភោជន បានដល់ភោជន ៥ យ៉ាង គឺបាយ ១ នំកុម្មាស ១ បបរ ១ ត្រី ១ សាច់ ១ ។ ពាក្យថា ឲ្យ គឺភិក្ខុនីឲ្យដោយកាយក្តី ដោយរបស់ជាប់នឹងកាយក្តី ដោយនិស្សគ្គិយក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីឲ្យទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។

(២១៣) ក៏ប៉ុន្តែមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីឲ្យគេឲ្យ មិនបានឲ្យដោយដៃខ្លួនឯង ១ ភិក្ខុនីដាក់ (ទុកពីចាំ) ហើយឲ្យ[១] ១ ភិក្ខុនីឲ្យគ្រឿងលាបកាយខាងក្រៅ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

## ចិត្តាគារវគ្គ សិក្ខាបទទី ៧

(២១៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទា

១ អដ្ឋកថាថា ភិក្ខុនីដាក់ខាទនីយភោជនីយលើផែនដី ហើយឲ្យដោយពាក្យថា យើងឲ្យរបស់នេះដល់អ្នកទាំងឡាយ ។

អនិស្សជ្ជិត្វា បរិភុញ្ជតិ ។ អញ្ញា ឧតុនិយោ ភិក្ខុនិយោ ន លភន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អាវសថចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាវសថចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាវសថចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អាវសថចីវរំ អនិស្សជ្ជិត្វា បរិភុញ្ជេយ្យ បាចិត្តិយន្តិ ។



ភិក្ខុនីមិនលះបង់អាវសថចីវរ[១] (ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់ (តែម្នាក់ឯង) ។ ពួកភិក្ខុនីឯទៀតដែលមានរដូវមិនបាន (ប្រើប្រាស់ផង) ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងមិនលះបង់អាវសថចីវរ(ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់(តែម្នាក់ឯង)សោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីមិនលះបង់អាវសថចីវរ (ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់(តែម្នាក់ឯង) ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងមិនលះបង់អាវសថចីវរ (ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់(តែម្នាក់ឯង)សោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនប្រគល់អាវសថចីវរ ហើយប្រើប្រាស់ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

---

១ ចីវរដែលគេយកទៅទុកនៅទីកន្លែងសម្រាប់ប្រើប្រាស់ ជាសាធារណៈដល់ភិក្ខុនីដែលមានរដូវទាំងអស់គ្នា ។

(៣១៥) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អាវសថចីវរំ នាម ឧតុនិយោ ភិក្ខុនិយោ បរិភុញ្ជន្តូតិ ទិន្នំ ហោតិ ។ អនិស្សជ្ជិត្វា បរិភុញ្ជេយ្យាតិ ទ្វេ តីហំ បរិភុញ្ជិត្វា ចតុត្ថេ ទិវសេ ធោវិត្វា ភិក្ខុនិយា វា សិក្ខមានាយ វា សាមណេរិយា វា អនិស្សជ្ជិត្វា បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។

(៣១៦) អនិស្សដ្ឋេ អនិស្សដ្ឋសញ្ញា បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អនិស្សដ្ឋេ វេមតិកា បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អនិស្សដ្ឋេ និស្សដ្ឋសញ្ញា បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ និស្សដ្ឋេ អនិស្សដ្ឋសញ្ញា អាបត្តិ ទុក្កដស្ស ។ និស្សដ្ឋេ វេមតិកា អាបត្តិ ទុក្កដស្ស ។ និស្សដ្ឋេ និស្សដ្ឋសញ្ញា អនាបត្តិ ។



(៣១៥) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃពួកជ័កកណ្ណរួចហើយ ។ ដែលហៅថា អាវសថចីវរ បានដល់ចីវរដែលគេយកប្រគេនបម្រុងទុកដោយពាក្យថា ភិក្ខុនីទាំងឡាយដែលមានរដូវត្រូវប្រើប្រាស់ចុះ ។ ពាក្យថា មិនប្រគល់ហើយប្រើប្រាស់ គឺភិក្ខុនីប្រើប្រាស់អស់ពីរបីត្រីហើយ ក្នុងថ្ងៃទីបួនលាងហើយមិនប្រគល់ឲ្យដល់ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរីក្តី ហើយប្រើប្រាស់(ម្នាក់ឯង) ត្រូវអាបត្តិបាចិត្តិយ ។

(៣១៦) ចីវរមិនទាន់បានប្រគល់ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រគល់ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរមិនទាន់បានប្រគល់ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរមិនទាន់បានប្រគល់ ភិក្ខុនីសំគាល់ថាប្រគល់ឲ្យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរប្រគល់ឲ្យហើយ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រគល់ ត្រូវអាបត្តិទុក្កដ ។ ចីវរប្រគល់ឲ្យហើយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរប្រគល់ឲ្យហើយ ភិក្ខុនីសំគាល់ថាប្រគល់ឲ្យហើយ មិនត្រូវអាបត្តិ ។

(៣១៧) អនាបត្តិ និស្សជ្ជិត្វា បរិភុញ្ជតិ បុន បរិយាយេន បរិភុញ្ជតិ អញ្ញា ឧតុនិយោ ភិក្ខុនិយោ ន ហោន្តិ អច្ឆិន្នចីវរិកាយ នដ្ឋចីវរិកាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ចិត្តាគារវគ្គស្ស អដ្ឋមសិក្ខាបទំ

(៣១៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី អាវសថំ អនិស្សជ្ជិត្វា ចារិកំ បក្កាមិ ។ តេន ខោ បន សមយេន ថុល្លនន្ទាយ ភិក្ខុនិយា អាវសថោ ឌយ្ហតិ[1] ។ ភិក្ខុនិយោ ឯវមាហំសុ ហន្ទយ្យេ ភណ្ឌកំ នីហរាមាតិ ។ ឯកច្ចា[2] ឯវមាហំសុ ន មយំ អយ្យេ នីហរិស្សាម យំ កិញ្ចិ នដ្ឋំ សព្វំ អម្ហេ អភិយុញ្ជិស្សតីតិ ។

---

១ ឱ ម. ឌយ្ហតិ ។ ២ ឯកច្ចា ភិក្ខុនិយោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



(៣១៧) ភាវៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុនីប្រគល់ឲ្យហើយប្រើប្រាស់ ១ ភិក្ខុនីប្រើប្រាស់តាមវេនជាថ្មីទៀត ១ ពួកភិក្ខុនីឯទៀតដែលមានរដូវក៏មិនមាន (ហើយភិក្ខុនីនោះទេរតែប្រើទៅមិនបានលះ) ១ ភិក្ខុនីដែលចោរដណ្តើមយកចីវរទៅ ១ ភិក្ខុនីដែលមានចីវរវិនាស ១ ភិក្ខុនីប្រើប្រាស់ក្នុងពេលមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## ចិត្តាគារវគ្គ សិក្ខាបទទី ៨

(៣១៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីមិនប្រគល់លំនៅ (ដល់អ្នកដទៃ) ហើយក៏ចៀសទៅកាន់ចារិក ។ ក្នុងសម័យនោះឯង ភ្លើងឆេះលំនៅរបស់ថុល្លនន្ទាភិក្ខុនី (នោះ) ។ ភិក្ខុនីទាំងឡាយពួកខ្លះនិយាយយ៉ាងនេះថា នែនាងម្ចាស់ទាំងឡាយ ណ្ហើយចុះ យើងនឹងជញ្ជូនរបស់ចេញ ។ ភិក្ខុនីទាំងឡាយពួកខ្លះទៀតនិយាយយ៉ាងនេះថា នែនាងម្ចាស់ទាំងឡាយ យើងនឹងមិនជញ្ជូនទេ ព្រោះរបស់ណាមួយបាត់ទៅ ហើយគេនឹងចោទប្រកាន់យើង ចំពោះរបស់ទាំងអស់ ។

ថុល្លនន្ទា ភិក្ខុនី បុនទេវ តំ អាវសថំ បច្ចាគន្ត្វា ភិក្ខុនិយោ បុច្ឆិ អបយ្យេ ភណ្ឌកំ នីហរិត្ថាតិ ។ ន មយំ អយ្យេ នីហរិម្ហាតិ ។ ថុល្លនន្ទា ភិក្ខុនី ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនិយោ អាវសថេ ឌយ្ហមានេ(១) ភណ្ឌកំ ន នីហរិស្សន្តីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អាវសថំ អនិស្សជ្ជិត្វា ចារិកំ បក្កមិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាវសថំ អនិស្សជ្ជិត្វា ចារិកំ បក្កមតីតិ(២) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី អាវសថំ អនិស្សជ្ជិត្វា ចារិកំ បក្កមិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ

១ ម. ឌយ្ហមានេ ។ ២ ឱ. បក្កាមីតិ ។ ម. បក្កាមីតិ ។



ថុល្លនន្ទាភិក្ខុនីត្រឡប់មកកាន់លំនៅនោះវិញទៀត ហើយសួរភិក្ខុនីទាំងឡាយថា នែនាងម្ចាស់ទាំងឡាយ ពួកនាងបានជញ្ជូនរបស់យើងចេញទេឬទេ ។ ពួកភិក្ខុនីទាំងនោះតបថា នែនាងម្ចាស់ ពួកយើងមិនបានជញ្ជូនចេញទេ ។ ថុល្លនន្ទាភិក្ខុនីក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ កាលបើលំនៅត្រូវភ្លើងឆេះ មិនគួរបើនឹងមិនជញ្ជូនរបស់ចេញផងសោះ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងមិនប្រគល់លំនៅ (ឲ្យនៅថែរក្សាសិន) ហើយសំរេចចៀសចេញទៅកាន់ចារិកដូច្នេះ សោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីមិនប្រគល់លំនៅសិន ហើយចៀសចេញទៅកាន់ចារិក ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងមិនប្រគល់លំនៅសិន ហើយចៀសចេញទៅកាន់ចារិកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើង

សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អាវសថំ អនិស្សជ្ជិត្វា ចារិកំ បក្កមេយ្យ បាចិត្តិយន្តិ ។

[៣១៩] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អាវសថោ នាម កវាដពទ្ធោ វុច្ចតិ ។ អនិស្សជ្ជិត្វា ចារិកំ បក្កមេយ្យាតិ ភិក្ខុនិយា វា សិក្ខមានាយ វា សាមណេរិយា វា អនិស្សជ្ជិត្វា បរិក្ខិត្តស្ស អាវសថស្ស បរិក្ខេបំ អតិក្កាមន្តិយា[១] អាបត្តិ បាចិត្តិយស្ស ។ អបរិក្ខិត្តស្ស អាវសថស្ស ឧបចារំ អតិក្កាមន្តិយា អាបត្តិ បាចិត្តិយស្ស ។

[៣២០] អនិស្សដ្ឋេ អនិស្សដ្ឋសញ្ញា បក្កមតិ អាបត្តិ បាចិត្តិយស្ស ។ អនិស្សដ្ឋេ វេមតិកា បក្កមតិ អាបត្តិ បាចិត្តិយស្ស ។ អនិស្សដ្ឋេ និស្សដ្ឋសញ្ញា បក្កមតិ អាបត្តិ បាចិត្តិយស្ស ។ អកវាដពទ្ធំ អនិស្សជ្ជិត្វា បក្កមតិ អាបត្តិ ទុក្កដស្ស ។

---

១ ម. ឧ. អតិក្កមន្តិយា ។



នូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនប្រគល់លំនៅ ហើយចៀសចេញទៅកាន់ចារិក ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៣១៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយដូចសិក្ខាបទទី ១ នៃចិត្តាគារវគ្គរួចហើយ ។ ដែលហៅថា លំនៅ សំដៅយកលំនៅដែលមានសន្ទះទ្វារជាប់ ។ ពាក្យថា មិនប្រគល់ហើយចៀសចេញទៅកាន់ចារិក សេចក្ដីថា ភិក្ខុនីមិនប្រគល់ដល់ភិក្ខុនីក្ដី សិក្ខមានាក្ដី សាមណេរីក្ដី ហើយឈានកន្លងរបងនៃលំនៅដែលមានរបង ត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុនីឈានកន្លងឧបចារនៃលំនៅដែលមិនមានរបង ក៏ត្រូវអាបត្តិបាចិត្តិយ ។

[៣២០] លំនៅដែលខ្លួនមិនបានប្រគល់ ភិក្ខុនីសំគាល់ថាមិនបានប្រគល់ឲ្យ ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ លំនៅដែលខ្លួនមិនបានប្រគល់ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ លំនៅដែលខ្លួនមិនបានប្រគល់ ភិក្ខុនីសំគាល់ថាប្រគល់ហើយ ក៏ចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនប្រគល់លំនៅដែលគ្មានសន្ទះទ្វារជាប់ ហើយចៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។

និស្សដ្ឋេ អនិស្សដ្ឋសញ្ញា អាបត្តិ ទុក្កដស្ស ។ និស្សដ្ឋេ វេមតិកា អាបត្តិ ទុក្កដស្ស ។ និស្សដ្ឋេ និស្សដ្ឋសញ្ញា អនាបត្តិ ។

(៣៦១) អនាបត្តិ និស្សជ្ជិត្វា បច្ចាមតិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ចិត្តាគារវគ្គស្ស នវមសិក្ខាបទំ

(៣៦២) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ តិរច្ឆានវិជ្ជំ បរិយាបុណន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ តិរច្ឆានវិជ្ជំ បរិយាបុណិស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ



សំពត់ដែលខ្លួនប្រគល់ហើយ ភិក្ខុនីសំគាល់ថាមិនទាន់ប្រគល់ ត្រូវអាបត្តិទុក្កដ ។ សំពត់ដែលខ្លួនប្រគល់ហើយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សំពត់ដែលខ្លួនប្រគល់ហើយ ភិក្ខុនីសំគាល់ថាប្រគល់ហើយ មិនត្រូវអាបត្តិ ។

(៣៦១) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦ យ៉ាង) គឺភិក្ខុនីប្រគល់ហើយទើបទៀសបញ្ចេញទៅ ១ កាលបើមានសេចក្តីអន្តរាយ ភិក្ខុនីកំបញ្ចេញទៅស្វែងរក (គ្មានទីប្រគល់ឲ្យទៅ) មិនបាន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយហើយកំបញ្ចេញទៅ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## ចិត្តាគារវគ្គ សិក្ខាបទទី៩

(៣៦២) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនីរៀនតិរច្ឆានវិជ្ជា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងរៀនតិរច្ឆានវិជ្ជាដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមគុណ ។ ពួកភិក្ខុនីបានឮមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមាន

អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ
ហិ នាម ឆព្ពគ្គិយា ភិក្ខុនិយោ តិរច្ឆានវិជ្ជំ បរិយាបុណិ-
ស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្ពគ្គិយា ភិក្ខុនិយោ
តិរច្ឆានវិជ្ជំ បរិយាបុណន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ
ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្ពគ្គិយា ភិក្ខុ-
និយោ តិរច្ឆានវិជ្ជំ បរិយាបុណិស្សន្តិ នេតំ ភិក្ខវេ អ-
ប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ
ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនី
តិរច្ឆានវិជ្ជំ បរិយាបុណេយ្យ បាចិត្តិយន្តិ ។

(៣៤៣) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុ-
នីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុ-
នីតិ ។ តិរច្ឆានវិជ្ជា នាម យង្កិញ្ចិ ពាហិរកំ អនត្ថ-
សញ្ហិតំ ។ បរិយាបុណេយ្យាតិ បទេន បរិយាបុណាតិ
បទេ បទេ អាបត្តិ បាចិត្តិយស្ស ។ អក្ខរាយ បរិយាបុ-
ណាតិ អក្ខរក្ខរាយ អាបត្តិ បាចិត្តិយស្ស ។



សេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល
បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនីមិនសមបើនឹងរៀនតិរច្ឆានវិជ្ជាសោះ ។បេ។
ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយាភិក្ខុនីរៀនតិរច្ឆាន-
វិជ្ជា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ
ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុ
ទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនីមិនគួរនឹងរៀនតិរច្ឆានវិជ្ជាទេ ម្នាលភិក្ខុ
ទាំងឡាយ អំពើនុ៎ះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា
ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវ
សិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយរៀនតិរច្ឆានវិជ្ជា ភិក្ខុនីនោះ ត្រូវ
អាបត្តិបាចិត្តិយ ។

(៣៤៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុង
សិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ចំណេះណាមួយជាខាងក្រៅ
ដែលមិនប្រកបដោយប្រយោជន៍ ចំណេះនោះឈ្មោះថា តិរច្ឆានវិជ្ជា ។
ពាក្យថា រៀន សេចក្តីថា ភិក្ខុនីរៀនដោយបទ ត្រូវអាបត្តិបាចិត្តិយ
គ្រប់ៗបទ ។ (បើ) រៀនដោយអក្សរ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗអក្សរ ។

[៣៦៦] អនាបត្តិ លេខំ បរិយាបុណាតិ ធារណំ បរិយាបុណាតិ គុត្តត្ថាយ បរិត្តំ បរិយាបុណាតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ចិត្តាគារវគ្គស្ស ទសមសិក្ខាបទំ

[៣៦៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ តិរច្ឆានវិជ្ជំ វាចេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ តិរច្ឆានវិជ្ជំ វាចេស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ តិរច្ឆានវិជ្ជំ វាចេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ



[៣៦៦] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីរៀនសរសេរអក្សរ ១ ភិក្ខុនីរៀនធារណសាស្ត្រ[១] ១ ភិក្ខុនីរៀនវិជ្ជាការពារខ្លួនសម្រាប់រក្សា (ខ្លួន) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## ចិត្តាគារវគ្គ សិក្ខាបទទី ១០

[៣៦៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងបង្រៀនតិរច្ឆានវិជ្ជាដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមសោះ ។ ភិក្ខុនីបានឮសំឡេងពាក្យមនុស្សទាំងឡាយកំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនីមិនសមបើនឹងបង្រៀនតិរច្ឆានវិជ្ជាសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួក

---

១. គឺភិក្ខុនីរៀនគម្ពីរវេទ ៣ ជាដើម ដើម្បីឲ្យចេះស្ទាត់នូវវិជ្ជាក្នុងគម្ពីរនោះៗ ។

ឆព្វគ្គិយា ភិក្ខុនិយោ តិរច្ឆានវិជ្ជំ វាចេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ តិរច្ឆានវិជ្ជំ វាចេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី តិរច្ឆានវិជ្ជំ វាចេយ្យ បាចិត្តិយន្តិ ។

(៣៦៦) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ តិរច្ឆានវិជ្ជា នាម យំកិញ្ចិ ពាហិរកំ អនត្ថសញ្ហិតំ ។ វាចេយ្យាតិ បទេន វាចេតិ បទេ បទេ អាបត្តិ បាចិត្តិយស្ស ។ អក្ខរាយ វាចេតិ អក្ខរក្ខរាយ អាបត្តិ បាចិត្តិយស្ស ។

(៣៦៧) អនាបត្តិ លេខំ វាចេតិ ធារណំ វាចេតិ គុត្តត្ថាយ បរិត្តំ វាចេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

ចិត្តាគារវគ្គោ បញ្ចមោ ។





ឆព្វគ្គិយាភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនីមិនគួរនឹងបង្រៀនតិរច្ឆានវិជ្ជាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយបង្រៀនតិរច្ឆានវិជ្ជា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៣៦៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ចំណេះណាមួយខាងក្រៅដែលមិនប្រកបដោយប្រយោជន៍ ចំណេះនោះឈ្មោះថា តិរច្ឆានវិជ្ជា ។ ពាក្យថា បង្រៀន គឺភិក្ខុនីបង្រៀនដោយបទ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗបទ ។ បង្រៀនដោយអក្សរ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗអក្សរ ។

[៣៦៧] ភិក្ខុនីដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីបង្រៀនសរសេរ១ ភិក្ខុនីបង្រៀនធារណសាស្ត្រ១ ភិក្ខុនីបង្រៀនវិជ្ជាការពារខ្លួនដើម្បីរក្សា(ខ្លួន)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាអាទិកម្មិក១ ។

ចិត្តាគារវគ្គទី ៥ ចប់ ។

# អារាមវគ្គស្ស បឋមសិក្ខាបទំ

(៣៦៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ គាមកាវាសេ ឯកចីវរា ចីវរកម្មំ ករោន្តិ ។ ភិក្ខុនិយោ អនាបុច្ឆា អារាមំ បវិសិត្វា យេន តេ ភិក្ខូ តេនុបសង្កមឹសុ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អនាបុច្ឆា អារាមំ បវិសិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អនាបុច្ឆា អារាមំ បវិសន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អនាបុច្ឆា អារាមំ បវិសិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អនាបុច្ឆា អារាមំ បវិសេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

# អារាមវគ្គ សិក្ខាបទទី ១

(៣៦៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប ទ្រទ្រង់នូវតែចីវរមួយៗ ម្នាក់ហើយធ្វើចីវរកម្ម (ដេរស្បង់ជាដើម) ក្នុងអាវាសដែលតាំងនៅជិតស្រុកតូចមួយ ។ ភិក្ខុនីទាំងឡាយមិនបានប្រាប់ហើយចូលទៅកាន់អារាម រួចចូលទៅរកភិក្ខុទាំងឡាយនោះ ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងមិនប្រាប់ (ជាមុន) ហើយចូលមកកាន់អារាមសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមិនប្រាប់ ហើយចូលទៅកាន់អារាម ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងមិនប្រាប់ហើយចូលទៅកាន់អារាមទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនបានប្រាប់ ហើយចូលទៅកាន់អារាម ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុនីទាំងឡាយយ៉ាងនេះហើយ ។

(៣៦៩) តេន ខោ បន សមយេន តេ ភិក្ខូ តម្ហា អាវាសា បក្កមឹសុ ។ ភិក្ខុនិយោ អយ្យា បក្កន្តាតិ អារាមំ នាគមឹសុ ។ អថខោ តេ ភិក្ខូ បុនទេវ តំ អាវាសំ បច្ចាគច្ឆឹសុ ។ ភិក្ខុនិយោ អយ្យា អាគតាតិ អាបុច្ឆា អារាមំ បវិសិត្វា យេន តេ ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា តេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ភិក្ខុនិយោ តេ ភិក្ខូ ឯតទវោចុំ កិស្ស តុម្ហេ ភគិនិយោ អារាមំ នេវ សម្មជ្ជិត្ថ ន បានីយំ បរិភោជនីយំ ឧបដ្ឋាបិត្ថាតិ(១) ។ ភគវតា អយ្យា សិក្ខាបទំ បញ្ញត្តំ ន អនាបុច្ឆា អារាមោ បវិសិតព្វោតិ តេន មយំ នាគមិម្ហាតិ(២) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សន្តំ ភិក្ខុំ អាបុច្ឆា អារាមំ បវិសិតុំ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី សន្តំ

១ ម. ឧ. ឧបដ្ឋាបិតន្តិ ។ ២ ម. ឧ. អាគមិម្ហាតិ ។



(៣៦៩) សម័យនោះឯង ភិក្ខុទាំងឡាយនោះចៀសចេញទៅចាកអាវាសនោះហើយ ។ ភិក្ខុនីទាំងឡាយមិនបានមកកាន់អារាមដោយគិតថា លោកម្ចាស់ទាំងឡាយចៀសចេញទៅហើយ ។ គ្រានោះឯង ភិក្ខុទាំងឡាយនោះត្រឡប់មកកាន់អាវាសនោះវិញទៀត ។ ភិក្ខុនីទាំងឡាយដឹងថា លោកម្ចាស់ទាំងឡាយមកដល់ហើយ ក៏ប្រាប់ហើយចូលទៅកាន់អារាមសំដៅទៅរកភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំភិក្ខុទាំងឡាយនោះហើយឈរនៅក្នុងទីគួរមួយ ។ លុះភិក្ខុនីទាំងនោះឈរនៅក្នុងទីគួរមួយហើយ ភិក្ខុទាំងឡាយនោះក៏និយាយពាក្យនេះថា នែនាងទាំងឡាយ ហេតុអ្វីក៏នាងទាំងឡាយមិនបោសអារាម មិនដាក់តាំងទុកទឹកផឹកទឹកប្រើប្រាស់ ។ ភិក្ខុនីទាំងឡាយនិយាយថា បពិត្រលោកម្ចាស់ទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទហើយថា ភិក្ខុនីមិនបានប្រាប់ មិនត្រូវចូលទៅកាន់អារាមឡើយ ហេតុនោះ (បានជា) យើងខ្ញុំទាំងឡាយមិនបានមក ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាមបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ

ភិក្ខុំ អនាបុច្ឆា អារាមំ បវិសេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣៣០] តេន ខោ បន សមយេន តេ ភិក្ខូ តម្ហា អាវាសា បក្កមិត្វា បុន តំ អាវាសំ បច្ចាគច្ឆិំសុ ។ ភិក្ខុនិយោ អយ្យា បក្កន្តាតិ អនាបុច្ឆា អារាមំ បវិសិំសុ ។ តាសំ កុក្កុច្ចំ អហោសិ ភគវតា សិក្ខាបទំ បញ្ញត្តំ ន សភិក្ខុកំ អនាបុច្ឆា អារាមោ បវិសិតព្វោតិ មយំ ច សភិក្ខុកំ អនាបុច្ឆា អារាមំ បវិសិម្ហា កច្ចិ នុ ខោ មយំ បាចិត្តិយំ អាបត្តិំ អាបន្នាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ជានំ សភិក្ខុកំ អារាមំ អនាបុច្ឆា បវិសេយ្យ បាចិត្តិយន្តិ ។

[៣៣១] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មិំ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ជានំ នាម សាមំ វា ជានាតិ អញ្ញេ វា



មិនបានប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាម ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តដល់ពួកភិក្ខុនីយ៉ាងនេះរួចហើយ ។

(៣៣០) គ្រាសម័យនោះឯង ភិក្ខុទាំងឡាយនោះចេញចាកអាវាសនោះ ហើយត្រឡប់មកកាន់អាវាសនោះវិញទៀត ។ ភិក្ខុនីទាំងឡាយដឹងថា លោកម្ចាស់ទាំងឡាយចៀសចេញទៅហើយក៏មិនបានប្រាប់ ហើយចូលទៅកាន់អារាម ។ ភិក្ខុនីទាំងឡាយនោះមានសេចក្តីរង្កៀសថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទហើយថា ភិក្ខុនីមិនទាន់បានប្រាប់ភិក្ខុដែលមាននៅ ហើយមិនត្រូវចូលទៅកាន់អារាមឡើយ ឯយើងទាំងឡាយមិនបានប្រាប់ភិក្ខុដែលមាននៅហើយចូលទៅកាន់អារាម យើងទាំងឡាយត្រូវអាបត្តិបាចិត្តិយដែរឬហ្ន៎ ។ ភិក្ខុនីទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយកាលដឹងហើយមិនបានប្រាប់ភិក្ខុដែលមាននៅហើយចូលទៅកាន់អារាម ត្រូវអាបត្តិបាចិត្តិយ ។

(៣៣១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបាចិត្តិកកណ្ឌរួចហើយ ។ ដែលឈ្មោះថា ភិក្ខុនីកាលដឹង (នោះ) គឺភិក្ខុនីដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ភិក្ខុនីនោះក្តី ពួកភិក្ខុ

តស្ស អារោចេត្វា វេ វា អារោចេត្វា ។ អភិក្ខុកោ នាម អារាមោ យត្ថ ភិក្ខូ រុក្ខមូលេបិ វសន្តិ ។ អនាបុច្ឆា គាមំ បវិសេយ្យាតិ ភិក្ខុំ វា សាមណេរំ វា អារាមិកំ វា អនាបុច្ឆា បរិក្ខិត្តស្ស គាមស្ស បរិក្ខេបំ អតិក្កមន្តស្ស អាបត្តិ បាចិត្តិយស្ស ។ អបរិក្ខិត្តស្ស គាមស្ស ឧបចារំ ឱក្កមន្តស្ស អាបត្តិ បាចិត្តិយស្ស ។

[៣៣៦] សភិក្ខុកេ សភិក្ខុកសញ្ញី សន្តំ ភិក្ខុំ អនាបុច្ឆា គាមំ បវិសតិ អាបត្តិ បាចិត្តិយស្ស ។ សភិក្ខុកេ វេមតិកោ សន្តំ ភិក្ខុំ អនាបុច្ឆា គាមំ បវិសតិ អាបត្តិ ទុក្កដស្ស ។ សភិក្ខុកេ អភិក្ខុកសញ្ញី សន្តំ ភិក្ខុំ អនាបុច្ឆា គាមំ បវិសតិ អនាបត្តិ ។ អភិក្ខុកេ សភិក្ខុកសញ្ញី អាបត្តិ ទុក្កដស្ស ។ អភិក្ខុកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អភិក្ខុកេ អភិក្ខុកសញ្ញី អនាបត្តិ ។



ដែលនៅគង់ការាមនោះ ប្រាប់ក្តី ។ ភិក្ខុចាំងឆ្ងាយទៅក្នុងទីណា សូម្បីក្រោមម្លប់ឈើ ទីនោះ (ក៏) ឈ្មោះថា គ្មានភិក្ខុ ។ ពាក្យថា ភិក្ខុមិនបានប្រាប់ហើយចូលទៅកាន់ស្រុក សេចក្តីថា ភិក្ខុមិនប្រាប់ភិក្ខុក្តី សាមណេរក្តី ក្មេងវត្តក្តី ហើយឈានកន្លងរបងស្រុកដែលមានរបង ត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុចូលទៅដល់ឧបចារស្រុកដែលគ្មានរបង ក៏ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៦] អារាមដែលមានភិក្ខុ ភិក្ខុសំគាល់ថាមានភិក្ខុ មិនបានប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយ ។ អារាមដែលមានភិក្ខុ ភិក្ខុមានសេចក្តីសង្ស័យ មិនប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់ស្រុក ត្រូវអាបត្តិទុក្កដ ។ អារាមដែលមានភិក្ខុ ភិក្ខុសំគាល់ថាមិនមានភិក្ខុ មិនបានប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់ស្រុក មិនត្រូវអាបត្តិ ។ អារាមដែលមិនមានភិក្ខុ ភិក្ខុសំគាល់ថាមានភិក្ខុ ត្រូវអាបត្តិទុក្កដ ។ អារាមដែលមិនមានភិក្ខុ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អារាមដែលមិនមានភិក្ខុ ភិក្ខុសំគាល់ថាមិនមានភិក្ខុ មិនត្រូវអាបត្តិ ។

(៣៣៣) អនាបត្តិ សន្តំ ភិក្ខុំ អាបុច្ឆា បវិសតិ អសន្តំ ភិក្ខុំ អនាបុច្ឆា បវិសតិ សីសានុលោកិកា គច្ឆតិ យត្ថ ភិក្ខុនិយោ សន្និបតិតា ហោន្តិ តត្ថ គច្ឆតិ អារាមេន មគ្គោ ហោតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អារាមវគ្គស្ស ទុតិយសិក្ខាបទំ

(៣៣៤) តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន អាយស្មតោ ឧបាលិស្ស ឧបជ្ឈាយោ អាយស្មា កប្បិតកោ សុសានេ វិហរតិ ។ តេន ខោ បន សមយេន ឆព្វគ្គិយានំ ភិក្ខុនីនំ មហត្តរា(១) ភិក្ខុនី កាលកតា ហោតិ ។ ឆព្វគ្គិយា ភិក្ខុនិយោ តំ ភិក្ខុនឹ នីហរិត្វា អាយស្មតោ កប្បិតកស្ស វិហារស្ស អវិទូរេ ឈាបេត្វា ថូបំ ការេត្វា គន្ត្វា តស្មឹ ថូបេ រោទន្តិ ។ អថខោ អាយស្មា កប្បិតកោ តេន សទ្ទេន ឧព្ពាឡ្ហោ

១ ម.ឆ. មហល្លកា ។



(៣៣៣) អំពើដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺភិក្ខុនីប្រាប់ភិក្ខុដែលមាននៅហើយទើបចូលទៅ១ ភិក្ខុនីមិនប្រាប់ព្រោះគ្មានភិក្ខុហើយចូលទៅ១ ភិក្ខុនីដែលក្រឡេកមើលឃើញសិស (ភិក្ខុនីដែលចូលទៅមុន) ហើយទើបទៅ១ ពួកភិក្ខុនីប្រជុំនៅក្នុងទីណា ភិក្ខុនីនោះក៏ទៅក្នុងទីនោះ១ ភិក្ខុនីដើរតាមផ្លូវដែលមានក្នុងវត្ត១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាអាទិកម្មិក១ ។

---

## អារាមវគ្គ សិក្ខាបទទី ២

(៣៣៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងកូដាគារសាលាក្នុងព្រៃមហាវន ទៀបក្រុងវេសាលី ។ គ្រានោះឯង ព្រះកប្បិតកៈដ៏មានអាយុជាឧបជ្ឈាយ៍នៃព្រះឧបាលិដ៏មានអាយុគង់នៅក្នុងព្រៃស្មសាន ។ សម័យនោះឯង ភិក្ខុនីដែលចាស់ជាងពួកឆព្វគ្គិយាភិក្ខុនីធ្វើមរណកាល ។ ពួកឆព្វគ្គិយាភិក្ខុនីនាំភិក្ខុនីនោះទៅ ហើយដុតភិក្ខុនីនោះក្នុងទីមិនឆ្ងាយពីកុដិព្រះកប្បិតកៈដ៏មានអាយុ ហើយធ្វើស្តូប (ចេតិយ) ហើយនាំគ្នាទៅយំជិតស្តូបនោះ ។ គ្រានោះឯង ព្រះកប្បិតកៈដ៏មានអាយុធុញទ្រាន់នឹងសំឡេងនោះ

តំ ថូបំ ភិន្ទិត្វា វិប្បកិរេសិ[១] ។ ឆព្វគ្គិយា ភិក្ខុនិយោ ឥមិនា កប្បិតកេន អម្ហាកំ អយ្យាយ ថូបោ ភិន្នោ ហន្ទ នំ ឃាតេមាតិ មន្តេសុំ ។ អញ្ញតរា ភិក្ខុនី អាយស្មតោ ឧបាលិស្ស ឯតមត្ថំ អារោចេសិ ។ អាយស្មា ឧបាលិ អាយស្មតោ កប្បិតកស្ស ឯតមត្ថំ អារោចេសិ ។ អថខោ អាយស្មា កប្បិតកោ វិហារា និក្ខមិត្វា និលីនោ អច្ឆិ ។ អថខោ ឆព្វគ្គិយា ភិក្ខុនិយោ យេនាយស្មតោ កប្បិតកស្ស វិហារោ តេនុប-សង្កមិំសុ ឧបសង្កមិត្វា អាយស្មតោ កប្បិតកស្ស វិហារំ បាសាណេហិ ច លេឌ្ឌូហិ ច ឱត្ថរាបេត្វា មតោ កប្បិតកោតិ បក្កមិំសុ ។ អថខោ អាយស្មា កប្បិត-កោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវា-សេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ អទ្ទសំសុ ខោ ឆព្វគ្គិយា ភិក្ខុនិយោ អាយស្មន្តំ កប្បិ-តកំ បិណ្ឌាយ ចរន្តំ ទិស្វាន ឯវមាហំសុ អយំ កប្បិ-តកោ ជីវតិ កោ នុ ខោ អម្ហាកំ មន្តំ សំហរីតិ ។

១ ឱ, ម. បកិរេសិ ។



ទំលាយស្តូបនោះឲ្យខ្ចាត់ខ្ចាយចេញ ។ ពួកឆព្វគ្គិយាភិក្ខុនីប្រឹក្សាគ្នាថា លោកកប្បិតកៈនេះទំលាយស្តូបភិក្ខុនីជាម្ចាស់របស់យើង បើដូច្នោះមានតែយើងនឹងសម្លាប់លោកកប្បិតកៈនោះ ។ ភិក្ខុនី១រូបក្រាបទូលរឿងនុ៎ះដល់ព្រះឧបាលិដ៏មានអាយុ ។ ព្រះឧបាលិដ៏មានអាយុក្រាបទូលរឿងនុ៎ះដល់ព្រះកប្បិតកៈដ៏មានអាយុ ។ លំដាប់នោះឯង ព្រះកប្បិតកៈដ៏មានអាយុចេញអំពីវិហារទៅពួន ។ ឯពួកឆព្វគ្គិយាភិក្ខុនីចូលដម្រង់ទៅឯលំនៅព្រះកប្បិតកដ៏មានអាយុ លុះចូលទៅហើយក៏ចោលកុដិព្រះកប្បិតកដ៏មានអាយុដោយដុំថ្មផងដោយដុំដីផង ហើយក៏ចៀសចេញទៅដោយគិតថា លោកកប្បិតកស្លាប់ហើយ ។ លំដាប់នោះឯង ព្រះកប្បិតកៈដ៏មានអាយុលុះកន្លងរាត្រីនោះក៏ស្លៀកហើយប្រដាប់បាត្រនិងចីវរក្នុងវេលាព្រឹកព្រហាម ហើយចូលទៅកាន់ក្រុងវេសាលីដើម្បីបិណ្ឌបាត ។ ពួកឆព្វគ្គិយាភិក្ខុនីបានឃើញលោកកប្បិតកៈដ៏មានអាយុកំពុងត្រាច់ទៅបិណ្ឌបាត លុះឃើញហើយបាននិយាយយ៉ាងនេះថា លោកកប្បិតកៈនេះនៅរស់ (ទេតើ) អ្នកណាហ្ន៎ានាំសេចក្តីប្រឹក្សា (គាថិកម្ចាំង) យើងទៅ (ប្រាប់លោក) ។ ពួកឆព្វគ្គិយា

អស្សោសុំ ខោ ឆព្វគ្គិយា ភិក្ខុនិយោ អយ្យេន កិរ ឧបាលិនា អម្ហាកំ អយ្យោ សំហរាបិតោតិ ។ តា អាយស្មន្តំ ឧបាលឹ អក្កោសិំសុ កថំ ហិ នាម អយំ កាសាវដោ មលមជ្ជនោ និហីនជច្ចោ អម្ហាកំ មត្តំ សំហរាបេស្សតីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ អយ្យំ ឧបាលឹ អក្កោសិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឧបាលឹ អក្កោសន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឧបាលឹ អក្កោសិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី ភិក្ខុំ អក្កោសេយ្យ វា បរិភាសេយ្យ វា បាចិត្តិយន្តិ ។

[៣៣៨] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុន្តិ ឧបសម្បន្នំ ។ អក្កោសេយ្យាតិ ទសហិ វា



ភិក្ខុនីបានឮពួកផ្សេងថា ដំណឹងថា លោកម្ចាស់ឧបាលិនាំសេចក្តីប្រែក្បាលយើងទៅប្រាប់ ។ ពួកឆព្វគ្គិយាភិក្ខុនីទាំងនោះក៏នាំគ្នាជេរព្រះឧបាលិដ៏មានអាយុថា លោកអ្នកកាត់ព្រះកេសនេះជាអ្នកដុសក្អែល (១) មានជាតិដ៏ថោកទាប មិនសមបើនឹងនាំយកសេចក្តីប្រែក្បាលរបស់យើងទៅប្រាប់សោះ ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនីមិនសមបើនឹងមកនាំគ្នាជេរលោកម្ចាស់ឧបាលិសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយាភិក្ខុនីជេរឧបាលិ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនីមិនគួរបើនឹងជេរឧបាលិទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយជេរគំរាមភិក្ខុ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៣៣៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌនោះហើយ ។ ពាក្យថា ភិក្ខុ បានដល់ឧបសម្បន្ន ។ ពាក្យថា ជេរ គឺភិក្ខុនីជេរដោយអក្កោសវត្ថុទាំង ១០ មួយណា

អក្កោសវត្ថូហិ អក្កោសតិ ឯតេសំ វា អញ្ញតរេន អាបត្តិ បាចិត្តិយស្ស ។ បរិភាសេយ្យ វាតិ ភយំ ឧបទំសេតិ អាបត្តិ បាចិត្តិយស្ស ។

(៣៣៦) ឧបសម្បន្នេ ឧបសម្បន្នសញ្ញា អក្កោសតិ វា បរិភាសតិ វា អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកា អក្កោសតិ វា បរិភាសតិ វា អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញា អក្កោសតិ វា បរិភាសតិ វា អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នំ អក្កោសតិ វា បរិភាសតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញា អាបត្តិ ទុក្កដស្ស ។

(៣៣៧) អនាបត្តិ អត្ថបុរេក្ខារាយ ធម្មបុរេក្ខារាយ អនុសាសនីបុរេក្ខារាយ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។





អក្កោសវត្ថុទាំង ១០ នោះ ដោយអក្កោសវត្ថុណាមួយ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា គំរាម គឺភិក្ខុនីសំដែងសេចក្ដីខ្លាច ត្រូវអាបត្តិបាចិត្តិយ ។

(៣៣៦) ឧបសម្បន្ន ភិក្ខុនីសំគាល់ថាឧបសម្បន្ន ហើយជេរក្ដី គំរាមក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយជេរក្ដី គំរាមក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុនីសំគាល់ថាមិនមែនឧបសម្បន្ន ហើយជេរក្ដី គំរាមក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីជេរក្ដី គំរាមក្ដី នូវអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៣៣៧) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីធ្វើអត្ថឲ្យជាប្រធាន ១ ធ្វើធម៌ឲ្យជាប្រធាន ១ ធ្វើពាក្យប្រៀនប្រដៅឲ្យជាប្រធាន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

# អារាមវគ្គស្ស តតិយសិក្ខាបទំ

[៣៣៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ចណ្ឌកាលី ភិក្ខុនី ភណ្ឌនការិកា ហោតិ កលហការិកា វិវាទការិកា ភស្សការិកា សង្ឃេ អធិករណការិកា ។ ថុល្លនន្ទា ភិក្ខុនី តស្សា កម្មេ កយិរមានេ[១] បដិក្កោសតិ ។

[៣៣៩] តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី គាមកំ អគមាសិ កេនចិទេវ ករណីយេន ។ អថខោ ភិក្ខុនីសង្ឃោ ថុល្លនន្ទា ភិក្ខុនី បក្កន្តាតិ ចណ្ឌកាលឹ ភិក្ខុនឹ អាបត្តិយា អទស្សនេ ឧក្ខិបិ ។ ថុល្លនន្ទា ភិក្ខុនី គាមកេ តំ ករណីយំ តីរេត្វា បុនទេវ សាវត្ថឹ បច្ចាគញ្ឆិ ។ ចណ្ឌកាលី ភិក្ខុនី ថុល្លនន្ទាយ ភិក្ខុនិយា អាគច្ឆន្តិយា នេវ អាសនំ បញ្ញបេសិ ន បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិ

---

១ ម. ករិយមានេ ។

# អារាមវគ្គ សិក្ខាបទទី ៣

(៣៣៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនីជាអ្នកធ្វើសេចក្តីបង្កហេតុ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីទាស់ទែង ធ្វើពាក្យរកគ្នា ជាអ្នកបង្កើតអធិករណ៍ក្នុងសង្ឃ ។ កាលសង្ឃកំពុងធ្វើកម្មដល់ចណ្ឌកាលីភិក្ខុនីនោះ ថុល្លនន្ទាភិក្ខុនីក៏ហាមឃាត់ ។

(៣៣៩) គ្រានោះឯង ថុល្លនន្ទាភិក្ខុនីបានទៅកាន់ស្រុកតូច(មួយ) ដោយកិច្ចនីមួយ ។ ទើបភិក្ខុនីសង្ឃដឹងថា ថុល្លនន្ទាភិក្ខុនីចៀសចេញទៅហើយ ក៏លើកវត្តចំពោះចណ្ឌកាលីភិក្ខុនី ព្រោះសេចក្តីមិនឃើញអាបត្តិ ។ ថុល្លនន្ទាភិក្ខុនីសម្រេចកិច្ចនោះក្នុងស្រុកតូចហើយក៏ត្រឡប់មកក្រុងសាវត្ថីវិញទៀត ។ ចណ្ឌកាលីភិក្ខុនីកាលដែលថុល្លនន្ទាភិក្ខុនីមក ក៏មិនក្រាលអាសនៈមិនដម្កល់ទឹកលាងជើងតាំងជើងទ្រនាប់ជើងជ្រញាត់លាងជើង មិនក្រោកទទួល

ន បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសិ ន បានីយេន អាបុច្ឆិ ។ ថុល្លនន្ទា ភិក្ខុនី ចណ្ឌកាលឹ ភិក្ខុនឹ ឯតទវោច កិស្ស ត្វំ អយ្យេ មយិ អាគច្ឆន្តិយា នេវ អាសនា វុដ្ឋាសិ ន បាទោទកំ បាទបីឋំ បាទកឋលិកំ និក្ខិបិ ន បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសិ ន បានីយេន អាបុច្ឆីតិ ។ ឯវំ ហិ បនាហំ អយ្យេ ករោមិ យថា តំ អនាថាយាតិ ។ កិស្ស បន ត្វំ អយ្យេ អនាថាតិ ។ ឥមា មំ អយ្យេ ភិក្ខុនិយោ អយំ អនាថា អប្បញ្ញាតា នត្ថិ ឥមិស្សា កាចិ បដិវត្តាតិ អាបត្តិយា អទស្សនេ ឧក្ខិបឹសូតិ ។ ថុល្លនន្ទា ភិក្ខុនី ពាលា ឯតា អព្យត្តា ឯតា នេតា ជានន្តិ កម្មំ វា កម្មទោសំ វា កម្មវិបត្តឹ វា កម្មសម្បត្តឹ វាតិ កុបិតា អនត្តមនា គណំ បរិភាសិ[1] ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា កុបិតា អនត្តមនា គណំ បរិភាសិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី កុបិតា អនត្តមនា គណំ បរិភាសតីតិ[2] ។ សច្ចំ

១-២ ឱ. ម. បរិភាសិ ។



បាត្រចីវរមិនសួរនាំដោយទឹកផឹក ។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងចណ្ឌកាលីភិក្ខុនីថា នែនាងម្ចាស់ កាលបើយើងមកដល់ហេតុអ្វីក៏នាងមិនក្រោកអាសនៈ មិនផ្តល់ទឹកលាងជើង ជើងតាំងសម្រាប់ដាក់ជើង ជ្រញាំជើង មិនក្រោកទទួលបាត្រចីវរមិនសួរនាំដោយទឹកផឹកសោះ ។ ចណ្ឌកាលីភិក្ខុនីនិយាយថា នែនាងម្ចាស់ បានជាខ្ញុំមិនធ្វើកិច្ចតាំងអម្បាលនេះ ព្រោះខ្ញុំជាស្រីអនាថា ។ ថុល្លនន្ទាភិក្ខុនីសួរថា នែនាងម្ចាស់ នាងជាស្រីអនាថា ព្រោះហេតុអ្វី ។ ចណ្ឌកាលីភិក្ខុនីនិយាយថា នែនាងម្ចាស់ ភិក្ខុនីអស់នេះលើកវត្តចំពោះខ្ញុំ ព្រោះមិនឃើញអាបត្តិដោយគិតខ្លាថា ភិក្ខុនីនេះជាស្រីអនាថាគ្មានអ្នកណាស្គាល់ គ្មានអ្នកណាមួយនោះពោលការក្រើដល់ភិក្ខុនីនេះទេ ។ ថុល្លនន្ទាភិក្ខុនីនិយាយថា ពួកភិក្ខុនីអស់នុះល្ងង់ ពួកភិក្ខុនីអម្បាលនុះមិនឆ្លាស ពួកភិក្ខុនីទាំងនុះមិនស្គាល់កម្ម ទោសរបស់កម្ម កម្មវិបត្តិ កម្មសម្បត្តិទេ ហើយក៏ផ្តាសាគណភិក្ខុនីដោយសេចក្តីក្រោធ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា នាងម្ចាស់ថុល្លនន្ទាមិនសមបើនឹងផ្តាសាគណភិក្ខុនីដោយសេចក្តីក្រោធសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីផ្តាសាគណភិក្ខុនីដោយសេចក្តីក្រោធ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាប

ភគវតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី ចណ្ឌីកតា គណំ បរិភាសិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី ចណ្ឌីកតា គណំ បរិភាសេយ្យ បាចិត្តិយន្តិ ។

(៣៤០) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ចណ្ឌីកតា នាម កោធនា វុច្ចតិ ។ គណោ នាម ភិក្ខុនីសង្ឃោ វុច្ចតិ ។ បរិភាសេយ្យាតិ ពាលា ឯតា អព្យត្តា ឯតា នេតា ជានន្តិ កម្មំ វា កម្មទោសំ វា កម្មវិបត្តឹ វា កម្មសម្បត្តឹ វាតិ បរិភាសតិ អាបត្តិ បាចិត្តិយស្ស ។ សម្ពហុលា ភិក្ខុនិយោ វា ឯកភិក្ខុនឹ វា អនុបសម្បន្នំ វា បរិភាសតិ អាបត្តិ ទុក្កដស្ស ។

(៣៤១) អនាបត្តិ អត្ថបុរេក្ខារាយ ធម្មបុរេក្ខារាយ អនុសាសនីបុរេក្ខារាយ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនគួរបើនឹងផ្តាសាគណភិក្ខុនីដោយសេចក្តីកំណាចទេ ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយផ្តាសាគណភិក្ខុនីដោយសេចក្តីកំណាច ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៤០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌហើយ ។ ដែលហៅថា កំណាច សំដៅយកសេចក្តីក្រោធ ។ ដែលហៅថា គណភិក្ខុនី សំដៅយកភិក្ខុនីសង្ឃ ។ ពាក្យថា ផ្តាសា គឺភិក្ខុនីផ្តាសាថា ភិក្ខុនីអស់នុ៎ះល្ងង់ ភិក្ខុនីអស់នុ៎ះមិនឆ្លាស ពួកភិក្ខុនីទាំងនុ៎ះមិនស្គាល់កម្ម ទោសរបស់កម្ម កម្មវិបត្តិ កម្មសម្បត្តិដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីផ្តាសាភិក្ខុនីច្រើនរូប មួយរូប អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៣៤១) អនាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីធ្វើអត្ថជាប្រធាន ១ ធ្វើធម៌ជាប្រធាន ១ ធ្វើពាក្យប្រៀនប្រដៅ

## ភោជនវគ្គស្ស បញ្ចមសិក្ខាបទំ

[៣៤៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ព្រាហ្មណោ ភិក្ខូ និមន្តេត្វា ភោជេសិ ។ ភិក្ខូ ភុត្តាវី បវារិតា ញាតិកុលានិ គន្ត្វា ឯកច្ចេ ភុញ្ជឹសុ ឯកច្ចេ បិណ្ឌបាតំ អាទាយ អគមំសុ ។ អថខោ សោ ព្រាហ្មណោ បដិវិស្សកេ ឯតទវោច ភិក្ខូ មយា អយ្យា សន្តប្បិតា ឯថ តុម្ហេបិ សន្តប្បេស្សាមីតិ ។ តេ ឯវមាហំសុ កឹ ត្វំ អយ្យ(១) អម្ហេ សន្តប្បេស្សសិ យេបិ តយា និមន្តិតា តេបិ អម្ហាកំ ឃរានិ អាគន្ត្វា ឯកច្ចេ ភុញ្ជឹសុ ឯកច្ចេ បិណ្ឌបាតំ អាទាយ អគមំសូតិ ។ អថខោ សោ ព្រាហ្មណោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខូ អម្ហាកំ ឃរេ ភុញ្ជិត្វា អញ្ញត្រ ភុញ្ជិស្សន្តិ ន ចាហំ បដិពលោ យាវទត្ថំ ទាតុន្តិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស

---

១ ឱ. ម. អយ្យោ ។

## ភោជនវគ្គ សិក្ខាបទទី ៥

(៣៤៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់និមន្តពួកភិក្ខុឲ្យឆាន់ ។ ពួកភិក្ខុឆាន់ហើយហាមភត្តហើយ ក៏ទៅកាន់ត្រកូលជាញាតិទាំងឡាយ ហើយភិក្ខុពួកខ្លះឆាន់ (ទៀត) ពួកខ្លះ (គ្រាន់តែ) នាំយកបិណ្ឌបាតទៅ ។ គ្រានោះឯង ព្រាហ្មណ៍នោះបាននិយាយពាក្យនេះនឹងពួកមនុស្សដែលស្និទ្ធស្នាលថា នែអ្នកម្ចាស់ទាំងឡាយ ខ្ញុំបានប្រគេនចង្ហាន់ពួកភិក្ខុឲ្យឆាន់បរិបូណ៌ហើយ ចូរអ្នកទាំងឡាយមកចុះ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឆ្អែតស្កប់ស្កល់ទៀត ។ ពួកមនុស្សទាំងនោះបាននិយាយពាក្យយ៉ាងនេះថា នែអ្នកម្ចាស់ អ្នកនឹងឲ្យពួកយើងឆ្អែតស្កប់ស្កល់ដូចម្ដេច ពួកភិក្ខុឯណាដែលអ្នកនិមន្ត ពួកភិក្ខុនោះមកផ្ទះរបស់យើងហើយ ពួកខ្លះក៏ឆាន់ ពួកខ្លះក៏នាំយកចង្ហាន់បិណ្ឌបាតទៅហើយ ។ ទើបព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុមិនសមបើនឹងឆាន់ក្នុងផ្ទះយើងរួចហើយ (ទៅ) ឆាន់ក្នុងផ្ទះដទៃ (ទៀត) សោះ ព្រោះថាខ្ញុំមិនអាចឲ្យ (លោកឆាន់) ឆ្អែតបរិបូណ៌បាន ។ ភិក្ខុទាំងឡាយបានឮព្រាហ្មណ៍

ព្រាហ្មណស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ភុត្តាវី បវារិតា អញ្ញត្រ ភុញ្ជិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ភុត្តាវី បវារិតា អញ្ញត្រ ភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ភុត្តាវី បវារិតា អញ្ញត្រ ភុញ្ជិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី និមន្តិតា វា បវារិតា វា ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយន្តិ ។

(៣៦៣) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ និមន្តិតា នាម បញ្ចន្នំ ភោជនានំ អញ្ញតរេន ភោជនេន និមន្តិតា ។ បវារិតា នាម អសនំ បញ្ញាយតិ ភោជនំ



នោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយឆាន់ហើយ ហាមភត្តហើយមិនសមបើនឹង (ទៅ) ឆាន់ក្នុងទីដទៃ (ទៀត) សោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឆាន់ហើយហាមភត្តហើយ (ទៅ) ឆាន់ក្នុងទីដទៃ (ទៀត) ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយឆាន់ហើយហាមភត្តហើយមិនគួរបើនឹងឆាន់ក្នុងទីដទៃ (ទៀត) ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយដែលគេនិមន្តហើយក្តី ហាមភត្តហើយក្តី ទំពាស៊ីក្តី ឆាន់ក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ ។

(៣៦៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបាចកដ៏កកណ្ឌដូចហើយ ។ ភិក្ខុនីដែលឈ្មោះថា គេនិមន្ត គឺភិក្ខុនីដែលគេនិមន្ត បណ្តាភោជន៥ យ៉ាង ដោយភោជនណាមួយ ។ ភិក្ខុនីដែលឈ្មោះថា ហាមភត្ត គឺកិរិយាឆាន់ក៏ប្រាកដ ភោជនក៏ប្រាកដ

បញ្ញាយតិ ហត្ថបាសេ ឋិតោ អភិហរតិ បដិក្ខេបោ បញ្ញាយតិ ។ ខាទនីយំ នាម បញ្ច ភោជនានិ យាគុំ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

(៣៤៤) និមន្តិតេ និមន្តិតសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ និមន្តិតេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ និមន្តិតេ អនិមន្តិតសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។



ភិក្ខុឈរក្នុងហត្ថបាស ទាយកបង្អោនបរិភោគមកចំពោះមុខ ភិក្ខុហាមឃាត់ប្រាកដ ។ ភក្សដែលឈ្មោះថា ខាទនីយៈ គឺលើកលែងតែភោជន ៥ យាគូ យាមកាលិក សត្តាហកាលិក យាវជីវិកចេញ ក្រៅពីនោះ ឈ្មោះថា ខាទនីយទាំងអស់ ។ ដែលហៅថា ភោជនីយ បានដល់ភោជន ៥ យ៉ាង គឺបាយ នំកុម្មាស សត្តុ ត្រី សាច់ ។ ភិក្ខុទទួលដោយគិតថា អញនឹងទំពាស៊ី នឹងឆាន់ភោជនផង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗ កះដែលលេបចូលទៅ ។

[៣៤៤] ខ្លួនគេនិមន្តហើយ ភិក្ខុសំគាល់ថានិមន្តហើយ ទំពាស៊ី ឬបរិភោគ នូវខាទនីយក្តី ភោជនីយក្តី ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនគេនិមន្តហើយ ភិក្ខុសង្ស័យ ហើយទំពាស៊ី ឬបរិភោគ នូវខាទនីយក្តី ភោជនីយក្តី ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនគេនិមន្តហើយ ភិក្ខុសំគាល់ថា មិនបានគេនិមន្ត ហើយទំពាស៊ី ឬបរិភោគ នូវខាទនីយក្តី ភោជនីយក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលយាមកាលិក សត្តាហកាលិក យាវជីវិក ប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ គ្រប់ៗ កះដែលលេបចូលទៅ ។

(៣៦៤) អនាបត្តិ អនិមន្តិតា អប្បវារិតា យាគុំ បិវតិ សាមិកេ អបលោកេត្វា ភុញ្ជតិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អារាមវគ្គស្ស បញ្ចមសិក្ខាបទំ

(៣៦៥) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី សាវត្ថិយំ អញ្ញតរិស្សា វីថិយា បិណ្ឌាយ ចរមានា យេន អញ្ញតរំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ តេ មនុស្សា តំ ភិក្ខុនឹ ភោជេត្វា ឯតទវោចុំ អញ្ញាបិ អយ្យេ ភិក្ខុនិយោ អាគច្ឆន្តូតិ ។ អថខោ សា ភិក្ខុនី កថំ អញ្ញា ភិក្ខុនិយោ នាគច្ឆេយ្យុន្តិ ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោច អមុកស្មឹ អយ្យេ ឱកាសេ ភយា សុនខា



(៣៦៤) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុនីដែលគេមិននិមន្ត ១ ភិក្ខុនីមិនបានហាមភត្ត ១ ភិក្ខុនីផឹកបបរ ១ ភិក្ខុនីប្រាប់ម្ចាស់ផ្ទះហើយទើបបរិភោគ ១ កាលបើមានបច្ច័យ (មានហេតុ) ភិក្ខុនីបរិភោគយាមកាលិក សត្តាហកាលិក ឬយាវជីវិក ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

---

## អារាមវគ្គ សិក្ខាបទទី ៥

(៣៦៥) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីមួយរូប ត្រាច់ទៅបិណ្ឌបាតតាមច្រកល្ហក ១ ក្នុងក្រុងសាវត្ថី ចូលទៅកាន់ត្រកូល ១ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុកហើយ ។ លំដាប់នោះឯង ពួកមនុស្សទាំងនោះអង្គាសភិក្ខុនីនោះឆាន់ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយសូម្បីដទៃ ក៏និមន្តមកចុះ ។ ទើបភិក្ខុនីនោះគិតថា ធ្វើដូចម្តេច កុំឲ្យភិក្ខុនីទាំងឡាយដទៃមកបានផង ហើយក៏ចូលទៅរកភិក្ខុនីទាំងឡាយ រួចបាននិយាយពាក្យនេះថា នែនាងម្ចាស់ ក្នុងទីឯណោះមានឆ្កែសាហាវ មានគោកាច មានកន្លែងផុក

ចណ្ឌោ ពលិពទ្ទោ ចិក្ខល្លោ ឱកាសោ មា ឯត្ថ អគមិត្ថាតិ ។ អញ្ញតរា ភិក្ខុនី តស្សា វិសិខាយ បិណ្ឌាយ ចរមានា យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ តេ មនុស្សា តំ ភិក្ខុនឹ ឯតទវោចុំ កិស្ស អយ្យេ ភិក្ខុនិយោ ន អាគច្ឆន្តីតិ ។ អថខោ សា ភិក្ខុនី តេសំ មនុស្សានំ ឯតមត្ថំ អារោចេសិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី កុលំ មច្ឆរាយិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី កុលំ មច្ឆរាយតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី កុលំ មច្ឆរាយិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី កុលមច្ឆរិនី អស្ស បាចិត្តិយន្តិ ។



នាងទាំងឡាយកុំទៅកាន់ទីនោះឡើយ ។ ភិក្ខុនីមួយរូបទៀតត្រូវទៅបិណ្ឌបាតកាន់ច្រកផ្លូវនោះ ចូលទៅកាន់ត្រកូលនោះ លុះចូលទៅដល់ហើយក៏អង្គុយលើអាសនៈដែលគេតាំងទុកហើយ ។ ទើបមនុស្សទាំងឡាយនោះទៀបភិក្ខុនីនោះទាន់ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ ហេតុអ្វីក៏ភិក្ខុនីទាំងឡាយមិនមក ។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុ៎ះដល់មនុស្សទាំងនោះ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងប្រព្រឹត្តកំណាញ់ត្រកូលសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីប្រព្រឹត្តកំណាញ់ត្រកូល ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនគួរបើនឹងប្រព្រឹត្តកំណាញ់ត្រកូលទេ ម្នាលភិក្ខុទាំងឡាយ អាការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមានសេចក្តីកំណាញ់ត្រកូល ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៣៤៧] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណកុលំ វេស្សកុលំ សុទ្ទកុលំ ។ មច្ឆរិនី អស្សាតិ កថំ ភិក្ខុនិយោ នាគច្ឆេយ្យុន្តិ ភិក្ខុនីនំ សន្តិកេ កុលស្ស អវណ្ណំ ភាសតិ អាបត្តិ បាចិត្តិយស្ស ។ កុលស្ស វា សន្តិកេ ភិក្ខុនីនំ អវណ្ណំ ភាសតិ អាបត្តិ បាចិត្តិយស្ស ។

[៣៤៨] អនាបត្តិ[១] ន មច្ឆរាយន្តី សន្តំយេវ អាទីនវំ អាចិក្ខតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អារាមវគ្គស្ស ឆដ្ឋសិក្ខាបទំ

[៣៤៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខុនិយោ គាមកាវាសេ វស្សំ វុត្ថា សាវត្ថឹ អគមំសុ ។ ភិក្ខុនិយោ តា ភិក្ខុនិយោ

១ ម. អនាបត្តិ កុលំ ន មច្ឆរាយន្តី ។

៣០៦



[៣៤៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា ត្រកូល បានដល់ត្រកូល ៤ យ៉ាងគឺត្រកូលក្សត្រិយ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលអ្នកជំនួញអ្នកធ្វើស្រែចំការ ១ ត្រកូលអ្នកស៊ីឈ្នួល ១ ។ ពាក្យថា មានសេចក្តីកំណាញ់ គឺភិក្ខុនីពោលទោសត្រកូលក្នុងសំណាក់ភិក្ខុនីទាំងឡាយដោយគិតថា ធ្វើដូចម្តេចកុំឲ្យភិក្ខុនីទាំងឡាយមកបានដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ។ ឬភិក្ខុនីពោលទោសភិក្ខុនីទាំងឡាយក្នុងសំណាក់ត្រកូល ក៏ត្រូវអាបត្តិបាចិត្តិយ ។

[៣៤៨] ករៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីមិនប្រព្រឹត្តកំណាញ់ ១ ភិក្ខុនីប្រាប់ទោសដែលមានពិត ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិកបុគ្គល ១ ។

---

## អារាមវគ្គ សិក្ខាបទទី ៦

[៣៤៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីច្រើនរូបនៅចាំវស្សាក្នុងអាវាសដែលតាំងនៅក្នុងស្រុកស្រែ ហើយបាននាំគ្នាទៅកាន់ក្រុងសាវត្ថី ។ ភិក្ខុនីទាំងឡាយ (ឯទៀត) បាននិយាយពាក្យនេះនឹង

ឯតទវោចុំ កត្ថាយ្យាយោ វស្សំ វុត្ថា កច្ចិ ឱវាទោ ឥទ្ធោ អហោសីតិ ។ នត្ថយ្យេ តត្ថ ភិក្ខូ កុតោ ឱវាទោ ឥទ្ធោ ភវិស្សតីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អភិក្ខុកេ អាវាសេ វស្សំ វសិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អភិក្ខុកេ អាវាសេ វស្សំ វសន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អភិក្ខុកេ អាវាសេ វស្សំ វសិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី អភិក្ខុកេ អាវាសេ វស្សំ វសេយ្យ បាចិត្តិយន្តិ ។





ភិក្ខុនីទាំងនោះថា លោកម្ចាស់ទាំងឡាយចាំវស្សាក្នុងទីណា ការឱវាទបានសម្រេចដែរឬ(១) ។ ភិក្ខុនីទាំងឡាយនោះនិយាយថា នែនាងម្ចាស់ ក្នុងទីនោះភិក្ខុទាំងឡាយគ្មានទេ ការឱវាទនឹងបានសម្រេចពីណា ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងនៅចាំវស្សាក្នុងអាវាសគ្មានភិក្ខុសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយនៅចាំវស្សាក្នុងអាវាសមិនមានភិក្ខុ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនពួកដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយនៅចាំវស្សាក្នុងអាវាសឥតភិក្ខុ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

---

១ អដ្ឋកថា ថា ឥទ្ធោ ដែលប្រកបដោយប្រយោជន៍ទាំងឡាយ ... ន: ពោលថា ប្រកបដោយសេចក្តីព្រមព្រៀងនូវលក្ខណៈ ។

[៣៨០] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អភិក្ខុកោ នាម អាវាសោ ន សក្កា ហោតិ ឱវាទាយ វា សំវាសាយ វា គន្តុំ ។ វស្សំ វសិស្សាមីតិ សេនាសនំ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋាបេតិ បរិវេណំ សម្មជ្ជតិ អាបត្តិ ទុក្កដស្ស ។ សហ អរុណុគ្គមនា អាបត្តិ បាចិត្តិយស្ស ។

[៣៨១] អនាបត្តិ វស្សូបគតា ភិក្ខូ បក្កន្តា វា ហោន្តិ វិព្ភន្តា វា កាលកតា វា បក្ខសង្កន្តា វា អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អារាមវគ្គស្ស សត្តមសិក្ខាបទំ

[៣៨២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខុនិយោ គាមកា-វាសេ វស្សំ វុដ្ឋា សាវត្ថឹ អគមំសុ ។ ភិក្ខុនិយោ តា



[៣៨០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីពិស្តារដូចក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ ។ អាវាសដែលភិក្ខុមិនអាចនឹងទៅ ឲ្យឱវាទក្តី នៅរួមក្តី ឈ្មោះថា អាវាសឥតភិក្ខុ ។ ភិក្ខុនីតាំងចិត្តថា អញនឹងនៅចាំវស្សាក្នុងទីនេះ ហើយក្រាលសេនាសនៈ ដម្កល់ទឹកផឹកទឹកប្រើ-ប្រាស់ បោសព្រែងទីបរិវេណ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ព្រមគ្នានឹងអរុណរះឡើង ។

[៣៨១] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុចាំវស្សាហើយចៀសចេញទៅក្តី សឹកទៅក្តី ស្លាប់ក្តី ចូលពួក(គឺទៅចូលសាសនាដទៃ)ក្តី ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

---

## អារាមវគ្គ សិក្ខាបទទី ៧

[៣៨២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីច្រើនរូប នៅចាំវស្សាក្នុងអាវាសដែលតាំងនៅក្នុងស្រុកក្រៅ ហើយមកដល់ទៅកាន់ក្រុងសាវត្ថី ។ ភិក្ខុនីទាំងឡាយជាអ្នកនិយាយពាក្យនេះទៅនឹងភិក្ខុនីទាំងឡាយនោះ

ភិក្ខុនិយោ ឯតទវោចុំ អាយ្យាយោ វស្សំវុត្ថា ភិក្ខូ[1] ភិក្ខុសង្ឃំ បវារេថាតិ ។ ន មយំ អយ្យេ ភិក្ខុសង្ឃំ បវារេមាតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ ប ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ វស្សំវុត្ថា ភិក្ខុសង្ឃំ ន បវារេស្សន្តីតិ ។ ប ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ វស្សំវុត្ថា ភិក្ខុសង្ឃំ ន បវារេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ វស្សំវុត្ថា ភិក្ខុសង្ឃំ ន បវារេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ ប ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី វស្សំវុត្ថា ឧភតោសង្ឃេ តីហិ ឋានេហិ ន បវារេយ្យ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា បាចិត្តិយន្តិ ។

---

១ ឱ. ម. ភិក្ខូតិ ន ទិស្សតិ ។



ថា នាងម្ចាស់ទាំងឡាយនៅចាំវស្សារួចហើយ ហើយបវារណាទីនឹងភិក្ខុ-សង្ឃវិញចុះ ។ ភិក្ខុនីទាំងឡាយនោះនិយាយថា ខែនាងម្ចាស់ ពួកយើងមិនទាន់បវារណាទីនឹងភិក្ខុសង្ឃទេ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រា-ថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយនៅចាំវស្សាហើយ មិនសមទីនឹងបវារណាទីនឹងភិក្ខុសង្ឃសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយនៅចាំវស្សាហើយមិនបវារណាទីនឹងភិក្ខុសង្ឃ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយនៅចាំវស្សាហើយមិនគួរបើនឹងមិនបវារណាទីនឹងភិក្ខុសង្ឃទេ ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយនៅចាំវស្សាហើយមិនបវារណាទីនឹងឧភតោសង្ឃ ដោយស្ថាន៣យ៉ាង គឺដោយឃើញក្ដី ដោយឮក្ដី ដោយរង្កៀសក្ដី ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៩៣) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ វស្សំ វុត្ថា នាម បុរិមំ វា តេមាសំ បច្ឆិមំ វា តេមាសំ វុត្ថា ។ ឯកកោសម្បិ ទ្វីហិ ហាទេហិ ចារិកំ បក្កមិស្សាមិ ធំវេ្ទន វា សុទេន វា បរិសក្កិយ វា ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

(៣៩៤) អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អារាមវគ្គស្ស អដ្ឋមសិក្ខាបទំ

(៣៩៥) តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ឆព្ពគ្គិយា ភិក្ខុនិយោ ឱវទន្តិ ។ ភិក្ខុនិយោ ឆព្ពគ្គិយា ភិក្ខុនិយោ ឯតទវោចុំ ឯថយ្យេ ឱវាទំ គមិស្សាមាតិ ។



(៣៩៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយដូចសិក្ខាបទទី១នៃឧទ្ទេសកណ្ឌរួចហើយ ។ ភិក្ខុនីនៅរស់ត្រីមាសខាងដើមក្ដី នៅរស់ត្រីមាសខាងចុងក្ដី ឈ្មោះថា នៅចាំវស្សាហើយ ។ ភិក្ខុនីក្រាន់តែដាក់ធុរៈថា អញនឹងមិនចៀសទៅណា ទី៥ ឬ ៦ ដោយសន្សំយោជន៍ គឺដោយយោជន៍ក្ដី ដោយពីរក្ដី ដោយកន្លៀសក្ដី ត្រូវអាបត្តិបាចិត្តិយ ។

(៣៩៤) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីមានសេចក្ដីអន្តរាយ ហើយស្វែងរក (ភិក្ខុនីសង្ឃ)មិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាអាទិកម្មិក១ ។

---

## អារាមវគ្គ សិក្ខាបទទី៨

(៣៩៥) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុចូលទៅកាន់លំនៅភិក្ខុនី ហើយទូន្មានពួកឆព្វគ្គិយាភិក្ខុនី ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងពួកឆព្វគ្គិយាភិក្ខុនីថា នែលោកម្ចាស់ទាំងឡាយ ចូរលោកទាំងឡាយមក ពួកយើងនឹងទៅ(ស្ដាប់)ឱវាទ ។

យម្បិ(១) មយំ អយ្យេ គច្ឆេយ្យាម ឱវាទស្ស ការណា អយ្យា ឆព្ពគ្គិយា ឥធេវ អាគន្ត្វា អម្ហេ ឱវទន្តីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខុនិយោ ឱវាទំ ន គច្ឆិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្ពគ្គិយា ភិក្ខុនិយោ ឱវាទំ ន គច្ឆន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្ពគ្គិយា ភិក្ខុនិយោ ឱវាទំ ន គច្ឆិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី ឱវាទាយ វា សំវាសាយ វា ន គច្ឆេយ្យ បាចិត្តិយន្តិ ។

(៣៥២) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឱវាទោ នាម អដ្ឋ គរុធម្មា ។ សំវាសោ នាម

១ ឱ. ម. យម្ហិ ។



ពួកឆព្វគ្គិយាភិក្ខុនីទាំងឡាយថា នែលោកម្ចាស់ទាំងឡាយ ពួកយើងមិនគួរទៅដោយហេតុនៃឱវាទទេ ព្រោះលោកម្ចាស់ឆព្វគ្គិយទាំងឡាយ តែងមកឲ្យឱវាទយើងក្នុងទីនេះឯង ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងមិនទៅកាន់ទីស្ដាប់ឱវាទសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីមិនទៅកាន់ទីស្ដាប់ឱវាទ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងមិនទៅកាន់ទីស្ដាប់ឱវាទ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនទៅដើម្បីឱវាទក្ដី ដើម្បីនៅរួមសំវាសក្ដី ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៥២) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយដូចក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ គរុធម៌ទាំង ៨ ឈ្មោះថាឱវាទ ។

ឯកកម្មំ ឯកុទ្ទេសោ សមសិក្ខតា ។ ឱវាទាយ វា សំវាសាយ វា ន គច្ឆិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៨៧] អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ទុតិយិកំ ភិក្ខុនឹ ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## អារាមវគ្គស្ស នវមសិក្ខាបទំ

[៣៨៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ឧបោសថម្បិ ន បុច្ឆន្តិ ឱវាទម្បិ ន យាចន្តិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឧបោសថម្បិ ន បុច្ឆិស្សន្តិ ឱវាទម្បិ ន យាចិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ឧបោសថម្បិ ន បុច្ឆន្តិ ឱវាទម្បិ ន យាចន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា



កម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សេចក្តីសិក្សាស្មើគ្នា ឈ្មោះថានៅរួម ។ ភិក្ខុនីត្រាន់តែដាក់ធុរៈថា អញនឹងមិនទៅដើម្បីឱវាទក្តី ដើម្បីនៅរួមក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៣៨៧] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីមានសេចក្តីអន្តរាយ ហើយស្វែងរកភិក្ខុនីជាគំរប់ពីរមិនបាន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## អារាមវគ្គ សិក្ខាបទទី ៩

(៣៨៨) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយមិនសួរឧបោសថផង មិនសូមឱវាទផង ។ ភិក្ខុទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងមិនសួរឧបោសថផង មិនសូមឱវាទផងដូច្នេះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមិនសួរឧបោសថផង មិនសូមឱវាទផង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី

កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ឧបោសថំបិ ន បុច្ឆិស្សន្តិ ឱវាទំបិ ន យាចិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ អន្វឌ្ឍមាសំ(១) ភិក្ខុនិយា ភិក្ខុសង្ឃតោ ទ្វេ ធម្មា បច្ចាសីសិតព្វា ឧបោសថបុច្ឆកញ្ច ឱវាទុបសង្កមនញ្ច តំ អតិក្កាមេន្តិយា បាចិត្តិយន្តិ ។

[៣៥៩] អន្វឌ្ឍមាសន្តិ អនុបោសថិកំ ។ ឧបោសថោ នាម ទ្វេ ឧបោសថា ចាតុទ្ទសិកោ ច បណ្ណរសិកោ ច ។ ឱវាទោ នាម អដ្ឋ គរុធម្មា ។ ឧបោសថំបិ ន បុច្ឆិស្សាមិ ឱវាទំបិ ន យាចិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៦០] អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

១ ឱ. ម. ពោត្ថកេសុ អយំ បាឋោ ន ហោតិ ។



ទាំងឡាយមិនសួរចំពោះនឹងមិនសួរឧបោសថផង មិនសូមឱវាទផងដែរ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរយ៉ាងអំពីភិក្ខុសង្ឃ គឺសួរឧបោសថ ១ ចូលទៅទទួលឱវាទ ១ រាល់ៗ កន្លះខែ កាលភិក្ខុនីឲ្យកន្លងកន្លះខែនោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

(៣៥៩) ត្រង់ពាក្យថា រាល់ៗ កន្លះខែ គឺត្រូវថ្ងៃឧបោសថ ។ ឧបោសថពីរយ៉ាង គឺឧបោសថក្នុងថ្ងៃទី ១៤ មួយ ឧបោសថក្នុងថ្ងៃទី ១៥ មួយ ឈ្មោះថា ថ្ងៃឧបោសថ ។ គរុធម៌ ៨ ឈ្មោះថា ឱវាទ ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អាត្មាអញមិនសួរឧបោសថផង មិនសូមឱវាទផង ត្រូវអាបត្តិបាចិត្តិយ ។

(៣៦០) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុនីមានសេចក្តីអន្តរាយហើយស្វែងរកភិក្ខុនីជាគ្នាប៉ុន្តែមិនបាន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## អារាមវគ្គស្ស ទសមសិក្ខាបទំ

[៣៦១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី បសាខេ ជាតំ គណ្ឌំ បុរិសេន សទ្ធិំ ឯកេនេកា ភេទាបេសិ ។ អថខោ សោ បុរិសោ តំ ភិក្ខុនឹ ទូសេតុំ ឧបក្កមិ ។ សា ភិក្ខុនី(១) វិស្សរមកាសិ ។ ភិក្ខុនិយោ ឧបធាវិត្វា តំ ភិក្ខុនឹ ឯតទវោចុំ កិស្ស ត្វំ អយ្យេ វិស្សរមកាសីតិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី បសាខេ ជាតំ គណ្ឌំ បុរិសេន សទ្ធិំ ឯកេនេកា ភេទាបេស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី បសាខេ ជាតំ គណ្ឌំ បុរិសេន សទ្ធិំ ឯកេនេកា ភេទាបេតីតិ(២) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី បសាខេ ជាតំ គណ្ឌំ បុរិសេន

---

១ ម. ភិក្ខុនីតិ នត្ថិ ។ ២ ម. ភេទាបេសីតិ ។

## អារាមវគ្គ សិក្ខាបទទី ១០

[៣៦១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនី ១ រូប តែម្នាក់ឯងម្នាក់ជាមួយនឹងបុរស ឲ្យគេទំលាយពកបូសដែលកើតត្រង់កាយខាងក្រោម ។ គ្រានោះឯង បុរសនោះព្យាយាមដើម្បីប្រទូស្ត នឹងភិក្ខុនីនោះ ។ ភិក្ខុនីនោះបានបន្លឺសំរែកខ្លាំង ។ ភិក្ខុនីទាំងឡាយ ក៏ស្ទុះចូលទៅ ហើយនិយាយពាក្យនេះនឹងភិក្ខុនីនោះថា នែលោកម្ចាស់ ហេតុអ្វីក៏នាងបន្លឺសំរែកខ្លាំងដូច្នេះ ។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុ៎ះ ដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះតែងពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីតែម្នាក់ឯងម្នាក់ជាមួយនឹងបុរស មិនសមបើនឹងឲ្យទំលាយពកបូស ដែលកើតត្រង់កាយខាងក្រោមសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីតែម្នាក់ឯងម្នាក់ជាមួយនឹងបុរសឲ្យទំលាយ ពកបូសដែលកើតត្រង់កាយខាងក្រោម ពិតមែនឬ ។ ភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីតែម្នាក់ឯងម្នាក់ជាមួយនឹងបុរស

សទ្ធឹ ឯកេនេកា ភេទាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី បសាខេ ជាតំ គណ្ឌំ វា រូហិតំ[១] វា អនបលោកេត្វា សង្ឃំ វា គណំ វា បុរិសេន សទ្ធឹ ឯកេនេកា ភេទាបេយ្យ វា ផាលាបេយ្យ វា ធោវាបេយ្យ វា អាលិម្បាបេយ្យ វា ពន្ធាបេយ្យ វា មោចាបេយ្យ វា បាចិត្តិយន្តិ ។

[៣៦៤] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បសាខំ នាម អធោនាភិ ឧព្ភជាណុមណ្ឌលំ ។ ជាតន្តិ តត្ថ ជាតំ ។ គណ្ឌោ នាម យោ កោចិ គណ្ឌោ ។ រូហិតំ នាម យំ កិញ្ចិ វណំ[២] ។ អនបលោកេត្វាតិ អនាបុច្ឆា ។ សង្ឃោ នាម ភិក្ខុនីសង្ឃោ វុច្ចតិ ។ គណោ នាម សម្ពហុលា ភិក្ខុនិយោ វុច្ចន្តិ ។ បុរិសោ នាម មនុស្សបុរិសោ ន យក្ខោ ន បេតោ ន តិរច្ឆានគតោ

១. រូហិតំ ។ ម. រុធិតំ ។ ២. ម. យង្កិញ្ចិ វណោ ។ យោ កោចិ វណោតិ បាឋេន ភវិតព្វំ ។



មិនគួរបើនឹងឲ្យទំលាយគណ្ឌឬបូសដែលកើតត្រង់កាយខាងក្រោមទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនបានប្រាប់សង្ឃក្តី គណៈក្តី ហើយនៅម្នាក់ឯងនឹងម្នាក់ឯងជាមួយនឹងបុរសឲ្យទំលាយក្តី វះក្តី លាងក្តី លាបក្តី ចងក្តី ស្រាយក្តី នូវគណ្ឌក្តី បូសក្តី ដែលកើតត្រង់កាយខាងក្រោម ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៦៤) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ សរីរប្រទេសខាងក្រោមត្រឹមផ្ចិតចុះទៅ ខាងលើត្រឹមមណ្ឌលជង្គង់ឡើងមក ហៅថា កាយខាងក្រោម ។ ពាក្យថា កើត គឺកើតក្នុងទីក្រោមផ្ចិតខាងលើមណ្ឌលជង្គង់នោះ ។ ដែលហៅថា គណ្ឌឬបូស គឺគណ្ឌឬបូសណាមួយ ។ ដែលហៅថា បូស គឺដំបៅណាមួយ ។ ពាក្យថា មិនប្រាប់ គឺមិនពិគ្រោះ ។ ដែលហៅថា សង្ឃ (ក្នុងទីនេះ) សំដៅយកភិក្ខុនីសង្ឃ ។ ដែលហៅថា គណៈ សំដៅយកភិក្ខុនីច្រើនរូប (ពីរបីរូប) ។ ដែលហៅថា បុរស គឺមនុស្សប្រុសដែលដឹងក្តី អាចប្រព្រឹត្តបាន មិនមែនយក្សប្រុស ប្រេតប្រុស តិរច្ឆានឈ្មោលទេ ។

វិញ្ញូ បដិពលោ ទូសេតុំ ។ សទ្ធិន្តិ ឯកតោ ។ ឯកេនេកាតិ បុរិសោ ចេវ ហោតិ ភិក្ខុនី ច ។ ភិន្ទាតិ អាណាបេតិ អាបត្តិ ទុក្កដស្ស ភិន្នេ អាបត្តិ បាចិត្តិយស្ស ។ ផាលេហីតិ អាណាបេតិ អាបត្តិ ទុក្កដស្ស ផាលិតេ អាបត្តិ បាចិត្តិយស្ស ។ ធោវាតិ អាណាបេតិ អាបត្តិ ទុក្កដស្ស ធោតេ អាបត្តិ បាចិត្តិយស្ស ។ អាលិម្បាតិ អាណាបេតិ អាបត្តិ ទុក្កដស្ស អាលិត្តេ(១) អាបត្តិ បាចិត្តិយស្ស ។ ពន្ធាតិ អាណាបេតិ អាបត្តិ ទុក្កដស្ស ពទ្ធេ អាបត្តិ បាចិត្តិយស្ស ។ មោចេហីតិ អាណាបេតិ អាបត្តិ ទុក្កដស្ស មុត្តេ អាបត្តិ បាចិត្តិយស្ស ។

(៣៦៣) អនាបត្តិ អបលោកេត្វា ភេទាបេតិ វា ផាលាបេតិ វា ធោវាបេតិ វា អាលិម្បាបេតិ វា ពន្ធាបេតិ វា មោចាបេតិ វា យា កាចិ វិញ្ញូ ទុតិយា(២) ហោតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

សិក្ខាបទំ ឆដ្ឋំ ។

១ ម.ឆ. លិត្តេ ។ ២ ម.ឆ. យោ កោចិ វិញ្ញូ ទុតិយោ ។



ពាក្យថា ជាមួយ គឺជាមួយគ្នា ។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺមានតែប្រុស ១ នឹងភិក្ខុនី ១ ប៉ុណ្ណោះ ។ ភិក្ខុនីបង្គាប់ថា អ្នកចូរទំលាយចុះ ត្រូវអាបត្តិទុក្កដ កាលបើគេទំលាយហើយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីបង្គាប់ថា អ្នកចូរវះចុះ ត្រូវអាបត្តិទុក្កដ កាលបើគេវះហើយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីបង្គាប់ថា អ្នកចូរលាងចុះ ត្រូវអាបត្តិទុក្កដ កាលបើគេលាងហើយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីបង្គាប់ថា ចូរអ្នកលាបចុះ ត្រូវអាបត្តិទុក្កដ កាលបើគេលាបហើយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីបង្គាប់ថា ចូរអ្នកចងរុំចុះ ត្រូវអាបត្តិទុក្កដ កាលបើគេចងរុំហើយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីបង្គាប់ថា ចូរអ្នកស្រាយចុះ ត្រូវអាបត្តិទុក្កដ កាលបើគេស្រាយហើយ ត្រូវអាបត្តិបាចិត្តិយ ។

(៣៦៣) ភិក្ខុនីមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីប្រាប់ (សង្ឃឬគណៈ) ហើយទើបឲ្យទំលាយក្តី ឲ្យវះក្តី ឲ្យលាងក្តី ឲ្យលាបក្តី ឲ្យចងរុំក្តី ឲ្យស្រាយក្តី ១ មានស្ត្រីណាមួយដែលដឹងក្តីជាគ្នា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

សិក្ខាបទ ទី ៦ ចប់ ។

## គព្ភិនីវគ្គស្ស បឋមសិក្ខាបទំ

[៣៦៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ គព្ភិនឹ វុដ្ឋាបេន្តិ ។ សា បិណ្ឌាយ ចរតិ ។ មនុស្សា ឯវមាហំសុ ទេថយ្យា-យ ភិក្ខំ គរុគព្ភា[១] អយ្យាតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ គព្ភិនឹ វុដ្ឋាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ គព្ភិនឹ វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ គព្ភិនឹ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ គព្ភិនឹ វុដ្ឋា-បេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ

១ ឱ. ម. គរុភារា ។

## គព្ភិនីវគ្គ សិក្ខាបទទី ១

[៣៦៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីមានគភ៌ ។ ភិក្ខុនីមានគភ៌នោះត្រាច់ទៅបិណ្ឌបាត ។ មនុស្សទាំងឡាយនិយាយយ៉ាងនេះថា ចូរអ្នកទាំងឡាយឲ្យភិក្ខាដល់លោកម្ចាស់ (ព្រោះ) លោកម្ចាស់មានគភ៌ធ្ងន់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីមានគភ៌សោះ ។ ភិក្ខុនីទាំងឡាយបានឮពាក្យមនុស្សទាំងឡាយកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីមានគភ៌សោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីមានគភ៌ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីមានគភ៌ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិន

។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី គព្ភិនឹ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៣៦៥] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ គព្ភិនី នាម អាបន្នសត្តា វុច្ចតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៣៦៦] គព្ភិនិយា គព្ភិនិសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ គព្ភិនិយា វេមតិកា វុដ្ឋាបេតិ អាបត្តិ ទុក្កដស្ស ។ គព្ភិនិយា អគព្ភិនិសញ្ញា វុដ្ឋាបេតិ អនាបត្តិ ។ អគព្ភិនិយា គព្ភិនិសញ្ញា អាបត្តិ ទុក្កដស្ស ។ អគព្ភិនិយា វេមតិកា អាបត្តិ ទុក្កដស្ស ។ អគព្ភិនិយា អគព្ភិនិសញ្ញា អនាបត្តិ ។



ទាំងស្រីជាប់ពោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់ស្រីមានគភ៌ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៣៦៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃមុសាវាទវគ្គហើយ ។ ដែលហៅថា ស្រីមានគភ៌ សំដៅយកស្រីដែលមានសត្វមកចាប់ផ្ទៃហើយ ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី(១) បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដព្រោះញត្តិ ត្រូវទុក្កដទាំងឡាយព្រោះកម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនីត្រូវអាបត្តិទុក្កដ ។

[៣៦៦] ស្រីមានគភ៌ ភិក្ខុនីសំគាល់ថាមានគភ៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ ស្រីមានគភ៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ស្រីមានគភ៌ ភិក្ខុនីសំគាល់ថាមិនមានគភ៌ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ ។ ស្រីមិនមានគភ៌ ភិក្ខុនីសំគាល់ថាមានគភ៌ ត្រូវអាបត្តិទុក្កដ ។ ស្រីមិនមានគភ៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ស្រីមិនមានគភ៌ ភិក្ខុនីសំគាល់ថាមិនមានគភ៌ មិនត្រូវអាបត្តិ ។

---

១ អាចារ្យស្រីសំដៅយកភិក្ខុនីជាគ្រូសូត្រ ។

(៣៦៧) អនាបត្តិ គព្ភិនឹ អគព្ភិនីសញ្ញា វុដ្ឋាបេតិ អគព្ភិនឹ អគព្ភិនីសញ្ញា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## គព្ភិនីវគ្គស្ស ទុតិយសិក្ខាបទំ

(៣៦៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ បាយន្តឹ វុដ្ឋាបេន្តិ ។ សា បិណ្ឌាយ ចរតិ ។ មនុស្សា ឯវមាហំសុ ទេថយ្យាយ ភិក្ខំ សទុតិយា(១) អយ្យាតិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បាយន្តឹ វុដ្ឋាបេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បាយន្តឹ

(១) សទុតិយិកាតិ ឆដ្ឋ បោត្ថកេ ទិស្សតិ ។



(៣៦៧) ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ស្រីមានគភ៌ ភិក្ខុនីសំគាល់ថាមិនមានគភ៌ ហើយឲ្យបួសឲ្យ ១ ស្រីមិនមានគភ៌ ភិក្ខុនីសំគាល់ថាមិនមានគភ៌ ហើយឲ្យបួសឲ្យ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

---

## គព្ភិនីវគ្គ សិក្ខាបទទី ២

(៣៦៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនអារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយឲ្យបួសឲ្យនូវស្រីមេដោះ ។ ភិក្ខុនីនោះត្រាច់ទៅបិណ្ឌបាត ។ មនុស្សទាំងឡាយបាននិយាយយ៉ាងនេះថា ចូរអ្នកទាំងឡាយឲ្យភិក្ខាដល់លោកម្ចាស់(ព្រោះ)លោកម្ចាស់មានគ្នីគ្នា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យបួសឲ្យនូវស្រីមេដោះសោះ ។ ភិក្ខុនីទាំងឡាយបានឮពាក្យមនុស្សទាំងឡាយកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបើនឹងឲ្យបួសឲ្យនូវស្រី

វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ចណ្ឌឹ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ចណ្ឌឹ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសា- ទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ចណ្ឌឹ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៣៦៩] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ចណ្ឌី នាម កោធនា វុច្ចតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ។ ទ្វីហិ កម្មវាចាហិ ទុក្កដា ។ កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស ។ គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។



មេះជោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុ- នីទាំងឡាយឲ្យឧបសម្បទាដល់ស្រីមេះជោះ ពិតមែនឬ ។ ភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យ ឧបសម្បទាដល់ស្រីមេះជោះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំ ឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីមេះជោះ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៣៦៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយ ដូចសិក្ខាបទទី ១ នៃពាក្យដកកណ្ឌទុះហើយ ។ ដែលហៅថា ស្រីមេះជោះ គឺបាភាក្តី ស្រីមេះជោះមែនៗក្តី ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួស ជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដ ព្រោះចប់ញត្តិ ត្រូវទុក្កដទាំងឡាយ ព្រោះចប់កម្មវាចាពីរលើក ចប់កម្មវាចា ឧបជ្ឈាយ៍ ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនី ត្រូវអាបត្តិទុក្កដ ។

[៣៧០] បាយន្តិយា បាយន្តិសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ បាយន្តិយា វេមតិកា វុដ្ឋាបេតិ អាបត្តិ ទុក្កដស្ស ។ បាយន្តិយា អបាយន្តិសញ្ញា វុដ្ឋាបេតិ អនាបត្តិ ។ អបាយន្តិយា បាយន្តិសញ្ញា អាបត្តិ ទុក្កដស្ស ។ អបាយន្តិយា វេមតិកា អាបត្តិ ទុក្កដស្ស ។ អបាយន្តិយា អបាយន្តិសញ្ញា អនាបត្តិ ។

[៣៧១] អនាបត្តិ បាយន្តី អបាយន្តិសញ្ញា វុដ្ឋាបេតិ អបាយន្តី អបាយន្តិសញ្ញា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## គព្ភិនីវគ្គស្ស តតិយសិក្ខាបទំ

[៣៧២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ



[៣៧០] ស្រីមេដោះ ភិក្ខុនីសំគាល់ថាស្រីមេដោះ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ ស្រីមេដោះ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ស្រីមេដោះ ភិក្ខុនីសំគាល់ថាមិនមែនស្រីមេដោះ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ ។ មិនមែនស្រីមេដោះ ភិក្ខុនីសំគាល់ថាស្រីមេដោះ ត្រូវអាបត្តិទុក្កដ ។ មិនមែនស្រីមេដោះ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនស្រីមេដោះ ភិក្ខុនីសំគាល់ថាមិនមែនស្រីមេដោះ មិនត្រូវអាបត្តិ ។

[៣៧១] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺស្រីមេដោះ ភិក្ខុនីសំគាល់ថាមិនមែនស្រីមេដោះ ហើយឲ្យឧបសម្បទា១ មិនមែនស្រីមេដោះ ភិក្ខុនីសំគាល់ថាមិនមែនស្រីមេដោះ ហើយឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើអំពីមុនបញ្ញត្តិ១ ។

---

## គព្ភិនីវគ្គ សិក្ខាបទទី ៣

[៣៧២] សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំង

ធម្មេសុ អសិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេន្តិ ។ តា ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ



ឡាយឲ្យឧបសម្បទាដល់សិក្ខមានា[១] ដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាង[២] អស់ពីរឆ្នាំ ។ ភិក្ខុនីទាំងឡាយ (ដែលទើបនឹងបួស) នោះជាស្រីល្ងង់មិនឈ្លាសមិនដឹងការគួរឬការមិនគួរ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏ទ្រង់ផោត ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា ទើបត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យភិក្ខុនីសន្មតឲ្យសិក្ខាសម្មតិ

---

១ សាមណេរីដែលនៅប្រព្រឹត្តធម៌ ៦ យ៉ាងមុននឹងឧបសម្បទាជាភិក្ខុនី ។ ២ ទាំងពីបាណាតិបាតាវេរមណី ទៅដល់វិកាលភោជនាវេរមណីសិក្ខាបទ ។

សិក្ខមានាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តាយ សិក្ខមានាយ សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អយ្យេ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ សិក្ខមានា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ សិក្ខមានា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមាយ សិក្ខមានាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ សិក្ខមានា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមាយ



ក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដល់សិក្ខមានា ។ ម្នាលភិក្ខុទាំងឡាយ ក៏សិក្ខាសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ ។ គឺសិក្ខមានានោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយសំពះបាទភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ ។ សិក្ខាសម្មតិនោះ ត្រូវសិក្ខមានានោះសូមអស់វារៈជាគំរប់ពីរផង ត្រូវសូមអស់វារៈជាគំរប់បីផង ។ ភិក្ខុនីដែលឆ្លាសប្រតិពល ត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ នាងនេះមានឈ្មោះនេះជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ ។ បើសិក្ខាសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដល់សិក្ខមានាឈ្មោះនេះ ។ នេះជាញត្តិ ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ នាងនេះមានឈ្មោះនេះជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ ។ សង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ

សិក្ខមានាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ ទេតិ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ សិក្ខមានាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតិយា ទានំ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមាយ សិក្ខមានាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ សា សិក្ខមានា ឯវំ វទេហីតិ វត្តព្វា បាណាតិបាតា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ អទិន្នាទានា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ អព្រហ្មចរិយា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ មុសាវាទា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ វិកាលភោជនា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមីតិ ។ អថខោ ភគវា តា ភិក្ខុនិយោ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។



ដល់សិក្ខមានា មានឈ្មោះនេះ ៗ ការឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាង អស់ពីរឆ្នាំ ដល់សិក្ខមានា មានឈ្មោះនេះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ សង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាង អស់ពីរឆ្នាំ ដល់សិក្ខមានា មានឈ្មោះនេះហើយ ។ ការឲ្យសិក្ខាសម្មតិនោះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយការស្ងៀមនៅយ៉ាងនេះ ។ សិក្ខមានានោះ ត្រូវភិក្ខុនីបង្គាប់ថា នាងចូរពោលយ៉ាងនេះហើយ បញ្ចេញវាចាថា ខ្ញុំសូមសមាទាននូវបាណាតិបាតាវេរមណី ជាសមាទានមិនកន្លង (ដាច់) អស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវអទិន្នាទានាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវអព្រហ្មចរិយាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវមុសាវាទាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវសុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវវិកាលភោជនាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះ ដោយបរិយាយជាច្រើន ។ បេ ។ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនេះ

ឯវញ្ច បន ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ

យា បន ភិក្ខុនី ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

(៣៧៣) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ អសិក្ខិតសិក្ខា នាម សិក្ខា វា ន ទិន្នា ហោតិ ទិន្នា វា សិក្ខា កុបិតា ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនិំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

(៣៧៤) ធម្មកម្មេ ធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា



ឲ្យភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌ទាំងឡាយ ៦ អស់ពីរវស្សា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៧៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ ។ ដែលហៅថា សិក្ខមានាដែលមិនបានសិក្សាសិក្ខា គឺសិក្ខមានាដែលភិក្ខុនីមិនបានឲ្យសិក្ខាក្តី សិក្ខមានាដែលភិក្ខុនីបានឲ្យសិក្ខាហើយ តែសិក្ខានោះដាច់ទៅក្តី ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនឹងអាចារិនី ត្រូវអាបត្តិទុក្កដ ។

(៣៧៤) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យ (សិក្ខមានា) ឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌

អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

(៣៧៥) អនាបត្តិ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## គព្ភិនីវគ្គស្ស ចតុត្ថសិក្ខាបទំ

(៣៧៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តិ ។ ភិក្ខុនិយោ ឯវមាហំសុ ឯថ សិក្ខមានេ ឥមំ ជានាហិ ឥមំ ទេហិ ឥមំ អាហរ ឥមិនា អត្ថោ ឥមំ កប្បិយំ ករោហីតិ ។ តា ឯវមាហំសុ ន មយំ អយ្យេ សិក្ខមានា



ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៣៧៥) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីញ៉ាំងសិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំឲ្យបានឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

## គព្ភិនីវគ្គ សិក្ខាបទទី ៤

(៣៧៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនជាអារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាង អស់ពីរឆ្នាំដែលសង្ឃមិនបានសន្មត ។ ភិក្ខុនីទាំងឡាយ (រូបឯទៀត) បាននិយាយយ៉ាងនេះថា នែសិក្ខមានាទាំងឡាយ ចូរនាងមក ចូរដឹងកិច្ចនេះ ចូរឲ្យរបស់នេះ ចូរនាំយករបស់នេះមក សេចក្តីត្រូវការដោយរបស់នេះ ចូរនាងធ្វើរបស់នេះឲ្យជាកប្បិយ ។ សិក្ខមានាទាំងនោះបាននិយាយតបយ៉ាងនេះថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនមែនជាសិក្ខមានា

ភិក្ខុនិយោ ឋាបេន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ សង្ឃេន អសម្មតំ វុដ្ឋាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ សង្ឃេន អសម្មតំ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ វុដ្ឋានសម្មុតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ



ខ ឲ្យឡើងជាភិក្ខុនី ។ ភិក្ខុនីទាំងឡាយ ។ល។ មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដែលសង្ឃមិនបានសន្មតសោះ ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដែលសង្ឃមិនបានសន្មត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដែលសង្ឃមិនបានសន្មតសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយ ទើបទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យភិក្ខុនីសង្ឃឲ្យវុដ្ឋានសម្មតិ[១]ដល់សិក្ខមានាដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ម្នាលភិក្ខុទាំងឡាយ ឯវុដ្ឋានសម្មតិនោះសង្ឃត្រូវ

១ ការសន្មតិនូវសិក្ខមានាដែលសមាទានសិក្ខាបទ ៦ ត្រឹមត្រូវគ្រប់ពីរឆ្នាំហើយដោះឲ្យលះបង់ លែងសមាទានទៅទៀត ។

ជាតិកា ។ តាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិត-
សិក្ខាយ សិក្ខមានាយ សង្ឃំ ឧបសង្កមិត្វា ឯកំសំ
ឧត្តរាសង្គំ ករិត្វា ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ
និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ
អយ្យេ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ទ្វេ វស្សានិ
ឆសុ ធម្មេសុ សិក្ខិតសិក្ខា សិក្ខមានា សង្ឃំ វុដ្ឋា-
នសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ
យាចិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ
ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នា-
មា ឥត្ថន្នាមាយ អយ្យាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ
សិក្ខិតសិក្ខា សិក្ខមានា សង្ឃំ វុដ្ឋានសម្មុតឹ យាចតិ ។
យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមាយ ទ្វេ
វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ
វុដ្ឋានសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ
អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ
ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា សិក្ខមានា
សង្ឃំ វុដ្ឋានសម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមាយ ទ្វេ



ឲ្យហើយនេះ ។ តើសិក្ខមានាដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ហើយនោះ ត្រូវចូលទៅរកសង្ឃធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ ។ សិក្ខមានាត្រូវសូមវុដ្ឋានសម្មតិអស់វារៈតំរប់ពីរដងផង ។ ត្រូវសូមអស់វារៈតំរប់បីដងផង ។ ត្រូវភិក្ខុនីដែលឈ្លាសប្រតិពលឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សិក្ខមានានេះមានឈ្មោះនេះរបស់លោកម្ចាស់មានឈ្មោះនេះ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ ។ បើវុដ្ឋានសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យវុដ្ឋានសម្មតិដល់សិក្ខមានាមានឈ្មោះនេះដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ នេះជាញត្តិ ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សិក្ខមានានេះមានឈ្មោះនេះរបស់លោកម្ចាស់មានឈ្មោះនេះបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ ។ សង្ឃឲ្យវុដ្ឋានសម្មតិដល់សិក្ខមានាមានឈ្មោះនេះ

វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ វុដ្ឋានសម្មុតឹ ទេតិ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ វុដ្ឋានសម្មុតិយា ទានំ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ វុដ្ឋានសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ភគវា តា ភិក្ខុនិយោ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ ។ យា បន ភិក្ខុនី ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ សង្ឃេន អសម្មតំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៣៩៩] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ សិក្ខិតសិក្ខា នាម ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ អសម្មតា នាម ញត្តិទុតិយេន



ដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ។ ការឲ្យវុដ្ឋានសម្មុតិដល់សិក្ខមានាមានឈ្មោះនេះដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ សមគួរដល់លោកម្ចាស់ណា លោកម្ចាស់នោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់ណា លោកម្ចាស់នោះត្រូវនិយាយឡើង ។ សង្ឃឲ្យវុដ្ឋានសម្មុតិដល់សិក្ខមានាមានឈ្មោះនេះ ដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ការឲ្យវុដ្ឋានសម្មុតិសមគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះដោយបរិយាយជាច្រើន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយញុំាងសិក្ខមានាដែលសិក្សាសិក្ខាហើយក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំដែលសង្ឃមិនបានសន្មតឲ្យបានបួសឲ្យ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៩៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា អស់ពីរឆ្នាំ គឺអស់ពីរឆ្នាំ ។ សិក្ខមានាដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាង ឈ្មោះថា សិក្សាសិក្ខា ។ សិក្ខមានាដែលសង្ឃមិនបានឲ្យវុដ្ឋានសម្មុតិដោយញត្តិទុតិយកម្ម

កម្មេន វុដ្ឋានសម្មតិ ន ទិន្នា ហោតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា ។ កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស ។ គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៣៧៨] ធម្មកម្មេ ធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៣៧៩] អនាបត្តិ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សិក្ខមានំ សង្ឃេន សម្មតំ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ឈ្មោះថាសង្ឃមិនបានសន្មត ។ ពាក្យថា ឲ្យបានឧបសម្បទា គឺឲ្យបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញ្ចឹងនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដព្រោះចប់ញត្តិ ត្រូវទុក្កដទាំងពីរ ព្រោះចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនឹងអាចារិនីត្រូវអាបត្តិទុក្កដ ។

[៣៧៨] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយញុំាងសិក្ខមានាឲ្យបានឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឧប-សម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៣៧៩] ភិក្ខុនីដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានាដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងរយៈពីរឆ្នាំដែលសង្ឃសន្មតហើយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

## គព្ភិនីវគ្គស្ស បញ្ចមសិក្ខាបទំ

(៣៨០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ឩនទ្វាទសវស្សំ គិហិគតំ វុដ្ឋាបេន្តិ ។ តា អក្ខមា ហោន្តិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសរីសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អនធិវាសកជាតិកា ហោន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឩនទ្វាទសវស្សំ គិហិគតំ វុដ្ឋាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ឩនទ្វាទសវស្សំ គិហិគតំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ឩនទ្វាទសវស្សំ គិហិគតំ វុដ្ឋាបេស្សន្តិ ឩនទ្វាទសវស្សា ហិ[១] ភិក្ខវេ

---

១ ឧ. ម. ឥទំ បទំ ន ហោតិ ។

## គព្ភិនីវគ្គ សិក្ខាបទទី ៥

(៣៨០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីគិហិគតាដែលមានវស្សាមិនគ្រប់ ១២ ឆ្នាំ ។ ពួកភិក្ខុនីបួសថ្មីទាំងនោះរមែងទ្រាំមិនបាននឹងត្រជាក់ ក្តៅ ឃ្លាន ស្រេក សម្ផស្សរបោមមូសខ្យល់កំដៅថ្ងៃនឹងសត្វទីឃជាតិ (គឺសត្វពស់) ទាំងឡាយ មានជាតិជាអ្នកមិនអត់ធន់នឹងពាក្យដែលបុគ្គលពោលមិនល្អ មានមកមិនល្អនឹងវេទនាដែលប្រព្រឹត្តក្នុងសរីរៈកើតឡើងនាំមកនូវសេចក្តីទុក្ខដ៏ក្លៀវក្លាដ៏ក្រហាយផ្សា មិនជាទីត្រេកអរ មិនគាប់ចិត្ត ជាទីនាំបង់នូវជីវិត ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាមិនគ្រប់១២ឆ្នាំសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាមិនគ្រប់១២ឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាមិនគ្រប់១២ឆ្នាំទេ

គិហិគតា អក្ខមា ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសរីសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អនធិវាសកជាតិកា ហោតិ ទ្វាទសវស្សា ច ខោ ភិក្ខវេ គិហិគតា ខមា ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសរីសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកា ហោតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី ឩនទ្វាទសវស្សំ គិហិគតំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។



ម្នាលភិក្ខុនីទាំងឡាយ ព្រោះថា ស្រីគិហិគតាដែលមានវស្សាមិនគ្រប់ ១២ ឆ្នាំ នៅមិនអត់ទ្រាំមិនបាននឹងត្រជាក់ក្តៅឃ្លានស្រេក សម្ផស្សរបោមមូសខ្យល់កំដៅថ្ងៃនិងសត្វលូនជាតិ (ពស់ខ្ទួចពស់ប៉ុ) ទាំងឡាយ មានជាតិជាអ្នកមិនអត់ធន់នឹងនូវពាក្យដែលគេពោលមិនល្អមានមកមិនល្អនឹងវេទនាដែលប្រព្រឹត្តក្នុងសរីរៈកើតឡើងនាំមកនូវសេចក្តីទុក្ខដ៏ក្លៀវក្លាដ៏ក្រហាយផ្សា មិនជាទីត្រេកអរមិនគាប់ចិត្តជាទីនាំបង់នូវជីវិត ម្នាលភិក្ខុទាំងឡាយ តែស្រីគិហិគតាមានវស្សាគ្រប់ ១២ ឆ្នាំហើយ រមែងជាអ្នកអត់ទ្រាំនូវត្រជាក់ក្តៅឃ្លានស្រេកសម្ផស្សរបោមមូសខ្យល់កំដៅថ្ងៃនិងសត្វលូនជាតិ (ពស់ខ្ទួចពស់ប៉ុ) ទាំងឡាយ មានជាតិជាអ្នកអត់ធន់នឹងនូវពាក្យដែលគេពោលមិនគាប់ចិត្តមានមកមិនល្អ (នឹង) វេទនាដែលប្រព្រឹត្តក្នុងសរីរៈកើតឡើងនាំមកនូវសេចក្តីទុក្ខដ៏ក្លៀវក្លាដ៏ផ្សាក្រហាយ មិនជាទីត្រេកអរ មិនជាទីគាប់ចិត្តជាទីនាំបង់នូវជីវិត ម្នាលភិក្ខុទាំងឡាយ កិរិយានេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាខ្វះពី ១២ ឆ្នាំ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៨១) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឩនទ្វាទសវស្សា នាម អប្បត្តទ្វាទសវស្សា ។ គិហិគតា នាម បុរិសន្តរគតា វុច្ចតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៣៨២] ឩនទ្វាទសវស្សាយ ឩនទ្វាទសវស្សសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ឩនទ្វាទសវស្សាយ វេមតិកា វុដ្ឋាបេតិ អាបត្តិ ទុក្កដស្ស ។ ឩនទ្វាទសវស្សាយ បរិបុណ្ណសញ្ញា វុដ្ឋាបេតិ អនាបត្តិ ។ បរិបុណ្ណទ្វាទសវស្សាយ ឩនទ្វាទសវស្សសញ្ញា អាបត្តិ



(៣៨១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌនេះហើយ ។ ដែលហៅថា មានវស្សាខ្វះពី ១២ ឆ្នាំ គឺស្រីដែលមានឆ្នាំមិនទាន់ដល់ ១២ ។ ដែលហៅថា ស្រីគិហិគតា សំដៅយកស្រីដែលធ្លាប់ទៅកាន់បុរសដទៃម្ដង (គឺស្រីធ្លាប់មានប្ដីហើយ) ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្ដី អាចារិនីក្ដី បាត្រក្ដី ចីវរក្ដី សន្មតសីមាក្ដី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដព្រោះញត្តិ ត្រូវទុក្កដពីរព្រោះកម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនឹងអាចារិនីត្រូវអាបត្តិទុក្កដ ។

(៣៨២) ស្រីគិហិគតាមានវស្សាមិនគ្រប់ ១២ ឆ្នាំ ភិក្ខុនីសំគាល់ថា មានវស្សាមិនគ្រប់ ១២ ឆ្នាំ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ ស្រីគិហិគតាមានវស្សាមិនគ្រប់ ១២ ឆ្នាំ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ស្រីគិហិគតាមានវស្សាមិនគ្រប់ ១២ ឆ្នាំ ភិក្ខុនីសំគាល់ថាគ្រប់ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ ។ ស្រីគិហិគតាមានវស្សា ១២ បរិបូណ៌ហើយ ភិក្ខុនីសំគាល់ថាមានវស្សាមិនគ្រប់ ១២ ត្រូវអាបត្តិ

ទុក្កដស្ស ។ បរិបុណ្ណទ្វាទសវស្សាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ បរិបុណ្ណទ្វាទសវស្សាយ បរិបុណ្ណសញ្ញា អនាបត្តិ ។

(៣៨៣) អនាបត្តិ ឩនទ្វាទសវស្សំ បរិបុណ្ណសញ្ញា វុដ្ឋាបេតិ បរិបុណ្ណទ្វាទសវស្សំ បរិបុណ្ណសញ្ញា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## គព្ភិនីវគ្គស្ស ឆដ្ឋសិក្ខាបទំ

(៣៨៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេន្តិ ។ តា ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ



ទុក្កដ ។ ស្រីគិហិគតាមានវស្សាពេញ ១២ ឆ្នាំហើយ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ស្រីគិហិគតាមានវស្សាពេញ ១២ ឆ្នាំហើយ ភិក្ខុនីក៏សំគាល់ថាបរិបូណ៌ហើយ មិនត្រូវអាបត្តិ ។

(៣៨៣) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺស្រីគិហិគតាមានវស្សាខ្វះពី ១២ ឆ្នាំ តែភិក្ខុនីសំគាល់ថាគ្រប់ ១២ ឆ្នាំ ហើយឲ្យឧបសម្បទា ១ ស្រីគិហិគតាមានវស្សាពេញ ១២ ឆ្នាំហើយ ភិក្ខុនីសំគាល់ថាពេញ ហើយឲ្យឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

## គព្ភិនីវគ្គ សិក្ខាបទទី ៦

(៣៨៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាពេញ ១២ ឆ្នាំហើយ ដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ។ ភិក្ខុនីបួសថ្មីទាំងឡាយនោះល្ងង់មិនឈ្លាសមិនដឹងកិច្ចគួរ ឬកិច្ចមិនគួរ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស

កថំ ហិ នាម ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវា-តិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិ-ត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ



ទិះដៀល បន្តុះបន្ដាប់ថា ភិក្ខុនីទាំងឡាយ ម្ដេចក៏បាននឹងឲ្យឧបសម្បទាដល់ស្រីគិហិគតា មានវស្សាគ្រប់ ១២ ឆ្នាំហើយ (តែ) មិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់ ១២ ឆ្នាំហើយ ដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់ ១២ ឆ្នាំហើយដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) ឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដល់ស្រីគិហិគតាដែលមានឆ្នាំគ្រប់ ១២ ហើយ ។ ម្នាលភិក្ខុទាំងឡាយ ក៏សិក្ខាសម្មតិនោះសង្ឃត្រូវឲ្យយ៉ាងនេះ ។ គឺស្រីគិហិគតាដែលមានឆ្នាំ ១២ បរិបូណ៌ហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទភិក្ខុនីទាំងឡាយ ទើបអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះ

អយ្យេ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ ទេតិ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទស-



ទីបីសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះជាគិហិគតារបស់លោកម្ចាស់មានឈ្មោះនេះមានវស្សា ១២ បរិបូណ៌ហើយ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំចំពោះសង្ឃ ។ សិក្ខាសម្មតិនោះត្រូវគិហិគតានោះសូមអស់វារៈគំរប់ពីរដងផង ត្រូវសូមអស់វារៈគំរប់បីដងផង ។ ភិក្ខុនីដែលឈ្លាសប្រតិពលត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ គិហិគតានេះមានឈ្មោះនេះរបស់លោកម្ចាស់មានឈ្មោះនេះមានវស្សា ១២ បរិបូណ៌ហើយ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំចំពោះសង្ឃ ។ បើសិក្ខាសម្មតិមានកាលគួរដល់សង្ឃហើយ សង្ឃគួរឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដល់គិហិគតាមានឈ្មោះនេះដែលមានវស្សា ១២ បរិបូណ៌ហើយ ។ នេះជាញត្តិ ។ បពិត្រលោកម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ គិហិគតានេះមានឈ្មោះនេះរបស់លោកម្ចាស់មានឈ្មោះនេះមានវស្សា១២ បរិបូណ៌ហើយ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំចំពោះសង្ឃ ឥឡូវសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់ស្រីគិហិគតាឈ្មោះនេះមានវស្សា ១២ បរិបូណ៌ហើយ ។ ការឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដល់ស្រីគិហិគតាមានឈ្មោះនេះដែលមានវស្សាគ្រប់ ១២ ហើយ

វស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ សា បរិបុណ្ណទ្វាទសវស្សា គិហិគតា ឯវំ វទេហីតិ វត្តព្វា បាណាតិបាតា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្ម សមាទានំ សមាទិយាមិ ។ បេ ។ វិកាលភោជនា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្ម សមាទានំ សមាទិយាមីតិ ។ អថខោ ភគវា តា ភិក្ខុនិយោ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។



គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ សិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ សង្ឃបានឲ្យដល់គិហិគតាមានឈ្មោះនេះដែលមានវស្សាគ្រប់ ១២ ហើយ ។ ការឲ្យសិក្ខាសម្មតិនោះគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ ស្រីគិហិគតានោះដែលមានវស្សាគ្រប់ ១២ ហើយ ត្រូវសង្ឃបង្គាប់ថា ចូរនាងពោលយ៉ាងនេះ គឺពោលថា ខ្ញុំសូមសមាទាននូវបាណាតិបាតាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ។ បេ ។ ខ្ញុំសូមសមាទាននូវវិកាលភោជនាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះ ដោយបរិយាយជាច្រើន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់ ១២ ហើយ ដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរវស្សា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៨៥) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បរិបុណ្ណទ្វាទសវស្សា នាម បត្តទ្វាទសវស្សា ។ គិហិគតា នាម បុរិសន្តរគតា វុច្ចតិ ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ អសិក្ខិតសិក្ខា នាម សិក្ខា វា ន ទិន្នា ហោតិ ទិន្នា វា សិក្ខា កុបិតា ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនិំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណាយ ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

(៣៨៦) ធម្មកម្មេ ធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា



(៣៨៥) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ ។ ស្រីគិហិគតាដែលមានវស្សាពេញ ១២ ហើយ ឈ្មោះថា មានវស្សាគ្រប់ ១២ ហើយ ។ ដែលហៅថា ស្រីគិហិគតា សំដៅយកស្រីដែលរួមទៅកាន់ប្រុសដទៃបាន ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ ។ សិក្ខាដែលសង្ឃមិនបានឲ្យក្ដី (ឬ) សិក្ខាដែលសង្ឃឲ្យហើយតែកម្រើក(ដាច់)ក្ដី នៃស្រីគិហិគតាណា ស្រីគិហិគតានោះ ឈ្មោះថា មិនបានសិក្សាសិក្ខា ។ ពាក្យថា ឲ្យឧបសម្បទា គឺឲ្យបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្ដី អាចារិនីក្ដី បាត្រក្ដី ចីវរក្ដី សន្មតសីមាក្ដី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដព្រោះញត្តិ ត្រូវទុក្កដព្រោះកម្មវាចាពីរ ខណៈចប់កម្មវាចាពីរ ចប់កម្មវាចាហើយ ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនី ត្រូវអាបត្តិទុក្កដ ។

(៣៨៦) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌

អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៣៨៧] អនាបត្តិ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## គព្ភិនីវគ្គស្ស សត្តមសិក្ខាបទំ

[៣៨៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តិ ។ ភិក្ខុនិយោ ឯវមាហំសុ ឯថ សិក្ខមានេ ឥមំ ជានាថ ឥមំ ទេថ ឥមំ អាហរថ ឥមិនា អត្ថោ ឥមំ កប្បិយំ ករោថាតិ ។ តា



ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៣៨៧] ការវុដ្ឋាបនមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីឲ្យបួសស្ត្រីដែលធ្លាប់នៅគ្រប់ប្តី មានវស្សាគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ ១ ។

---

## គព្ភិនីវគ្គ សិក្ខាបទទី ៧

[៣៨៨] សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុនីតែងឲ្យបួសស្ត្រីដែលធ្លាប់នៅគ្រប់ប្តី មានវស្សាគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ (តែ) សង្ឃមិនបានសន្មត ។ ពួកភិក្ខុនីពោលយ៉ាងនេះថា នែសិក្ខមានា នាងចូរមក ចូរដឹងរបស់នេះ ចូរឲ្យរបស់នេះ ចូរនាំយករបស់នេះមក យើងត្រូវការដោយរបស់នេះ ចូរធ្វើរបស់នេះឲ្យជាកប្បិយ ។ ភិក្ខុនីបួសថ្មី

ឯវមាហំសុ ន មយំ អយ្យេ សិក្ខមានា ភិក្ខុនិយោ មយន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ



ទាំងឡាយនោះបានឆ្លើយយ៉ាងនេះថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនមែនជាសិក្ខមានាទេ យើងខ្ញុំជាភិក្ខុនី ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦ យ៉ាងអស់ពីរឆ្នាំ (តែ)សង្ឃមិនបានសន្មតឲ្យសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីគិហិគតាដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦ យ៉ាងអស់ពីរឆ្នាំ (តែ) សង្ឃមិនបានសន្មត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦ យ៉ាងអស់ពីរឆ្នាំហើយ (តែ)សង្ឃមិនបានសន្មតឲ្យទេ ម្នាលភិក្ខុទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្តល់នូវសម្មតិដល់ស្រីគិហិគតាដែលមានវស្សាគ្រប់១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ

វុដ្ឋានសម្មុតិ ទាតព្វា ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អយ្យេ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា សង្ឃំ វុដ្ឋានសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា សង្ឃំ វុដ្ឋានសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ



ហើយ ។ ម្នាលភិក្ខុទាំងឡាយ តែវុដ្ឋានសម្មុតិនោះសង្ឃត្រូវឲ្យយ៉ាងនេះ ។ ស្រីគិហិគតាដែលមានវស្សាគ្រប់ ១២ ហើយបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទានៃភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ឈ្មោះនេះជាគិហិគតារបស់លោកម្ចាស់ឈ្មោះនេះ មានវស្សាគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មុតិនឹងសង្ឃ ។ ឯវុដ្ឋានសម្មុតិ ស្រីគិហិគតានោះត្រូវសូមអស់វារៈពីរដងផង ត្រូវសូមអស់វារៈបីដងផង ។ ភិក្ខុនីដែលឈ្លាសប្រតិពលត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ស្រីគិហិគតានេះឈ្មោះនេះរបស់លោកម្ចាស់ឈ្មោះនេះមានវស្សាគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មុតិនឹងសង្ឃ ។ បើវុដ្ឋានសម្មុតិកម្មមានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យវុដ្ឋានសម្មុតិដល់ស្រីគិហិគតាឈ្មោះនេះដែលមានវស្សាគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ នេះជាញត្តិ ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ស្រីគិហិគតានេះមាន

អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា សង្ឃំ វុដ្ឋានសម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតឹ ទេតិ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតិយា ទានំ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ភគវា តា ភិក្ខុនិយោ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។



ឈ្មោះនេះរបស់លោកម្ចាស់ឈ្មោះនេះមានវស្សាគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ ។ សង្ឃឲ្យវុដ្ឋានសម្មតិដល់ស្រីគិហិគតាមានឈ្មោះនេះ មានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ការឲ្យវុដ្ឋានសម្មតិដល់ស្រីគិហិគតាមានឈ្មោះនេះ ដែលមានវស្សាគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ សង្ឃបានឲ្យវុដ្ឋានសម្មតិដល់ស្រីគិហិគតាមានឈ្មោះនេះដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ការឲ្យវុដ្ឋានសម្មតិនោះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះដោយបរិយាយជាច្រើនហើយ ។ល។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់ ១២ ហើយបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរវស្សាហើយ តែសង្ឃមិនសន្មត (ឲ្យ) ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៨៩) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បរិបុណ្ណទ្វាទសវស្សា នាម បត្តទ្វាទសវស្សា ។ គិហិគតា នាម បុរិសន្តរគតា វុច្ចតិ ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ សិក្ខិតសិក្ខា នាម ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ អសម្មតា នាម ញត្តិទុតិយេន កម្មេន វុដ្ឋានសម្មុតិ ន ទិន្នា ហោតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៣៩០] ធម្មកម្មេ ធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា



(៣៨៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ ។ ស្រីគិហិគតាមានវស្សាពេញ១២ហើយ ឈ្មោះថា មានវស្សាគ្រប់១២ហើយ ។ ដែលហៅថា ស្រីគិហិគតា សំដៅយកស្ត្រីម្នាក់ដែលលះបង់ទៅកាន់បុរសដទៃបាន ។ ពាក្យថា ពីរវស្សា គឺអស់ពីរឆ្នាំ ។ ស្រីគិហិគតាដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង ឈ្មោះថា សិក្សាសិក្ខាហើយ ។ ស្រីគិហិគតាដែលសង្ឃមិនបានឲ្យវុដ្ឋានសម្មតិ ដោយកម្មមានញត្តិជាគំរប់ពីរ ឈ្មោះថា សង្ឃមិនបានសន្មត ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទាហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដព្រោះចប់ញត្តិ ត្រូវទុក្កដទាំងឡាយព្រោះចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនឹងអាចារិនីត្រូវអាបត្តិទុក្កដ ។

(៣៩០) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា

អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

(៣៤១) អនាបត្តិ បរិបុណ្ណទ្វាទសវស្សំ គិហិគតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សម្មតិយា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## តតិយវគ្គស្ស អដ្ឋមសិក្ខាបទំ

(៣៤២) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី សហជីវិនិំ វុដ្ឋាបេត្វា ទ្វេ វស្សានិ នេវ អនុគ្គណ្ហាតិ ន អនុគ្គណ្ហាបេតិ ។ តា ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា សហជីវិនិំ វុដ្ឋាបេត្វា ទ្វេ វស្សានិ នេវ



កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៣៤១] អ្នកដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគត ដែលមានអាយុគ្រប់ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សង្ឃសន្មតហើយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីធ្វើកន្លងមុនបង្អស់ ១ ។

---

## តតិយវគ្គ សិក្ខាបទទី ៨

[៣៤២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនីឲ្យឧបសម្បទាដល់សិស្សានាជាសហជីវិនី ហើយមិនបានប្រៀនប្រដៅខ្លួនឯង មិនឲ្យអ្នកដទៃប្រៀនប្រដៅអស់ពីរឆ្នាំ ។ ភិក្ខុនីទាំងឡាយនោះល្ងង់ខ្លៅ មិនស្គាល់គួរឬមិនគួរ ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្ទោសថា លោកម្ចាស់ថុល្លនន្ទា មិនគួរបើនឹងឲ្យឧបសម្បទាដល់សិស្សានាជាសហជីវិនី

អនុគ្គណ្ហិស្សតិ ន អនុគ្គណ្ហាបេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សហជីវិនឹ វុដ្ឋាបេត្វា ទ្វេ វស្សានិ នេវ អនុគ្គណ្ហាតិ ន អនុគ្គណ្ហាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សហជីវិនឹ វុដ្ឋាបេត្វា ទ្វេ វស្សានិ នេវ អនុគ្គណ្ហិស្សតិ ន អនុគ្គណ្ហាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី សហជីវិនឹ វុដ្ឋាបេត្វា ទ្វេ វស្សានិ នេវ អនុគ្គណ្ហេយ្យ ន អនុគ្គណ្ហាបេយ្យ បាចិត្តិយន្តិ ។

(៣៨៣) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សហជីវិនី នាម សទ្ធិវិហារិនី វុច្ចតិ ។ វុដ្ឋាបេត្វាតិ ឧបសម្បាទេត្វា ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ នេវ អនុគ្គណ្ហេយ្យាតិ ន សយំ អនុគ្គណ្ហេយ្យ ឧទ្ទេសេន



ហើយមិនបង្រៀនខ្លួនឯង មិនឲ្យគេបង្រៀនអស់ពីរឆ្នាំសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនដោយខ្លួនឯង មិនឲ្យគេបង្រៀនអស់ពីរឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនដោយខ្លួនឯងនឹងមិនឲ្យគេបង្រៀនអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនដោយខ្លួនឯង មិនឲ្យគេបង្រៀនអស់ពីរវស្សា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៨៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា សិក្ខមានាជាសហជីវិនី សំដៅយកសិក្ខមានាជាសទ្ធិវិហារិនី (កូនសិស្ស) ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ ។ ពាក្យថា មិនបង្រៀន (ខ្លួនឯង) គឺមិនបង្រៀនដោយបាលី អដ្ឋកថា សេចក្ដីនាន

បរិបុច្ឆាយ ឱវាទេន អនុសាសនិយា ។ ន អនុគ្គណ្ហាបេយ្យាតិ ន អញ្ញំ អាណាបេយ្យ ។ ទ្វេ វស្សានិ នេវ អនុគ្គណ្ហិស្សាមិ ន អនុគ្គណ្ហាបេស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

[៣៩៤] អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## គព្ភិនីវគ្គស្ស នវមសិក្ខាបទំ

[៣៩៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ វុដ្ឋាបិតំ បវត្តិនឹ ទ្វេ វស្សានិ នានុពន្ធន្តិ ។ តា ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ វុដ្ឋាបិតំ បវត្តិនឹ ទ្វេ វស្សានិ នានុពន្ធិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ



ប្រៀនប្រដៅដោយខ្លួនឯង ។ ពាក្យថា មិនឲ្យគេប្រៀន គឺមិនបង្គាប់អ្នកដទៃ ។ ភិក្ខុនីត្រាតែដាក់ធុរៈថា អញនឹងមិនប្រៀនខ្លួនឯង មិនឲ្យគេប្រៀនអស់ពីរឆ្នាំ ត្រូវអាបត្តិបាចិត្តិយ ។

[៣៩៤] ករណីដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន៥ យ៉ាង) គឺ ភិក្ខុនីមានសេចក្តីអន្តរាយ ហើយស្វែងរកគ្នាមិនបាន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានភ័យ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

## គព្ភិនីវគ្គ សិក្ខាបទទី៩

[៣៩៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយមិនតាមបម្រើភិក្ខុនីជាបវត្តិនី (ឧបជ្ឈាយ៍) ដែលបំបួសខ្លួនអស់ពីរឆ្នាំ ។ ពួកភិក្ខុនីទាំងនោះល្ងង់មិនឆ្លាស មិនស្គាល់ការគួរមិនគួរ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងមិនតាមបម្រើភិក្ខុនីជាបវត្តិនីដែលបំបួសខ្លួនអស់ពីរឆ្នាំសោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមិនតាមបម្រើ

វុដ្ឋាបិតំ បវត្តិនឹ ទ្វេ វស្សានិ នានុពន្ធតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ វុដ្ឋាបិតំ បវត្តិនឹ ទ្វេ វស្សានិ នានុពន្ធិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី វុដ្ឋាបិតំ បវត្តិនឹ ទ្វេ វស្សានិ នានុពន្ធេយ្យ បាចិត្តិយន្តិ ។

(៣៩៦) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ វុដ្ឋាបិតន្តិ ឧបសម្បាទិតំ ។ បវត្តិនីតិ ឧបជ្ឈាយា[១] វុច្ចតិ ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ នានុពន្ធេយ្យាតិ ន សយំ ឧបដ្ឋហេយ្យ ។ ទ្វេ វស្សានិ នានុពន្ធិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

(៣៩៧) អនាបត្តិ ឧបជ្ឈាយា ពាលា វា ហោតិ អលជ្ជិនី វា គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

១ ម. ឧបជ្ឈា ។



ភិក្ខុនីជាបវត្តិនីដែលបំបួសខ្លួនអស់ពីរឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងមិនបម្រើភិក្ខុនីជាបវត្តិនីដែលបំបួសខ្លួនអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនតាមបម្រើភិក្ខុនីជាបវត្តិនី ដែលបំបួសខ្លួនអស់ពីរវស្សា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៩៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយដូចសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា បំបួសខ្លួន គឺឲ្យឧបសម្បទាដល់ខ្លួន ។ ដែលហៅថា ភិក្ខុនីជាបវត្តិនី សំដៅយកភិក្ខុនីជាឧបជ្ឈាយ៍ ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ ។ ពាក្យថា មិនតាមបម្រើ គឺមិនបម្រើដោយខ្លួនឯង ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អាត្មានឹងមិនតាមបម្រើអស់ពីរឆ្នាំ ត្រូវអាបត្តិបាចិត្តិយ ។

(៣៩៧) ភិ. ដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺ ឧបជ្ឈាយ៍ល្ងង់ ១ ឧបជ្ឈាយ៍មិនមានខ្មាស ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

## គព្ភិនីវគ្គស្ស ទសមសិក្ខាបទំ

[៣៨៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី សហជីវិនឹ វុដ្ឋាបេត្វា នេវ វូបកាសេតិ[១] ន វូបកាសាបេតិ[២] ។ សាមិកា អគ្គហេសុំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា សហជីវិនឹ វុដ្ឋាបេត្វា នេវ វូបកាសេស្សតិ ន វូបកាសាបេស្សតិ សាមិកា អគ្គហេសុំ សចាយំ ភិក្ខុនី បក្កន្តា អស្ស ន ច សាមិកា គណ្ហេយ្យុន្តិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សហជីវិនឹ វុដ្ឋាបេត្វា នេវ វូបកាសេតិ ន វូបកាសាបេតិ សាមិកា អគ្គហេសុន្តិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សហជីវិនឹ វុដ្ឋាបេត្វា នេវ វូបកាសេស្សតិ ន វូបកាសាបេស្សតិ សាមិកា អគ្គហេសុំ នេតំ ភិក្ខវេ អប្បសន្នានំ

---

១ ម. នេវ វូបកាសេសិ ។ ២ ម. ន វូបកាសាបេសិ ។

## គព្ភិនីវគ្គ សិក្ខាបទទី ១០

[៣៨៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី (កូនសិស្ស) ហើយ មិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅ ។ ប្តីបានចាប់យកទៅ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទាមិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅសោះ ប្តីបានចាប់យកទៅ ប្រសិនបើភិក្ខុនីនេះចៀសចេញទៅហើយ ប្តីប្រាកដជាមិនបានចាប់យកទៅទេ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនីហើយមិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅ ប្តីបានចាប់យកទៅ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនីហើយមិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅ ប្តីបានចាប់យកទៅទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់

ក បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី សហជីវិនឹ វុដ្ឋាបេត្វា នេវ វូបកាសេយ្យ ន វូបកាសាបេយ្យ អន្តមសោ ឆប្បញ្ច យោជនានិបិ បាចិត្តិយន្តិ ។

(៣៩៩) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សហជីវិនី នាម សទ្ធិវិហារិនី វុច្ចតិ ។ វុដ្ឋាបេត្វាតិ ឧបសម្បាទេត្វា ។ នេវ វូបកាសេយ្យាតិ ន សយំ វូបកាសេយ្យ ។ ន វូបកាសាបេយ្យាតិ ន អញ្ញំ អាណាបេយ្យ ។ នេវ វូបកាសេស្សាមិ ន វូបកាសាបេស្សាមិ អន្តមសោ ឆប្បញ្ច យោជនានិបីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

(៤០០) អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ទុតិយិកំ ភិក្ខុនឹ ន លភតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

តុវដ្ដវគ្គោ សត្តមោ ។



ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិននាំយកទៅ មិនឲ្យគេនាំយកទៅ ដោយហោចទៅអស់ ៥-៦ យោជន៍ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៩៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា សិក្ខមានាជាសហជីវិនី សំដៅយកសិក្ខមានាជាសទ្ធិវិហារិនី (កូនសិស្ស) ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ពាក្យថា មិននាំយកទៅ គឺមិននាំយកទៅខ្លួនឯង ។ ពាក្យថា មិនឲ្យគេនាំយកទៅ គឺមិនបង្គាប់អ្នកដទៃ ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អាត្មាអញនឹងមិននាំយកទៅ មិនឲ្យអ្នកដទៃនាំយកទៅដោយហោចទៅសូម្បីអស់ ៥-៦ យោជន៍ ត្រូវអាបត្តិបាចិត្តិយ ។

(៤០០) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុនីមានសេចក្ដីអន្តរាយហើយស្វែងរកភិក្ខុនីជាគំរប់ពីរមិនបាន ១ ភិក្ខុនីមានភ័យចំ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ ១ ។

តុវដ្ដវគ្គ ទី ៧ ចប់ ។

# កុមារីភូតវគ្គស្ស បឋមសិក្ខាបទំ

[៦០១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ឩនវីសតិវស្សំ កុមារីភូតំ វុដ្ឋាបេន្តិ ។ តា អក្ខមា ហោន្តិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសរីសប-សម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អនធិវាសកជាតិកា ហោន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឩនវីសតិវស្សំ កុមារីភូតំ វុដ្ឋាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ឩនវីសតិវស្សំ កុមារីភូតំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិ-

# កុមារីភូតវគ្គ សិក្ខាបទទី ១

[៦០១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់កុមារីភូត (សាមណេរី) ដែលមានអាយុមិនគ្រប់ ២០ ឆ្នាំ ។ ពួកភិក្ខុនីបួសថ្មីទាំងនោះជាអ្នកអត់ទ្រាំមិនបាននឹងត្រជាក់ក្តៅ ឃ្លានស្រេកនឹងសម្ផស្សរបស់រោមរុយ មូស ខ្យល់ កំដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ មានជាតិជាអ្នកមិនអត់ធន់នឹងនូវពាក្យដែលគេនិយាយមិនគាប់ចិត្ត មានមកមិនល្អ នឹងវេទនាដែលប្រព្រឹត្តទៅក្នុងសរីរកាយកើតឡើងជាទុក្ខ ដ៏ក្លៀវក្លា ដ៏ក្រហល់ក្រហាយ មិនជាទីត្រេកអរ មិនគាប់ចិត្ត ជាទីនាំបង់នូវជីវិត ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់កុមារីភូតដែលមានអាយុមិនគ្រប់ ២០ ឆ្នាំសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់កុមារីភូតដែលមានអាយុខ្វះពី ២០ ឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី

ៈយា ឩនវីសតិវស្សំ កុមារីភូតំ វុដ្ឋាបេស្សន្តិ ឩនវីសតិវស្សា ហិ(១) ភិក្ខវេ កុមារីភូតា អក្ខមា ហោតិ សីតស្ស ឧណ្ហស្ស ។បេ។ បាណហរានំ អនធិវាសកជាតិកា ហោតិ វីសតិវស្សា ច ខោ ភិក្ខវេ កុមារីភូតា ខមា ហោតិ សីតស្ស ឧណ្ហស្ស ។បេ។ បាណហរានំ អធិវាសកជាតិកា ហោតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី ឩនវីសតិវស្សំ កុមារីភូតំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៤០៦] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឩនវីសតិវស្សា នាម អប្បត្តវីសតិវស្សា ។ កុមារីភូតា នាម សាមណេរី វុច្ចតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ

១ ឱ. ហោន្តិ អយំ សព្វត្ថ ហោតិ ។



ពាំនឹងឲ្យឧបសម្បទាដល់កុមារីភូតាដែលមានឆ្នាំខ្វះពី ២០ ទេ ម្នាលភិក្ខុទាំងឡាយ ព្រោះថាកុមារីភូតាមានឆ្នាំខ្វះពី ២០ ជាអ្នកមិនអត់ទ្រាំនូវត្រជាក់និងក្តៅ ។បេ។ មានជាតិជាអ្នកមិនអត់ទ្រាំនូវទុក្ខវេទនាជាទីនាំបង់នូវជីវិត ម្នាលភិក្ខុទាំងឡាយ ឯកុមារីភូតាមានឆ្នាំ ២០ ទើបអត់ទ្រាំនូវត្រជាក់ក្តៅ ។បេ។ មានជាតិជាអ្នកអត់ទ្រាំនូវទុក្ខវេទនាជាទីនាំបង់នូវជីវិតបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែនញ៉ាំងជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់កុមារីភូតាមានឆ្នាំខ្វះពី ២០ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៤០៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយដូចសិក្ខាបទទី១នៃផ្លាកចិកកណ្ឌរួចហើយ ។ កុមារីភូតាមានឆ្នាំមិនដល់២០ ឈ្មោះថា មានឆ្នាំខ្វះពី ២០ ។ ដែលហៅថា កុមារីភូតា សំដៅយកសាមណេរី ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី

អាបត្តិ ទុក្កដស្ស ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៦០៣] ឩនវីសតិវស្សាយ ឩនវីសតិវស្សសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ឩនវីសតិវស្សាយ វេមតិកា វុដ្ឋាបេតិ អាបត្តិ ទុក្កដស្ស ។ ឩនវីសតិវស្សាយ បរិបុណ្ណសញ្ញា វុដ្ឋាបេតិ អនាបត្តិ ។ បរិបុណ្ណវីសតិវស្សាយ ឩនវីសតិវស្សសញ្ញា អាបត្តិ ទុក្កដស្ស ។ បរិបុណ្ណវីសតិវស្សាយ វេមតិកា អាបត្តិ ទុក្កដស្ស ។ បរិបុណ្ណវីសតិវស្សាយ បរិបុណ្ណសញ្ញា អនាបត្តិ ។

[៦០៤] អនាបត្តិ ឩនវីសតិវស្សំ បរិបុណ្ណសញ្ញា វុដ្ឋាបេតិ បរិបុណ្ណវីសតិវស្សំ បរិបុណ្ណសញ្ញា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដតាំងពីវាចា ២ ខណៈចប់កម្មវាចាតែ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនី ត្រូវអាបត្តិទុក្កដ ។

[៦០៣] សាមណេរីមានឆ្នាំខ្វះពី ២០ ភិក្ខុនីសំគាល់ថាមានឆ្នាំខ្វះពី ២០ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ សាមណេរីមានឆ្នាំខ្វះពី ២០ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ សាមណេរីមានឆ្នាំខ្វះពី ២០ ភិក្ខុនីសំគាល់ថាគ្រប់ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ ។ សាមណេរីមានឆ្នាំគ្រប់ ២០ ហើយ ភិក្ខុនីសំគាល់ថាមានឆ្នាំខ្វះពី ២០ ត្រូវអាបត្តិទុក្កដ ។ សាមណេរីមានឆ្នាំគ្រប់ ២០ ហើយ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សាមណេរីមានឆ្នាំគ្រប់ ២០ ហើយ ភិក្ខុនីសំគាល់ថាគ្រប់ហើយ មិនត្រូវអាបត្តិ ។

[៦០៤] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺសាមណេរីមានឆ្នាំខ្វះពី ២០ (តែ) ភិក្ខុនីសំគាល់ថាគ្រប់ហើយ ក៏ឲ្យឧបសម្បទា ១ សាមណេរីមានឆ្នាំគ្រប់ ២០ ហើយ ភិក្ខុនីក៏សំគាល់ថាគ្រប់ ២០ ហើយឲ្យឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដែលជាដើមបញ្ញត្តិ ១ ។

## កុមារីភូតវគ្គស្ស ទុតិយសិក្ខាបទំ

[៤០៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារីភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេន្តិ ។ តា ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារីភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារីភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា ។ បេ ។ កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារីភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ

## កុមារីភូតវគ្គ សិក្ខាបទទី ២

[៤០៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់កុមារីភូត (សាមណេរី) មានឆ្នាំគ្រប់ ២០ ហើយ (តែ) មិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ។ ភិក្ខុនីបួសថ្មីទាំងនោះនៅល្ងង់មិនឆ្លាត មិនស្គាល់ការគួរមិនគួរ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យឧបសម្បទាដល់កុមារីភូតដែលមានឆ្នាំគ្រប់ ២០ ហើយ (តែ) មិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់កុមារីភូតមានឆ្នាំគ្រប់ ២០ ហើយ តែមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់កុមារីភូតមានឆ្នាំគ្រប់ ២០ ហើយ មិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ

អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អដ្ឋារសវស្សាយ កុមារិភូតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តាយ អដ្ឋារសវស្សាយ កុមារិភូតាយ សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អយ្យេ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ អដ្ឋារសវស្សា កុមារិភូតា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា តតិយម្បិ យាចិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ អដ្ឋារសវស្សា កុមារិភូតា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមាយ អដ្ឋារសវស្សាយ កុមារិភូតាយ ទ្វេ វស្សានិ



អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា ហើយទើបត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ។ ឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ ដល់កុមារិកាដែលមានឆ្នាំ ១៨ ។ ម្នាលភិក្ខុទាំងឡាយ ក៏សិក្ខាសម្មតិនោះសង្ឃត្រូវឲ្យយ៉ាងនេះ ។ គឺកុមារិកាមានឆ្នាំ ១៨ នោះត្រូវចូលទៅរកសង្ឃធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ឈ្មោះនេះជាកុមារិកាមានឆ្នាំ ១៨ របស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ ។ កុមារិកានោះត្រូវសូមសិក្ខាសម្មតិនោះអស់វារៈពីរដងផង ត្រូវសូមអស់វារៈបីដងផង ។ ភិក្ខុនីដែលឈ្លាសប្រតិពលត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ កុមារិកានេះឈ្មោះនេះមានឆ្នាំ ១៨ របស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ ។ បើសិក្ខាសម្មតិមានកាលគួរដល់សង្ឃហើយ សូមសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំដល់កុមារិកា

បាចិត្តិយកណ្ឌេ កុមារីភូតវគ្គស្ស ទុតិយសិក្ខាបទេ សិក្ខាសម្មតិ

ឆសុ ធម្មេសុ សិក្ខាសម្មតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ ។ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ អដ្ឋារសវស្សា កុមារីភូតា សង្ឃំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមាយ អដ្ឋារសវស្សាយ កុមារីភូតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតឹ ទេតិ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ អដ្ឋារសវស្សាយ កុមារីភូតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតិយា ទានំ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមាយ អដ្ឋារសវស្សាយ កុមារីភូតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខាសម្មតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។ សា អដ្ឋារសវស្សា កុមារីភូតា ឯវំ វទេហីតិ វត្តព្វា បាណាតិបាតា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ អទិន្នាទានា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ អព្រហ្មចរិយា វេរមណឹ



បាចិត្តិយកណ្ឌ កុមារីភូតវគ្គ សិក្ខាបទទី ២ សិក្ខាសម្មតិ

មានឈ្មោះនេះមានអាយុ ១៨ ឆ្នាំ ។ នេះជាញត្តិ ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ កុមារីភូតានេះមានឈ្មោះនេះរបស់លោកម្ចាស់ឈ្មោះនេះមានឆ្នាំ ១៨ សូមសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ ។ ឥឡូវសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំដល់កុមារីភូតាមានឆ្នាំ១៨ មានឈ្មោះនេះ ។ ការឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំដល់កុមារីភូតាមានអាយុ១៨ មានឈ្មោះនេះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ សង្ឃបានឲ្យសិក្ខាសម្មតិក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំដល់កុមារីភូតាមានអាយុ ១៨ ឆ្នាំ មានឈ្មោះនេះហើយ ។ ការឲ្យសិក្ខាសម្មតិនោះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវកិរិយានេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ កុមារីភូតាមានអាយុ ១៨ នោះសង្ឃត្រូវបង្គាប់ថា នាងចូរថាយ៉ាងនេះ គឺការថា

ខ្ញុំសូមសមាទាននូវបាណាតិបាតាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ

ខ្ញុំសូមសមាទាននូវអទិន្នាទានាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ

ខ្ញុំសូមសមាទាននូវអព្រហ្មចរិយាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ

ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ មុសាវាទា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមិ វិកាលភោជនា វេរមណឹ ទ្វេ វស្សានិ អវីតិក្កម្មសមាទានំ សមាទិយាមីតិ ។ អថខោ ភគវា តា ភិក្ខុនិយោ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី បរិបុណ្ណវីសតិវស្សំ កុមារិភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ អសិក្ខិតសិក្ខំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

(៤០៦) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បរិបុណ្ណវីសតិវស្សា នាម បត្តវីសតិវស្សា ។ កុមារិភូតា នាម សាមណេរី វុច្ចតិ ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ អសិក្ខិតសិក្ខា នាម សិក្ខា វា ន ទិន្នា ហោតិ ទិន្នា វា សិក្ខា កុបិតា ។



ខ្ញុំសូមសមាទាននូវមុសាវាទាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវសុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវវិកាលភោជនាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុនីទាំងនោះ ដោយបរិយាយជាច្រើន ។ បេ ។ ម្នាលភិក្ខុនីទាំងឡាយ ពួកភិក្ខុនីគប្បីលើកសិក្ខាបទនេះឡើងសំដែងយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យបួសនូវសាមណេរីដែលមានឆ្នាំពេញ ២០ ហើយ មិនបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ ២ វស្សា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

(៤០៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃពួកគព្ភិនីវគ្គរួចហើយ ។ សាមណេរីមានឆ្នាំដល់ ២០ ហើយ ឈ្មោះថា មានឆ្នាំពេញ ២០ ។ ដែលហៅថា កុមារីភូតា សំដៅយកសាមណេរី ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ ។ សិក្ខាដែលសង្ឃមិនបានឲ្យក្តី សិក្ខាដែលសង្ឃឲ្យហើយតែកម្រើកជាបត្តិ របស់សាមណេរីណា សាមណេរីនោះឈ្មោះថា មិនបានសិក្សាសិក្ខា ។

វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនិំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៤០៣] ធម្មកម្មេ ធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៤០៤] អនាបត្តិ បរិបុណ្ណវីសតិវស្សំ កុមារិភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អាត្មាអញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដក្នុងខណៈចប់ញត្តិ ។ ត្រូវទុក្កដទាំងឡាយ ខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនី ត្រូវអាបត្តិទុក្កដ ។

(៤០៣) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៤០៤) វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់កុមារីភូតាមានឆ្នាំគ្រប់ ២០ ហើយ សិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

## កុមារិភូតវគ្គស្ស តតិយសិក្ខាបទំ

[៤០៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារិភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តិ ។ ភិក្ខុនិយោ ឯវមាហំសុ ឯថ សិក្ខមានា ឥមំ ជានាថ ឥមំ ទេថ ឥមំ អាហរថ ឥមិនា អត្ថោ ឥមំ កប្បិយំ ករោថាតិ ។ តា ឯវមាហំសុ ន មយំ អយ្យេ សិក្ខមានា ភិក្ខុនិយោ មយន្តិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារិភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារិភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេន្តីតិ ។ សច្ចំ

## កុមារីភូតវគ្គ សិក្ខាបទទី ៣

(៤០៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់កុមារីភូតមានឆ្នាំគ្រប់ ២០ ហើយ សិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងហើយ (តែ) សង្ឃមិនបានសន្មត ។ ភិក្ខុនីទាំងឡាយបាននិយាយយ៉ាងនេះថា នែនាងសិក្ខមានា នាងទាំងឡាយចូរមក ចូរដឹងកិច្ចនេះ ចូរឲ្យរបស់នេះ ចូរនាំរបស់នេះមក យើងត្រូវការដោយរបស់នេះ នាងទាំងឡាយចូរធ្វើរបស់នេះឲ្យជាកប្បិយ ។ ភិក្ខុនីបួសថ្មីទាំងឡាយនោះបាននិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនមែនជាសិក្ខមានាទេ យើងខ្ញុំជាភិក្ខុនីទេតើ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់កុមារីភូតមានឆ្នាំពេញ ២០ ហើយសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ (តែ) សង្ឃមិនបានសន្មតសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់កុមារីភូតមានឆ្នាំពេញ ២០ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំ (តែ) សង្ឃមិនបានសន្មត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាប

អប្បិច្ឆា ។ បេ ។ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បរិបុណ្ណវីសតិវស្សំ កុមារីភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បរិបុណ្ណវីសតិវស្សាយ កុមារីភូតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តាយ បរិបុណ្ណវីសតិវស្សាយ កុមារីភូតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អយ្យេ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណវីសតិវស្សា កុមារីភូតា ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា សង្ឃំ វុដ្ឋានសម្មតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា ។ តតិយម្បិ យាចិតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ



ទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យវុដ្ឋាបនដល់កុមារីភូតាមានអាយុពេញ ២០ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ (តែ) សង្ឃមិនបានសន្មតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីសង្ឃឲ្យវុដ្ឋានសម្មតិដល់កុមារីភូតាមានឆ្នាំពេញ ២០ ហើយ សិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ម្នាលភិក្ខុទាំងឡាយ ឯវុដ្ឋានសម្មតិនោះសង្ឃត្រូវឲ្យយ៉ាងនេះ ។ កុមារីភូតាមានឆ្នាំពេញ ២០ ហើយ ដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលី ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់ឈ្មោះនេះជាកុមារីភូតារបស់លោកម្ចាស់ឈ្មោះនេះមានឆ្នាំពេញ ២០ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ ។ វុដ្ឋានសម្មតិនោះត្រូវកុមារីភូតានោះសូមជាគំរប់ការៈពីរដង ត្រូវសូមគំរប់ការៈបីដងផង ។ ភិក្ខុនីដែលឈ្លាសប្រតិពលត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់

សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា សង្ឃំ វុដ្ឋានសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បរិបុណ្ណទ្វាទសវស្សា គិហិគតា ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា សង្ឃំ វុដ្ឋានសម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតឹ ទេតិ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតិយា ទានំ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ គិហិគតាយ ទ្វេ វស្សានិ ឆសុ ធម្មេ-



សូមសង្ឃស្តាប់ខ្ញុំ កុមារីកាអ្នកមានឈ្មោះនេះ របស់លោកម្ចាស់ឈ្មោះនេះមានឆ្នាំពេញ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ ។ បើវុដ្ឋានសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យវុដ្ឋានសម្មតិដល់កុមារីកាអ្នកមានឈ្មោះនេះមានឆ្នាំពេញ ១២ ហើយ ដែលបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ នេះជាញត្តិ ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ កុមារីកាអ្នកមានឈ្មោះនេះ របស់លោកម្ចាស់ឈ្មោះនេះមានឆ្នាំពេញ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ ។ ឥឡូវសង្ឃឲ្យវុដ្ឋានសម្មតិដល់កុមារីកាអ្នកមានឈ្មោះនេះមានឆ្នាំពេញ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ការឲ្យវុដ្ឋានសម្មតិដល់កុមារីកាអ្នកមានឈ្មោះនេះមានឆ្នាំពេញ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ សង្ឃបានឲ្យវុដ្ឋានសម្មតិដល់កុមារីកាអ្នកមានឈ្មោះនេះមានឆ្នាំពេញ ១២ ហើយ បានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាង

សិក្ខិតសិក្ខាយ វុដ្ឋានសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ភគវា តា ភិក្ខុនិយោ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនី បរិបុណ្ណវីសតិវស្សំ កុមារិភូតំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន អសម្មតំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៤១០] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បរិបុណ្ណវីសតិវស្សា នាម បត្តវីសតិវស្សា ។ កុមារិភូតា នាម សាមណេរី វុច្ចតិ ។ ទ្វេ វស្សានីតិ ទ្វេ សំវច្ឆរានិ ។ សិក្ខិតសិក្ខា នាម ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ អសម្មតា នាម ញត្តិទុតិយេន កម្មេន វុដ្ឋានសម្មុតិ ន ទិន្នា ហោតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនិំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ



អស់ពីរឆ្នាំហើយ ។ ការឲ្យវុដ្ឋានសម្មតិនោះគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះដោយបរិយាយដ៏ច្រើន ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់កុមារីភូតាមានឆ្នាំពេញ ២០ ហើយ សិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ដែលសង្ឃមិនបានសន្មត (ឲ្យ) ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៤១០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ កុមារីភូតាមានឆ្នាំដល់ ២០ ហើយ ឈ្មោះថាមានឆ្នាំពេញ ២០ ហើយ ។ ដែលហៅថា កុមារីភូតា សំដៅយកសាមណេរី ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ ។ ដែលហៅថា បានសិក្សាសិក្ខា គឺបានសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាង ។ ដែលហៅថា សង្ឃមិនបានសន្មត គឺសង្ឃមិនបានឲ្យវុដ្ឋានសម្មតិដោយញត្តិទុតិយកម្ម ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មត

អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៦១១] ធម្មកម្មេ ធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។

[៦១២] អនាបត្តិ បរិបុណ្ណវីសតិវស្សំ សិក្ខមានំ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខំ សង្ឃេន សម្មតំ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



សីមាក្ដី ត្រូវអាបត្តិទុក្កដ ។ ត្រូវទុក្កដព្រោះចប់ញត្តិ ត្រូវទុក្កដទាំងឡាយព្រោះចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារ្យនីត្រូវអាបត្តិទុក្កដ

[៦១១] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៦១២] អា. ដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់កុមារីក្លាមានឆ្នាំពេញ២០ហើយ សិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ សង្ឃសន្មតហើយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីមុនបញ្ញត្តិ ១ ។

# កុមារីភូតវគ្គស្ស ចតុត្ថសិក្ខាបទំ

(៤១៣) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ឩនទ្វាទសវស្សា វុដ្ឋាបេន្តិ ។ តា ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ សទ្ធិវិហារិនិយោបិ ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឩនទ្វាទសវស្សា វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ឩនទ្វាទសវស្សា វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ឩនទ្វាទសវស្សា វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី ឩនទ្វាទសវស្សា វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

# កុមារីភូតវគ្គ សិក្ខាបទទី ៤

(៤១៣) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់ ១២ ឲ្យបួសឧបសម្បទា (ដល់ស្រីដទៃ) ។ ភិក្ខុនីជាឧបជ្ឈាយ៍ទាំងឡាយនោះល្ងង់មិនឈ្លាសមិនដឹងការគួរ ឬមិនគួរ ។ ពួកសទ្ធិវិហារិនី(ក៏)ល្ងង់មិនឈ្លាសមិនដឹងការគួរ ឬមិនគួរដែរ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់ ១២ មិនគួរបើនឹងឲ្យបួសឧបសម្បទា (ដល់ស្រីដទៃ) សោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់ ១២ ឲ្យបួសឧបសម្បទា (ដល់ស្រីដទៃ) ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់ ១២ មិនសមបើនឹងឲ្យបួសឧបសម្បទា (ដល់ស្រីដទៃ) ទេ ម្នាលភិក្ខុទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមានវស្សាមិនគ្រប់ ១២ ហើយឲ្យបួសឧបសម្បទា (គេ) ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៦១៦) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឩ-នទ្វាទសវស្សា នាម អប្បត្តទ្វាទសវស្សា ។ វុដ្ឋាបេយ្យា-តិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិ-យស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

(៦១៧) អនាបត្តិ បរិបុណ្ណទ្វាទសវស្សា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## កុមារីភូតវគ្គស្ស បញ្ចមសិក្ខាបទំ

[៦១៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សា សង្ឃេន អសម្មតា វុដ្ឋាបេន្តិ ។ តា ពាលា ហោន្តិ



[៦១៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយដូចក្នុងសិក្ខាបទទី ១ នៃពួកពិតកណ្ឌរួចហើយ ។ ភិក្ខុនីមានវស្សាមិនទាន់ដល់ ១២ ឈ្មោះថា មានវស្សាមិនគ្រប់ ១២ ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អាត្មានឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ។ ត្រូវទុក្កដ ព្រោះគណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយ ព្រោះគណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនី ត្រូវអាបត្តិទុក្កដ ។

(៦១៧) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីមានវស្សាពេញ ១២ ហើយឲ្យឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

---

## កុមារីភូតវគ្គ សិក្ខាបទទី ៥

[៦១៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយមានវស្សាពេញ ១២ បរិបូណ៌ហើយ (តែ) សង្ឃមិនបានសន្មត ក៏ឲ្យឧបសម្បទា (ដល់ពួកកុលធីតា) ។ ភិក្ខុនីទាំងនោះល្ងង់

អនុញ្ញាតា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ សទ្ធិវិហារិនិយោបិ ពាលា ហោន្តិ អព្យត្តា ន ជានន្តិ កប្បិយំ វា អកប្បិយំ វា ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សា សង្ឃេន អសម្មតា វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សា សង្ឃេន អសម្មតា វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ បរិបុណ្ណទ្វាទសវស្សា សង្ឃេន អសម្មតា វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បរិបុណ្ណទ្វាទសវស្សាយ ភិក្ខុនិយា វុដ្ឋាបនសម្មុតឹ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ តាយ បរិបុណ្ណទ្វាទសវស្សាយ ភិក្ខុនិយា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា វុឌ្ឍានំ



មិនឈ្លាស មិនដឹងការគួរ ឬមិនគួរ ។ ពួកភិក្ខុនីជាសទ្ធិវិហារិនី ក៏ល្ងង់ មិនឈ្លាស មិនស្គាល់ការគួរ ឬមិនគួរ(ដូចគ្នាដែរ) ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមានវស្សាពេញ ១២ហើយ (តែ) សង្ឃមិនបានសន្មត មិនសមបើនឹងឲ្យឧបសម្បទាសោះ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមានវស្សាពេញ ១២ហើយ សង្ឃមិនបានសន្មត ហើយឲ្យឧបសម្បទា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមានវស្សាពេញ ១២ហើយ (តែ) សង្ឃមិនបានសន្មត មិនគួរនឹងឲ្យឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនទាំងឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីដែលមានវស្សាពេញ ១២ហើយ ។ ម្នាលភិក្ខុទាំងឡាយ គឺវុដ្ឋាបនសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ ។ គឺភិក្ខុនីដែលមានវស្សាពេញ ១២ហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុនីដែលចាស់ ។

ភិក្ខុនីនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ អយ្យេ ឥត្ថន្នាមា បរិបុណ្ណទ្វាទសវស្សា ភិក្ខុនី សង្ឃំ វុដ្ឋាបនសម្មុតឹ យាចាមីតិ ។ ទុតិយម្បិ យាចិតព្វា ។ តតិយម្បិ យាចិតព្វា ។ សា ភិក្ខុនី សង្ឃេន បរិច្ឆិន្ទិតព្វា[១] ព្យត្តាយំ ភិក្ខុនី លជ្ជិនីតិ ។ សចេ ពាលា ច ហោតិ អលជ្ជិនី ច ន ទាតព្វា ។ សចេ ពាលា ហោតិ លជ្ជិនី ន ទាតព្វា ។ សចេ ព្យត្តា ហោតិ អលជ្ជិនី ន ទាតព្វា ។ សចេ ព្យត្តា ច ហោតិ លជ្ជិនី ច ទាតព្វា ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា បរិបុណ្ណទ្វាទសវស្សា ភិក្ខុនី សង្ឃំ វុដ្ឋាបនសម្មុតឹ យាចតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ ភិក្ខុនិយា វុដ្ឋាបនសម្មុតឹ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ

១ ម. បរិច្ឆិតព្វា ។



ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលយ៉ាងនេះថា បពិត្រព្រះសង្ឃជាម្ចាស់ ខ្ញុំមានឈ្មោះនេះ ជាភិក្ខុនីមានវស្សាពេញ ១២ ហើយ សូមវុដ្ឋាបនសម្មតិនឹងសង្ឃ ។ ភិក្ខុនីនោះត្រូវសូមវុដ្ឋាបនសម្មតិនោះអស់វារៈពីរដងផង ត្រូវសូមអស់វារៈបីដងផង ។ ភិក្ខុនីនោះសង្ឃគប្បីកំណត់ឲ្យដឹងថា ភិក្ខុនីនេះជាអ្នកឆ្លាសមានសេចក្តីអៀនខ្មាស ។ បើភិក្ខុនីនោះល្ងង់ផង មិនមានសេចក្តីខ្មាសផង សង្ឃមិនគប្បីឲ្យវុដ្ឋាបនសម្មតិទេ បើភិក្ខុនីនោះល្ងង់ (តែ) មានសេចក្តីខ្មាស សង្ឃក៏មិនគប្បីឲ្យ បើភិក្ខុនីឆ្លាស (តែ) មិនមានសេចក្តីខ្មាស សង្ឃក៏មិនគប្បីឲ្យ (ដែរ) បើភិក្ខុនីនោះឆ្លាសផង មានសេចក្តីខ្មាសផង សង្ឃគប្បីឲ្យបាន ។ ម្នាលភិក្ខុទាំងឡាយ ក៏វុដ្ឋាបនសម្មតិនោះសង្ឃគប្បីឲ្យយ៉ាងនេះ ។ គឺភិក្ខុនីដែលឆ្លាសប្រតិពលគប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះមានវស្សាពេញ ១២ ហើយ សូមវុដ្ឋាបនសម្មតិនឹងសង្ឃ ។ បើវុដ្ឋាបនសម្មតិកម្មនេះមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីមានឈ្មោះនេះ ដែលមានវស្សាពេញ ១២ ហើយ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ

អយំ ឥត្ថន្នាមា បរិបុណ្ណទ្វាទសវស្សា ភិក្ខុនី សង្ឃំ វុដ្ឋាបនសម្មុតឹ យាចតិ ។ សង្ឃោ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ ភិក្ខុនិយា វុដ្ឋាបនសម្មុតឹ ទេតិ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ ភិក្ខុនិយា វុដ្ឋាបនសម្មុតិយា ទានំ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមាយ បរិបុណ្ណទ្វាទសវស្សាយ ភិក្ខុនិយា វុដ្ឋាបនសម្មុតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ភគវា តា ភិក្ខុនិយោ អនេកបរិយាយេន វិគរហិត្វា ធម្មីកថាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី បរិបុណ្ណទ្វាទសវស្សា សង្ឃេន អសម្មតា វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៤០៧] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បរិបុណ្ណទ្វាទសវស្សា នាម បត្តទ្វាទសវស្សា ។ អសម្មតា



ភិក្ខុនីនេះមានឈ្មោះនេះមានវស្សាពេញ ១២ ហើយ សូមវុដ្ឋាបនសម្មតិនឹងសង្ឃ ។ សង្ឃឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីឈ្មោះនេះមានវស្សាពេញ ១២ ហើយ ។ ការឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីឈ្មោះនេះមានវស្សាពេញ ១២ ហើយ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគប្បីនិយាយឡើង ។ សង្ឃបានឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីឈ្មោះនេះ មានវស្សាពេញ ១២ ហើយ ។ ការឲ្យវុដ្ឋាបនសម្មតិនោះគួរដល់សង្ឃហើយ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់តិះដៀលភិក្ខុនីទាំងឡាយនោះដោយបរិយាយដ៏ច្រើន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមានវស្សា ១២ បរិបូណ៌ហើយ សង្ឃមិនបានសន្មត (ហើយឲ្យឧបសម្បទា) ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤០៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ភិក្ខុនីមានវស្សាដល់ ១២ ហើយ ឈ្មោះថា មានវស្សា ១២ បរិបូណ៌ហើយ ។ ភិក្ខុនីដែលសង្ឃ

នាម ញត្តិទុតិយេន កម្មេន វុដ្ឋានសម្មុតិ ន ទិន្នា ហោតិ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៤០៨] ធម្មកម្មេ ធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញា វុដ្ឋាបេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញា អាបត្តិ ទុក្កដស្ស ។





មិនបានឲ្យវុដ្ឋានសម្មតិដោយញត្តិទុតិយកម្ម ឈ្មោះថា សង្ឃមិនបានសន្មត ។ ពាក្យថា ឲ្យឧបសម្បទា គឺញុំាងកុលធីតាឲ្យដល់នូវគុណធំក្រៃលើ (គឺសេចក្ដីជាភិក្ខុនីភាព) ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្ដី អាចារិនីក្ដី បាត្រក្ដី ចីវរក្ដី សន្មតសីមាក្ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីត្រូវទុក្កដព្រោះចប់ញត្តិ ត្រូវទុក្កដទាំងពីរព្រោះចប់កម្មវាចាពីរ លុះចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនឹងអាចារិនីត្រូវអាបត្តិទុក្កដ ។

(៤០៨) កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៦១៩] អនាបត្តិ បរិបុណ្ណទ្វាទសវស្សា សង្ឃេន សម្មតា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## កុមារីភូតវគ្គស្ស ឆដ្ឋសិក្ខាបទំ

[៦២០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី ភិក្ខុនិសង្ឃំ ឧបសង្កមិត្វា វុដ្ឋាបនសម្មុតឹ យាចតិ ។ អថខោ ភិក្ខុនិសង្ឃោ ថុល្លនន្ទំ ភិក្ខុនឹ បរិគ្គណ្ហិត្វា អលំ តាវ តេ អយ្យេ វុដ្ឋាបិតេនាតិ វុដ្ឋាបនសម្មុតឹ ន អទាសិ ។ ថុល្លនន្ទា ភិក្ខុនី សាធូតិ បដិស្សុណិ ។ តេន ខោ បន សមយេន ភិក្ខុនិសង្ឃោ អញ្ញាសំ ភិក្ខុនីនំ វុដ្ឋាបនសម្មុតឹ ទេតិ ។ ថុល្លនន្ទា ភិក្ខុនី ឧជ្ឈាយតិ ខីយតិ វិបាចេតិ អហមេវ នូន ពាលា អហមេវ អលជ្ជិនី យំ សង្ឃោ អញ្ញាសំ ភិក្ខុនីនំ វុដ្ឋាបនសម្មុតឹ ទេតិ មយ្ហមេវ ន ទេតីតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា



[៦១៩] ពួកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីមានវស្សា ១២ បរិបូណ៌ហើយ សង្ឃបានសន្មតហើយ ឲ្យឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

---

## កុមារីភូតវគ្គ សិក្ខាបទទី ៦

[៦២០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ចូលទៅរកភិក្ខុនីសង្ឃហើយសូមវុដ្ឋាបនសម្មតិ ។ លំដាប់នោះឯង ភិក្ខុនីសង្ឃសង្កេតថុល្លនន្ទាភិក្ខុនីហើយឃាត់ថា នែវលោកម្ចាស់ លោកមិនគួរនឹងឲ្យឧបសម្បទានោះឡើយទេ ហើយក៏មិនឲ្យវុដ្ឋាបនសម្មតិ ។ ថុល្លនន្ទាភិក្ខុនីទទួលពាក្យថាសាធុ ។ គ្រាសម័យនោះឯង ភិក្ខុនីសង្ឃ ឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីទាំងឡាយដទៃ ។ ថុល្លនន្ទាភិក្ខុនីពោលទោស តិះដៀល បន្តុះបង្អាប់ថា ខ្ញុំឯងល្ងង់ទេ ខ្ញុំឯងមិនមានសេចក្តីខ្មាស (បានជា) សង្ឃឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីទាំងឡាយដទៃ មិនឲ្យដល់ខ្ញុំ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ

ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ចណ្ឌ-
កាលី អលន្តាវ តេ អយ្យេ វុដ្ឋាបិតេនាតិ វុច្ចមានា
សាធូតិ បដិស្សុណិត្វា បច្ឆា ខីយនធម្មំ[១] អាបជ្ជិស្សតីតិ
។បេ។ សច្ចំ កិរ ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី អលន្តាវ
តេ អយ្យេ វុដ្ឋាបិតេនាតិ វុច្ចមានា សាធូតិ បដិស្សុណិត្វា
បច្ឆា ខីយនធម្មំ អាបជ្ជតីតិ[២] ។ សច្ចំ ភគវាតិ ។ វិគរហិ
ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ចណ្ឌកាលី ភិក្ខុនី
អលន្តាវ តេ អយ្យេ វុដ្ឋាបិតេនាតិ វុច្ចមានា សាធូតិ
បដិស្សុណិត្វា បច្ឆា ខីយនធម្មំ អាបជ្ជិស្សតិ នេតំ ភិក្ខវេ
អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ
ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី
អលន្តាវ តេ អយ្យេ វុដ្ឋាបិតេនាតិ វុច្ចមានា សាធូតិ ប-
ដិស្សុណិត្វា បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ បាចិត្តិយន្តិ ។

១ ឱ. ម. ខីយធម្មំ ។ ឯវំ សព្វត្ថ ញាតព្វំ ។ ២ ឱ. ម. អាបជ្ជីតិ ។



ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ចណ្ឌកាលី កាល
ដែលសង្ឃឃាត់ថា នែនាងម្ចាស់ មិនគួរនាងឲ្យបួសឧបសម្បទាទៅឡើយទេ
ដូច្នេះ ទទួលពាក្យថាសាធុហើយ មិនគួរនឹងពោលតិះដៀលជាខាង
ក្រោយសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ
ឮថា ចណ្ឌកាលីភិក្ខុនីកាលដែលសង្ឃឃាត់ថា នែលោកម្ចាស់ មិនគួរ
នាងឲ្យបួសឧបសម្បទាទៅឡើយទេដូច្នេះ ទទួលពាក្យថាសាធុហើយ តែ
ក្រោយត្រឡប់តិះដៀលវិញ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូល
ថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់
បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនី កាលសង្ឃឃាត់ថា
នែនាងម្ចាស់ មិនគួរនាងឲ្យបួសឧបសម្បទាទៅឡើយទេដូច្នេះ ទទួលពាក្យ
ថាសាធុហើយ មិនគួរបើនឹងពោលតិះដៀលជាខាងក្រោយទេ ម្នាលភិក្ខុ
ទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះ-
ថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវ
សិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយកាលដែលសង្ឃនិយាយថា នែ
លោកម្ចាស់ មិនគួរលោកឲ្យបួសឧបសម្បទាទៅឡើយទេដូច្នេះ ទទួលពាក្យ
ថាសាធុហើយ តែក្រោយត្រឡប់តិះដៀលវិញ ត្រូវអាបត្តិបាចិត្តិយ ។

(៤៦១) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អលំ តាវ តេ អយ្យេ វុដ្ឋាបិតេនាតិ អលំ តាវ តេ អយ្យេ ឧបសម្បាទិតេន ។ សាធូតិ បដិស្សុណិត្វា បច្ឆា ខីយនធម្មំ អាបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។

(៤៦២) អនាបត្តិ បកតិយា ឆន្ទា ទោសា មោហា ភយា ករោន្តំ ខីយតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## កុមារីភូតវគ្គស្ស សត្តមសិក្ខាបទំ

(៤៦៣) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា សិក្ខមានា ថុល្លនន្ទំ ភិក្ខុនឹ ឧបសង្កមិត្វា ឧបសម្បទំ យាចិ ។ ថុល្លនន្ទា ភិក្ខុនី តំ សិក្ខមានំ សចេ មេ ត្វំ អយ្យេ ចីវរំ ទស្សសិ ឯវាហំ វុដ្ឋាបេស្សាមីតិ ។ នេវ វុដ្ឋាបេតិ



(៤៦១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយដូចក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា នែលោកម្ចាស់ មិនឲ្យលោកឲ្យឧបសម្បទាទៅឡើយទេ សេចក្តីថា នែលោកម្ចាស់ លោកមិនគួរញុំាងកុលធីតាឲ្យបានឧបសម្បទាទៅឡើយទេ ។ ភិក្ខុនីទទួលពាក្យថា សាធុ ហើយ ក្រោយមកត្រឡប់តិះដៀលវិញ ត្រូវអាបត្តិបាចិត្តិយ ។

(៤៦២) អាបត្តិមិនត្រូវ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីតិះដៀលសង្ឃដែលធ្វើព្រោះសេចក្តីស្រឡាញ់ ព្រោះស្អប់ ព្រោះវង្វេង ព្រោះខ្លាចដោយប្រក្រតី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## កុមារីភូតវគ្គ សិក្ខាបទទី ៨

(៤៦៣) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សិក្ខមានា ១ រូប ចូលទៅរកថុល្លនន្ទាភិក្ខុនី ហើយសូមឧបសម្បទា ។ ថុល្លនន្ទាភិក្ខុនី និយាយនឹងសិក្ខមានានោះថា នែនាងម្ចាស់ បើនាងឲ្យចីវរដល់យើង យើងនឹងឲ្យនាងម្ចាស់បានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយក៏មិនឲ្យសិក្ខមានានោះបានឧបសម្បទាសោះ តាំងមិនធ្វើសេចក្តីខ្វល់ខ្វាយ

ន វុដ្ឋាបនាយ ឧស្សុក្កំ ករោតិ ។ អថខោ សា
សិក្ខមានា ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា
ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ
វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា សិក្ខ-
មានំ សចេ មេ ត្វំ អយ្យេ ចីវរំ ទស្សសិ ឯវាហំ
តំ វុដ្ឋាបេស្សាមីតិ វត្វា នេវ វុដ្ឋាបេស្សតិ ន វុដ្ឋាបនាយ
ឧស្សុក្កំ ករិស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ
ថុល្លនន្ទា ភិក្ខុនី សិក្ខមានំ សចេ មេ ត្វំ អយ្យេ
ចីវរំ ទស្សសិ ឯវាហំ តំ វុដ្ឋាបេស្សាមីតិ វត្វា នេវ
វុដ្ឋាបេតិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករោតីតិ ។ សច្ចំ
ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម
ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សិក្ខមានំ សចេ មេ ត្វំ
អយ្យេ ចីវរំ ទស្សសិ ឯវាហំ តំ វុដ្ឋាបេស្សាមីតិ វត្វា
នេវ វុដ្ឋាបេស្សតិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករិស្សតិ
នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។



ដើម្បីឲ្យបានឧបសម្បទា ។ ទើបសិក្ខមានានោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនី
ទាំងឡាយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។បេ។
ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់
ថុល្លនន្ទាមិនគួរបើនឹងនិយាយនឹងសិក្ខមានាថា នែនាងម្ចាស់ បើនាងនឹងឲ្យ
ចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះដូច្នេះ
ហើយមិនឲ្យសិក្ខមានានោះបានឧបសម្បទា ទាំងមិនធ្វើសេចក្ដីខ្វល់ខ្វាយ
ដើម្បីឲ្យបានឧបសម្បទាសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាល
ភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីនិយាយនឹងសិក្ខមានាដូច្នេះថា នែនាង
ម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទាដោយ
អាការយ៉ាងនេះ ហើយមិនឲ្យសិក្ខមានានោះបានឧបសម្បទា ទាំងមិនធ្វើ
សេចក្ដីខ្វល់ខ្វាយដើម្បីឲ្យបានឧបសម្បទា ពិតមែនឬ ។ ភិក្ខុទាំងឡាយ
ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មាន
ព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹង
និយាយនឹងសិក្ខមានាដូច្នេះថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង
យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ ហើយមិនឲ្យបានឧប
សម្បទា ទាំងមិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីឲ្យបានឧបសម្បទាទេ ម្នាល
ភិក្ខុទាំងឡាយ កិរិយានេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ

ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យ យា បន ភិក្ខុនី សិក្ខមានំ សចេ មេ ត្វំ អយ្យេ ចីវរំ ទស្សសិ ឯវាហន្តំ វុដ្ឋាបេស្សាមីតិ វត្វា សា បច្ឆា អនន្តរាយិកិនី នេវ វុដ្ឋាបេយ្យ ន វុដ្ឋាបនាយ ឧស្សុក្កំ ករេយ្យ បាចិត្តិយន្តិ ។

(៤៦៤) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សិក្ខមានា នាម ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ សចេ មេ ត្វំ អយ្យេ ចីវរំ ទស្សសិ ឯវាហន្តំ វុដ្ឋាបេស្សាមីតិ ឯវាហន្តំ ឧបសម្បាទេស្សាមីតិ ។ សា បច្ឆា អនន្តរាយិកិនីតិ អសតិ អន្តរាយេ ។ នេវ វុដ្ឋាបេយ្យាតិ ន សយំ វុដ្ឋាបេយ្យ ។ ន វុដ្ឋាបនាយ ឧស្សុក្កំ ករេយ្យាតិ ន អញ្ញំ អាណាបេយ្យ ។ នេវ វុដ្ឋាបេស្សាមិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។





។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយនិយាយនឹងសិក្ខមានាដូច្នេះថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ ដល់ត្រាក្រោយភិក្ខុនីនោះមិនមានសេចក្ដីអន្តរាយ ហើយមិនឲ្យ (សិក្ខមានានោះ) បានឧបសម្បទា មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីឲ្យបានឧបសម្បទា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៦៤) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌប្រាប់ហើយ ។ ស្រីដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាង អស់ពីរឆ្នាំហើយ ឈ្មោះថាសិក្ខមានា ។ ពាក្យថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ សេចក្ដីថា យើងនឹងបំបួសនាងជាភិក្ខុនីដោយអាការយ៉ាងនេះ ។ ពាក្យថា ដល់ត្រាក្រោយភិក្ខុនីនោះមិនមានសេចក្ដីអន្តរាយ គឺកាលបើមិនមានសេចក្ដីអន្តរាយ ។ ពាក្យថា មិនឲ្យសិក្ខមានានោះបានឧបសម្បទា គឺមិនបំបួស (សិក្ខមានានោះ) ជាភិក្ខុនីដោយខ្លួនឯង ។ ពាក្យថា មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីឲ្យបានឧបសម្បទា គឺមិនបង្គាប់ភិក្ខុនីដទៃ ។ ភិក្ខុនីនោះគ្រាន់តែដាក់ធុរៈថា អញនឹងមិនឲ្យបានឧបសម្បទា នឹងមិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីឲ្យគេឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។

[៤៤៥] អនាបត្តិ សចេ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## កុមារីភូតវគ្គស្ស អដ្ឋមសិក្ខាបទំ

(៤៤៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា សិក្ខមានា ថុល្លនន្ទំ ភិក្ខុនឹ ឧបសង្កមិត្វា ឧបសម្បទំ យាចិ ។ ថុល្លនន្ទា ភិក្ខុនី តំ សិក្ខមានំ[១] សចេ មំ ត្វំ អយ្យេ ទ្វេ វស្សានិ អនុពន្ធិស្សសិ ឯវាហំ តំ វុដ្ឋាបេស្សាមីតិ ។ សា ន វុដ្ឋាបេតិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករោតិ ។ អថ ខោ សា សិក្ខមានា ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា សិក្ខមានំ សចេ មំ ត្វំ អយ្យេ ទ្វេ វស្សានិ

១ ម. ឯត្ថន្តរេ និគហោបាតិ ទិស្សតិ ។



[៤៤៥] ភិក្ខុនីដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៥ យ៉ាង) គឺកាលបើមានសេចក្តីអន្តរាយ ភិក្ខុនីស្វែងរក (ភិក្ខុនីដទៃ) មិនបាន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## កុមារីភូតវគ្គ សិក្ខាបទទី ៨

(៤៤៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សិក្ខមានាមួយរូប ចូលទៅរកថុល្លនន្ទាភិក្ខុនី ហើយសូមឧបសម្បទា ។ ថុល្លនន្ទាភិក្ខុនីនិយាយនឹងសិក្ខមានានោះថា នែនាងម្ចាស់ បើនាងនឹងកាន់បម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យឧបសម្បទាសោះ ។ ទើបសិក្ខមានានោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងនិយាយនឹងសិក្ខមានាថា នែនាង បើនាងនឹងកាន់បម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទា

អនុពន្ធិស្សសិ ឯវាហំ វុដ្ឋាបេស្សាមីតិ វត្វា នេវ វុដ្ឋាបេស្សតិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សិក្ខមានំ សចេ មំ ត្វំ អយ្យេ ទ្វេ វស្សានិ អនុពន្ធិស្សសិ ឯវាហំ វុដ្ឋាបេស្សាមីតិ វត្វា នេវ វុដ្ឋាបេតិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករោតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី សិក្ខមានំ សចេ មំ ត្វំ អយ្យេ ទ្វេ វស្សានិ អនុពន្ធិស្សសិ ឯវាហំ វុដ្ឋាបេស្សាមីតិ វត្វា នេវ វុដ្ឋាបេស្សតិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី សិក្ខមានំ សចេ មំ ត្វំ អយ្យេ ទ្វេ វស្សានិ អនុពន្ធិស្សសិ ឯវាហំ វុដ្ឋាបេស្សាមីតិ វត្វា សា បច្ឆា អនន្តរាយិកិនី នេវ វុដ្ឋាបេយ្យ ន វុដ្ឋាបនាយ ឧស្សុក្កំ ករេយ្យ បាចិត្តិយន្តិ ។





ដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យឧបសម្បទានោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីនិយាយនឹងសិក្ខមានាថា នែនាង បើនាងនឹងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យឧបសម្បទា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងនិយាយនឹងសិក្ខមានាថា នែនាង បើនាងនឹងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទានឹងមិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយនិយាយនឹងសិក្ខមានាថា នែនាង បើនាងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ តែក្រោយភិក្ខុនីនោះមិនមានសេចក្តីអន្តរាយ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យឧបសម្បទា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៦៦៧] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សិក្ខមានា នាម ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ សចេ មេ ត្វំ អយ្យេ ទ្វេ វស្សានិ អនុពន្ធិស្សសីតិ ទ្វេ វស្សានិ ឧបដ្ឋហិស្សសិ ។ ឯវាហន្តំ វុដ្ឋាបេស្សាមីតិ ឯវាហន្តំ ឧបសម្បាទេស្សាមិ ។ សា បច្ឆា អនន្តរាយិកិនីតិ អសតិ អន្តរាយេ ។ នេវ វុដ្ឋាបេយ្យាតិ ន សយំ វុដ្ឋាបេយ្យ ។ ន វុដ្ឋាបនាយ ឧស្សុក្កំ ករេយ្យាតិ ន អញ្ញំ អាណាបេយ្យ ។ នេវ វុដ្ឋាបេស្សាមិ ន វុដ្ឋាបនាយ ឧស្សុក្កំ ករិស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

[៦៦៨] អនាបត្តិ សតិ អន្តរាយេ បរិយេសិត្វា ន លភតិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



[៦៦៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ស្រីដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាង អស់ពីរឆ្នាំ ឈ្មោះថាសិក្ខមានា ។ ពាក្យថា នែនាង បើនាងនឹងតាមបម្រើអស់ពីរឆ្នាំ សេចក្តីថា នាងនឹងបម្រើអស់ពីរឆ្នាំ ។ ពាក្យថា យើងនឹងឲ្យនាងបានឧបសម្បទាដោយអាការយ៉ាងនេះ សេចក្តីថា យើងនឹងបំបួសនាងជាភិក្ខុនីដោយអាការយ៉ាងនេះ ។ ពាក្យថា គ្រាក្រោយភិក្ខុនីនោះមិនមានសេចក្តីអន្តរាយ គឺកាលបើមិនមានសេចក្តីអន្តរាយ ។ ពាក្យថា មិនឲ្យឧបសម្បទា គឺមិនឲ្យឧបសម្បទាដោយខ្លួនឯង ។ ពាក្យថា មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យឧបសម្បទា គឺមិនបង្គាប់ភិក្ខុនីដទៃ ។ ភិក្ខុនីនោះត្រាន់តែដាក់ធុរៈថា អាត្មានឹងមិនឲ្យឧបសម្បទា នឹងមិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។

[៦៦៨] ភាពដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីមានសេចក្តីអន្តរាយហើយស្វែងរក (ភិក្ខុនីដទៃ) មិនបាន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ (គ្រោះថ្នាក់) ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

# កុមារីភូតវគ្គស្ស នវមសិក្ខាបទំ

[៦៤៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី បុរិសសំសដ្ឋំ កុមារកសំសដ្ឋំ ចណ្ឌឹ សោកាវស្សំ[១] ចណ្ឌកាលឹ សិក្ខមានំ វុដ្ឋាបេតិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា បុរិសសំសដ្ឋំ កុមារកសំសដ្ឋំ ចណ្ឌឹ សោកាវស្សំ ចណ្ឌកាលឹ សិក្ខមានំ វុដ្ឋាបេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី បុរិសសំសដ្ឋំ កុមារកសំសដ្ឋំ ចណ្ឌឹ សោកាវស្សំ ចណ្ឌកាលឹ សិក្ខមានំ វុដ្ឋាបេតីតិ[២] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី បុរិសសំសដ្ឋំ កុមារកសំសដ្ឋំ ចណ្ឌឹ សោកាវស្សំ ចណ្ឌកាលឹ សិក្ខមានំ វុដ្ឋាបេស្សតិ នេតំ

១ ម. សោកាវាសំ ។ ឯវំ សព្វត្ថ ញាតព្វំ ។ ២ ម. វុដ្ឋាបេសីតិ ។

# កុមារីភូតវគ្គ សិក្ខាបទទី ៩

[៦៤៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ឲ្យសិក្ខមានាឈ្មោះចណ្ឌកាលីជាស្រីច្រឡូកច្រឡំដោយបុរស ច្រឡូកច្រឡំដោយក្មេងប្រុស ជាស្រីកាចជាស្រីបណ្ដាលសេចក្ដីសោក (ដល់បុរសដទៃ) ឲ្យបានឧបសម្បទា ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនគួរបើនឹងឲ្យចណ្ឌកាលីសិក្ខមានាដែលច្រឡូកច្រឡំនឹងប្រុស ច្រឡូកច្រឡំនឹងក្មេងប្រុស ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោកឲ្យបានឧបសម្បទាសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យចណ្ឌកាលីសិក្ខមានាដែលជាស្រីច្រឡូកច្រឡំដោយប្រុស ច្រឡូកច្រឡំដោយក្មេងប្រុស ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោកឲ្យបានឧបសម្បទា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសមបើនឹងឲ្យចណ្ឌកាលីសិក្ខមានាដែលជាស្រីច្រឡូកច្រឡំដោយប្រុស ច្រឡូកច្រឡំដោយក្មេងប្រុស ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោក ឲ្យបាន

ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី បុរិសសំសដ្ឋំ កុមារកសំសដ្ឋំ ចណ្ឌឹ សោកាវាសំ សិក្ខមានំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៤៣០] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បុរិសោ នាម បត្តវីសតិវស្សោ ។ កុមារកោ នាម អប្បត្តវីសតិវស្សោ ។ សំសដ្ឋា នាម អននុលោមិកេន កាយិកវាចសិកេន សំសដ្ឋា ។ ចណ្ឌី នាម កោធនា វុច្ចតិ ។ សោកាវាសា នាម បរេសំ ទុក្ខំ ឧប្បាទេតិ សោកំ អាវិសតិ ។ សិក្ខមានា នាម ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ



ប្រសើរទេ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយញ៉ាំងសិក្ខមានាដែលច្រឡូកច្រឡំដោយបុរស ដែលច្រឡូកច្រឡំដោយកុមារ ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោក ឲ្យបានឧបសម្បទា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៣០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ ។ ជនដែល(មានអាយុ)ដល់២០ឆ្នាំហើយ ឈ្មោះថាបុរស ។ ក្មេងប្រុសដែលមិនទាន់ដល់២០ឆ្នាំ ឈ្មោះថាកុមារ ។ សិក្ខមានាដែលពាក់ព័ន្ធដោយកិច្ចប្រព្រឹត្តទៅក្នុងកាយនិងកិច្ចប្រព្រឹត្តទៅក្នុងវាចាមិនសមគួរ ឈ្មោះថាច្រឡូកច្រឡំ ។ សិក្ខមានាដែលឈ្មោះថា ជាស្រីកាច សំដៅយកស្រីដែលមានសេចក្ដីក្រោធ ។ ដែលឈ្មោះថា ជាស្រីបណ្ដាលសេចក្ដីសោក គឺសិក្ខមានាញ៉ាំងសេចក្ដីទុក្ខឲ្យកើតឡើង គឺញ៉ាំងសេចក្ដីសោកឲ្យចូលត្រងសន្ដានដល់ពួកជនដទៃ ។ ស្រីដែលសិក្សាសិក្ខាក្នុងធម៌៦ យ៉ាងអស់ពីរឆ្នាំហើយ ឈ្មោះថាសិក្ខមានា ។ ពាក្យថា ឲ្យឧបសម្បទា គឺឲ្យបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្ដី គរុនីក្ដី បាត្រក្ដី ចីវរក្ដី សន្មតសីមាក្ដី

អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបដ្ឋាបេន្តិយា អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៤៣៧] អនាបត្តិ អជានន្តី វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## កុមារិភូតវគ្គស្ស ទសមសិក្ខាបទំ

[៤៣៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី មាតាបិតូហិបិ សាមិកេនបិ អននុញ្ញាតំ សិក្ខមានំ វុដ្ឋាបេតិ ។ មាតាបិតរោបិ សាមិកោបិ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា អម្ហេហិ អននុញ្ញាតំ សិក្ខមានំ វុដ្ឋាបេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ មាតាបិតូនំបិ សាមិកស្សបិ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ



ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីត្រូវទុក្កដ ខណៈចប់ញត្តិ ត្រូវទុក្កដពីរ ខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនីត្រូវអាបត្តិទុក្កដ ។

[៤៣៧] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺ ភិក្ខុនីកាលមិនដឹងឲ្យឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិកៈ ១ ។

---

## កុមារិភូតវគ្គ សិក្ខាបទទី ១០

[៤៣៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន
របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីឲ្យ
សិក្ខមានាដែលមាតាបិតាផង ស្វាមីផង មិនបានអនុញ្ញាតឲ្យឧបសម្បទា ។
មាតាបិតាផង ស្វាមីផង ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកថុល្លន
ថុល្លនន្ទា មិនសមបើនឹងឲ្យសិក្ខមានាដែលយើងមិនបានអនុញ្ញាតបានឧប
សម្បទាសោះ ។ ភិក្ខុនីទាំងឡាយបានឮមាតាបិតាផង ស្វាមីផង កំពុងពោល
ទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយឯណា មានសេចក្ដី

អបញ្ញត្ត ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា ថុល្លនន្ទា មាតាបិតូហិ អននុញ្ញាតំ សិក្ខមានំ វុដ្ឋាបេស្សតីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី មាតាបិតូហិ អននុញ្ញាតំ សិក្ខមានំ វុដ្ឋាបេតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ថុល្លនន្ទា ភិក្ខុនី មាតាបិតូហិ អននុញ្ញាតំ សិក្ខមានំ វុដ្ឋាបេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី មាតាបិតូហិ វា សាមិកេន វា អននុញ្ញាតំ សិក្ខមានំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

(៤៣៣) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ មាតាបិតរោ នាម ជនកា វុច្ចន្តិ ។ សាមិកោ នាម យេន បរិគ្គហិតា ហោតិ ។ អននុញ្ញាតាតិ អនាបុច្ឆា ។



ទ្រាំទ្រាំមិនបាន ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ម្តេចក៏នាងថុល្លនន្ទាមិនសុំមាតាបិតាសិន ឲ្យសិក្ខមានាដែលមាតាបិតាផង ស្វាមីផង មិនបានអនុញ្ញាតបួសឧបសម្បទាសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យសិក្ខមានាដែលមាតាបិតាផង ស្វាមីផង មិនទាន់អនុញ្ញាតបួសឧបសម្បទា ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីមិនសុំមាតាបិតាសិនឲ្យសិក្ខមានាដែលមាតាបិតាផង ស្វាមីផង មិនបានអនុញ្ញាតបួសឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ញុំាងសិក្ខមានាដែលមាតាបិតាក្តី ស្វាមីក្តី មិនទាន់អនុញ្ញាតឲ្យឧបសម្បទា ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៣៣) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយថា សិក្ខាបទទី ១ នៃពួកភិក្ខុនីរួចហើយ ។ ជនដែលឈ្មោះថា មាតាបិតា សំដៅយកជនដែលញុំាងកូនឲ្យកើត ។ បុរសណាហួងហែងកូនស្រី បុរសនោះឈ្មោះថាស្វាមី ។ ពាក្យថា មិនអនុញ្ញាត គឺមិនចុះយល់ព្រម ។

សិក្ខមានា នាម ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិត-សិក្ខា ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋា-បេស្សាមីតិ គណំ វា អាចរិនិំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្ម-វាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

(៤៣៤) អនាបត្តិ អជានន្តី វុដ្ឋាបេតិ អបលោ-កេត្វា វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## កុមារីភូតវគ្គស្ស ឯកាទសមសិក្ខាបទំ

(៤៣៥) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី សិក្ខមានំ វុដ្ឋាបេស្សាមីតិ ថេរេ ភិក្ខូ សន្និបាតេត្វា បហុតំ ខាទនីយំ ភោជនីយំ បស្សិត្វា ន តាវាហំ អយ្យា សិក្ខមានំ វុដ្ឋាបេស្សាមីតិ



ស្រីដែលសិក្សាសិក្ខាក្នុងធម៌ទាំង ៦ យ៉ាងអស់ពីរឆ្នាំ ឈ្មោះថាសិក្ខមានា ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសឲ្យ ។ ភិក្ខុនីគិតថា អាត្មាអញនឹងឲ្យឧប-សម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីត្រូវទុក្កដព្រោះញត្តិ ត្រូវទុក្កដទាំងឡាយព្រោះកម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនី ត្រូវអាបត្តិទុក្កដ ។

(៤៣៤) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីមិនដឹងឲ្យឧបសម្បទា ១ ភិក្ខុនីឲ្យលា (មាតាបិតានិងស្វាមី) ហើយទើបឲ្យឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិកបុគ្គល ១ ។

---

## កុមារីភូតវគ្គ សិក្ខាបទទី ១១

(៤៣៥) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តវេឡុវ័ននៃកាក-លន្ទកនិវាបស្ថាន(១) ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីប្រជុំភិក្ខុជាថេរៈទាំងឡាយដោយគិតថា អាត្មាអញនឹងឲ្យឧបសម្បទាសិក្ខមានាផ្ទេរដល់ឃើញខាទនីយភោជនីយាហារច្រើន (ក៏ក្រឡប់) និយាយថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំនឹងមិនទាន់ឲ្យឧបសម្បទាសិក្ខមានាទៅឡើយទេ

---

១ មានសេចក្តីពិស្តារក្នុងសង្ឃាទិសេសសិក្ខាបទទី ៩ នៃខាងដើមរួចហើយ ។

[illegible]

១ ម. វុដ្ឋាបេសិ ។





[illegible]

១ [illegible]

ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី បារិវាសិយឆន្ទទានេន សិក្ខមានំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

[៤៣៦] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ បារិវាសិយឆន្ទទានេនាតិ វុដ្ឋិតាយ បរិសាយ ។ សិក្ខមានា នាម ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនឹ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

[៤៣៧] អនាបត្តិ អវុដ្ឋិតាយ បរិសាយ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ដល់ភិក្ខុនីទាំងឡាយ ភិក្ខុនីទាំងឡាយចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់សិក្ខមានា ដោយឲ្យឆន្ទៈឈ្មោះបារិវាសិក ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៣៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ដោយឲ្យឆន្ទៈឈ្មោះបារិវាសិក គឺបរិសទ្យក្រោកចេញទៅហើយ ។ ដែលហៅថា សិក្ខមានា សំដៅយកសាមណេរីដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីត្រូវទុក្កដព្រោះញត្តិ ត្រូវទុក្កដព្រោះកម្មវាចាទាំងឡាយ ២ ខណៈចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនឹងអាចារិនីត្រូវអាបត្តិទុក្កដ ។

(៤៣៧) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ ពួកយ៉ាងនេះ) គឺ កាលបើបរិសទ្យមិនទាន់បានក្រោកចេញទៅហើយ ភិក្ខុនីឲ្យឧបសម្បទា ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

[៤៣៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ អនុវស្សំ វុដ្ឋាបេន្តិ ។ ឧបស្សយោ ន សម្មតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អនុវស្សំ វុដ្ឋាបេស្សន្តិ ឧបស្សយោ ន សម្មតីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អនុវស្សំ វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អនុវស្សំ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អនុវស្សំ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ



[៤៣៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទារាល់ឆ្នាំ ។ កន្លែងសម្រាប់ភិក្ខុនីនៅក៏មិនគ្រប់គ្រាន់ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទារាល់ឆ្នាំសោះ (ព្រោះ) កន្លែងសម្រាប់នៅមិនគ្រប់គ្រាន់ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះ (ក៏) ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទារាល់ឆ្នាំសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទារាល់ឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទារាល់ឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អនុវស្សំ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

(៤៣៩) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អនុវស្សន្តិ អនុសំវច្ឆរំ ។ វុដ្ឋាបេយ្យាតិ ឧបសម្បាទេយ្យ ។ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនិំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

(៤៤០) អនាបត្តិ ឯកន្តរិកំ វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## កុមារីភូតវគ្គស្ស តេរសមសិក្ខាបទំ

(៤៤១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន



ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ឲ្យឧបសម្បទារាល់ឆ្នាំ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៣៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា រាល់ឆ្នាំ គឺគ្រប់ឆ្នាំ ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី ។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីត្រូវទុក្កដព្រោះញត្តិ ត្រូវទុក្កដទាំងឡាយព្រោះកម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនឹងអាចារិនីត្រូវអាបត្តិទុក្កដ ។

(៤៤០) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទារំលងមួយឆ្នាំ ។ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដែលជាដើមបញ្ញត្តិ ១ ។

---

## កុមារីភូតវគ្គ សិក្ខាបទទី ១៣

(៤៤១) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយ

ខោ បន សមយេន ភិក្ខុនិយោ ឯកំ វស្សំ(១) ទ្វេ វុដ្ឋាបេន្តិ ។ ឧបស្សយោ តថេវ ន សម្មតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឯកំ វស្សំ ទ្វេ វុដ្ឋាបេស្សន្តិ ឧបស្សយោ តថេវ ន សម្មតីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឯកំ វស្សំ ទ្វេ វុដ្ឋាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ឯកំ វស្សំ ទ្វេ វុដ្ឋាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ឯកំ វស្សំ ទ្វេ វុដ្ឋាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី ឯកំ វស្សំ ទ្វេ វុដ្ឋាបេយ្យ បាចិត្តិយន្តិ ។

១ ម. ឯកវស្សំ ។ ឯវំ សព្វត្ថ ញាតព្វំ ។





ឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង ១ ឆ្នាំ ។ កន្លែងជាទីនៅក៏មិនល្មមគ្រាន់ដូច្នោះទៀត ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះទៀតថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង ១ ឆ្នាំសោះ (ព្រោះថា) លំនៅមិនគ្រាន់ដូច្នោះទៀត ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង ១ ឆ្នាំសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង ១ ឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង ១ ឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង ១ ឆ្នាំ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៦៦៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឯកំ វស្សន្តិ ឯកំ សំវច្ឆរំ ។ ទ្វេ វុដ្ឋាបេយ្យាតិ ទ្វេ ឧបសម្បាទេយ្យ ។ ទ្វេ វុដ្ឋាបេស្សាមីតិ គណំ វា អាចរិនិំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ទុក្កដា កម្មវាចាបរិយោសានេ ឧបជ្ឈាយាយ អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិនិយា ច អាបត្តិ ទុក្កដស្ស ។

(៦៦៧) អនាបត្តិ ឯកន្តរិកំ ឯកំ[១] វុដ្ឋាបេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

កុមារីភូតវគ្គោ អដ្ឋមោ ។

១ ម. ឧ. ហេដ្ឋិមេសុ អយំ បាឋោ ន ហោតិ ។



(៦៦៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ ពាក្យនេះមានសេចក្តីអធិប្បាយដូចសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ក្នុង ១ ឆ្នាំ គឺក្នុង ១ ខួប ។ ពាក្យថា ឲ្យឧបសម្បទាដល់ស្រីពីររូប គឺបំបួសស្រីពីររូប ។ ភិក្ខុនី ។ ភិក្ខុនីគិតថា អាត្មានឹងឲ្យឧបសម្បទាដល់ស្រីពីររូប ហើយស្វែងរកគណៈក្តី អាចារិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីត្រូវអាបត្តិទុក្កដព្រោះញត្តិ ត្រូវទុក្កដពីរព្រោះកម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈនិងអាចារិនី ត្រូវអាបត្តិទុក្កដ ។

(៦៦៧) ការបំបួសមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់ស្រី ១ រូប រំលងមួយឆ្នាំ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិកៈ ១ ។

កុមារីភូតវគ្គទី ៨ ចប់ ។

## ឆត្តុបាហនវគ្គស្ស បឋមសិក្ខាបទំ

[៦៤៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ ឆត្តុបាហនំ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឆត្តុបាហនំ ធារេស្សន្តិ សេយ្យថាបិ គិហិនិយោ(១) កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ ឆត្តុបាហនំ ធារេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឆត្តុបាហនំ ធារេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឆត្តុបាហនំ ធារេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន

១ ម. គិហិកាមភោគិនិយោតិ ។

## ឆត្តុបាហនវគ្គ សិក្ខាបទទី ១

[៦៤៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនីទាំងឡាយទ្រទ្រង់ឆ័ត្រនឹងស្បែកជើង ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងទ្រទ្រង់ឆ័ត្រនឹងស្បែកជើងដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនគួរបើនឹងទ្រទ្រង់ឆ័ត្រនឹងស្បែកជើងសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីទាំងឡាយទ្រទ្រង់ឆ័ត្រនឹងស្បែកជើង ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងទ្រទ្រង់ឆ័ត្រនឹងស្បែកជើងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែង

ភិក្ខុនី ឆត្តុបាហនំ ធារេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៥៥៨) តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី គិលានា ហោតិ ។ តស្សា វិនា ឆត្តុបាហនំ ន ផាសុ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ គិលានាយ ភិក្ខុនិយា ឆត្តុបាហនំ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនី អគិលានា ឆត្តុបាហនំ ធារេយ្យ បាចិត្តិយន្តិ ។

(៥៥៩) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អគិលានា នាម យស្សា វិនា ឆត្តុបាហនំ ផាសុ ហោតិ ។ គិលានា នាម យស្សា វិនា ឆត្តុបាហនំ ន ផាសុ ហោតិ ។ ឆត្តំ នាម តីណិ ឆត្តានិ សេតច្ឆត្តំ កិលញ្ជច្ឆត្តំ បណ្ណច្ឆត្តំ មណ្ឌលពទ្ធំ[១] ។ ធារេយ្យាតិ សកិម្បិ ធារេតិ អាបត្តិ បាចិត្តិយស្ស ។

១ ឱ.ម. សលាកពទ្ធំ ទិស្សតិ ។



ទៀតចូរសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ ទ្រទ្រង់ឆត្រនឹងស្បែកជើង ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ ។

(៥៥៨) សម័យនោះឯង ភិក្ខុនីមួយរូបឈឺ ភិក្ខុនីនោះមិនបានទ្រទ្រង់ឆត្រនឹងស្បែកជើងក៏មិនសប្បាយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆត្រនឹងស្បែកជើងដល់ភិក្ខុនីឈឺ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ មិនឈឺ ទ្រទ្រង់ឆត្រនឹងស្បែកជើង ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៥៥៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ភិក្ខុនីណាវៀរចាកឆត្រនឹងស្បែកជើង ហើយនៅតែសប្បាយ ភិក្ខុនីនោះឈ្មោះថាមិនឈឺ ។ ភិក្ខុនីណាវៀរចាកឆត្រនឹងស្បែកជើង ហើយមិនសប្បាយ ភិក្ខុនីនោះឈ្មោះថាឈឺ ។ ដែលហៅថាឆត្រ គឺឆត្រមាន ៣ យ៉ាង ឆត្រដែលធ្វើដោយសំពត់ស ១ ឆត្រដែលត្បាញដោយចង្អេរឫស្សី ១ ឆត្រដែលធ្វើដោយស្លឹកឈើ ១ (ឆត្រទាំងនេះ) ដែលគេចងឲ្យមានរាងមូលចងឲ្យជាប់មាំដោយឆ្អឹងឆត្រ ។ ពាក្យថា ទ្រទ្រង់ គឺភិក្ខុនីប្រើប្រាស់សូម្បីម្តង (គឺ) ត្រូវអាបត្តិបាចិត្តិយ ។

(៤៤៧) អគិលានា អគិលានសញ្ញា ឆត្តុបាហនំ ធារេតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានា វេមតិកា ឆត្តុបាហនំ ធារេតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានា គិលានសញ្ញា ឆត្តុបាហនំ ធារេតិ អាបត្តិ បាចិត្តិយស្ស ។ ឆត្តំ ធារេតិ ន ឧបាហនំ អាបត្តិ ទុក្កដស្ស ។ ឧបាហនំ ធារេតិ ន ឆត្តំ អាបត្តិ ទុក្កដស្ស ។ គិលានា អគិលានសញ្ញា អាបត្តិ ទុក្កដស្ស ។ គិលានា វេមតិកា អាបត្តិ ទុក្កដស្ស ។ គិលានា គិលានសញ្ញា អនាបត្តិ ។

(៤៤៨) អនាបត្តិ គិលានាយ អារាមេ អារាមូបចារេ ធារេតិ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## ឆត្តុបាហនវគ្គស្ស ទុតិយសិក្ខាបទំ

(៤៤៩) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខុនិយោ យានេន



(៤៤៧) ភិក្ខុនីមិនឈឺ សំគាល់ថាមិនឈឺ ហើយទ្រទ្រង់ឆ័ត្រនិងស្បែកជើង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនឈឺ មានសេចក្ដីសង្ស័យ ហើយទ្រទ្រង់ឆ័ត្រនិងស្បែកជើង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនឈឺ សំគាល់ថាឈឺ ហើយទ្រទ្រង់ឆ័ត្រនិងស្បែកជើង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីទ្រទ្រង់ឆ័ត្រមិនពាក់ស្បែកជើង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីពាក់ស្បែកជើងមិនបាំងឆ័ត្រ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈឺ សំគាល់ថាមិនឈឺ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈឺ តែមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈឺ សំគាល់ថាឈឺ មិនត្រូវអាបត្តិ ។

(៤៤៨) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុនីឈឺ ១ ភិក្ខុនីទ្រទ្រង់ឆ័ត្រនិងស្បែកជើងក្នុងអារាម ១ ក្នុងឧបចារៈនៃអារាម ១ ភិក្ខុនីទ្រទ្រង់ក្នុងវេលាមានសេចក្ដីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## ឆត្តុបាហនវគ្គ សិក្ខាបទទី ២

(៤៤៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនី

បាចិត្តិយកណ្ឌេ ឆត្តុបាហនវគ្គស្ស ទុតិយសិក្ខាបទំ បឋមបញ្ញត្តិ

យាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ យានេន យាយិស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ យានេន យាយិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ យានេន យាយន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ យានេន យាយិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី យានេន យាយេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។



បាចិត្តិយកណ្ឌ ឆត្តុបាហនវគ្គ សិក្ខាបទទី ២ សេចក្ដីបញ្ញត្តិជាដំបូង

ទាំងឡាយមានដំណើរទៅដោយយាន ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងទៅដោយយានដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងទៅដោយយានសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីទាំងឡាយទៅដោយយាន ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងទៅដោយយានទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយទៅដោយយាន ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ ។

[៤៨០] តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី គិលានា ហោតិ ន សក្កោតិ បទសា គន្តុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ គិលានាយ ភិក្ខុនិយា យានំ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អគិលានា យានេន យាយេយ្យ បាចិត្តិយន្តិ ។

[៤៨១] យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អគិលានា នាម សក្កោតិ បទសា គន្តុំ ។ គិលានា នាម ន សក្កោតិ បទសា គន្តុំ ។ យានំ នាម វយ្ហំ រថោ សកដំ សន្ទមានិកា សិវិកា បាដង្កី ។ យាយេយ្យាតិ សកិម្បិ យានេន យាយតិ អាបត្តិ បាចិត្តិយស្ស ។

[៤៨២] អគិលានា អគិលានសញ្ញា យានេន យាយាតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានា វេមតិកា យានេន យាយតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានា



(៤៨០) គ្រានោះឯង ភិក្ខុនីមួយរូបឈឺមិនអាចនឹងដើរទៅដោយជើងបាន ។ ភិក្ខុនីទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដល់ភិក្ខុនីមានជម្ងឺ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនឈឺ ហើយទៅដោយយាន ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៨១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយវគ្គរួចហើយ ។ ភិក្ខុនីដែលអាចទៅដោយជើងបាន ឈ្មោះថាមិនឈឺ ។ ភិក្ខុនីណាដែលមិនអាចទៅដោយជើងបាន ភិក្ខុនីនោះឈ្មោះថាឈឺ ។ វ៉ៅ រថ រទេះ រថប្រចាំង គ្រៀន គ្រែស្នែង អង្រឹង ឈ្មោះថាយាន ។ ពាក្យថាទៅ គឺភិក្ខុនីទៅតែម្តង ត្រូវអាបត្តិបាចិត្តិយ ។

(៤៨២) ភិក្ខុនីមិនឈឺ សំគាល់ថាមិនឈឺ ហើយទៅដោយយាន ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនឈឺ តែសង្ស័យ ហើយទៅដោយយាន ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនឈឺ សំគាល់ថាឈឺ ហើយទៅ

គិលានសញ្ញា យានេន យាយតិ អាបត្តិ បាចិត្តិយស្ស ។ គិលានា អគិលានសញ្ញា អាបត្តិ ទុក្កដស្ស ។ គិលានា វេមតិកា អាបត្តិ ទុក្កដស្ស ។ គិលានា គិលានសញ្ញា អនាបត្តិ ។

(៤៩៣) អនាបត្តិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆត្តុបាហនវគ្គស្ស តតិយសិក្ខាបទំ

(៤៩៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី អញ្ញតរិស្សា ឥត្ថិយា កុលូបិកា ហោតិ ។ អថ ខោ សា ឥត្ថី តំ ភិក្ខុនឹ ឯតទវោច ឥមំ អយ្យេ សង្ឃាណឹ អមុកាយ នាម ឥត្ថិយា ទេហីតិ ។ អថ ខោ សា ភិក្ខុនី សចាហំ បត្តេន អាទាយ គច្ឆាមិ វិស្សរោ មេ ភវិស្សតីតិ បដិមុញ្ចិត្វា អគមាសិ ។ តស្សា រថិកាយ សុត្តកេ ឆិន្នេ វិប្បកិរិ-

---

១ ឱ. កុលុបិកា ។ ម. កុលូបិកា ។



ដោយយាន ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីឈឺ សំគាល់ថាមិនឈឺ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈឺ កើតសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈឺ សំគាល់ថាឈឺ មិនត្រូវអាបត្តិ ។

(៤៩៣) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយផ្សេង ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិ ដើមបញ្ញត្តិ ១ ។

---

## ឆត្តុបាហនវគ្គ សិក្ខាបទទី ៣

(៤៩៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីមួយរូប ជាជីកុនរបស់ស្រីម្នាក់ ។ លំដាប់នោះឯង ស្រីនោះបាននិយាយពាក្យនេះ នឹងភិក្ខុនីនោះថា បពិត្រនាងម្ចាស់ ណ្ហើយចុះ សូមនាងម្ចាស់ឲ្យវត្ថុក្រវាត់ បាន្ទុះនេះដល់ស្រីឈ្មោះឯណោះទៅ ។ ទើបភិក្ខុនីនោះគិតថា បើអញដាក់ ក្នុងបាត្រហើយទៅ អញមុខជានឹងភ្លេច គិតដូច្នោះហើយក៏ក្រវាត់ដើរទៅ ។ កាលបើខ្សែ (សំពត់ហោត) ដាច់ទៅ គ្រឿង (វៀរក្រវាត់ក) ព្រុះរកាយពេញដី

យឹំសុ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ សង្ឃាណឹ ធារេស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តាសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី សង្ឃាណឹ ធារេស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី សង្ឃាណឹ ធារេតីតិ[1] ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី សង្ឃាណឹ ធារេស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី សង្ឃាណឹ ធារេយ្យ បាចិត្តិយន្តិ ។

(៤៩៩) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សង្ឃាណី នាម យា កាចិ កដូបកា ។ ធារេយ្យាតិ សកឹ បិ ធារេតិ អាបត្តិ បាចិត្តិយស្ស ។

---

១ ម. ធារេសីតិ ។

ផ្សំនោះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងពាក់ខ្សែក្រវាត់ដូចជាពួកស្រីគ្រហស្ថជាអ្នកបរិភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងពាក់ខ្សែក្រវាត់សោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីពាក់ខ្សែក្រវាត់ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងពាក់ខ្សែក្រវាត់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយពាក់ខ្សែក្រវាត់ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៩៩) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ របស់ណាមួយសម្រាប់ប្រើជាប់ចង្កេះ របស់នោះឈ្មោះថាខ្សែក្រវាត់ ។ ពាក្យថា ពាក់ គឺភិក្ខុនីប្រើប្រាស់តែម្ដង ក៏ត្រូវអាបត្តិបាចិត្តិយ ។

(៤៨៦) អនាបត្តិ អាពាធប្បច្ចយា កដិសុត្តកំ ធារេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆត្តុបាហនវគ្គស្ស បឋមសិក្ខាបទំ

(៤៨៧) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ ឥត្ថាលង្ការំ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឥត្ថាលង្ការំ ធារេស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ ឥត្ថាលង្ការំ ធារេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឥត្ថាលង្ការំ ធារេន្តីតិ ។



(៤៨៦) អនាបត្តិដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីពាក់ខ្សែចង្កេះព្រោះហេតុនៃអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាអាទិកម្មិក១ ។

---

## ឆត្តុបាហនវគ្គ សិក្ខាបទទី ១

(៤៨៧) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយ ទ្រទ្រង់គ្រឿងប្រដាប់ស្រី (គ្រហស្ថ) ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងប្រើប្រាស់គ្រឿងអលង្ការរបស់ស្រី ដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះ(ក៏)ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនគួរបើនឹងប្រើប្រាស់គ្រឿងអលង្ការរបស់ស្រីសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយប្រើប្រាស់គ្រឿងអលង្ការរបស់ស្រី ពិតមែនឬ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឥត្ថាលង្ការំ ធារេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ឥត្ថាលង្ការំ ធារេយ្យ បាចិត្តិយន្តិ ។

[៤៥៨] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ឥត្ថាលង្ការោ នាម សីសុបគោ គីវុបគោ ហត្ថុបគោ បាទុបគោ កដុបគោ[១] ។ ធារេយ្យាតិ សកឹបិ ធារេតិ អាបត្តិ បាចិត្តិយស្ស ។

[៤៥៩] អនាបត្តិ អាពាធប្បច្ចយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

១ ។ សីសូបគោ គីវូ. . . ហត្ថូ. . . បាទូ. . . កដូបគោតិ ទិស្សន្តិ ។



ភិក្ខុនីទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុនីទាំងឡាយ ឆព្វគ្គិយា ភិក្ខុនីទាំងឡាយមិនសមបីនឹងប្រើប្រាស់គ្រឿងអលង្ការរបស់ស្រីទេ ម្នាលភិក្ខុនីទាំងឡាយ សេចក្ដីនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះ-ថ្លាទេ ។បេ។ ម្នាលភិក្ខុនីទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយប្រើប្រាស់គ្រឿងអលង្ការរបស់ស្រី ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៥៨) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ គ្រឿងប្រដាប់ក្បាល គ្រឿងប្រដាប់ក គ្រឿងប្រដាប់ដៃ គ្រឿងប្រដាប់ជើង គ្រឿងប្រដាប់ចង្កេះ ឈ្មោះថា គ្រឿងប្រដាប់របស់ស្រី (ក្នុងសិក្ខាបទនេះ) ។ ពាក្យថា ប្រើប្រាស់ គឺភិក្ខុនីពាក់សូម្បីម្ដង ក៏ត្រូវអាបត្តិបាចិត្តិយ ។

(៤៥៩) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីប្រើប្រាស់ព្រោះហេតុនៃអាពាធ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## ឆត្តុបាហនវគ្គស្ស បញ្ចមសិក្ខាបទំ

(៤៦០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ គន្ធវណ្ណកេន ន្ហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ គន្ធវណ្ណកេន ន្ហាយិស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ គន្ធវណ្ណកេន ន្ហាយិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ គន្ធវណ្ណកេន ន្ហាយន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ គន្ធវណ្ណកេន ន្ហាយិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ

## ឆត្តុបាហនវគ្គ សិក្ខាបទទី ៥

(៤៦០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាប ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាបដូចជាពួកស្រីគ្រហស្ថជាអ្នកបរិភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនគួរបើនឹងងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាបសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាប ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនគួរបើនឹងងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាបទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា

វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី គន្ធវណ្ណកេន នហាយេយ្យ បាចិត្តិយន្តិ ។

(៦៦១) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ គន្ធោ នាម យោ កោចិ គន្ធោ ។ វណ្ណកំ នាម យង្កិញ្ចិ វណ្ណកំ ។ នហាយេយ្យាតិ នហាយតិ បយោគេ ទុក្កដំ នហានបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

(៦៦២) អនាបត្តិ អាពាធប្បច្ចយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆត្តុបាហនវគ្គស្ស ឆដ្ឋសិក្ខាបទំ

(៦៦៣) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ វាសិតកេន បិញ្ញាកេន នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ



ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាប ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៦៦១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបុកមិកកណ្ឌរួចហើយ ។ ដែលហៅថា គ្រឿងក្រអូប សំដៅយកវត្ថុណាមួយមានក្លិនក្រអូប ។ ដែលហៅថា គ្រឿងលាប សំ-ដៅយករបស់ណាមួយសម្រាប់លាប ។ ពាក្យថា ងូតទឹក គឺភិក្ខុនីកំពុងងូត ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលងូត ងូតស្រេច ត្រូវអាបត្តិបាចិត្តិយ ។

(៦៦២) អ្នកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីងូតព្រោះហេតុនៃអាពាធ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិក ១ ។

---

## ឆត្តុបាហនវគ្គ សិក្ខាបទទី ៦

(៦៦៣) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឆព្វគ្គិយា ភិក្ខុនីទាំងឡាយងូតទឹកដោយគ្រឿងអប់គ្រឿងល្អិត ។ មនុស្សទាំងឡាយ

វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ វាសិតកេន បិញ្ញាកេន នហាយិស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ វាសិតកេន បិញ្ញាកេន នហាយិស្សន្តីតិ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ វាសិតកេន បិញ្ញាកេន នហាយន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ វាសិតកេន បិញ្ញាកេន នហាយិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី វាសិតកេន បិញ្ញាកេន នហាយេយ្យ បាចិត្តិយន្តិ ។



ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងងូតទឹកដោយគ្រឿងអប់ គ្រឿងលំអិត ដូចជាពួកស្រីគ្រហស្ថអ្នកបរិភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងងូតទឹកដោយគ្រឿងអប់គ្រឿងលំអិតសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីងូតទឹកដោយគ្រឿងអប់គ្រឿងលំអិត ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងងូតទឹក ដោយគ្រឿងអប់គ្រឿងលំអិតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយងូតទឹកដោយគ្រឿងអប់គ្រឿងលំអិត ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៦៦៤] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ វាសិតកំ នាម យេនកេញ្ចិ គន្ធវាសិតកំ(១) ។ បិញ្ញាកំ នាម តិលបិដ្ឋំ វុច្ចតិ ។ ឧព្វដ្ដាបេយ្យាតិ ឧព្វដ្ដាបេតិ បយោគេ ទុក្កដំ ឧព្វដ្ដាបិតេ អាបត្តិ បាចិត្តិយស្ស ។

[៦៦៥] អនាបត្តិ អាពាធប្បច្ចយា បកតិបិញ្ញាកេន ឧព្វដ្ដេតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆត្តុបាហនវគ្គស្ស សត្តមសិក្ខាបទំ

[៦៦៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ភិក្ខុនិយា ឧព្វដ្ដាបេន្តិបិ បរិមទ្ទាបេន្តិបិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ភិក្ខុនិយា ឧព្វដ្ដាបេស្សន្តិបិ បរិមទ្ទាបេស្សន្តិបិ សេយ្យថាបិ គិហិនិយោ កាមភោគិ-

១ ម. វាសិតកំ ។



(៦៦៤) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ដែលហៅថា គ្រឿងអប់នោះ គឺគ្រឿងអប់ដែលមានក្លិនក្រអូបណាមួយ ។ ដែលហៅថា គ្រឿងល្អិត សំដៅយកម្សៅល្ង ។ ពាក្យថា ឲ្យគក់ សេចក្តីថា ភិក្ខុនីឲ្យគក់ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យគក់ ឲ្យគក់ស្រេច ត្រូវអាបត្តិបាចិត្តិយ ។

(៦៦៥) ពួកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុនីឲ្យគក់ដោយគ្រឿងល្អិតជាប្រក្រតីព្រោះហេតុនៃអាពាធ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

---

## ឆត្តុបាហនវគ្គ សិក្ខាបទទី ៧

(៦៦៦) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងវត្តជេតពនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយឲ្យភិក្ខុនីគក់ខ្លះ ច្របាច់ខ្លះ ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យភិក្ខុនីគក់ខ្លះ ច្របាច់ខ្លះ ដូចជាពួកស្រីគ្រហស្ថជា

និយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈា-យន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ភិក្ខុនិយា ឧម្មទ្ទាបេស្សន្តិ បរិមទ្ទាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ភិក្ខុនិយា ឧម្មទ្ទា-បេន្តិ បរិមទ្ទាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ភិក្ខុនិយា ឧម្មទ្ទាបេស្សន្តិ បរិមទ្ទាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី ភិក្ខុនិយា ឧម្មទ្ទាបេយ្យ វា បរិមទ្ទា-បេយ្យ វា បាចិត្តិយន្តិ ។

(៦៦៧) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុនិយាតិ អញ្ញាយ ភិក្ខុនិយា ។ ឧម្មទ្ទាបេយ្យ វាតិ ឧម្មទ្ទាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរិមទ្ទាបេយ្យ វាតិ សម្ពាហាបេតិ អាបត្តិ បាចិត្តិយស្ស ។





ពួកបរិភោគកាមដូច្នោះ ។ ភិក្ខុនីទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះ-ដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរប្រើនឹងឲ្យភិក្ខុនីគក់គ្នុះ ច្របាច់គ្នុះនោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យភិក្ខុនីគក់គ្នុះ ច្របាច់គ្នុះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរប្រើនឹងឲ្យភិក្ខុនីគក់គ្នុះ ច្របាច់គ្នុះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យភិក្ខុនីគក់គ្នុះក្ដី ច្របាច់ក្ដី ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៦៦៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ឲ្យភិក្ខុនី គឺឲ្យភិក្ខុនីដទៃ ។ ពាក្យថា គក់គ្នុះក្ដី គឺភិក្ខុនីឲ្យគេគក់ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ច្របាច់ក្ដី គឺភិក្ខុនីឲ្យគេច្របាច់ ត្រូវអាបត្តិបាចិត្តិយ ។

[៤៦៨] អនាបត្តិ គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

## ឆត្តុបាហនវគ្គស្ស អដ្ឋម-នវម-ទសមសិក្ខាបទានិ

[៤៦៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ សិក្ខមានាយ ឧម្មទ្ទាបេន្តិបិ បរិមទ្ទាបេន្តិបិ ។ បេ ។ សាមណេរិយា ឧម្មទ្ទាបេន្តិបិ បរិមទ្ទាបេន្តិបិ ។ បេ ។ គិហិនិយា ឧម្មទ្ទាបេន្តិបិ បរិមទ្ទាបេន្តិបិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ គិហិនិយា ឧម្មទ្ទាបេស្សន្តិបិ បរិមទ្ទាបេស្សន្តិបិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ



(៤៦៨) ភាពដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

## ឆត្តុបាហនវគ្គ សិក្ខាបទទី ៨-៩-១០

(៤៦៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយ ឲ្យសិក្ខមានាគក់ខ្លួន ច្របាច់ខ្លួន ។ បេ ។ ឲ្យសាមណេរីគក់ខ្លួន ច្របាច់ខ្លួន ។ បេ ។ ឲ្យស្រីគ្រហស្ថគក់ខ្លួន ច្របាច់ខ្លួន ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យស្រីគ្រហស្ថគក់ខ្លួន ច្របាច់ខ្លួន ដូចជាពួកស្រីគ្រហស្ថជាអ្នកបរិភោគកាមសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹង

គិហិនិយា ឧម្មទ្ទាបេស្សន្តិ បរិមទ្ទាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ គិហិនិយា ឧម្មទ្ទាបេន្តិ បរិមទ្ទាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ គិហិនិយា ឧម្មទ្ទាបេស្សន្តិ បរិមទ្ទាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យុំ យា បន ភិក្ខុនី គិហិនិយា ឧម្មទ្ទាបេយ្យ វា បរិមទ្ទាបេយ្យ វា បាចិត្តិយន្តិ ។

(៤៧០) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ សិក្ខមានា នាម ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ សាមណេរី នាម ទសសិក្ខាបទិកា ។ គិហិនី នាម អគារិនី វុច្ចតិ ។ ឧម្មទ្ទាបេយ្យ វាតិ ឧម្មទ្ទាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរិមទ្ទាបេយ្យ វាតិ សម្ពាហាបេតិ អាបត្តិ បាចិត្តិយស្ស ។



ឲ្យស្រីគ្រហស្ថគក់ខ្លួន ច្របាច់ខ្លួន ។ បេ ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យស្រីគ្រហស្ថគក់ខ្លួន ច្របាច់ខ្លួន ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យស្រីគ្រហស្ថគក់ខ្លួន ច្របាច់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយឲ្យស្រីគ្រហស្ថគក់ក្ដី ច្របាច់ក្ដី ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៧០) ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ដែលហៅថា សិក្ខមានា បានដល់សាមណេរីដែលសិក្សាសិក្ខាក្នុងធម៌ ៦ យ៉ាងអស់ពីរឆ្នាំហើយ ។ ដែលហៅថា សាមណេរី បានដល់ស្រីអ្នកបួសដែលរក្សាសិក្ខាបទ ១០ ។ ដែលហៅថា ស្រីគ្រហស្ថ សំដៅយកស្រីដែលនៅគ្រប់គ្រងផ្ទះ ។ ពាក្យថា ឲ្យគក់ក្ដី សេចក្ដីថា ភិក្ខុនីឲ្យគេគក់ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ឲ្យច្របាច់ក្ដី សេចក្ដីថា ភិក្ខុនីឲ្យគេច្របាច់ ត្រូវអាបត្តិបាចិត្តិយ ។

[៤៨៧] អនាបត្តិ អាពាធប្បច្ចយា អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆត្តុបាហនវគ្គស្ស ឯកាទសមសិក្ខាបទំ

[៤៨៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ ភិក្ខុស្ស បុរតោ អនាបុច្ឆា អាសនេ និសីទន្តិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ភិក្ខុស្ស បុរតោ អនាបុច្ឆា អាសនេ និសីទិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ ភិក្ខុស្ស បុរតោ អនាបុច្ឆា អាសនេ និសីទន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ ភិក្ខុស្ស បុរតោ អនាបុច្ឆា អាសនេ និសីទិស្សន្តិ[១] នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ

១ ម. និសីទិស្សន្តិ ។



[៤៨៧] អ្នកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុនីមានហេតុនៃអាពាធ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិដើមបញ្ញត្តិ ១ ។

---

## ឆត្តុបាហនវគ្គ សិក្ខាបទទី ១១

[៤៨៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយ មិនសួរប្រាប់ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ ។ ភិក្ខុទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើមិនប្រាប់ហើយ អង្គុយលើអាសនៈខាងមុខភិក្ខុសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមិនប្រាប់ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនបានប្រាប់ មិនគួរបើនឹងអង្គុយលើអាសនៈខាងមុខភិក្ខុទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ

ភិក្ខុនីយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ភិក្ខុស្ស បុរតោ អនាបុច្ឆា អាសនេ និសីទេយ្យ បាចិត្តិយន្តិ ។

[៤៧៣] យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ ភិក្ខុស្ស បុរតោតិ ឧបសម្បន្នស្ស បុរតោ ។ អនាបុច្ឆាតិ អនបលោកេត្វា ។ អាសនេ និសីទេយ្យាតិ អន្តមសោ ឆមាយម្បិ(១) និសីទតិ អាបត្តិ បាចិត្តិយស្ស ។

[៤៧៤] អនាបុច្ឆិតេ អនាបុច្ឆិតសញ្ញា អាសនេ និសីទតិ អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ វេមតិកា អាសនេ និសីទតិ អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ អាបុច្ឆិតសញ្ញា អាសនេ និសីទតិ អាបត្តិ បាចិត្តិយស្ស ។ អាបុច្ឆិតេ អនាបុច្ឆិតសញ្ញា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ អាបុច្ឆិតសញ្ញា អនាបត្តិ ។

---

១ ម. ឆមាយបិ ។



ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនប្រាប់ហើយ អង្គុយលើអាសនៈខាងមុខភិក្ខុ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៤៧៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ខាងមុខភិក្ខុ គឺខាងមុខនៃឧបសម្បន្ន ។ ពាក្យថា មិនបានប្រាប់ គឺមិនបានពិគ្រោះ ។ ពាក្យថា អង្គុយលើអាសនៈ គឺភិក្ខុនីអង្គុយដោយហោចទៅសូម្បីលើផែនដី ក៏ត្រូវអាបត្តិបាចិត្តិយ ។

[៤៧៤] ភិក្ខុដែលខ្លួនមិនបានប្រាប់ ភិក្ខុនីសំគាល់ថាមិនបានប្រាប់មែន ហើយអង្គុយលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលខ្លួនមិនបានប្រាប់ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយអង្គុយលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលខ្លួនមិនបានប្រាប់ ភិក្ខុនីសំគាល់ថាបានប្រាប់ ហើយអង្គុយលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលខ្លួនបានប្រាប់ ភិក្ខុនីសំគាល់ថាមិនបានប្រាប់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលខ្លួនបានប្រាប់ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលខ្លួនបានប្រាប់ ភិក្ខុនីសំគាល់ថាបានប្រាប់ហើយមែន មិនត្រូវអាបត្តិ ។

(៤៧៥) អនាបត្តិ អាបុច្ឆា អាសនេ និសីទតិ គិលាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆត្តុបាហនវគ្គស្ស ទ្វាទសមសិក្ខាបទំ

(៤៧៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភិក្ខុនិយោ អនោកាសកតំ ភិក្ខុំ បញ្ហំ បុច្ឆន្តិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អនោកាសកតំ ភិក្ខុំ បញ្ហំ បុច្ឆិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ អនោកាសកតំ ភិក្ខុំ បញ្ហំ បុច្ឆន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនិយោ អនោកាសកតំ ភិក្ខុំ បញ្ហំ បុច្ឆិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ



(៤៧៥) ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុនីប្រាប់ហើយទើបអង្គុយលើអាសនៈ ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាតាងដើមបញ្ញត្តិ ១ ។

---

## ឆត្តុបាហនវគ្គ សិក្ខាបទទី ១២

(៤៧៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីទាំងឡាយសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាសជាមុន ។ ភិក្ខុទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាសសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាសទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អនោកាសកតំ ភិក្ខុំ បញ្ហំ បុច្ឆេយ្យ បាចិត្តិយន្តិ ។

(៤៧៧) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អនោកាសកតន្តិ អនាបុច្ឆា ។ ភិក្ខុន្តិ ឧបសម្បន្នំ ។ បញ្ហំ បុច្ឆេយ្យាតិ សុត្តន្តេ ឱកាសំ ការាបេត្វា វិនយំ វា អភិធម្មំ វា បុច្ឆតិ អាបត្តិ បាចិត្តិយស្ស ។ វិនយេ ឱកាសំ ការាបេត្វា សុត្តន្តំ វា អភិធម្មំ វា បុច្ឆតិ អាបត្តិ បាចិត្តិយស្ស ។ អភិធម្មេ ឱកាសំ ការាបេត្វា សុត្តន្តំ វា វិនយំ វា បុច្ឆតិ អាបត្តិ បាចិត្តិយស្ស ៕

(៤៧៨) អនាបុច្ឆិតេ អនាបុច្ឆិតសញ្ញា បញ្ហំ បុច្ឆតិ អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ វេមតិកា បញ្ហំ បុច្ឆតិ អាបត្តិ បាចិត្តិយស្ស ។ អនាបុច្ឆិតេ អាបុច្ឆិតសញ្ញា បញ្ហំ បុច្ឆតិ អាបត្តិ បាចិត្តិយស្ស ។ អាបុច្ឆិតេ អនាបុច្ឆិតសញ្ញា អាបត្តិ ទុក្កដស្ស ។





ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

(៤៧៧) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ពាក្យថា មិនបានសូមឱកាស គឺមិនបានផ្ញើ ។ ពាក្យថា ចំពោះភិក្ខុ គឺចំពោះឧបសម្បន្ន ។ ពាក្យថា សួរបញ្ហា គឺភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងព្រះសូត្រ ហើយបែរទៅសួរវិន័យក្ដី អភិធម្មក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងវិន័យ ហើយបែរទៅសួរព្រះសូត្រក្ដី អភិធម្មក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងអភិធម្ម ហើយបែរទៅសួរព្រះសូត្រក្ដី វិន័យក្ដី ត្រូវអាបត្តិបាចិត្តិយ ។

(៤៧៨) ភិក្ខុដែលខ្លួនមិនបានសូមឱកាស ភិក្ខុនីសំគាល់ថាមិនបានសូមឱកាសមែន ហើយសួរបញ្ហា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលខ្លួនមិនបានសូមឱកាស ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយសួរបញ្ហា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលខ្លួនមិនបានសូមឱកាស តែភិក្ខុនីសំគាល់ថាបានសូមឱកាស ហើយសួរបញ្ហា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលខ្លួនបានសូមឱកាស តែភិក្ខុនីសំគាល់ថាមិនបានសូមឱកាស ត្រូវអាបត្តិទុក្កដ ។

អាបុច្ឆិតេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អាបុច្ឆិតេ អាបុច្ឆិតសញ្ញា អនាបត្តិ ។

(៤៧៩) អនាបត្តិ ឱកាសំ ការាបេត្វា បុច្ឆតិ អនោទិស្ស ឱកាសំ ការាបេត្វា យត្ថ កត្ថចិ បុច្ឆតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

---

## ឆត្តុបាហនវគ្គស្ស តេរសមសិក្ខាបទំ

(៤៨០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី អសង្កច្ចិកា គាមំ បិណ្ឌាយ បាវិសិ ។ តស្សា រថិយាយ គច្ឆន្តិយា វាតមណ្ឌលិកា សង្ឃាដិយោ ឧក្ខិបឹសុ ។ មនុស្សា ឧក្កុដ្ឋឹ អកំសុ សុន្ទរោ អយ្យាយ ថនុទរោតិ[១] ។ សា ភិក្ខុនី មនុស្សេហិ ឧប្បណ្ឌិយមានា មង្កុ អហោសិ ។ អថខោ សា ភិក្ខុនី ឧបស្សយំ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ ។

---

១ ម. សុន្ទរា អយ្យាយ ថនុទរកំ ។



ភិក្ខុនីដែលមិនបានសួរឱកាស តែភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីមិនបានសួរឱកាស ភិក្ខុនីសំគាល់ថាបានសួរឱកាសហើយ មិនត្រូវអាបត្តិ ។

(៤៧៩) ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសហើយសួរ ១ ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសមិនចំពោះហើយ សួរក្នុងទីកន្លែងណាមួយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិកម្មិកបុគ្គល ១ ។

---

## ឆត្តុបាហនវគ្គ សិក្ខាបទទី ១៣

(៤៨០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុនីមួយរូបគ្មានសម្ពត់រោមគ្រុនចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ខ្យល់ក្បួចទាំងឡាយ បក់សើយសង្ឃាដីទាំងឡាយរបស់ភិក្ខុនីនោះ ។ មនុស្សទាំងឡាយ ធ្វើសំឡេងហោរឡើងថា ដោះនិងពោះលោកម្ចាស់ល្អណាស់ ។ ភិក្ខុនីនោះកាលដែលមនុស្សទាំងឡាយចំអកឲ្យ (យ៉ាងនោះហើយ) ក៏មានសេចក្ដីអៀនខ្មាស ។ ទើបភិក្ខុនីនោះទៅកាន់សំណាក់ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ ។

តា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី អសង្កច្ចិកា គាមំ បវិសិស្សតីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនី អសង្កច្ចិកា គាមំ បវិសតីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ភិក្ខុនី អសង្កច្ចិកា គាមំ បវិសិស្សតិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អសង្កច្ចិកា គាមំ បវិសេយ្យ បាចិត្តិយន្តិ ។

(៤៨១) យា បនាតិ យា យាទិសា ។ បេ ។ ភិក្ខុនីតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អសង្កច្ចិកាតិ វិនា សង្កច្ចិកំ ។ សង្កច្ចិកំ នាម អធក្ខកំ ឧព្ភនាភិ តស្ស បដិច្ឆាទនត្ថាយ ។ គាមំ បវិសេយ្យាតិ បរិក្ខិត្តស្ស គាមស្ស បរិក្ខេបំ អតិក្កាមន្តិយា អាបត្តិ បាចិត្តិយស្ស ។ អបរិក្ខិត្តស្ស គាមស្ស ឧបចារំ ឱក្កមន្តិយា អាបត្តិ បាចិត្តិយស្ស ។

---
១ ម. បវិសតិ ។



ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងគ្មានសំពត់ពោកគូទហើយចូលទៅកាន់ស្រុកសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីគ្មានសំពត់ពោកគូទ ហើយចូលទៅកាន់ស្រុក ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងគ្មានសំពត់ពោកគូទ ហើយចូលទៅកាន់ស្រុកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ គ្មានសំពត់ពោកគូទចូលទៅកាន់ស្រុក ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

[៤៨១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា គ្មានសំពត់ពោកគូទ គឺលះបង់សំពត់ពោកគូទ ។ សំពត់ប្រើសម្រាប់ក្រោម តាំងពីដងកាំបិតចុះមក ខាងលើតាំងពីផ្ចិតឡើងទៅ សំពត់ដែលគេប្រើដើម្បីបិទបាំងសរីរប្រទេសនោះ ហៅថា សំពត់ពោកគូទ ។ ពាក្យថា ចូលទៅកាន់ស្រុក គឺភិក្ខុនីណា ឆ្លងនូវរបងស្រុកដែលមានរបង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីណា ចូលដល់ឧបចារស្រុកដែលគ្មានរបង ត្រូវអាបត្តិបាចិត្តិយ ។

(៤៩២) អនាបត្តិ អច្ឆិន្នចីវរិកាយ នដ្ឋចីវរិកាយ គិលានាយ អសតិយា អជានន្តិយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

ឆត្តុបាហនវគ្គោ(១) នវមោ ។

(៤៩៣) ឧទ្ទិដ្ឋា ខោ អយ្យាយោ ឆសដ្ឋិសតា បាចិត្តិយា ធម្មា ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បាចិត្តិយា និដ្ឋិតា(២) ។

១ ឆត្តវគ្គោតិ បាឋោ ។ ២ ម. យ. ខុទ្ទកំ និដ្ឋិតំ ។





(៤៩២) ភិក្ខុនីមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមានវៀរលែង) គឺ ភិក្ខុនីមានចីវរចោរដណ្តើមយកទៅ ១ ភិក្ខុនីមានចីវរវិនាស ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមិនមានសតិ ១ ភិក្ខុនីមិនដឹងខ្លួន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

ឆត្តុបាហនវគ្គ ទី ៩ ចប់ ។

(៤៩៣) បពិត្រលោកម្ចាស់ទាំងឡាយ បាចិត្តិយធម៌ទាំងឡាយ ១៦៦ ខ្ញុំបានសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងបាចិត្តិយធម៌ទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះ ទើបលោកស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

បាចិត្តិយ ចប់ ។

# បាដិទេសនីយកណ្ឌំ

ឥមេ ខោ បនយ្យាយោ អដ្ឋ បាដិទេសនីយា

ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

[៤៨៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ សប្បឹ វិញ្ញាបេត្វា ភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ សប្បឹ វិញ្ញាបេត្វា ភុញ្ជិស្សន្តិ កស្ស សម្បន្នំ ន មនាបំ កស្ស សាទុំ ន រុច្ចតីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។បេ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ សប្បឹ វិញ្ញាបេត្វា ភុញ្ជិស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ សប្បឹ វិញ្ញាបេត្វា ភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ

# បាដិទេសនីយកណ្ឌ

បពិត្រលោកម្ចាស់ទាំងឡាយ ការបត្តិទាំងឡាយឈ្មោះ

បាដិទេសនីយ ៨ នេះមកកាន់ឧទ្ទេស ។

[៤៨៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយសូមទឹកដោះរាវឆាន់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងសូមទឹកដោះរាវឆាន់សោះ អ្នកណាមិនគាប់ចិត្តនឹងវត្ថុដែលសម្បូណ៌ អ្នកណាមិនគាប់ចិត្តនឹងវត្ថុដែលឆ្ងាញ់ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងសូមទឹកដោះរាវឆាន់សោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយសូមទឹកដោះរាវឆាន់ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ

ឆព្វគ្គិយា ភិក្ខុនិយោ សប្បិំ វិញ្ញាបេត្វា ភុញ្ជិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី សប្បិំ វិញ្ញាបេត្វា ភុញ្ជេយ្យ បដិទេសេតព្វំ តាយ ភិក្ខុនិយា គារយ្ហំ អយ្យេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៤៨៨] តេន ខោ បន សមយេន ភិក្ខុនិយោ គិលានា ហោន្តិ ។ គិលានបុច្ឆិកា ភិក្ខុនិយោ គិលានា ភិក្ខុនិយោ ឯតទវោចុំ កច្ចិ អយ្យេ ខមនីយំ កច្ចិ យាបនីយន្តិ ។ បុព្វេ មយំ អយ្យេ សប្បិំ វិញ្ញាបេត្វា ភុញ្ជាម តេន នោ ផាសុ ហោតិ ឥទានិ បន ភគវតា បដិក្ខិត្តន្តិ កុក្កុច្ចាយន្តា ន វិញ្ញាបេម តេន នោ ន ផាសុ ហោតីតិ ។ ភគវតោ ឯតមត្ថំ





មិនសមបើនឹងសូមទឹកដោះរាវឆាន់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយសូមទឹកដោះរាវឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះនូវអាបត្តិនោះ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគបញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ ។

(៤៨៨) សម័យនោះឯង ភិក្ខុនីទាំងឡាយមានជម្ងឺ ។ ភិក្ខុនីទាំងឡាយជាអ្នកសួរជម្ងឺ បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងឡាយដែលឈឺថា នែលោកម្ចាស់ លោកគាប់អត់ទ្រាំសេចក្ដីទុក្ខបានឬទេ លោកគាប់ញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានឬទេ ។ ភិក្ខុនីដែលឈឺទាំងឡាយនោះនិយាយថា នែលោកម្ចាស់ កាលពីដើមយើងទាំងឡាយសូមទឹកដោះរាវឆាន់បាន ហេតុនោះយើងមានសេចក្ដីសប្បាយ តែឥឡូវនេះយើងទាំងឡាយរង្កៀសថា ការសូមនោះព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ដូច្នេះហើយមិនហ៊ានសូម ហេតុនោះហើយយើងទាំងឡាយមិនមានសេចក្ដីសប្បាយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មាន

អាកាសេ ។បេ។ អនុជានាមិ ភិក្ខវេ គិលានាយ ភិក្ខុនិយា សប្បឹ វិញ្ញាបេត្វា ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យា បន ភិក្ខុនី អគិលានា សប្បឹ វិញ្ញាបេត្វា ភុញ្ជេយ្យ បដិទេសេតព្វំ តាយ ភិក្ខុនិយា គារយ្ហំ អយ្យេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

(៨៤៦) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អគិលានា នាម យស្សា វិនា សប្បិនា ផាសុ ហោតិ ។ គិលានា នាម យស្សា វិនា សប្បិនា ន ផាសុ ហោតិ ។ សប្បិ នាម គោសប្បិ វា អជិកាសប្បិ វា មហិំសសប្បិ[១] វា យេសំ មំសំ កប្បតិ តេសំ សប្បិ ។ អគិលានា អត្តនោ អត្ថាយ វិញ្ញាបេតិ បយោគេ ទុក្កដំ បដិលាភេន ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

---

១ ម. មហិំស ក សប្បិ ។ ម. មហឹសា ក សប្បិ ។



ព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុនីឈឺសូមទឹកដោះរាវឆាន់បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនឈឺសូមទឹកដោះរាវឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះជិនព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះនូវអាបត្តិនោះ ។

(៨៤៦) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ភិក្ខុនីណាលះបង់ទឹកដោះរាវហើយបានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថាមិនឈឺ ។ ភិក្ខុនីណាលះបង់ទឹកដោះរាវហើយមិនមានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថាឈឺ ។ ដែលហៅថា ទឹកដោះរាវ គឺទឹកដោះរាវរបស់គោក្តី ទឹកដោះរាវរបស់ពពែក្តី ទឹកដោះរាវរបស់ក្របីក្តី សាច់ពួកសត្វណាគួរ ទឹកដោះរាវរបស់សត្វពួកនោះក៏គួរដែរ ។ ភិក្ខុនីមិនឈឺសូមប្រយោជន៍ដើម្បីខ្លួន ត្រូវទុក្កដក្នុងប្រយោគដែលសូម ភិក្ខុនីទទួលដោយគិតថា នឹងឆាន់ ត្រូវអាបត្តិទុក្កដក្នុងខណៈដែលបានមក ។ ត្រូវអាបត្តិបាដិទេសនីយគ្រប់ៗករៈដែលលេបចូលទៅ ។

[៤៨៧] អគិលានា អគិលានសញ្ញា សប្បិំ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាដិទេសនីយស្ស ។ អគិលានា វេមតិកា សប្បិំ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាដិទេសនីយស្ស ។ អគិលានា គិលានសញ្ញា សប្បិំ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាដិទេសនីយស្ស ។ គិលានា អគិលានសញ្ញា អាបត្តិ ទុក្កដស្ស ។ គិលានា វេមតិកា អាបត្តិ ទុក្កដស្ស ។ គិលានា គិលានសញ្ញា អនាបត្តិ ។

[៤៨៨] អនាបត្តិ គិលានាយ គិលានា ហុត្វា វិញ្ញាបេត្វា អគិលានា ភុញ្ជតិ គិលានាយ សេសកំ ភុញ្ជតិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

[៤៨៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ តេលំ វិញ្ញាបេត្វា ភុញ្ជន្តិ ។ សង្ខេបោ ។ មធុំ វិញ្ញាបេត្វា ភុញ្ជន្តិ ។

៤១០

វិន័យបិដក ភិក្ខុនីវិភង្គ

(៤៨៧) ខ្លួនមិនឈឺ ភិក្ខុនីសំគាល់ថាមិនឈឺ ហើយសូមទឹកដោះរាវឆាន់ ត្រូវអាបត្តិបាដិទេសនីយ ។ ខ្លួនមិនឈឺ (តែ) ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសូមទឹកដោះរាវឆាន់ ត្រូវអាបត្តិបាដិទេសនីយ ។ ខ្លួនមិនឈឺ ភិក្ខុនីសំគាល់ថាឈឺ ហើយសូមទឹកដោះរាវឆាន់ ត្រូវអាបត្តិបាដិទេសនីយ ។ ខ្លួនឈឺ ភិក្ខុនីសំគាល់ថាមិនឈឺ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ (តែ) ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ ភិក្ខុនីសំគាល់ថាឈឺ មិនត្រូវអាបត្តិ ។

(៤៨៨) ការៈវេលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺ ភិក្ខុនីឈឺ ១ ភិក្ខុនីឈឺសូម (គេបានមក) ហើយត្រឡប់ជាមិនឈឺឆាន់ ១ ភិក្ខុនីឆាន់របស់សល់អំពីភិក្ខុនីឈឺ ១ ភិក្ខុនីបានអំពីសំណាក់ពួកញាតិ ១ អំពីសំណាក់ពួកជនបវារណា ១ ភិក្ខុនីសូមដើម្បីប្រយោជន៍អ្នកដទៃ ១ ភិក្ខុនីបានមកដោយទ្រព្យរបស់ខ្លួន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

(៤៨៩) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនីនាំគ្នាសូមប្រេងឆាន់ ។ សេចក្តីបំព្រួញ ។ សូមទឹកឃ្មុំឆាន់ ។ សូមស្ករ

ផាណិតំ វិញ្ញាបេត្វា ភុញ្ជន្តិ ។ មច្ឆំ វិញ្ញាបេត្វា ភុញ្ជន្តិ ។ មំសំ វិញ្ញាបេត្វា ភុញ្ជន្តិ ។ ខីរំ វិញ្ញាបេត្វា ភុញ្ជន្តិ[1] ។ ទធឹ វិញ្ញាបេត្វា ភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ទធឹ វិញ្ញាបេត្វា ភុញ្ជិស្សន្តិ កស្ស សម្បន្នំ ន មនាបំ កស្ស សាទុំ ន រុច្ចតីតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ ទធឹ វិញ្ញាបេត្វា ភុញ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ទធឹ វិញ្ញាបេត្វា ភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ទធឹ វិញ្ញាបេត្វា ភុញ្ជិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី ទធឹ វិញ្ញាបេត្វា ភុញ្ជេយ្យ បដិទេសេតព្វំ

[1] ចិន្តិ ចាប់ខ ភាគុំ ។



អំពៅឆាន់ ១ សូមត្រីឆាន់ ១ សូមសាច់ឆាន់ ១ សូមទឹកដោះស្រស់ឆាន់ ១ សូមទឹកដោះជូរឆាន់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងសូមទឹកដោះជូរឆាន់សោះ អ្នកណាដែលមិនគាប់ចិត្តនឹងរបស់សម្បូណ៌ អ្នកណាដែលមិនចូលចិត្តនឹងរបស់ឆ្ងាញ់ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងសូមទឹកដោះជូរឆាន់សោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយសូមទឹកដោះជូរឆាន់ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងសូមទឹកដោះជូរឆាន់សោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយសូមទឹកដោះជូរឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះថា

តាយ ភិក្ខុនិយា គារយ្ហំ អយ្យេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៤៩០) តេន ខោ បន សមយេន ភិក្ខុនិយោ គិលានា ហោន្តិ ។ គិលានបុច្ឆិកា ភិក្ខុនិយោ គិលានា ភិក្ខុនិយោ ឯតទវោចុំ កច្ចិ អយ្យេ ខមនីយំ កច្ចិ យាបនីយន្តិ ។ បុព្វេ មយំ អយ្យេ ឃតំ វិញ្ញាបេត្វា ភុញ្ជាម តេន នោ ផាសុ ហោតិ ឥទានិ បន ភគវតា បដិក្ខិត្តន្តិ កុក្កុច្ចាយន្តា ន វិញ្ញាបេម តេន នោ ន ផាសុ ហោតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ គិលានាយ ភិក្ខុនិយា ឃតំ វិញ្ញាបេត្វា ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ យា បន ភិក្ខុនី អគិលានា ឃតំ វិញ្ញាបេត្វា ភុញ្ជេយ្យ បដិទេសេតព្វំ តាយ



បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះជាបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះនូវអាបត្តិនោះ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយយ៉ាងនេះ ។

(៤៩០) សម័យនោះឯង ភិក្ខុនីទាំងឡាយមានជម្ងឺ ។ ភិក្ខុនីទាំងឡាយជាអ្នកសួរជម្ងឺ បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងឡាយដែលឈឺថា នែលោកម្ចាស់ លោកគាប់សព្វជាបានទេ អាចញ៉ាំងឥរិយាបថឲ្យប្រព្រឹត្តទៅបានទេ ។ ភិក្ខុនីឈឺទាំងឡាយនោះ និយាយថា នែលោកម្ចាស់ ពីដើមយើងទាំងឡាយសូមទឹកដោះថ្លាឆាន់បាន ហេតុនោះ យើងទាំងឡាយក៏សប្បាយ តែឥឡូវនេះ យើងទាំងឡាយខ្លាចថា ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (បានជា) មិនសូម ហេតុនោះទើបយើងទាំងឡាយមិនសប្បាយ ។ ភិក្ខុនីទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីឈឺសូមទឹកដោះថ្លាឆាន់បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនឈឺ សូមទឹកដោះថ្លាឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះថា

ភិក្ខុនិយោ គារយ្ហំ អយ្យេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

(៤៩១) យា បនាតិ យា យាទិសា ។បេ។ ភិក្ខុនីតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតា ភិក្ខុនីតិ ។ អគិលានា នាម យស្សា វិនា ទធិនា ផាសុ ហោតិ ។ គិលានា នាម យស្សា វិនា ទធិនា ន ផាសុ ហោតិ ។ តេលំ នាម តិលតេលំ សាសបតេលំ មធុកតេលំ ឯរណ្ឌតេលំ វសាតេលំ ។ មធុ នាម មក្ខិកាមធុ ។ ផាណិតំ នាម ឧច្ឆុម្ហា និព្វត្តំ ។ មច្ឆោ នាម ឧទកោ ចរោ វុច្ចតិ ។ មំសំ នាម យេសំ មំសំ កប្បតិ តេសំ មំសំ ។ ខីរំ នាម គោខីរំ វា អជិកាខីរំ វា មហិំសខីរំ វា យេសំ មំសំ កប្បតិ តេសំ ខីរំ ។ ទធិ នាម តេសញ្ញេវ ទធិ ។ អគិលានា អត្តនោ



បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះខ្លួនអាបត្តិនោះ ។

(៤៩១) ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី ១ នៃបាដិទេសនីយកណ្ឌរួចហើយ ។ ភិក្ខុនីណាវៀរចាកទឹកដោះជូរ បានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថា មិនឈឺ ។ ភិក្ខុនីណាមួយវៀរទឹកដោះជូរមិនបានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថា ឈឺ ។ ដែលហៅថា ប្រេង គឺប្រេងគ្រាប់ល្ង ប្រេងគ្រាប់ស្ពៃ ប្រេងគ្រាប់ស្រម៉ ប្រេងគ្រាប់ល្ហុងខ្វង ប្រេងដែលចំរាញ់ពីខ្លាញ់ ។ ដែលហៅថា ទឹកឃ្មុំ គឺទឹកឃ្មុំដែលឃ្មុំធ្វើ ។ ដែលហៅថា ស្ករអំពៅ គឺស្ករកើតពីអំពៅ ។ ដែលហៅថា ត្រី សំដៅយកសត្វទឹក ។ ដែលហៅថា សាច់ គឺសាច់ពួកសត្វណាគួរ ( សម្រាប់យក ) សាច់ពួកសត្វនោះឯង ។ ដែលហៅថា ទឹកដោះស្រស់ គឺទឹកដោះស្រស់របស់គោក្តី ទឹកដោះស្រស់របស់ពពែក្តី ទឹកដោះស្រស់របស់ក្របីក្តី សាច់របស់ពួកសត្វណាគួរ ទឹកដោះស្រស់របស់សត្វទាំងឡាយនោះក៏គួរដែរ ។ ដែលហៅថា ទឹកដោះជូរ គឺទឹកដោះជូររបស់សត្វទាំងឡាយនោះឯង ។ ភិក្ខុនីមិនឈឺសូមប្រយោជន៍ដើម្បីខ្លួន

អត្តាយ វិញ្ញាបេតិ បយោគេ ទុក្កដំ បដិលាភេន ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោ-ហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

(៤៨២) អគិលានា អគិលានសញ្ញា ទធឹ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាដិទេសនីយស្ស ។ អគិលានា វេមតិកា ទធឹ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាដិទេស-នីយស្ស ។ អគិលានា គិលានសញ្ញា ទធឹ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាដិទេសនីយស្ស ។ គិលានា អគិលានសញ្ញា អាបត្តិ ទុក្កដស្ស ។ គិលានា វេមតិ-កា អាបត្តិ ទុក្កដស្ស ។ គិលានា គិលានសញ្ញា អនាបត្តិ ។

(៤៨៣) អនាបត្តិ គិលានាយ គិលានា ហុត្វា វិញ្ញា-បេត្វា អគិលានា ភុញ្ជតិ គិលានាយ សេសកំ ភុញ្ជតិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។



ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម ភិក្ខុនីទទួលដោយគិតថា អញនឹងបរិ-ភោគ ត្រូវអាបត្តិទុក្កដក្នុងខណៈដែលបានមក ត្រូវអាបត្តិបាដិទេសនីយ គ្រប់ៗ [illegible]ដែលលេបចូលទៅ ។

(៤៨២) ភិក្ខុនីមិនឈឺ សំគាល់ថាមិនឈឺ ហើយសូមទឹកដោះជូរឆាន់ ត្រូវអាបត្តិបាដិទេសនីយ ។ ភិក្ខុនីមិនឈឺ តែមានសេចក្ដីសង្ស័យ ហើយសូមទឹកដោះជូរឆាន់ ត្រូវអាបត្តិបាដិទេសនីយ ។ ភិក្ខុនីមិនឈឺ សំគាល់ថាឈឺ ហើយសូមទឹកដោះជូរឆាន់ ត្រូវអាបត្តិបាដិទេសនីយ ។ ភិក្ខុនីឈឺ សំគាល់ថាមិនឈឺ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈឺ តែមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីឈឺ សំគាល់ថាឈឺ មិនត្រូវអាបត្តិ ។

(៤៨៣) [illegible]ដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺភិក្ខុនីឈឺ ១ ភិក្ខុនីឈឺសូម (តែបានមក) ហើយឆាន់ ១ ភិក្ខុនីឆាន់របស់សល់អំពីភិក្ខុនីឈឺ ១ ភិក្ខុនីបានពីសំណាក់ពួកញាតិ ១ អំពីសំណាក់ពួកជនបវារណា ១ ភិក្ខុនីសូមដើម្បីប្រយោជន៍ជនដទៃ ១ ភិក្ខុនីបានដោយទ្រព្យរបស់ខ្លួន ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាខាងដើមបញ្ញត្តិ ១ ។

[៤៤៦] ឧទ្ទិដ្ឋា ខោ អយ្យាយោ អដ្ឋ បាដិទេសនីយា ធម្មា ។ តត្ថយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ បរិសុទ្ធេត្ថយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បាដិទេសនីយា និដ្ឋិតា[១] ។

---

១ ម. បាដិទេសនីយំ និដ្ឋិតំ ។



[៤៤៦] បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះបាដិទេសនីយ ៨ ខ្ញុំសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ លោកម្ចាស់ទាំងឡាយបរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះបានជាស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

បាដិទេសនីយ ចប់ ។

# សេក្ខិយកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ សេក្ខិយា

ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

(៦៤៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា[១] និវាសេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេស្សន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ឆព្វគ្គិយា ភិក្ខូ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ

---

[១] ម. ឱលម្ពេត្វា ។

# សេក្ខិយកណ្ឌ

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះ

សេក្ខិយៈ សម្បូណ៌នេះតែងមកកាន់ឧទ្ទេស ។

(៦៤៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយស្លៀកស្បង់យោល (ស្រយ) មុខខ្លះ (ស្រយ) ក្រោយខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងស្លៀកស្បង់យោល (ស្រយ) មុខខ្លះ (ស្រយ) ក្រោយខ្លះដូចជាពួកគ្រហស្ថបរិភោគកាមសោះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុទាំងឡាយមិនគួរបើនឹងស្លៀកស្បង់យោល (ស្រយ) មុខខ្លះ (ស្រយ) ក្រោយខ្លះសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយភិក្ខុទាំងឡាយស្លៀកស្បង់យោល (ស្រយ) មុខខ្លះ (ស្រយ) ក្រោយខ្លះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ

ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយាតិ ។

(៤៩៦) បរិមណ្ឌលំ និវាសេតព្វំ នាភិមណ្ឌលំ ជាណុមណ្ឌលំ បដិច្ឆាទេន្តិយា ។ យា អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តា និវាសេតិ អាបត្តិ ទុក្កដស្ស ។

(៤៩៧) អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តិយា គិលានាយ អាបទាសុ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។ សង្ខេបោ ។

(៤៩៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករោន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ ឧទកេ



ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនគួរបើ នឹងស្លៀកសំយុងមុខខ្លះ សំយុងក្រោយខ្លះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគួរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីគប្បីធ្វើសេចក្តីសិក្សាថា អាត្មានឹងស្លៀកឲ្យជាប់រិមណ្ឌល ។

(៤៩៦) ភិក្ខុនីត្រូវស្លៀកឲ្យជាប់រិមណ្ឌល គឺបិទបាំងមណ្ឌលផ្ចិត មណ្ឌលជង្គង់ ។ ភិក្ខុនីណាមួយប្រកាន់យកសេចក្តីមិនអើពើ ហើយស្លៀកសំយុងមុខ ឬសំយុងក្រោយ ត្រូវអាបត្តិទុក្កដ ។

(៤៩៧) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុនីមិនក្លែង ១ ភិក្ខុនីមិនមានសតិ ១ ភិក្ខុនីមិនដឹងខ្លួន ១ ភិក្ខុនីឈឺ ១ ភិក្ខុនីមានសេចក្តីអន្តរាយ ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាអាទិដើមបញ្ញត្តិ ១ ។ សេចក្តីសង្ខេប ។

(៤៩៨) សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនីទាំងឡាយបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះក្នុងទឹក ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ

ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករិស្សន្តិ សេយ្យថាបិ គិហិនិយោ កាមភោគិនិយោតិ ។ អស្សោសុំ ខោ ភិក្ខុនិយោ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយន្តានំ វិបាចេន្តានំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខិយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករិស្សន្តីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ។ បេ ។ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករោន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ ឆព្វគ្គិយា ភិក្ខុនិយោ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ភិក្ខុនិយោ ឥមំ សិក្ខាបទំ ឧទ្ទិសន្តុ ។ ឧទកេ ឧច្ចារំ វា



មិនសមបើនឹងធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះក្នុងទឹកដូចជាពួកស្រីគ្រហស្ថបរិភោគកាមៈសោះ ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះ ក្នុងទឹកសោះ ។ ទើបភិក្ខុនីទាំងឡាយនោះក្រាបបង្គំទូលដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ។ បេ ។ ត្រាស់សួរចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីទាំងឡាយធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះ ក្នុងទឹក ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះក្នុងទឹកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសំដែងឡើង

បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយាតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៨៩៩] តេន ខោ បន សមយេន គិលានា ភិក្ខូ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ កាតុំ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ កាតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយាតិ ។

[៩០០] ន ឧទកេ អគិលានេន ឧច្ចារោ វា បស្សាវោ វា ខេឡោ វា កាតព្វោ យោ អនាទរិយំ បដិច្ច ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោតិ អាបត្តិ ទុក្កដស្ស ។



នូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនធ្វើឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយ យ៉ាងនេះ ។

[៨៩៩] សម័យនោះឯង ភិក្ខុទាំងឡាយឈឺ ក៏រង្កៀស (មិនហ៊ាន) ធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះ ក្នុងទឹក ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគមានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺធ្វើឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹកបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញមិនឈឺនឹងមិនធ្វើឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក ។

[៩០០] ភិក្ខុមិនឈឺ មិនត្រូវធ្វើឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹកឡើយ ភិក្ខុណាមិនឈឺ អាស្រ័យសេចក្ដីមិនអើពើ ហើយធ្វើឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

(៨០១) អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តិយា គិលានាយ ថលេ កតា ឧទកំ ឱត្ថរតិ អាបទាសុ ឧម្មត្តិកាយ ខិត្តចិត្តាយ វេទនដ្ដាយ អាទិកម្មិកាយាតិ ។

(៨០២) ឧទ្ទិដ្ឋា ខោ អយ្យាយោ សេខិយា ធម្មា ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

សេខិយា និដ្ឋិតា ។



(៨០១) វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១០ យ៉ាង) គឺ ភិក្ខុនីមិនក្រែង១ ភិក្ខុនីមិនមានសតិ១ ភិក្ខុនីមិនដឹងខ្លួន១ ភិក្ខុនីឈឺ១ ភិក្ខុនីធ្វើឧច្ចារៈ (ជាដើម) លើគោកហើយហូរទៅក្នុងទឹក១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីមានចិត្តរវើរវាយ១ ភិក្ខុនីមានវេទនាគ្របសង្កត់១ ភិក្ខុនីជាអាទិកម្មិក១ ។

(៨០២) បពិត្រលោកម្ចាស់ទាំងឡាយ ធម៌ទាំងឡាយឈ្មោះសេខិយៈ ខ្ញុំសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងធម៌ទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសូមសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសូមសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ លោកម្ចាស់ទាំងឡាយបរិសុទ្ធក្នុងធម៌ទាំងនេះហើយ ហេតុនោះបានជាស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

សេខិយៈ ចប់ ។

## អធិករណសមថា ឱសានំ

(៥០៣) ឥមេ ខោ បនាយ្យាយោ សត្ត អធិករណសមថា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។ ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយ សម្មុខាវិនយោ ទាតព្វោ សតិវិនយោ ទាតព្វោ អមូឡ្ហវិនយោ ទាតព្វោ បដិញ្ញាតករណំ[១] យេភុយ្យសិកា តស្ស បាបិយសិកា[២] តិណវត្ថារកោតិ ។ ឧទ្ទិដ្ឋា ខោ អយ្យាយោ សត្ត អធិករណសមថា ធម្មា ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ។ បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

អធិករណសមថា និដ្ឋិតា ។

១ ម. បដិញ្ញាយ ករេតព្វំ ។ ២ ម. តស្សបាបិយសិកា ។

## អធិករណសមថៈ ទីបំផុត

(៥០៣) បពិត្រលោកម្ចាស់ទាំងឡាយ ធម៌សម្រាប់រម្ងាប់នូវអធិករណ៍ទាំងឡាយ ៧ នេះឯង តែងមកកាន់ឧទ្ទេស ។ សង្ឃត្រូវឲ្យសម្មុខាវិន័យ ឲ្យសតិវិន័យ ឲ្យអមូឡ្ហវិន័យ សង្ឃត្រូវធ្វើបដិញ្ញាតករណៈ ត្រូវធ្វើយេភុយ្យសិកា ត្រូវធ្វើតស្សបាបិយសិកា ត្រូវធ្វើតិណវត្ថារក[១] ដើម្បីរម្ងាប់ ដើម្បីស្ងប់នូវអធិករណ៍ទាំងឡាយដែលកើតឡើងហើយ ៗ ។ បពិត្រលោកម្ចាស់ទាំងឡាយ ធម៌ទាំងឡាយ ឈ្មោះអធិករណសមថៈ ទាំង ៧ ខ្ញុំសំដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងធម៌ទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ ខ្ញុំសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។ លោកម្ចាស់ទាំងឡាយបរិសុទ្ធក្នុងធម៌ទាំងនេះហើយ ហេតុនោះបានជាស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

អធិករណសមថៈ ចប់ ។

១ មានសេចក្ដីអធិប្បាយពិស្ដារក្នុងមហាវិភង្គ ទុតិយភាគរួចហើយ ។

(៥០៤) ឧទ្ទិដ្ឋំ ខោ អយ្យាយោ និទានំ ឧទ្ទិដ្ឋា អដ្ឋ បារាជិកា ធម្មា ឧទ្ទិដ្ឋា សត្តរស សង្ឃាទិសេសា ធម្មា ឧទ្ទិដ្ឋា តឹស និស្សគ្គិយា បាចិត្តិយា ធម្មា ឧទ្ទិដ្ឋា ឆសដ្ឋិសតា បាចិត្តិយា ធម្មា ឧទ្ទិដ្ឋា អដ្ឋ បាដិទេសនីយា ធម្មា ឧទ្ទិដ្ឋា សេខិយា ធម្មា ឧទ្ទិដ្ឋា សត្ត អធិករណសមថា ធម្មា ។ ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វាហេវ សមគ្គាហិ សម្មោទមានាហិ អវិវទមានាហិ សិក្ខិតព្វន្តិ ។

ភិក្ខុនីវិភង្គោ និដ្ឋិតោ ។

---



(៥០៤) បពិត្រលោកម្ចាស់ទាំងឡាយ និទានខ្ញុំសំដែងឡើងហើយ អាបត្តិបារាជិក ៨ ខ្ញុំសំដែងឡើងហើយ អាបត្តិសង្ឃាទិសេស ១៧ ខ្ញុំសំដែងឡើងហើយ អាបត្តិនិស្សគ្គិយបាចិត្តិយ ៣០ ខ្ញុំសំដែងឡើងហើយ អាបត្តិបាចិត្តិយ ១៦៦ ខ្ញុំសំដែងឡើងហើយ អាបត្តិបាដិទេសនីយ ៨ ខ្ញុំសំដែងឡើងហើយ ធម៌ឈ្មោះសេក្ខិយៈទាំងឡាយខ្ញុំសំដែងឡើងហើយ ធម៌ឈ្មោះអធិករណសមថៈ ៧ ខ្ញុំសំដែងឡើងហើយ ។ ពាក្យរបស់ព្រះដ៏មានព្រះភាគនោះមានប្រមាណប៉ុណ្ណេះមកហើយក្នុងសូត្រ រាប់បញ្ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេសរាល់កន្លះខែ ។ អ្នកលោកម្ចាស់ទាំងឡាយគ្រប់អង្គព្រមព្រៀងគ្នា ស្រុះស្រួលគ្នា កុំទាស់ទែងគ្នា សិក្សាក្នុងពុទ្ធវចនៈនោះចុះ ។

ភិក្ខុនីវិភង្គ ចប់ ។

# សង្ខេបក្បួនប្រាប់មាតិកា


លេខទំព័រ

បារាជិកទី ១ ........ ១

និទានបុរសឈ្មោះសុទិន្ន ជាបៅទីតារមាតា ........ ៣

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ៨

បទភាជនីយ និងការៈដែលមិនត្រូវអាបត្តិ ........ ១១, ១៦

បារាជិកទី ២ ........ ១៧

និទានលោកធនិយកុម្ភការបុត្ត ........ ៣

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៩

បទភាជនីយ និងការៈដែលមិនត្រូវអាបត្តិ ........ ២១

បារាជិកទី ៣ ........ ២៣

និទានសម្ពហុលភិក្ខុ ........ ៣

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ២៦

ការសូត្រសមនុភាសនកម្ម ........ ២៧

បទភាជនីយ និងការៈដែលមិនត្រូវអាបត្តិ ........ ២៨, ២៩

បារាជិកទី ៤ ........ ៣០

និទានវគ្គុមុទាតីរិយភិក្ខុ ........ ៣

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ៣១, ៣២

បទភាជនីយ និងការៈដែលមិនត្រូវអាបត្តិ ........ ៣៤

វត្ថុសារីសារ ........ ៣៨

លេខទំព័រ


សត្តរសកណ្ឌ ៣៦

## សង្ឃាទិសេសទី ១ 〃

និទានទោយាសម្នាក់ ប្រភេទឃ្លាំង . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិ . . . . . . . . . . ៣៨
សិក្ខាបទវិភង្គ និងបទភាជនីយ . . . . . . . . . . ៤០
ភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៤១

## សង្ឃាទិសេសទី ២ ៤០

និទានភរិយាស្ដេចសេដ្ឋី . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៤៤
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៤៨, ៤៦

## សង្ឃាទិសេសទី ៣ ៤៧

និទានភិក្ខុនី ជាសំស្បូរទាក់ទិលនឹងភិក្ខុនី . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិជាដំបូង និងនិទានភិក្ខុនីពីររូប . . . . . . . . . . ៤៨
អនុប្បញ្ញត្តិ ទី ១ . . . . . . . . . . ៤៨
និទានភិក្ខុនីច្រើនរូប និងអនុប្បញ្ញត្តិ ទី ២ . . . . . . . . . . ៥០, ៥១
អនុប្បញ្ញត្តិ ទី ៣ និងសិក្ខាបទវិភង្គ . . . . . . . . . . ៥៣
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៥៤, ៥៥

## សង្ឃាទិសេសទី ៤ ៥៥

និទានចណ្ឌកាលីភិក្ខុនី . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៥៧, ៥៨
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៥៨, ៦០




លេខទំព័រ


## សង្ឃាទិសេសទី ៥ ៦០

និទានសុន្ទរីនន្ទាភិក្ខុនី . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គនិងភាពដែលមិនត្រូវអាបត្តិ . . . . . . ៦១, ៦២, ៦៣

## សង្ឃាទិសេសទី ៦ ៦៤

និទានសុន្ទរីនន្ទាភិក្ខុនី . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៦៦
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៦៧, ៦៨

## សង្ឃាទិសេសទី ៧ ៦៨

និទានចណ្ឌកាលីភិក្ខុនី . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៧០
ការស្មូត្រសមនុភាសនកម្ម . . . . . . . . . . ៧៣
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៧៦

## សង្ឃាទិសេសទី ៨ ៧៧

និទានចណ្ឌកាលីភិក្ខុនី . . . . . . . . . . 〃
សិក្ខាបទវិភង្គ និងការស្មូត្រសមនុភាសនកម្ម . . . . . . . . . . ៧៨, ៨០
ភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៨៣

## សង្ឃាទិសេសទី ៩ ៨៤

និទានថុល្លនន្ទាភិក្ខុនី ជាអន្តេវាសិនីរបស់ថុល្លនន្ទាភិក្ខុនី . . . . . . . . . . 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៨៥-៨៦
ការស្មូត្រសមនុភាសនកម្ម និងបទភាជនីយ . . . . . . . . . . ៨៨, ៨៩
ភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៩១

លេខទំព័រ

សង្ឃាទិសេសទី ១០ ..... ៩១

និទានថុល្លនន្ទាភិក្ខុនី..... ”
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ..... ៩៣, ៩៤
ការសូត្រសមនុភាសនកម្ម និងបទភាជនីយ..... ៩៧, ១០០
ភិក្ខុនីដែលមិនត្រូវអាបត្តិ និងទេសនាសមាន..... ១០១

និស្សគ្គិយកណ្ឌ

បត្តវគ្គ សិក្ខាបទទី ១ ..... ១០៣

និទានឆព្វគ្គិយាភិក្ខុនី..... ”
សិក្ខាបទវិភង្គ និងបទភាជនីយ..... ១០៤, ១០៧
ភិក្ខុនីដែលមិនត្រូវអាបត្តិ និងរឿងឆព្វគ្គិយាភិក្ខុនី ..... ១០៨

បត្តវគ្គ សិក្ខាបទទី ២ ..... ១០៩

និទានភិក្ខុនីច្រើនរូប..... ”
សិក្ខាបទវិភង្គ និងភិក្ខុនីដែលមិនត្រូវអាបត្តិ ..... ១១១, ១១២

បត្តវគ្គ សិក្ខាបទទី ៣ ..... ១១២

និទានថុល្លនន្ទាភិក្ខុនី..... ”
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ..... ១១៤
បទភាជនីយ និងភិក្ខុនីដែលមិនត្រូវអាបត្តិ ..... ១១៥, ១១៦

បត្តវគ្គ សិក្ខាបទទី ៤ ..... ១១៦

និទានថុល្លនន្ទាភិក្ខុនីមានជម្ងឺ ..... ”
សិក្ខាបទវិភង្គ និងបទភាជនីយ..... ១១៨, ១១៩
ភិក្ខុនីដែលមិនត្រូវអាបត្តិ ..... ១២០



លេខទំព័រ

បត្តវគ្គ សិក្ខាបទទី ៥ ..... ១២០

និទានថុល្លនន្ទាភិក្ខុនី មានជម្ងឺ..... ”
បទភាជនីយ និងភិក្ខុនីដែលមិនត្រូវអាបត្តិ..... ១២៣, ១២៤

បត្តវគ្គ សិក្ខាបទទី ៦ ..... ១២៥

និទានមេឃាសកច្រើនរូប ..... ”
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ..... ១២៦
បទភាជនីយ និងភិក្ខុនីដែលមិនត្រូវអាបត្តិ..... ១២៧

បត្តវគ្គ សិក្ខាបទទី ៧ ..... ១២៨

និទានឧបាសកច្រើនរូប..... ”
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ..... ១២៩
បទភាជនីយ និងភិក្ខុនីដែលមិនត្រូវអាបត្តិ ..... ១៣០

បត្តវគ្គ សិក្ខាបទទី ៨ ..... ១៣២

និទានភិក្ខុនីច្រើនរូប..... ”
សេចក្ដីបញ្ញត្តិ និងបទភាជនីយ..... ១៣៤
ភិក្ខុនីដែលមិនត្រូវអាបត្តិ..... ១៣៥

បត្តវគ្គ សិក្ខាបទទី ៩ ..... ១៣៦

និទានភិក្ខុនីច្រើនរូប..... ”
សេចក្ដីបញ្ញត្តិ និងបទភាជនីយ..... ១៣៧, ១៣៨
ភិក្ខុនីដែលមិនត្រូវអាបត្តិ ..... ១៣៩

លេខទំព័រ

បត្តវគ្គ សិក្ខាបទទី ១០ ........ ១៦០
និទានថុល្លនន្ទាភិក្ខុនី ........ 〃
សេចក្ដីបញ្ញត្តិ និងបទភាជនីយ ........ ១៦១, ១៦២
ករណីដែលមិនត្រូវអាបត្តិ ........ ១៦៣

ចីវរវគ្គ សិក្ខាបទទី ១ ........ ១៦៤
និទានថុល្លនន្ទាភិក្ខុនី ........ 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៦៥
ករណីដែលមិនត្រូវអាបត្តិ ........ ១៦៧

ចីវរវគ្គ សិក្ខាបទទី ២ ........ ១៦៨
សេចក្ដីបញ្ញត្តិ និងបទភាជនីយ ........ ១៦៩, ១៧០
ករណីដែលមិនត្រូវអាបត្តិ និងវត្ថុសាវសេស ........ ១៧០, ១៧២

លសុណវគ្គ សិក្ខាបទទី ១ ........ ១៧៣
និទានឧបាសកម្នាក់ ........ 〃
សិក្ខាបទវិភង្គ និងករណីដែលមិនត្រូវអាបត្តិ ........ ១៧៥, ១៧៦

លសុណវគ្គ សិក្ខាបទទី ២ ........ ១៧៧
និទានឆព្វគ្គិយាភិក្ខុនី ........ 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៧៨
ករណីដែលមិនត្រូវអាបត្តិ ........ ១៧៩

លសុណវគ្គ សិក្ខាបទទី ៣ ........ ១៧៩



លេខទំព័រ

សេចក្ដីបញ្ញត្តិ-សិក្ខាបទវិភង្គ និងករណីដែលមិនត្រូវអាបត្តិ ........ ១៨០

លសុណវគ្គ សិក្ខាបទទី ៤ ........ ១៨១
និទានស្រីស្នំ ........ 〃
សេចក្ដីបញ្ញត្តិ និងករណីដែលមិនត្រូវអាបត្តិ ........ ១៨២

លសុណវគ្គ សិក្ខាបទទី ៥ ........ ១៨៣
និទានព្រះនាងមហាបជាបតីគោតមី ........ 〃
បទភាជនីយ និងករណីដែលមិនត្រូវអាបត្តិ ........ ១៨៤, ១៨៥

លសុណវគ្គ សិក្ខាបទទី ៦ ........ ១៨៦
និទានមហាមាត្យឈ្មោះអារោហន្ត ........ 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៨៧
ករណីដែលមិនត្រូវអាបត្តិ ........ ១៨៨

លសុណវគ្គ សិក្ខាបទទី ៧ ........ ១៨៩
និទានពួកភិក្ខុនី ចាំញាសូមស្រូវ ........ 〃
សិក្ខាបទវិភង្គ និងករណីដែលមិនត្រូវអាបត្តិ ........ ១៩០

លសុណវគ្គ សិក្ខាបទទី ៨ ........ ១៩១
និទានព្រាហ្មណ៍ម្នាក់ ជាពលរាមាត្យ ........ 〃
សិក្ខាបទវិភង្គ និងករណីដែលមិនត្រូវអាបត្តិ ........ ១៩៣

លសុណវគ្គ សិក្ខាបទទី ៩ ........ ១៩៤
និទានព្រាហ្មណ៍ម្នាក់មានស្រែស្រូវដំណើប ........ 〃
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៩៥

លេខទំព័រ

ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ១៧៥

លសុណវគ្គ សិក្ខាបទទី ១០ ១៧៦

និទានចុទ្ទិយាភិក្ខុនី និងសេចក្តីបញ្ញត្តិ . . . . . . . . . . . . . . . . ១៧៧
សិក្ខាបទវិភង្គ និងភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . ១៧៨

អន្ធការវគ្គ សិក្ខាបទទី ១ ១៧៩

និទានបុរសជាញាតិរបស់ភិក្ខុនី ជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី . . . . . . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . . . . ១៨០
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ១៨១

អន្ធការវគ្គ សិក្ខាបទទី ២ ១៨១

និទានបុរសជាញាតិរបស់ភិក្ខុនី ជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី . . . . . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . . . . ១៨២
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ១៨៣

អន្ធការវគ្គ សិក្ខាបទទី ៣ ១៨៤

និទានបុរសជាញាតិរបស់ភិក្ខុនី ជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . . . . ១៨៤
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ១៨៥

អន្ធការវគ្គ សិក្ខាបទទី ៤ ១៨៦

និទានថុល្លនន្ទាភិក្ខុនី . . . . . . . . . . . . . . . . . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . . ១៨៧, ១៨៨
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ១៨៨



លេខទំព័រ

អន្ធការវគ្គ សិក្ខាបទទី ៥ ១៨៩

និទានភិក្ខុនី ១ រូប . . . . . . . . . . . . . . . . . . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . . . ១៩១
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ១៩៣

អន្ធការវគ្គ សិក្ខាបទទី ៦ ១៩៣

និទានថុល្លនន្ទាភិក្ខុនី . . . . . . . . . . . . . . . . . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . ១៩២, ១៩៤
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ១៩៥

អន្ធការវគ្គ សិក្ខាបទទី ៧ ១៩៦

និទានភិក្ខុនីច្រើនរូប . . . . . . . . . . . . . . . . . . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . . . ១៩៨
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ២០០

អន្ធការវគ្គ សិក្ខាបទទី ៨ ២០០

និទានភិក្ខុនី ជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី . . . . . . . . . . . . "
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . . . . . . . . ២០១
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ២០២

អន្ធការវគ្គ សិក្ខាបទទី ៩ ២០៣

និទានចណ្ឌកាឡីភិក្ខុនី សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . ២០៣, ២០៤
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ២០៥

លេខទំព័រ

អន្ធការវគ្គ សិក្ខាបទទី ១០ ៦០៥

និទានចណ្ឌកាលីភិក្ខុនី - សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ ..... ២០៥, ២០៦

តុវដ្ដវគ្គ សិក្ខាបទទី ១ ៦០៧

និទានសិក្ខមានាដល់ទីក្នុង - សេចក្តីបញ្ញត្តិ - សិក្ខាបទវិភង្គនិងវារៈដែលមិនត្រូវអាបត្តិ . ២០៧, ២០៨

តុវដ្ដវគ្គ សិក្ខាបទទី ២ ៦០៨

និទានព្រះថេរមាតាព្រះភទ្ទាកាបិលានីនឹងអនុញ្ញាតសំពត់ក្នុងទីល............ ៕

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.................... ២០៩, ២១០

វារៈដែលមិនត្រូវអាបត្តិ....................... ២១១

តុវដ្ដវគ្គ សិក្ខាបទទី ៣ ៦១០

និទានភិក្ខុនី ១ រូបមានសំពត់សម្រាប់ធ្វើចីវរ............... ៕

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.................... ២១២, ២១៣

វារៈដែលមិនត្រូវអាបត្តិ....................... ២១៥

តុវដ្ដវគ្គ សិក្ខាបទទី ៤ ៦១៥

និទានថុល្លនន្ទាភិក្ខុនីធ្វើចីវរ...................... ៕

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.................. ២១៦

វារៈដែលមិនត្រូវអាបត្តិ ...................... ២១៧

តុវដ្ដវគ្គ សិក្ខាបទទី ៥ ៦១៧

និទានភិក្ខុនី ២ រូប.......................... ២១៨

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ................. ២១៩

វារៈដែលមិនត្រូវអាបត្តិ........................ ២២០



លេខទំព័រ

តុវដ្ដវគ្គ សិក្ខាបទទី ៦ ៦២០

និទានគ្រែរួលចង្ក្រានរបស់ថុល្លនន្ទាភិក្ខុនី.................. ៕

សេចក្តីបញ្ញត្តិ........................... ២២១

សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ.................. ២២២

តុវដ្ដវគ្គ សិក្ខាបទទី ៧ ៦២៣

និទានអកាលយ៉ាវ ហើយឡើងនិងភិក្ខុនីសង្ឃ................. ៕

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ................... ២២៤

វារៈដែលមិនត្រូវអាបត្តិ ...................... ២២៥

តុវដ្ដវគ្គ សិក្ខាបទទី ៨ ៦២៥

និទានថុល្លនន្ទាភិក្ខុនី........................ ៕

សេចក្តីបញ្ញត្តិ........................... ២២៦

សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ ................ ២២៧

តុវដ្ដវគ្គ សិក្ខាបទទី ៩ ៦២៧

និទាន...របស់ថុល្លនន្ទាភិក្ខុនី.................. ៕

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.................. ២២៨

វារៈដែលមិនត្រូវអាបត្តិ....................... ២៣០

តុវដ្ដវគ្គ សិក្ខាបទទី ១០ ៦៣០

និទានបោះបង់ចោលវិហារ...................... ៕

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.................. ២៣៣

វារៈដែលមិនត្រូវអាបត្តិ ...................... ២៣៤

លេខទំព័រ

តុវដ្ដវគ្គ សិក្ខាបទទី ១ ៦៣៧

និទានភិក្ខុនីពីររូប.......................... ״

សេចក្តីបញ្ញត្តិ-សិក្ខាបទវិភង្គ និងភាពដែលមិនត្រូវអាបត្តិ .......... ២៣៦

តុវដ្ដវគ្គ សិក្ខាបទទី ២ ៦៣៨

និទានភិក្ខុនីពីររូប.......................... ״

សេចក្តីបញ្ញត្តិ.......................... ២៣៧

សិក្ខាបទវិភង្គ.......................... ២៣៨

ភាពដែលមិនត្រូវអាបត្តិ .......................... ២៣៩

តុវដ្ដវគ្គ សិក្ខាបទទី ៣ ៦៣៩

និទានថុល្លនន្ទាភិក្ខុនី.......................... ״

សេចក្តីបញ្ញត្តិ.......................... ២៤០

សិក្ខាបទវិភង្គ.......................... ២៤១

ភាពដែលមិនត្រូវអាបត្តិ .......................... ២៤២

តុវដ្ដវគ្គ សិក្ខាបទទី ៤ ៦៤១

និទានថុល្លនន្ទាភិក្ខុនី.......................... ״

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......................... ២៤៣

ភាពដែលមិនត្រូវអាបត្តិ .......................... ២៤៤

តុវដ្ដវគ្គ សិក្ខាបទទី ៥ ៦៤៤

និទានភទ្ទាកាបិលានីភិក្ខុនី.......................... ״

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......................... ២៤៥





លេខទំព័រ

សេចក្តីបញ្ញត្តិទី ២.......................... ២៤៨

ភាពដែលមិនត្រូវអាបត្តិ .......................... ២៤៩

តុវដ្ដវគ្គ សិក្ខាបទទី ៦ ៦៤៨

និទានចណ្ឌកាលីភិក្ខុនី .......................... ״

សិក្ខាបទវិភង្គ.......................... ២៥០

ភាពដែលមិនត្រូវអាបត្តិ .......................... ២៥១

តុវដ្ដវគ្គ សិក្ខាបទទី ៧ ៦៥៣

និទានភិក្ខុនីទាំងឡាយ.......................... ״

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......................... ២៥៤

ភាពដែលមិនត្រូវអាបត្តិ .......................... ២៥៥

តុវដ្ដវគ្គ សិក្ខាបទទី ៨ ៦៥៦

និទានភិក្ខុនីទាំងឡាយ.......................... ״

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......................... ២៥៧

ភាពដែលមិនត្រូវអាបត្តិ .......................... ២៥៨

តុវដ្ដវគ្គ សិក្ខាបទទី ៩ ៦៥៨

និទានគូតភិក្ខុនី.......................... ״

ភាពដែលមិនត្រូវអាបត្តិ .......................... ២៦០

តុវដ្ដវគ្គ សិក្ខាបទទី ១០ ៦៦០

និទានភិក្ខុនីទាំងឡាយ.......................... ״

លេខទំព័រ

ចិត្តាគារវគ្គ សិក្ខាបទទី ១ ........ ៦៦៣

និទានទៅមើលរោងគំនូរ. . . . . . . . . . 〃
សិក្ខាបទវិភង្គ និងភាវៈដែលមិនត្រូវអាបត្តិ . . . . . . ២៦៦, ២៦៧

ចិត្តាគារវគ្គ សិក្ខាបទទី ២ ........ ៦៦៤

និទានភិក្ខុនីទាំងឡាយ. . . . . . . . . . 〃
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . ២៦៨

ចិត្តាគារវគ្គ សិក្ខាបទទី ៣ ........ ៦៦៧

និទានឆព្វគ្គិយាភិក្ខុនី. . . . . . . . . . 〃
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . ២៦៩

ចិត្តាគារវគ្គ សិក្ខាបទទី ៤ ........ ៦៦៩

និទានភិក្ខុនីទាំងឡាយ. . . . . . . . . . 〃
សិក្ខាបទវិភង្គ និងភាវៈដែលមិនត្រូវអាបត្តិ . . . . . . ២៧០

ចិត្តាគារវគ្គ សិក្ខាបទទី ៥ ........ ៦៧០

និទានភិក្ខុនី ១ រូប. . . . . . . . . . 〃
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ. . . . . . . . . ២៧២
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . ២៧៤

ចិត្តាគារវគ្គ សិក្ខាបទទី ៦ ........ ៦៧៤

និទានថុល្លនន្ទាភិក្ខុនី. . . . . . . . . . 〃
សិក្ខាបទវិភង្គ និងភាវៈដែលមិនត្រូវអាបត្តិ . . . . . . ២៧៥



លេខទំព័រ

ចិត្តាគារវគ្គ សិក្ខាបទទី ៧ ........ ៦៧៦

និទានថុល្លនន្ទាភិក្ខុនី. . . . . . . . . . 〃
សិក្ខាបទវិភង្គ និងភាវៈដែលមិនត្រូវអាបត្តិ . . . . . . ២៧៧, ២៧៨

ចិត្តាគារវគ្គ សិក្ខាបទទី ៨ ........ ៦៧៩

និទានថុល្លនន្ទាភិក្ខុនី. . . . . . . . . . 〃
សេចក្តីបញ្ញត្តិ និងភាវៈដែលមិនត្រូវអាបត្តិ . . . . . . ២៨២

ចិត្តាគារវគ្គ សិក្ខាបទទី ៩ ........ ៦៨២

និទានឆព្វគ្គិយាភិក្ខុនី. . . . . . . . . . 〃
សេចក្តីបញ្ញត្តិ និងភាវៈដែលមិនត្រូវអាបត្តិ . . . . . . ២៨៣, ២៨៤

ចិត្តាគារវគ្គ សិក្ខាបទទី ១០ ........ ៦៨៤

និទានឆព្វគ្គិយាភិក្ខុនី. . . . . . . . . . 〃
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ. . . . . . . . . ២៨៨
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . 〃

អារាមវគ្គ សិក្ខាបទទី ១ ........ ៦៨៦

និទានភិក្ខុច្រើនរូប. . . . . . . . . . 〃
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . ២៩០

អារាមវគ្គ សិក្ខាបទទី ២ ........ ៦៩០

និទានព្រះកប្បិតក. . . . . . . . . . 〃
សេចក្តីបញ្ញត្តិ. . . . . . . . . . ២៩២
ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . ២៩៣

លេខទំព័រ

ភោជនវគ្គ សិក្ខាបទទី ៣ ... ២៩៦

និទានបញ្ញកាលិកភិក្ខុនី និងបុព្វន្តភិក្ខុនី ... ״

សិក្ខាបទវិភង្គ និងភារៈដែលមិនត្រូវអាបត្តិ ... ២៩៦

ភោជនវគ្គ សិក្ខាបទទី ៤ ... ២៩៧

និទានព្រាហ្មណ៍ម្នាក់ និងភិក្ខុនីជាច់ ... ״

បទភាជនីយ និងភារៈដែលមិនត្រូវអាបត្តិ ... ២៩៩, ៣០០

ភោជនវគ្គ សិក្ខាបទទី ៥ ... ៣០០

និទានភិក្ខុនីមួយរូប ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣០១, ៣០២

ភោជនវគ្គ សិក្ខាបទទី ៦ ... ៣០២

និទានភិក្ខុនីច្រើនរូប ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣០៤

ភោជនវគ្គ សិក្ខាបទទី ៧ ... ៣០៤

និទានភិក្ខុនីច្រើនរូប ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣០៥, ៣០៦

ភោជនវគ្គ សិក្ខាបទទី ៨ ... ៣០៦

និទានភេសជ្ជិយភិក្ខុ ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣០៨



លេខទំព័រ

ភោជនវគ្គ សិក្ខាបទទី ៩ ... ៣០៨

និទានភិក្ខុនីទាំងឡាយ ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣០៩

ភោជនវគ្គ សិក្ខាបទទី ១០ ... ៣១០

និទានភិក្ខុនីមួយរូប ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣១១, ៣១២

អចេលកវគ្គ សិក្ខាបទទី ១ ... ៣១៣

និទានភិក្ខុនីទាំងឡាយ ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣១៤, ៣១៥

អចេលកវគ្គ សិក្ខាបទទី ២ ... ៣១៦

និទានភិក្ខុនីច្រើនរូប ... ״

សិក្ខាបទវិភង្គ និងភារៈដែលមិនត្រូវអាបត្តិ ... ៣១៧

អចេលកវគ្គ សិក្ខាបទទី ៣ ... ៣១៧

និទានភិក្ខុនីទាំងឡាយឲ្យរបស់ឲ្យទានដល់សិក្ខមានា ... ៣១៩, ៣២០

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣២១, ៣២២

អចេលកវគ្គ សិក្ខាបទទី ៤ ... ៣២២

និទានភិក្ខុនីឲ្យរបស់ឲ្យទានដល់សិក្ខមានា ... ״

សេចក្ដីបញ្ញត្តិ និងភារៈដែលមិនត្រូវអាបត្តិ ... ៣២៤, ៣២៥

លេខទំព័រ

គព្ភិនីវគ្គ សិក្ខាបទទី ៥ ៣២៧

និទានភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា មានវស្សាមិនគ្រប់ ១២ ឆ្នាំ . . . ·

សិក្ខាបទវិភង្គ នឹងភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . ៣២៨, ៣៣០

គព្ភិនីវគ្គ សិក្ខាបទទី ៦ ៣៣០

និទានភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា. . . . . . . . . . . . . . . . . ·

សេចក្តីបញ្ញត្តិ. . . . . . . . . . . . . . . . . . . . . . ៣៣៣

ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . ៣៣៨

គព្ភិនីវគ្គ សិក្ខាបទទី ៧ ៣៣៨

និទានភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា. . . . . . . . . . . . . . . ·

សិក្ខាបទវិភង្គ នឹងភាវៈដែលមិនត្រូវអាបត្តិ. . . . . . . . . . . . . ៣៣៨, ៣៤០

គព្ភិនីវគ្គ សិក្ខាបទទី ៨ ៣៤០

និទានថុល្លនន្ទាភិក្ខុនី. . . . . . . . . . . . . . . . . . . . . ·

សេចក្តីបញ្ញត្តិ នឹងភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . ៣៤១, ៣៤២

គព្ភិនីវគ្គ សិក្ខាបទទី ៩ ៣៤២

និទានភិក្ខុនីមិនបម្រើឧបជ្ឈាយ៍ . . . . . . . . . . . . . . . . . . ·

សេចក្តីបញ្ញត្តិ នឹងភាវៈដែលមិនត្រូវអាបត្តិ. . . . . . . . . . . . . ៣៤៣

គព្ភិនីវគ្គ សិក្ខាបទទី ១០ ៣៤៤

និទានថុល្លនន្ទាភិក្ខុនី. . . . . . . . . . . . . . . . . . . . . ·

សេចក្តីបញ្ញត្តិ នឹងភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . ៣៤៥





លេខទំព័រ

កុមារីភូតវគ្គ សិក្ខាបទទី ១ ៣៤៦

និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី. . . . . . . . . . . . . . . . . . . ·

សេចក្តីបញ្ញត្តិ នឹងសភាវៈដែលមិនត្រូវអាបត្តិ. . . . . . . . . . . . . . . ៣៤៧ ៣៤៨

កុមារីភូតវគ្គ សិក្ខាបទទី ២ ៣៤៩

និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី. . . . . . . . . . . . . . . . . . . ·

ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . . ៣៥៣

កុមារីភូតវគ្គ សិក្ខាបទទី ៣ ៣៥៤

និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី. . . . . . . . . . . . . . . . . . ·

សេចក្តីបញ្ញត្តិ នឹងភាវៈដែលមិនត្រូវអាបត្តិ. . . . . . . . . . . . . . ៣៥៧, ៣៥៨

កុមារីភូតវគ្គ សិក្ខាបទទី ៤ ៣៥៩

និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី. . . . . . . . . . . . . . . . . . ·

ភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . ៣៦០

កុមារីភូតវគ្គ សិក្ខាបទទី ៥ ៣៦០

និទានភិក្ខុនីទាំងឡាយមានវស្សាពេញ ១២. . . . . . . . . . . . . . . ·

វុដ្ឋាបនសម្មតិ. . . . . . . . . . . . . . . . . . . . . . . ៣៦០

សេចក្តីបញ្ញត្តិ នឹងភាវៈដែលមិនត្រូវអាបត្តិ. . . . . . . . . . . . . . ៣៦៣, ៣៦៤

កុមារីភូតវគ្គ សិក្ខាបទទី ៦ ៣៦៥

និទានចណ្ឌកាលីភិក្ខុនី. . . . . . . . . . . . . . . . . . . . . . ·

សិក្ខាបទវិភង្គ នឹងភាវៈដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . ៣៦៧

លេខទំព័រ

កុមារីភូតវគ្គ សិក្ខាបទទី ៧ ៣៦៧

និទានសិក្ខមានា ១ រូប .......................... ក

សេចក្ដីបញ្ញត្តិ-សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .......... ៣៦៩, ៣៧០

កុមារីភូតវគ្គ សិក្ខាបទទី ៨ ៣៧០

និទានសិក្ខមានា ១ រូប .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៧២

កុមារីភូតវគ្គ សិក្ខាបទទី ៩ ៣៧៣

និទានថុល្លនន្ទាភិក្ខុនី .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៧៤, ៣៧៥

កុមារីភូតវគ្គ សិក្ខាបទទី ១០ ៣៧៥

និទានថុល្លនន្ទាភិក្ខុនី .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៧៦, ៣៧៧

កុមារីភូតវគ្គ សិក្ខាបទទី ១១ ៣៧៧

និទានថុល្លនន្ទាភិក្ខុនី .......................... ក

ភរៈដែលមិនត្រូវអាបត្តិ .................... ៣៧៩

កុមារីភូតវគ្គ សិក្ខាបទទី ១២ ៣៨០

និទានភិក្ខុនីកាន់ស្បាយ [illegible] .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៨១



លេខទំព័រ

កុមារីភូតវគ្គ សិក្ខាបទទី ១៣ ៣៨១

និទានភិក្ខុនីកាន់ស្បាយ .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៨៣

ឆត្តុបាហនវគ្គ សិក្ខាបទទី ១ ៣៨៤

និទានឆព្វគ្គិយាភិក្ខុនី .......................... ក

សេចក្ដីបញ្ញត្តិ-សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .......... ៣៨៥, ៣៨៦

ឆត្តុបាហនវគ្គ សិក្ខាបទទី ២ ៣៨៦

និទានឆព្វគ្គិយាភិក្ខុនី .......................... ក

សេចក្ដីបញ្ញត្តិជាន់ក្រោយ .......................... ៣៨៧

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៨៨, ៣៨៩

ឆត្តុបាហនវគ្គ សិក្ខាបទទី ៣ ៣៨៩

និទានភិក្ខុនី ១ រូប .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៩០, ៣៩១

ឆត្តុបាហនវគ្គ សិក្ខាបទទី ៤ ៣៩១

និទានឆព្វគ្គិយាភិក្ខុនី (ទ្រទ្រង់គ្រឿងប្រដាប់ស្ត្រី) .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៩២

ឆត្តុបាហនវគ្គ សិក្ខាបទទី ៥ ៣៩៣

និទានឆព្វគ្គិយាភិក្ខុនី .......................... ក

សិក្ខាបទវិភង្គ និងភរៈដែលមិនត្រូវអាបត្តិ .................... ៣៩៤

លេខទំព័រ

ឆត្តុបាហនវគ្គ សិក្ខាបទទី ៦ ...... ៣៩៤

និទានបុគ្គលភិក្ខុនី ...... ។
សិក្ខាបទវិភង្គ និងករណីដែលមិនត្រូវអាបត្តិ ...... ៣៩៥

ឆត្តុបាហនវគ្គ សិក្ខាបទទី ៧ ...... ៣៩៦

និទានភិក្ខុនីទាំងឡាយ ...... ។
សេចក្តីបញ្ញត្តិ និងករណីដែលមិនត្រូវអាបត្តិ ...... ៣៩៧, ៣៩៨

ឆត្តុបាហនវគ្គ សិក្ខាបទទី ៨.៩.១០ ...... ៣៩៨

និទានភិក្ខុនីទាំងឡាយ ...... ។
សេចក្តីបញ្ញត្តិ និងករណីដែលមិនត្រូវអាបត្តិ ...... ៣៩៩, ៤០០

ឆត្តុបាហនវគ្គ សិក្ខាបទទី ១១ ...... ៤០០

និទានភិក្ខុនីទាំងឡាយ មិនប្រាប់ស្រាប់តែអង្គុយលើអាសនៈតាងមុខ ...... ។
សេចក្តីបញ្ញត្តិ និងករណីដែលមិនត្រូវអាបត្តិ ...... ៤០១, ៤០២

ឆត្តុបាហនវគ្គ សិក្ខាបទទី ១២ ...... ៤០២

និទានភិក្ខុនីស្លៀកបញ្ចាំងភិក្ខុ ...... ។
សេចក្តីបញ្ញត្តិ និងករណីដែលមិនត្រូវអាបត្តិ ...... ៤០៣, ៤០៤

ឆត្តុបាហនវគ្គ សិក្ខាបទទី ១៣ ...... ៤០៤

និទានភិក្ខុនីមួយរូប ឈ្មោះស៊ីតល់ភោគពុង ...... ។
សេចក្តីបញ្ញត្តិ និងករណីដែលមិនត្រូវអាបត្តិ ...... ៤០៥, ៤០៦
ឧទ្ទានគាថា ...... ៤០៦



លេខទំព័រ

បាដិទេសនីយកណ្ឌ ...... ៤០៧

និទានភិក្ខុនី សូមទឹកដោះរាវថ្លា ...... ។
សេចក្តីបញ្ញត្តិជាលំដាប់ និងករណីដែលមិនត្រូវអាបត្តិ ...... ៤០៧, ៤០៨
ឧទ្ទានគាថា ...... ៤០៨

សេខិយកណ្ឌ ...... ៤០៩

និទានភិក្ខុនី ស្លៀកយឺតយោក ...... ។
ករណីដែលមិនត្រូវអាបត្តិ ...... ៤១៣
សេចក្តីបញ្ញត្តិជាលំដាប់ ...... ៤១៧
ឧទ្ទានគាថា ...... ៤២០

អធិករណសមថៈ ទីបំផុត ...... ៤២១

ឧទ្ទានគាថា ...... ៤២២

---